# សៀវភៅ មង្គលត្ថទីបនីប្រែ

ភាគទី៤ នេះ

ខ្ញុំអនុញ្ញាតឲ្យផ្សាយជាធម្មទានតាម វ៉ិបសាយ នេះ បានតាមត្រូវការ ។

វត្តខ្មែរសាន់តាអាណា សហរដ្ឋអាមេរិក ថ្ងៃ ១៥ កើត ខែមាឃ ព.ស.២៥៥៨


2630 N, Grand Ave.
Santa Ana, CA 92705
(714) 771-7344


ធម្មទានឈ្នះអស់ទានទាំងពួង

# មង្គលត្ថទីបនីប្រែ

## ភាគទី៤

ប្រែនិងរៀបរៀងដោយ


**ភិក្ខុវិនយធរោ**

(មហាឃិន-នឿន



ផ្សាយជាធម្មទាន

លើកទី១

ចំនួន ១២០០ ក្បាល



រក្សាសិទ្ធិ



ព.ស.២៥៣៨

# មង្គលត្ថទីបនីប្រែ

## ភាគទី ៥

–

[illegible]

([illegible])

ប្រែនិងរៀបរៀង

[illegible]

និង

[illegible] លើកទី ១

ចំនួន ១.២០០ក្បាល

———

រក្សាសិទ្ធិ

ព.ស.២៥៤៨ គ.ស.២០០៥

[illegible]

# មង្គលត្ថទីបនីប្រែ

## ភាគទី ៤

~~~~~

**ភិក្ខុវិនយធរោ**

**(មហាឃិន-នៀន)**

ប្រែនិងរៀបរៀង

***ជំនួយដល់សមណសិស្សពុទ្ធិកមធ្យមសិក្សា***

និង

***ផ្សាយជាធម្មទាន លើកទី ១***


ចំនួន ១.២០០ក្បាល

-----------



***រក្សាសិទ្ធិ***



ព.ស.២៥៣៨ គ.ស.១៩៩៥



***ហាមទិញ-លក់***
~~~~~

រក្សាសិទ្ធិគ្រប់យ៉ាង

**រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ ។**

រូបរាងកាយរបស់សត្វទាំងឡាយតែងចាស់ជរាគ្រាំគ្រា
ចំណែកឯនាមនិងគោត្រ មិនដែលចាស់ជរាឡើយ ។



**ភិក្ខុវិនយធរោ មហាឃិន~នឿន**

មានដើមកំណើតនៅ

*ភូមិខាងជើង ឃុំទួលព្រហ្ម ស្រុកមោងឫស្សី ខេត្តបាត់ដំបង*

**សៀវភៅមង្គលត្ថទីបនីប្រែ** ទាំង៤ភាគនេះ ខ្ញុំអ្នកប្រែ សូមបញ្ជាក់ថា កាលធ្វើជាលើកដំបូងនេះ គឺប្រៀបឧបមាដូចជាការទ្រួសត្រាយកាប់ឆ្ការផ្លូវទុកតែប៉ុណ្ណោះឯង ពុំទាន់ចាត់ថា បានធ្វើល្អត្រឹមត្រូវមួយរយភាគរយនោះទេ ព្រោះខ្ញុំមានចំណេះចេះដឹងខាងផ្នែកអក្សរសាស្ត្រខ្មែរ-បាលីតិចតួចស្តួចស្តើងណាស់ ។

**បោះពុម្ពជំនួយសមណសិស្សពុទ្ធិកមធ្យមសិក្សា**
**និងចែកផ្សាយជាធម្មទាន**

បេញអំពី

**មជ្ឈមណ្ឌលសហគមន៍ព្រះសង្ឃខ្មែរ និង ពុទ្ធិកសមាគមន៍សង្ឃ**
**នៅតាមវត្តនានា ប្រចាំសហរដ្ឋអាមេរិក**

* * *

*សូមសមណសិស្សដែលបានខ្ចីសៀវភៅនេះ ទៅសិក្សារៀនសូត្រគ្រប់ៗរូប មេត្តាជួយថែរក្សាសៀវភៅនេះឱ្យបានល្អ កុំឱ្យសរសេរ កុំឱ្យមានការរហែកដាច់ដាចខូចខាត...ហើយពេលសិក្សាចប់ សូមមេត្តាយកទៅតម្កល់ទុកក្នុងបណ្ណាល័យវត្តដែលបានខ្ចីមកនោះដូចដើមវិញ ដើម្បីឱ្យសមណសិស្សជំនាន់ក្រោយខ្ចីយកទៅសិក្សាបន្តទៅទៀត ព្រោះសៀវភៅនេះមានតិចតួចណាស់ ។*

*សូមអរគុណ*


*សៀវភៅ* **មង្គលត្ថទីបនីប្រែ** *ទាំង ៤ ភាគនេះ*
*បានបោះពុម្ពផ្សាយជាធម្មទាន លើកទី១ នៅថ្ងៃសៅរ៍*
*១៥ កើត ខែវិសាខ ឆ្នាំកុរ សប្តស័ក ព.ស.២៥៣៨*
*ត្រូវនឹងថ្ងៃ ១៣ ខែឧសភា ១៩៩៥*

សៀវភៅ **មង្គលត្ថទីបនីប្រែ ភាគទី ៤** នេះ

សម្រាប់តម្កល់ទុកជា **សម្បត្តិសង្ឃ** ក្នុង

**បណ្ណាល័យ**

វត្ត______________________________

ឃុំ______________________________

ស្រុក_____________________________

ខេត្ត_____________________________

នៅថ្ងៃ___កើត____រោច ខែ______________

ឆ្នាំ___________________ព.ស.២៥៣___

*និងសម្រាប់ឲ្យសមណសិស្សពុទ្ធិកវិទ្យាល័យ ខ្ចីយកទៅសិក្សារៀនសូត្យស្រាវជ្រាវ រួចហើយត្រូវយកមកតម្កល់ទុកក្នុងបណ្ណាល័យវិញ ព្រោះជាសម្បត្តិសង្ឃ មួយទៀតព្រោះសៀវភៅនេះមានចំនួនតិចតួចពេកណាស់ ។*

អ្នកចែក_ភិក្ខុ [signature]_____

អ្នកទទួល____________________________

# មាតិការឿង


| ឈ្មោះធម៌ | ទំព័រ |
|---|---|
| **១-អារម្ភកថារបស់អ្នកផ្តើបនិងរៀបរៀង** | **ក** |
| **២-(ពណ៌នាអំពីសេចក្តីនៃគាថាទី ៧)** | |
| ពណ៌នាអំពីភាពជាអ្នកមានកតញ្ញូ | ១ |
| ពណ៌នាអំពីការស្តាប់ធម៌ | ៤៨ |
| **៣-ពណ៌នាអំពីសេចក្តីនៃគាថាទី ៨** | ៨៩ |
| ពណ៌នាអំពីសេចក្តីអត់ធន់ | ៩០ |
| ពណ៌នាអំពីភាពជាអ្នកដែលគេប្រដៅងាយ | ១៣១ |
| ពណ៌នាអំពីការឃើញនូវសមណៈ | ១៥១ |
| ពណ៌នាអំពីការសន្ទនាធម៌ | ១៧៧ |
| **៤-ពណ៌នាអំពីសេចក្តីនៃគាថាទី ៩** | ១៨២ |
| ពណ៌នាអំពីតបៈ | ១៨៣ |
| ពណ៌នាអំពីព្រហ្មចរិយៈ | ២៣៤ |
| ពណ៌នាអំពីការឃើញអរិយសច្ច | ២៦២ |
| ពណ៌នាអំពីការធ្វើព្រះនិព្វានឲ្យជាក់ច្បាស់ | ២៨៣ |

**៥-ពណ៌នាអំពីសេចក្ដីនៃគាថាទី ១០** ៣១៥

អកម្បិតចិត្តកថា ៣១៧

ពណ៌នាអំពីចិត្តដែលមិនសោកសៅ ៣៣៦

ពណ៌នាពីចិត្តប្រាសចាកកិលេសដូចជាធូលី ៣៥៧

ពណ៌នាអំពីចិត្តដែលក្សេម ៣៨៤

**៦-ពណ៌នាអំពីសេចក្ដីនៃគាថាទី ១១** ៤០៤

ការតែងមង្គលត្ថទីបនី ៤២២

សេចក្ដីប្រាថ្នារបស់អ្នកតែង ៤២៣

* * *

# អារម្ភកថា

---

សៀវភៅ **មង្គលត្ថទីបនីប្រែ ភាគទី ៤** នេះ គឺខ្ញុំ ភិក្ខុ **ចិនយធរោ មហាយិន - សៀន** បំរុងនឹងផ្ដួចផ្ដើមប្រែរៀបរៀង មកជាភាសាខ្មែរយើង ជាយូរយារណាស់មកហើយ គឺតាំងពីពេលដែលខ្ញុំ កំពុងនៅសិក្សាមកម្ល៉េះ (ព. ស. ២៥២៤ គ. ស. ១៩៨១ ) តែឱកាសពុំបានហុចឱ្យ ព្រោះជាប់រវល់ខ្លាំងពេក ក្នុងការសិក្សាភាសាបាលី ឱ្យបានរីកចំរើនឡើងជាបន្ថែមតទៅទៀតផង និងក្នុងពេលនោះ នឹងរកឧបករណ៍ក្បួនច្បាប់ដែលជាភាសាខ្មែរសម្រាប់ជំនួយ ក៏គ្មានផងដែរ ។ គម្រោងការនេះ ខ្ញុំក៏ពុំបានបោះបង់ចោលដែរ ទោះបីជាខ្ញុំបានរសាត់អណ្ដែតឆ្ងាយសែនឆ្ងាយ អំពីមាតុភូមិជាទីស្នេហា ហើយបានទៅរស់នៅឯបរទេស ជាប្រទេសដែលមិនកាន់ព្រះពុទ្ធសាសនា មានវប្បធម៌ ទំនៀមទំលាប់ ខុសប្លែកផ្សេងពីប្រទេសយើងក៏ដោយ ក៏គម្រោងការនេះនៅតែដក់ជាប់ក្នុងចិត្តខ្ញុំជានិច្ច ។

នៅក្នុងថ្ងៃពុធ ១១ រោច ខែពិសាខ ឆ្នាំវក ចត្វាស័ក ព.ស. ២៥៣៥ ត្រូវនឹងថ្ងៃទី ២៧ ខែឧសភា ១៩៩២ ( ឆ្នាំ

ដែលក្រុមអង្គការសហប្រជាជាតិ ចូលមកជួយរៀបចំធ្វើការ បោះឆ្នោតនៅប្រទេសកម្ពុជា ) ខ្ញុំក៏បានវិលត្រឡប់ចូលមក ទស្សនាមាតុភូមិរបស់ខ្ញុំផងដែរ ហើយបានចូលទៅពិនិត្យ មើលការសិក្សាព្រះបរិយត្តិធម៌ ទាំងផ្នែកបាលី ទាំងផ្នែកព្រះ ធម្មវិន័យ ដែលព្រះសង្ឃកំពុងតែសិក្សានៅតាមវត្តនានា ដូច ជា *វត្តមហាមន្ត្រី វត្តលង្កា វត្តនិរោធរង្សី* ជាដើម ដោយមាន **សម្តេចព្រះមង្គលទេពាចារ្យ ( អ៊ុំ - ស៊ុំ )** អគ្គាធិការពុទ្ធិកសិក្សា បាននាំដំណើរជូនទៅផងដែរ ។

ពេលនោះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាទីបំផុត ដោយបានឃើញនូវព្រះសង្ឃអង្គសាមណេរ ខិតខំយកព្រះទ័យ ទុកដាក់ ក្នុងការសិក្សាព្រះបរិយត្តិធម៌ គឺបានឮព្រះភិក្ខុសង្ឃ សាមណេរអង្គខ្លះកំពុងទន្ទេញបាលីវេយ្យាករណ៍ អង្គខ្លះទន្ទេញ ប្រជុំកងធម៌ អង្គខ្លះហាត់ប្រែធម្មបទ លោកគ្រូអាចារ្យខ្លះកំពុង បង្ហាត់ប្រែណោតប្រយោគ តាមបែបពីបូរាណ... គំហើញ និង ការឮសូរស័ព្ទព្រះធម៌ដ៏ពិរោះត្រចៀកនេះ រឹតតែធ្វើឱ្យខ្ញុំរំភើប ចិត្តឥតឧបមា ព្រោះនឹកសង្ឃឹមថា ព្រះពុទ្ធសាសនា ដែលបាន

វិនាសសាបសូន្យ ស្ទើរតែរលត់អស់ ដោយសារភ្លើងសង្គ្រាម ជាងពីរទសវត្សរ៍ មកហើយនោះ នឹងបានរីកចំរើនឡើងវិញ ដោយពិត ហើយបានជំរុញខ្ញុំ ឱ្យរឹតតែមានសទ្ធាជ្រះថ្លាឡើង ជាអភិយោភាព ...។ មួយទៀតសោត ធ្វើឲ្យខ្ញុំនឹកគិត ថា តើ នឹងរកពិធីជួយ ដល់សមណសិស្សបែបណា? ខ្ញុំយល់ឃើញ ថា សមណសិស្សដែលកំពុងសិក្សាពុទ្ធិកបឋមសិក្សា (ពេល នោះ) ដូចជាពុំមានបញ្ហាឡើយ ព្រោះមានគ្រូ និងក្បួនច្បាប់ សម្រាប់ជួយច្រើន តែចំណែកតទៅឆ្នាំក្រោយ ៗ ទៀត នឹង មានសមណសិស្សពុទ្ធិកមធ្យមសិក្សា ដោយពិត ឯគ្រូ និងក្បួន ច្បាប់ ខ្ញុំយល់ឃើញ ថា ដូចជាមានបញ្ហាខ្លះ ព្រោះពុំសូវមាន ច្រើន ។

ហេតុនេះហើយ ខ្ញុំមានគំនិតគិត ថា នឹងរកសៀវភៅ **មង្គលត្ថទីបនី** ដែលនៅជាភាសាបាលីទាំង ៤ ភាគ មកបកប្រែ ជាភាសាសម្រាយខ្មែរយើង ដើម្បីជាជំនួយ ដល់សមណសិស្ស ពុទ្ធិកមធ្យមសិក្សា ដែលនឹងសិក្សានៅអនាគតកាល ហើយបាន ដើរស្រាវជ្រាវរកសៀវភៅទាំងនោះ តែរកពុំបានឡើយ សូម្បី

តែសម្តេចព្រះមង្គលទេពាចារ្យ ( អ៊ុំ - ស៊ុំ )   ក៏ព្រះអង្គពុំទាន់មានដែរ ព្រោះរោងពុម្ពជប៉ុនពុំទាន់បានបោះពុម្ពជាជំនួយ ។

ពេលខ្ញុំត្រឡប់ទៅវត្តខេមរពុទ្ធិការាម សហរដ្ឋអាមេរិកវិញ   ស្រាប់តែមានព្រះភិក្ខុមួយអង្គ   ព្រះនាម ម្ជូ - ហ្វូយ លោកបានយកនូវសៀវភៅមង្គលត្ថទីបនី ភាគទី ៣  និងទី ៤ ដែលជាភាសាបាលីមកបង្ហាញឱ្យខ្ញុំមើល   ហើយខ្ញុំក៏បានសុំខ្ចីលោកសិន ដើម្បីនឹងយកមកប្រែជាភាសាខ្មែរយើង ដោយបានចាប់ផ្តើមប្រែ នៅថ្ងៃសៅរ៍ ២ រោច ខែបុស្ស ឆ្នាំរកា បញ្ចស័ក ព.ស. ២៥៣៦  ត្រូវនឹងថ្ងៃទី ៩ ខែមករា ១៩៩៣   ហើយបានប្រែចប់សព្វគ្រប់  នៅថ្ងៃពុធ  ៨ រោច ខែចេត្រ  ឆ្នាំរកា បញ្ចស័ក ព.ស. ២៥៣៦   ត្រូវនឹងថ្ងៃទី ១៤  ខែមេសា ឆ្នាំ ១៩៩៣ ។

លុះប្រែចប់ហើយ  ខ្ញុំក៏បានផ្ញើរសំណៅមង្គលត្ថទីបនី (១) នេះ ទៅប្រគេនព្រះតេជះគុណព្រះ **ធម្មលិខិត លាស់-ឡាយ** វត្តសន្សំកុសល ក្រុងភ្នំពេញ ដើម្បីត្រួតពិនិត្យឱ្យបានត្រឹមត្រូវ តែភាគទី៤ នេះ  ព្រះអង្គពុំអាចជួយត្រួតពិនិត្យបានទេ  ព្រោះ

---

*១- ភាគទី ១-២ ព្រះអង្គបានជួយត្រួតពិនិត្យចប់សព្វគ្រប់ ។*

មានការជាប់រវល់ច្រើនពេក ក្នុងកិច្ចការផ្សាយព្រះពុទ្ធសាសនា ក្រោយមក ខ្ញុំក៏បានយកសំណៅ *មង្គលត្ថទីបនីប្រែ ភាគទី ៤* នេះ ទៅប្រគេនព្រះតេជះគុណ **អធិបតីសង្ឃ (សោ-ឃន)** ប្រចាំសហគមន៍ព្រះសង្ឃខ្មែរ គង់នៅ*វត្តត្រៃរតនារាម ទីក្រុងឡូវែល រដ្ឋម៉ាសាឈូសេត សហរដ្ឋអាមេរិក* ដើម្បីឱ្យព្រះអង្គជួយត្រួតពិនិត្យជំនួសវិញ ព្រះអង្គក៏បានទទួលយល់ព្រមដោយពេញព្រះទ័យជាទីបំផុត ហើយបានជួយត្រួតពិនិត្យកែសម្រួលរហូតដល់បានសម្រេចជាស្ថាពរ ។

ក្នុងការបកប្រែពីភាសាមួយទៅភាសាមួយទៀតនេះ គឺពិតជាមានការពិបាកណាស់ ហើយពិតជាមានការភ្លាំងភ្លាត់ខុស ឃ្លាតចាកអំពីអត្ថន័យធម៌អាចខ្លះ ។ ដោយអចេតនាខ្លះ ដោយការចេះមិនដល់ខ្លះ ជាពុំខានឡើយ ។ ក្នុងការប្រែនេះសោត គោលគំនិតរបស់ខ្ញុំ គឺប្រែរក្សាទុកភាសាបាលីភាគច្រើន មានន័យថា គឺមិនចង់ឱ្យឃ្លាតចាកអំពីភាសាបាលីច្រើនឡើយ ដើម្បីឱ្យអ្នកសិក្សាឆាប់រកស័ព្ទប្រែបានដោយងាយ តែខេមរភាសា (ភាសាខ្មែរយើង) ពិតជានឹងពិបាកស្តាប់បន្តិច ។

ខ្មែរពិតជានឹងពិបាកស្ដាប់បន្តិច ។

ហេតុដូច្នេះ ខ្ញុំអ្នកប្រែ សូមមេត្តាខន្តីអភ័យទោសអំពីសំណាក់ព្រះតេជះគុណ និងអស់លោកដែលឆ្លៀវឆ្លាត ក្នុងអក្សរសាស្ត្របាលីក្ដី ខ្មែរក្ដី បើមានការខុសភ្លាំងភ្លាត់ត្រង់កន្លែងណានិមួយនោះ ហើយសូមមេត្តាជួយឱ្យយោបល់ និងជួយកែតម្រូវ ដើម្បីធ្វើសៀវភៅនេះ ឱ្យរឹតតែបានល្អប្រសើរឡើង ។ សង្ឃឹម ថា ព្រះតេជះគុណ អស់លោក នឹងផ្ដល់យោបល់ដ៏ល្អ ហើយអភ័យទោសដល់ខ្ញុំជាពុំខាន ។

ខ្ញុំសូមឧទ្ទិសសៀវភៅនេះ ដល់សមណសិស្សគ្រប់ព្រះអង្គ និងពុទ្ធសាសនិកជនទូទៅ សូមយកទៅសិក្សា ឱ្យបានឆាប់ចេះឆាប់យល់ ឆ្លៀវឆ្លាតក្នុងព្រះបរិយត្តិធម៌ ហើយយកព្រះធម៌នោះទៅផ្សព្វផ្សាយដល់ពុទ្ធបរិស័ទទាំងឡាយ ដើម្បីលើកស្ទួយព្រះពុទ្ធសាសនា ឱ្យបានរីកចំរើនឡើងតរៀងទៅ ។

មួយទៀត សូមឱ្យការសិក្សា នូវព្រះធម្មវិន័យ របស់សមណសិស្សគ្រប់ ៗ រូប និងពុទ្ធបរិស័ទទាំងអស់ បានសម្រេចសមដូចមនោរថ ដែលបានប្រាថ្នាហើយ កុំបីអាក់ខានឡើយ ។

ខ្ញុំសូមឧទ្ទិសបុណ្យកុសល ដែលកើតអំពីធម្មទាននេះ ជូនចំពោះបិតាឈ្មោះ **ឃិន - ឃឿម** មាតាឈ្មោះ **ហិង - អម** ព្រមទាំងជីដូនជីតា ញាតិកាទាំង ៧ សន្តាន និងសព្វសត្វទាំងអស់ ដែលបានចែកឋានទៅហើយនោះ សូមឱ្យវិញ្ញាណក្ខន្ធរបស់លោកអ្នកទាំងនោះ បានទទួលអនុមោទនា នូវបុណ្យកុសលដែលខ្ញុំបានឧទ្ទិសផ្សាយទៅឱ្យនេះ ហើយសូមឱ្យបានសម្រេចនូវសម្បត្តិទាំងឡាយ ៣ ប្រការ គឺ សម្បត្តិមនុស្ស ទេវតា និងព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។

**វត្តខេមរពុទ្ធិការាម**

2100 W. Willow Street

Long Beach, CA 90810

U. S. A.

*ថ្ងៃសៅរ៍ ១៥កើត ខែមាឃ ឆ្នាំរកា បញ្ចស័ក ព.ស.២៥៣៦*

*ត្រូវនឹងថ្ងៃទី ៦ ខែកុម្ភៈ ១៩៩៣*

# សេចក្តីថ្លែងអំណរព្រះគុណនិងអរគុណ

៙៙៙

ខ្ញុំសូមថ្លែងអំណរព្រះគុណ និងអរគុណដ៏ជ្រាលជ្រៅ

-ចំពោះ **សម្តេចព្រះមង្គលទេពាចារ្យ ( អ៊ុំ - ស៊ុំ )** អគ្គាធិការនៃពុទ្ធិកសិក្សា *វត្តមហាមន្ត្រី* ទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដែលព្រះអង្គបានផ្តល់ព្រះយោបល់ដ៏ល្អ ៗ និងបានផ្តល់នូវក្បួនច្បាប់ផ្សេង ៗ មានសៀវភៅមង្គលត្ថទីបនីនេះ និងបទានុក្រមធម្មបទជាដើម តាមសេចក្តីត្រូវការ ។

-ចំពោះ ព្រះតេជះគុណ **អធិបតីសឡ (សៅ-ឃន)** ប្រចាំ *មជ្ឈមណ្ឌលសហគមព្រះសង្ឃខ្មែរ នៅវត្តត្រៃរតនារាម ទីក្រុងឡូវែល រដ្ឋម៉ាសាឈូសេត សហរដ្ឋអាមេរិក* ដែលបានចំណាយពេលវេលា ជួយត្រួតពិនិត្យ កែសម្រួលពាក្យពេចន៍ និងអត្ថន័យផ្សេង ៗ ដើម្បីធ្វើសៀវភៅនេះ ឱ្យបានល្អប្រសើរឡើង រហូតដល់បានចប់សព្វគ្រប់ ។

-ចំពោះ ព្រះតេជះគុណ **គង់ - ឈាន** ចៅអធិការ

**ទន្លខ្មែរ ខេមរពុទ្ធិការាម** ទីក្រុងឡុងបិច សហរដ្ឋអាមេរិក ដែលបានជួយផ្តល់យោបល់និងគំនិតផ្សេង ៗ ។

-ចំពោះ ភិក្ខុ ម្លូ - ហួយ ដែលបានឱ្យខ្ចីសៀវភៅ មង្គលត្ថទីបនីភាគទី ៣ និងភាគទី ៤ ដើម្បីយកមកប្រែ ។

-ចំពោះ ភិក្ខុ អ៊ុខ - អ៊ិន វត្តប្រោះស្ទ ក្រុងប្រោះស្ទ សហរដ្ឋអាមេរិក, ភិក្ខុ ច្រាជ្ញ - សារ៉ាន វត្តឧណ្ណាលោម កុដិលេខ ៤២ ទីក្រុងភ្នំពេញ និងលោកបណ្ឌិតករនិពន្ធ **ហៀម - គឿន** ដែលបានជួយយកសំណៅមង្គលត្ថទីបនីនេះ ទៅប្រគេន **ព្រះធម្មលិខិត លាស់ -ឡាយ** ដើម្បីត្រួតពិនិត្យ តែ ភាគទី៣-៤ នេះ ព្រះតេជះគុណ **លាស់-ឡាយ** ពុំបានត្រួតទេ ។

-ចំពោះ ព្រះតេជះគុណ **ឯម-គឿខ អតិប្បញ្ញោ មេគណ ខេត្តកំពត** ដែលបានជួយត្រួតពិនិត្យនូវអក្ខរាវិរុទ្ធ និង ពាក្យពេចន៍ ដើម្បីធ្វើសៀវភៅនេះ ឱ្យបានល្អប្រសើរឡើង ។

-ចំពោះ ភិក្ខុ **ព្រះមហា សម - សក្តិ** សុវណ្ណរតនោ ដែលបានជួយយកសៀវភៅមង្គលត្ថទីបនីនេះ ទៅចូលរោង

ពុម្ព ដើម្បីបោះពុម្ពឱ្យបានសម្រេច តាមសេចក្តីត្រូវការ ។

-ចំពោះ លោក 'យឹម- ជ័យ និងលោក ឃុំ - ឆយ ដែលបានជួយកែសម្រួល និងជួយដំឡើងគ្រឿងកុំព្យូទ័រដោយយកចិត្តទុកដាក់ជាទីបំផុត ។

ម្យ៉ាងទៀត ខ្ញុំសូមថ្លែងអំណរព្រះគុណនិងអរគុណជាទីបំផុត ចំពោះព្រះតេជះគុណ ព្រះថេរានុថេរៈ អស់លោក លោកស្រី ព្រមទាំងញាតិញោមជាពុទ្ធបរិស័ទទាំងអស់ ដែលបានជួយឧបត្ថម្ភ ក្នុងការបោះពុម្ពសៀវភៅនេះ ឱ្យបានសម្រេចជាស្ថាពរ ។

សូមប្រគេនមគ្គផល ដែលកើតពីធម្មទានានិសង្ស នេះ ដល់ព្រះតេជះគុណ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ សូមឱ្យព្រះអង្គមានព្រះជន្មាយុយឺនយូរ ជាងរយព្រះវស្សា ដើម្បីជាទីពឹង របស់ពុទ្ធសាសនិកជនទាំងឡាយ តរៀងទៅហោង ។

សូមឱ្យញាតិញោមទាំងឡាយ បានទទួលនូវបុណ្យកុសលនេះ ស្មើ ៗគ្នា និងសូមឱ្យបានជួបប្រទះតែនឹងសេចក្តីសុខ-ចម្រើនគ្រប់ប្រការ កុំបីអាក់ខានឡើយ ។

សូមឱ្យព្រះរាជាណាចក្រកម្ពុជា ជាទីកំសត់ ឆាប់បាន ទទួលនូវសុខសន្តិភាព ដែលប្រកបដោយព្រះធម៌ នៃអង្គព្រះ សម្មាសម្ពុទ្ធបរមគ្រូ ដោយពិត, សូមឱ្យរាជរដ្ឋាភិបាលគ្រប់ជាន់ ថ្នាក់ និងគ្រប់គណៈបក្សទាំងអស់ ដឹកនាំប្រទេសជាតិ ព្រះ រាជាណាចក្រកម្ពុជា ប្រកបដោយសម្មាទិដ្ឋិ ដើម្បីជោគជ័យ សេចក្ដីសុខ-ចម្រើន និងសុភមង្គល ជូនដល់ប្រជានុរាស្ត្រ ទូទាំងប្រទេស ដែលកំពុងក្រីក្រលំបាក ស្រេកឃ្លាន នូវសេចក្ដី សុខសន្តិភាព និងស្ងប់ខ្ញើមបំផុតនូវសង្គ្រាម សព្វថ្ងៃនេះ ។

សូមឧទ្ទិសកុសលនេះផងដែរ ដល់ពួកបញ្ញវន្ត អ្នក ស្នេហាជាតិ យុវជនយុវតី ប្រជាពលរដ្ឋ អ្នកស្លូតត្រង់គ្រប់ជាន់ គ្រប់ស្រទាប់ ដែលបានបូជាជីវិតដើម្បីមាតុភូមិ ដោយចិត្ត ស្មោះស្ម័គ្រ គ្រប់កាលៈទេសៈ សូមបានទទួលកុសលដែលកើត អំពីធម្មទាននេះ ហើយសូមឱ្យវិញ្ញាណក្ខន្ធ នៃអ្នកទាំងអស់ នោះ បានសោយសុខដ៏ប្រសើរ ក្នុងសុគតិភព កុំបីខាន ។

⊙ ⊙ ⊙

# សេចក្ដីបញ្ជាក់

ខ្ញុំបានត្រួតពិនិត្យដោយរហ័សជាទីបំផុត នូវសៀវភៅមង្គលត្ថទីបនីនេះ ដែលបានប្រែនិងរៀបរៀងដោយ ព្រះមហា ឃិន នឿន វិនយធរោ ក្នុងគោលបំណងជាជំនួយ ដល់សមណសិស្សពុទ្ធិកមធ្យមសិក្សា និងចែកជាធម្មទានផង ។

ដូច្នេះ ដើម្បីឱ្យវណ្ណកម្មនេះ មានលក្ខណៈទូលំទូលាយមែនទែនទៀតនោះ ព្រះមហា ឃិន នឿន តំណែងរបស់ព្រះអង្គជាអនុប្រធានទី២ របស់សហគមន៍ព្រះសង្ឃខ្មែរ ក៏បានប្រគល់ទៅឱ្យសហគមន៍ព្រះសង្ឃខ្មែរ ដែលមានព្រះភិក្ខុ សៅ-ឃន ធម្មថេរោ ជាប្រធានជួយពិនិត្យ និងកែសម្រួលជាចុងក្រោយ ។

អាស្រ័យហេតុនេះ ខ្ញុំយល់ឃើញថា សៀវភៅនេះមានប្រយោជន៍ច្រើនណាស់ សម្រាប់សមណសិស្ស ដែលកំពុងរៀនប្រែគម្ពីរមង្គលថ្មីៗ ព្រោះអាចធ្វើឱ្យយល់ងាយ បានតាមគួរដល់សេចក្ដីត្រូវការពុំខានឡើយ ។

<u>សូមអរគុណ</u>

មណ្ឌលសហគមន៍ ថ្ងៃទី[illegible] ខែសីហា ឆ្នាំ១៩៩៥

ប្រធានសហគមន៍ព្រះសង្ឃខ្មែរ

ព្រះភិក្ខុ សៅ ឃន ធម្មថេរោ

# មង្គលត្ថទីបនីប្រែ

## ភាគទី ៤

### ពណ៌នាអំពីគាថាថាអ្នកមានកតញ្ញូ

(១) កិរិយាដឹង នូវឧបការៈ ដែលបុគ្គលណាមួយបានធ្វើហើយ តិចក្តី ច្រើនក្តី ដោយភាពគឺកិរិយានឹករឭក ជារឿយ ៗ ឈ្មោះថា **កតញ្ញុតា** ។ មួយទៀត បុណ្យទាំងឡាយនុ៎ះឯង ឈ្មោះថា មានឧបការៈដ៏ច្រើន ដល់សត្វមានជីវិតទាំងឡាយ ព្រោះការពារ នូវសេចក្តីទុក្ខមានសេចក្តីទុក្ខ ក្នុងនរកជាដើមបាន, ការនឹកឃើញឧបការៈសូម្បីនៃបុណ្យទាំងឡាយនោះ ព្រោះកិរិយាការពារនូវសេចក្តីទុក្ខក្នុងនរកជាដើម ដោយហេតុណា, ហេតុនោះគប្បីជ្រាប ថា **កតញ្ញុតា** ។ បុគ្គលអ្នកដឹងឧបការគុណដែលអ្នកដទៃបានធ្វើហើយដល់ខ្លួន ក្នុងបទថា " **កតញ្ញុតា** " នោះ រមែងជាបុគ្គលដែលគេរកបានដោយកម្រ ។ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ក្នុងបឋមវគ្គ នៃតតិយបណ្ណាសកៈ ក្នុងទុកនិបាត អង្គុត្តរនិកាយ ថា " ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះ រកបានដោយកម្រក្នុងលោក ។ បុគ្គល ២ ពួក តើដូចម្តេច ។

គឺ បុគ្គលដែលធ្វើឧបការៈទុកមុន ១ បុគ្គលដែលដឹងឧបការៈ ដែលអ្នកដទៃបានធ្វើហើយ ធ្វើតបវិញ ១, ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួក នេះឯង រកបានដោយកម្រ ក្នុងលោក " ។

(២) អដ្ឋកថាទុកនិបាត អង្គុត្តរនិកាយនោះថា " បណ្ដាបុគ្គល ២ ពួកនោះ បុគ្គលអ្នកធ្វើឧបការៈមុន ឈ្មោះថា **បុព្វការី** ។ បុគ្គលអ្នកដឹង នូវឧបការៈដែលបុព្វការីនោះ បានធ្វើហើយ ធ្វើតបពួដីខាងក្រោយ ឈ្មោះថា **កតញ្ញូកតវេទី** ។ បណ្ដាបុគ្គលទាំង ២ ពួកនោះ បុព្វការីបុគ្គល រមែងធ្វើសេចក្ដីសម្គាល់ថា ' អាត្មាអញ តែងឲ្យនូវបំណុល ' ។ បុគ្គលអ្នកធ្វើ ពួដីខាងក្រោយ រមែងធ្វើសេចក្ដីសម្គាល់ថា ' អាត្មាអញ នឹងដោះបំណុល " ។

ដីកាទុកនិបាត អង្គុត្តរនិកាយនោះ និង ដីកាបុគ្គលបញ្ញត្តិ ថា " ពាក្យថា ' **ឥណំ ទេមីតិ សញ្ញំ ករោតិ** ' មានសេចក្ដីថា រមែង ដូចជាធ្វើសេចក្ដីសម្គាល់ យ៉ាងដូច្នោះ " ។

ក៏ក្នុងពាក្យថា " **សញ្ញំ ករោតិ** " នេះ សូម្បីសេចក្ដីដែលប្រាសចាកអំពី **វិយ** ស័ព្ទ ក៏ត្រឹមត្រូវ យ៉ាងនោះ ដូចគ្នាដែរ ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទ្រង់សោយព្រះជាតិជាស្ដេចសេក កាលនឹងទ្រង់សំដែងធម៌ ដល់ព្រាហ្មណ៍ ជាកោសិយគោត្រ ទើបទ្រង់ត្រាស់ ក្នុងកេទារជាតក ថា ÷

“ បពិត្រកោសិយៈ សត្វបក្សីទាំងឡាយ នៅមិនទាន់ដុះស្លាបជុំជិត ជាកូនតូចៗ របស់ខ្ញុំ មាននៅ, កូនតូចៗ ទាំងនោះ ដែលខ្ញុំចិញ្ចឹមហើយ នឹងចិញ្ចឹមខ្ញុំវិញ, ហេតុនោះ ខ្ញុំត្រូវឲ្យបុណ ដល់កូនតូចៗ ទាំងនោះ, មួយទៀត មាតាបិតា របស់ខ្ញុំ ចាស់គ្រាំគ្រា មានវ័យកន្លងហើយ, ខ្ញុំពាំ (នូវស្រូវសាលី របស់អ្នក) ដោយចំពុះ យកទៅជូនមាតាបិតាទាំងនោះ ត្រូវដោះបំណុលដែលគាត់ធ្វើហើយ ក្នុងកាលមុន”។

(៣) អដ្ឋកថាបុគ្គលប្បញ្ញត្តិ ថា “ បទថា ‘ ទុល្លភា ’ គឺ មិនមែនរកបានដោយងាយ ។ បុគ្គលអ្នកធ្វើមុននុ៎ះឯង ឈ្មោះថា បុព្វការី ។ បទថា ‘ កតវេទី ’ មានសេចក្ដីថា រមែងប្រកាសនូវឧបការៈ ដែលបុព្វការីបុគ្គលបានធ្វើហើយ គឺ ធ្វើឲ្យអ្នកដទៃដឹងបានដល់ ឲ្យប្រាកដច្បាស់ ។ បុគ្គល ២ ពួកនោះ គប្បីសំដែងដោយគ្រហស្ថ និង បព្វជិតទាំងឡាយ ។ ក៏បណ្ដាពួកគ្រហស្ថ មាតានិងបិតា ឈ្មោះថា បុព្វការី ។ ចំណែក បុត្រធីតា កាលប្រតិបត្តិមាតាបិតា និង ធ្វើសាមីចិកម្ម មានកិរិយាក្រាបថ្វាយបង្គំជាដើម ដល់មាតានិងបិតាទាំងឡាយនោះ ឈ្មោះថា កតវេទី ។ បណ្ដាពួកបព្វជិត អាចារ្យនិងព្រះឧបជ្ឈាយ៍ ឈ្មោះថា បុព្វការី ។

អន្តេវាសិក និងសទ្ធិវិហារិកទាំងឡាយ កាលប្រតិបត្តិអាចារ្យ និង ព្រះឧបជ្ឈាយ៍ និង ធ្វើសាមីចិកម្មមានកិរិយាក្រាបថ្វាយបង្គំជាដើម ដល់អាចារ្យ និង ព្រះឧបជ្ឈាយ៍ទាំងនោះ ឈ្មោះថា កតវេទី ៗ ដើម្បីប្រយោជន៍ដល់កិរិយាប្រកាសបុគ្គលទាំងនោះ ឲ្យប្រាកដ គប្បីសំដែងរឿងព្រះសោណត្ថេរ អ្នកចិញ្ចឹមព្រះឧបជ្ឈាយ៍ ជាដើម ៗ

ន័យមួយទៀត ៗ កាលបើបុគ្គលដទៃ មិនបានធ្វើឧបការៈសោះឡើយ, បុគ្គលអ្នកមិនបានពិចារណា នូវឧបការៈ ដែលអ្នកដទៃធ្វើហើយ ចំពោះខ្លួន ហើយធ្វើ ឈ្មោះថា បុព្វការី ប្រៀបដូចជាមាតានិងបិតា ១ ពួក, អាចារ្យនិងព្រះឧបជ្ឈាយ៍ ១ ពួក ៗ បុគ្គលនោះ ឈ្មោះថា រកបានដោយកម្រ ព្រោះសត្វទាំងឡាយ ត្រូវតណ្ហាគ្របសង្កត់ ៗ បុគ្គលអ្នកដឹង ប្រកាសឲ្យអ្នកដទៃដឹង នូវឧបការៈដែលអ្នកដទៃធ្វើហើយ ចំពោះខ្លួន ដោយភាពជាឧបការៈឲ្យប្រព្រឹត្តទៅតាមសមគួរ ដល់ឧបការៈដែលអ្នកដទៃ ធ្វើហើយ ឈ្មោះថា កតញ្ញូកតវេទី ប្រៀបដូចជា អ្នកប្រតិបត្តិត្រឹមត្រូវចំពោះមាតាបិតា អាចារ្យនិងព្រះឧបជ្ឈាយ៍ ៗ សូម្បីបុគ្គលនោះក៏ឈ្មោះថា រកបានដោយកម្រ ព្រោះសត្វទាំងឡាយ ត្រូវអវិជ្ជាគ្របសង្កត់ ៗ មួយទៀត បុគ្គលអ្នកស្និទ្ធស្នាល ដោយមិនមានហេតុ ឈ្មោះថា បុព្វការី, បុគ្គលអ្នកស្និទ្ធស្នាល ដោយមានហេតុ

ឈ្មោះថា **កតញ្ញូកតវេទី** ។ បុគ្គលអ្នកធ្វើ ដោយមិនសំឡឹងនូវហេតុមានជាអាទិ៍ យ៉ាងនេះ ថា "បុគ្គលនេះ នឹងធ្វើ (តបវិញ) ដល់អាត្មាអញ" ដូច្នេះ ឈ្មោះថា **បុព្វការី** ។ បុគ្គលអ្នកធ្វើដោយសំឡឹងនូវហេតុមានជាអាទិ៍ យ៉ាងនេះ ថា "បុគ្គលនេះ នឹងធ្វើ (តបវិញ) ដល់អាត្មាអញ" ដូច្នេះ ឈ្មោះថា **កតញ្ញូកតវេទី** ។ បុគ្គលអ្នកងងឹតមកហើយ ក្រោយមកភ្លឺស្វាង ឈ្មោះថា **បុព្វការី** ។ បុគ្គលអ្នកភ្លឺស្វាងមកហើយ ក្រោយមកក៏ភ្លឺស្វាង ឈ្មោះថា **កតញ្ញូកតវេទី** ។ បុគ្គលអ្នកសំដែង ឈ្មោះថា **បុព្វការី** ។ បុគ្គលអ្នកប្រតិបត្តិ ឈ្មោះថា **កតញ្ញូកតវេទី** ។ ព្រះអរហន្តសម្មាសម្ពុទ្ធឈ្មោះថា **បុព្វការី** ក្នុងលោកព្រមទាំងទេវលោក ។ ព្រះអរិយសាវ័កឈ្មោះថា **កតញ្ញូកតវេទី** " ។

(៤) បណ្ដាបទទាំងនោះ ក្នុងបទ ថា "**អាចរិយុបជ្ឈាយា**" នេះ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅ ÷ លក្ខណៈនៃអាចារ្យ និង ព្រះឧបជ្ឈាយ៍ គឺ និគ្រោធសាមណេរ ជាព្រះខីណាស្រព ត្រូវព្រះបាទអសោកធម្មរាជត្រាស់សួរ ឆ្លើយដោះស្រាយហើយ ។ មែនពិតព្រះធម្មសង្គាហកាចារ្យ បានពោលពាក្យនេះទុក ក្នុងនិទានកថា ថា "ព្រះបាទអសោកធម្មរាជ ទ្រង់ត្រាស់សួរ ថា 'បពិត្រសាមណេរ បុគ្គលដែលឈ្មោះថា ព្រះឧបជ្ឈាយ៍នេះ គឺជាបុគ្គលបែបណា ?' ។

សាមណេរ ថ្វាយព្រះពរ ថា ‘ព្រះមហារាជ អ្នកដែលឃើញនូវទោស តូចនិងធំ ហើយដាស់តឿន គ្រើនរំលឹក ឈ្មោះថា ព្រះឧបជ្ឈាយ៍ ’។ ព្រះបាទអសោកធម្មរាជ ទ្រង់ត្រាស់សួរ ថា ‘បពិត្រសាមណេរ អ្នកដែលឈ្មោះថា អាចារ្យនេះ តើបុគ្គលបែបណា? ’។ សាមណេរ ថ្វាយព្រះពរ ថា “បពិត្រព្រះមហារាជ បុគ្គលដែលឲ្យអន្តេវាសិកនិង សទ្ធិវិហារិក ស្ថិតនៅ ក្នុងធម៌ដែលគួរសិក្សា ក្នុងព្រះពុទ្ធសាសនា នេះ ឈ្មោះថា អាចារ្យ ’ ។

(៥) ដីកានិទានកថានោះថា “ បុគ្គលណា ចូលទៅសំឡឹង រំពៃ ទោសតូចនិងធំ ហេតុនោះ បុគ្គលនោះ ឈ្មោះថា ព្រះឧបជ្ឈាយ៍ ហេតុនោះ និគ្រោធសាមណេរ ទើបពោលថា ‘ **វជ្ជាវជ្ជំ ទិស្វា ចោទេតា សារេតា ច** ” ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា ‘**វជ្ជាវជ្ជំ**’ បានដល់ ទោសតូចនិងទោសធំ ” ។

ដីកាមហាខន្ធកៈថា “ ក៏ **អ** អក្សរនេះ មានវុឌ្ឍិ ជាអត្ថ ដូចជា **អ** អក្សរ ក្នុងពាក្យថា ‘ **ផលាផលំ** ’ ជាដើម ”។

ដីកានិទានកថា ថា “ បទថា ‘ **ចោទេតា** ’ មានសេចក្ដីថា បុគ្គលអ្នកពោល ដាស់តឿនថា ‘ អំពើនេះ អ្នកធ្វើមិនល្អ, ពាក្យនេះ អ្នកនិយាយមិនល្អ ’ ដូច្នេះ ជាដើម ។ បទថា ‘ **សារេតា** ’ មាន សេចក្ដីថា កាលបើគេនឹករលើក នូវទោស របស់ខ្លួនមិនឃើញទេ,

ក៏ញុំាងសតិឲ្យកើតឡើង, ម្យ៉ាងទៀត មានសេចក្តីថា ឲ្យនឹករលឹក គឺ ឲ្យប្រព្រឹត្ត ក្នុងកិរិយាប្រតិបត្តិដោយប្រពៃ ។ បុគ្គលដែលឈ្មោះថា អាចារ្យ ព្រោះឲ្យសិស្សានុសិស្ស សិក្សានូវមារយាទ ដោយន័យជាអាទិ៍ថា 'អ្នកគប្បីទន្ទេញព្រះពុទ្ធវចនៈយ៉ាងនេះ, គប្បីឈានទៅមុខ យ៉ាងដូច្នេះ, គប្បីថយក្រោយ យ៉ាងនេះ' ដូច្នេះ ហេតុនោះ និគ្រោធសាមណេរ ទើបពោលថា 'ឥមស្មឹ សាសនេ សិក្ខិតព្វធម្មេសុ បតិដ្ឋាបេតា' ដូច្នេះ ។ ក្នុងបទថា 'សិក្ខិតព្វធម្មេសុ' នោះ ព្រះពុទ្ធវចនៈទាំងអស់ និង ធម៌មានសីលជាដើម ឈ្មោះថា ធម៌ដែលគួរសិក្សា" ។

សូម្បីដោយសេចក្តី បណ្តាអាចារ្យនិងព្រះឧបជ្ឈាយ៍ទាំងនេះ គ្រូ ឈ្មោះថា ព្រះឧបជ្ឈាយ៍ ។ ព្រោះហេតុនោះ ក្នុងអដ្ឋកថាមហាខន្ធកៈ លោកពោលថា "បទថា 'អនុបជ្ឈាយកា' មានសេចក្តីថា អ្នកវៀរចាកគ្រូ ដែលជាអ្នកចាំសំឡឹងរំពៃ នូវទោសតូចនិងទោសធំ' ហើយពោលថា 'ក្នុងពាក្យថា 'ឧបសម្បទាបេក្ខៈ គឺ ភិក្ខុទាំងឡាយ គប្បីឲ្យកាន់យក នូវព្រះឧបជ្ឈាយ៍ ជាមុន' ដូច្នេះ មានវិគ្រោះថា ដែលឈ្មោះថា ព្រះឧបជ្ឈាយ៍ ព្រោះចូលទៅសំឡឹងរំពៃ នូវទោសតូចនិងទោសធំ" ដូច្នេះ ។

ដីកាមហាខន្ធកៈនោះ ថា "ដោយពាក្យថា 'ឈ្មោះថា ព្រះ

ឧបជ្ឈាយ៍ ព្រោះចូលទៅសំឡឹងរំពៃ នូវទោសតូចនិងធំ ' នេះ ព្រះអដ្ឋកថាចារ្យ សំដែងថា ' ឧបជ្ឈា ស័ព្ទ មានសេចក្ដីស្មើគ្នា នឹង **ឧបជ្ឈាយ** ស័ព្ទ " ។

នវដីកាថា " ដោយបទថា ' **ឧបជ្ឈា** ' នេះ ព្រះអដ្ឋកថាចារ្យ តែងសំដែងថា ' **ឧបជ្ឈា** ស័ព្ទ ជា **អា** ការន្ត មានសេចក្ដីស្មើគ្នានឹង **ឧបជ្ឈាយ** ស័ព្ទ ' ។ មួយទៀត គប្បីឃើញសន្និដ្ឋានថា ' ឧបជ្ឈា ស័ព្ទនុ៎ះឯង លោកធ្វើការលប់ **យ** អក្សរចេញ ពោលហើយ យ៉ាងនោះ ក្នុងទុតិយាវិភត្តិនិងបឋមាវិភត្តិ ព្រោះភាវៈនៃ **ឧបជ្ឈា** ស័ព្ទ ប្រកបមិនបាន ក្នុងតតិយាវិភត្តិជាដើម ' ដូច្នេះ " ។

(៦) បុគ្គលដែលឈ្មោះថា អាចារ្យ ព្រោះជាអ្នកដែលកូនសិស្ស គប្បីប្រព្រឹត្ត ដោយអើពើ ។ អាចារ្យនោះ មាន ៤ ពួក ។ ព្រោះហេតុនោះ ក្នុងញាតិបលិពោធកថា ក្នុងគម្ពីរវិសុទ្ធិមគ្គ ព្រះពុទ្ធឃោសាចារ្យ ទើបពោលសេចក្ដីថា " អាចារ្យ ៤ ពួក គឺ បព្វជ្ជាចារ្យ ១ ឧបសម្បទាចារ្យ ១ និស្សយាចារ្យ ១ ឧទ្ទេសាចារ្យ ១ " ។

ក៏បណ្ដាអាចារ្យទាំង ៤ ពួកនេះ អាចារ្យអ្នកបង្រៀនធម៌ ឈ្មោះថា ឧទ្ទេសាចារ្យ ។ ហេតុនោះ ក្នុងដីកាមហាខន្ធកៈ ព្រះដីកាចារ្យ ទើបពោលថា " អាចារ្យដែលឲ្យសិក្ខាបទទាំងឡាយ

នេះ ឈ្មោះថា បព្វជ្ជាចារ្យ ។ អាចារ្យដែលសូត្រកម្មវាចា ក្នុងការឧបសម្បទ នេះ ឈ្មោះថា ឧបសម្បទាចារ្យ ។ អាចារ្យដែលឲ្យឧទ្ទេស និង បរិបុច្ឆា នេះ ឈ្មោះថា ធម្មាចារ្យ " ។

ចំណែក អាចារ្យដែលភិក្ខុអង្គុយច្រហោង ក្នុងសំណាក់ ហើយពោលពាក្យ កាន់យកនិស្ស័យ ៣ ដង ថា " បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោក ជាអាចារ្យ របស់ខ្ញុំ, ខ្ញុំនឹងនៅអាស្រ័យលោកដ៏មានអាយុ " ដូច្នេះ នេះ ឈ្មោះថា និស្សយាចារ្យ ។

(៧) ក៏ក្នុងពាក្យថា " **អន្តេវាសិកសទ្ធិវិហារិកា** " នេះ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ÷ សាមណេរ និង ភិក្ខុដែលកាន់យក នូវព្រះឧបជ្ឈាយ៍ ឧបសម្បទ ពោលពាក្យ កាន់យកនូវនិស្ស័យ ក្នុងសំណាក់ នៃភិក្ខុរូបណា ថា " បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់ ជាព្រះឧបជ្ឈាយ៍ របស់ខ្ញុំ " ដូច្នេះ, ភិក្ខុរូបនោះ ឈ្មោះថា ជាព្រះឧបជ្ឈាយ៍ របស់សាមណេរ និង ភិក្ខុទាំងឡាយនោះ, សាមណេរ និង ភិក្ខុទាំងនោះ ជាសទ្ធិវិហារិក របស់ភិក្ខុដែលជាព្រះឧបជ្ឈាយ៍នោះ ។ ក៏អន្តេវាសិក មាន ៤ ពួក ដោយអំណាចអាចារ្យ គឺ បព្វជ្ជន្តេវាសិក ១ ឧបសម្បទន្តេវាសិក ១ និស្សយន្តេវាសិក ១ ធម្មន្តេវាសិក ១ ។ ចំណែក ពាក្យថា " អ្នកប្រព្រឹត្តដ៏សមគួរ ដល់ឧបការៈ ដែលអ្នកដទៃធ្វើហើយ " នេះ

រមែងសមគ្នា ដោយអដ្ឋកថាតិកនិបាត អង្គុត្តរនិកាយ ។

(៨) មែនពិត ក្នុងអដ្ឋកថាតិកនិបាត អង្គុត្តរនិកាយនោះ លោកពោលថា " បុគ្គលដែលដឹង នូវកម្មដែលបុព្វការីជននោះធ្វើហើយថា ' បុគ្គលនេះ បានធ្វើឧបការៈ ដល់អាត្មាអញ ' ដូច្នេះហើយ ធ្វើឲ្យគេដឹង គឺ ឲ្យប្រាកដច្បាស់ ហើយធ្វើតបវិញ ឈ្មោះថា **កតញ្ញូកតវេទី** " ។

ដីកាតិកនិបាត អង្គុត្តរនិកាយនោះថា " បុគ្គលដែលដឹង គឺប្រកាសឲ្យអ្នកដទៃដឹង នូវឧបការៈដែលបុព្វការីជន ធ្វើហើយ ក្នុងខ្លួន ដោយភាពជាឧបការៈ ឲ្យប្រព្រឹត្តទៅសមគួរ ដល់ឧបការៈដែលអ្នកដទៃធ្វើហើយ ឈ្មោះថា **កតញ្ញូកតវេទី** ហេតុនោះទើបលោកពោលថា ' **ឥមិនា មយ្ហំ កតំ** ' ដូច្នេះ ជាដើម " ។

ដីកាបុគ្គលបញ្ញត្តិថា " បុគ្គលអ្នកមានចិត្ត ប្រកបដោយប្រយោជន៍ ដែលប្រព្រឹត្តទៅ វៀរចាកហេតុ ឈ្មោះថា **អការណវច្ឆលោ** ( អ្នកដែលស្និទ្ធស្នាលដោយមិនមានហេតុ ) ។ បុគ្គលដែលមិនសំឡឹង នូវប្រយោជន៍ សូម្បីជាអនាគត ក៏ឈ្មោះថា ជាកតញ្ញូបុគ្គល ដូចគ្នា (តែ) មិនឈ្មោះថា **បុព្វការី** ព្រោះប្រៀបធៀបឧបការៈ ដែលគេធ្វើហើយនោះ គឺខ្លួនបានទទួលក្នុងកាលមុន ហេតុនោះ ទើបលោកពោលថា ' **ករិស្សតិ មេ** ' ដូច្នេះជាដើម " ។

អនុដីកាថា " បទថា ' បុរិមគ្គហិតំ ' មានសេចក្ដីថា ដែលខ្លួនទទួលហើយ ជាដំបូង ដោយគិតថា ' អ្នកនេះ នឹងធ្វើដល់អាត្មាអញ ' ដូច្នេះ ជាដើម ។ ២ បទថា ' តំ កតំ ' មានសេចក្ដីថា ឧបការៈនោះ គឺ ប្រាកដដូច្នេះ " ។

(៩) អដ្ឋកថាសង្គីតិសូត្រថា " បទថា ' តមោ ' ប្រែថា ជាអ្នកងងឹតហើយ ។ បទថា ' តមបរាយនោ ' មានវិគ្រោះថា សេចក្ដីងងឹតនុ៎ះឯង ជាទីទៅ គឺ ជាដំណើរទៅ ព្ធដ៏ខាងមុខ នៃបុគ្គលនោះ ហេតុនោះ បុគ្គលនោះ ឈ្មោះថា **តមបរាយនោ** (អ្នកមានសេចក្ដីងងឹតទៅខាងមុខ ) ។ ក្នុងបទទាំងពួង ក៏គប្បីជ្រាបសេចក្ដី យ៉ាងដូច្នេះ ។ ក៏បណ្ដាបុគ្គល ៤ ពួកនេះ បុគ្គលទី ១ កើតក្នុងត្រកូលចណ្ឌាលជាដើម ដែលជាត្រកូលថោកទាបរកចិញ្ចឹមជីវិតដោយលំបាក មានអត្តភាពអាក្រក់ ( ថែមទាំង ) បំពេញទុច្ចរិត ៣ យ៉ាងទៀតផង ។ បុគ្គលទី ២ ក៏ជាអ្នកដូច្នោះដែរ ( ប៉ុន្តែ ) រមែងបំពេញសុចរិត ៣ យ៉ាង ។ បុគ្គលទី ៣ កើតក្នុងត្រកូលក្សត្រជាដើម ដែលជាត្រកូលប្រសើរ មានបាយនិងទឹកច្រើន មានអត្តភាពបរិបូណ៌ ( ប៉ុន្តែ ) រមែងបំពេញទុច្ចរិត ៣ យ៉ាង ។ បុគ្គលទី ៤ ក៏ជាអ្នកដូច្នោះដែរ ( ថែមទាំង ) បំពេញសុចរិត ៣ យ៉ាងទៀតផង " ។

ដីកាសង្គីតិសូត្រនោះថា “ បទថា ‘ តមោ ’ មានសេចក្ដីថា ឈ្មោះថា ជាអ្នកងងឹត ព្រោះភាវៈជាអ្នកមិនប្រាកដ ៗ ហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា “ អន្ធការភូតោ ” ។ បទថា ‘ អន្ធការភូតោ ’ មានសេចក្ដីថា ជាអ្នកដូចជាសេចក្ដីងងឹត មានហើយ គឺ កើតហើយ, ម្យ៉ាងទៀត ដល់ហើយ នូវកិរិយាតាំងចុះក្នុងសេចក្ដីងងឹតដោយភាពជាអ្នកមិនប្រាកដ ៗ បទថា ‘ តមមេវ ’ មានសេចក្ដីថា សេចក្ដីងងឹត ដែលមានលក្ខណៈដូចបានពោលមកហើយនុ៎ះឯង ជាទីទៅ គឺ ជាដំណើរទៅ បានដល់ ជាទីតាំងចុះចំពោះមុខ គឺ ខាងមុខ ៗ ដោយបទថា ‘ នីចេ ។ បេ ។ និព្វត្តោ ’ នេះ ព្រះអដ្ឋកថាចារ្យ សំដែងនូវភាវៈ នៃបុគ្គលនោះជាអ្នកងងឹត ៗ ដោយបទថា ‘ តីណិ ទុច្ចរិតានិ បរិបូរេតិ ’ នេះ ព្រះអដ្ឋកថាចារ្យ សំដែងនូវភាវៈ នៃបុគ្គលនោះ ជាអ្នកមានសេចក្ដីងងឹត ជាទីទៅ ពន្លឺខាងមុខ ៗ ក្នុង ២ បទនេះ គប្បីជ្រាបសេចក្ដី តាមទំនងនៃន័យដែលពោលហើយ ព្រោះដល់នូវភាពជាអ្នកប្រាកដ ” ។

(១០) អដ្ឋកថាតតិយវគ្គ ក្នុងកោសលសំយុត្ត និង អដ្ឋកថាទុតិយបណ្ណាសកៈ ក្នុងចតុក្កនិបាត អង្គុត្តរនិកាយ ថា “បុគ្គលឈ្មោះថា ជាអ្នកងងឹត ព្រោះប្រកបដោយសេចក្ដីងងឹត មានកើតក្នុង

ត្រកូលថោកទាប ពួជីខាងក្រោយជាដើម ។ ឈ្មោះថា ជាអ្នកមានសេចក្ដីងងឹតទៅខាងមុខ ព្រោះកិរិយាទៅកើតក្នុងនរក ម្ដងទៀតដោយកាយទុច្ចរិតជាដើម ។ សូម្បីដោយបទទាំង ២ ដូចពោលមកហើយនេះ ក៏ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ សេចក្ដីងងឹតនៃខន្ធន៌ះផងដែរ ។ បុគ្គលអ្នកប្រកបដោយសេចក្ដីរុងរឿង មានកើតក្នុងត្រកូលស្តុកស្តម្ភ ក្នុងកាលជាខាងក្រោយជាដើម ឈ្មោះថា បុគ្គលអ្នកមានពន្លឺ អធិប្បាយថា ជាអ្នកភ្លឺស្វាងហើយ ។ ឈ្មោះថា ជាអ្នកមានពន្លឺភ្លឺស្វាងទៅខាងមុខ ព្រោះកិរិយាចូលដល់ភាពរុងរឿង គឺ ទៅកើតក្នុងស្ថានសួគ៌ទៀត ដោយកាយសុចរិត ជាដើម ” ។

ដីកាតតិយវគ្គ ក្នុងកោសលសំយុត្ត ជាដើមនោះ ថា “ ឈ្មោះថា ជាអ្នកងងឹត ព្រោះប្រៀបដូចជាងងឹត ព្រោះភាពជាអ្នកមិនប្រាកដ ហេតុមានកើតក្នុងត្រកូលថោកទាប ក្នុងកាលខាងក្រោយជាដើម ។ បុគ្គលឈ្មោះថា ជាអ្នកងងឹត ព្រោះប្រកបដោយសេចក្ដីងងឹតនោះ ។ ក៏លោកពោល វោហារថា ងងឹត របស់បុគ្គល ព្រោះប្រកបដោយសេចក្ដីងងឹតនោះ ដូចជាឧទាហរណ៍ថា ‘ បុគ្គលឈ្មោះថា ជាអ្នកមានសេចក្ដីកំណាញ់ ព្រោះប្រកបដោយសេចក្ដីកំណាញ់ស្វិតស្វាញ ’ ។ ព្រោះហេតុនោះ បទថា ‘ តមោ ’ ទើបមានសេចក្ដីថា ជាអ្នកងងឹត គឺ ប្រៀបដូចជាធ្វើ នូវភាពជា

បុគ្គលអ្នកងងឹត កើតហើយ ព្រោះភាពមិនប្រាកដ ឬដល់នូវការតាំងចុះ ក្នុងសេចក្ដីងងឹត ។ សេចក្ដីងងឹត មានលក្ខណៈដូចពោលមកហើយនុ៎ះឯង ជាទីទៅ គឺ ជាដំណើរទៅ បានដល់ ជាទីតាំងចុះព្ធដ៏ខាងមុខ គឺ ខាងមុខ របស់បុគ្គលនោះ ហេតុនោះ បុគ្គលនោះឈ្មោះថា ជាអ្នកមានសេចក្ដីងងឹតជាទីទៅខាងមុខ ដូច្នេះឯង ។ ដោយ តម ស័ព្ទទាំង ២ យ៉ាង ព្រះអដ្ឋកថាចារ្យ សំដែងសេចក្ដីងងឹត នៃខន្ធប៉ុណ្ណោះ, មិនបានសំដែងសេចក្ដីងងឹតគឺអន្ធការទេ ។ មួយទៀត ក្នុងបទថា ' ខន្ធតមោ ' នេះ គប្បីឃើញកិរិយាកើតឡើងនៃខន្ធ ដែលវៀរចាកសម្បត្តិនុ៎ះឯង ។ បុគ្គលឈ្មោះថា ជាអ្នកភ្លឺស្វាង ព្រោះរមែងរុងរឿង ដោយភាពប្រាកដ ហេតុមានការកើតក្នុងត្រកូលស្អុកស្គម ក្នុងកាលជាខាងក្រោយ ជាដើម ។ ពាក្យទាំងពួងមានជាអាទិ៍ថា ' ប្រកបដោយសេចក្ដីរុងរឿងនោះ ' គប្បីជ្រាប តាមន័យដែលបានពោលមកហើយ ' ដូច្នេះ " ។

ដីកាបុគ្គលប្បញ្ញត្តិ ថា "បុគ្គលអ្នកងងឹត មានសេចក្ដីភ្លឺស្វាងជាទីទៅខាងមុខ មិនអាស្រ័យផលបុណ្យរស់នៅឡើយ រមែងធ្វើនូវបុណ្យទាំងឡាយ ហេតុនោះ ទើបលោកពោល ថា ' បុព្វការី " ។

អនុដីកា ថា "បុគ្គលអ្នកអាស្រ័យផលបុណ្យរស់នៅ រមែងស្ថិតនៅ ក្នុងចំណែកនៃកតញ្ញូ ហេតុនោះ ទើបព្រះដីកាចារ្យ

ពោលថា ‘ មិនអាស្រ័យផលបុណ្យរស់នៅ ” ។ ដីកាទុកនិបាត អង្គុត្តរនិកាយ ក៏យ៉ាងដូច្នោះដែរ ។

(១១) បុគ្គលអ្នកមានកតញ្ញូ រមែងជាអ្នករកបានដោយកម្រ យ៉ាងនេះឯង, បុគ្គលជាអ្នករកបានដោយកម្រ ដោយចំណែកណា, ឯភាពជាអ្នកមានកតញ្ញូ ក៏រមែងរកបានដោយកម្រ ដោយចំណែកនោះដែរ ។ ក៏ភាពជាអ្នកមានកតញ្ញូនោះ របស់បុគ្គលនោះ រមែងឲ្យបានដល់ នូវភាពជាអ្នកគួរសរសើរ ថា “ បុគ្គលនេះ ជាអ្នករកបានដោយកម្រ ” ។ ព្រោះហេតុនោះឯង ភាពជាអ្នកមានកតញ្ញូនោះ ទើបឈ្មោះថា ជាមង្គល ។ ដោយហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោលថា “ ភាពជាអ្នកមានកតញ្ញូនោះ បណ្ឌិតគប្បីជ្រាបថា ‘ ជាមង្គល ’ ព្រោះជាហេតុ នៃកិរិយាសម្រេចគុណវិសេស មានប្រការផ្សេងៗ មានភាវៈជាអ្នកគួរសរសើរ ថា ‘ ជាសប្បុរស ’ ដូច្នេះ ជាដើម ” ។ មែនពិត បុគ្គលអ្នកមានកតញ្ញូ ជាអ្នកដែលរកបានដោយកម្រណាស់, មិនមែនជាអ្នករកបានដោយងាយដូចជាបុគ្គលអកតញ្ញូឡើយ ។ ព្រោះថា បុគ្គលអកតញ្ញូមានច្រើន ដូច្នេះ។

បណ្តាបុគ្គលទាំង ២ ពួកនោះ បុគ្គលអ្នកមានកតញ្ញូ រមែងបានសម្រេច នូវប្រយោជន៍សុខ មានកិរិយាសរសើរជាដើម ក្នុងលោកនេះ, បុគ្គលអកតញ្ញូ រមែងសម្រេច នូវហេតុដែលមិន

មែនជាប្រយោជន៍ មានកិរិយានិន្ទាជាដើម ក្នុងលោកនេះ ។ ក្នុងសេចក្តីនោះ មានរឿងទាំងនេះ ( ជាឧទាហរណ៍ ) ។

## ( រឿងព្រះបាទបទុម )

(១២) ក្នុងអតីតកាល ព្រះរាជាក្រុងពារាណសី ទ្រង់មានព្រះរាជបុត្រ ៧ ព្រះអង្គ ។ បណ្តាព្រះរាជបុត្រទាំង ៧ ព្រះអង្គនោះ ព្រះរាជកុមារ ព្រះនាមបទុម ដែលជាព្រះជេដ្ឋា របស់ព្រះរាជ-កុមារទាំងអស់ ជាព្រះពោធិសត្វ ។ ព្រះរាជា ទ្រង់ញ៉ាំងសេចក្តីរង្កៀសសង្ស័យ ឲ្យកើតឡើង ក្នុងព្រះរាជបុត្រទាំងនោះ ថា " ព្រះរាជបុត្រទាំងនេះ គប្បីសម្លាប់អាត្មាអញហើយ ដណ្តើមយកទាំងរាជសម្បត្តិ " ហើយទ្រង់ត្រាស់ថា " នែបុត្រសំឡាញ់ ចូរអ្នកទាំងឡាយ កុំនៅក្នុងព្រះនគរនេះឡើយ, ចូរពួកអ្នកទៅក្នុងទីដទៃ ដោយកាលកន្លងទៅនៃបិតា ចាំមកទទួលយករាជសម្បត្តិចុះ " ។ ព្រះរាជបុត្រទាំងនោះ ចៀសចេញទៅ ព្រមទាំងព្រះមហេសីទាំងឡាយ របស់ខ្លួនៗ កាលមិនបានព្រះក្រយាហារនិងទឹក ក្នុងផ្លូវទុរគមលំបាកមួយ ក្នុងចន្លោះផ្លូវ ទើបសម្លាប់មហេសី របស់ព្រះរាជបុត្រពៅគេបង្អស់ ហើយចែកគ្នាជា ១៣ ចំណែក ហើយទ្រង់សោយនូវសាច់ ។ ចំណែក ព្រះពោធិសត្វ ទ្រង់ទុកសាច់

១ ចំណែក ក្នុង ២ ចំណែកដែលខ្លួននិងមហេសីបានហើយ សោយតែមួយចំណែកប៉ុណ្ណោះ ជាមួយនឹងមហេសី ។ ព្រះរាជបុត្រទាំងនោះ ទ្រង់សម្លាប់ស្ត្រី ៦ នាក់ ហើយទ្រង់សោយ (សាច់) ក្នុង ៦ ថ្ងៃ ដោយន័យនេះ ។ ឯព្រះពោធិសត្វ ទ្រង់ទុកសាច់មួយថ្ងៃមួយចំណែក ៗ ជារៀងរាល់ថ្ងៃ ។ ក្នុងថ្ងៃទី ៧ ព្រះពោធិសត្វបាននៅសល់សាច់ ៦ ចំណែក ដោយប្រការដូច្នេះ ។ ព្រះពោធិសត្វនោះ ឲ្យសាច់ ៦ ចំណែក ដល់ព្រះរាជបុត្រទាំងនោះ ដែលប្រាថ្នាចង់សម្លាប់ព្រះមហេសី របស់ព្រះអង្គ ហើយទ្រង់ត្រាស់ថា "នែព្រះអនុជទាំងឡាយ ក្នុងថ្ងៃនេះ អ្នកទាំងឡាយ ចូរសោយនូវចំណែកទាំងនេះចុះ, ក្នុងថ្ងៃស្អែក យើងទាំងអស់គ្នា នឹងដឹង " ដូច្នេះហើយក្នុងពេលដែលព្រះរាជបុត្រទាំងនោះ ទ្រង់ផ្ទំលក់ស្កប់ស្កល់ ទើបទ្រង់នាំព្រះមហេសីរត់ចេញទៅ ទ្រង់លើកលីព្រះមហេសី ដែលមិនអាចនឹងយាងទៅបាន ដោយព្រះអង្សា ទ្រង់ចេញអំពីផ្លូវទុគ៌មលំបាកក្នុងវេលាព្រះអាទិត្យរះឡើង, កាលបើព្រះមហេសីទ្រង់មានព្រះសវនីយ៍ថា "បពិត្រព្រះស្វាមី ទូលព្រះបង្គំទ្រង់ស្រេកទឹក" ដូច្នេះ, កាលមិនបានទឹក ទើបទ្រង់យកព្រះខ័នមកកាប់ នូវព្រះជានុ ខាងស្តាំ ហើយទ្រង់ឲ្យព្រះមហេសី សោយព្រះលោហិត ។ ព្រះស្វាមីនិងព្រះជាយាទាំង ២ ព្រះអង្គនោះ ទ្រង់យាងមកដល់មហាគង្គា

ដោយលំដាប់ ទ្រង់សាងបណ្ណសាលា ទ្រង់សម្រេចការរស់នៅ ត្រង់ទីបត់នៃទន្លេគង្គា ។

ក្នុងកាលនោះ មនុស្សទាំងឡាយ (ចាប់) នូវចោរម្នាក់ដែលប្រព្រឹត្តខុសនឹងព្រះរាជាមកកាត់ដៃ ជើង ត្រចៀក និង ច្រមុះហើយដាក់ក្នុងទូកកំគ្រោលមួយ ទំលាក់ចោលហើយ ក្នុងទន្លេគង្គា ។ បុរសកំបុត ធ្វើសំឡេងស្រែកយ៉ាងខ្លាំង ដល់ទីស្ថាននោះហើយ ។ ព្រះពោធិសត្វ ទ្រង់ព្រះសណ្ដាប់សំឡេងនោះហើយ ទ្រង់ស្រង់នូវបុរសកំបុតនោះឡើង ដោយសេចក្ដីករុណា ទ្រង់នាំទៅបណ្ណសាលាហើយ ទ្រង់បានធ្វើការរក្សាដំបៅ ដោយកិរិយាស្ងំ ដោយទឹកអម្ចត់ និងលាបថ្នាំជាដើម ។ ចំណែក ព្រះមហេសី របស់ព្រះពោធិសត្វ ទ្រង់ខ្ពើមរអើម នូវបុរសកំបុតនោះ ទ្រង់យាងស្ដោះទឹកមាត់ ។ ព្រះពោធិសត្វ ទ្រង់ឲ្យបុរសកំបុត ព្រមទាំងព្រះមហេសីនៅក្នុងអាស្រមបទ ហើយព្រះអង្គឯង ក៏នាំយកនូវផលាផលមកចិញ្ចឹម ។ ព្រះមហេសីនោះ ទ្រង់មានព្រះទ័យប្រតិព័ទ្ធ ចំពោះបុរសកំបុត ទ្រង់ប្រព្រឹត្តខុស ជាមួយនឹងបុរសកំបុតនោះ ទ្រង់មានព្រះបំណងសម្លាប់ព្រះពោធិសត្វ ដោយឧបាយកល ទើបទ្រង់មានព្រះសវនីយ៍ ថា "បពិត្រព្រះស្វាមី ទូលព្រះបង្គំកាលជិះនៅលើព្រះអង្សារបស់ព្រះអង្គ ចេញអំពីផ្លូវទុរគមលំបាក ឃើញភ្នំមួយ

ហើយបានបួងសួងថា 'បពិត្របពិតទេវតា ដ៏ចំរើន បើនាងខ្ញុំ ព្រមទាំងស្វាមី មិនមានសេចក្តីអន្តរាយ នឹងបានជីវិត, នាងខ្ញុំនឹងធ្វើនូវពលិកម្ម ដល់អ្នក ' ដូច្នេះ, ឥឡូវនេះ ទូលព្រះបង្គំ នឹងធ្វើពលិកម្ម ដល់ទេវតានោះ" ដូច្នេះហើយ ក៏នាំព្រះពោធិសត្វ ទៅក្នុងទីនោះ មានព្រះសវនីយ៍ ថា "បពិត្រព្រះស្វាមី ព្រះអង្គប៉ុណ្ណោះ ជាទេវតាដ៏ប្រសើរ, ទូលព្រះបង្គំធ្វើប្រទក្សិណ ថ្វាយបង្គំព្រះអង្គ មុនហើយនឹងធ្វើពលិកម្ម ដល់ទេវតា ជាខាងក្រោយ" ដូច្នេះហើយ ទើបឲ្យព្រះពោធិសត្វ ទ្រង់គង់បែរព្រះភក្ត្រឆ្ពោះទៅរកជ្រោះ បូជាហើយដោយបុប្ផាទាំងឡាយ ឈរនៅក្បែរព្រះបិដ្ឋិ ធ្វើដូចជាចង់ថ្វាយបង្គំ ប្រហារត្រង់ព្រះបិដ្ឋិ (ខ្នង) ហើយច្រានព្រះពោធិសត្វ ឲ្យធ្លាក់ចុះទៅក្នុងជ្រោះ ស្រេចហើយក៏បានត្រឡប់មក កាន់សំណាក់នៃបុរសកំបុតវិញ ។ ចំណែក ព្រះពោធិសត្វ កាលធ្លាក់ទៅ ក៏បានធ្លាក់ទៅ លើគុម្ពឈើដែលមិនមានបន្លាមួយគុម្ព លើចុងដើមឧទុម្ពរ កាលមិនអាច ដើម្បីយាងទៅ ទីដទៃបាន ក៏ទ្រង់គង់សោយនូវផ្លែឧទុម្ពរ ពួដ៏ចន្លោះមែកឈើ ។

ក៏មានស្តេចទន្សោងមួយ មានខ្លួនយ៉ាងធំ ធ្លាប់ឡើងមកអំពីជើងភ្នំ មកស៊ីផ្លែឈើនោះ ។ ស្តេចទន្សោងនោះ ឡើងមកដើម្បីស៊ីនូវផ្លែឈើ ឃើញព្រះពោធិសត្វហើយ ក៏ដល់នូវសេចក្តីស្និទ្ធស្នាល

ជាមួយនឹងព្រះពោធិសត្វនោះ សួរនូវហេតុដែលព្រះពោធិសត្វនោះមកក្នុងទីនោះ ស្តាប់រឿងនោះហើយ ទើបឲ្យព្រះពោធិសត្វនោះគង់នៅលើខ្នង របស់ខ្លួន នាំឡើងផុតពីជ្រោះ ហើយក៏ចេញពីព្រៃ ដាក់នៅលើផ្លូវធំ ហើយក៏ចូលទៅកាន់ព្រៃដូចដើមវិញ ។ ព្រះពោធិសត្វស្តេចយាងទៅកាន់បច្ចន្តគ្រាម គង់នៅក្នុងទីនោះ ដោយកាលកន្លងទៅនៃព្រះបិតា ទ្រង់ទទួលនូវរាជសម្បត្តិ ជាព្រះរាជាទ្រង់ព្រះនាមបទុម ទ្រង់ត្រាស់បញ្ជា ឲ្យសាងសាលាទាន ៦ ខ្នង ទ្រង់បានបរិច្ចាគព្រះរាជទ្រព្យ ៦ សែន ថ្វាយទាន ជារៀងរាល់ថ្ងៃ ។

ឯស្ត្រីអាក្រក់នោះ បានលើកលីបុរសកំបុតនោះ ដោយស្មាហើយចេញពីព្រៃ ដើរសុំទានគេ ក្នុងទីលំនៅនៃមនុស្ស ចិញ្ចឹមបុរសកំបុតនោះ ត្រូវពួកមនុស្សសួរថា “បុរសនេះ ត្រូវជាអ្វីរបស់នាង ?” ដូច្នេះ ទើបពោលថា “នាងខ្ញុំជាធីតារបស់ឪពុកធំ របស់បុរសនុ៎ះ, បុរសនុ៎ះ ជាកូនរបស់ឪពុកមា របស់នាងខ្ញុំ, ញាតិទាំងឡាយបានលើកនាងខ្ញុំ ឲ្យដល់បុរសនុ៎ះឯង, នាងខ្ញុំនោះ ចិញ្ចឹមប្តី របស់ខ្លួន សូម្បីជាអ្នកមានទោសដល់ស្លាប់ ក៏ដើរសុំទានគេចិញ្ចឹមដែរ” ។ មនុស្សទាំងឡាយ គិតថា “ស្ត្រីនេះ ជាអ្នកបំពេញវត្តចំពោះប្តី” ដូច្នេះហើយ ក៏បានឲ្យយាគូនិងភ័ត្ត ដ៏ច្រើនលើសលប់ និង ឲ្យករញ្ជើផ្តៅយ៉ាងមាំទាំ ដោយប្រាប់ថា “ចូរនាងឲ្យប្តី របស់នាងអង្គុយ

ក្នុងកញ្ជើនេះ ហើយទៅចុះ"។ ឯស្ត្រីអាក្រក់នោះ បានធ្វើ យ៉ាងដូច្នោះ ត្រាច់ចរទៅ បានទៅដល់ក្រុងពារាណសី ដើរបរិភោគ ក្នុងសាលាទានទាំងឡាយ ។ ព្រះពោធិសត្វ ទ្រង់ព្រះរាជទាន នូវទានវត្ត ដល់ពួកយាចក ៨ នាក់ខ្លះ ១០ នាក់ខ្លះ ក្នុងសាលាទាន ដោយព្រះហស្តព្រះអង្គឯង កាលស្តេចទ្រង់យាងមកវិញ ទ្រង់ទតព្រះនេត្រឃើញស្ត្រីអាក្រក់នោះ ត្រង់ចន្លោះផ្លូវ ទើបទ្រង់ត្រាស់សួរថា "នុ៎ះ គឺជាអ្វី ?"។ ពួករាជបុរសក្រាបទូលថា "បពិត្រព្រះសម្មតិទេព ស្ត្រីនុ៎ះ គឺជាស្ត្រីដែលបំពេញវត្តចំពោះប្តីម្នាក់"។ ព្រះពោធិសត្វ ទ្រង់ត្រាស់ឲ្យហៅស្ត្រីនោះមក ទ្រង់ចាំបាន ទើបទ្រង់ត្រាស់ឲ្យយកបុរសកំបុតចេញ អំពីកញ្ជើ ហើយទ្រង់ត្រាស់សួរ ។ ស្ត្រីអាក្រក់នោះ បានក្រាបទូល ដោយន័យមុននុ៎ះឯង ។ ព្រះរាជាទ្រង់ត្រាស់ថា "នាងមែនឬ ? ជាមហេសី របស់បទុមកុមារ ជាព្រះធីតា របស់ព្រះរាជាអង្គនុ៎ះ មានព្រះនាមយ៉ាងនុ៎ះ សោយនូវលោហិតព្រះជានុ (ក្បាលជង្គង់) របស់យើង ហើយក៏មានចិត្តប្រតិព័ទ្ធ ចំពោះបុរសកំបុតនេះ បានច្រានយើងទម្លាក់ ក្នុងជ្រោះ, ឥឡូវនេះ នាងឯងនោះ បានកាន់យកសេចក្តីស្លាប់ ពួដីថ្វាស់ ហើយសម្គាល់យើង ថា 'ស្លាប់ហើយ' ទើបមកហើយ" ដូច្នេះហើយ ទ្រង់ត្រាស់បញ្ជាពួកអាមាត្យ ថា "អ្នកទាំងឡាយ ចូរយកអង្រែ

វាយបុរសកំបុតនេះ ឲ្យស្លាប់ទៅ, ចូរកាត់នូវត្រចៀកនិងច្រមុះ របស់ស្ត្រីអាក្រក់នេះចេញ ” ។ ព្រះពោធិសត្វនុ៎ះ ទ្រង់មិនអាចនឹង អត់ធន់ នូវសេចក្ដីក្រោធខឹងបាន ទើបទ្រង់ត្រាស់បញ្ជាឲ្យដាក់ព្រះ រាជអាជ្ញាដល់ជនទាំង ២ នាក់នោះ យ៉ាងនេះ ក៏ពិតមែន, ទោះបី ជាយ៉ាងនោះក៏ដោយ ក៏ព្រះអង្គមិនបានទ្រង់ត្រាស់បញ្ជាឲ្យធ្វើ យ៉ាង ដូច្នោះឡើយ ។ ព្រះរាជា ទ្រង់ធ្វើព្រះពិរោធ ឲ្យចុះថយហើយ ទ្រង់ត្រាស់បញ្ជាឲ្យចង យ៉ាងជាប់លាប់ ដោយប្រការដែលស្ត្រីនោះ មិនអាចនឹងទម្លាក់ នូវកញ្ជើចុះអំពីក្បាលបាន ហើយទ្រង់ត្រាស់ឲ្យ ដាក់បុរសកំបុត ក្នុងកញ្ជើនោះ ទ្រង់ត្រាស់ឲ្យនិរទេសចេញអំពី ព្រះរាជធានី របស់ព្រះអង្គ ។

រឿងព្រះរាជាព្រះនាមបទុម មកក្នុងអដ្ឋកថាចូឡបទុមជាតក
ក្នុងបញ្ចមវគ្គ នៃទុកនិបាត ។

## ( រឿងតក្កបណ្ឌិត )

(១៣) ក្នុងអតីតកាល ព្រះពោធិសត្វកើតជាតាបស នៅ ដោយសេចក្ដីសុខដែលកើតអំពីឈាន ក្នុងបណ្ណសាលា ក្បែរមាត់ ច្រាំងនៃទន្លេគង្គា ។ ក្នុងកាលនោះ ធីតានៃសេដ្ឋីក្រុងពារាណសី ឈ្មោះថា ទុដ្ឋកុមារី ជាស្រីកាចសាហាវ ឆ្នាស ជេរប្រទេច វាយដំ

នូវពួកកម្មករទាំងឡាយ ។ តមក ថ្ងៃមួយ កម្មករទាំងឡាយ បាននាំនាងទៅ ដោយពោលថា "ពួកយើង នឹងលេង (ទឹក) ក្នុងទន្លេគង្គា" ដូច្នេះហើយ ក៏ចោលនាង ក្នុងទន្លេគង្គានោះ ។ សេដ្ឋីធីតានោះ ស្រែកយំ ត្រូវទឹកកួច បានទៅដល់ទីជិតនៃសាលា របស់ព្រះពោធិសត្វ ក្នុងពេលពាក់កណ្ដាលយប់ ។ តាបស បានស្រង់នាងនោះឡើង ដោយសេចក្ដីករុណាចំពោះនាង ហើយដុតភ្លើងឲ្យ, កាលបើសេចក្ដីរងា បាត់ហើយ, ក៏ឲ្យផលានុផល ហើយសួរថា "នាងនៅ ក្នុងទីក្រុងណា ?" ។ សេដ្ឋីធីតា ពោលថា "នាងខ្ញុំនៅក្នុងទីក្រុងពារាណសី" ។ តាបស ពោលថា "សូមនាងអញ្ជើញទៅ ក្នុងពេលនេះចុះ" ។ នាងគិតថា "អាត្មាអញ នឹងធ្វើឲ្យតាបសនេះ ដាច់សីល ហើយនាំតាបសនោះទៅ" ហើយបានធ្វើយ៉ាងនោះ បានទៅហើយ ។ ឯតាបស មានសីលខាតហើយ សាបសូន្យចាកឈានហើយ បានទៅកាន់បច្ចន្តគ្រាមមួយ ជាមួយនឹងស្ត្រីនោះ លក់ទឹកដោះរាវជូរថ្លា ចិញ្ចឹមស្ត្រីនោះ ។ ហេតុនោះ ពួកមនុស្ស ទើបដាក់ឈ្មោះ ព្រះពោធិសត្វនោះថា "តក្កបណ្ឌិត" ។ ក៏មនុស្សទាំងឡាយ បានឲ្យនូវស្បៀងដល់ព្រះពោធិសត្វនោះ ហើយពោលថា "សូមលោកប្រាប់ នូវការងារ ដែលប្រកបល្អ ឬមិនល្អ ដល់ពួកយើងខ្ញុំ ហើយនៅ ក្នុងទីនេះចុះ" ដូច្នេះហើយ ក៏បានឲ្យ

ព្រះពោធិសត្វនៅ ក្នុងខ្ទម ក្បែរមាត់ទ្វារផ្ទះ ។ ក្រោយមក ថ្ងៃមួយ ចោរទាំងឡាយ បានប្លន់នូវផ្ទះនោះ ហើយក៏បាននាំយកភរិយារបស់តក្កបណ្ឌិតទៅ ។ មេចោរ បានធ្វើនាងនោះ ជាភរិយា ។ នាងនោះ ប្រាថ្នានឹងឲ្យមេចោរសម្លាប់តក្កបណ្ឌិតចោល ទើបបានបញ្ជូនដំណឹងទៅ ដល់តក្កបណ្ឌិតនោះថា “នាងខ្ញុំ ត្រូវពួកចោរនាំយកមក រស់នៅជាទុក្ខ, សូមបងអញ្ជើញមក នាំយកប្អូនទៅ” ដូច្នេះ ឃើញតក្កបណ្ឌិតនោះមក ក្នុងទីនោះហើយ ទើបពោលថា “បើពួកយើងទាំង ២ នាក់ នឹងនាំគ្នាទៅ ក្នុងពេលឥឡូវនេះ, ចោរនឹងដេញតាម ហើយសម្លាប់ពួកយើងទាំង ២ នាក់ចោល, ពួកយើង នឹងទៅ ក្នុងពេលយប់ចុះ” ដូច្នេះហើយ ក៏ឲ្យតក្កបណ្ឌិតនោះ អង្គុយក្នុងជោកស្រូវ ក្នុងពេលដែលមេចោរមកផឹកសុរាស្រវឹងហើយ ក្នុងពេលល្ងាច ទើបប្រាប់ (ដល់មេចោរ) ។ ចោរ ចាប់តក្កបណ្ឌិតនោះផ្តួល ហើយវាយ ដោយកែងដៃជាដើម តាមសេចក្តីពេញចិត្ត ចងឲ្យដេកហើយ ។ តក្កបណ្ឌិតនោះ ត្រូវចោរវាយដំមិនបានពោលពាក្យអ្វីដទៃឡើយ ពោលតែពាក្យនេះ តែម៉្យាងថា “បុគ្គលអ្នកក្រោធខឹង បុគ្គលអកតញ្ញូ បុគ្គលអ្នកស៊ិកសៀត បុគ្គលអ្នកប្រទូសរ៉ាយមិត្រ” ។ ឯចោរដេកលក់ ក្រោកឡើងហើយ, កាលបើសុរា ស្វាងហើយ, ទើបចាប់ផ្តើមវាយដំ តក្កបណ្ឌិតនោះ

ម្តងទៀត ។ ឯតក្កបណ្ឌិតនោះក៏ពោលយ៉ាងដូច្នោះឯង ។ ចំណែក ចោរ គិត ថា "បុរសនេះ ពោលតែពាក្យនេះប៉ុណ្ណោះ មិនបានពោល ពាក្យដទៃឡើយ, នេះ គឺជាអ្វី ?" សួរហើយ ក៏បានស្តាប់រឿង រ៉ាវទាំងអស់ ហើយគិត ថា "ស្ត្រីនេះ ប្រតិបត្តិខុស ក្នុងបុគ្គលអ្នក មានឧបការៈយ៉ាងនេះ, ស្ត្រីនុ៎ះ គប្បីធ្វើនូវសេចក្តីអន្តរាយ ដល់ អញផងដែរ, អាត្មាអញគប្បីសម្លាប់ស្ត្រីនុ៎ះចោល" ដូច្នេះ ក៏បាន ដាស់ឲ្យស្ត្រីនោះក្រោកឡើង ហើយប្រាប់ ថា "ចូរនាងមក, យើង នឹងសម្លាប់ បុរសនុ៎ះចោល" ទៅដល់ក្រៅផ្ទះហើយ ក៏សម្លាប់ស្ត្រី នោះចោល ហើយនាំតក្កបណ្ឌិត ទៅកាន់ផ្ទះ ពោល ថា "ឥឡូវនេះ តើអ្នក នឹងអញ្ជើញទៅ ក្នុងទីណា ?" ។ តក្កបណ្ឌិត ពោលថា "ខ្ញុំនឹងទៅបួស នៅក្នុងព្រៃ" ។ មេចោរ ពោល ថា "ចំណែក ខ្ញុំ ក៏នឹងបួសដែរ" ។ ជនទាំង ២ នាក់នោះ លុះបួសហើយ ញុំាង ឈាននិងអភិញ្ញាឲ្យកើតឡើងហើយ ក៏ទៅកើតក្នុងព្រហ្មលោក ។

រឿងតក្កបណ្ឌិត មកក្នុងអដ្ឋកថាតក្កជាតក ក្នុងសត្តមវគ្គ ឯកនិបាត ។

## ( រឿងជន ៤ នាក់ )

(១៤) ក្នុងអតីតកាល ព្រះពោធិសត្វ កើតជាតាបស នៅ ក្នុងបណ្ណសាលា ក្បែរមាត់ច្រាំងទន្លេគង្គា ។ ក្នុងកាលនោះ

ព្រះរាជបុត្រ របស់ព្រះរាជាក្រុងពារាណសី ទ្រង់មានព្រះនាមថា ទុដ្ឋកុមារ ជាមនុស្សដែលរឹងត្អឹង អាក្រក់អាក្រី មិនជាទីស្រឡាញ់ពេញចិត្ត នៃមនុស្សទាំងពួង ប្រៀបដូចជាធូលីចូលភ្នែក និង ដូចជាបីសាចដែលមកហើយ ដើម្បីនឹងស៊ី ។ ថ្ងៃមួយ ព្រះរាជឱរសនោះ ទ្រង់ក្រសាល (ទឹក) ក្នុងទន្លេគង្គា ទ្រង់ត្រាស់ថា "នែនាយចូរពួកអ្នកអញ្ជើញមក, ចូរនាំខ្ញុំទៅកាន់ទីកណ្ដាលនៃស្ទឹង ហើយនាំមកវិញ"។ មនុស្សទាំងនោះ នាំព្រះរាជឱរសនោះទៅចោលហើយ ក៏រត់បាត់អស់ទៅ ។ ព្រះរាជឱរសនោះត្រូវទឹកកួចយកទៅទតព្រះនេត្រឃើញនូវគល់ឈើមួយ ហើយគង់នៅលើគល់ឈើនោះ ទ្រង់ព្រះកន្សែង អណ្ដែត(លើទឹក) ទៅ ។

ក្នុងកាលនោះ សេដ្ឋីនៅក្នុងទីក្រុងពារាណសីម្នាក់ កប់ទ្រព្យ ៤០ កោដិ ក្បែរមាត់ច្រាំងនៃទន្លេ ព្រោះសេចក្ដីត្រូវការ ក្នុងទ្រព្យ (ស្លាប់ទៅ) ក៏ទៅកើតជាពស់លើខ្នងនៃកំណប់ទ្រព្យ ។ ឯសេដ្ឋីម្នាក់ទៀត បានកប់ទ្រព្យទុក ៣០ កោដិ ក្នុងកន្លែងនោះ ដូចគ្នាដែរ ព្រោះសេចក្ដីត្រូវការក្នុងទ្រព្យ (ស្លាប់ទៅ) ក៏ទៅកើតជាកណ្ដុរក្នុងទីនោះឯង ។ ទីលំនៅ នៃសត្វទាំងនោះ លិចចូលទឹកហើយ ។ សត្វទាំងនោះ ចេញទៅហើយ ក៏ឃើញគល់ឈើនោះ ព្រមទាំងព្រះរាជកុមារនោះទ្រង់គង់នៅ (លើ) ទើបឡើងទៅដេក នៅលើខ្នង

នៃគល់ឈើនុ៎ះឯងដូចគ្នា ។ ក៏នៅក្បែរមាត់ស្ទឹង មានដើមរកាមួយដើម ។ កូនសត្វសេកមួយ នៅលើដើមរកានោះ ។ ដើមឈើរលំដួលហើយ លើខ្នងទឹក ។ ឯកូនសត្វសេក ឃើញគល់ឈើនោះហើយ ក៏ឡើងទៅពួននៅហើយ ។ ជនទាំង ៤ នាក់នោះ ទៅដោយអាការៈយ៉ាងនោះ បានទៅដល់ក្បែរបណ្ណសាលា នៃតាបសក្នុងវេលាពាក់កណ្ដាលយប់ ។ តាបស បានឮសំឡេងព្រះកន្សែងរបស់ព្រះរាជឱរស ទើបបាននិមន្តទៅកាន់មាត់ស្ទឹង ដោយសេចក្ដីករុណា ក្នុងសត្វទាំង ៤ នោះ ក៏បានស្រង់សត្វទាំង ៤ នោះ ឡើងមក ហើយនាំទៅកាន់អាស្រម បង្កាត់ភ្លើង កំដៅសរីរៈនៃសត្វទាំង ៣ មានពស់ជាដើម ឲ្យស្ងួតមុនគេ ដោយគិតថា "សត្វទាំងនេះ មានកម្លាំងតិចជាង" ហើយទើប កំដៅសរីរៈនៃព្រះរាជឱរស ឲ្យស្ងួតជាខាងក្រោយ សូម្បីកាលឲ្យនូវអាហារ ក៏ឲ្យដល់សត្វទាំង ៣ មានពស់ជាដើមនុ៎ះឯងមុន ហើយទើបបានថ្វាយនូវផលាផលដល់ព្រះរាជឱរសនោះ ជាខាងក្រោយ ។

ព្រះរាជកុមារ ទ្រង់ព្រះតម្រិះថា "តាបសកោងនេះ មិនរាប់អានអញ ធ្វើសេចក្ដីរាប់អាន ដល់សត្វតិរច្ឆានទាំងឡាយ" ដូច្នេះហើយ បានចងអាឃាត ក្នុងតាបសនោះ នៅអាស្រ័យបាន ២-៣ ថ្ងៃហើយ កាលនឹងទៅ បានគិតថា "អញនឹងសម្លាប់ តាបសនេះ

ដែលមក កាន់សំណាក់ របស់ខ្លួន ” ហើយពោលថា “ បពិត្រព្រះគុណម្ចាស់ដ៏ចំរើន កាលបើខ្ញុំម្ចាស់ តាំងនៅ ក្នុងរាជសម្បត្តិហើយ, សូមព្រះគុណម្ចាស់ គប្បីនិមន្តមក, ខ្ញុំព្រះករុណា នឹងទំនុកបំរុងព្រះគុណម្ចាស់ ដោយបច្ច័យ ៤ ” ហើយស្តេចយាងចេញទៅ ។ ឯពស់ កាលនឹងទៅ ថ្វាយបង្គំតាបសនោះហើយ ពោលថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ព្រះគុណម្ចាស់ បានធ្វើឧបការៈដ៏ច្រើន ដល់ខ្ញុំព្រះករុណា, ខ្ញុំព្រះករុណា បានកប់ទ្រព្យ មានប្រមាណប៉ុណ្ណោះទុកក្នុងទីកន្លែងឈ្មោះនុ៎ះ, បើព្រះគុណម្ចាស់មានកិច្ចដោយទ្រព្យ, សូមព្រះគុណម្ចាស់ គប្បីនិមន្តទៅ ក្នុងទីនោះ ហើយហៅថា “ ទីឃៈ” ដូច្នេះហើយ ក៏គេចចេញទៅ ។ ចំណែក សត្វកណ្តុរ ពោលដូច្នោះដែរ ហើយពោលថា “ បើព្រះគុណម្ចាស់ មានកិច្ចដោយទ្រព្យ, សូមព្រះគុណម្ចាស់ គប្បីនិមន្តទៅ ក្នុងទីនោះ ហើយស្រែកហៅថា “ ឧន្ទុរៈ ” ដូច្នេះហើយ ក៏គេចចេញទៅ ។ ចំណែកកូនសត្វសេក ថ្វាយបង្គំតាបសហើយ ពោលថា “ បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ទ្រព្យរបស់ខ្ញុំព្រះករុណា មិនមានទេ, ប៉ុន្តែ បើព្រះគុណម្ចាស់ មានសេចក្តីត្រូវការដោយស្រូវសាលីពណ៌ក្រហម, សូមព្រះគុណម្ចាស់ គប្បីនិមន្តមក កាន់ទីលំនៅ របស់ខ្ញុំព្រះករុណាចុះ ” ដូច្នេះហើយ ក៏គេចចេញទៅ ។ ព្រះរាជឱរស ស្តេចយាងទៅ

ហើយ មិនយូរប៉ុន្មានឡើយ ក៏ស្ដេចទ្រង់ស្ថិតនៅ ក្នុងរាជសម្បត្តិ ។ ព្រះពោធិសត្វ មានព្រះបំណងចង់សាកល្បង នូវសត្វទាំង ៣ មានពស់ជាដើមជាមុន ទើបទៅកាន់ទីលំនៅ របស់សត្វទាំង ៣ នោះ ។ ឯសត្វទាំង ៣ នោះ បានចេញអំពីទីលំនៅ របស់ខ្លួនៗ មកថ្វាយបង្គំព្រះពោធិសត្វនោះ ។ ព្រះពោធិសត្វនោះ ចេញអំពីទីនោះហើយ មានព្រះបំណងនឹងសាកល្បងព្រះរាជា ទើបទៅកាន់ព្រះរាជឧទ្យាន បានសំណាក់នៅក្នុងទីនោះ ក្នុងថ្ងៃព្រឹកឡើង ក៏និមន្តទៅ កាន់ព្រះនគរ ដោយភិក្ខាចារវត្ត ។

ក្នុងខណៈនោះ ព្រះរាជា ទ្រង់គង់នៅលើកដំរីដ៏ប្រសើរ ទ្រង់ធ្វើប្រទក្សិណព្រះនគរ ទ្រង់ទតព្រះនេត្រឃើញ នូវព្រះពោធិសត្វនោះពីចម្ងាយភ្លាម ក៏ទ្រង់ព្រះតម្រិះ ថា "តាបសកោងនេះ មានបំណងនឹងនៅឆាន់ ក្នុងសំណាក់របស់អញហើយ ទើបនិមន្តមក, តាបសកោងនេះ មិនទាន់ប្រកាសគុណដែលខ្លួនបានធ្វើហើយដល់អញ ក្នុងទីកណ្ដាលនៃបរិស័ទ ដរាបណា, អញនឹងឲ្យគេកាត់ក្បាល តាបសកោងនេះ ដរាបនោះ" ដូច្នេះហើយ ទើបទ្រង់ត្រាស់បញ្ជាពួករាជបុរស ។ រាជបុរសទាំងនោះ ទៅចងព្រះពោធិសត្វហើយវាយប្រហារ គ្រប់ៗផ្លូវបែកជា ៤ នាំទៅហើយ កាន់ស្ថានទីកន្លែងសម្លាប់ ។ ក្នុងស្ថានទីដែលគេវាយប្រហារហើយ ៗ ព្រះពោធិសត្វ

នោះ បានពោល នូវគាថានេះ តែប៉ុណ្ណោះឯង ថា ÷

(១៥) " បានឮថា នរៈពួកខ្លះ ក្នុងលោកនេះ បាន[១] និយាយពិត យ៉ាងនេះថា ឧសដែលគេស្រង់ឡើង អំពីទឹក ប្រសើរជាង, នរៈពួកខ្លះដែលគេស្រង់ ឡើង (អំពីទឹក) មិនប្រសើរសោះឡើយ " ។

បណ្ដាបទទាំងនោះ បទ ថា " សច្ចំ កិរេវមាហំសុ " មានសេចក្ដីថា បានឮថា ជនទាំងឡាយ តែងនិយាយគ្នា តាមពិតត្រង់យ៉ាងនេះឯង ។ បាទគាថា ថា " នរា ឯកច្ចិយា ឥធ " មានសេចក្ដីថា បុរសជាបណ្ឌិតពួកខ្លះ ក្នុងលោកនេះ ។ បាទគាថា ថា " កដ្ឋំ បល្លវិតំ សេយ្យោ " មានសេចក្ដីថា ឈើស្ងួតដែលអណ្ដែតនៅលើទឹកទន្លេ ដែលបុគ្គលស្រង់ឡើងហើយ ដាក់ទុកលើគោក ប្រសើរជាង ។ ព្រោះហេតុអ្វី ? ។ ព្រោះថា ឈើស្ងួតនោះ រមែងមានឧបការៈ ដើម្បីប្រយោជន៍ដល់កិរិយាចម្អិន នូវយាគូនិងភត្តជាដើមក៏បាន ដើម្បីប្រយោជន៍ដល់កិរិយាអាំង ដល់បុគ្គលទាំងឡាយ ដែលរសាប់រសល់ដោយរងាក៏បាន និងដើម្បីប្រយោជន៍ដល់កិរិយាបំបាត់ នូវសេចក្ដីអន្តរាយទាំងឡាយ ឯទៀតក៏បាន ។ បាទគាថា ថា " ន ត្វេវេកច្ចិយោ នរោ " មានសេចក្ដី

---

១- ត្រៃបិដក ភាគទី ៥៨ / ទំព័រទី ៣១ ។

ថា ចំណែក នរៈពួកខ្លះ គឺ បុរសអាក្រក់ ជាអ្នកប្រទូសរ៉ាយមិត្រ ជាអ្នកអកតញ្ញូ ត្រូវទឹកកួចយកទៅ ដែលអាត្មាអញចាប់ដៃស្រង់ឡើងហើយ មិនប្រសើរសោះឡើយ ។ ពិតមែន យ៉ាងដូច្នោះ អាត្មាអញ ស្រង់បុរសអាក្រក់នេះឡើងហើយ ទើបបាននាំយកនូវសេចក្ដីទុក្ខមកឲ្យ ដល់ខ្លួន ។

បណ្ដាបុរសទាំងនោះ ពួកជនដែលជាបណ្ឌិតទាំងឡាយ បានស្ដាប់ពាក្យនោះហើយ សួរ ថា " បពិត្រអ្នកបួសដ៏ចំរើន មានគុណអ្វីខ្លះ ដែលលោកបានធ្វើហើយ ដល់ព្រះរាជា របស់ពួកយើងខ្ញុំទាំងឡាយ ? " ។ ព្រះពោធិសត្វនោះ បានប្រាប់រឿងរ៉ាវ ទាំងអស់ហើយ ។ មនុស្សទាំងឡាយ ស្ដាប់ពាក្យនោះហើយ ក្រោធខឹងថា " ព្រះរាជាអង្គនេះ ជាអ្នកប្រទូសរ៉ាយមិត្រ រមែងមិនដឹងសូម្បីនូវហេតុត្រឹមតែគុណ របស់អ្នកដែលឲ្យជីវិត ដល់ខ្លួន, ពួកយើងទាំងឡាយអាស្រ័យព្រះរាជាអង្គនេះ នឹងបានសេចក្ដីសុខ មកអំពីណា ?, អ្នកទាំងឡាយ ចូរចាប់ព្រះរាជាអង្គនេះទុក " ដូច្នេះហើយ ក៏នាំគ្នាស្ទុះក្រោកឡើង ដោយជុំវិញ ញាំងព្រះរាជាអង្គនោះ ដែលទ្រង់គង់នៅលើ កដំរីន៉ុះឯង ឲ្យក្ស័យព្រះជន្ម ដោយស្នា លំពែង ដុំថ្ម និងកំណាត់ឈើជាដើម ហើយចាប់ព្រះបាទទាំងទ្វេ អូសយកទៅចោលក្នុងខ្នងនៃស្នាមភ្លោះ ហើយបានអភិសេកព្រះពោធិសត្វជំនួស ។

ព្រះពោធិសត្វនោះ ទ្រង់គ្រងរាជសម្បត្តិ ដោយធម៌ ស្តេចយាងទៅកាន់ទីលំនៅ នៃសត្វទាំង ៣ មានពស់ជាដើមនោះ ទ្រង់ទទួលនូវប្រាក់ ៧០ កោដិ ដែលពស់និងសត្វកណ្ដុរថ្វាយហើយ និង ទ្រង់នាំយកសត្វទាំង ៣ នោះទៅ ក្រោយមក ទ្រង់ត្រាស់បញ្ជាឲ្យធ្វើនូវរូងមាស ដើម្បីប្រយោជន៍ដល់ការនៅរបស់សត្វពស់, រូងកែវផលិក ដើម្បីប្រយោជន៍ដល់ការនៅ របស់សត្វកណ្ដុរ, ទ្រុងមាស ដើម្បីប្រយោជន៍ដល់ការនៅ របស់សត្វសេក ហើយទ្រង់ត្រាស់ ឲ្យព្រះរាជទាន នូវលាជដែលមានរសឆ្ងាញ់ ដល់ពស់និងសត្វសេក នូវអង្ករស្រូវសាលីដែលមានក្លិនក្រអូប ដល់សត្វកណ្ដុរ ។

រឿងជន ៤ នាក់ មកក្នុងអដ្ឋកថាសច្ចំកិរជាតក ក្នុងអដ្ឋមវគ្គ ឯកនិបាត ។

## ( រឿងជន ៣ នាក់ )

(១៦) ក្នុងអតីតកាល មហាសេដ្ឋី ក្នុងទីក្រុងរាជគ្រឹះ បាននាំធីតា របស់សេដ្ឋីក្នុងជនបទមក ដើម្បីប្រយោជន៍ដល់បុត្រ របស់ខ្លួន ។ ចំណែក ធីតានោះជាស្រ្តីអា កាលសំដែងនូវអាការៈដូចជាស្ត្រីដែលមានគភ៌ ទើបបានជំខ្នងដៃនិងជើង ធ្វើឲ្យហើមប៉ោងឡើង ហើយសំដែង នូវកិរិយាធំឡើងនៃពោះ ដោយការចងរុំកំណាត់សំពត់ រាល់ៗថ្ងៃ ញុំាងស្រីមេនំម្នាក់ ឲ្យដឹងនូវកិច្ចនោះ ដោយ

កន្លងទៅ ៩ ខែ ទើបបានសុំលាឪពុកក្មេកនិងម៉ែក្មេក ថា " ឥឡូវនេះ នាងខ្ញុំ នឹងទៅកាន់ផ្ទះឪពុក ក្នុងជនបទ ហើយសម្រាលកូន " ដូច្នេះហើយ ក៏បានគេចចេញទៅ ។

គ្រានោះ ស្ត្រីកំសត់ម្នាក់ ធ្វើដំណើរទៅ ជាមួយនឹងអ្នករទេះ សម្រាលកូនប្រុស ក្រោមម្លប់ជ្រៃមួយដើម ក្នុងចន្លោះផ្លូវ, កាលបើអ្នកបររទេះទៅ តាំងអំពីព្រលឹមស្រាង, ទើបគិត ថា " អាត្មាអញវៀរចាកអំពីអ្នកបររទេះហើយ នឹងមិនអាចធ្វើដំណើរទៅបានទេ " ដូច្នេះ ក៏បានចោលមន្ទិលនៃគភ៌និង កូន ដើរទៅហើយ ។ ទេវតាទាំងឡាយ ក៏ថែរក្សានូវទារក ។ បានឮថា ទារកនោះ គឺជាព្រះពោធិសត្វនុ៎ះឯង ។ ចំណែក ធីតានៃសេដ្ឋី ទៅដល់ទីនោះហើយ ក៏គិត ថា " អាត្មាអញនឹងធ្វើនូវសរីរកិច្ច " ដូច្នេះ ទើបបានទៅកាន់គល់ជ្រៃ ជាមួយនឹងស្រីមេនំនោះ ឃើញទារក មានសម្បុរដូចជាមាស ទើបពោល ថា " នៃនាង កិច្ចរបស់យើង បានសំរេចហើយ " ហើយផ្លាស់កំណាត់សំពត់ចេញ បានយកឈាម និងមន្ទិល នៃគភ៌មកលាបកន្លែងក្បាលពោះ ហើយប្រាប់នូវភាព នៃខ្លួនជាអ្នកសម្រាលកូន ដល់ជនអ្នកជិតខាង បានពទារក ត្រឡប់ចេញអំពីគល់ជ្រៃនោះឯង ។ មាតាបិតា បានដាក់ឈ្មោះទារកនោះ ថា " និគ្រោធ " ។ ក្នុងថ្ងៃជាមួយគ្នានោះដែរ ឯកូនប្រុសា របស់អនុសេដ្ឋី ធ្វើដំណើរ

ទៅកាន់ផ្ទះនៃត្រកូល ដើម្បីប្រយោជន៍ដល់ការសម្រាលកូន ក៏បានសម្រាលកូន ក្រោមមែកឈើមួយដើម ត្រង់ចន្លោះផ្លូវ ហើយក៏បានត្រឡប់មកវិញ ។ ជនទាំងឡាយ បានដាក់ឈ្មោះឲ្យដល់ទារកនោះថា "សាខៈ" ។ ក្នុងថ្ងៃនោះឯង ឯភរិយារបស់ជាងដេរ ជាអ្នកនៅអាស្រ័យមហាសេដ្ឋី ក៏សម្រាលកូនក្នុងចន្លោះនៃកំណាត់សំពត់ ។ ជនទាំងឡាយ បានដាក់ឈ្មោះ ឲ្យទារកនោះថា "បោត្តិកៈ" ។ មហាសេដ្ឋី បានឲ្យគេនាំទារកទាំង ២ នោះមក ក្នុងថ្ងៃដែលកុមារឈ្មោះនិគ្រោធកើតហើយ ចិញ្ចឹមឲ្យធំធាត់ ព្រមជាមួយនឹងកុមារឈ្មោះនិគ្រោធនោះដូចគ្នាដែរ ។ កុមារទាំង ៣ នាក់នោះ ចំរើនពេញវ័យដូចគ្នាហើយ ក៏បានទៅកាន់ទីក្រុងតក្កសីលា រៀនចេះចប់សិល្បសាស្ត្រហើយ កាលចារិកទៅកាន់ជនបទ បានដល់ទីជិតនៃក្រុងពារាណសី ដោយលំដាប់ ក៏ដេកនៅក្រោមដើមឈើមួយ ។ ក៏លើដើមឈើនោះ មានមាន់ជាច្រើននៅអាស្រ័យ ។ បណ្ដាមាន់ទាំងនោះ មាន់ដែលនៅខាងលើ ជុះអាចម៍ដាក់លើខ្លួននៃមាន់ដែលនៅខាងក្រោម ។ មាន់ដែលនៅខាងក្រោម សួរថា "អ្នកណាជុះអាចម៍នេះទម្លាក់មក ?" ។ មាន់ដែលនៅខាងលើ ពោលថា "នែសំឡាញ់ ចូរអ្នកកុំក្រោធខឹងឡើយ, ខ្ញុំមិនដឹង ទើបជុះអាចម៍ទម្លាក់មក" ។ មាន់ដែលនៅខាងក្រោម ពោលថា "នែវើយ

អ្នកសម្គាល់នូវសរីរៈរបស់ខ្ញុំ ថាជាទីកន្លែងសម្រាប់ជុះអាចម៍ របស់ខ្លួនអ្នកឬ, អ្នកមិនដឹងប្រមាណរបស់ខ្ញុំទេឬ?, ក៏បុគ្គលណាមួយសម្លាប់ខ្ញុំហើយ ស៊ីសាច់, អ្នកនោះនឹងបានទ្រព្យ ១ ពាន់ អំពីព្រឹកព្រលឹមមែនពិត "។ មាន់ដែលនៅខាងលើ ពោលថា " នែវើយអ្នក, សូម្បីកាលបើខ្ញុំពោលថា 'មិនដឹង' ដូច្នេះ, ក៏ក្រោធខឹងធ្វើមានះ ដោយហេតុមានប្រមាណប៉ុណ្ណោះ, ក៏បុគ្គលណា សម្លាប់ខ្ញុំហើយបរិភោគសាច់ដុំ, បុគ្គលនោះពិតជានឹងបានជាព្រះរាជា អំពីព្រឹកព្រលឹម, បុគ្គលណា បរិភោគសាច់ត្រង់កណ្ដាល, បុគ្គលនោះនឹងបានជាសេនាបតី, បុគ្គលណាបរិភោគសាច់ជាប់ឆ្អឹង, បុគ្គលនោះនឹងបានជាអ្នកថែរក្សាឃ្លាំង "។

បោតិកកុមារ ក្រោកឡើង ក្នុងពេលជិតភ្លឺ អង្គុយច្របាច់ជើងរបស់និគ្រោធកុមារ បានឮពាក្យ របស់មាន់ទាំង ២ នោះ ហើយទើបលបៗឡើងទៅ ចាប់យកមាន់ដែលនៅខាងលើ មកសម្លាប់ហើយអាំង ឮដីរងើកភ្លើង បានឲ្យសាច់ដុំ ដល់និគ្រោធ ឲ្យសាច់ត្រង់កណ្ដាល ដល់សាខៈ ឯខ្លួនឯងបរិភោគសាច់ជាប់ឆ្អឹង ស្រេចហើយ ប្រាប់រឿងរ៉ាវទាំងអស់ ។ កុមារទាំង ៣ នាក់នោះ បានចូលទៅកាន់ក្រុងពារាណសី ក្នុងពេលបរិភោគអាហារព្រឹក បរិភោគបាយលាយដោយទឹកដោះ ក្នុងផ្ទះនៃព្រាហ្មណ៍ម្នាក់ហើយ ក៏ចេញ

អំពីនគរ ចូលទៅកាន់ឧទ្យាន ។ និគ្រោធកុមារ ដេកនៅលើផ្ទាំងសីលា ។ កុមារ ២ នាក់ក្រៅពីនេះ ដេកហើយ ខាងក្រៅ ។

ក្នុងកាលនោះ ព្រះរាជាក្រុងពារាណសី ទ្រង់ទិវង្គតហើយបាន ៧ ថ្ងៃ ។ គ្រានោះ ពួកអាមាត្យមានបុរោហិតជាដើម បានលែង (ផ្សង) នូវបុស្សរថទៅហើយ ។

ក្នុងដីកាកស្សបសំយុត្ត លោកពោលថា "រថមង្គល ឈ្មោះថា បុស្សរថ" ។ បុស្សរថ បានទៅដល់ឧទ្យានហើយ ក៏បានតាំងកល់ទើរ ឈប់នៅហើយ ។ បុរោហិត ត្រួតមើលលក្ខណៈ ត្រង់បាទជើងហើយ ទើបឱ្យប្រគំនូវតូរ្យតន្ត្រីគ្រប់បែបយ៉ាង បានអភិសេកនិគ្រោធកុមារ ឱ្យស្ថិតនៅ ក្នុងតំនែរនៃរតនៈ ក្នុងឧទ្យាននោះឯង ។ ព្រះបាទនិគ្រោធកុមារ ទ្រង់ព្រះរាជទាន នូវតំណែងនៃសេនាបតីដល់សាខកុមារ ហើយស្តេចយាងទៅ កាន់ព្រះនគរ ។ ចំណែកបោតិកកុមារ ក៏បានចូលទៅ ជាមួយនឹងព្រះរាជាអង្គនោះដូចគ្នា ។

ថ្ងៃមួយ ព្រះរាជាទ្រង់នឹករលឹកទៅដល់មាតាបិតា ទើបបានបញ្ជូនបោតិកកុមារម្នាក់ឯង ទៅកាន់ព្រះនគររាជគ្រឹះ ដោយព្រះរាជឱង្ការ ថា "ចូរអ្នកទៅ នាំមាតាបិតាទាំង ២ នាក់នោះមក" ។ បោតិកកុមារនោះទៅហើយ, កាលបើមាតាបិតាទាំងនោះ មិនមក, ទើបខ្លួនឯងតែម្នាក់គត់ ត្រឡប់មកវិញ គិតថា "អាត្មាអញ នឹង

បន្ទោបង់សេចក្ដីនឿយហត់ ក្នុងការធ្វើដំណើរ ក្នុងផ្ទះនៃសេនាបតីហើយ ចាំទៅគាល់ព្រះរាជា ជាខាងក្រោយ " ដូច្នេះហើយ ក៏បានទៅក្នុងផ្ទះ នៃសេនាបតីនោះ បានឲ្យគេទៅប្រាប់ ថា " បោតិកៈ ជាសំឡាញ់ របស់អ្នកមករក "ៗ សាខសេនាបតី បានចងពៀរ ក្នុងបោតិកៈនោះ ថា " បោតិកៈនេះ មិនឲ្យភាពជាព្រះរាជា ដល់អញ, បានឲ្យដល់និគ្រោធកុមារ "ៗ ព្រោះហេតុនោះ សាខសេនាបតី គ្រាន់តែឮពាក្យរបស់ទូតប៉ុណ្ណោះ ក៏ក្រោធខឹង ហើយពោល ថា " អ្នកណា ជាសំឡាញ់របស់អ្នកនេះ?, វាជាមនុស្សឆ្កួត ជាកូនស្រីអ្នកបម្រើ, ពួកអ្នកចូរចាប់វាទុក" ដូច្នេះហើយ បានឲ្យអ្នកបម្រើវាយតប់បោតិកៈ ដោយដៃ ជើង ជង្គង់និងកែងដៃ ឲ្យចាប់ក អូសចេញទៅហើយ ៗ ឯបោតិកៈ គិត ថា " សាខៈនេះ ជាមនុស្សអកតញ្ញូ ប្រទូសរ៉ាយមិត្រ, និគ្រោធបណ្ឌិត ជាមនុស្សកតញ្ញូ ជាសប្បុរស, អាត្មាអញ នឹងទៅកាន់ដំណាក់នៃនិគ្រោធបណ្ឌិតនោះតែប៉ុណ្ណោះ" ដូច្នេះ ហើយបានទៅក្រាបទូល នូវភារៈនៃមាតាបិតា មិនបានមកថ្វាយដល់ព្រះរាជា ៗ ចំណែក សាខសេនាបតី គិត ថា " បោតិកៈគប្បីបំបែកអញ ក្នុងដំណាក់ព្រះរាជា, ប៉ុន្តែ បើអញទៅហើយ, វា នឹងមិនអាចក្រាបទូលពាក្យអ្វីបានឡើយ " ទើបទៅ ក្នុងព្រះរាជដំណាក់នោះដូចគ្នាដែរ ៗ បោតិកៈ បានក្រាបទូល នូវកម្មដែល

សាខៈនោះបានធ្វើហើយ ថ្វាយដល់ព្រះរាជាភ្លាម ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ទ្រង់ព្រះពិរោធ ទ្រង់ត្រាស់បញ្ជាឲ្យសម្លាប់សាខៈនោះចោល ។ បោតិកៈក្រាបទូលហាម ថា "បពិត្រព្រះមហារាជ សូមព្រះអង្គ ទ្រង់អត់ទោសឲ្យ ដល់អសប្បុរសផងចុះ" ។ ព្រះរាជា ទ្រង់អត់ទោសឲ្យដល់សាខៈហើយ ទ្រង់មានព្រះបំណងនឹងព្រះរាជទាន នូវតំណែងសេនាបតី ដល់បោតិកៈវិញ, កាលបើបោតិកៈនោះមិនប្រាថ្នា, ទើបទ្រង់បានព្រះរាជទានតំណែងភណ្ឌាគារិកដែលគួរដល់ការពិចារណាពួកសេនាទាំងអស់ ។ បានឮថា តំណែងនោះ មិនធ្លាប់មានឡើយ ក្នុងកាលមុន, ទើបតែកើតមានឡើងចាប់ដើមអំពីថ្ងៃនោះមក ។ ក្នុងកាលក្រោយមក បោតិកភណ្ឌាគារិកចំរើនដោយបុត្រនិងធីតា កាលនឹងទូន្មាននូវបុត្រធីតា ទើបពោលគាថានេះ ក្នុងនិគ្រោធជាតក(១) ក្នុងទសកនិបាត ថា ÷

(១៧) " បុគ្គលគប្បីសេពគប់ នូវនិគ្រោធបណ្ឌិតតែម្យ៉ាង, កុំគប្បីសេពគប់ នូវសាខសេនាបតីឡើយ, ការស្លាប់ ក្នុងសំណាក់ នៃនិគ្រោធ ជាការប្រសើរ, ការរស់នៅ ក្នុងសំណាក់សាខៈ ពុំប្រសើរឡើយ " ។

រឿងជន ៣ នាក់ ចប់ ។

---

១- ត្រៃបិដក ភាគទី ៥៨ / ទំព័រទី ៦ ។

(១៨) បុគ្គលអកតញ្ញូ រមែងដល់នូវអនិដ្ឋផល មានការនិន្ទាជាដើម ដោយប្រការដូច្នេះ ។ ចំណែក កតញ្ញូបុគ្គល សូម្បីព្រះសាស្តា ក៏ទ្រង់ត្រាស់សរសើរហើយ ។ ក្នុងសេចក្តីនោះ មានរឿងនេះ ( ជាឧទាហរណ៍ ) ។

## ( រឿងរាធព្រាហ្មណ៍ )

បានឮថា ក្នុងទីក្រុងរាជគ្រឹះ ព្រាហ្មណ៍ចាស់ជរា ឈ្មោះថារាធៈ ត្រូវកូនប្រពន្ធ មិនរាប់អាន ទើបទៅកាន់វត្តវេឡុវ័ន សូមនូវការបព្វជ្ជា ។ ភិក្ខុពួកខ្លះ មិនប្រាថ្នាចង់ឲ្យរាធព្រាហ្មណ៍នោះបួស ព្រោះអាងថា " ព្រាហ្មណ៍នេះចាស់ហើយ " ។ ព្រះសាស្តាទ្រង់ជ្រាបហេតុនោះហើយ ទើបត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ ភិក្ខុអង្គណា នឹករលឹកនូវឧបការៈ របស់ព្រាហ្មណ៍នោះបានខ្លះ? " ។

ក្នុងព្រះតម្រាស់នោះ បទថា " អធិការំ " បានដល់ ការធ្វើឲ្យក្រៃលែង, មានពាក្យអធិប្បាយ ថា " បានដល់ សក្ការៈ " ។

គ្រានោះ ព្រះមហាសារីបុត្រដ៏មានអាយុ បានក្រាបទូល ថា " បពិត្រព្រះអង្គដ៏ចំរើន ព្រាហ្មណ៍នោះ បានប្រើឲ្យគេប្រគេននូវអាហារប្រមាណមួយវែក ដល់ខ្ញុំព្រះករុណា ដែលកំពុងនិមន្តទៅបិណ្ឌបាត ក្នុងទីក្រុងរាជគ្រឹះនេះ, បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះ

ករុណា នឹករលឹកឃើញនូវឧបការៈនេះឯង របស់រាធព្រាហ្មណ៍នោះបាន"។ ព្រះសាស្តាទ្រង់ត្រាស់ថា "ម្នាលសារីបុត្រ ល្អណាស់ៗ, ម្នាលសារីបុត្រ ក៏សប្បុរសទាំងឡាយ ជាអ្នកមានកតញ្ញូ ជាអ្នកមានកតវេទី, ម្នាលសារីបុត្រ បើដូច្នោះ ចូរអ្នកឲ្យព្រាហ្មណ៍នោះបួស ចូរឲ្យឧបសម្បទចុះ"។ ព្រះថេរៈ ឲ្យព្រាហ្មណ៍នោះបួសហើយ នាំទៅកាន់អាវាសក្បែរស្រុកៗ ព្រះថេរៈឲ្យទាំងអាវាសទាំងបិណ្ឌបាតដ៏ប្រណិត ដែលខ្លួនបានហើយ ដល់ព្រះរាធត្ថេរនោះឯង ដែលជាអ្នកមានលាភ រកបានដោយកម្រ ព្រោះជាអ្នកបួសហើយមិនយូរ ក្នុងអាវាសនោះ ឯខ្លួនឯង ក៏និមន្តទៅបិណ្ឌបាតៗ ព្រះរាធត្ថេរ បាននូវសេនាសនៈនិងភោជន ដែលជាទីសប្បាយហើយ រៀនកម្មដ្ឋាន ក្នុងសំណាក់ នៃព្រះថេរៈនុ៎ះឯង មិនយូរប៉ុន្មាន ក៏បានសម្រេចនូវព្រះអរហត្តៗ

រឿងរាធព្រាហ្មណ៍ មកក្នុងអដ្ឋកថាឯកទុត្តវគ្គ ក្នុងឯកនិបាត

អង្គុត្តរនិកាយ និងក្នុងមហាខន្ធកៈ ។

(១៩) គ្រានោះ បានកើតមានការសន្ទនាគ្នា ក្នុងទីកណ្តាលជំនុំព្រះសង្ឃ ថា "ព្រះសារីបុត្តត្ថេរ ជាអ្នកមានកតញ្ញូ កតវេទី"។ ព្រះសាស្តា ទ្រង់ព្រះសណ្តាប់នូវការសន្ទនានោះហើយ ទើបទ្រង់បានត្រាស់ថា "សូម្បីក្នុងកាលមុន ព្រះសារីបុត្រនេះ កើតជាដំរី ក៏ជា

អ្នកមានកតញ្ញូ កតវេទីដូចគ្នាដែរ" ដូច្នេះ ទ្រង់ត្រាស់អលីនចិត្តជាតក ក្នុងបឋមវគ្គ នៃទុកនិបាត ។ ព្រោះហេតុនោះ ភិក្ខុគប្បីជាអ្នកមាន កតញ្ញូ ដូចជាព្រះធម្មសេនាបតី និង ព្រះអានន្ទត្ថេរ យ៉ាងដូច្នោះ ។

## ( រឿងព្រះអានន្ទត្ថេរ )

បានឮថា ព្រះថេរៈ មានសទ្ធិវិហារិក ប្រមាណ ៥០០ រូប ។ បណ្ដាសទ្ធិវិហារិកទាំងនោះ ភិក្ខុឈ្មោះមួយរូប ជាអ្នកមានឧបការៈ ជាច្រើន ដល់ព្រះថេរៈ តែងបោសសំអាតបរិវេណ តាំងទឹកសម្រាប់ ឆាន់ និង ទឹកសម្រាប់ប្រើប្រាស់ ប្រគេនឈើស្ទន់ ទឹកលាងមុខ និង ទឹកសម្រាប់ស្រង់ ជម្រះបង្គន់ រោងភ្លើង និងទីសេនាសនៈ រមែង ធ្វើកិច្ចការ មានការច្របាច់ដៃ ច្របាច់ព្រះបាទ និងគក់ខ្នងជាដើម ។ ឯព្រះថេរៈ បានប្រគេនសំពត់សាដកទាំងអស់ ៥០០ កំណាត់ ដែល ព្រះបាទកោលស ទ្រង់មានព្រះទ័យជ្រះថ្លា ក្នុងធម្មកថា របស់ខ្លួន ព្រះរាជទានហើយ ដល់ភិក្ខុឈ្មោះនោះតែមួយរូប ដោយអំណាច ពេញចិត្ត ថា " ភិក្ខុរូបនេះប៉ុណ្ណោះ ជាអ្នកមានឧបការៈច្រើន " ។ ភិក្ខុឈ្មោះនោះ បានចែកសំពត់សាដក ទាំងអស់នោះ ប្រគេនដល់ ភិក្ខុទាំងឡាយដែលរួមព្រះឧបជ្ឈាយ៍ របស់ខ្លួន ។ ពួកភិក្ខុទាំង នោះ ធ្វើជាចីវរ ស្លៀកនិងគ្រងហើយ ក៏និមន្តទៅកាន់សំណាក់ព្រះ

សាស្តា ក្រាបថ្វាយបង្គំហើយ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន ធម្មតាការឲ្យ ដោយរើសមុខ នៅមាន ដល់ព្រះសោតាបន្នឬ ?"។ ព្រះសាស្តា ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមានទេ"។ ភិក្ខុទាំងនោះ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន ព្រះអានន្ទត្ថេរ ព្រះឧបជ្ឈាយ៍ របស់ខ្ញុំព្រះករុណាទាំងឡាយ បានប្រគេននូវសំពត់ ៥០០ កំណាត់ ដល់ភិក្ខុកម្លោះតែមួយរូបប៉ុណ្ណោះ, ឯភិក្ខុកម្លោះ នោះ ក៏បានប្រគេន នូវសំពត់សាដក ដែលខ្លួនបានហើយ ដល់ខ្ញុំព្រះ ករុណាទាំងឡាយ"។ ព្រះសាស្តា ទ្រង់ត្រាស់ថា "ម្នាលភិក្ខុ ទាំងឡាយ ព្រះអានន្ទ មិនមែនឲ្យដោយការរើសមុខទេ, តែ ភិក្ខុ រូបនោះ ជាអ្នកមានឧបការៈច្រើន ដល់ព្រះអានន្ទនោះ; ហេតុនោះ ព្រះអានន្ទ ទើបបានឲ្យហើយ ដល់ភិក្ខុដែលមានឧបការៈ ដល់ខ្លួន ដោយអំណាចឧបការៈ ដោយអំណាចនៃគុណ និង ដោយអំណាច នៃសេចក្តីពេញចិត្ត ដោយគិតថា 'ធម្មតាការធ្វើឧបការៈតប ដល់ បុគ្គលអ្នកធ្វើឧបការៈ ទើបសមគួរ' ដូច្នេះ ព្រោះភាពនៃខ្លួនជា អ្នកមានកតញ្ញូកតវេទី, សូម្បីបោរាណកបណ្ឌិតទាំងឡាយ ក៏បាន ធ្វើឧបការៈតប ដល់បុគ្គលដែលបានធ្វើឧបការៈដល់ខ្លួនដូចគ្នាដែរ" ដូច្នេះហើយ ទ្រង់ត្រាស់នូវគុណជាតក ក្នុងបឋមវគ្គ នៃទុកនិបាត ។ សូម្បីពាក្យថា "សិគាលជាតក" នេះ ក៏ជាឈ្មោះ នៃគុណជាតកនេះ

ដូចគ្នាដែរ ។ ព្រះសាស្តា លុះទ្រង់ត្រាស់ យ៉ាងដូច្នេះឯងហើយ ទើបទ្រង់ត្រាស់តិរិតិវច្ឆជាតក ក្នុងបឋមវគ្គ នៃតិកនិបាត ម្តងទៀត ។ រឿងអតីតកាល ក្នុងជាតកទាំង ២ គប្បីត្រួតមើល ក្នុងជាតក ។

រឿងព្រះអានន្ទត្ថេរ ចប់ ។

(២០) មួយទៀត សម្បរាយភព នៃកតញ្ញូបុគ្គល ជាសុគតិ, នៃអកតញ្ញូបុគ្គល ជាទុគ្គតិ យ៉ាងនេះឯង ។ សេចក្តីនេះ គប្បីសំដែង ដោយអកតញ្ញុតាសូត្រ ទី ៣ នៃទុតិយវគ្គ ក្នុងបញ្ចមបណ្ណាសកៈ នៃចតុក្កនិបាត អង្គុត្តរនិកាយ ។ មែនពិត បុគ្គលអកតញ្ញូ ជាអ្នកមានទុគ្គតិជាទីទៅខាងមុខ ដោយពិតប្រាកដ ។ ក្នុងសេចក្តីនោះ មានរឿងនេះ ( ជាឧទាហរណ៍ ) ។

( រឿងព្រានព្រៃ )

ក្នុងអតីតកាល អ្នកថ្មើរព្រៃនៅក្រុងពារាណសីម្នាក់ កាលស្វែងរកគ្រឿងចិញ្ចឹមជីវិត របស់ខ្លួន ក្នុងហិមវន្តប្រទេស បានវង្វេងផ្លូវហើយ ដើរស្រែកទួញយំ ។

ក្នុងកាលនោះ ព្រះពោធិសត្វ កើតជាស្តេចដំរីស ឈ្មោះថាសីលវនាគ ព្រោះជាសត្វដែលមានសីល បានឮសំឡេងស្រែកយំរបស់អ្នកថ្មើរព្រៃនោះហើយ ត្រូវសេចក្តីករុណា ដាស់តឿនហើយ

ទើបបានឲ្យអ្នកថ្មើរព្រៃនោះជិះលើខ្នង នាំចេញអំពីព្រៃ យកទៅដាក់ដល់លំនៅនៃមនុស្ស ហើយពោលថា "ម្នាលបុរសដ៏ចំរើន ចូរអ្នកអញ្ជើញទៅ តាមផ្លូវនេះចុះ, ប៉ុន្តែ អ្នកទោះបីជា ត្រូវគេសួរ នូវទីលំនៅ របស់ខ្ញុំក៏ដោយ សូមកុំប្រាប់ ដល់នរណាម្នាក់ឡើយ" ។

ក៏ព្រានព្រៃនោះ ជាអ្នកទ្រុស្តមិត្រ ជាអ្នកអកតញ្ញូ ក្នុងពេលដែលអង្គុយ លើខ្នងព្រះពោធិសត្វនុ៎ះឯង បានកំណត់គ្រឿងសម្គាល់ គឺដើមឈើនិងភ្នំទុក ទៅដល់ក្រុងពារាណសីហើយ បានឃើញពួកជាងធ្វើភ្លុក ទើបពោលថា "ម្នាលអ្នកដ៏ចំរើន ពួកអ្នកបាន សូម្បីនូវភ្លុកដំរីរស់ហើយ តើទទួលយកទេ ?" ដូច្នេះ បានឮថា "ធម្មតាភ្លុកដំរីរស់ មានតម្លៃច្រើនជាង ភ្លុកដំរីស្លាប់" ទើបកាន់យកនូវស្បៀង និងដែករណាររដីមុត ដើរចូលទៅរកព្រះពោធិសត្វ ហើយសុំនូវភ្លុក ។ ព្រះពោធិសត្វ ឲ្យព្រានព្រៃនោះ កាត់ចុងភ្លុកទាំង ២ ហើយយកប្រមោយចាប់ភ្លុកទាំង ២ នោះទុក បានធ្វើការប្រណិធានថា "អាត្មាអញ នឹងឲ្យ ដោយគិតថា 'ភ្លុកទាំងគូនេះ មិនមែនជាទីស្រឡាញ់របស់អាត្មាអញ' ដូច្នេះ ក៏ពុំមែនសោះឡើយ, ក៏ប៉ុន្តែ ព្រះសព្វញ្ញុតញ្ញាណ របស់អាត្មាអញ ជាទីស្រឡាញ់ក្រៃលែងជាងភ្លុកទាំងទ្វេនេះ ដោយចំនួន ១ រយ ១ ពាន់ ១ សែនដង, ការឲ្យភ្លុក របស់អាត្មាអញនោះ ចូរប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់

កិរិយាចាក់ធ្លុះនូវព្រះសព្វញ្ញុតញ្ញាណចុះ" ដូច្នេះហើយ ទើបបានឲ្យ (ភ្លុក) ហើយ ។ ព្រានព្រៃនោះ បានយកភ្លុកនោះ ត្រឡប់ទៅបានលក់អស់ហើយ, កាលបើតម្លៃនោះ អស់ហើយ, ទើបបានទៅសុំភ្លុកដែលនៅសល់ ម្ដងទៀត ។ ឯស្ដេចដំរី ក៏បានឲ្យហើយដល់ព្រានព្រៃនោះ ។ កាលបើតម្លៃនោះឯង អស់ហើយ, ព្រានព្រៃនោះ ក៏បានទៅសុំ ម្ដងទៀត ។ ឯស្ដេចដំរី ពោលថា " ប្រពៃហើយ " បានក្រាប ដូចជាគោក្រាប ។ ចំណែក ព្រានព្រៃ ជាអ្នកអកតញ្ញូនោះ ឡើងកាន់ពោងដំរីហើយ យកក្ដោលជើងជាន់ធាក់ចុងភ្លុកទាំង ២ ពន្លះសាច់ចេញហើយ បានយកដែករណារ មកអារនូវគល់ភ្លុកស្រេចហើយ ក៏ចៀសចេញទៅ ។ កាលបើព្រានព្រៃនោះ គ្រាន់តែលះផុត នូវឧបចារៈនៃការឃើញ របស់ស្ដេចដំរីប៉ុណ្ណោះ, មហាប្រឹថពី សូម្បីអាចទ្រទ្រង់ នូវភ្នំព្រះសុមេរុនិងភ្នំយុគន្ធជាដើម ដែលមានទម្ងន់ដ៏ធ្ងន់បានក៏ដោយ ក៏ដូចជាមិនអាចនឹងទ្រ នូវគំនរនៃការមិនមានគុណ របស់ព្រានព្រៃនោះ បានឡើយទើបញែកប្រឡោះឲ្យ (ស្រូប) ហើយ ។ ក្នុងខណៈនោះឯង អណ្ដាតភ្លើងក្នុងអវីចីនរក បានឆេះចេញមក ចាប់រួបយកព្រានព្រៃ អកតញ្ញូទ្រុស្តមិត្រនោះទៅហើយ ។

គ្រានោះ រុក្ខទេវតាដែលស្ថិតនៅ ក្នុងដងព្រៃនោះ បានពោល

គាថានេះ ក្នុងសីលវជាតក (១) ក្នុងអដ្ឋមវគ្គ នៃឯកនិបាត ថា ÷

(២១) " ប្រសិនបើគេឲ្យផែនដីទាំងមូល ដល់បុរស
អកតញ្ញូ ជាអ្នកឃើញទោសជានិច្ច ក៏មិនគប្បីញុំាង
បុរសអកតញ្ញូនោះ ឲ្យត្រេកអរបានឡើយ " ។

បណ្ដាបទទាំងនោះ បទ ថា " **អកតញ្ញុស្ស** " បានដល់ អ្នកមិនដឹងនូវគុណដែលគេធ្វើហើយ ដល់ខ្លួន ។ បទថា " **បោសស្ស** " ប្រែថា បុរស ។ បទថា " **វិវរទស្សិនោ** " មានសេចក្ដីថា សំឡឹងចាំមើលប្រហោង គឺ ឱកាសនុ៎ះឯង ។ បាទគាថាថា " **សព្វញ្ចេ បឋវី ទជ្ជា** " មានសេចក្ដីថា សូម្បីប្រសិនបើ គេគប្បីឲ្យចក្រពត្តិរាជទាំងមូល ឬក៏ គប្បីត្រឡប់មហាប្រឹថពីនេះឡើង ហើយឲ្យនូវឱជារសនៃផែនដី ដល់បុគ្គលប្រាកដដូច្នោះ ។ បាទគាថា ថា " **នេវ នំ អភិរាធយេ** " មានសេចក្ដីថា នរណា សូម្បីធ្វើយ៉ាងដូច្នេះ ក៏នឹងមិនអាច ដើម្បីនឹងញុំាងបុគ្គលដែលកំចាត់គុណ ដែលគេធ្វើហើយ រូបនេះ ឲ្យត្រេកអរ គឺ ឲ្យជ្រះថ្លាបានឡើយ ។

ទេវតានោះបន្លឺនូវពាក្យនោះ យ៉ាងនេះហើយ ទើបសំដែងធម៌ៗ ស្ដេចដំរី ស្ថិតនៅរហូតមួយជីវិតហើយ ក៏បានទៅតាមយថាកម្ម ។

រឿងព្រានព្រៃ ចប់ ។

---

១- ត្រៃបិដក ភាគទី ៥៨ / ទំព័រទី ៣១ ។

បុគ្គលអកតញ្ញូ រមែងមានសម្បរាយភព ជាទុគ្គតិ ដោយប្រការដូច្នេះឯង ។ ចំណែក កតញ្ញូបុគ្គល ចូលដល់សុគតិភពរាប់មិនអស់ឡើយ ។ នឹងមានប្រយោជន៍អ្វី ដោយរឿង (ដែលជាឧទាហរណ៍) ដូច្នេះឯង ។

ពណ៌នានំពីបទ ថា ភាពជាអ្នកមានកតញ្ញូ ចប់ ។

ប្រែចប់ ថ្ងៃព្រហស្បតិ៍ ១៤ រោច ខែបុស្ស ព.ស. ២៥៣៦

ត្រូវនឹង ថ្ងៃ ទី ២១ ខែមករា ១៩៩៣

> *សាមគ្គីជាកម្លាំង សាមគ្គីនាំឱ្យបានសេចក្តីសុខ*
> *ប្រទេសជាតិខ្វះការសាមគ្គីមិនបានសុខឡើយ ។*

# ពណ៌នាអំពីការស្ដាប់ធម៌

~~~

(២២) អដ្ឋកថាថា “ ក្នុងកាលណា ចិត្តជាធម្មជាតដែលប្រកបព្រមដោយឧទ្ធច្ចៈ ឬ ត្រូវអកុសលវិតក្ក មានកាមវិតក្ក ជាដើមណាមួយ គ្របសង្កត់ហើយ, ក្នុងកាលនោះ ការស្ដាប់ធម៌ ដើម្បីបន្ទោបង់ នូវអកុសលវិតក្កទាំងនោះ ឈ្មោះថា **ការស្ដាប់ធម៌តាមកាល** ” ។

( **វិតក្ក ៣ យ៉ាង** )

អដ្ឋកថាតិកៈ ក្នុងសង្គីតិសូត្រថា “ ការត្រិះរិះ ដែលប្រកបព្រមដោយកាម ឈ្មោះថា **កាមវិតក្ក** ។ ការត្រិះរិះ ដែលប្រកបព្រមដោយព្យាបាទ ឈ្មោះថា **ព្យាបាទវិតក្ក** ។ ការត្រិះរិះដែលប្រកបព្រមដោយការបៀតបៀន ឈ្មោះថា **វិហឹសាវិតក្ក** ។ បណ្ដាវិតក្កទាំង ៣ យ៉ាងនោះ វិតក្ក ២ យ៉ាង រមែងកើតឡើងទាំងក្នុងពួកសត្វ ទាំងក្នុងពួកសង្ខារ ។ មែនពិត កាមវិតក្ក តែងកើតឡើង ដល់បុគ្គលដែលត្រិះរិះ ទៅដល់សត្វ ឬ សង្ខារ ដែលជាទីស្រឡាញ់ ពេញចិត្ត ។ ព្យាបាទវិតក្ក រមែងកើតឡើង ចាប់ដើមតាំងអំពីក្រោធខឹងហើយ សំឡឹងមើល រហូតដល់ញ៉ាំងសត្វ ឬ សង្ខារដែលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត ឲ្យវិនាសសាបសូន្យទៅ ។
~~~

វិហឹសាវិតក្ក មិនកើតឡើង ក្នុងសង្ខារឡើយ ។ ព្រោះថា សង្ខារឈ្មោះថា ត្រូវបុគ្គលណា គប្បីឲ្យដល់នូវសេចក្តីទុក្ខ តែងមិនមាន ។ ប៉ុន្តែ វិហឹសាវិតក្ក រមែងកើតឡើង ក្នុងសត្វទាំងឡាយ ក្នុងពេលដែលគិត ថា 'ចូរឲ្យសត្វទាំងនេះ ត្រូវគេសម្លាប់ ឬ ចូរខាតសូន្យចូរវិនាសទៅ ឬ ចូរកុំឲ្យមានឡើយ' ដូច្នេះ " ។

ដីកាតិកៈ ក្នុងសង្គីតិសូត្រនោះ ថា " ក្នុងពាក្យនេះ ថា '**កាមប្បដិសំយុត្តោ**' កាម មាន ២ យ៉ាង គឺ វត្ថុកាម ១ កិលេសកាម ១ ។ បណ្តាកាមទាំង ២ យ៉ាងនោះ គប្បីប្រកបសេចក្តីថា 'សេចក្តីត្រិះរិះ ដែលប្រកបព្រម ដោយកាមទាំងឡាយ ដោយអំណាចកិរិយាធ្វើឲ្យជាអារម្មណ៍ ក្នុងផ្នែកនៃវត្ថុកាម (ចាត់ជាវត្ថុកាមវិតក្ក), ប៉ុន្តែ ក្នុងផ្នែកនៃកិលេសកាម សេចក្តីត្រិះរិះដែលប្រកបដោយកាម ដោយអំណាចការមកជួបប្រទះ (ចាត់ជាកិលេសកាមវិតក្ក)' ។ ក្នុងបទថា '**ព្យាបាទប្បដិសំយុត្តោ**' ជាដើម គប្បីជ្រាបសេចក្តី ដោយអំណាចការមកជួបប្រទះ ។ បើប្រកាន់យកសេចក្តី ថា 'ការត្រិះរិះ សូម្បីប្រកបដោយហេតុនៃការព្យាបាទ ក៏ឈ្មោះថាប្រកបព្រមដោយព្យាបាទ' ដូច្នេះ, រមែងមិនបានយោជនា សូម្បីដោយប្រការទាំង ២ យ៉ាង តែម្តង ។ ន័យសូម្បីក្នុងពាក្យ ថា 'ប្រកបដោយវិហឹសាវិតក្ក' នេះ ក៏ន័យនេះ

ដូចគ្នាដែរ ។ ចេតនា ឈ្មោះថា **វិហឹសា** ព្រោះជាគ្រឿងបៀតបៀនសត្វទាំងឡាយ ម្យ៉ាងទៀត ជាកិរិយាបៀតបៀនសត្វទាំងឡាយ, គប្បីជ្រាបសេចក្តីនៃស័ព្ទ យ៉ាងនេះ ថា 'សេចក្តីត្រិះរិះដែលប្រកបព្រម ដោយវិហឹសានោះ ឈ្មោះថា **វិហឹសាបដិសំយុត្ត**' ។ កិរិយាប្រារព្ធនូវសង្ខារទាំងឡាយ ដែលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត ហើយកើតព្យាបាទវិតក្ក គប្បីសំដែង ដោយអំណាចការប៉ះទង្គិចនូវវត្ថុដែលមិនមែនជាឋានៈ ។ ដើម្បីសំដែងនូវខេត្តដែននៃព្យាបាទវិតក្ក ព្រះអដ្ឋកថាចារ្យ ពោលថា '**យាវ វិនាសនា**' ។ ក៏បាណាតិបាតប៉ុណ្ណោះ រមែងមាន ព្រោះកិរិយាធ្វើសត្វឲ្យវិនាសដូច្នេះឯង ។ សួរថា 'ព្រោះហេតុអ្វី ? ព្រះអដ្ឋកថាចារ្យ ទើបពោលថា 'សង្ខារ ឈ្មោះថា គឺបុគ្គលគប្បីឲ្យដល់សេចក្តីទុក្ខ តែងមិនមាន' សង្ខារទាំងឡាយណា ដែលដឹងបានហើយថា សត្វ ដែលលោកប្រាថ្នាហើយ ថា 'ជាសង្ខារដែលបុគ្គលគប្បីឲ្យដល់សេចក្តីទុក្ខបាន' ដូច្នេះ, សូម្បីសង្ខារទាំងឡាយនោះ ដោយសេចក្តី ក៏គឺសង្ខារនុ៎ះឯង មិនមែនទេឬ ?' ។ ឆ្លើយថា 'ពាក្យនុ៎ះពិតមែន' ។ ប៉ុន្តែសង្ខារទាំងឡាយណា ជាប់ទាក់ទងនឹងឥន្ទ្រីយ៍ រមែងសោយនូវទុក្ខព្រោះជាសភាពដែលមានវិញ្ញាណ, ព្រោះហេតុនោះ សង្ខារទាំងឡាយនោះ រមែងជាអារម្មណ៍ នៃវិហឹសាវិតក្ក ដែលលោកប្រាថ្នា

ហើយ រមែងដឹងបានថា ជាសត្វ ៗ តែសង្ខារទាំងឡាយណា មិនសោយនូវសេចក្ដីទុក្ខ ព្រោះមិនប្រកបដោយលក្ខណៈ ដូចបានពោលមកហើយ, ព្រះអដ្ឋកថាចារ្យ សំដៅយកសង្ខារទាំងឡាយនោះទើបពោលថា 'វិហឹសាវិតក្ក រមែងមិនកើតឡើង ក្នុងសង្ខារទាំងឡាយ' ៗ មួយទៀត វិហឹសាវិតក្ក រមែងកើតឡើង ក្នុងទីណា និងរមែងកើតឡើង ដោយប្រការណា, ដើម្បីនឹងសំដែងនូវទីនោះ និងប្រការនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា 'ឥមេ សត្តា' ដូច្នេះ ជាដើម " ៗ

(២៣) អដ្ឋកថាថា " អាចារ្យដទៃទៀត ពោលថា 'ការស្ដាប់ធម៌ ក្នុងថ្ងៃទី ៥ ៗ ឈ្មោះថា ការស្ដាប់ធម៌ តាមកាល ៗ សមដូចជាព្រះធម្មសង្គាហកាចារ្យពោលថា 'ព្រះអនុរុទ្ធត្ថេរ ដ៏មានអាយុ ក្រាបទូលថា 'បពិត្រព្រះអង្គដ៏ចំរើន ក៏ខ្ញុំព្រះករុណាទាំងឡាយ រមែងប្រជុំគ្នា ដោយវាចាជាគ្រឿងពោល ដែលប្រកបដោយធម៌ រហូតទាំងរាត្រី ដែលមានក្នុងថ្ងៃទី ៥ នេះឯង " ៗ

បណ្ដាបទទាំងនោះ បទថា " បញ្ចាហិកំ " ជាដើម ព្រះថេរៈនោះ ពោលហើយ ក្នុងសំណាក់នៃព្រះសាស្ដា ក្នុងចូឡគោសិង្គសូត្រ ក្នុងចតុត្ថវគ្គ នៃមូលបណ្ណាសកៈ ៗ

អដ្ឋកថាចូឡគោសិង្គសូត្រថា " បទថា ' បញ្ចាហិកំ

ខោ បន ’ មានសេចក្ដីថា ការស្ដាប់ធម៌នេះ ក្នុងថ្ងៃទាំង ៣ គឺ ក្នុងថ្ងៃ ទី ១៤ ក្នុងថ្ងៃ ទី ១៥ ក្នុងថ្ងៃ ទី ៨ ឈ្មោះថា ការស្ដាប់ធម៌ តាមប្រក្រតីមែនពិត ៗ ព្រះថេរៈទាំង ៣ រូប ធ្វើនូវការស្ដាប់ធម៌ដោយប្រក្រតីនោះ មិនដែលខាត, ក្នុងថ្ងៃ ទី ៥ ៗ ព្រះថេរៈទាំង ២ រូប ស្រង់ទឹក ក្នុងវេលាមិនទាន់ព្រលប់ ហើយនិមន្តទៅ កាន់ទីលំនៅ របស់ព្រះអនុរុទ្ធត្ថេរ, ព្រះថេរៈទាំង ៣ រូប អង្គុយក្នុងទីនោះហើយ សួរបញ្ហានឹងគ្នាទៅវិញទៅមក បណ្ដាបិដកទាំង ៣ បិដកណាមួយ ដោះស្រាយបញ្ហាដល់គ្នានឹងគ្នា, កាលបើព្រះថេរៈទាំង ៣ រូបនោះសន្ទនាគ្នា យ៉ាងនោះឯង, ព្រះអរុណ ក៏រះឡើង ៗ ព្រះអនុរុទ្ធត្ថេរ សំដៅយកការស្ដាប់ធម៌ តាមប្រក្រតីនោះ ទើបបានពោលពាក្យនេះ ថា ‘ បញ្ចាហិកំ ខោ បន ’ ដូច្នេះ ជាដើម ” ។

ដីកាចូឡគោសិង្គសូត្រនោះថា “ ២ បទថា ‘ តំ អខណ្ឌំ ’ មានសេចក្ដីថា ធ្វើនូវការស្ដាប់ធម៌ ក្នុងថ្ងៃទាំង ៣ នោះ មិនដែលឲ្យខាត ដោយអំណាចការប្រព្រឹត្ត ៗ បទថា ‘ ឯតំ ’ ជាពាក្យបញ្ជាក់ដល់ពាក្យថា ‘ បញ្ចាហិកំ ខោ បន ’ ដូច្នេះ ជាដើម ៗ ការស្ដាប់ធម៌ មាន ក្នុងថ្ងៃ ទី ៥ ៗ ហេតុនោះ ទើបឈ្មោះថា បញ្ចាហិកំ មានក្នុងថ្ងៃ ទី ៥ ” ។

(២៤) មួយទៀត បុគ្គលចូលទៅរកកល្យាណមិត្រទាំង

ឡាយ ហើយអាចដើម្បីនឹងស្តាប់ធម៌ ដែលបន្ទោបង់ការសង្ស័យរបស់ខ្លួនចេញបាន ក្នុងកាលណា, ការស្តាប់ធម៌ សូម្បីក្នុងកាលនោះ គប្បីជ្រាប ថា " ការស្តាប់ធម៌តាមកាល " ។ ដោយហេតុនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សំដែងធម៌ ដល់ភិក្ខុទាំងឡាយទើបទ្រង់ត្រាស់ ក្នុងបាបណិកសូត្រ ក្នុងទុតិយវគ្គ បឋមណណ្ណាសកៈក្នុងតិកនិបាត អង្គុត្តរនិកាយ ថា " ភិក្ខុចូលទៅរកភិក្ខុជាពហុស្សូតទាំងឡាយនោះ មួយដងមួយកាល រមែងដណ្តឹង រមែងសាកសួរ ថា 'បពិត្រលោកម្ចាស់ដ៏ចំរើន ព្រះពុទ្ធវចនៈនេះ តើយ៉ាងដូចម្តេច ?, សេចក្តីនៃព្រះពុទ្ធវចនៈនេះ តើយ៉ាងដូចម្តេច ? " ។ ភិក្ខុពហុស្សូតទាំងនោះ រមែងបើកបង្ហាញ នូវធម៌ដែលតថាគតមិនទាន់បានបើកបង្ហាញ រមែងធ្វើឲ្យរាក់ នូវធម៌ដែលតថាគតមិនទាន់បានធ្វើឲ្យរាក់ និង រមែងបន្ទោបង់ នូវសេចក្តីសង្ស័យ ក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃសេចក្តីសង្ស័យ ដ៏ច្រើនជាអនេក ដល់ភិក្ខុរូបនោះ " ។

បណ្តាបទទាំងនោះ បទ ថា " តេ " មានសេចក្តីថា ភិក្ខុចូលទៅរកភិក្ខុទាំងឡាយ ជាពហុស្សូត ជាកល្យាណមិត្រ មួយដងមួយកាល ។

ក្នុងអដ្ឋកថាបាបណិកសូត្រនោះ លោកពោល ថា " បទ ថា

'បរិបុច្ឆតិ' មានសេចក្តីថា រមែងដណ្តឹងសួរ នូវប្រយោជន៍និងមិនមែនជាប្រយោជន៍ គឺ ហេតុនិង មិនមែនជាហេតុ ។ បទថា 'បរិបញ្ហតិ' មានសេចក្តីថា រមែងសាកសួរ គឺ រមែងពិចារណានូវធម៌ដែលខ្លួនមិនទាន់ដឹងថា 'អាត្មាអញនឹងសួរ នូវបទនេះ" ។

ដីកាបាបណិកសូត្រនោះ ថា " បទថា 'បរិបុច្ឆតិ' មានសេចក្តីថា រមែងដណ្តឹងសួរ នូវព្រះពុទ្ធវចនៈ ដែលគប្បីសួរ ដោយចំណែកទាំងពួង ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា 'អត្ថានត្ថំ ការណាការណំ បុច្ឆតិ' ។ បទថា 'បរិបញ្ហតិ' បានដល់ រមែងពិចារណា " ។

## ( ថ្ងៃបកតិឧបោសថ )

(២៥) ចំណែក ក្នុងអដ្ឋកថាគិលានសូត្រ ក្នុងគិលានវគ្គនៃបឋមបណ្ណាសកៈ ក្នុងតិកនិបាត អង្គុត្តរនិកាយ លោកពោលថា "ការសំដែងធម៌ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់អនុញ្ញាតហើយ ១ ខែ ៨ ដង " ។

ឈ្មោះថា វារៈ ៨ ក្នុងអដ្ឋកថាគិលានសូត្រនោះ បានដល់ថ្ងៃនៃបកតិឧបោសថ ៨ ថ្ងៃ គឺ ក្នុងជុណ្ហបក្ខ ( ខាងខ្នើត ) ៤ ថ្ងៃ គឺ ថ្ងៃទី ៥ ថ្ងៃទី ៨ ថ្ងៃទី ១៤ ថ្ងៃទី ១៥, ឯក្នុងកាឡបក្ខ

(ខាងនោះ) ក៏ដូច្នោះដែរ គឺ ថ្ងៃទី ៥ ថ្ងៃទី ៨ ថ្ងៃទី ១៤ ថ្ងៃខែដាច់ ។ សួរថា "តិថីទី ៥ មិនបានមក ក្នុងបាលីទាំងពួង មិនមែនទេឬ ?"។ ឆ្លើយថា "ពិតមែន ។ តែ តិថីទី ៥ នោះ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ បានតាំងទុកហើយ" ។

សមដូចពាក្យលោកពោលហើយ ក្នុងអដ្ឋកថាភយភេរវសូត្រ ថា "បានឮថា ក្នុងកាលមុន កាលបើព្រះដ៏មានព្រះភាគ ទ្រង់មិនទាន់ឧបត្តិឡើងក្តី ទ្រង់ឧបត្តិឡើងហើយ តែពុំទាន់បរិនិព្វានទៅហើយក្តី, លោកមិនបានកំណត់តិថីទី ៥ ទុកឡើយ, ប៉ុន្តែ កាលបើព្រះដ៏មានព្រះភាគ ទ្រង់បរិនិព្វានទៅហើយ, ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ក៏គិតគ្នា ថា 'ការស្តាប់ធម៌ នឹងមាន ក៏ដោយកាលដ៏យូរអង្វែង'។ តាំងពីពេលនោះមក ទើបបានសម្មតិតែងតាំងថ្ងៃធម្មស្សវនៈ ថា 'តិថីទី ៥'។ ចាប់ដើមអំពីថ្ងៃនោះមក តិថីទី ៥ នោះ ទើបកើតទៅជាថ្ងៃ ដែលលោកបានកំណត់ហើយ ។ ប៉ុន្តែ ថ្ងៃបញ្ចមីនោះ ព្រះដ៏មានព្រះភាគ ទ្រង់មិនបានកំណត់យកឡើយ ក្នុងព្រះសូត្រនេះ ព្រោះមិនប្រព្រឹត្តទៅសព្វៗកាល ដោយប្រការដូច្នេះ"។

ក៏បទថា "ចាតុទ្ទសី" នេះ រមែងបាន ក្នុងបក្ខទាំង ២ ។ ដោយហេតុនោះ ក្នុងអដ្ឋកថាភយភេរវសូត្រ ទើបលោកពោលថា

“រាត្រីមួយ ទី ១៤ ជាទីពេញ នៃថ្ងៃទី ១៤ រោច ចាប់ដើមអំពីថ្ងៃទី ១ នៃបក្ខទៅ ឈ្មោះថា ចាតុទ្ទសី ។ ថ្ងៃបញ្ចទសី និងថ្ងៃអដ្ឋមី ក៏ដូច្នោះដែរ ។ បទថា “បក្ខស្ស” គឺ នៃសុក្កបក្ខ និងកណ្ហបក្ខ មាន ៦ រាត្រី ព្រោះបែងចែករាត្រីទាំងនោះ ឲ្យទៅជាបក្ខមួយៗ ៣ រាត្រី ។ ព្រោះហេតុនោះ គប្បីប្រកបពាក្យថាបក្ខក្នុងទីគ្រប់ស្ថាន ថា ‘បក្ខស្ស ចាតុទ្ទសី, បក្ខស្ស បញ្ចទសី, បក្ខស្ស អដ្ឋមី’ ដូច្នេះ” ។

ដីកាភយភេរវសូត្រនោះថា “ពាក្យថា ‘បឋមទិវសតោ បភូតិ’ គឺ ចាប់ដើមតាំង អំពីថ្ងៃបាដិបទខាងដើមទៅ”.។

(២៦) ព្រោះហេតុនោះ ការស្តាប់ធម៌ សូម្បីក្នុងថ្ងៃទាំងឡាយ ៨ នៃខែ ក៏ឈ្មោះថា ការស្តាប់ធម៌តាមកាល ដូច្នេះ ។ ការស្តាប់ធម៌តាមកាលនោះនុ៎ះ ឈ្មោះថា ជាមង្គល ព្រោះជាហេតុឲ្យបានសម្រេចគុណវិសេសច្រើនប្រការ មានលះបង់នូវនីវរណធម៌ផង បាននូវអានិសង្ស ៤ ផង ឲ្យបានសម្រេចកិរិយាអស់ទៅនៃអាសវកិលេសជាដើមផង ។ សមដូចជាព្រះតម្រាស់ ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ព្រះអរិយសាវក ធ្វើឲ្យមានប្រយោជន៍ ធ្វើទុកក្នុងចិត្ត កំណត់ដោយចិត្តទាំងពួង ផ្ទៀងសោតៈ ចាំស្តាប់ធម៌, ក្នុងសម័យនោះ

នីវរណធម៌ទាំង ៥ រមែងមិនមាន ដល់ព្រះអរិយសាវកនេះ, ក្នុងសម័យនោះ ពោជ្ឈង្គ ៧ រមែងដល់ នូវការចំរើនបរិបូណ៌ ” ។

បាលីពោជ្ឈង្គសំយុត្ត ក្នុងមហាវគ្គ ។

(២៧) អដ្ឋកថាកស្សបសំយុត្ត ថា “ បទថា ‘ អដ្ឋិកត្វា ’ មានសេចក្ដីថា ធ្វើខ្លួនឲ្យមានប្រយោជន៍ដោយធម៌នោះ, មួយទៀត ធ្វើធម៌នោះ ឲ្យមានប្រយោជន៍ដោយគិតថា ‘ ធម៌នេះជាប្រយោជន៍ ដល់អាត្មាអញ ’ ។ បទថា ‘ មនសិកត្វា ’ គឺ តាំងទុកក្នុងចិត្ត ។ ២ បទថា ‘ សព្វចេតសា សមន្នាហរិត្វា ’ មានសេចក្ដីថា មិនបណ្ដោយចិត្ត ឲ្យចេញទៅខាងក្រៅ សូម្បីបន្តិចបន្តួចបាន កំណត់ដោយចិត្តជាគ្រឿងកំណត់ទាំងពួង ។ បទថា ‘ ឱហិតសោតោ ’ គឺ តាំងត្រចៀកចុះហើយ ” ។

ដីកាកស្សបសំយុត្តនោះ ថា “ ចិត្តជាគ្រឿងស្ដាប់ តាំងតែអំពីដំបូង រហូតដល់ទីបំផុត ព្រះអដ្ឋកថាចារ្យ បានអធិប្បាយហើយ ថា ‘ ចិត្តទាំងពួង ’ ហេតុនោះ ទើបពោល ថា ‘ មិនឲ្យចិត្តចេញទៅខាងក្រៅ សូម្បីបន្តិចបន្តួចបានឡើយ ” ។ ព្រះអដ្ឋកថាចារ្យ តែងសំដែង នូវកិរិយាតាំងស៊ប់ ដោយពាក្យថា សព្វចេតោ នោះ ។ ពាក្យ ថា “ សព្វេន ។បេ។ សមន្នាហរិត្វា ” មានសេចក្ដីថា កំណត់នូវធម៌ប៉ុណ្ណោះ ដោយចិត្តជាគ្រឿងកំណត់ទាំងពួង ដែល

ប្រព្រឹត្តទៅ ក្នុងចន្លោះៗ ចាប់ដើមតាំងអំពីដំបូង រហូតទៅដល់ចប់ព្រះធម៌ទេសនា ។ បទថា 'ឋបិតស្សោតោ' មានសេចក្តីថា មានត្រចៀកតាំងនៅស៊ប់ហើយ ក្នុងព្រះធម៌ " ។

(២៨) អដ្ឋកថាពោជ្ឈង្គសំយុត្តថា " ពាក្យថា 'បញ្ច នីវរណា តស្មឹ សមយេ ន ហោន្តិ សត្ត ពោជ្ឈង្គា តស្មឹ សមយេ ភាវនាបារិបូរឹ គច្ឆន្តិ' មានសេចក្តីថា ក៏កាលបើព្រះអរិយសាវកស្តាប់នូវធម្មស្សវនៈ ដែលជាទីសប្បាយ, នីវរណធម៌ ៥ យ៉ាង រមែងមាននៅ ក្នុងទីឆ្ងាយ ៗ ក៏ប្រសិនបើ ព្រះអរិយសាវកនោះ អាចដើម្បីនឹងញ៉ាំងគុណវិសេស ឲ្យកើតឡើងបាន ក្នុងទីនោះឯង, ពោជ្ឈង្គ ៧ រមែងដល់ នូវកិរិយាចំរើនពេញបរិបូណ៌ ដល់ព្រះអរិយសាវកនោះ ដោយប្រការដូច្នេះ ។ បើព្រះអរិយសាវកនោះ មិនអាច, ចាប់ដើមពីនោះមក លោកទៅកាន់ទីសម្រាក ក្នុងពេលយប់និងទីសម្រាក ក្នុងពេលថ្ងៃ ហើយមិនលះបង់បីតិនោះឯងញាំញីនូវនីវរណធម៌ទាំង ៥ បានហើយ នឹងញ៉ាំងគុណវិសេស ឲ្យកើតឡើង, សូម្បីលោកមិនអាចញ៉ាំងគុណវិសេស ឲ្យកើតឡើងក្នុងទីនោះបានទេ មិនទាន់លះបង់បីតិនោះឯង រហូតចន្លោះ ៧ ថ្ងៃ គ្រប់សង្កត់នីវរណធម៌ ទាំងឡាយបានហើយ នឹងញ៉ាំងគុណវិសេសឲ្យកើតឡើង ៗ ព្រះដ៏មានព្រះភាគ ទ្រង់សំដៅយកហេតុដែល

ពោលមកហើយនេះ ទើបទ្រង់ត្រាស់ នូវព្រះតម្រាស់នេះ ថា ‘ បញ្ច នីវរណា ។ បេ ។ ភាវនា បារិបូរឹ គច្ឆន្តិ ’ ដូច្នេះ ។ មែនពិត ពោជ្ឈង្គដែលព្រះអរិយសាវកបាន មួយគ្រាហើយ ដោយអំណាច ការស្តាប់ធម៌ មានបីតិនិងបាមោជ្ជជាបច្ច័យ អាស្រ័យភាពជាអ្នក ត្រេកអរក្នុងការងារជាដើម រមែងសាបសូន្យទៅបាន ។ ក៏ប៉ុន្តែ ពោជ្ឈង្គទាំងឡាយ សូម្បីកាលបានរដូវដែលជាទីសប្បាយជាដើម យ៉ាងដូច្នោះហើយ កើតឡើងម្តងទៀត ព្រះដ៏មានព្រះភាគ ទ្រង់ ត្រាស់ ថា ‘ រមែងដល់នូវកិរិយាចំរើនបរិបូណ៌ ក្នុងសម័យនោះ ” ។

(២៩) ដីកាពោជ្ឈង្គសំយុត្តនោះ ថា “ នីវរណធម៌ទាំង ៥ យ៉ាង ឈ្មោះថា មាននៅ ក្នុងទីឆ្ងាយ ព្រោះមិនមានឱកាសតាំងនៅ ស៊ប់ ។ ២ បទថា ‘ តមេវ បីតឹ ’ មានសេចក្តីថា ឈ្មោះថា មិនលះបង់ នូវបីតិដែលកើតឡើងហើយ ដោយអំណាចការស្តាប់ ធម៌ដែលជាទីសប្បាយ ដោយកិរិយាកំណត់អាការ ដែលកើតឡើង ហើយនៃបីតិនោះ ក្នុងគ្រានោះ ព្រោះញ៉ាំងបីតិនោះ ឲ្យកើតឡើង ជាញឹកញាប់ ។ ហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា ‘ បញ្ច នីវរណោ វិក្ខម្ភិត្វា ’ ដូច្នេះ ។ ២ បទថា ‘ ឥទំ សន្ធាយ ’ មានសេចក្តីថា ធម្មបីតិនោះ មិនសាបសូន្យ អស់ថ្ងៃមានប្រមាណ ត្រឹមណា ជាធម្មជាតិបានបច្ច័យហើយ រមែងនាំគុណវិសេសមកឲ្យ

អស់ថ្ងៃមានប្រមាណត្រឹមនោះ ។ ព្រះអដ្ឋកថាចារ្យ សំដៅយកនូវសេចក្តីនេះ ទើបពោលពាក្យនេះថា “ **បញ្ច នីវរណា តស្មឹ សមយេ ន ហោន្តិ** ’ ដូច្នេះជាដើម ។ ពាក្យថា ‘ **បីតិប្បា-មោជ្ជប្បច្ចយា ។ប។ នស្សន្តិ** ’ មានសេចក្តីថា រមែងមិនប្រាកដ ព្រោះមិនប្រព្រឹត្តទៅ ដោយអំណាចបច្ច័យដែលជាសឹកសត្រូវ ។ សូម្បីពោជ្ឈង្គដែលកើតឡើងថ្មីទៀត ដោយអំណាចបច្ច័យដែលមានចំណែកស្មើគ្នា ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ‘ក្នុងសម័យនោះ រមែងដល់នូវកិរិយាចំរើនបរិបូណ៌ ’ ព្រោះប្រព្រឹត្តទៅ ដោយអំណាចញ៉ាំងកិច្ចឲ្យសម្រេច ” ។

## ( អានិសង្សនៃការស្តាប់ធម៌ )

(៣០) ការស្តាប់ធម៌ រមែងជាហេតុឲ្យបានសម្រេច នូវការលះបង់នីវរណធម៌បាន ដោយប្រការដូច្នេះ ។

បានឮថា ព្រាហ្មណ៍ទាំងឡាយ ៥០០ នាក់ បួសហើយ ក៏មិនទៅ ដើម្បីស្តាប់ធម៌ ដោយគិតថា “ ព្រះសម្មាសម្ពុទ្ធ កាលទ្រង់ត្រាស់ ដោយលិង្គ វចនៈ វិភ័ត្តិ បទ និង ព្យញ្ជនៈ ជាដើម នឹងទ្រង់ត្រាស់តែសេចក្តី ដែលពួកយើងដឹងហើយប៉ុណ្ណោះ សេចក្តីដែលពួកយើងមិនដឹង ព្រះអង្គនឹងទ្រង់ត្រាស់អ្វីបាន ? ” ។

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់នូវព្រឹត្តិហេតុនោះ ក៏ទ្រង់ត្រាស់ឲ្យហៅភិក្ខុទាំងនោះមកហើយ កាលនឹងទ្រង់សំដែងថា “ព្រោះហេតុអ្វី អ្នកទាំងឡាយ ទើបធ្វើ យ៉ាងដូច្នេះ ? អ្នកទាំងឡាយ ចូរស្តាប់ធម៌ ដោយគោរព, កាលបើអ្នកទាំងឡាយ ស្តាប់និងស្វាធ្យាយនូវធម៌ ដោយគោរព គប្បីសង្ឃឹមអានិសង្ស មានប្រមាណប៉ុណ្ណោះនេះបាន ” ដូច្នេះ ទើបទ្រង់ត្រាស់សោតានុគតសូត្រ[១] ក្នុងបញ្ចមវគ្គនៃចតុត្ថបណ្ណាសកៈ ចតុក្កនិបាត អង្គុត្តរនិកាយ ថា “ម្នាលភិក្ខុទាំងឡាយ អានិសង្សទាំងឡាយ ៤ ប្រការ នៃធម៌ដែលចូលទៅកាន់ត្រចៀករឿយ ៗ ជាធម៌ដែលបុគ្គលចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះដោយទិដ្ឋិ គឺបញ្ញា រមែងកើតប្រាកដ ។ អានិសង្ស ៤ ប្រការ តើដូចម្តេច ? ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ រៀននូវធម៌ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ ។ ធម៌ទាំងនោះជាសភាវៈចូលទៅកាន់ត្រចៀករឿយ ៗ នៃភិក្ខុនោះ ដែលបានចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះ ដោយទិដ្ឋិបាន ។ ភិក្ខុនោះ ភ្លេចសតិស្មារតី ធ្វើមរណកាលទៅ រមែងចូលទៅកាន់ទេវនិកាយណាមួយ ។ បទនៃធម៌ទាំងឡាយ រមែងប្រាកដច្បាស់ដល់ភិក្ខុនោះ ដែលមានសេចក្តីសុខ ក្នុងទេវនិកាយនោះ ។ ម្នាល

---

១- ត្រៃបិដក ភាគទី ៤៣ / ទំព័រទី ១០៧

ភិក្ខុទាំងឡាយ ការកើតឡើងនៃសតិ ឈ្មោះថា ជាការយឺតយូរ, ឯភិក្ខុនោះ វេលាដល់នូវគុណវិសេស ក៏ឆាប់រហ័សជាងសតិនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ១ នៃធម៌ដែលចូលទៅកាន់ត្រចៀករឿយៗ ។ល។ ដែលភិក្ខុចាក់ធ្លុះ ដោយទិដ្ឋិ រមែងកើតប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុរៀនធម៌ គឺសុត្តៈ ។ល។ រមែងចូលទៅកាន់ទេវនិកាយណាមួយ ។ បទនៃធម៌ទាំងឡាយ មិនសូវប្រាកដច្បាស់ ដល់ភិក្ខុនោះដែលមានសេចក្តីសុខក្នុងទេវនិកាយនោះឯង ក៏ប៉ុន្តែ ភិក្ខុជាអ្នកមានឫទ្ធិ ដល់នូវសេចក្តីស្ទាត់ជំនាញខាងផ្លូវចិត្ត រមែងសំដែងធម៌ ដល់ទេវបរិស័ទបាន ។ ភិក្ខុនោះ រមែងមានសេចក្តីត្រិះរិះយ៉ាងនេះ ថា 'អាត្មាអញបានប្រព្រឹត្តព្រហ្មចរិយៈ អំពីមុន ក្នុងព្រះធម្មវិន័យណា, នេះ គឺព្រះធម្មវិន័យនោះឯង' ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃសតិឈ្មោះថាជាការយឺតយូរ, ឯភិក្ខុនោះ វេលាដល់នូវគុណវិសេស ក៏ឆាប់រហ័សជាងសតិនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាបុរសអ្នកឈ្លាសវៃ ខាងសំឡេងស្គរ, បុរសនោះ ដើរទៅកាន់ផ្លូវឆ្ងាយ បានឮសំឡេងស្គរ, បុរសនោះ ក៏មិនមានសេចក្តីសង្ស័យ ឬសេចក្តីងឿងឆ្ងល់ នឹងសំឡេងស្គរនោះឯង ថា 'សំឡេងស្គរមែន ឬក៏មិនមែនសំឡេងស្គរទេ' ដូច្នេះឡើយ, បុរសនោះ គប្បីដល់នូវ

សេចក្ដីចូលចិត្តថា ‘សំឡេងស្គរ’ ដោយពិត មានឧបមាយ៉ាងណា, ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក៏មានឧបមេយ្យដូច្នោះដែរ រៀននូវធម៌ គឺ សុត្តៈ ។ល។ គ្រានោះ ភិក្ខុនោះជាអ្នកមានសតិស្មារតី ជាអ្នកដល់នូវគុណវិសេស យ៉ាងឆាប់រហ័សណាស់ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ២ នៃធម៌ទាំងឡាយ ដែលចូលទៅកាន់ត្រចៀករឿយៗ ។ល។ ដែលភិក្ខុចាក់ធ្លុះ ដោយទិដ្ឋិ រមែងកើតប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុរៀននូវធម៌ គឺ សុត្តៈ ។ល។ រមែងចូលទៅកាន់ទេវនិកាយណាមួយ ។ ចំណែកនៃធម៌ទាំងឡាយ មិនប្រាកដច្បាស់ ដល់ភិក្ខុនោះដែលមានសេចក្ដីសុខ ក្នុងទេវនិកាយនោះឡើយ ។ ទាំងមិនមែនជាភិក្ខុមានឫទ្ធិ ដល់នូវសេចក្ដីស្ទាត់ជំនាញខាងផ្លូវចិត្ត ហើយសំដែងធម៌ ដល់ទេវបរិស័ទបានឡើយ ។ គ្រាន់តែថា ទេវបុត្រ អាចសំដែងធម៌ ដល់ទេវបរិស័ទបានប៉ុណ្ណោះ ។ ភិក្ខុនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ‘ព្រះធម្មវិន័យនោះ នេះឯង ។ល។ ជាអ្នកដល់នូវគុណវិសេស យ៉ាងឆាប់រហ័ស ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាបុរស ជាអ្នកឈ្លាសវៃនឹងសំឡេងស័ង្ខ, បុរសនោះ ដើរទៅកាន់ផ្លូវឆ្ងាយ ។ល។ គ្រានោះ ភិក្ខុនោះ ជាអ្នកមានសតិ ជាអ្នកដល់នូវគុណវិសេស យ៉ាងឆាប់រហ័ស ។ ម្នាលភិក្ខុទាំងឡាយ

នេះជាអានិសង្សទី ៣ នៃធម៌ទាំងឡាយ ដែលចូលទៅកាន់ត្រចៀក រឿយៗ ។ល។ ដែលភិក្ខុចាក់ធ្លុះ ដោយទិដ្ឋិ រមែងកើតប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុរៀនធម៌ គឺ សុត្តៈ ។ល។ រមែងចូលទៅកាន់ទេវនិកាយណាមួយ ។ ចំណែកនៃធម៌ទាំងឡាយ មិនប្រាកដច្បាស់ ដល់ភិក្ខុនោះ ដែលមានសេចក្តីសុខ ក្នុងទេវនិកាយនោះ ។ល។ ទាំងមិនមែនជាភិក្ខុមានឫទ្ធិ ។ល។ ទាំងមិនមែនជាទេវបុត្រ អាចសំដែងធម៌ ដល់ទេវបរិស័ទបានទេ ។ តែបើមានឧបបាតិកសត្វ រលឹកនូវឧបបាតិកសត្វថា 'ម្នាលគ្នាយើង ពួកយើង បានប្រព្រឹត្តព្រហ្មចរិយៈ អំពីមុន ក្នុងព្រះធម្មវិន័យណា, អ្នករលឹកបាននូវព្រះធម្មវិន័យនោះដែរឬ' ដូច្នេះ ។ ទេវបុត្រនោះក៏និយាយយ៉ាងនេះថា 'ម្នាលគ្នាយើង យើងរលឹកបាន, ម្នាលគ្នាយើង យើងរលឹកបាន' ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃសតិ ឈ្មោះថាយឺតយូរ, គ្រានោះ ភិក្ខុនោះជាអ្នកដល់នូវគុណវិសេស យ៉ាងឆាប់រហ័សជាងសតិនោះ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាសំឡាញ់ពីរនាក់ លេងអាចម៍ដីជាមួយគ្នា, សំឡាញ់ទាំងពីរនាក់នោះ មកជួបគ្នា ក្នុងទីណាមួយៗ, សំឡាញ់ (ម្នាក់) ក៏និយាយទៅនឹងសំឡាញ់ (ម្នាក់) នោះនុ៎ះ យ៉ាងនេះថា 'នៃសំឡាញ់ ឯងរលឹកបាន នូវហេតុនេះដែរឬទេ ? នៃសំឡាញ់

តើឯងរលឹកបាន សូម្បីនូវហេតុនេះដែរឬទេ ?' ដូច្នេះ, សំឡាញ់នោះ គប្បីឆ្លើយតបយ៉ាងនេះថា 'នែសំឡាញ់ ! ខ្ញុំរលឹកបាន នែសំឡាញ់ ខ្ញុំរលឹកបាន' ដូច្នេះ មានឧបមាយ៉ាងណា, ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក៏មានឧបមេយ្យដូច្នោះដែរ រៀននូវធម៌ គឺ សុត្តៈ ។ល។ តែបើមានឧបបាតិកសត្វ រំលឹកឧបបាតិកសត្វថា 'ម្នាលគ្នាយើង អ្នករលឹកនូវធម្មវិន័យនោះដែរឬទេ ? ។ល។ គ្រានោះឯង ភិក្ខុនោះជាអ្នកដល់នូវគុណវិសេស យ៉ាងឆាប់រហ័ស ។ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ៤ នៃធម៌ទាំងឡាយ ដែលចូលទៅកាន់ត្រចៀករឿយ ៗ ។ល។ ដែលភិក្ខុចាក់ធ្លុះដោយទិដ្ឋិ រមែងកើតប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៤ ប្រការនេះ នៃធម៌ទាំងឡាយដែលចូលទៅកាន់ត្រចៀករឿយ ៗ ដែលភិក្ខុចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះ ដោយទិដ្ឋិ រមែងកើតប្រាកដ " ។

(៣១) អដ្ឋកថាសោតានុគតសូត្រនោះ ថា " បទថា 'សោតានុគតានំ' មានសេចក្តីថា ដែលភិក្ខុផ្ទៀងសោតប្បសាទចុះហើយ កំណត់ដោយសោត គឺញាណ ។ ២ បទថា '**អានិសំសា បាដិកង្ខា**' មានសេចក្តីថា គុណានិសង្ស ដែលភិក្ខុនោះគប្បីសង្ឃឹមបាន ។ ២ បទថា '**ធម្មំ បរិយាបុណាតិ**'

មានសេចក្តីថា រមែងសិក្សាធម៌ដែលជាបែបផែន ជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា មានអង្គ ៩ មានសុត្តៈ គេយ្យៈ ជាដើម ៗ បទថា 'សោតានុគតា' បានដល់ ទៅតាមត្រចៀក គឺ ចូលកាន់ត្រចៀក ៗ បទថា 'មនសានុបេក្ខិតា' ប្រែថា ត្រួតមើលដោយចិត្ត ៗ ២ បទថា 'ទិដ្ឋិយា សុប្បដិវិទ្ធា' មានសេចក្តីថា ចាក់ធ្លុះ គឺ ធ្វើឲ្យជាក់ច្បាស់ល្អ ដោយបញ្ញា តាមផល និងតាមហេតុ ៗ ពាក្យថា 'មុដ្ឋស្សតិ កាលំ កុរុមានោ' នេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ ព្រោះភាវៈជាអ្នកមិនមានសតិជាគ្រឿងនឹករលឹក នូវព្រះពុទ្ធវចនៈ ក៏ទេដែរ, តែព្រះអង្គទ្រង់ត្រាស់សំដៅយកកាលកិរិយារបស់បុថុជ្ជន ៗ មែនពិត បុថុជ្ជន ឈ្មោះថា ជាអ្នកភ្លេចភ្លាំងសតិ ធ្វើមរណកាល ៗ បទថា 'ឧបបជ្ជតិ' មានសេចក្តីថា ស្ថិតនៅក្នុងសីលដ៏បរិសុទ្ធ រមែងទៅកើតនៅ ក្នុងទេវលោក ៗ បទថា 'ធម្មបទាបិលបន្តិ' មានសេចក្តីថា ធម៌គឺព្រះពុទ្ធវចនៈឯណា ដែលភ្លេចភ្លាំងដោយការទន្ទេញ គឺ មិនបានចាំរត់មាត់ ក្នុងកាលមុន របស់ភិក្ខុអ្នកមានសេចក្តីសុខ ជាអ្នកកើតហើយក្នុងភពជាទីបំផុត, ធម៌គឺព្រះពុទ្ធវចនៈទាំងអស់នោះ រមែងប្រាកដច្បាស់ គឺ រមែងជាក់ច្បាស់ បានដល់ ប្រាកដយ៉ាងច្បាស់លាស់ ដូចជាស្រមោល ក្នុងកញ្ចក់ដ៏ភ្លឺថ្លា ៗ ពាក្យថា 'ទន្ធោ

**ភិក្ខវេ សតុប្បាទោ** ' មានសេចក្តីថា ការកើតឡើង នៃសតិជាគ្រឿងរលឹកដល់ព្រះពុទ្ធវចនៈនុ៎ះឯង យឺតយូរ គឺ ធូន់ ។ ពាក្យថា ' **អថ សោ សតោ ខិប្បំយេវ វិសេសគាមី ហោតិ** ' មានសេចក្តីថា រមែងជាអ្នកទៅដល់ព្រះនិព្វាន ។ ពាក្យថា ' **ឥទ្ធិមា ចេតោវសិប្បត្តោ** ' មានសេចក្តីថា ព្រះខីណាស្រព អ្នកដល់ព្រមដោយឫទ្ធិ ដល់នូវភាពជាអ្នកស្ទាត់ជំនាញនៃចិត្ត ។ **វា** ស័ព្ទ ក្នុងពាក្យថា ' **អយំ វា សោ ធម្មវិនយោ** ' នេះ មានវិការវៈ ជាអត្ថ ។ បទថា ' **យត្ថ** ' គឺ ក្នុងព្រះធម្មវិន័យណា ។ ២ បទថា ' **ព្រហ្មចរិយំ អចរឹ** ' មានសេចក្តីថា អាត្មាអញនៅប្រព្រឹត្តព្រហ្មចរិយៈ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ព្រះតម្រាស់ថា ' **ព្រហ្មចរិយំ អចរឹ** ' នេះ ដោយអំណាចកិរិយារលឹកដល់ព្រះពុទ្ធវចនៈ ថា ' ព្រះពុទ្ធវចនៈនេះឯង អាត្មាអញបានរៀនហើយ ក្នុងកាលមុន ' ។ បទថា ' **ទេវបុត្តោ** ' មានសេចក្តីថា ទេវបុត្រជាធម្មកថិកមួយអង្គ ដូចជាបញ្ចាលចណ្ឌទេវបុត្រ ហត្ថកមហាព្រហ្មនិង ដូចជាសនង្កុមារមហាព្រហ្ម ។ ពាក្យថា ' **ឱបបាតិកោ ឱបបាតិកំ** ' មានសេចក្តីថា ទេវបុត្រដែលកើតមុន តែងឲ្យទេវបុត្រកើតក្រោយ រលឹកបាន ។ ដោយពាក្យថា ' **សហាបំសុកីឡកា** ' នេះ ព្រះដ៏មានព្រះភាគ ទ្រង់សំដែងនូវភាវៈ នៃសំឡាញ់ទាំង ២

នាក់នោះ ធ្វើសេចក្ដីស្និទ្ធស្នាលគ្នាមក អស់កាលដ៏យូរ ។ បទថា 'សមាគច្ឆេយ្យុំ' មានសេចក្ដីថា គប្បីមកជួបមុខគ្នា លើសាលា ឬក្រោមដើមឈើ ។ ពាក្យថា 'ឯវំ វទេយ្យ' មានសេចក្ដីថា សំឡាញ់ដែលអង្គុយ មុនគេ លើសាលា ឬក្រោមដើមឈើ គប្បីពោលនឹងសំឡាញ់ដែលមកហើយ ខាងក្រោយ យ៉ាងនោះ " ។

(៣២) ដីកាសោតានុគតសូត្រនោះ ថា "បទថា 'សោតានុគតានិ' មានសេចក្ដីថា ដែលទៅតាមសោតប្បសាទហើយ ចាំទុក គឺ ស្ទាត់ជំនាញ បានដល់ រត់មាត់ ។ ក៏ធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅ យ៉ាងនោះ ឈ្មោះថាជាធម៌ គឺភិក្ខុផ្ទៀងសោតប្បសាទហើយ កំណត់ដោយល្អ ដោយសោតញាណ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា 'បសាទសោតេ' ដូច្នេះជាដើម ។ មែនពិត ព្រះពុទ្ធវចនៈដែលភិក្ខុអង្គណា បានរៀនហើយ ចងចាំទុក ស្ទាត់ជំនាញ មិនភ្លេចភ្លាំង ឈ្មោះថា រមែងកំណត់ទុក ដោយល្អ ក៏ពុំមែនដែរ ។ ភិក្ខុនោះ, កាលបើអ្នកណាមួយពោល ថា 'សូមលោកម្ចាស់និមន្តសំដែងនូវសូត្រ ឬជាតកឈ្មោះនុ៎ះ' ដូច្នេះ, រមែងពោល ថា 'អាត្មានឹងស្វាធ្យាយ ប្រៀបធៀប ផ្គូរផ្គងហើយ នឹងដឹងបាន' ដូច្នេះ ។ (តែ) ព្រះពុទ្ធវចនៈ ដែលភិក្ខុអង្គណា បានរៀន ចងចាំទុក ស្ទាត់ជំនាញហើយ រមែងដូចជាភវង្គសោត ។

ភិក្ខុនោះ, កាលបើអ្នកណាមួយ ពោលហើយថា 'សូមលោកម្ចាស់សំដែងនូវសូត្រ ឬ ជាតកឈ្មោះនោះ' ដូច្នេះ, រមែងលើកយកមកសំដែង នូវសូត្រ ឬ ជាតកនោះ បានភ្លាម ។ ព្រះអដ្ឋកថាចារ្យសំដៅយកពាក្យ ដែលពោលមកហើយនោះ ទើបពោលពាក្យនេះថា 'ញាណស្សេវ តេន វវត្ថាបិតានិ' ដូច្នេះ ។ បទថា 'វវត្ថាបិតានិ' មានសេចក្ដីថា ធ្វើឱ្យរត់មាត់ ចងចាំទុកបាន ដោយអំណាចខាងដើម និងខាងចុង នៃបាលីនិងអនុសន្ធិ ។ ២ បទថា 'វចសា បរិចិតា' មានសេចក្ដីថា ទន្ទេញ ដោយមាត់ ដោយអំណាចនៃសុត្តទសកៈ វគ្គទសកៈ បណ្ណាសកទសកៈ ។ អធិប្បាយថា 'កំណត់ដោយន័យថា 'កន្លងទៅហើយបាន ១០ សូត្រ កន្លងទៅហើយបាន ១០ វគ្គ' ដូច្នេះជាដើម ហើយទន្ទេញដោយមាត់' ។ ក្នុងបទថា 'វចសា បរិចិតា' នេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់អធិប្បាយការអប់រំ ដោយវាចា ដោយអំណាចនៃវគ្គជាដើម, ប៉ុន្តែ ព្រះអង្គមិនបានត្រាស់អធិប្បាយ ការអប់រំ ដោយវាចា នៃចំណែកមួយរបស់សូត្រ និង ត្រឹមតែសូត្រឡើយ ។ បទថា 'មនសានុបេក្ខិតា' មានសេចក្ដីថា ត្រួតមើល គឺ គិត ដោយចំណែក ឈ្មោះថាពិនិត្យមើល ដោយចិត្ត ។ កាលបើភិក្ខុណា គិតដោយចិត្ត នូវព្រះពុទ្ធវចនៈ ដែលខ្លួនបានស្វាធ្យាយហើយ ដោយវាចា, ព្រះពុទ្ធវចនៈ

រមែងប្រាកដ ក្នុងទីនោះៗ, គឺ ប្រាកដជាក់ច្បាស់ ដូចជារូបប្រាកដជាក់ច្បាស់ ដល់បុគ្គលដែលឈរទ្រោលប្រទីបដ៏ធំ យ៉ាងនោះឯងៗ ព្រះដ៏មានព្រះភាគ ទ្រង់សំដៅយកភិក្ខុនោះ ទើបត្រាស់ព្រះតម្រាស់នេះ ថា 'សុប្បដិវិទ្ធា' ដូច្នេះ ៗ អធិប្បាយថា 'ចាក់ធ្លុះដោយប្រពៃ គឺ តាមពិត ធ្វើមិនឲ្យស្មុគស្មាញ គឺ មិនឲ្យសាំញ៉ាំ" ៗ

(៣៣) ការស្តាប់ធម៌ រមែងជាហេតុឲ្យបានសម្រេចនូវអានិសង្ស ៤ ប្រការ ដោយប្រការដូច្នេះ ៗ ក៏ជនទាំងឡាយ លុះបានស្តាប់ធម៌ហើយ ក៏សម្រេចធម៌ជាទីអស់ទៅនៃអាសវៈ គណនាត្រារាប់ពុំបាន ៗ ព្រោះហេតុនោះ អ្នកណាមួយ ក៏មិនគួរជាអ្នកខ្ជិលស្តាប់ធម៌ឡើយ, មួយទៀត គប្បីដូចជាភិក្ខុកម្លោះជាដើម ដែលនិមន្តទៅកាន់ផ្លូវឆ្ងាយ យ៉ាងដូច្នេះឯង" ៗ

## ( រឿងភិក្ខុកម្លោះ )

បានឮថា ភិក្ខុកម្លោះ ១ រូប នៅក្នុងតិស្សមហាវិហារ ក្នុងមហាគ្រាម បានស្តាប់ ថា "ព្រះមហាធាតកភាណកត្ថេរ នឹងសំដែងនូវរឿងមហាវេស្សន្តរជាតក ដែលប្រដាប់ដោយគាថា ១ ពាន់ ក្នុងទីយវាបិយវិហារ" ទើបចេញអំពីទីនោះ ហើយនិមន្តមក អស់ចម្ងាយផ្លូវ ៩ យោជន៍ តែមួយថ្ងៃគត់ ៗ ក្នុងខណៈនោះឯង

ព្រះថេរៈ ចាប់ផ្ដើមសំដែងធម៌ ៗ ភិក្ខុកម្លោះ កំណត់បានតែគាថាទីបញ្ចប់ ព្រមជាមួយនឹងគាថាខាងដើម ប៉ុណ្ណោះ ព្រោះភាវៈនៃខ្លួនកើតមានសេចក្ដីក្រហល់ក្រហាយ ក្នុងរាងកាយ ព្រោះនិមន្តមកអំពីផ្លូវឆ្ងាយ ៗ គ្រានោះ ក្នុងពេលដែលព្រះថេរៈ សំដែង ថា "**ឥទមវោច**" ដូច្នេះហើយ ក្រោកឡើង, ភិក្ខុកម្លោះនោះ ក៏បានឈរស្រែកយំ ថា "កម្មគឺការមក របស់អាត្មាអញ កើតទៅជាមោឃៈហើយ" ៗ ពេលនោះ មនុស្សម្នាក់ ពិតដល់ព្រះថេរៈ ថា "បពិត្រលោកម្ចាស់ដ៏ចំរើន ភិក្ខុកម្លោះមួយអង្គ បាននិមន្តមកអំពីតិស្សមហាវិហារ ដើម្បីស្ដាប់នូវធម្មកថា របស់លោកម្ចាស់, ភិក្ខុនោះ បានឈរស្រែកយំ ថា 'ការមករបស់អាត្មាអញ កើតទៅជាគ្មានប្រយោជន៍ហើយ' ព្រោះភាវៈជាអ្នកមានកាយក្រហល់ក្រហាយហើយ" ដូច្នេះ ៗ ព្រះថេរៈពោល ថា "ចូរអ្នកអញ្ជើញទៅ, ចូរអ្នកប្រាប់ឲ្យភិក្ខុនោះយល់ ថា 'ថ្ងៃស្អែកនេះ អាត្មានឹងសំដែង ម្ដងទៀត" ដូច្នេះហើយ សំដែង ក្នុងថ្ងៃទី ២ ៗ ភិក្ខុកម្លោះបានស្ដាប់ធម្មកថានោះហើយ ក៏បានសម្រេចជាព្រះសោតាបន្ន ៗ

រឿងភិក្ខុកម្លោះ ចប់ ៗ

## ( រឿងស្រីឲ្យកូនបៅដោះ )

(៣៤) ឯស្ត្រីម្នាក់ នៅក្នុងស្រុកឈ្មោះ ឧលភកោលកណ្ណិ

កាលឲ្យកូនតូចបៅដោះ បានឮថា "ព្រះមហាអភយត្ថេរ អ្នកសំដែងទីឃនិកាយ នឹងសំដែងនូវបដិបទានៃអរិយវង្ស" ដូច្នេះហើយ ក៏បានដើរទៅអស់រយៈផ្លូវ ៥ យោជន៍ បានចូលទៅកាន់វិហារ ក្នុងពេលដែលព្រះថេរៈ អ្នកសំដែងក្នុងវេលាថ្ងៃគង់ហើយនុ៎ះឯង ឲ្យកូនដេកនៅលើផែនដី ហើយបានឈរស្តាប់ធម៌ របស់ព្រះថេរៈដែលសំដែងក្នុងវេលាថ្ងៃ បានឈរស្តាប់នូវការសូត្រជាបទផងដែរ ។ កាលបើព្រះថេរៈអ្នកសូត្រជាបទ ក្រោកហើយ, ព្រះមហាអភយត្ថេរ អ្នកសូត្រទីឃនិកាយ ក៏បានប្រារព្ធនូវមហាអរិយវង្សបដិបទាដែលប្រកបដោយការសន្តោស ក្នុងបច្ច័យ ៤ និងមានភាវនាជាទីត្រេកអរ ។ ស្ត្រីនោះក៏បានឈរប្រណម (អញ្ជលី) ហើយ ។ ឯព្រះថេរៈ បានសំដែងធម៌ រហូតដល់អរុណរះឡើង ។ ព្រះអរុណរះឡើង ១ កិរិយាសំដែងរបស់ព្រះថេរៈ ថា "ឥទមវោច" ដូច្នេះ ១ កិរិយាបានសម្រេចសោតាបត្តិផល របស់ឧបាសិកា ១ បានមានហើយ ក្នុងខណៈជាមួយគ្នានុ៎ះឯង ។

រឿងស្ត្រីបំបៅដោះកូន ចប់ ។

រឿងទាំង ២ នេះ ព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថាឋានសូត្រ ក្នុងបញ្ចមវគ្គ បឋមបណ្ណាសកៈ ក្នុងតិកនិបាតអង្គុត្តរនិកាយ ។

(៣៥) ដីកាឋានសូត្រនោះ ថា "បទថា 'គាថាសហស្សំ'

គឺ មានគាថា ១ ពាន់ ៗ បទថា 'បដ្ឋានគាថាយ' មានសេចក្ដីថា ដោយគាថាចាប់ផ្ដើម គឺ ដោយគាថាខាងដើម ៗ ឈ្មោះថា **បដ្ឋានគាថា** ព្រោះគាថានោះជាគាថាចាប់ផ្ដើម ៗ ភិក្ខុកម្លោះនោះ កំណត់នូវធម្មកថា ដែលព្រះថេរៈពោលហើយ ក្នុងចន្លោះ នៃគាថាខាងដើម និងគាថាជាទីបញ្ចប់ទាំង ២ មិនបាន ព្រោះខ្លួនជាអ្នកមានរាងកាយនឿយហត់ហើយ ៗ កិរិយាសូត្រជាបទ ចាត់ជាធម្មកថា ក្នុងវេលាល្ងាច ៗ បទថា 'បគ្គណ្ហាតិ' មានសេចក្ដីថា ស្ត្រីនោះ ធ្វើឲ្យប្រចក្ស ទទួលយក បានដល់ ស្ដាប់ដោយគោរព" ៗ

(៣៦) ការស្ដាប់ធម៌ របស់បុគ្គល អ្នកដល់ព្រមហើយដោយឧបនិស្ស័យ រមែងជាហេតុឲ្យបានសម្រេចមគ្គ ក្នុងបច្ចុប្បន្ន ដោយពិត ដោយប្រការដូច្នេះ, ចំណែក បុគ្គលអ្នកប្រាសចាកឧបនិស្ស័យ រមែងជាហេតុឲ្យបានសម្រេចមគ្គ ក្នុងអនាគតកាល ៗ ក៏ក្នុងរឿងនេះ មានសច្ចកនិគ្រន្ថជាដើម ជាឧទាហរណ៍ ៗ

## ( រឿងសច្ចកនិគ្រន្ថ )

បានឮថា និគ្រន្ថឈ្មោះសច្ចកៈ ក្នុងទីក្រុងវេសាលី ជាបណ្ឌិត មានវាចាឈ្លាសវៃ កាលញុំាងព្រះរាជកុមារទាំងឡាយ ឲ្យសិក្សាសិល្បសាស្ត្រ ក្នុងគ្រានោះ គេភ័យហើយថា "ពោះរបស់អាត្មាអញ

គប្បីប្រេះបែក ព្រោះពេញប្រៀបដោយបញ្ញា " ទើបយកបន្ទះដែក មករុំព័ទ្ធពោះ ហើយត្រាច់ទៅ ។ សូម្បីពាក្យថា "អគ្គិវេស្សនោ" ក៏ជាឈ្មោះ របស់និគ្រន្ថនោះដូចគ្នា ។ ថ្ងៃមួយ គេក៏ចូលទៅគាល់ព្រះសាស្តាហើយ បានស្តាប់នូវចូឡសច្ចកសូត្រ ស្អែកមួយទៀត ក៏បានចូលទៅគាល់ហើយ បានស្តាប់នូវមហាសច្ចកសូត្រ ។ សូត្រទាំងនោះ មាននៅក្នុងចតុត្ថវគ្គ មូលបណ្ណាសកៈ ។ សច្ចកនិគ្រន្ថនោះបានស្តាប់ នូវសូត្រទាំងនោះហើយ ក៏មិនបានសម្រេចនូវអភិសម័យ មិនបានបួស មិនបានតាំងនៅ ក្នុងសរណៈឡើយ ។ សួរថា " ព្រោះហេតុអ្វី ទើបព្រះដ៏មានព្រះភាគ ទ្រង់សំដែងធម៌ ដល់សច្ចកនិគ្រន្ថនុ៎ះ ? " ។ ឆ្លើយថា " ព្រោះដើម្បីប្រយោជន៍ដល់វាសនា ក្នុងអនាគតកាល " ។ មែនពិត ព្រះដ៏មានព្រះភាគទ្រង់ទតឃើញ ថា " ឧបនិស្ស័យ របស់សច្ចកនិគ្រន្ថនេះ ក្នុងពេលឥឡូវនេះឯង មិនទាន់មាន, ប៉ុន្តែ តាំងអំពីតថាគតបរិនិព្វាន កន្លងទៅហើយបាន ២១៨ ព្រះវស្សា សាសនានឹងស្ថិតនៅគង់វង់ ក្នុងតម្ពបណ្ណិទ្វីប, សច្ចកនិគ្រន្ថនេះ នឹងកើតក្នុងផ្ទះនៃត្រកូល ក្នុងកោះនោះ, កាលបើដល់វេលាហើយ, នឹងបានបួស រៀនចប់ព្រះត្រៃបិដក ចំរើនវិបស្សនាហើយ ក៏បានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទា ជាព្រះមហាខីណាស្រព ព្រះនាមថា កាឡពុទ្ធរក្ខិត" ។ ព្រះ

ដ៏មានព្រះភាគ ទ្រង់ទតឃើញហេតុនេះហើយ ទើបទ្រង់សំដែងធម៌ដើម្បីប្រយោជន៍ នឹងឲ្យមានវាសនា ក្នុងអនាគតកាល ។ ចំណែកសច្ចកនិគ្រន្ថនោះ, កាលបើព្រះសាសនា តាំងនៅមាំហើយ ក្នុងតម្ពបណ្ណិទ្វីប យ៉ាងដូច្នោះឯង, ច្យុតចាកទេវលោកហើយ បានមកកើត ក្នុងត្រកូលអាមាត្យមួយ ក្នុងភិក្ខាចារគ្រាម នៃទក្ខិណាគិរីវិហារ, កាលបើដល់វេលាហើយ, ក៏បានបួស រៀនព្រះពុទ្ធវចនៈគឺព្រះត្រៃបិដក គ្រប់គ្រងគណៈ មានភិក្ខុសង្ឃពួកច្រើនហែហមហើយ បាននិមន្តទៅ ដើម្បីជួបព្រះឧបជ្ឈាយ៍ ។ ព្រះឧបជ្ឈាយ៍ប្រាថ្នានឹងដាស់តឿនភិក្ខុនោះ ទើបមិនបានធ្វើហើយ សូម្បីគ្រាន់តែពាក្យប្រស្រ័យជាមួយ ។ ភិក្ខុនោះ ក្រោកឡើងហើយ ក្នុងពេលទៀបភ្លឺ បានចូលទៅរកព្រះឧបជ្ឈាយ៍ ពោល ថា " បពិត្រព្រះគុណម្ចាស់ដ៏ចំរើន, កាលបើខ្ញុំព្រះករុណា ធ្វើការរៀនគន្ថធុរៈ បានមកហើយ, ព្រះគុណម្ចាស់ មិនបានធ្វើសូម្បីគ្រាន់តែពាក្យប្រស្រ័យជាមួយឡើយ, តើខ្ញុំព្រះករុណា មានទោសអ្វីទៅ ? " ។ ព្រះថេរៈពោល ថា "ម្នាលពុទ្ធរក្ខិត ដ៏មានអាយុ អ្នកកុំធ្វើសេចក្ដីសម្គាល់ ថា 'កិច្ចនៃបព្វជិត របស់អាត្មាអញ ដល់ទីបំផុតហើយ ដោយហេតុមានប្រមាណប៉ុណ្ណោះឯងឡើយ' ដូច្នេះ " ។ ព្រះពុទ្ធរក្ខិត ពោលថា " បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណា នឹងធ្វើអ្វី ? " ។

ព្រះឧបជ្ឈាយ៍ពោលថា "ចូរអ្នកលះបង់ពួកគណៈចេញហើយទំលាយនូវសេចក្ដីយឹតយូរចោល ធ្វើសមណធម៌ចុះ"។ ព្រះពុទ្ធរក្ខិតនោះតាំងនៅក្នុងឱវាទ របស់ព្រះឧបជ្ឈាយ៍នោះហើយ ធ្វើយ៉ាងដូច្នោះ ក៏បានសម្រេចអរហត្ត ព្រមទាំងបដិសម្ភិទា ។ នេះជាសេចក្ដីសង្ខេប ក្នុងមង្គលត្ថទីបនីនេះ ។ ចំណែក សេចក្ដីពិស្ដារ គប្បីត្រួតមើល ក្នុងអដ្ឋកថាមហាសច្ចកសូត្រចុះ ។

រឿងសច្ចកនិគ្រន្ថ ចប់ ។

សូម្បីរឿងមណ្ឌូកទេវបុត្រ ក្នុងបញ្ចមវគ្គ វិមានវត្ថុ ក៏គប្បីពោល ។

(៣៧) មួយទៀត បុគ្គលពួកខ្លះ គិតថា "ធម៌នេះជ្រាលជ្រៅណាស់ មិនប្រាកដច្បាស់ ដល់អាត្មាអញដែលកំពុងស្ដាប់" ដូច្នេះ ក៏មិនប្រាថ្នាចង់ស្ដាប់ធម៌ដែលជ្រាលជ្រៅ ។ រឿងនោះមិនសមគួរ ។ ព្រោះថា សូម្បីធម៌ដែលជ្រាលជ្រៅ ក៏គប្បីស្ដាប់ដោយពិត, សូម្បីមានត្រឹមតែបាលី ក៏គប្បីស្ដាប់ដែរ ។ ព្រោះថាការស្ដាប់ធម៌ដូច្នោះ រមែងកើតជាវាសនា ក្នុងអនាគតកាលបាន ។ ក៏ក្នុងសេចក្ដីនេះ មានពស់ថ្លាន់ជាដើម ជាឧទាហរណ៍ ។

## ( រឿងពស់ថ្លាន់ )

បានឮថា ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមថាកស្សបៈ ពស់

ថ្លាន់មួយ បានកំណត់យកនូវនិមិត្តក្នុងសំឡេង របស់ភិក្ខុអ្នករៀនព្រះអភិធម្មទាំងឡាយ ដែលកំពុងសូធ្យាយអាយតនកថា ធ្វើកាលៈទៅហើយ បានទៅកើត ក្នុងឋានសួគ៌ សោយសម្បត្តិក្នុងឋានសួគ៌ រហូតដល់ពេលដែលព្រះសាស្តា នៃយើងទ្រង់បរិនិព្វាន, កាលបើព្រះសាស្តាទ្រង់បរិនិព្វានទៅហើយ, ក៏បានកើតក្នុងត្រកូលព្រាហ្មណ៍ ៗ ទារកនោះធំពេញវ័យហើយ បានទៅបួស ក្នុងសាសនារបស់ពួកអាជីវក ជាអាជីវកឈ្មោះជនសោណៈ បានជាអ្នកទៅកាន់ត្រកូលនៃព្រះអគ្គមហេសីរបស់ព្រះបាទពិន្ទុសារ ព្រះនាមធម្មា ។ ក្នុងគ្រានោះ ព្រះនាងធម្មាទេវី ទ្រង់ (ព្រះគភ៌) ព្រះអសោកកុមារ ទ្រង់បានចាញ់ព្រះគភ៌ យ៉ាងនេះ ថា "អាត្មាអញ ប្រាថ្នានឹងជាន់ព្រះច័ន្ទដោយព្រះបាទម្ខាង ព្រះអាទិត្យដោយព្រះបាទម្ខាង ហើយសោយនូវដួងតារា ដុំវលាហក អាចម៍ដី និងព្រៃឈើ " ។

ព្រះរាជា ទ្រង់ព្រះសណ្ដាប់រឿងនោះហើយ ព្រោះភារៈនៃព្រះអង្គទ្រង់ឈ្លាសវៃ ក្នុងឧបាយកល ទើបទ្រង់ត្រាស់បញ្ជាឲ្យពួកអាមាត្យធ្វើនំអំបែងធំ ២ ដុំ ហើយទ្រង់ត្រាស់ ថា "នេះជាព្រះច័ន្ទ, នេះជាព្រះអាទិត្យ" ហើយ ទ្រង់ត្រាស់បញ្ជា ឲ្យធ្វើនំស្ងោរ (នំកូនត្រី) មានសណ្ឋានដូចជាតារា នំគ្រាប់ល្ង ដែលមានអាការៈ ដូចជាដុំនៃវលាហក និងគ្រឿងបង្អែម ដូចជាព្រៃឈើ ទ្រង់ត្រាស់បញ្ជាឲ្យ

ជម្រះព្រះលានហ្លួង ទ្រង់ឲ្យក្រាលកន្ទេលដែលមានប្រហោងខាងលើ ហើយទ្រង់យកគ្រឿងបង្អែម ដែលឡើងប៉ោងហើយៗ ចាកប្រហោងនៃកន្ទេល ទ្រង់ត្រាស់ថា "ទាំងអស់នេះជាអាចម៍ដី" ដូច្នេះហើយ ទ្រង់ត្រាស់បញ្ជាឲ្យធ្វើថ្វាយព្រះទេពី តាមព្រះបំណងៗ ឯព្រះនាងទេវី ទ្រង់បានធ្វើតាមព្រះបំណងហើយ ៗ ការចាញ់ព្រះគភ៌ បានស្ងប់រម្ងាប់ហើយ ៗ ព្រះរាជា ទ្រង់មានព្រះបំណងនឹងទ្រង់ជ្រាបនូវការសម្រេច នៃការចាញ់ព្រះគភ៌ ទើបទ្រង់ត្រាស់សួរអាជីវកឈ្មោះជនសោណៈៗ អាជីវកឈ្មោះជនសោណៈនោះ ក្រាបទូលថ្វាយព្រះរាជានូវពាក្យតែប៉ុណ្ណោះឯង ថា "បពិត្រព្រះមហារាជ ព្រះទេពីនឹងបានព្រះរាជបុត្រដ៏ប្រសើរបរិបូណ៌ដោយព្រះធញ្ញលក្ខណៈ" ដូច្នេះហើយ ក៏ចូលទៅគាល់ព្រះទេវី ម្តងទៀត ក្រាបទូល យ៉ាងនេះថា "បពិត្រព្រះទេវី ព្រះឱរសរបស់ព្រះអង្គ នឹងបានជាព្រះរាជា, កិរិយាជាន់លើព្រះច័ន្ទនិងព្រះអាទិត្យ របស់ព្រះអង្គ គឺជាបុព្វនិមិត្តនៃភារៈនៃព្រះរាជា ១០១ ព្រះអង្គ ក្នុងជម្ពូទ្វីបទាំងមូល នឹងជាអ្នកបម្រើ របស់ព្រះរាជឱរសនោះ, កិរិយាទ្រង់សោយដួងតារា នឹងជាបុព្វនិមិត្ត នៃការធ្វើគត់ដល់ព្រះភាតា ដែលមានព្រះមាតាផ្សេងគ្នា ជាអ្នករួមមតិក ដែលមិនជាទីសព្វព្រះទ័យ, កិរិយាទ្រង់សោយនូវដុំវលាហក នឹងជាបុព្វនិមិត្ត នៃការកាត់ផ្តាច់នូវលទ្ធិខុស

ហើយលើកស្ទួយព្រះពុទ្ធសាសនា, កិរិយាសោយអាចម៍ដី នឹងជាបុព្វនិមិត្ត នៃការផ្សាយនូវព្រះអាជ្ញាទៅក្នុងទីប្រមាណ ១ យោជន៍ខាងក្រោមនៃផែនដី, កិរិយាសោយនូវព្រៃឈើ ពោលគឺព្រៃព្រឹក្សា និង ដងព្រៃ នឹងជាបុព្វនិមិត្ត នៃការផ្សាយនូវព្រះអាជ្ញាទៅ ក្នុងទីមានប្រមាណ ១ យោជន៍ ខាងលើអាកាស" ដូច្នេះ ។ អាជីវកឈ្មោះជនសោណៈនោះ ទៅកាន់ទីប្រមាណ ១០០ យោជន៍អំពីទីនោះហើយ រស់នៅក្នុងទីកន្លែងមួយ ។

ក្នុងកាលក្រោយមក ព្រះអសោកកុមារ ទ្រង់បានស្ថិតនៅក្នុងរាជសម្បត្តិហើយ ទ្រង់ព្រះសណ្ដាប់នូវរឿងរ៉ាវ ទាំងអស់ដែលព្រះមាតាទ្រង់ត្រាស់ប្រាប់ ទើបមានព្រះបំណងចង់ធ្វើនូវសក្ការៈ ដល់អាជីវកឈ្មោះជនសោណៈ ហើយទ្រង់បានបញ្ជូន នូវរាជបុរសទាំងឡាយ ព្រមទាំងគ្រែស្នែងមាសទៅហើយ ។ អាជីវកឈ្មោះជនសោណៈនោះ ត្រូវរាជបុរសទាំងនោះនាំយកមក បានឃើញនូវទីលំនៅ របស់ព្រះអស្សគុត្តត្ថេរ ក្នុងចន្លោះផ្លូវ ទើបគិត ថា "ភូមិប្រទេសនេះ ជាឱកាសជាទីនៅ របស់ពួកបព្វជិតទាំងឡាយ" ដូច្នេះ ទើបចុះអំពីគ្រែស្នែង ដើរទៅកាន់ទីនោះ បានឃើញសត្វទាំងឡាយ មានរាជសីហ៍ និង ខ្លាធំ ជាដើម មិនបានបៀតបៀនគ្នានិងគ្នា ត្រឡប់ទៅជាបានមេត្តាចិត្ត ប្រជុំគ្នាជាពួកក្រុម ក្នុងទីនោះៗ ដោយ

អានុភាពនៃមេត្តា របស់ព្រះថេរៈ ទើបសួរ ថា "សត្វទាំងនេះឈ្មោះអ្វីទៅ ?" ។ ព្រះថេរៈ ត្រួតមើលនូវគុណសម្បត្តិដែលជាបុព្វហេតុ របស់ជនសោណៈនោះ ក៏បានឃើញនូវការស្ដាប់អាយតនកថា អំពីកាលមុន ទើបគិត ថា "នោះឯងជាឧបនិស្ស័យ របស់គេ" ហើយ បានពោល ថា "ម្នាលអ្នកដ៏មានអាយុ សត្វទាំងឡាយនេះ ឈ្មោះថា **អាយតនៈ**" ។ អាជីវកនោះ បានស្ដាប់នូវបទ ថា "**អាយតនៈ**" ហើយ បានញុំាងហិរិនិងឱត្តប្បៈ ឲ្យកើតឡើងហើយ ក៏អង្គុយប្រហោង ។ ព្រះថេរៈ បានឲ្យសំពត់ស្រង់ទឹក ដល់អាជីវកនោះហើយ ។ អាជីវកនោះ បួសហើយ ក្នុងសំណាក់នៃព្រះថេរៈ រៀនកម្មដ្ឋាន ចំរើនវិបស្សនាហើយ ក៏បានសម្រេចព្រះអរហត្ត ។

រឿងពស់ថ្លាន់ មកក្នុងគម្ពីរមហាវង្ស ។

សូម្បីរឿងសត្វប្រចៀវតូច ក្នុងអដ្ឋកថាអដ្ឋសាលី ក៏គប្បីពោល ។

## ( រឿងសត្វប្រចៀវតូច )

(៣៨) បានឮថា ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាម កកុសន្ធៈ មេមាន់មួយ នៅក្បែរនឹងអាសនសាលា ។ មេមាន់នោះ បានស្ដាប់សំឡេងសូត្រធម៌ របស់ភិក្ខុអ្នកចំរើនវិបស្សនាមួយអង្គ កំពុងតែស្វាធ្យាយនូវវិបស្សនាកម្មដ្ឋាន ទើបកំណត់យកនិមិត្ត ក្នុងសំឡេង

ថា "នុំះជាធម៌" ដូច្នេះ ត្រូវសត្វខ្លែងមួយសម្លាប់ ច្យុតហើយ បានទៅកើតជារាជធីតាព្រះនាមថា ឧព្វរី បួសហើយ ក្នុងសំណាក់ នៃនាងបរិព្វាជិកាទាំងឡាយ ។ ក្នុងកាលក្រោយមក នាងចូលទៅកាន់វច្ចកុដិ ឃើញហ្វូងដង្កូវហើយ ក៏បានញ៉ាំងបុឡុវកសញ្ញាឲ្យកើតឡើង បានសម្រេចបឋមឈានហើយ ច្យុតចាកអត្តភាពនោះមកកើត ក្នុងព្រហ្មលោក ច្យុតចាកព្រហ្មលោកនោះហើយ ក៏បានកើតក្នុងត្រកូលសេដ្ឋី មិនយូរប៉ុន្មាន ក៏បានច្យុតហើយ ទៅកើតជាកូនជ្រូកមេ ក្នុងទីក្រុងរាជគ្រឹះ ក្នុងពុទ្ធុប្បាទនេះ ។

ព្រះសាស្តា ទ្រង់ទតព្រះនេត្រឃើញ សត្វជ្រូកមេនោះហើយ ទ្រង់ធ្វើការញញឹម ត្រូវព្រះអានន្ទក្រាបទូលសួរហើយ ទ្រង់ត្រាស់សំដែងរឿងរ៉ាវទាំងអស់ ទ្រង់សំដែងនូវគាថា ក្នុងតណ្ហាវគ្គ នៃធម្មបទ ថា "យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ..."ដូច្នេះជាដើម ។

ចំណែក មេជ្រូកនោះ ច្យុតអំពីអត្តភាពនោះហើយ កើតជារាជធីតា ក្នុងសុវណ្ណភូមិ ច្យុតអំពីនោះហើយ បានទៅកើតក្នុងស្រុកឈ្មោះវនវាសី ច្យុតអំពីនោះហើយ បានទៅកើត ក្នុងក្រុងពារាណសី ច្យុតអំពីនោះហើយ បានទៅកើតជាធីតា របស់អ្នកលក់សេះ ក្បែរកំពង់ឈ្មោះសុប្បារកៈ ច្យុតអំពីនោះហើយ បានទៅកើតជាធីតា របស់នាយនាវា ក្បែរកំពង់ឈ្មោះកាវីរៈ ច្យុតអំពីនោះហើយ ក៏បាន

ទៅកើតជាធីតា នៃឥស្សរជន ក្នុងអនុរាធបុរី ច្យុតអំពីនោះហើយ បានទៅកើតជាធីតា របស់សុមនកុដុម្ពិក៍ ឈ្មោះថាសុមនា ក្នុងស្រុក ភេក្កន្តគ្រាម ក្នុងទិសទក្សិណ នៃអនុរាធបុរីនុ៎ះឯង ។ នាងសុមនា នោះ បានកើត ១២ ជាតិ តាំងអំពីអត្តភាពជាមេមាន់ រហូតដល់ មានអត្តភាពជាធីតារបស់កុដុម្ពិក៍ ដោយប្រការដូច្នេះ ។ ក្នុងពេល ក្រោយមក នាងទៅកាន់ផ្ទះ របស់មហាអាមាត្យ ឈ្មោះថា លកុណ្ដកអតិអម្ពរ នៃព្រះរាជាទ្រង់ព្រះនាមទុដ្ឋគាមិណី ។ ក្នុងគ្រា នោះ ព្រះមហាអតុលត្ថេរ នៅក្នុងកោដិបព្វតមហាវិហារ និមន្ត ទៅបិណ្ឌបាត ក្នុងស្រុកនោះ ឃើញនាងហើយ ហៅភិក្ខុទាំងឡាយ មកប្រាប់ ថា "ម្នាលលោកដ៏មានអាយុ កូនជ្រូកមេ កើតហើយ បានដល់ភាពជាភរិយា របស់មហាអាមាត្យ, រឿងនោះ អស្ចារ្យ មែនហ្ន៎ ! " ។ នាងបានស្ដាប់ពាក្យនោះហើយ ដឹងនូវអត្តភាពក្នុង អតីតៈរបស់ខ្លួនបាន ដោយញាណជាគ្រឿងរលឹកជាតិ ក៏កើតសេចក្ដី សង្វេគតក់ស្លុត បានសុំស្វាមីបួស ក្នុងសំណាក់នៃពួកនាងភិក្ខុនី បានស្ដាប់មហាសតិបដ្ឋានសូត្រ ក្នុងតិស្សមហាវិហារហើយ បានជា សោតាបន្ន ក្នុងកាលក្រោយមក បានស្ដាប់នូវ អាសីវិសោបមសូត្រ ក្នុងកល្លកមហាវិហារ ហើយក៏បានសម្រេច នូវព្រះអរហត្ត ។

រឿងមេមាន់ មកក្នុងអដ្ឋកថាធម្មបទ ។

(៣៩) ការស្តាប់ធម៌ ដែលបុគ្គលបានអប់រំ ដោយល្អហើយ រមែងឲ្យបានសម្រេចនូវព្រះអរហត្ត ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ ក្នុងបញ្ចមវគ្គ នៃតតិយបណ្ណាសកៈ[១] ក្នុងចតុក្កនិបាត អង្គុត្តរនិកាយ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ ថា “ ម្នាលភិក្ខុទាំងឡាយ កាល ( នៃកុសលធម៌ ) ៤ យ៉ាងនេះ កាលបើបុគ្គលចំរើនដោយប្រពៃ ឲ្យប្រព្រឹត្តទៅដោយប្រពៃ រមែងឲ្យដល់នូវការអស់ទៅនៃអាសវៈ ដោយលំដាប់ ។ កាល ៤ យ៉ាង តើដូចម្តេច ? គឺ ការស្តាប់ធម៌តាមកាល ១ ការសាកច្ឆាធម៌តាមកាល ១ ការសំដែងធម៌តាមកាល ១ ការចំរើនវិបស្សនាតាមកាល ១, ម្នាលភិក្ខុទាំងឡាយ កាល ៤ យ៉ាងនេះឯង ។ ល ។ រមែងឲ្យដល់នូវការអស់ទៅនៃអាសវៈទាំងឡាយ ដោយលំដាប់ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភ្លៀងមានតំណក់ដ៏ថ្លោស ធ្លាក់ចុះមកពីលើកំពូលភ្នំ, ទឹកកាលហូរទៅកាន់ទីទំនាប រមែងញ៉ាំងជ្រោះ អូរនិងប្រឡាយនៃភ្នំឲ្យពេញ, លុះជ្រោះ អូរ និងប្រឡាយ នៃភ្នំពេញប្រៀបហើយ, រមែងញ៉ាំងបារាយណ៍តូច ( បឹងតូច ) ឲ្យពេញ, លុះបារាយណ៍តូច ពេញប្រៀបហើយ, រមែងញ៉ាំងបារាយណ៍ធំ ( បឹងធំ ) ឲ្យពេញ, លុះបារាយណ៍ធំពេញហើយ, រមែងញ៉ាំងស្ទឹងតូចឲ្យពេញ, លុះស្ទឹងតូចពេញប្រៀបហើយ, រមែងញ៉ាំង

១_ ត្រៃបិដក ភាគទី ៤២ / ទំព័រទី ៣៥៥ ។

ស្ទឹងធំឲ្យពេញ, លុះស្ទឹងធំពេញប្រៀបហើយ, រមែងញុំាងសមុទ្រសាគរឲ្យពេញ មានឧបមាយ៉ាងណា, ម្នាលភិក្ខុទាំងឡាយ កាលទាំង ៤ យ៉ាងនេះឯង ។ល។ រមែងឲ្យដល់ នូវការអស់ទៅនៃអាសវៈ ដោយលំដាប់ ក៏មានឧបមេយ្យយ៉ាងនោះដែរ " ។

សូត្រទី ៧ ចប់ ។

(៤០) អដ្ឋកថាសត្តមសូត្រនោះ ថា " បទ ថា ' **កាលា** ' នេះ ជាឈ្មោះនៃកុសលធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅ ក្នុងកាលនោះ ៗ គឺ ក្នុងថ្ងៃស្តាប់ធម៌ ៗ កាលទាំងឡាយនោះ ដែលបុគ្គលចំរើន និង ឲ្យប្រព្រឹត្តទៅ ។ ២ បទ ថា ' **អាសវានំ ខយំ** ' បានដល់ ព្រះអរហត្ត " ។

ដីកាសត្តមសូត្រនោះ ថា " ដោយបរមត្ថ ការប្រកបកិច្ចមានភាវនាជាដើម នៃកាលដែលមិនមានប្រាកដជាសភាព រមែងមិនបានសម្រេច ហេតុនោះ ព្រះអដ្ឋកថាចារ្យទើបពោល ថា ' **កាលាតិ តស្មឹ តស្មឹ ។ បេ ។ ឯតំ អធិវចនំ** ' ដូច្នេះ ៗ មែនពិត កុសលធម៌ ដែលបុគ្គលប្រព្រឹត្តព្រមដោយកាល ដែលលោកពោលដោយ **កាល** ស័ព្ទ ក្នុងបទ ថា **កាល** នេះ ព្រោះមិនមានកិច្ចផ្សេងដទៃទៀត " ។

(៤១) អដ្ឋកថាចតុត្ថសូត្រ បញ្ចមវគ្គ ក្នុងទុតិយបណ្ណាសកៈ

តិកនិបាត អង្គុត្តរនិកាយ ថា "បទ ថា 'ថូលផុសិតកេ' គឺ មាន តំណក់ធំ ៗ ក្នុងពាក្យថា 'បព្វតកន្ទរបទរសាខា' នេះ គប្បី ជ្រាបវិនិច្ឆ័យ ដូចតទៅ ÷ ប្រទេសនៃភ្នំណា ត្រូវទឹកដែលបាន ឈ្មោះថា កំ ច្រោះហើយ គឺ ត្រូវទឹកបំផ្លាញហើយ ដែលលោក ហៅថា 'និតម្ពៈខ្លះ នទីនិកុញ្ជៈខ្លះ' ទីប្រទេសនោះ ឈ្មោះថា កន្ទរៈ ៗ ប្រទេសនៃផែនដី, កាលបើភ្លៀងមិនធ្លាក់ រហូតដល់ ៨ ខែ, ក៏បែកក្រហែង, ប្រទេសនោះ ឈ្មោះថា បទរៈ ៗ ជងអូរ តូច ដែលហូរធ្លាក់ទៅកាន់បឹងតូច ឈ្មោះថា សាខា ៗ បឹងតូចៗ (អន្លង់) ឈ្មោះថា កុសុព្ភៈ ៗ បឹងធំ ៗ ឈ្មោះថា មហា-សោព្ភៈ ៗ ស្ទឹងតូច ឈ្មោះថា កុន្នទី ៗ ទន្លេធំមានទន្លេគង្គានិង ទន្លេយមុនាជាដើម ឈ្មោះថា មហានទី " ៗ

ដីកាចតុក្កសូត្រនោះថា "ព្រះអដ្ឋកថាចារ្យពោលថា 'កន្ទរោ' ដូច្នេះ ព្រោះធ្វើអត្ថាធិប្បាយថា 'ប្រទេសនៃភ្នំ ត្រូវទឹកឈ្មោះថា កំ ច្រោះហើយ' ៗ ប្រទេសនៃភ្នំ ដែលប្រជាលោកហៅថា 'និតម្ពោ' ដូច្នេះខ្លះ ព្រោះភាវៈជាប្រទេស ដែលកើតហើយអំពី ទន្លេ ដោយកិរិយាកើតឡើងនៃទឹកតាមទីទំនាប ៗ ដែលលោក ហៅថា 'នទីនិកុញ្ជោ' ដូច្នេះខ្លះ ព្រោះជាដែនកើតមុននៃទន្លេៗ ២ បទថា 'អដ្ឋ មាសេ' មានសេចក្តីថា រហូត ៨ ខែ ដោយ

អំណាចហោមន្តរដូវ និង គិម្ហរដូវ ។ ប្រឡាយទឹកតូច ឈ្មោះថា សាខៈ ព្រោះប្រៀបដូចជាមែក ។ បឹងតូច ឈ្មោះថា កុសុព្ភៈ ព្រោះធ្វើអាទេស ឱ អក្សរជា ឧ អក្សរ ។ ទឹករមែងហូរមកអំពីប្រទេសដែលខ្ពស់ ពួដីខាងលើ រមែងជក់នៅ និង រហូរទៅ ក្នុងជលាល័យណា, ជលាល័យនោះ ឈ្មោះថា កុសុព្ភៈ គឺ បឹងតូច ។ ស្ទឹងតូចដែលហូរចេញមក អំពីជើងនៃបព៌តជាដើម ឈ្មោះថា ស្ទឹងតូច " ។

(៤២) ក៏បុគ្គលណា មិនស្តាប់ធម៌ដោយគោរព, បុគ្គលនោះ ឈ្មោះថា រមែងប្រតិបត្តិ ដើម្បីសេចក្តីសាបសូន្យទៅនៃសាសនា, ចំណែក បុគ្គលណា ស្តាប់ធម៌ដោយគោរព, បុគ្គលនោះ ឈ្មោះថា រមែងប្រតិបត្តិ ដើម្បីសេចក្តីមិនសាបសូន្យទៅនៃសាសនា ។ ដោយហេតុនោះ ក្នុងបឋមវគ្គ ចតុត្ថបណ្ណាសកៈ បញ្ចកនិបាត[១] អង្គុត្តរនិកាយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា " ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ រមែងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ? ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ ក្នុងព្រះសាសនានេះ មិនស្តាប់ធម៌ដោយគោរព ១ មិនរៀនធម៌ដោយគោរព ១ មិនទ្រទ្រង់ (ចាំទុក) ធម៌ ដោយគោរព ១ មិនបាន

១_ ត្រៃបិដក ភាគទី ៤៥ / ទំព័រទី ៩៥ ។

ពិចារណាសេចក្តីនៃធម៌ ដែលខ្លួនទ្រទ្រង់ហើយដោយគោរព ១ ដឹងសេចក្តី ដឹងធម៌ហើយ មិនប្រតិបត្តិធម៌តាមសមគួរដល់ធម៌ ដោយគោរព ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៥ យ៉ាងនេះឯង រមែងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ " ។

ចតុត្ថសូត្រ ចប់ ។

អដ្ឋកថាចតុត្ថសូត្រនោះ ថា " ពាក្យថា ' **ន សក្កច្ចំ ធម្មំ សុណន្តិ** ' មានសេចក្តីថា ជាអ្នកមិនផ្ទៀងត្រចៀកចុះ ធ្វើកិច្ចការដែលធ្វើល្អហើយស្តាប់ ។ បទថា ' **ន បរិយាបុណន្តិ** ' មានសេចក្តីថា សូម្បីរៀនធម៌តាមដែលស្តាប់ហើយ ក៏រមែងមិនរៀនដោយគោរពដែរ " ។

ពណ៌នាអំពីការស្តាប់ធម៌តាមកាល ចប់ ។

(៤៣) ព្រះដ៏មានព្រះភាគទ្រង់ត្រាស់មង្គល ៥ ប្រការ គឺ÷ សេចក្តីគោរព ១ ការប្រព្រឹត្តិបន្ទាបខ្លួន ១ សេចក្តីសន្តោស ១ ភាពជាអ្នកមានកតញ្ញូ ១ ការស្តាប់ធម៌តាមកាល ១ ដោយគាថានេះ ដោយប្រការដូច្នេះឯង ។ សូម្បីពាក្យជាគាថានេះ ក៏ជាបថ្យាវត្ត ។ ក៏អាចារ្យពួកខ្លះ ពោល ថា " ក្នុងបាទទី ៣ ន គណៈថា ' មសរ ' ដូច្នេះ ព្រោះព្រះបូរាណាចារ្យពោលហើយថា ' បញ្ចមំ លហុ សព្វត្ថ ( អក្សរទី ៥ ក្នុងបាទទាំងពួង

ជា លហុ ) ”។ ដូចជា ក្នុងបាទគាថា ថា “សព្វត្ថ សោត្ថឹ គច្ឆន្តិ” នេះ ព្រះដ៏មានព្រះភាគ ទ្រង់ប្រាថ្នាអក្សរទី ៥ ជា គរុ ព្រោះចុះនិគ្គហិតអាគម យ៉ាងណាមិញ, សូម្បីក្នុងគាថា ថា “ កាលេន ធម្មស្សវនំ ” នេះ ក៏យ៉ាងដូច្នោះដែរ ព្រះដ៏មានព្រះភាគទ្រង់ប្រាថ្នាអក្សរទី ៥ ជា គរុ ព្រោះធ្វើ ស អក្សរត្រួតគ្នា ២ តួ ។ ក៏បើកាន់យកសេចក្តីដូច្នោះ ក៏កើតទៅជា ភ គណៈ ថា ‘មស្សវ’ ។ ពាក្យថា “ បញ្ចមំ លហុ សព្វត្ថ ( អក្សរទី ៥ ក្នុងបាទទាំងពួងជា លហុ ) ”នេះ លោកមិនបានពោល ក្នុងវុត្តោទយ្យទ្បើយ ។

ក៏កាលបើអាចារ្យពោល ថា “ បដ្ឋាវេ សព្វគេ បាទេ (ក្នុងបដ្ឋាវន័យ កាលបើបាទមានគរុសុទ្ធ) ” ដូច្នេះ ទើបប្រាថ្នាបដ្ឋាវន័យដែលជាបឋម ជា គរុ ទាំងអស់ ក្នុងព្រឹទ្ធិទាំងពួង, ក្នុងបាទគាថាទី ៣ នោះ អក្សរទី ៥ ជា លហុ នឹងមានមកពីណា ? ។ ក្នុងបដ្ឋាវន័យនេះ ថា “ មោ មោ គោ គោ វិជ្ជុម្មាលា ( ម គណៈ ២ ពួកក្តី គរុ ២ តួក្តី មានក្នុងព្រឹទ្ធិណា, ព្រឹទ្ធិណានោះ ឈ្មោះថា វិជ្ជុម្មាលា ) ដូច្នេះជាដើម ជានិទស្សនៈ ។

ព្រោះហេតុនោះ ពាក្យថា “ បញ្ចមំ លហុ សព្វត្ថ ” នេះមិនគប្បីជឿ ដោយសេចក្តីជាសារៈទ្បើយ ។

ពណ៌នាសេចក្តីនៃគាថាទី ៧ ចប់ ។

## ពណ៌នាអំពីសេចក្ដីនៃគាថាទី៨

~~~

(៤៤) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ៨ ដូចតទៅនេះ ÷ កិរិយាអត់ធន់ ឈ្មោះថា **ខន្តិ** ៗ ភាវៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ ឈ្មោះថា **សោវចស្សតា** ៗ កិរិយាសំឡឹងមើលនូវបុគ្គលទាំងឡាយ ដែលមានកិលេសស្ងប់រម្ងាប់ហើយ ឈ្មោះថា **កិរិយាបានឃើញនូវសមណៈទាំងឡាយ** ៗ

បទ ថា "**កាលេន**" គឺ ក្នុងកាលដែលដល់ភាពជាកាលដ៏សមគួរ ៗ ការសន្ទនា គឺ កិរិយាពោលជាមួយគ្នា នូវធម៌ ឈ្មោះថា **ធម្មសាកច្ឆា** ៗ

បទ ថា "**ឯតំ**" មានសេចក្ដីថា ម្នាលទេវតា អ្នកចូរប្រកាន់យក ថា 'សេចក្ដីអត់ធន់ ១ ភាវៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ ១ កិរិយាបានឃើញ នូវសមណៈទាំងឡាយ ១ ការសន្ទនាធម៌ ១, កម្មទាំង ៤ ប្រការ មានសេចក្ដីអត់ធន់ជាដើមនេះ ជាមង្គលដ៏ឧត្ដម' ៗ សេចក្ដីសង្ខេប ក្នុងគាថានេះ មានតែប៉ុណ្ណោះ ៗ ចំណែក សេចក្ដីពិស្ដារ ក្នុងគាថានេះ ដូចតទៅនេះ ÷

\* \* \*
~~~

---

(៤៥) លោកពោលហើយ ក្នុងអដ្ឋកថា ថា " ភិក្ខុដែលប្រកប ដោយសេចក្ដីអត់ធន់ គឺ សេចក្ដីអត់ទ្រាំណា រមែងជាអ្នកមិនមានអាការៈខុសប្លែក ប្រៀបដូចជាមិនបានឮនិង ប្រៀបដូចជាមិនបានឃើញ នូវបុគ្គលដែលជេរប្រទេច ដោយអក្កោសវត្ថុ ១០ ប្រការ ឬនូវបុគ្គលអ្នកបៀតបៀន ដោយការសម្លាប់ និងដោយគ្រឿងចងជាដើម ប្រៀបដូចជាខន្តិវាទីតាបសដូច្នោះ រមែងធ្វើទុកក្នុងចិត្ត ដោយភាពជាអ្នកចំរើន ព្រោះមិនមានសេចក្ដីខុសប្រែលែងជាងនោះទៅទៀត ដូចជាព្រះបុណ្ណត្ថេរ ដ៏មានអាយុ យ៉ាងដូច្នោះ, សេចក្ដីអត់ធន់ គឺ សេចក្ដីអត់ទ្រាំនោះ ឈ្មោះថា ខន្តិ " ។

(៤៦) បណ្ដាឧទាហរណ៍ទាំង ២ រឿងនោះ ខ្ញុំនឹងពណ៌នារឿងខន្តិវាទីតាបស ដូចតទៅនេះ ÷

## ( រឿងខន្តិវាទីតាបស )

ក្នុងអតីតកាល ព្រះពោធិសត្វកើតជាព្រាហ្មណ៍ឈ្មោះ កុណ្ឌៈ ក្នុងទីក្រុងពារាណសី បួសជាតាបស នៅក្នុងហិមវន្តប្រទេស អស់កាលដ៏យូរ បានទៅកាន់ទីក្រុងពារាណសី ដើម្បីប្រយោជន៍ដល់ការសេពនូវរសជាតិប្រៃនិងជូរ មានសេនាបតីទំនុកបំរុងហើយនៅក្នុងព្រះរាជឧទ្យាន ។

ក្រោយមក ក្នុងថ្ងៃមួយ ព្រះរាជាទ្រង់ព្រះនាមថា កលាពុ ទ្រង់សោយសុរាស្រវឹងខូចព្រះសតិ មានពួកអ្នករបាំចោមរោម ហើយ ទ្រង់ស្តេចយាងទៅកាន់ព្រះឱទ្យាន ទ្រង់បានព្រះបន្ទំដាក់ព្រះសិរសី លើភ្លៅរបស់ស្ត្រីដែលជាទីស្រឡាញ់ និងជាទីពេញព្រះទ័យម្នាក់ ។ គ្រានោះ ពួកស្រីឯទៀត នាំគ្នាទៅចោលព្រះរាជាដើរទៅក្នុងឱទ្យាន បានឃើញព្រះពោធិសត្វគង់នៅ ក្រោមគល់សាលព្រឹកដែលមានផ្ការីកស្គុសស្គាយ ទើបថ្វាយបង្គំព្រះពោធិសត្វហើយអង្គុយស្តាប់ធម៌ ។ ព្រះរាជា ទ្រង់តើនពីព្រះបន្ទំហើយកាលទ្រង់ទតព្រះនេត្រ មិនឃើញស្រីទាំងនោះ ទើបទ្រង់ព្រះពិរោធហើយទ្រង់បានកាន់ព្រះខ័ន ស្តេចយាងទៅហើយ ។ ពេលនោះស្រីដែលជាទីពេញព្រះទ័យ ដ៏ក្រៃលែងម្នាក់ បានទាញយកព្រះខ័នអំពីព្រះហស្ត របស់ព្រះអង្គចេញ ។ ព្រះរាជា ទ្រង់ត្រាស់សួរថា " នែសមណៈ តើអ្នកមានប្រក្រតីពោល យ៉ាងដូចម្តេច ? " ។

តាបស. បពិត្រមហារាជ អាត្មាមានប្រក្រតីពោលខន្តី ។

ព្រះរាជា. ឈ្មោះថា ខន្តិនុំះ គឺជាអ្វី ? ។

តាបស . គឺសេចក្តីមិនក្រោធខឹង ចំពោះបុគ្គលដទៃ ដែលជេរប្រទេច វាយប្រហារ និង មើលងាយមើលថោក ។

ព្រះរាជាទ្រង់ត្រាស់ថា " ឥឡូវនេះ អញនឹងឃើញនូវភាវៈ

នៃលោកម្ចាស់ ជាអ្នកមានសេចក្ដីអត់ធន់ ” ដូច្នេះ ទ្រង់ត្រាស់ឲ្យហៅអ្នកសម្លាប់ចោរមកហើយ ទ្រង់ត្រាស់ថា “ ចូរអ្នកអូសតាបសអាក្រក់នេះចេញ ហើយផ្ដួលទៅលើផែនដី យករំពាត់ដែលមានបន្លាមក ហើយឲ្យនូវការវាយប្រហារបាន ២ ពាន់ដង ក្នុងទីទាំង ៤ កន្លែង គឺ ខាងមុខ ខាងក្រោយ និងក្នុងទីទាំងសងខាង ” ។ អ្នកសម្លាប់ចោរនោះបានធ្វើហើយ តាមព្រះរាជបញ្ជា ។ ព្រះរាជាទ្រង់ត្រាស់សួរទៀតថា “ តើលោកម្ចាស់ មានប្រក្រតីពោល យ៉ាងដូចម្ដេច ? ” ។ តាបស ថ្វាយព្រះពរថា “ បពិត្រព្រះមហារាជអាត្មាភាពមានប្រក្រតីពោលការអត់ធន់, ក៏ព្រះអង្គទ្រង់សម្គាល់ថា ‘ សេចក្ដីអត់ធន់ មាននៅក្នុងចន្លោះស្បែក របស់អាត្មាភាព ឬ ? ’ ខន្តិនេះ មិនមាននៅក្នុងចន្លោះស្បែកនេះទេ, តែខន្តិនេះ ស្ថិតនៅក្នុងចន្លោះនៃហឫទ័យ ដែលជ្រៅ របស់អាត្មាភាពឯណោះ ” ។ ព្រះរាជា ទ្រង់ត្រាស់ថា “ចូរអ្នកកាត់ដៃជើង របស់តាបសនេះ”។ បុរសនោះ បានធ្វើហើយ តាមព្រះរាជបញ្ជា ។ ព្រះរាជា ទ្រង់បានត្រាស់សួរជាថ្មីម្ដងទៀត ។ តាបសថ្វាយព្រះពរថា “ បពិត្រព្រះមហារាជ អាត្មាភាព មានប្រក្រតីពោលខន្តិ, ក៏ព្រះអង្គទ្រង់សម្គាល់ថា ‘ ខន្តិមាននៅ ត្រង់ចុងម្រាមដៃនិងជើង របស់អាត្មាភាពឬ ? ’ តែខន្តិនុ៎ះ មិនមែនមាននៅ ត្រង់ចុងដៃជើងនេះទេ ” ។

ព្រះរាជាទ្រង់ត្រាស់ ថា "ចូរអ្នកកាត់ត្រចៀកនិងច្រមុះ របស់តាបសនេះចេញ"ៗ បុរសនោះ បានធ្វើហើយតាមព្រះរាជបញ្ជា ៗ ព្រះរាជាទ្រង់ត្រាស់សួរហើយ យ៉ាងដូច្នោះឯង ម្តងទៀត, កាលបើខន្តិវាទីតាបសនោះ ថ្វាយព្រះពរដោយន័យ ដូចបានពោលមកហើយ, ទើបទ្រង់ព្រះពិរោធ ទ្រង់ធាក់ចំកណ្តាលដើមទ្រូង នៃព្រះពោធិសត្វ ដោយកែងព្រះបាទ ហើយស្តេចយាងគេចចេញទៅ ត្រូវផែនដីស្រូបត្រង់ទ្វារឧទ្យាននុ៎ះឯង បានទៅកើតក្នុងអវីចិនរកហើយ ៗ ក៏កាលបើព្រះរាជានោះ គ្រាន់តែស្តេចយាងគេចចេញទៅប៉ុណ្ណោះ, សេនាបតី ក៏បានជូតលោហិត របស់ព្រះពោធិសត្វ ឲ្យព្រះពោធិសត្វគង់ដោយសន្សឹមៗ ហើយពោលយ៉ាងនេះ ថា "បពិត្រលោកម្ចាស់ដ៏ចំរើន បើលោកម្ចាស់ មានបំណងនឹងក្រោធខឹង ក៏គប្បីក្រោធខឹង ចំពោះព្រះរាជាអ្នកធ្វើសេចក្តីខុស ក្នុងលោកម្ចាស់តែម្នាក់គត់ប៉ុណ្ណោះចុះ, សូមកុំគប្បីក្រោធខឹង ចំពោះពួកអ្នកដទៃឡើយ"ៗ តាបសបានស្តាប់ នូវពាក្យនោះហើយ ទើបពោលគាថានេះ ក្នុងខន្តិវាទិជាតក[១] ក្នុងទុតិយវគ្គ ចតុក្កនិបាត ថា ÷

(៤៧) "ព្រះរាជាណា កាត់ដៃទាំងពីរក្តី កាត់ជើងទាំងពីរក្តី កាត់ត្រចៀកនិងច្រមុះក្តី របស់អាត្មាភាព,

---

១_ ត្រៃបិដក ភាគទី ៥៨ / ទំព័រទី ១៩៩ ។

> សូមឲ្យព្រះរាជានោះ ទ្រង់មានព្រះជន្មយឺនយូរ, ពួកអ្នកប្រាជ្ញដូចយ៉ាងអាត្មាភាព មិនក្រោធខឹងឡើយ "។

បណ្ដាបទទាំងនោះ បទ ថា " មារិសា " មានសេចក្ដីថា ពួកបណ្ឌិតអ្នកប្រកប ដោយកម្លាំងគឺខន្ដី ប្រាកដស្មើដោយអាត្មារមែងមិនក្រោធខឹង ថា ' បុរសនេះ បានជេរប្រទេច វាយប្រហារ មើលងាយមើលថោក កាត់នូវអាត្មាអញ "។ តាបសលុះពោលយ៉ាងនេះហើយ ក៏បានធ្វើកាលៈ ក្នុងទីនោះភ្លាម ក្នុងថ្ងៃនោះឯង ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ ក្នុងជាតកនោះ ថា ÷

> " សមណៈជាអ្នកសំដែងនូវខន្ដី បានមានហើយក្នុងអតីតកាល, ព្រះបាទកាសី ទ្រង់បានត្រាស់បញ្ជាឲ្យសម្លាប់សមណៈនោះ អ្នកតាំងនៅក្នុងខន្ដី "។

អដ្ឋកថាជាតកនោះ ថា " បណ្ដាបទទាំងនោះ បទថា ' អតីតមទ្ធានេ ' គឺ ក្នុងរយៈពេល ដែលកន្លងហួសមកហើយ ។ បទ ថា ' ខន្ដិទីបនោ ' គឺ ជាអ្នកពោលសរសើរនូវខន្ដី ពោលគឺសេចក្ដីអត់ធ្មត់ ។ បទ ថា ' អឆេទយិ ' គឺ ទ្រង់ត្រាស់បញ្ជាឲ្យសម្លាប់ហើយ "។

(៤៨) ក្នុង ២ បទ ថា "អាយស្មា បុណ្ណត្ថេរោ" គប្បីសំដែងឧទាហរណ៍ ដូចតទៅនេះ ÷

បានឮថា កុដុម្ពីក៏ឈ្មោះបុណ្ណៈ ក្នុងទីក្រុងសុនាបរន្តជនបទ ទៅកាន់ទីក្រុងសាវត្ថី ដើម្បីនឹងលក់ដូរតាមរទេះ បានស្តាប់ព្រះធម៌ទេសនា របស់ព្រះសាស្តាហើយ ក៏មានគោលបំណងចង់បួស ទើបឲ្យគេទៅហៅនាយភណ្ឌាគារិក មកប្រាប់ ថា "ចូរអ្នកឲ្យទ្រព្យទាំងអស់នេះ ដល់ប្អូនប្រុសរបស់ខ្ញុំ ដែលមានឈ្មោះថា ចូឡបុណ្ណៈ" ដូច្នេះហើយ ក៏បានប្រគល់ទ្រព្យទាំងអស់ទៅឲ្យ ហើយបានបួស ក្នុងសំណាក់ នៃព្រះសាស្តា ជាអ្នកមានចិត្តផ្តោតចំពោះកម្មដ្ឋាន ។

គ្រានោះ កាលបើព្រះបុណ្ណត្ថេរនោះ នៅក្នុងក្រុងសាវត្ថី ធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាន, កម្មដ្ឋាននោះ ក៏មិនប្រាកដ ។ ពេលនោះ ព្រះបុណ្ណៈ គិត ថា "ជនបទនេះ មិនជាទីសប្បាយ" ហើយមានបំណងចង់និមន្តទៅ កាន់ទីក្រុងសុនាបរន្តជនបទតែប៉ុណ្ណោះ ទើបបានចូលទៅគាល់ព្រះសាស្តា ហើយក្រាបទូលសុំនូវព្រះឱវាទ ។

ព្រះសាស្តា ទ្រង់បានប្រទាន នូវឱវាទ ដល់ព្រះបុណ្ណៈនោះ ដោយន័យ ដែលបានពោលមកហើយ ក្នុងបុណ្ណោវាទសូត្រ ក្នុងបញ្ចមវគ្គ ឧបរិបណ្ណាសកៈ និង ក្នុងចតុត្ថវគ្គ ទុតិយបណ្ណាសកៈ នៃសឡាយតនវគ្គ[១] ហើយទើបទ្រង់ត្រាស់សួរ ថា "តើអ្នកនឹងនៅ

១_ ត្រៃបិដក ភាគទី ៣៥ / ទំព័រទី ១៣៥ ។

ក្នុងជនបទណា ? ” ។ ព្រះបុណ្ណៈ ក្រាបទូល ថា “ បពិត្រព្រះអង្គដ៏ចំរើន មានជនបទ ១ ឈ្មោះសុនាបរន្តៈ, ខ្ញុំព្រះអង្គនឹងនៅក្នុងសុនាបរន្តជនបទនោះ ” ។ គ្រានោះ ព្រះសាស្ដា ទ្រង់ជ្រាបភាវៈនៃព្រះបុណ្ណត្ថេរនោះ ជាអ្នកប្រកបព្រម ដោយអធិវាសនខន្តីហើយទើបទ្រង់ត្រាស់ឲ្យព្រះបុណ្ណត្ថេរបន្លឺនូវសីហនាទ ក្នុងស្ថានទីទាំង ៧ កន្លែង ទ្រង់បានប្រទាន នូវសាធុការ ដល់ព្រះបុណ្ណត្ថេរនោះ ហើយទ្រង់អនុញ្ញាត នូវការនិមន្តទៅ ក្នុងសុនាបរន្តជនបទនោះ ។

(៤៩) ក្នុងបុណ្ណោវាទសូត្រនោះ មានបាលី ដូចតទៅនេះ ÷ ព្រះដ៏មានបុណ្យទ្រង់ត្រាស់សួរថា “ ម្នាលបុណ្ណៈ ពួកមនុស្សនៅក្នុងសុនាបរន្តជនបទ កាចៗណាស់, ម្នាលបុណ្ណៈ ពួកមនុស្សនៅក្នុងសុនាបរន្តជនបទ រឹងរូសណាស់, ម្នាលបុណ្ណៈ បើពួកមនុស្សក្នុងសុនាបរន្តជនបទ នឹងជេរប្រទេចអ្នក, ម្នាលបុណ្ណៈ តើអ្នកនឹងមានគំនិតដូចម្ដេច ក្នុងដំណើរនោះ ? ” ។

ព្រះបុណ្ណៈបានក្រាបទូលថា “ បពិត្រព្រះអង្គដ៏ចំរើន បើពួកមនុស្សក្នុងសុនាបរន្តជនបទ នឹងជេរប្រទេច នូវខ្ញុំព្រះអង្គ ៗ នឹងមានគំនិត ក្នុងដំណើរនោះ យ៉ាងនេះថា ‘ ពួកមនុស្សទាំងឡាយក្នុងសុនាបរន្តជនបទនេះ ស្រួលដែរ, ពួកមនុស្សទាំងឡាយ ក្នុងសុនាបរន្តជនបទនេះ ស្រួលល្អដែរ, ព្រោះថា មនុស្សទាំងអម្បាល

នេះ មិនឲ្យនូវការប្រហារ ដល់ខ្ញុំព្រះអង្គ ដោយបាទដៃ' បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ នឹងមានគំនិត ក្នុងដំណើរនុ៎ះ យ៉ាងនេះឯង, បពិត្រព្រះសុគត ខ្ញុំព្រះអង្គ នឹងមានគំនិត ក្នុងដំណើរនុ៎ះ យ៉ាងនេះឯង "ៗ

ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា "ម្នាលបុណ្ណៈ ក៏បើពួកមនុស្សក្នុងសុនាបរន្តជនបទ នឹងឲ្យនូវការប្រហារ ដល់អ្នក ដោយបាទដៃ, ម្នាលបុណ្ណៈ តើអ្នកនឹងមានគំនិត ក្នុងដំណើរនោះ យ៉ាងដូចម្តេច ? "ៗ

ព្រះបុណ្ណត្ថេរ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន បើពួកមនុស្សក្នុងសុនាបរន្តជនបទ នឹងឲ្យនូវការប្រហារ ដល់ខ្ញុំព្រះអង្គ ដោយបាទដៃ, ខ្ញុំព្រះអង្គនឹងមានគំនិត ក្នុងដំណើរនោះ យ៉ាងនេះថា 'ពួកមនុស្សក្នុងសុនាបរន្តជនបទនេះ ស្រួលដែរ, ពួកមនុស្សក្នុងសនាបរន្តជនបទនេះ ស្រួលល្អដែរ, ព្រោះថា ពួកមនុស្សទាំងអម្បាលនេះ មិនឲ្យនូវការប្រហារ ដល់ខ្ញុំព្រះអង្គ ដោយដុំដីទេ' បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងមានគំនិត ក្នុងដំណើរនុ៎ះ យ៉ាងនេះឯង, បពិត្រព្រះសុគត ខ្ញុំព្រះអង្គនឹងមានគំនិតក្នុងដំណើរនុ៎ះ យ៉ាងនេះឯង "ៗ

ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា "ម្នាលបុណ្ណៈ ក៏បើពួក

មនុស្សក្នុងសុនាបរន្តជនបទ នឹងប្រហារអ្នក ដោយដុំដី, តើអ្នកនឹងមានគំនិត យ៉ាងដូចម្ដេចវិញ ក្នុងដំណើរនោះ ? ” ។

ព្រះបុណ្ណត្ថេរ ក្រាបទូលថា “ បពិត្រព្រះអង្គដ៏ចំរើន ក៏បើពួកមនុស្សក្នុងសុនាបរន្តជនបទ នឹងប្រហារខ្ញុំព្រះអង្គ ដោយដុំដី, ខ្ញុំព្រះអង្គ នឹងមានគំនិត ក្នុងដំណើរនោះ យ៉ាងនេះថា ‘ ពួកមនុស្សក្នុងសនាបរន្តជនបទនេះ ស្រួលដែរ, ពួកមនុស្សក្នុងសនាបរន្ត-ជនបទនេះ ស្រួលល្អដែរ, ព្រោះថា មនុស្សទាំងអម្បាលនេះ នឹងមិនប្រហារនូវខ្ញុំព្រះអង្គ ដោយដំបងទេ ’ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ នឹងមានគំនិត ក្នុងដំណើរនេះ យ៉ាងនេះឯង, បពិត្រព្រះសុគត ខ្ញុំព្រះអង្គ នឹងមានគំនិត ក្នុងដំណើរនេះ យ៉ាងនេះឯង ” ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា “ ម្នាលបុណ្ណៈ ក៏បើពួកមនុស្សក្នុងសុនាបរន្តជនបទ នឹងប្រហារអ្នក ដោយដំបង, តើអ្នកនឹងមានគំនិត យ៉ាងដូចម្ដេចវិញ ក្នុងដំណើរនោះ ? ” ។

ព្រះបុណ្ណត្ថេរ ក្រាបទូលថា “ បពិត្រព្រះអង្គដ៏ចំរើន ក៏បើពួកមនុស្សក្នុងសុនាបរន្តជនបទ នឹងប្រហារខ្ញុំព្រះអង្គ ដោយដំបង, ខ្ញុំព្រះអង្គ នឹងមានគំនិត ក្នុងដំណើរនោះ យ៉ាងនេះថា ‘ ពួកមនុស្សក្នុងសនាបរន្តជនបទនេះ ស្រួលដែរ, ពួកមនុស្សក្នុងសនាបរន្ត-ជនបទនេះ ស្រួលល្អដែរ, ព្រោះថា មនុស្សទាំងអម្បាលនេះ នឹង

មិនប្រហារ នូវខ្ញុំព្រះអង្គ ដោយគ្រឿងសស្ត្រាទេ ’ បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គ នឹងមានគំនិតក្នុងដំណើរនុ៎ះ យ៉ាងនេះឯង, បពិត្រព្រះសុគត ខ្ញុំព្រះអង្គ នឹងមានគំនិត ក្នុងដំណើរនុ៎ះ យ៉ាងនេះឯង ” ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរ ថា “ម្នាលបុណ្ណៈ ក៏បើពួកមនុស្សក្នុងសុនាបរន្តជនបទ នឹងប្រហារអ្នក ដោយគ្រឿងសស្ត្រា, តើអ្នកនឹងមានគំនិត ដូចម្តេចវិញ ក្នុងដំណើរនេះ ? ” ។

ព្រះបុណ្ណត្ថេរ ក្រាបទូល ថា “ បពិត្រព្រះអង្គដ៏ចំរើន ក៏បើពួកមនុស្សក្នុងសុនាបរន្តជនបទ នឹងប្រហារខ្ញុំព្រះអង្គ ដោយគ្រឿងសស្ត្រា, ខ្ញុំព្រះអង្គ នឹងមានគំនិត ក្នុងដំណើរនោះ យ៉ាងនេះថា ‘ ពួកមនុស្សក្នុងសុនាបរន្តជនបទនេះ ស្រួលដែរ, ពួកមនុស្សក្នុងសុនាបរន្តជនបទនេះ ស្រួលល្អដែរ, ព្រោះថា មនុស្សទាំងអម្បាលនេះ នឹងមិនប្រហារជីវិតខ្ញុំព្រះអង្គ ដោយគ្រឿងសស្ត្រាដ៏មុតទេ ’ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ នឹងមានគំនិត ក្នុងដំណើរនុ៎ះ យ៉ាងនេះឯង, បពិត្រព្រះសុគត ខ្ញុំព្រះអង្គ នឹងមានគំនិត ក្នុងដំណើរនុ៎ះ យ៉ាងនេះឯង ” ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា “ ម្នាលបុណ្ណៈ ក៏បើពួកមនុស្សក្នុងសុនាបរន្តជនបទ នឹងយកគ្រឿងសស្ត្រាដ៏មុត មកផ្តាច់

ជីវិតរបស់អ្នក, ម្នាលបុណ្ណៈ តើអ្នកនឹងមានគំនិត យ៉ាងដូចម្ដេចវិញ ក្នុងដំណើរនុ៎ះ ? ” ។

ព្រះបុណ្ណត្ថេរ ក្រាបទូល ថា “បពិត្រព្រះអង្គដ៏ចំរើន បើពួកមនុស្សក្នុងសុនាបរន្តជនបទ នឹងយកគ្រឿងសស្ត្រាដ៏មុត មកផ្ដាច់ជីវិត របស់ខ្ញុំព្រះអង្គ, ខ្ញុំព្រះអង្គនឹងមានគំនិត ក្នុងដំណើរនោះយ៉ាងនេះ ថា ‘មានមែនពិត, ពួកសាវ័ក របស់ព្រះមានបុណ្យដែលនឿយណាយ ធុញទ្រាន់ ខ្ពើមឆ្អើម ចំពោះកាយនិងជីវិតរមែងស្វែងរកនូវគ្រឿងសស្ត្រាសម្រាប់ប្រហារជីវិត, គ្រឿងសស្ត្រាសម្រាប់ប្រហារជីវិតនេះនោះ មិនបាច់ស្វែងរកឡើយ ខ្ញុំព្រះអង្គបានហើយ’ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ នឹងមានគំនិតក្នុងដំណើរនុ៎ះ យ៉ាងនេះឯង, បពិត្រព្រះសុគត ខ្ញុំព្រះអង្គនឹងមានគំនិត ក្នុងដំណើរនុ៎ះ យ៉ាងនេះឯង ” ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា “ម្នាលបុណ្ណៈ ប្រពៃហើយ ប្រពៃហើយ, ម្នាលបុណ្ណៈ អ្នកប្រកប ដោយសេចក្ដីស្ងប់រម្ងាប់ គឺសេចក្ដីអត់ធន់នេះ អាចនឹងនៅ ក្នុងសុនាបរន្តជនបទបាន, ម្នាលបុណ្ណៈ ចូរអ្នកសម្គាល់ នូវកាលដ៏គួរ (នឹងទៅ) ក្នុងកាលឥឡូវនេះចុះ” ។

(៥០) អដ្ឋកថាបុណ្ណោវាទសូត្រនោះ ថា “បណ្ដាបទទាំង

នោះ បទថា 'ចណ្ឌា' បានដល់ កាចសាហាវ គឺ អាក្រក់ ។ បទថា 'ផរុសា' បានដល់ រឹងរូស ។ បទថា 'អក្កោសិស្សន្តិ' មានសេចក្តីថា នឹងជេរប្រទេច ដោយគ្រឿងជេរ ១០ ប្រការ ។ បទថា 'បរិភាសិស្សន្តិ' បានដល់ នឹងគម្រាមកំហែងថា 'ឈ្មោះថា សមណៈ យ៉ាងដូចម្តេច, ពួកយើងនឹងធ្វើ នូវកម្មយ៉ាងនេះមួយ យ៉ាងនេះមួយ ដល់អ្នក ។ បទថា 'ឯវមេត្ថ' មានសេចក្តីថា ខ្ញុំព្រះអង្គ នឹងមានគំនិត ក្នុងដំណើរនុ៎ះ យ៉ាងនេះឯង ។ បទថា 'ទណ្ឌេន' គឺ ដោយដំបងពេលីប្រវែង ៤ ហត្ថ ឬ ដោយអន្លង់ ដែលមានថ្នាំង ។ បទថា 'សត្ថេន' គឺ ដោយគ្រឿងសស្ត្រា ដែលមានមុខ មុតតែម្ខាងជាដើម ។ បទថា 'សត្ថហារកំ' មានសេចក្តីថា រមែងស្វែងរកគ្រឿងសស្ត្រា ដែលនឹងនាំយកជីវិតទៅ ។ ព្រះថេរៈសំដៅយក នូវការស្វែងរកគ្រឿងសស្ត្រា ដែលនឹងនាំចេញ (នូវជីវិត) របស់ពួកភិក្ខុដែលបានស្តាប់ នូវអសុភកថា ក្នុងរឿងនៃតតិយបារាជិក ហើយខ្ពើមឆ្អើម ចំពោះអត្តភាព ទើបបានពោលហើយនូវពាក្យនេះ ។ សេចក្តីអត់ធន់គប្បីជ្រាប ថា 'ទមៈ' ក្នុងបទ ថា 'ទមុបសមេន' នេះ ។ ពាក្យថា 'ឧបសមៈ' គឺជាពាក្យវេវចនៈ របស់ពាក្យថា ទមៈ នោះឯង " ។

(៥១) ដីកាសឡាយតនវគ្គថា " បទថា 'ទុដ្ឋា' គឺ ជា

អ្នកក្រោធខឹង ។ ក៏ពួកមនុស្សទាំងនោះ ព្រះអដ្ឋកថាចារ្យពោលថា 'ជាអ្នកកាចសាហាវ' ព្រោះជាអ្នកត្រូវទោសៈប្រទូសរ៉ាយហើយ ។ បទថា 'កិព្វិសា' គឺ លាមក ។ បទថា 'ផរុសា' មានសេចក្តីថា ឈ្មោះថាជាអ្នកអាក្រក់ ព្រោះមិនមានសេចក្តីស្រឡាញ់ដោយអំណាចសេចក្តីចូលចិត្ត សូម្បីត្រឹមតែបន្តិចឡើយ ម្យ៉ាងទៀត ឈ្មោះថា ជាអ្នកអាក្រក់អាក្រី ព្រោះពោលពាក្យអាក្រក់ ។ ក៏ពួកមនុស្សក្នុងសុនាបរន្តជនបទទាំងនោះ ដូច្នោះឯង ទើបឈ្មោះថា ជាអ្នកអាក្រក់ ហេតុនោះ ទើបលោកពោល ថា 'ជាអ្នករឹងរូស' ។ ២ បទថា 'ឥទញ្ច តេ' មានសេចក្តីថា ពួកមនុស្សទាំងនោះ នឹងគម្រាមកំហែង ដោយការសំដែងភ័យថា 'ពួកយើងនឹងធ្វើ នូវកម្មដែលមិនជាទីប្រាថ្នា មានជាអាទិ៍យ៉ាងនេះ គឺ កាត់ដៃ កាត់ជើង កាត់ច្រមុះ ឈ្មោះនេះផង ដល់អ្នក' ។ បទថា 'យដិកមុគ្គរេន' បានដល់ ដោយអន្លងខ្លី ។ បានឮថា មនុស្សទាំងនោះ សំដែងនូវអាការៈគឺដុំពក ត្រង់ខាងចុង នៃដំបងនោះ ។ ព្រោះហេតុនោះ ទើបលោកពោលថា 'ដោយដំបងដុំពក' ។ ដោយគ្រឿងសស្ត្រា ដែលមានមុខមុតតែម្ខាងជាដើម ។ គ្រឿងប្រហារ ឈ្មោះថា សស្ត្រា ព្រោះសម្លាប់ គឺ ព្រោះបៀតបៀន នូវសត្វទាំងឡាយ ។ គ្រឿងសស្ត្រានោះឯងផង ឈ្មោះថា ហារកៈ

ព្រោះនាំចេញនូវជីវិតផង ហេតុនោះ ទើបឈ្មោះថា **សត្ថហារកៈ** (គ្រឿងសស្ត្រាដែលនាំចេញនូវជីវិត)។ ខន្តី បណ្ឌិតគប្បីជ្រាបថា **ទមៈ** ព្រោះបង្ក្រាប គឺ រម្ងាប់ នូវសេចក្ដីមិនអត់ធន់។ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា ‘ពាក្យថា **ឧបសមៈ** ជាវេវចនៈ របស់ពាក្យថា **ទមៈ** នោះឯង”។

ដីកាឧបរិបណ្ណាសកៈ ថា “សភាវៈណា បង្ក្រាប គឺ ហាមប្រាម នូវបាបធម៌ មានព្យាបាទ ការបៀតបៀន ការរមិលគុណគេ និងការប្រកាន់ជាដើម ហេតុនោះ សភាវៈនោះ.ឈ្មោះថា **ទមៈ** គឺ ខន្តី ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា ‘ខន្តីបណ្ឌិតគប្បីជ្រាបថា **ទមៈ**’។ សភាវៈនោះ ឈ្មោះថា **ទមៈ** ព្រោះអត្ថថា កំចាត់នូវបាបធម៌មានព្យាបាទជាដើម និង ឈ្មោះថា **ឧបសមៈ** ព្រោះអត្ថថា ចូលទៅរម្ងាប់ នូវបាបធម៌មានព្យាបាទជាដើមនោះឯង ព្រោះហេតុនោះ ទើបឈ្មោះថា ទាំងបង្ក្រាប ទាំងចូលទៅរម្ងាប់ បានដល់ អធិវាសនខន្តី”។

ព្រះថេរៈ លុះបន្លឺនូវសីហនាទ ដែលប្រកបដោយខន្តី ដោយពាក្យថា “ពួកមនុស្សក្នុងសុនាបរន្តជនបទនេះ ស្រួលដែរហ្ន៎” ដូច្នេះជាដើម ក្នុងហេតុទាំង ៧ យ៉ាងនេះ គឺ ក្នុងការជេរ ក្នុងការប្រទេចផ្ដាសា ក្នុងការប្រហារដោយបាទដៃ ក្នុងការប្រហារ

ដោយដុំដី ក្នុងការប្រហារដោយដំបង ក្នុងការប្រហារដោយគ្រឿងសស្ត្រា ក្នុងការផ្ដាច់បង់ចាកជីវិត របស់ពួកជនដទៃ ហើយក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ បាននិមន្តទៅក្នុងសុនាបរន្តជនបទនោះហើយ ក៏ចូលទៅចាំព្រះវស្សា ក្នុងមកុឡការាម បានសម្រេចនូវវិជ្ជា ៣ ក្នុងចន្លោះនៃវស្សានោះឯង បានបរិនិព្វានហើយ ។ សេចក្ដីសង្ខេប ក្នុងមង្គលត្ថទីបនីនេះ មានតែប៉ុណ្ណោះ ។ ចំណែកសេចក្ដីពិស្ដារ អ្នកសិក្សាគប្បីត្រួតមើល ក្នុងបុណ្ណោវាទសូត្រព្រមទាំងអដ្ឋកថា និង ដីកា ។

(៥២) សេចក្ដីអត់ធន់ គឺ សេចក្ដីអត់ទ្រាំ ដែលកើតឡើងដល់បុគ្គល អ្នកប្រាកដស្មើដោយ ព្រះបុណ្ណត្ថេរ និង ខន្តិវាទីតាបសឈ្មោះថា ខន្តី ដោយប្រការដូច្នេះ ។

សូម្បីក្នុងអដ្ឋកថាសង្គីតិសូត្រ លោកក៏បានពោលហើយ ថា "អធិវាសនខន្តី ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ យ៉ាងនេះ ថា 'ក្នុងមាតិកាដែលលើកយកមកតាំងទុកថា ខន្តី នោះ ខន្តី តើដូចម្ដេច ? គឺសេចក្ដីអត់ធន់ ភាវៈគឺសេចក្ដីអត់ធន់ ភាវៈគឺសេចក្ដីអត់ទ្រាំ ភាវៈជាអ្នកមិនកាចសាហាវ កិរិយាមិនឲ្យស្រក់ទឹកភ្នែក ភាវៈនៃចិត្តរីករាយណា, ទាំងអស់នេះ ឈ្មោះថា ខន្តី" ។

ដីកាសង្គីតិសូត្រនោះ ថា "កិរិយាអត់ទ្រាំ ឈ្មោះថា កិរិយា

អត់ធន់ គឺ ភាវៈគឺការលើកយកអំពើអាក្រក់ និងពាក្យអាក្រក់ របស់ពួកជនដទៃ មកទុកលើខ្លួន ហើយអត់ធន់ ដោយការមិនធ្វើការក្រោធតបវិញ ៗ កិរិយាមិនក្រោធ ឈ្មោះថា ភាវៈជាអ្នកមិនកាចសាហាវ ៗ កិរិយាមិនឲ្យទឹកភ្នែកកើតឡើង ក្នុងភ្នែកទាំងទ្វេ របស់ពួកជនដទៃ ដោយអំណាចការក្រោធខឹង ឈ្មោះថា កិរិយាមិនឲ្យទឹកភ្នែកស្រក់ ៗ ភាវៈជាអ្នកមានចិត្តជារបស់ខ្លួននៃចិត្ត ឈ្មោះថា ភាពជាអ្នកមានចិត្តរីករាយសប្បាយ គឺ ភាវៈនៃចិត្តមិនមានព្យាបាទ ដែលជារបស់ខ្លួន ឈ្មោះថា ភាពជាអ្នកមានចិត្តជារបស់នៃខ្លួន ៗ ម្យ៉ាងទៀត អារម្មណ៍ដែលជាប់ទាក់ទងជាមួយនឹងចិត្ត ឈ្មោះថា ចិត្ត ៗ ភាវៈជាអ្នកមានចិត្តជារបស់នៃខ្លួន ដោយចិត្តដែលប្រកបព្រមដោយបីតិ ដែលប្រកាន់យក ដោយភាពជាធម្មជាតិប្រសើរឆើត ហើយកើតឡើង ក្នុងចន្លោះនៃចិត្តនោះ ឈ្មោះថា ភាពជាអ្នកមានចិត្តជារបស់នៃខ្លួន ៗ ម្យ៉ាងទៀត បុគ្គលអ្នកមានចិត្តជារបស់នៃខ្លួន, ភាវៈនៃបុគ្គលអ្នកមានចិត្តជារបស់ខ្លួននោះ ឈ្មោះថា ភាពជាអ្នកមានចិត្តជារបស់នៃខ្លួន ៗ ភាពជាអ្នកមានចិត្តជារបស់នៃខ្លួននោះ មិនមានដល់សត្វឡើយ ព្រោះហេតុនោះ ដើម្បីនឹងហាមនូវបុគ្គលជាដើម ទើបលោកពោល ថា ' នៃចិត្ត ' ដូច្នេះ " ៗ

(៥៣) ដីកាសព្វាសវសូត្រ ក្នុងមូលបណ្ណាសកៈថា “ខន្តី ឈ្មោះថា **អធិវាសនា** ព្រោះជាគ្រឿងអត់ទ្រាំ គឺ អត់ធន់ នៃបុគ្គល បានដល់ សេចក្ដីមិនក្រោធខឹង ដែលប្រព្រឹត្តទៅ ដោយអាការអត់ធន់ ចំពោះហេតុទាំងឡាយ មានត្រជាក់ជាដើម ឬ បានដល់ កុសលក្ខន្ធ ៤ យ៉ាង ដែលមានអទោសៈនោះជាប្រធាន” ។

សេចក្ដីអត់ធន់នោះផង ជាគ្រឿងអត់ទ្រាំផង ព្រោះហេតុនោះទើបឈ្មោះថា **អធិវាសនខន្តី** ។

ចំណែក ក្នុងដីកាទុកនិបាត អង្គុត្តរនិកាយ លោកពោលថា “ខន្តី មានសេចក្ដីអត់ទ្រាំជាលក្ខណៈ ឈ្មោះថា អធិវាសនខន្តី” ។

(៥៤) អដ្ឋកថាសព្វាសវសូត្រថា “ខន្តីនេះ រមែងអត់ទ្រាំ គឺ រមែងលើកឡើង នូវធម្មជាតិមានត្រជាក់ជាដើម ហើយដាក់ឲ្យនៅលើខ្លួនតែម្ដង បានដល់ មិនមែនជាធម្មជាតិដែលមិនអត់ទ្រាំលះបង់ចោល ក៏ទេឡើយ ព្រោះហេតុនោះ ទើបលោកពោលថា ‘សេចក្ដីអត់ទ្រាំ’ ដូច្នេះ” ។

ដីកាសព្វាសវសូត្រនោះថា “ខន្តី ដែលអត់ទ្រាំ នូវធម្មជាតិមានត្រជាក់ជាដើម ដែលចូលមកដល់ហើយ រមែងដូចជាឲ្យធម្មជាតិមានត្រជាក់ជាដើមនោះ ស្ថិតនៅលើខ្លួន ព្រោះហេតុនោះទើបលោកពោលថា ‘អារោបេត្វា វាសេតិយេវ’ ដូច្នេះ ។

បទថា 'ន និវស្សតិ' គឺ មិនកំចាត់ ។ ក៏បុគ្គលណា មិនអត់ធន់ នូវត្រជាក់ជាដើម, បុគ្គលនោះ រមែងដូចជារលាស់ចេញ គឺ កំចាត់ចោល នូវធម្មជាតិមានត្រជាក់ជាដើមនោះ" ។

ដោយ **អាទិ** សព្ទ ក្នុងបទថា "**សីតាទយោ**" នេះ លោកប្រកាន់យកបច្ច័យទាំងឡាយ មានទុក្ខវេទនាដែលកើតឡើងអំពីកំដៅ សម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ ពស់តូច ពស់ធំ សេចក្ដីស្រេកឃ្លាន និងពាក្យជាគន្លងដែលគេពោលមិនល្អជាដើម ។

(៥៥) ក៏បុគ្គលណា អត់ធន់ គឺ អត់ទ្រាំ នូវត្រជាក់បាន រមែងមិនកំរើក ញាប់ញ័រ ដោយត្រជាក់ សូម្បីមានប្រមាណតិច ប្រៀបដូចជាបុគ្គលអ្នកមិនក្លាហាន រមែងមិនលះបង់ នូវកម្មដ្ឋាន, បុគ្គលនោះ ឈ្មោះថា ជាអ្នកអត់ធន់ ចំពោះត្រជាក់បាន ប្រៀបដូចជាព្រះលោមសនាគត្ថេរ យ៉ាងនោះឯង ។

## ( រឿងព្រះលោមសនាគត្ថេរ )

បានឮថា ព្រះថេរៈ កាលនៅក្នុងផ្ទះជាទីបំពេញនូវសេចក្ដីព្យាយាម ក្នុងបិយង្គុគុហា លើចេតិយបព៌ត ក្នុងពេលដែលហិមៈធ្លាក់ ក្នុងចន្លោះខែ ៨ បានពិចារណានូវលោកន្តរិកនរក មិនបានលះបង់ចោលនូវកម្មដ្ឋានឡើយ អត់ទ្រាំនៅ ក្នុងទីកណ្ដាលវាល ។

ក៏បុគ្គលណាអត់ទ្រាំនូវកំដៅ សូម្បីមានប្រមាណច្រើនបាន, បុគ្គលនោះឯង ប្រៀបដូចជាព្រះថេរៈអង្គនេះ ឈ្មោះថា ជាអ្នកអត់ធន់ចំពោះកំដៅបាន ។ បានឮថា ព្រះថេរៈ គង់ធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាន ក្នុងទីចង្ក្រមខាងក្រៅ ក្នុងពេលខាងក្រោយនៃភ័ត្ត ក្នុងរដូវក្តៅ ។ ឯញើស ក៏ហូរចេញមក អំពីខ្លៀក របស់លោក ៗ ពេលនោះ អន្តេវាសិក ប្រាប់លោកថា "បពិត្រលោកម្ចាស់ សូមលោកម្ចាស់និមន្តគង់ ក្នុងទីនេះ, មានឱកាសត្រជាក់ល្អ" ។ ព្រះថេរៈ ពោលថា "ម្នាលអ្នកដ៏មានអាយុ ខ្ញុំគង់នៅក្នុងទីនេះ ព្រោះភ័យខ្លាចក្តៅនុ៎ះឯង" បានគង់ពិចារណាអវីចិមហានរករឿយ ៗ ។

រឿងព្រះលោមសនាគត្ថេរ ចប់ ។

(៥៦) ដីកាសព្វាសវសូត្រនោះ ថា "ការលះបង់ចោលនូវកម្មដ្ឋាន ឈ្មោះថា ការកម្រើកញាប់ញ័រ របស់ភិក្ខុអ្នកចំរើននូវកម្មដ្ឋាន ព្រោះហេតុនោះ ទើបលោកពោលថា 'រមែងកម្រើករមែងញាប់ញ័រ រមែងលះបង់នូវកម្មដ្ឋាន' ។ ២បទថា 'ឧណ្ហំ សហតិ' មានសេចក្តីថា ក៏កាលនឹងអត់ធន់នូវកំដៅ ក៏មិនអត់ធន់ ដូចជាពួកសមណៈស្រាតជាដើម, ដោយពិត រមែងអត់ធន់ដោយមិនលះបង់នូវកម្មដ្ឋាន ហេតុនោះ ទើបលោកពោលថា 'បុគ្គលនោះឯង រមែងដូចជាព្រះថេរៈ' ។ បទថា 'ពហិចង្កមេ'

គឺ ក្នុងទីចង្រ្កមខាងក្រៅអំពីគុហា ។ ព្រះថេរៈ បានពោលហើយ ព្រោះភ័យខ្លាចអំពីក្តៅនុ៎ះឯង ។ ២ បទថា **'អវីចិមហានិរយំ បច្ចវេក្ខិត្វា'** បានដល់ ពិចារណា យ៉ាងនេះថា 'អវីចិមហានរក នោះឯង អាត្មាអញបានសោយហើយ អស់កាលច្រើនជាអនេក, ឯសេចក្តីក្តៅនេះជារបស់ស្រាលជាងអវីចិមហានរកនោះ' ដូច្នេះ" ។

(៥៧) ក៏បុគ្គលណា កាលមិនបាន នូវអាហារ ឬទឹកផឹក អស់វារៈ ២ - ៣ ដង ពិចារណានូវការកើតក្នុងប្រេតវិស័យ របស់ខ្លួន ក្នុងសង្សារវដ្តដែលគ្មានទីបំផុតក្តី ត្រូវសម្ផ័ស្ស នៃរបោម មូស ខ្យល់ និងកំដៅថ្ងៃ ដែលមានប្រមាណច្រើន មកពាល់ត្រូវហើយ ពិចារណា នូវការកើតក្នុងកំណើត នៃសត្វតិរច្ឆានក្តី ត្រូវសម្ផ័ស្ស នៃពស់តូច ពស់ធំ មកពាល់ត្រូវហើយ ពិចារណានូវអត្តភាពក្នុង កាលមុនដែលអន្ទោលទៅមក ក្នុងមាត់នៃសត្វកាចសាហាវ មាន រាជសីហ៍និងខ្លាធំជាដើម ក្នុងសង្សារវដ្តដែលរកទីបំផុតគ្មាន អស់ កាលជាអនេកក្តី ហើយមិនកម្រើកញាប់ញ័រ មិនលះបង់កម្មដ្ឋាន ចោលឡើយ ដូចជាព្រះបធានិយត្ថេរ យ៉ាងនោះឯង, បុគ្គលនេះ ឈ្មោះថា ជាអ្នកអត់ធន់ ចំពោះសេចក្តីស្រេកឃ្លានជាដើមបាន ។

( រឿងព្រះបធានិយត្ថេរ )

(៥៨) បានឮថា ពស់មានពិសដ៏ពន្លឹក ខាំព្រះថេរៈ លោក

កំពុងតែស្ដាប់នូវអរិយវង្ស ក្នុងផ្ទះជាទីបំពេញ នូវសេចក្ដីព្យាយាម ឈ្មោះកណ្ណិការ ក្នុងខណ្ឌវេលវិហារ ។ ព្រះថេរៈដឹងហើយ មានចិត្តជ្រះថ្លា គង់ស្ដាប់ធម៌ធ្វើព្រងើយ ។ កម្លាំងនៃពិស បានខ្លាំងក្លាហើយ ។ ព្រះថេរៈ ពិចារណាសីល ចាប់ផ្ដើមតាំងអំពីរោងនៃឧបសម្ប័ទ បានញុំាងបីតិឲ្យកើតឡើងហើយថា " អាត្មាអញជាអ្នកមានសីលបរិសុទ្ធ " ។ ពិសពស់ បានត្រឡប់ចូលទៅកាន់ផែនដីហើយ ព្រមជាមួយគ្នានឹងការកើតឡើងនៃចិត្ត ។ ព្រះថេរៈបាននូវចិត្តដែលមានអារម្មណ៍តែមួយ ក្នុងទីនោះឯង ហើយចំរើនវិបស្សនា បានសម្រេចហើយ នូវព្រះអរហត្ត ។

រឿងព្រះបធានិយត្ថេរ ចប់ ។

(៥៩) ដីកាសព្វាសវសូត្រនោះថា " បទថា ' បរិសុទ្ធ-សីលោម្ហិ ' មានសេចក្ដីថា ព្រះថេរៈគិតថា ' អាត្មាអញជាអ្នកមានសីលបរិសុទ្ធ ' ដូច្នេះហើយ មិនបានគិតដល់សេចក្ដីស្លាប់ សូម្បីក្នុងទីទាំងពួង ញុំាងបីតិដែលមានសេចក្ដីមិនក្ដៅក្រហាយ ជាមូលហេតុ ឲ្យកើតឡើងហើយ ។ បទថា ' សហ ចិត្តុប្បាទា ' គឺ ព្រមជាមួយគ្នានឹងកិរិយាកើតឡើង នៃផរណាបីតិតែម្ដង ។ ២ បទថា ' វិសំ និវត្តិត្វា ' មានសេចក្ដីថា ពិសពស់ ត្រូវកម្លាំងនៃបីតិគ្របសង្កត់ហើយ ទើបបានត្រឡប់ធ្លាក់ចេញ តាមមុខនៃ

របួសដែលពស់ខាំនុះឯង ៗ បទថា ‘តត្ថេវ’ គឺ ក្នុងទីកន្លែងដែលត្រូវពស់ខាំនុះឯង ៗ ២ បទថា ‘ចិត្តេកគ្គតំ លភិត្វា’ គឺសម្រេចនូវសេចក្ដីតាំងចិត្តខ្ជាប់ ដោយន័យជាអាទិ៍ថា ‘កាយរបស់ភិក្ខុដែលមានចិត្តប្រកបដោយបីតិ រមែងស្ងប់រម្ងាប់’ ដូច្នេះ” ៗ

រឿងព្រះថេរៈ ទាំង ២ រូប ដែលពោលមកហើយ មកក្នុងអដ្ឋកថាសព្វាសវសូត្រ ៗ

## ( រឿងព្រះបិណ្ឌបាតិកត្ថេរ )

(៦០) បានឮថា ភិក្ខុ ៣០ រូប ចូលទៅចាំព្រះវស្សា នៅក្នុងវិហារឈ្មោះគរវាលអង្គណៈ ក្នុងថ្ងៃឧបោសថ តែងសំដែងនូវមហាអរិយវង្ស ដែលមានសេចក្ដីសន្ដោសក្នុងបច្ច័យ ៤ និង ភាវនាដែលជាទីត្រេកអរ រាល់កន្លះខែម្ដង ៗ ព្រះថេរៈអ្នកមានកិរិយាត្រាច់ទៅដើម្បីបិណ្ឌបាតជាវត្តមួយរូប មកហើយខាងក្រោយ បានគង់ហើយ ក្នុងទីដែលកំបាំង ៗ គ្រានោះ ពស់ត្បាល់ ១ (ពស់វែកនាម) ខាំព្រះថេរៈនោះ ដូចជាយកដង្កាប់ចាប់សាច់កំភួនជើង ៗ ព្រះថេរៈគិតថា “ក្នុងថ្ងៃនេះ អាត្មាអញនឹងមិនធ្វើសេចក្ដីអន្តរាយដល់ការស្ដាប់ធម៌” ហើយបានចាប់ពស់ត្បាល់ ច្រកទុកក្នុងស្បៀងស្ដាប់ធម៌ធ្វើព្រងើយ ៗ កិរិយារះឡើងនៃព្រះអាទិត្យ ១ កិរិយាអត់សង្កត់នូវពិសបានហើយ សម្រេចនូវផល ៣ របស់ព្រះថេរៈ ១

កិរិយាដែលពិសចយត្រឡប់ចូលទៅកាន់ផែនដីវិញ តាមកន្លែងដែលពស់ខាំនុ៎ះឯង ១ កិរិយាចប់ធម្មកថារបស់ព្រះថេរៈជាធម្មកថិក ១ បានមានហើយ ក្នុងខណៈជាមួយគ្នាតែម្ដង ៗ ព្រះថេរៈ ស្រាយស្បែងហើយ លែងពស់ត្បាល់ចេញទៅ ៗ

រឿងព្រះបិណ្ឌបាតិកត្ថេរ មកក្នុងអដ្ឋកថាឋានសូត្រ ក្នុងបញ្ចមវគ្គ
បឋមបណ្ណាសកៈ ក្នុងតិកនិបាត អង្គុត្តរនិកាយ ។

(៦១) ដីកាឋានសូត្រនោះ ថា " បទថា ' បច្ឆាភាគេន ' គឺ ខាងក្រោយខ្នងនៃព្រះធម្មកថិកត្ថេរ ៗ ពស់ត្បាល់ ឈ្មោះថា គោណសៈ ៗ ព្រះថេរៈ គិត ថា ' អាត្មាអញ នឹងមិនធ្វើនូវសេចក្ដីអន្តរាយដល់ការស្ដាប់ធម៌ ' ដូច្នេះ ដោយប្រាថ្នា ថា ' ក្នុងសេចក្ដីអន្តរាយនៃការស្ដាប់ធម៌ សេចក្ដីអន្តរាយនៃការបាននូវឋានសួគ៌ និងមគ្គ គប្បីមានដល់បុគ្គលជាច្រើន ' ៗ បទថា ' វិសំ ' មានសេចក្ដីថា គ្របសង្កត់នូវកម្លាំងនៃពិស ដោយតេជះនៃវិបស្សនា "ៗ

(៦២) ក៏បុគ្គលណា ស្ដាប់នូវពាក្យសំដី ដែលគេពោលមិនល្អ ដោយអំណាចនៃការជេរប្រទេច ហើយពិចារណាគុណនៃខន្តីមិនញាប់ញ័រ ដូចជាព្រះទីឃភាណកអភយត្ថេរ យ៉ាងនោះ, បុគ្គលនោះ ឈ្មោះថា ជាអ្នកអត់ធន់នូវពាក្យដែលគេពោលមិនល្អបាន ៗ

( រឿងព្រះទីឃភាណកអភយត្ថេរ )

បានឮថា ព្រះថេរៈ សំដែងនូវបដិបទា នៃមហាអរិយវង្ស ព្រោះជាបដិបទា របស់ភិក្ខុអ្នកមានសេចក្ដីសន្តោស ក្នុងបច្ច័យ ៤ និងមានភាវនាដែលជាទីត្រេកអរ ។ អ្នកស្រុកជាច្រើន គ្រប់ៗ គ្នាទាំងអស់ ក៏នាំគ្នាមក ។ សក្ការៈដ៏ច្រើន កើតឡើងហើយ ដល់ព្រះថេរៈ ។ ព្រះមហាថេរ មួយអង្គទៀត មិនអាចដើម្បីអត់ទ្រាំបាន ទើបជេរប្រទេច នូវព្រះទីឃភាណកអភយត្ថេរនោះ ដោយពាក្យជាដើម ថា " ព្រះទីឃភាណកៈ ធ្វើនូវសេចក្ដីកោលាហល រហូតទាំងរាត្រី ដោយអាង ថា 'អាត្មាអញសំដែងនូវអរិយវង្ស" ។ ក៏ព្រះថេរៈទាំង ២ រូប កាលនិមន្តទៅកាន់វត្តរបស់ខ្លួន បាននិមន្តទៅហើយ តាមផ្លូវតែមួយ អស់រយៈផ្លូវមានប្រមាណ ១ គាវុត ។ ព្រះមហាថេរនោះ ជេរប្រទេចហើយ នូវព្រះទីឃភាណកៈនោះ រឿយៗទៅ រហូតផ្លូវប្រមាណ ១ គាវុត ។

គ្រានោះ ផ្លូវទៅកាន់វិហារ របស់ព្រះថេរៈទាំង ២ រូប បែកគ្នា ក្នុងទីស្ថានណា, ព្រះទីឃភាណកត្ថេរ ឈរនៅត្រង់ទីស្ថាននោះ ថ្វាយបង្គំព្រះមហាថេរនោះ ហើយពោល ថា " បពិត្រលោកម្ចាស់ដ៏ចំរើន នុ៎ះ គឺជាផ្លូវ របស់លោកម្ចាស់ " ។ ព្រះមហាថេរនោះធ្វើដូចជាមិនឮ និមន្តទៅហើយ ។ ឯព្រះថេរៈ និមន្ត

ទៅដល់វិហារហើយ ត្រូវពួកអន្តេវាសិកសួរថា "បពិត្រលោកម្ចាស់ដ៏ចំរើន តើលោកម្ចាស់មិនបានពោលពាក្យអ្វីមួយ នឹងព្រះមហាថេរ ដែលដេរប្រទេច របួតចប់ផ្លូវ ១ គាវុត ដែរឬទេ ?" ដូច្នេះហើយ ទើបពោលថា "ម្នាលលោកដ៏មានអាយុ សេចក្ដីអត់ធន់នុះឯង ជាភារៈរបស់ខ្ញុំ, សេចក្ដីមិនអត់ធន់ មិនមែនជាភារៈរបស់ខ្ញុំទេ, ខ្ញុំមិនដែលឃើញនូវការឃ្លាតឆ្ងាយអំពីកម្មដ្ឋាន សូម្បីក្នុងខណៈដែលលើកជើងម្ខាងសោះឡើយ" ។

រឿង ព្រះទីឃភាណកអភយត្ថេរ ចប់ ។

(៦៣) ដីកាសព្វាសវសូត្រនោះថា "សេចក្ដីសន្តោស ក្នុងបច្ច័យទាំងឡាយផង ភាវនាផង ឈ្មោះថា ជាទីមកត្រេកអររបស់ភិក្ខុនុះ ព្រោះភាវៈជាហេតុដែលបុគ្គលគប្បីត្រេកអរ ហេតុនោះ ទើបឈ្មោះថា ជាអ្នកមានសេចក្ដីសន្តោស ក្នុងបច្ច័យ និងភាវនាជាទីមកត្រេកអរ ។ ភាវៈនៃភិក្ខុជាអ្នកមានសេចក្ដីសន្តោសក្នុងបច្ច័យ និង ភាវនាជាទីមកត្រេកអរនោះ ឈ្មោះថា **បច្ចយសន្តោសភាវនារាមតា** (ភាវៈនៃភិក្ខុជាអ្នកមានសេចក្ដីសន្តោសក្នុងបច្ច័យនិងភាវនាជាទីមកត្រេកអរ ។ ដោយភាវៈនៃភិក្ខុជាអ្នកមានសេចក្ដីសន្តោស ក្នុងបច្ច័យ និងភាវនាជាទីមកត្រេកអរនោះ" ។

(៦៤) ក៏បុគ្គលណា រមែងអត់ធន់ នូវទុក្ខវេទនា បានដោយពិត រមែងមិនញាប់ញ័រ ដូចជាព្រះបធានិយត្ថេរ យ៉ាងដូច្នោះ, បុគ្គលនេះ ឈ្មោះថា ជាអ្នកអត់ធន់ ចំពោះវេទនាបាន ។

## ( រឿងព្រះបធានិយត្ថេរ )

បានឮមកថា កាលបើព្រះថេរៈ ឈរញ៉ាំងពេលវេលាឲ្យកន្លងទៅ ដោយសេចក្ដីព្យាយាម រហូតរាត្រីហើយ, ខ្យល់ក្នុងពោះបានកើតឡើងហើយ ។ ព្រះថេរៈនោះ កាលមិនអាចដើម្បីនឹងឲ្យខ្យល់ក្នុងពោះនោះ ស្ងប់រម្ងាប់ទៅបាន ទើបវិលមកវិលទៅ ។ ព្រះបិណ្ឌបាតិកត្ថេរ បានឈរនៅក្បែរខាងទីចង្ក្រម ពោលនឹងព្រះបធានិយត្ថេរនោះ ថា "ម្នាលលោកដ៏មានអាយុ ធម្មតាបព្វជិតរមែងជាអ្នកមានសេចក្ដីអត់ទ្រាំជាប្រក្រតី" ។ ព្រះបធានិយត្ថេរនោះ ពោលថា "បពិត្រលោកម្ចាស់ ប្រពៃហើយ" ដូច្នេះ បានអត់ធន់ហើយ សិងនៅស្ងៀមតែម្តង ។ ខ្យល់បានពុះបេះដូងរហូតដល់ផ្ចិត ។ ព្រះថេរៈ បង្ក្រាបនូវសេចក្ដីវេទនាបានហើយ កាលពិចារណា ក៏សម្រេចជាព្រះអនាគាមី ដោយកាលមួយរំពេចប៉ុណ្ណោះឯង បានបរិនិព្វានហើយ ។

រឿងព្រះបធានិយត្ថេរ ចប់ ។

(៦៥) ដីកាសព្វាសវសូត្រនោះ ថា " កាលបើខ្យល់ចាប់ផ្ដើម ដើម្បីពុះនូវបេះដូងនុ៎ះឯង, ព្រះថេរៈ ក៏បានសម្រេចជាព្រះអនាគាមី ដោយរយៈពេលមួយរំពេច គឺ ដោយខណៈ ៗ បទថា ' **បរិនិព្វាយិ** ' គឺ បានសម្រេចនូវព្រះអរហត្ត បរិនិព្វានហើយ " ៗ

រឿងព្រះថេរៈ ទាំង ២ រូប តាមដែលបានពោលមកហើយ មកក្នុងអដ្ឋកថាសព្វាសវសូត្រ ៗ

សូម្បីរឿង របស់ព្រះថេរៈអង្គឯទៀត ដែលអត់ធន់នូវវេទនា ហើយបានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទា ជាសមសីសី បរិនិព្វានហើយ ក្នុងអដ្ឋកថាមហាសតិបដ្ឋានសូត្រ ក្នុងទីឃនិកាយ មហាវគ្គ និង ក្នុងអដ្ឋកថាសតិបដ្ឋានសូត្រ ក្នុងមូលបណ្ណាសកៈ បណ្ឌិតក៏គប្បីសំដែងផងដែរ ៗ

(៦៦) បុគ្គល អ្នកប្រកបដោយអធិវាសនខន្តី បានសម្រេចនូវគុណដូចបានពោលមកហើយ ដោយប្រការដូច្នេះឯង ៗ ព្រោះហេតុនោះ សេចក្ដីអត់ធន់នោះ របស់បុគ្គលនោះ គប្បីជ្រាបថា " ជាមង្គល " ព្រោះជាហេតុបានសម្រេច នូវគុណតាមដែលបានពោលមកហើយផង នូវសេចក្ដីសរសើរផង ៗ ព្រោះថា បុគ្គលដែលប្រាកដដូច្នោះ រមែងជាអ្នក គឺតាបសឫសី ទេវតា និងព្រះពុទ្ធជាម្ចាស់ គប្បីកោតសរសើរ ៗ ពិតមែនដូច្នោះ សរភង្គតាបស

កាលនឹងសំដែងធម៌ ដល់សក្កទេវរាជ ទើបបានពោលគាថានេះ ក្នុងសរភង្គជាតក ក្នុងចត្តាឡីសនិបាត (១) ថា ÷

" បុគ្គលសម្លាប់សេចក្តីក្រោធបានហើយ រមែងមិនក្រៀមក្រំ ក្នុងកាលណាមួយឡើយ, ឥសីទាំងឡាយរមែងសរសើរ នូវកិរិយាលះបង់នូវសេចក្តីលុបគុណគេ, បុគ្គលគប្បីអត់ធន់ ចំពោះពាក្យអាក្រក់ ដែលបុគ្គលទាំងពួងពោលហើយ, ពួកសប្បុរស ពោលនូវសេចក្តីអត់ធន់នុ៎ះថា ជាគុណជាតិដ៏ឧត្តម " ។

បណ្តាបទទាំងនោះ ២ បទថា "កោធំ វធិត្វា" មានសេចក្តីថា ចោលនូវសេចក្តីក្រោធខឹងបានហើយ រមែងមិនសោកសៅ ។ មែនពិត បុគ្គលកាលនឹងសោកសៅ រមែងសោកសៅ ព្រោះចិត្តដែលក្រោធខឹងនុ៎ះឯង ។ ព្រោះមិនមានសេចក្តីក្រោធខឹង សេចក្តីសោកសៅ នឹងមានមកអំពីណាបាន ។ ព្រោះហេតុនោះ ទើបលោកពោល ថា "រមែងមិនសោកសៅក្នុងកាលណាមួយឡើយ" ។ បទថា "មក្ខប្បហានំ" មានសេចក្តីថា ឥសីទាំងឡាយ រមែងពោលសរសើរ នូវកិរិយាលះបង់នូវការលុបគុណគេ ពោលគឺភាវៈជាមនុស្សអកតញ្ញូ ដែលមានការលុបគុណគេ គឺបុគ្គលដទៃបានធ្វើ

១_ ត្រៃបិដក ភាគទី ៦០ / ទំព័រទី ២៣៥ ។

ហើយដល់ខ្លួនជាលក្ខណៈ ៗ បទថា " **សព្វេសំ** " មានសេចក្ដីថា បុគ្គលគប្បីអត់ធន់ នូវពាក្យអាក្រក់ សូម្បីរបស់បុគ្គលទាំងពួង ទាំងថ្នាក់ទាប ថ្នាក់កណ្ដាលនិងថ្នាក់ខ្ពង់ខ្ពស់ ៗ ២ បទថា " **ឯតំ ខន្តី** " មានសេចក្ដីថា កិរិយាអត់ធន់នូវពាក្យសំដី របស់បុគ្គលទាំងពួងណា, សប្បុរសទាំងឡាយ គឺបោរាណកបណ្ឌិតទាំងឡាយពោលហើយ គឺរមែងពោល នូវសេចក្ដីអត់ធន់នុ៎ះ ថា " ជាគុណជាតិដ៏ឧត្តម " ៗ ក៏ភាពជាអ្នកប្រសើរជាដើម របស់សត្វទាំងឡាយ គឺបុគ្គលណាមួយ ក៏មិនអាចដើម្បីនឹងដឹងបាន ដោយហេតុត្រឹមតែឃើញរូប, ព្រោះថា សូម្បីពួកសប្បុរស រមែងប្រាកដត្រាច់ចរទៅ ដោយរូបនៃពណ៌សម្បុរ របស់បុគ្គលអាក្រក់ក៏សឹងមានដែរ ៗ ក៏ក្នុងរឿងនេះ មានព្រះមជ្ឈន្តិកត្ថេរ ជាឧទាហរណ៍ ព្រោះហេតុណា ៗ ព្រោះហេតុនោះ កិរិយាអត់ធន់ចំពោះពាក្យសំដី របស់ជនទាំងពួង លោកពោលថា " ជាគុណជាតិដ៏ឧត្តម " ៗ

(៦៧) ក៏បុគ្គលណា គឺខ្លួនដឹងហើយថា " អ្នកនេះទាបថោកជាងអញ " ដូច្នេះ, ការអត់ធន់នូវពាក្យអាក្រក់ របស់បុគ្គលនោះ ជាការប្រសើរជាង ៗ ហេតុនោះ សរភង្គតាបស ទើបពោល ថា÷

" **បុគ្គលគប្បីអត់ធន់ នូវពាក្យ របស់បុគ្គលដ៏ប្រសើរ**(១)

១ _ ត្រៃបិដក ភាគទី ៦០ / ទំព័រទី ២៣៥ ។

ព្រោះសេចក្ដីខ្លាច, ឯបុគ្គលគប្បីអត់ធន់ នូវពាក្យ
របស់បុគ្គលស្មើៗគ្នា ព្រោះហេតុនៃការប្រណាំង
ប្រជែង, ចំណែកបុគ្គលណា ក្នុងលោកនេះ គប្បី
អត់ធន់នូវពាក្យ របស់បុគ្គលថោកទាបនេះបាន,
សប្បុរសទាំងឡាយ ពោលនូវសេចក្ដីអត់ធន់នុ៎ះ
(របស់បុគ្គលនោះ) ថា ជាគុណជាតិដ៏ខ្ពង់ខ្ពស់"។

អដ្ឋកថាជាតក ថា "បណ្ដាបទទាំងនោះ ២ បទថា 'ឯតំ ខន្តិ' មានសេចក្ដីថា ចំណែកសេចក្ដីអត់ធន់នូវពាក្យ របស់បុគ្គលថោកទាប ដោយជាតិនិងគោត្រជាដើមនេះណាមួយ, បោរាណកបណ្ឌិតទាំងឡាយតែងពោលសេចក្ដីអត់ធន់នុ៎ះ ថា 'ជាគុណជាតិដ៏ឧត្ដម'។ អធិប្បាយថា ឯសេចក្ដីអត់ធន់ចំពោះពាក្យសំដី របស់បុគ្គលប្រសើរដោយជាតិជាដើម ព្រោះសេចក្ដីខ្លាច របស់បុគ្គលអ្នកស្មើៗគ្នា ព្រោះឃើញទោស ក្នុងការប្រណាំងប្រជែងគ្នា មានការធ្វើឲ្យក្រ្រៃលែងជាងហេតុជាលក្ខណៈនុ៎ះឯណាមួយ, សេចក្ដីអត់ធន់នេះមិនឈ្មោះថា អធិវាសនខន្តីឡើយ"។

(៦៨) រឿងធ្លាប់មានមកហើយ សង្គ្រាមរវាងអសុរ និងទេវតា បានមានហើយ ៗ ពួកទេវតាបានឈ្នះហើយ ទើបចង

អសុរិន្ទឈ្មោះវេបចិត្តិ ហើយនាំទៅកាន់សំណាក់នៃសក្កទេវរាជ ។ វេបចិត្តិអសុរិន្ទនោះ ជេរប្រទេចនូវសក្កៈ ដែលជាស្ដេចនៃទេវតា ដោយអក្កោសវត្ថុ ១០ យ៉ាងនេះ ថា "អ្នកជាចោរ ជាមនុស្សពាល ជាមនុស្សវង្វេង ជាគោ ជាលា ជាអូដ្ឋ ជាសត្វនរក អ្នកជាសត្វតិរច្ឆាន, សុគតិរបស់អ្នកមិនមានឡើយ, ទុគ្គតិប៉ុណ្ណោះ ដែលអ្នកគប្បីសង្ឃឹម" និងប្រទេច ដោយពាក្យជាដើម ថា "នៃស្ដេចសក្កៈកញ្ជាស់ អ្នកនឹងមិនឈ្នះ រហូតកាលទាំងពួងទេ, ពេលណា ជ័យជំនះ នឹងមានដល់ពួកអសុរ, ពេលនោះ ខ្ញុំនឹងចងអ្នកឯងយ៉ាងនេះ ឲ្យដេកត្រង់មាត់ទ្វារ នៃភពរបស់អសុរ ហើយវាយសំពង" ។ ស្ដេចសក្កទេវរាជ ទ្រង់មានជ័យជំនះហើយ រមែងមិនយកព្រះទ័យទុកដាក់នូវពាក្យនោះ ព្រោះភាវៈនៃព្រះអង្គទ្រង់មានអធ្យាស្រ័យរឹងប៉ឹង ក្នុងខន្តីនិងសោរច្ចៈ អស់កាលជាយូរអង្វែងហើយ ។

លំដាប់នោះ មាតលីទេវបុត្រ គិតថា " សក្កទេវរាជនេះ ទ្រង់អត់ធន់ នូវពាក្យអាក្រក់ទាំងនេះ ព្រោះទ្រង់ភ័យខ្លាចឬហ្ន៎ ? ឬថា ព្រោះភាវៈនៃព្រះអង្គទ្រង់ប្រកប ដោយអធិវាសនខន្តី " ដូច្នេះហើយ ទើបទូលសួរ នូវសេចក្ដីនោះ ។

(៦៩) គ្រានោះ សក្កទេវរាជ ទ្រង់ត្រាស់ថា " យើងអត់ធន់ (នូវពាក្យ) របស់ស្ដេចវេបចិត្តិ ព្រោះសេចក្ដីខ្លាចក៏ពុំមែន,

ព្រោះសេចក្តីអន់ថយកម្លាំងក៏ពុំមែនដែរ " ដូច្នេះ ហើយត្រាស់ថា

" ប្រយោជន៍ទាំងឡាយ មានប្រយោជន៍របស់ខ្លួន យ៉ាងក្រៃលែង, ប្រយោជន៍ដែលក្រៃលែងជាង សេចក្តីអត់ធន់ តែងមិនមានឡើយ, បុគ្គលណាមួយ ក៏ដោយ ជាអ្នកមានកម្លាំង ជាអ្នកស្ងប់រម្ងាប់ រមែង អត់ទ្រាំ (នូវពាក្យ) របស់បុគ្គលអ្នកអន់ថយកម្លាំង បាន, បណ្ឌិតទាំងឡាយ ពោលសេចក្តីអត់ធន់នោះ របស់បុគ្គលនោះ ថាប្រសើរជាង, ព្រោះអ្នកអន់ ថយកម្លាំង រមែងរុករានទន្ទ្រាន ជានិច្ចកាល " ។

អដ្ឋកថាសក្កសំយុត្តនោះថា " បណ្តាបទទាំងនោះ បទថា 'សទត្ថបរមា' គឺ មានប្រយោជន៍របស់ខ្លួន យ៉ាងក្រៃលែង ។ បាទគាថាថា 'ខន្ត្យា ភិយ្យោ ន វិជ្ជតិ' មានសេចក្តីថា បណ្តា ប្រយោជន៍ទាំងឡាយ មានប្រយោជន៍របស់ខ្លួនយ៉ាងក្រៃលែងនោះ ប្រយោជន៍ដែលក្រៃលែងជាងខន្តី រមែងមិនមាន ។ ២ បទថា 'តមាហុ បរមំ' មានសេចក្តីថា បុគ្គលណា ជាអ្នកមានកម្លាំង រមែងអត់ធន់បាន, បណ្ឌិតទាំងឡាយ ពោលហើយនូវសេចក្តីអត់ ធន់នោះ របស់បុគ្គលនោះ ថា ប្រសើរជាង " ។

ដីកាសក្កសំយុត្តនោះ ថា “ប្រយោជន៍ដទៃ ដែលក្រៃលែងជាងខន្តី ឈ្មោះថាមិនមាន ព្រោះហាមប្រាមនូវអនត្ថៈ(មិនមែនជាប្រយោជន៍) ដែលជាអារម្មណ៍របស់ប្រយោជន៍នោះ ដោយចន្លោះហើយ មិនលះបង់នូវប្រយោជន៍សុខ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងប្រព្រឹត្តទៅក្នុងសម្បរាយិកភព ។ បណ្ឌិតទាំងឡាយ ពោលសេចក្ដីអត់ធន់ថា ប្រសើរជាង ព្រោះគ្របសង្កត់នូវបច្ច័យដែលជាសឹកសត្រូវ ដែលមានកម្លាំងដ៏ប្រសើរបានហើយ ប្រព្រឹត្តទៅ” ។

សេចក្ដីសង្ខេប ក្នុងមង្គលត្ថទីបនីនេះ មានតែប៉ុណ្ណេះឯង ។ ចំណែកសេចក្ដីពិស្ដារ គប្បីត្រួតមើល ក្នុងសក្កសំយុត្ត ។

ចំណែកក្នុងដីកាអនុមានសូត្រ លោកពោលហើយថា “បទថា ‘អបសាទេតិ’ គឺ រមែងរុករាន ឬ គម្រាមកំហែង” ។

ព្រោះហេតុនោះ ក្នុងពាក្យថា “និច្ចំ ខិបតិ ទុព្ពលោ” នេះ បទថា ‘ខិបតិ’ នឹងអធិប្បាយថា រមែងរុករាន គឺ រមែងសម្លុតក៏សមគួរដែរ ។

(៧០) បានឮថា ព្រាហ្មណ៍ ៤ នាក់ ជាបងប្អូននឹងគ្នាក្រោធខឹង ចំពោះព្រះសាស្ដា ហើយជេរប្រទេចព្រះសាស្ដា ដោយប្រការផ្សេង ៗ ដោយន័យដែលបានពោលមកហើយ ក្នុងព្រាហ្មណ-សំយុត្ត ត្រូវព្រះសាស្ដាទ្រង់ណែនាំឲ្យប្រពៃហើយ ក៏បានបួសហើយ

មិនយូរប៉ុន្មាន ក៏បានសម្រេចនូវព្រះអរហត្ត ។ ពួកភិក្ខុ ក៏បានសន្ទនាគ្នា ថា "ម្នាលអ្នកដ៏មានអាយុ ព្រះពុទ្ធគុណ អស្ចារ្យណាស់ហ្ន៎!, ក៏ព្រះសាស្តា សូម្បីត្រូវពួកព្រាហ្មណ៍ទាំងនោះ ជេរប្រទេចហើយ ក៏មិនបានត្រាស់នូវព្រះតម្រាស់អ្វីឡើយ ត្រឡប់បានជាទីពឹង ដល់ព្រាហ្មណ៍ទាំងនោះទៅវិញ" ។ ព្រះសាស្តា ទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ទ្រង់ត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ តថាគត ព្រោះជាអ្នកប្រកបដោយកម្លាំង គឺ ខន្តី មិនប្រទូសរ៉ាយក្នុងបុគ្គលដែលប្រទូស្ត ទើបបានជាទីពឹងរបស់មហាជន ដោយពិត" ដូច្នេះហើយ ទ្រង់ត្រាស់គាថានេះ ក្នុងព្រាហ្មណវគ្គ[១] ធម្មបទ ថា ÷

"បុគ្គលណា មិនប្រទូស្ត រមែងអត់សង្កត់ នូវពាក្យ
ជេរផង ការបៀតបៀន និងការចងផងបាន, ទើប
តថាគត ហៅបុគ្គលដែលមានខន្តីជាកម្លាំង មានខន្តី
ជាវេហ៍ពលនោះឯង ថា ជាព្រាហ្មណ៍" ។

អដ្ឋកថាធម្មបទ ថា "បណ្តាបទទាំងនោះ បទថា 'អទុដ្ឋោ' មានសេចក្តីថា បុគ្គលណា ជាអ្នកមានចិត្តមិនក្រោធខឹង រមែងអត់ធន់ នូវការជេរប្រទេច ដោយអក្កោសវត្ថុ ១០ យ៉ាង ការវាយដោយបាតដៃជាដើម និងការចង ដោយគ្រឿងចងមានខ្នោះឃ្នាង

១_ ត្រៃបិដក ភាគទី ៥២ / ទំព័រទី ១០៥ ។

ជាដើមនុ៎ះ, តថាគតហៅបុគ្គលនោះ គឺ អ្នកនោះ ឈ្មោះថាជាអ្នកមានខន្តីជាកម្លាំង ព្រោះភាវៈជាអ្នកប្រកប ដោយកម្លាំង គឺខន្តី ឈ្មោះថា ជាអ្នកមានរេហ៍ពលជាកម្លាំង ព្រោះភាវៈជាអ្នកប្រកប ដោយកងពលគឺខន្តី ដែលជាកងទ័ពដោយពិត ព្រោះកើតឡើងជារឿយៗ ថា ជាព្រាហ្មណ៍ " ។

អដ្ឋកថាវាសេដ្ឋសូត្រ ក្នុងមជ្ឈិមបណ្ណាសកៈ ថា " បទថា 'តិតិក្ខតិ' គឺ រមែងអត់ធន់ ។ បទថា 'ខន្តិពលំ' បានដល់ កម្លាំង គឺអធិវាសនខន្តី ។ ក៏អធិវាសនខន្តីនោះ ដែលកើតឡើងហើយ ១ គ្រា រមែងមិនបានឈ្មោះថាជារេហ៍ពលឡើយ, ប៉ុន្តែដែលកើតឡើងជារឿយ ៗ រមែងឈ្មោះថា ជារេហ៍ពលបាន ។ ក៏អធិវាសនខន្តីនោះ ឈ្មោះថារេហ៍ពល ព្រោះភាវៈនៃសេចក្ដីអត់ធន់នោះមាន " ។

ដីកាវាសេដ្ឋសូត្រនោះ ថា " ខន្តី មានសេចក្ដីអត់ទ្រាំជាលក្ខណៈ ជាកម្លាំង របស់ចិត្តនុ៎ះ រមែងមាន ហេតុនោះ ចិត្តនោះឈ្មោះថា មានខន្តីជាកម្លាំង ។ ២ បទថា 'តស្សា អត្ថិតាយ' បានដល់ ព្រោះភាវៈនៃខន្តីដែលកើតឡើងរឿយ ៗ នោះ គឺ សេនាពោលគឺខន្តី ដែលកំចាត់បង់នូវមារនិងសេនានៃមារ ដែលចូលទៅសន្សំ ដោយការកើតឡើងបន្តបន្ទាប់គ្នាមាននៅ ៗ រេហ៍ពល

គឺ កងពល របស់ចិត្តនុ៎ះ មាន ហេតុនោះ ចិត្តនោះ ឈ្មោះថា មានរេហ៍ពល " ។

ដីកាខត្តិយវគ្គថា " ពួក ៣ នៃស័ព្ទ មានចក្កស័ព្ទជាដើម រមែងប្រព្រឹត្តទៅ ក្នុងសេនាផង ក្នុងអង្គនៃសេនាផង ដោយភាវៈជារបស់ស្មើគ្នា ។ ការដណ្តើមយកជ័យជំនះ គឺសេនា រមែងធ្វើដោយវត្ថុណា ហេតុនោះ វត្ថុនោះ ឈ្មោះថា ចក្រ ។ ពលៈ ធាតុ រមែងប្រព្រឹត្តទៅ ក្នុងកិរិយាការពារ ។ អនៈ ធាតុ ចុះក្នុងអត្ថថា បញ្ចេញសំឡេង ចុះ ណ្វក បច្ច័យ " ។

(៧១) បុគ្គលអ្នកប្រកបដោយខន្តី រមែងជាអ្នក គឺពួកឥសីជាដើមសរសើរហើយ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ បុគ្គលមិនគប្បីក្រោធតប ចំពោះបុគ្គលអ្នកក្រោធខឹង ដល់ខ្លួនឡើយ ។ ព្រោះបុគ្គលកាលក្រោធតប ចំពោះបុគ្គលអ្នកក្រោធខឹង រមែងជាអ្នកអាក្រក់ជាង ។

ព្រោះហេតុនោះ ស្តេចសក្កទេវរាជ ទើបទ្រង់ត្រាស់ ថា ÷

" បុគ្គលណា រមែងក្រោធតប ចំពោះបុគ្គលអ្នក
ក្រោធខឹង, បុគ្គលនោះ រមែងជាអ្នកអាក្រក់ជាង
បុគ្គលនោះតែម្តង ព្រោះសេចក្តីក្រោធខឹងនោះ,

បុគ្គល កាលមិនក្រោធតប នឹងបុគ្គលអ្នកក្រោធខឹង រមែងឈ្នះសង្គ្រាមដែលគេឈ្នះបាន ដោយកម្រ ” ។

អដ្ឋកថាសក្កសំយុត្ត ថា “ បណ្ដាបទទាំងនោះ បាទគាថាថា ‘ តស្សេវ តេន បាបិយោ ’ មានសេចក្ដីថា បុគ្គលណា រមែងក្រោធតប នឹងបុគ្គលអ្នកក្រោធខឹង, បុគ្គលនោះ ជាអ្នកអាក្រក់ជាង បុគ្គលនោះទៅទៀត ព្រោះសេចក្ដីក្រោធខឹងនោះ ” ។

(៧២) ព្រោះហេតុនោះ បុគ្គលកាលសំឡឹងឃើញទោសនៃសេចក្ដីមិនអត់ធន់ គប្បីស្ថិតនៅក្នុងអធិវាសនខន្តី ។ ព្រោះថាបុគ្គលអ្នកស្ថិតនៅ ក្នុងអធិវាសនខន្តីនោះឯង រមែងជាអ្នកបាននូវឈ្មោះថា ជាអ្នកស្ងប់ស្ងៀមជាដើម ។ សេចក្ដីនេះ គប្បីសំដែងដោយរឿង នៃស្ត្រីមេផ្ទះ ឈ្មោះថា វេទេហិកា ។

## ( រឿងនាងវេទេហិកា )

បានឮថា ក្នុងអតីតកាល ក្នុងទីក្រុងសាវត្ថី មានស្ត្រីមេផ្ទះ ឈ្មោះថា វេទេហិកា ជាអ្នកស្ងប់ស្ងៀម ជាអ្នកប្រព្រឹត្តឱនលំទោន ស្ងប់រម្ងាប់ ។ កិត្តិស័ព្ទដ៏ល្អ របស់នាង បានឮល្បីផ្សាយទៅ យ៉ាងដូច្នេះ ថា “ នាងវេទេហិកា ជាអ្នកស្ងប់ស្ងៀម នាងវេទេហិកាជាអ្នកប្រព្រឹត្តបន្ទាបខ្លួន នាងវេទេហិកាជាអ្នកស្ងប់ ” ។

ក៏នាងវេទេហិកានោះ មានស្រីបម្រើម្នាក់ ឈ្មោះនាងកាឡី ជាស្រីឧស្សាហ៍ មិនខ្ជិលច្រអូស ចេះចាត់ចែងការងារ យ៉ាងល្អ ។ នាងទាសីនោះគិតថា "អ្នកជាម្ចាស់ របស់អញ រមែងមិនធ្វើសេចក្ដីក្រោធខឹង ដែលមាននៅខាងក្នុង ឲ្យប្រាកដឬហ្ន៎? ឬថាសេចក្ដីក្រោធខឹងមិនមាន, បើដូច្នោះ មានតែអាត្មាអញ សាកល្បងនូវអ្នកជាម្ចាស់មើល" ដូច្នេះហើយ បានក្រោកឡើងក្នុងពេលថ្ងៃ ។ នាងវេទេហិកាពោលថា "នែវើយ នាងកាឡី ហេតុអ្វី បានជានាងឯង ក្រោកក្នុងពេលថ្ងៃ?, នាងមានសេចក្ដីមិនសប្បាយឬ?" ។ នាងទាសីពោលថា "បពិត្រអ្នកជាម្ចាស់ នាងខ្ញុំឥតមានសេចក្ដីមិនសប្បាយអ្វីទេ" ។ នាងវេទេហិកាពោលថា "នែវើយ! បើនាងមិនមានសេចក្ដីមិនសប្បាយអ្វីទេ, នែនាងទាសីចង្រៃ ព្រោះហេតុអ្វី បានជានាងឯងក្រោក ក្នុងពេលថ្ងៃ?" ដូច្នេះ ហើយក្រោធខឹងមិនសប្បាយចិត្ត បានធ្វើមុខក្រញ៉ូវហើយ ។

គ្រានោះ នាងកាឡីគិតថា "សេចក្ដីក្រោធខឹង មាននៅព្ធីខាងក្នុង នៃអ្នកជាម្ចាស់ របស់អញដោយពិត, មិនមែនមិនមានទេ, បើដូច្នោះ មានតែអាត្មាអញ សាកល្បងមើល ឲ្យច្រើនឡើងជាភិយ្យោភាព" ដូច្នេះ ទើបបានក្រោកឡើង ថ្ងៃជាង (មុន) ក្នុងថ្ងៃស្អែកឡើង ។ នាងវេទេហិកា បានក្រោធខឹងលើសដើម

ទាញយកកន្លះទ្វារមកហើយ ប្រហារត្រង់ក្បាល ៗ ក្បាលបែកហើយ ៗ នាងកាឡីមានក្បាលបែកហើយ មានឈាមហូរជោកទើបស្រែកប្រាប់ ដល់ពួកស្ត្រីអ្នកនៅជិតខាង ថា " ម្នាលនាងទាំងឡាយ ចូរពួកអ្នកមើលនូវកម្ម របស់ស្ត្រីអ្នកស្ងប់ស្ងៀមចុះ, ម្នាលនាងទាំងឡាយ ចូរពួកអ្នកមើលនូវកម្ម របស់ស្ត្រីអ្នកប្រព្រឹត្តបន្ទាបខ្លួនចុះ, ម្នាលនាងទាំងឡាយ ចូរពួកអ្នកមើលនូវកម្ម របស់ស្ត្រីអ្នកស្ងប់រម្ងាប់ចុះ " ៗ ដោយកាលដទៃពីនោះ កិត្តិស័ព្ទដ៏អាក្រក់របស់នាងវេទេហិកា ក៏ឮល្បីផ្សាយទៅ យ៉ាងដូច្នេះ ថា " នាងវេទេហិកា ជាស្ត្រីកាចសាហាវ នាងវេទេហិកា ជាស្ត្រីមិនប្រព្រឹត្តបន្ទាបខ្លួន នាងវេទេហិកា ជាស្ត្រីមិនស្ងប់រម្ងាប់ " ៗ

(៧៣) គុណមានប្រមាណត្រឹមណា, ទោសក៏កើតឡើងទ្វេគុណជាងគុណនោះ មានប្រមាណត្រឹមនោះ ៗ ធម្មតាគុណរមែងសន្សំម ៗ ចូលមក ៗ ទោស តែមួយថ្ងៃប៉ុណ្ណោះ រមែងផ្សព្វផ្សាយទៅបាន ៗ សូម្បីព្រះដ៏មានព្រះភាគ ទ្រង់មានបំណងនឹងទ្រង់សំដែង នូវទោសនៃសេចក្ដីមិនអត់ធន់ ដល់ពួកភិក្ខុទាំងឡាយហើយ ទ្រង់ប្រកប ក្នុងសេចក្ដីអត់ធន់ ទើបទ្រង់បាននាំនូវអតីតនិទាននេះមកហើយ ទ្រង់ត្រាស់ម្ដងទៀតដូចគាថា " ម្នាលភិក្ខុទាំងឡាយ យ៉ាងដូច្នោះឯង, បុគ្គលពួកខ្លះ ក្នុងលោកនេះ

រមែងជាអ្នកស្ងប់ស្ងៀមហើយ ស្ងប់ស្ងៀមទៀត ជាអ្នកប្រព្រឹត្តបន្ទាបខ្លួនហើយ បន្ទាបទៀត ជាអ្នកស្ងប់រម្ងាប់ហើយ ស្ងប់រម្ងាប់ទៀត រហូតវេលាដែលពាក្យសំដី ដែលមិនជាទីពេញចិត្ត មិនទាន់មកប៉ះពាល់នូវខ្លួនគេ, ម្នាលភិក្ខុទាំងឡាយ ក៏ពេលណា ពាក្យសំដីដែលមិនជាទីពេញចិត្ត មកប៉ះពាល់នូវភិក្ខុ, ពេលនោះ គឺអ្នកទាំងឡាយ គប្បីដឹងថា 'ភិក្ខុជាអ្នកស្ងប់ស្ងៀម' គប្បីដឹងថា 'ជាអ្នកប្រព្រឹត្តបន្ទាបខ្លួន' គប្បីដឹងថា 'ជាអ្នកស្ងប់រម្ងាប់ " ។

រឿងនាងវេទេហិកា មកក្នុងកកចូបមសូត្រ ក្នុងតតិយវគ្គ មូលបណ្ណាសកៈ ។

(៧៤) អដ្ឋកថាកកចូបមសូត្រនោះថា "បទថា 'សោរតា' គឺ ប្រកបដោយភាពជាអ្នកស្ងប់ស្ងៀម ។ បទថា 'និវាតា' គឺ ប្រព្រឹត្តបន្ទាបខ្លួន ។ បទថា 'ឧបសន្តា' គឺ ស្ងប់រម្ងាប់ ។ បទថា 'ទក្ខា' បានដល់ ឆ្លាតក្នុងការងារ មានដាំបាយ ក្រាលទីដេកនិងទ្រោលប្រទីបជាដើម ។ បទថា 'អនលសា' គឺ ខ្នះខ្នែង ។ បទថា 'សុសំវិហិតកម្មន្តា' គឺ មានការងារតាំងទុកហើយ ដោយល្អ ។ បទថា 'បដិវិស្សកានំ' បានដល់ អ្នកនៅជិតខាងផ្ទះ ។ បទថា 'ឧជ្ឈាបេសិ' គឺ ឲ្យអ្នកដទៃមើលងាយ ។ បទថា 'ចណ្ឌី' បានដល់ ជាអ្នកមិនស្ងប់ស្ងៀម គឺជាអ្នកអាក្រក់អាក្រី ។ បទថា

'សោរតសោរតោ' បានដល់ ជាអ្នកស្ងប់ស្ងៀម យ៉ាងក្រៃលែង គឺ រមែងដល់នូវភាពជាអ្នក ដែលគេគប្បីពោលបាន ថា "ជាព្រះសោតាបន្នបុគ្គល ជាព្រះសកទាគាមី ជាព្រះអនាគាមី ជាព្រះអរហន្តបុគ្គល" ។ បទថា 'ផុសន្តិ' មានសេចក្តីថា ពាក្យសំដីមកកាន់គន្លង ប៉ះពាល់ត្រូវ ឬ ប៉ះទង្គិច ។ ច្រើនបទ ថា 'អថ ភិក្ខុ សោរតោតិ វេទិតព្វោ' មានសេចក្តីថា ក្នុងកាលនោះ ភិក្ខុអ្នកតាំងនៅ ក្នុងអធិវាសនខន្តី គប្បីដឹងថា 'ជាអ្នកស្ងប់ស្ងៀម"។

ដីកាកកចូបមសូត្រនោះថា "បទថា 'សោរច្ចេន' បានដល់ ដោយសេចក្តីប្រុងប្រយ័ត្ន ។ បទថា 'និវាតវុត្តិ' បានដល់ ជាអ្នកធ្វើនូវកិរិយាឱនលំទោនជាប្រក្រតី ។ បទថា 'និព្វុតា' បានដល់ មានសេចក្តីក្តៅក្រហាយ ព្រោះទុច្ចរិត ស្ងប់រម្ងាប់ហើយ ។ បទថា 'ឧដ្ឋាហិកា' បានដល់ មានសេចក្តីព្យាយាម ជាហេតុក្រោកឡើង ។ បទថា 'កិព្វិសា' បានដល់ ទាបថោក" ។

ការពណ៌នាអំពីបទ ថា សេចក្តីអត់ធន់ ចប់ ។

⁂

ប្រែចប់ ថ្ងៃអង្គារ ៣ រោច ខែមាឃ ឆ្នាំរកា បញ្ចស័ក ព. ស. ២៥៣៦
ថ្ងៃទី៩ កុម្ភៈ ១៩៩៣

# ពណ៌នាអំពីភាពជាអ្នកដែលគេប្រដៅងាយ

---

(៧៥) លោកពោលហើយ ក្នុងអដ្ឋកថាថា “ភាវៈគឺ បុគ្គលកាលត្រូវគេពោល ប្រកបដោយធម៌ មិនដល់នូវការក្រេវក្រោធ ឬភាវៈជាអ្នកនៅស្ងៀម ឬក៏ការគិតនូវគុណនិងទោស ហើយធ្វើនូវការអើពើ ការគោរព និងកិរិយាបន្ទាបខ្លួន យ៉ាងក្រៃលែងនៅចំពោះមុខ ហើយធ្វើកិរិយាពោលថា ‘ប្រពៃហើយ’ ដូច្នេះ ឈ្មោះថា ភាពជាអ្នកដែលគេប្រដៅបានដោយងាយ” ។

ក្នុងបទថា “**សោវចស្សតា**” នោះ មានការចំណែក ដូចតទៅនេះ ÷ **សុវចោ សោវចស្សំ សោវចស្សតា** ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យនោះ ដូចតទៅនេះ ÷ បុគ្គលដែលគេគប្បីប្រដៅបានដោយងាយ ឈ្មោះថា **សុវចោ** ។ ចេតនាដែលប្រព្រឹត្តទៅ ដោយអំណាចកិរិយាអើពើ របស់បុគ្គលដែលគេប្រដៅបានដោយងាយ ឈ្មោះថា **សោវចស្សំ** ។ ភាពមាននៅ នៃបុគ្គលដែលគេប្រដៅបាន ដោយងាយ ឈ្មោះថា **សោវចស្សតា** ។ ដោយហេតុនោះ ក្នុងអដ្ឋកថាទុកៈ ក្នុងសង្គីតិសូត្រ លោកពោលហើយថា “ការប្រដៅបានដោយលំបាក ក្នុងបុគ្គលអ្នកប្រកាន់រឹងត្អឹង អ្នកត្រេកអរក្នុងការពោលជំទាស់

អ្នកមិនអើពើនុ៎ះ រមែងមាន ហេតុនោះ បុគ្គលនេះ ឈ្មោះថា ជាអ្នកដែលគេប្រដៅបានដោយលំបាក ។ កម្មរបស់បុគ្គលដែលគេប្រដៅបានដោយលំបាកនោះ ឈ្មោះថា **ទោវចស្សំ** ។ ភាវៈនៃកម្មរបស់បុគ្គលដែលគេប្រដៅបានដោយក្រនោះ ឈ្មោះថា **ទោវចស្សតា** ។ ភាពនៃបុគ្គលដែលគេប្រដៅបានដោយក្រនោះ ដោយសេចក្តី ក៏គឺជាសង្ខារក្ខន្ធ ។ អាចារ្យពួកខ្លះពោល ថា "ភាពនៃបុគ្គលដែលគេប្រដៅបានដោយក្រនេះ ជាឈ្មោះ នៃខន្ធទាំង ៤ ដែលប្រព្រឹត្តទៅដោយអាការនេះ" ។ ភាពនៃបុគ្គលដែលគេប្រដៅបានដោយងាយគប្បីជ្រាប ដោយន័យដែលផ្ទុយគ្នា នៃពាក្យដែលពោលហើយ " ។

(៧៦) ដីកាសង្គីតិសូត្រនោះ ថា "បទថា 'វិប្បដិកូលគ្គាហិម្ហិ' គឺ ប្រកាន់យកប្លែកផ្សេងគ្នា អំពីការប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ។ កម្មដែលជាសត្រូវដល់ការប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌នោះឯង គឺការប្រតិបត្តិមិនល្អ ជាទីពេញចិត្ត គឺជាទីប្រាថ្នារបស់បុគ្គលនុ៎ះ ហេតុនោះ បុគ្គលនុ៎ះ ឈ្មោះថា ជាអ្នកមានសេចក្តីត្រេកអរក្នុងកិរិយាពោលជំទាស់ ។ ក្នុងបុគ្គលអ្នកមានសេចក្តីត្រេកអរក្នុងកិរិយាពោលជំទាស់នោះ ។ ក៏បុគ្គលអ្នកប្រាកដ យ៉ាងនេះ រមែងជាអ្នកប្រាសចាក អំពីសេចក្តីអើពើ និងសេចក្តីគោរពក្នុងរបៀបនៃសាសនា ដែលជាឱវាទ និងក្នុងបុគ្គលអ្នកឲ្យនូវឱវាទ

ហេតុនោះ ទើបលោកពោលថា 'ជាអ្នកមិនអើពើ' ។ ២ បទថា 'តស្ស កម្មំ' មានសេចក្ដីថា ចេតនាដែលប្រព្រឹត្តទៅ ដោយអំណាចសេចក្ដីមិនអើពើ របស់បុគ្គលដែលគេប្រដៅបានដោយក្រនោះ ឈ្មោះថា **ទោវចស្សំ** ។ ២ បទថា **'តស្ស ភាវោ'** គឺ ភាពមាននៃកម្ម របស់បុគ្គលដែលគេប្រដៅបាន ដោយលំបាកដែលបានពោលមកហើយនោះ ឈ្មោះថា **ទោវចស្សតា** ។ ព្រោះហេតុនោះឯង ទើបលោកពោលថា 'ភាពនៃបុគ្គលដែលគេប្រដៅបានដោយលំបាកនោះ ដោយអត្ថ ក៏គឺជាសង្ខារក្ខន្ធ' ។ ក៏លោកពោលហើយ យ៉ាងដូច្នេះ ព្រោះភាវៈនៃសង្ខារក្ខន្ធ មានចេតនាជាប្រធាន ។ បទថា **'ឯតេនាការេន'** មានសេចក្ដីថា ដោយអាការៈគឺភាពជាអ្នកមិនប្រកាន់យកខាងស្ដាំ ។ ភាពនៃបុគ្គលជាអ្នកដែលគេប្រដៅបានដោយងាយ គប្បីជ្រាប ដោយន័យដែលផ្ទុយផ្សេងពីគ្នា នៃពាក្យដែលបានពោលមកហើយ ដោយពាក្យជាដើមថា 'កិរិយាប្រដៅបាន ដោយងាយ ក្នុងបុគ្គលអ្នកប្រកាន់យកដោយខាងស្ដាំ អ្នកត្រេកអរក្នុងការអនុលោមតាម ប្រព្រឹត្តទៅមួយអន្លើដោយសេចក្ដីអើពើនុ៎ះ រមែងមាន ហេតុនោះ បុគ្គលនោះឈ្មោះថា ជាអ្នកដែលគេប្រដៅបានដោយងាយ" ។

(៧៧) ភាពនៃបុគ្គលដែលគេប្រដៅបាន ដោយងាយនោះ

លោកហៅថា " ជាធម៌ធ្វើនូវទីពឹង " ។ ព្រោះហេតុនោះ ទើប ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ ក្នុងសូត្រទី ៧ ក្នុងទុតិយវគ្គ ទសកនិបាត អង្គុត្តរនិកាយ ថា " ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែល គេប្រដៅងាយ ប្រកបដោយធម៌ជាគ្រឿងធ្វើនូវភារៈ ជាអ្នកប្រដៅ ងាយ ជាអ្នកអត់ធន់ ទទួលយកនូវពាក្យប្រៀនប្រដៅ ដោយចំណែក ខាងស្តាំ ដោយហេតុណា, ធម៌នេះឯង ជាធម៌គួររលឹករកគ្នា " ។

(៧៨) អដ្ឋកថាសត្តមសូត្រនោះ និង អដ្ឋកថាទសកៈ ក្នុង សង្គីតិសូត្រ ថា " បណ្តាបទទាំងនោះ បទថា ' សុវចោ ' មានសេចក្តី ថា ជាអ្នកដែលគេគប្បីប្រដៅ គឺ គប្បីទូន្មានបាន ដោយងាយ ។ បទថា ' ខមោ ' មានសេចក្តីថា ត្រូវគេប្រដៅ ដោយពាក្យធ្ងន់ អាក្រក់ ដោយពាក្យរឹងរូស ក៏អត់ធន់បាន គឺ មិនចេះក្រោធខឹង ។ ២ បទថា ' បទក្ខិណគ្គាហី អនុសាសនី ' មានសេចក្តីថា បុគ្គល ពួកខ្លះ កាលគេប្រៀនប្រដៅ រមែងទទួលយក ដោយចំណែកខាង ឆ្វេង គឺ រមែងពោលជំទាស់ ឬ មិនស្តាប់ដើរចេញទៅ យ៉ាងណា មិញ, មិនធ្វើយ៉ាងដូច្នោះ ហើយពោលថា ' ម្នាលអ្នកដ៏ចំរើន ចូរអ្នកទាំងឡាយប្រៀនប្រដៅ ចូរទូន្មានចុះ, កាលបើអ្នកទាំង ឡាយមិនប្រៀនប្រដៅទេ, បុគ្គលដទៃ អ្នកណាទៅ នឹងប្រៀន ប្រដៅ ' ដូច្នេះហើយ ឈ្មោះថា ទទួលយកនូវចំណែកខាងស្តាំ " ។

ដីកាសត្ថមសូត្រនិងសត្តិកិសូត្រនោះថា " បទថា 'ខមោ' គឺ ជាអ្នកអត់ធន់ ។ ដើម្បីនឹងសំដែង នូវភារៈ នៃភិក្ខុនោះ ជាអ្នកអត់ធន់នោះឯង ទើបលោកពោលពាក្យជាដើមថា 'គាឡ្ហ' ។ បទថា 'វាមតោ' គឺ ដោយខុស ឬ ដោយមិនធ្វើទុកក្នុងចិត្តដោយឧបាយ ។ បទថា 'បដិប្បរតិ' គឺ រមែងតាំងនៅ ដោយភាពជាសឹកសត្រូវ ។ បទថា 'បទក្ខិណំ' គឺ រមែងទទួលយក ដោយល្អ ឬ ដោយធ្វើទុកក្នុងចិត្តដោយឧបាយ " ។

អដ្ឋកថាអនុមានសូត្រ ក្នុងទុតិយវគ្គ មូលបណ្ណាសកៈថា " បទថា 'បដិប្ផរតិ' បានដល់ ជាអ្នកក្រោធខឹងតប គឺ ជាសឹកសត្រូវ តាំងនៅ " ។

ដីកាអនុមានសូត្រនោះថា " បដិ សព្ទ គឺជាបរិយាយនៃបច្ចត្ថិកៈ សព្ទ ។ សេចក្តីព្យាយាម ឈ្មោះថា កិរិយាផ្សាយទៅ បានដល់ កិរិយាតាំងចុះ ដោយអាការៈយ៉ាងដូច្នេះ ក្នុងទីនេះ ព្រោះហេតុនោះ ទើបលោកពោល ថា ' បទថា 'បដិប្ផរតិ' បានដល់ ជាអ្នកក្រោធខឹងតប គឺ ជាសឹកសត្រូវ តាំងនៅ " ។

(៧៩) ភារៈនៃបុគ្គលដែលគេប្រដៅងាយនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា " ជាមង្គល " ព្រោះជាហេតុនៃកិរិយាបានទុវឱវាទានុសាសនី អំពីសំណាក់ នៃបុគ្គលអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ

ស្មើគ្នា និង ព្រោះជាហេតុនៃការសម្រេចនូវគុណគឺការលះបង់ទោសៈ ចោលបាន ។ ព្រោះហេតុនោះ ព្រះមហាមោគ្គល្លានត្ថេរ កាលនឹងសំដែងធម៌ដល់ភិក្ខុទាំងឡាយ ទើបពោល ក្នុងអនុមានសូត្រ ថា " ម្នាលលោកដ៏មានអាយុ ក៏ប្រសិនបើ ភិក្ខុបវារណាទុក ថា ' សូមលោកដ៏មានអាយុទាំងឡាយ ប្រៀនប្រដៅខ្ញុំចុះ, ខ្ញុំជាអ្នកដែលលោកដ៏មានអាយុទាំងឡាយ គប្បីប្រៀនប្រដៅបាន ' ។ ប៉ុន្តែ ភិក្ខុនោះ ជាអ្នកដែលគេប្រដៅបាន ដោយកម្រ ប្រកបដោយធម៌ជាគ្រឿងធ្វើនូវភាវៈជាអ្នកដែលគេប្រដៅបាន ដោយកម្រ មិនចេះអត់ធន់ មិនទទួលយកនូវអនុសាសនី ដោយចំណែកខាងស្តាំ, គ្រានោះឯង បុគ្គលអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរស្មើគ្នារមែងមិនសម្គាល់នូវភិក្ខុនោះ ថាជាអ្នកគួរប្រៀនប្រដៅបាន មិនសម្គាល់ថាជាអ្នកគួរទូន្មានបាន និងមិនសម្គាល់នូវសេចក្តីស្និទ្ធស្នាល ដែលខ្លួនគប្បីជួបប្រទះ ក្នុងបុគ្គលនោះ " ដូច្នេះ និង ថា " ម្នាលលោកដ៏មានអាយុ ក៏ប្រសិនបើ ភិក្ខុមិនបវារណា ថា ' សូមលោកដ៏មានអាយុទាំងឡាយ ប្រៀនប្រដៅខ្ញុំចុះ, ខ្ញុំជាអ្នកដែលលោកដ៏មានអាយុទាំងឡាយគប្បីប្រៀនប្រដៅបាន ' ។ ប៉ុន្តែ ភិក្ខុនោះជាអ្នកដែលគេប្រដៅងាយ ប្រកបដោយធម៌ជាគ្រឿងធ្វើនូវភាវៈ ជាអ្នកដែលគេប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកនូវអនុសាសនី ដោយ

ចំណែកខាងស្តាំ, គ្រានោះឯង សព្រហ្មចារីបុគ្គល រមែងសម្គាល់នូវភិក្ខុនោះ ថា ជាអ្នកគួរប្រៀនប្រដៅបាន រមែងសម្គាល់ថា ជាអ្នកគួរទូន្មានបាន និងរមែងសម្គាល់ នូវសេចក្តីស្និទ្ធស្នាល ដែលខ្លួនគប្បីបានជួបប្រទះ ក្នុងបុគ្គលនោះ ” ។

(៨០) អដ្ឋកថាអនុមានសូត្រនោះថា “ បណ្តាបទទាំងនោះ ២ បទថា ‘ **អប្បទក្ខិណគ្គាហី អនុសាសនី** ’ មានសេចក្តីថា បុគ្គលណា ត្រូវបុគ្គលដទៃ ប្រៀនប្រដៅ ទើបពោលថា ‘ ព្រោះហេតុអ្វី បានជាពួកអ្នកប្រៀនប្រដៅខ្ញុំ ?, ខ្ញុំរមែងដឹង នូវរបស់ដែលគួរនិងមិនគួរ មានទោសនិងមិនមានទោស មានប្រយោជន៍និងមិនមានប្រយោជន៍ ដល់ខ្លួន ” ដូច្នេះ, បុគ្គលនេះ ឈ្មោះថា រមែងមិនទទួលយកនូវអនុសាសនី ដោយចំណែកខាងស្តាំ ឈ្មោះថា រមែងទទួលយក ដោយចំណែកខាងឆ្វេង, ព្រោះហេតុនោះ ទើបលោកពោលថា ‘ ជាអ្នកមិនទទួលយកនូវអនុសាសនី ដោយចំណែកខាងស្តាំជាប្រក្រតី ’ ដូច្នេះ ” ។

ដីកាអនុមានសូត្រនោះថា “ អ្នកទទួលយក ដោយចំណែកខាងស្តាំជាប្រក្រតី ឈ្មោះថា **បទក្ខិណគ្គាហី** ។ អ្នកមានប្រក្រតីទទួលយកដោយចំណែកខាងស្តាំ មិនមាន ឈ្មោះថាអ្នកមានប្រក្រតីមិនទទួលយក ដោយចំណែកខាងស្តាំ ។ បទថា ‘ **វាមតោ** ’

ប្រែថា ខាងឆ្វេង, អធិប្បាយថា 'ដោយបរិយាយដែលផ្ទុយផ្សេងពីគ្នា ចាកពាក្យដែលបានពោលមកហើយ " ។

បណ្តាធម៌ទាំងនោះ ធម៌ ១៦ ប្រការ មានភាពជាអ្នកប្រាថ្នាលាមកជាដើម ឈ្មោះថា ធម៌ជាគ្រឿងធ្វើនូវភាវៈ ជាអ្នកដែលគេប្រដៅបានដោយកម្រ ព្រោះជាហេតុធ្វើ នូវភាពជាអ្នកដែលគេប្រដៅបានដោយកម្រ ។ ធម៌ ១៦ ប្រការ មានភាពជាអ្នកប្រាថ្នាតិចជាដើម ឈ្មោះថា ធម៌ជាគ្រឿងធ្វើនូវភាវៈ ជាអ្នកដែលគេប្រដៅបានដោយងាយ ព្រោះមានន័យផ្ទុយគ្នា អំពីធម៌ជាគ្រឿងធ្វើនូវភាពជាអ្នកដែលគេប្រដៅបាន ដោយកម្រនោះ ។ ធម៌ទាំងអស់នោះ អ្នកសិក្សា គប្បីត្រួតមើល ក្នុងអនុមានសូត្រ ។

(៨១) ក៏ធម្មតាបុគ្គលដែលគេប្រដៅងាយ ឈ្មោះថា រមែងប្រតិបត្តិ ដើម្បីលះបង់នូវទោស របស់ខ្លួនផង របស់បុគ្គលដទៃផង ។ ព្រោះហេតុនោះ ភាពជាអ្នកដែលគេប្រដៅងាយ របស់បុគ្គលនោះ រមែងជាហេតុបានសម្រេច នូវគុណគឺការលះបង់ នូវទោសបាន ។ មួយទៀត ភាពជាអ្នកដែលគេប្រដៅងាយ ឈ្មោះថា ជាមង្គល ព្រោះភាវៈជាអ្នកមិននៅឆ្ងាយពីការបានសម្រេចនូវគុណវិសេស ។ ព្រោះហេតុនោះ ទើបលោកពោល ក្នុងអដ្ឋកថាមេត្តសូត្រ ថា " ក៏បុគ្គលណា ត្រូវបុគ្គលដទៃប្រដៅ ថា 'របស់នេះ អ្នកមិនគប្បីធ្វើ'

ដូច្នេះ ក៏ពោល ថា ‘ អ្នកបានឃើញហើយឬ ? អ្នកបានឮហើយឬ ? អ្នកជាអ្វីនឹងខ្ញុំ បានជាមកប្រៀនប្រដៅ អ្នកជាព្រះឧបជ្ឈាយ៍ ជាអាចារ្យ ជាមិត្រដែលជួបគ្នាម្តងៗ ជាមិត្រមាំមួនឬ ? ’ ដូច្នេះខ្លះក៏មាន, រមែងបៀតបៀន ដោយភាពជាអ្នកនៅស្ងៀមខ្លះក៏មាន, យល់ព្រមហើយ មិនធ្វើដូច្នោះក៏មាន, បុគ្គលនោះ រមែងស្ថិតនៅក្នុងទីឆ្ងាយ អំពីការបានសម្រេចនូវគុណវិសេស ។ ចំណែកបុគ្គលណា កាលត្រូវគេប្រៀនប្រដៅ ក៏ពោលថា ‘ បពិត្រលោកដ៏ចំរើន ប្រពៃណាស់, លោកម្ចាស់ពោលត្រូវហើយ, ធម្មតាទោសរបស់ខ្លួន រមែងមើលឃើញ ដោយលំបាក, លោកម្ចាស់បានឃើញនូវកម្មដូច្នេះហើយ អាស្រ័យនូវសេចក្តីអនុគ្រោះ ហើយគប្បីប្រៀនប្រដៅខ្ញុំម្តងទៀតចុះ, យូរពេលណាស់ ខ្ញុំនឹងបានឱវាទអំពីសំណាក់ របស់លោកម្ចាស់ ’ ដូច្នេះ និងរមែងប្រតិបត្តិតាមសមគួរដល់ឱវាទដែលលោកបានប្រៀនប្រដៅ, បុគ្គលនោះ រមែងស្ថិតនៅ ក្នុងទីមិនឆ្ងាយ អំពីការបានសម្រេច នូវគុណវិសេស ។ ហេតុនោះ បុគ្គលកាលទទួលពាក្យ របស់អ្នកដទៃយ៉ាងនេះហើយធ្វើ (តាម) ទើបបានឈ្មោះថា ជាអ្នកដែលគេប្រដៅងាយ ” ។

(៨២) ក៏បុគ្គលដែលគេប្រដៅងាយ មាន ២ ពួក, ពួកខ្លះគួរសរសើរ, ពួកខ្លះ មិនគួរសរសើរ, ព្រោះហេតុនោះ ទើបព្រះ

ដ៏មានព្រះភាគ ត្រាស់ក្នុងកកចូបមសូត្រថា “ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ជាអ្នកដែលគេប្រដៅងាយ ដល់នូវភាពជាអ្នកដែលគេប្រដៅងាយ ព្រោះហេតុនៃចីពរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ, តថាគត មិនហៅភិក្ខុនោះថា ‘ជាអ្នកដែលគេប្រដៅងាយ’ ឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ? ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុនោះ កាលបើមិនបាននូវចីពរ ។ល។ បរិក្ខារនោះ មិនមែនជាអ្នកដែលគេប្រដៅងាយឡើយ, មិនមែនដល់នូវភាពជាអ្នកដែលគេប្រដៅងាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកភិក្ខុណា កាលធ្វើសក្ការៈចំពោះធម៌ កាលធ្វើសេចក្ដីគោរពធម៌ កាលប្រព្រឹត្តឱនលំទោនធម៌ រមែងជាអ្នកដែលគេប្រដៅងាយ រមែងដល់នូវភាពដែលគេប្រដៅងាយ, តថាគតហៅភិក្ខុនោះថា ‘ជាអ្នកដែលគេប្រដៅងាយ’ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ពួកអ្នកទាំងឡាយ គប្បីសិក្សា ក្នុងព្រះធម្មវិន័យនេះ យ៉ាងដូច្នេះថា ‘ពួកយើង កាលធ្វើសក្ការៈចំពោះធម៌ ធ្វើសេចក្ដីគោរពធម៌ ប្រព្រឹត្តឱនលំទោននូវធម៌ នឹងជាអ្នកដែលគេប្រដៅងាយ នឹងដល់នូវភាពជាអ្នកដែលគេប្រដៅបានដោយងាយ’ ដូច្នេះ, ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងដូច្នេះឯង” ។

(៨៣) អដ្ឋកថាកកចុបមសូត្រនោះថា “បណ្តាបទទាំងនោះ ២ បទថា ‘**យោ ចីវរ ។ប។ បរិក្ខារហេតុ**’ មានសេចក្តីថា ភិក្ខុណា កាលបាននូវវត្ថុដ៏ប្រណិតៗ ទាំងឡាយ មានចីពរជាដើម នេះ រមែងធ្វើនូវការបរិកម្មជើង និងការបរិកម្មខ្នងជាដើម ដោយកិរិយាពោលពាក្យដដែលៗប៉ុណ្ណោះ ។ បទថា ‘**អលភមានោ**’ បានដល់ កាលមិនបាន ដូចជាខ្លួនធ្លាប់បាន ក្នុងកាលមុន ។ ២ បទថា ‘**ធម្មំយេវ សក្ករោន្តោ**’ បានដល់ ធ្វើនូវធម៌ប៉ុណ្ណោះឲ្យជាទីសក្ការៈ គឺឲ្យជារបស់ដែលខ្លួនបានធ្វើល្អហើយ ។ បទថា ‘**គរុករោន្តោ**’ បានដល់ ធ្វើឲ្យជាទីគោរព គឺឲ្យធ្ងន់ ។ បទថា ‘**អបចាយមានោ**’ បានដល់ សំដែងនូវកិរិយាកោតក្រែង គឺកិរិយាប្រព្រឹត្តិឱនលំទោន ចំពោះធម៌ដោយពិត” ។

(៨៤) ព្រោះហេតុនោះ បុគ្គលគប្បីធ្វើនូវការគោរពធម៌ហើយ ជាអ្នកដែលគេប្រដៅងាយ ដូចជាព្រះរាធត្ថេរ ដូច្នោះឯង ។

## ( រឿងព្រះរាធត្ថេរ )

បានឮថា ព្រះរាធត្ថេរនោះ បួសហើយ ក្នុងសំណាក់នៃព្រះសារីបុត្តត្ថេរ ដោយន័យដែលបានពោលហើយ ក្នុងកតញ្ញុតាកថា ។ ព្រះថេរៈ បាននាំព្រះរាធត្ថេរនោះ ទៅកាន់គាមកាវាស ហើយនៅ

ក្នុងទីនោះ បានទូន្មានប្រៀនប្រដៅព្រះរាធត្ថេរនោះ ជារឿយៗ ថា " របស់នេះ អ្នកគប្បីធ្វើ, របស់នេះ អ្នកមិនគប្បីធ្វើឡើយ " ដូច្នេះ ៗ ព្រះរាធត្ថេរនោះ បានជាអ្នកដែលគេប្រដៅងាយ ជាអ្នកមានប្រក្រតីទទួលយកអនុសាសនី ដោយចំណែកខាងស្តាំ; ព្រោះហេតុនោះ ព្រះរាធត្ថេរ កាលប្រតិបត្តិតាមឱវាទ ដែលព្រះសារីបុត្របានដាស់តឿនហើយ ដោយ ២-៣ ថ្ងៃប៉ុណ្ណោះ ក៏បានសំរេចព្រះអរហត្ត ៗ ព្រះថេរៈ បាននាំព្រះរាធត្ថេរនោះ ទៅថ្វាយបង្គំព្រះសាស្តា អង្គុយហើយ ត្រូវព្រះសាស្តាត្រាស់សួរ ថា " ម្នាលសារីបុត្រ តើកូនសិស្សរបស់អ្នក ជាអ្នកដែលគេប្រដៅងាយឬទេ ? " ដូច្នេះហើយ ក្រាបទូល ថា " បពិត្រព្រះអង្គដ៏ចំរើន ត្រូវហើយ, កូនសិស្សរបស់ខ្ញុំព្រះអង្គ ជាអ្នកដែលគេប្រដៅងាយ យ៉ាងក្រៃលែង, កាលបើខ្ញុំព្រះអង្គពោលទោសអ្វីមួយ, ក៏មិនដែលក្រោធខឹងឡើយ " ៗ

ព្រះសាស្តា កាលនឹងទ្រង់ធ្វើព្រះរាធត្ថេរនោះ ឲ្យជាបែបយ៉ាងហើយ ទ្រង់ឱវាទនូវភិក្ខុទាំងឡាយ ទើបទ្រង់ត្រាស់ ថា " ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុគប្បីជាអ្នកដែលគេប្រដៅងាយ ដូចជាព្រះរាធត្ថេរដូច្នោះ, សូម្បីត្រូវគេចង្អុលបង្ហាញទោសហើយ ដាស់តឿនក៏មិនត្រូវក្រោធខឹងឡើយ " ដូច្នេះ កាលនឹងទ្រង់ឱវាទ ដោយបរិយាយ សូម្បីដទៃផ្សេងទៀត ទើបទ្រង់ត្រាស់ ថា " ក៏បុគ្គលអ្នក

ឲ្យនូវឱវាទ ភិក្ខុគប្បីឃើញថា ដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យឲ្យដូច្នោះ ”។ អធិប្បាយថា “ ប្រៀបដូចជាមនុស្សកំសត់ មិនធ្វើនូវសេចក្ដីក្រោធខឹង ក្នុងបុគ្គលអ្នកគម្រាមកំហែងក្ដី វាយប្រហារក្ដីដោយពោល ថា ‘ ចូរអ្នកទទួលយកទ្រព្យនេះចុះ ’ ដូច្នេះហើយ ប្រាប់នូវកំណប់ទ្រព្យឲ្យ ជាអ្នកមានតែសេចក្ដីត្រេកអរតាមប៉ុណ្ណោះយ៉ាងណាមិញ, កាលបើបុគ្គលប្រាកដដូច្នោះ ឃើញទោសដែលមិនសមគួរ ឬសេចក្ដីភ្លាំងភ្លាត់ហើយ បង្ហាញប្រាប់, ភិក្ខុមិនគួរធ្វើសេចក្ដីក្រោធខឹង, គប្បីជាអ្នកត្រេកអរដោយពិត, គឺ ត្រូវតែបវារណាតែម្ដង ថា ‘ បពិត្រលោកម្ចាស់ដ៏ចំរើន កម្មដ៏ធំ គឺលោកម្ចាស់ទាំងឡាយ កាលស្ថិតនៅក្នុងឋានៈជាអាចារ្យនិងព្រះឧបជ្ឈាយ៍របស់ខ្ញុំ ដាស់តឿន ឈ្មោះថាបានធ្វើហើយ, សូមលោកម្ចាស់ទាំងឡាយ គប្បីដាស់តឿនខ្ញុំ ម្ដងទៀត ’ ដូច្នេះ ក៏យ៉ាងដូច្នោះដែរ ”។

រឿងព្រះរាធត្ថេរ មកក្នុងអដ្ឋកថាគាថា ថា “ និធីនំវ បវត្តារំ ” ដូច្នេះជាដើម ក្នុងបណ្ឌិតវគ្គនៃធម្មបទ ។

(៨៥) បុគ្គលដែលគេប្រដៅងាយ រមែងបាននូវសេចក្ដីសុខដោយប្រការដូច្នេះឯង ។ ក្នុងរឿងបានសេចក្ដីសុខ របស់អ្នកដែលគេប្រដៅងាយនេះ គប្បីសំដែងតិបល្លត្ថជាតក ក្នុងទុតិយវគ្គឯកនិបាត និងភិសបុប្ផជាតក ក្នុងទុតិយវគ្គ ឆក្កនិបាត ។ ចំណោក

បុគ្គលដែលគេប្រដៅបានដោយកម្រ រមែងបាននូវសេចក្ដីទុក្ខ ។ ក្នុងរឿងបានសេចក្ដីទុក្ខ របស់បុគ្គលដែលគេប្រដៅបាន ដោយកម្រនេះ គប្បីសំដែងវេឡុកជាតក វេទព្ភជាតក ក្នុងបញ្ចមវគ្គ ឯកនិបាត គោធជាតក ក្នុងបណ្ណារសមវគ្គ នៃឯកនិបាតនោះដូចគ្នាដែរ និងឥន្ទសមានគោត្តជាតក ក្នុងទុតិយវគ្គ នៃទុកនិបាត ។

(៨៦) ក៏បុគ្គលណា រមែងធ្វើតាមពាក្យ របស់បុគ្គលអ្នកប្រៀនប្រដៅ ព្រោះភាពនៃខ្លួនជាអ្នកដែលគេប្រដៅងាយ, បុគ្គលនោះ រមែងបាននូវសេចក្ដីសុខ ។ ឯបុគ្គលណា មិនធ្វើតាម, បុគ្គលនោះ រមែងបាននូវសេចក្ដីទុក្ខ ។ ក៏ក្នុងសេចក្ដីនេះ មានរឿងឈ្មួញ ៥០០ នាក់ ក្នុងអតីតកាល ជាឧទាហរណ៍ ។

## ( រឿងពាណិជ្ជ ៥០០ នាក់ )

ក្នុងអតីតកាល មាននគរយក្ស ឈ្មោះថា សិរីសវត្ថុ ក្នុងតម្ពបណ្ណិទ្វីប ។ កាលបើឈ្មួញទាំងឡាយ ដែលមានទូកបែកធ្លាយ មកដល់ហើយ, យក្សទាំងឡាយ ក្នុងនគរនោះ បានឲ្យនូវយាគូនិងភ័ត្តជាដើម ដល់ឈ្មួញទាំងនោះ ហើយសួរថា “អ្នកទាំងឡាយ មកហើយក្នុងនគរនេះ ដោយការងារអ្វី ?” ។ ឈ្មួញទាំងឡាយប្រាប់ថា “ពួកយើងជាអ្នកលិចទូក បានជាមកក្នុងនគរនេះ” ។

ពួកនាងយក្ខិនីនោះ ប្រាប់ថា " នែលោកម្ចាស់ទាំងឡាយ ល្អហើយ កាលបើពួកប្តីរបស់ខ្ញុំទាំងឡាយ ឡើងទូកទៅហើយ, កន្លងទៅបាន ៣ ខែហើយ, អ្នកទាំងនោះ នឹងស្លាប់ហើយ, ឯពួកលោកម្ចាស់ក៏នៅជាឈ្មួញដដែល, ពួកយើង នឹងបានជាភរិយា របស់លោកម្ចាស់ទាំងឡាយ " ដូច្នេះហើយ ក៏លួងលោម ពួកឈ្មួញទាំងនោះនាំទៅកាន់នគរយក្ស, បើពួកមនុស្ស ដែលខ្លួនចាប់បានអំពីមុននៅសល់, ក៏យកសោពិសេស មកដាក់មនុស្សទាំងនោះ ហើយឃាំងទុកក្នុងគុក យកមនុស្សដែលខ្លួនចាប់បានមកខាងក្រោយ ធ្វើជាប្តីរបស់ខ្លួនៗ, ប៉ុន្តែកាលបើមិនបានពួកមនុស្សដែលលិចទូក ក្នុងទីជាទីនៅរបស់ខ្លួនៗទេ ក៏ត្រាច់ចរទៅកាន់ច្រាំង នៃសមុទ្រ យ៉ាងដូច្នេះ គឺ កាន់ច្រាំងសមុទ្រ ឈ្មោះកល្យាណី ខាងត្រើយនាយកាន់ច្រាំងសមុទ្រ ឈ្មោះនាគទ្វីប ខាងត្រើយអាយ ៗ នេះគឺជាប្រពៃណីយ៍ របស់ពួកនាងយក្ខិនីទាំងឡាយ ៗ

ក្រោយមក ថ្ងៃមួយ ពួកឈ្មួញ ៥០០ នាក់ បានលិចទូកហើយ ក៏នាំគ្នាហែលទឹកឡើង ត្រង់កៀរនគរ ពួកនាងយក្ខិនីនោះ ៗ ពួកនាងយក្ខិនីទាំងនោះ លួងលោមពួកឈ្មួញទាំងនោះហើយ នាំមកហើយ បានចងពួកមនុស្សដែលខ្លួនចាប់បានមកក្នុងពេលមុន ឃាំងទុកក្នុងគុកហើយ ៗ ពេលនោះ នាងយក្ខិនីជាចម្បង ក៏បានយក

នាយឈ្មួញជាចម្បងធ្វើជាប្ដី, ពួកនាងយក្ខិនីក្រៅអំពីនេះ ក៏យកពួកឈ្មួញដែលសេសសល់ ធ្វើជាប្ដី, ក្នុងវេលារាត្រី កាលបើពួកឈ្មួញទាំងនោះ ដេកលក់ហើយ, ទើបក្រោកឡើងទៅខាំស៊ី ពួកមនុស្សទាំងឡាយ ក្នុងគុក ហើយបានត្រឡប់មកវិញ ។ នាយឈ្មួញជាចម្បង កាលលបឃ្លាំមើល ទើបដឹង ថា ភរិយារបស់ខ្លួនជានាងយក្ខិនី ហើយប្រាប់ដល់ពួកឈ្មួញឯទៀតៗ ពោល ថា "មកអ្នកទាំងឡាយ, ពួកយើងនឹងរត់គេចចេញទៅ" ។ បណ្ដាពួកឈ្មួញទាំងនោះ ពួកឈ្មួញ ២៥០ នាក់ មិនព្រមទៅ ដោយគិតថា "ពួកយើងមិនអាច ដើម្បីនឹងលះបង់ចោលនាងយក្ខិនីទាំងនេះបានឡើយ" ។ ឈ្មួញជាចម្បងនោះ នាំពួកឈ្មួញ ២៥០ នាក់ ដែលជឿតាមពាក្យរបស់ខ្លួន គេចចេញទៅហើយ ។

ក៏ក្នុងគ្រានោះ ព្រះពោធិសត្វទ្រង់កើតជាស្ដេចសេះវលាហក មានខ្លួនសសុទ្ធ មានឫទ្ធិ ហោះហើរទៅកាន់វេហាបាន បានទៅកាន់តម្ពបណ្ណិទ្វីប ចាកហិមវន្តប្រទេស បានស៊ីស្រូវសាលីដែលកើតឯង ហើយទើបត្រាច់ទៅ, ក៏កាលនឹងត្រាច់ទៅ ក៏និយាយជាភាសានៃមនុស្ស ដែលពេញប្រៀបដោយសេចក្ដីករុណា ៣ ដង ថា "បុគ្គលអ្នកប្រាថ្នានឹងទៅកាន់ជនបទ មានដែរឬទេ ?" ។ ពួកឈ្មួញទាំងនោះ បានឮនូវពាក្យ របស់ស្ដេចសេះពោធិសត្វនោះ

ហើយ ទើបប្រណមអញ្ជលី ពោលថា "ពួកយើងខ្ញុំ នឹងទៅ" ។ ស្តេចសេះពោលថា "បើដូច្នោះ ចូរពួកអ្នកឡើងជិះលើខ្នងខ្ញុំចុះ" ។ គ្រានោះ ពួកឈ្មួញខ្លះ បានឡើងជិះលើខ្នង, ពួកខ្លះ ចាប់កន្ទុយ, ពួកខ្លះ ឈរប្រណមអញ្ជលី ។ ស្តេចសេះនោះ បាននាំពួកឈ្មួញទាំងអស់ ដោយទីបំផុត សូម្បីពួកឈ្មួញដែលឈរប្រណមអញ្ជលីទៅដោយអានុភាពនៃខ្លួន ឲ្យស្ថិតនៅក្នុងស្ថានទីរៀង ៗ ខ្លួនហើយ ក៏បានទៅកាន់ទីលំនៅរបស់ខ្លួនដូចដើមវិញ ។ ឯមនុស្ស ២៥០ នាក់ ដែលមិនព្រមភៀសខ្លួនរត់ចេញ ត្រូវពួកនាងយក្ខិនីស៊ីហើយ ក្នុងពេលដែលពួកឈ្មួញដទៃទៀតលិចទូកមកដល់ហើយ ។

(៨៧) ចំណែកព្រះសាស្តា លុះទ្រង់សំដែងនូវអតីតនិទាននេះហើយ ទើបទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ពួកឈ្មួញទាំងឡាយ ដែលដល់នូវអំណាច របស់ពួកនាងយក្ខិនីទាំងនោះ ដល់នូវកិរិយាអស់ទៅនៃជីវិតហើយ, ពួកឈ្មួញដែលជឿតាមពាក្យរបស់ស្តេចសេះវលាហក បានស្ថិតនៅ ក្នុងទីលំនៅឋានរៀងៗខ្លួនហើយ យ៉ាងណាមិញ, បរិស័ទ ៤ ដែលមិនធ្វើតាមឱវាទ របស់ព្រះពុទ្ធទាំងឡាយ រមែងបាននូវសេចក្តីទុក្ខដ៏ធំ ក្នុងទីដែលធ្វើនូវកម្មដោយគ្រឿងចង ៥ យ៉ាងជាដើម ក្នុងអបាយទាំង ៤, ចំណែកបរិស័ទអ្នកធ្វើតាមឱវាទ រមែងដល់នូវឋានៈទាំងឡាយនេះ គឺ

កុសលសម្បត្តិ ៣ យ៉ាង សួគ៌ដែលជាទីប្រាថ្នា ៦ ជាន់ ព្រហ្មលោក ២០ ជាន់ និងអមតមហានិព្វាន ហើយរមែងសោយនូវសេចក្ដីសុខដ៏ច្រើន ក៏យ៉ាងដូច្នោះដែរ" ដូច្នេះហើយ ទើបទ្រង់ត្រាស់នូវ ២ គាថា ក្នុងបញ្ចមវគ្គ នៃទុកនិបាត[(១)] ថា ÷

" ពួកនរជនណា មិនធ្វើតាមឱវាទ ដែលព្រះពុទ្ធទ្រង់សំដែងហើយ, ពួកនរជននោះ នឹងដល់នូវសេចក្ដីវិនាស ដូចជាពួកឈ្មួញ ដែលអារក្សទឹកទាំងឡាយលួងលោមហើយ ដល់នូវសេចក្ដីវិនាសដូច្នោះ ។ ម្យ៉ាងទៀត ពួកនរជនណា ធ្វើតាមឱវាទ ដែលព្រះពុទ្ធទ្រង់សំដែងហើយ, ពួកនរជននោះ នឹងដល់នូវត្រើយគឺព្រះនិព្វាន ដោយសួស្ដី ដូចជាពួកឈ្មួញដែលធ្វើតាមឱវាទ របស់ស្ដេចវលាហក ដល់ហើយនូវត្រើយ នៃសេចក្ដីសួស្ដី យ៉ាងដូច្នោះឯង " ។

បណ្ដាបទទាំងនោះ បទថា " ន ករោន្តិ " ប្រែថា នឹងមិនធ្វើ ៗ បាទគាថា ថា " ព្យសនន្តេ គមិស្សន្តិ " មានសេចក្ដីថា នរជនទាំងនោះ នឹងដល់នូវសេចក្ដីវិនាស យ៉ាងធំ ៗ បាទគាថា ថា "រក្ខសីហិវ វាណិជា" សេចក្ដីថា ដូចពួកឈ្មួញដែលពួកអារក្ស

---

១_ ត្រៃបិដក ភាគទី ៥៨ / ទំព័រទី ៩៧ ។

ទឹកលួងលោមហើយ ។ បាទគាថា ថា "សោត្ថិបារំ គមិស្សន្តិ" មានសេចក្តីថា នឹងដល់នូវព្រះនិព្វាន ដោយគ្មានសេចក្តីអន្តរាយ ។ បាទគាថា ថា "វលាហកេនេវ វាណិជា" មានសេចក្តីថា ដូចជាពួកឈ្មួញ ដែលស្តេចសេះវលាហកពោល ថា 'ពួកអ្នកចូរមកចុះ' ដូច្នេះ ហើយធ្វើតាមពាក្យរបស់ស្តេចវលាហកនោះ ។ អធិប្បាយថា 'ប្រៀបដូចជា ពួកឈ្មួញទាំងនោះ ទៅដល់ច្រាំងសមុទ្រហើយ បានទៅកាន់ទីឋានរបស់ខ្លួនៗ យ៉ាងណាមិញ, នរជនទាំងឡាយ ដែលធ្វើតាមឱវាទ របស់ព្រះពុទ្ធជាដើម រមែងដល់ត្រើយនៃសំសារវដ្ត គឺ ព្រះនិព្វានបាន ក៏ដូច្នោះដែរ " ។

រឿងពួកឈ្មួញ មកក្នុងអដ្ឋកថាវលាហកជាតក ។

(៨៨) ព្រោះហេតុនោះ បុគ្គលកាលរលឹកដល់ឱវាទ របស់ព្រះសុគតនេះ គប្បីជាអ្នកដែលគេប្រដៅងាយពិត, មិនគប្បីជាអ្នកដែលគេប្រដៅក្រឡើយ ។ មួយទៀត បុគ្គលអ្នកប្រាថ្នាឲ្យព្រះសាសនា តាំងនៅបានយូរ គប្បីជាអ្នកដែលគេប្រដៅងាយពិត ។ ព្រោះថា ភាពនៃបុគ្គលជាអ្នកដែលគេប្រដៅងាយ រមែងប្រព្រឹត្តទៅ ដើម្បីមិនឲ្យព្រះសាសនាសាបសូន្យ, ចំណែក ភាពនៃបុគ្គលជាអ្នកដែលគេប្រដៅក្រ រមែងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសាសនាសាបសូន្យ ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទើបត្រាស់

ក្នុងសូត្រទី ៦ ក្នុងបឋមវគ្គ នៃចតុត្ថបណ្ណាសកៈ ក្នុងបញ្ចកនិបាត អង្គុត្តរនិកាយ ថា "ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ រមែងជាអ្នកដែលគេប្រដៅក្រ ប្រកបដោយធម៌ជាគ្រឿងធ្វើនូវភាវៈជាអ្នកដែលគេប្រដៅក្រ មិនចេះអត់ធន់ មិនទទួលយកអនុសាសនីដោយចំណែកខាងស្តាំជាប្រក្រតី, ម្នាលភិក្ខុទាំងឡាយ ធម៌ទី ២ នេះ រមែងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មសាបសូន្យ អន្តរធានទៅ" ដូច្នេះ និង ថា " ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ រមែងជាអ្នកដែលគេប្រដៅងាយ ប្រកបដោយធម៌ជាគ្រឿងធ្វើនូវភាវៈជាអ្នកដែលគេប្រដៅងាយ ចេះអត់ធន់ ទទួលយកអនុសាសនីដោយចំណែកខាងស្តាំជាប្រក្រតី, ម្នាលភិក្ខុទាំងឡាយ ធម៌ទី ២ នេះ រមែងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មតាំងនៅបានយូរ ដើម្បីមិនឲ្យព្រះសទ្ធម្មសាបសូន្យ អន្តរធានទៅបាន" ដូច្នេះឯង ។

ពណ៌នាអំពីបទ ថា ភាពជាអ្នកដែលគេប្រដៅបានដោយងាយ ចប់ ។

❀
❀ ❀

ប្រែចប់ ថ្ងៃសុក្រ ៦ រោច ខែមាឃ ឆ្នាំវកា បញ្ចស័ក ព. ស. ២៥៣៦
ថ្ងៃ ទី ១២ កុម្ភៈ ១៩៩៣

## ពណ៌នាអំពីការឃើញនូវសមណៈ

(៨៩) កិរិយាចូលទៅរក កិរិយាទំនុកបំរុង កិរិយារលឹកដល់ កិរិយាបានឮ និងកិរិយាបានឃើញ នូវបព្វជិតទាំងឡាយ ដែលមានកិលេសស្ងប់រម្ងាប់ហើយ ជាអ្នកមានកាយ វាចា ចិត្តនិងបញ្ញាបានអប់រំមកហើយ ជាអ្នកប្រកបដោយការហ្វឹកហាត់ដ៏ប្រសើរ ឈ្មោះថា **កិរិយាឃើញនូវសមណៈទាំងឡាយ** ។ កិច្ចមានកិរិយាចូលទៅរកជាដើម សូម្បីទាំងអស់ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា "ការឃើញ ដោយទេសនាយ៉ាងទាប" ។ កិច្ចមានកិរិយាចូលទៅរកជាដើមនោះ គប្បីជ្រាប ថា "ជាមង្គល" ។ សួរថា "ព្រោះហេតុអ្វី ?" ។ ឆ្លើយថា "ព្រោះភាពជារបស់ដែលមានឧបការច្រើន" ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគទើបទ្រង់ត្រាស់ ក្នុងពោជ្ឈង្គសំយុត្ត(១) មហាវគ្គ ថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយនោះណា ជាអ្នកដល់ព្រមដោយសីល ដល់ព្រមដោយសមាធិ ដល់ព្រមដោយបញ្ញា ដល់ព្រមដោយវិមុត្តិ ដល់ព្រមដោយវិមុត្តិញ្ញាណទស្សនៈ, ម្នាលភិក្ខុទាំងឡាយ សូម្បីកិរិយាឃើញនូវភិក្ខុទាំងឡាយនោះ តថាគតពោលថា មានឧបការច្រើន ។ សូម្បីការស្តាប់ភិក្ខុទាំងនោះ តថាគត ។ល។

---

១_ ត្រៃបិដក ភាគទី ៣៩ / ទំព័រទី ៤៩ ។

សូម្បីកិរិយាចូលទៅរកភិក្ខុទាំងនោះ តថាគត ។ល។ សូម្បីកិរិយាចូលទៅអង្គុយជិតភិក្ខុទាំងនោះ តថាគត ។ល។ សូម្បីកិរិយានឹករលឹកដល់ភិក្ខុទាំងនោះ តថាគត ។ល។ ម្នាលភិក្ខុទាំងឡាយ សូម្បីកិរិយាបួសតាមភិក្ខុទាំងនោះ តថគតពោលថា មានឧបការច្រើន ។ រឿងនោះ ព្រោះហេតុអ្វី ? ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្តាប់ធម៌ របស់ភិក្ខុទាំងឡាយនោះហើយ រមែងជាអ្នកគេចចេញហើយនៅដោយការគេចចេញ ២ យ៉ាង គឺ ការគេចចេញដោយកាយ ១ ការគេចចេញដោយចិត្ត ១ ។ ភិក្ខុនោះ កាលនឹងគេចចេញ ហើយនៅ យ៉ាងដូច្នោះ រមែងរំលឹករឿយ ៗ រមែងត្រិះរិះរឿយ ៗ នូវធម៌នោះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុកាលគេចចេញហើយនៅដូច្នោះ រមែងរំលឹករឿយ ៗ រមែងត្រិះរិះរឿយ ៗ នូវធម៌នោះ, ក្នុងសម័យនោះ សតិសម្ពោជ្ឈង្គ ឈ្មោះថា ភិក្ខុបានប្រារព្ធហើយ, ក្នុងសម័យណា ភិក្ខុចំរើននូវសតិសម្ពោជ្ឈង្គ, ក្នុងសម័យនោះ សតិសម្ពោជ្ឈង្គ រមែងដល់នូវការពេញដោយការចំរើន របស់ភិក្ខុ ។ ភិក្ខុនោះ កាលមានស្មារតីនៅដូច្នោះ ក៏រមែងស្រាវជ្រាវ រាវរក ដល់នូវការពិចារណានូវធម៌នោះ ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុកាលមានស្មារតីនៅដូច្នោះ រមែងស្រាវជ្រាវ រាវរក ដល់នូវ

ការពិចារណានូវធម៌នោះ ដោយបញ្ញា ។ ធម្មវិចយសម្ពោជ្ឈង្គ (អង្គនៃប្រាជ្ញាជាគ្រឿងត្រាស់ដឹងគឺកិរិយាត្រិះរិះធម៌) ឈ្មោះថា ភិក្ខុបានប្រារព្ធហើយ ក្នុងសម័យនោះ ។ ល ។ រមែងដល់នូវការពេញដោយការចំរើន របស់ភិក្ខុ ។ កាលបើភិក្ខុនោះស្រាវជ្រាវ រាវរក ដល់នូវការពិចារណានូវធម៌នោះ ដោយបញ្ញា, សេចក្ដីព្យាយាម មិនធូរថយ រមែងឈ្មោះថា ភិក្ខុនោះបានប្រារព្ធហើយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា កាលបើភិក្ខុ ស្រាវជ្រាវរាវរក នូវធម៌នោះ ដោយបញ្ញា ។ ល ។ សេចក្ដីព្យាយាម មិនធូរថយ, ក្នុងសម័យនោះ វិរិយសម្ពោជ្ឈង្គ (អង្គនៃប្រាជ្ញាជាគ្រឿងត្រាស់ដឹងគឺសេចក្ដីព្យាយាម) រមែងឈ្មោះថា ភិក្ខុនោះបានប្រារព្ធហើយ ។ ល ។ រមែងដល់នូវការពេញ ដោយការចំរើន របស់ភិក្ខុ ។ កាលបើភិក្ខុមានសេចក្ដីព្យាយាមប្រារព្ធហើយ, បីតិប្រាសចាកអាមិស គឺកិលេស ក៏កើតឡើង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា កាលបើភិក្ខុមានសេចក្ដីព្យាយាមប្រារព្ធហើយ, បីតិប្រាសចាកអាមិសគឺកិលេសក៏កើតឡើង, ក្នុងសម័យនោះ បីតិសម្ពោជ្ឈង្គ (អង្គនៃប្រាជ្ញាជាគ្រឿងត្រាស់ដឹងគឺបីតិ) រមែងឈ្មោះថា ភិក្ខុនោះបានប្រារព្ធហើយ ។ ល ។ រមែងដល់នូវការពេញដោយការចំរើន របស់ភិក្ខុ ។ កាលបើភិក្ខុមានចិត្ត

ប្រកបដោយបីតិ កាយក៏ស្ងប់រម្ងាប់ ចិត្តក៏ស្ងប់រម្ងាប់ ។ ម្នាល ភិក្ខុទាំងឡាយ ក្នុងសម័យណា កាលភិក្ខុមានចិត្តប្រកបដោយ បីតិ, កាយក៏ស្ងប់ ចិត្តក៏ស្ងប់, ក្នុងសម័យនោះ បស្សទ្ធិសម្ពោជ្ឈង្គ (អង្គនៃប្រាជ្ញាជាគ្រឿងត្រាស់ដឹងគឺសេចក្តីស្ងប់រម្ងាប់) ឈ្មោះថា ភិក្ខុបានប្រារព្ធហើយ ។ ល ។ រមែងដល់នូវការពេញដោយការ ចំរើន របស់ភិក្ខុ ។ កាលបើភិក្ខុមានកាយស្ងប់រម្ងាប់ ដល់នូវ សេចក្តីសុខហើយ, ចិត្តក៏តម្កល់នៅខ្ជាប់ខ្ជួន ។ ម្នាលភិក្ខុទាំង ឡាយ ក្នុងសម័យណា កាលបើភិក្ខុមានកាយស្ងប់រម្ងាប់ ដល់នូវ សេចក្តីសុខហើយ, ចិត្តក៏តម្កល់នៅខ្ជាប់ខ្ជួន, ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ សមាធិសម្ពោជ្ឈង្គ (អង្គនៃប្រាជ្ញាជាគ្រឿងត្រាស់ ដឹងគឺការតម្កល់ចិត្តមាំ) ឈ្មោះថា ភិក្ខុបានប្រារព្ធហើយ ។ ល ។ រមែងដល់នូវការពេញដោយការចំរើន របស់ភិក្ខុ ។ ភិក្ខុនោះ រមែងជាអ្នកសំឡឹង ដោយប្រពៃ នូវចិត្តដែលបានតម្កល់មាំហើយ ដូច្នោះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុជាអ្នក សំឡឹង ដោយប្រពៃ នូវចិត្តដែលបានតម្កល់មាំហើយ ដូច្នោះ, ក្នុង សម័យនោះ ឧបេក្ខាសម្ពោជ្ឈង្គ ( អង្គនៃប្រាជ្ញាជាគ្រឿងត្រាស់ ដឹងគឺសេចក្តីព្រងើយកន្តើយ ) ឈ្មោះថា ភិក្ខុបានប្រារព្ធហើយ, ក្នុងសម័យនោះ ភិក្ខុចំរើននូវឧបេក្ខាសម្ពោជ្ឈង្គ, ក្នុងសម័យនោះ

ឧបេក្ខាសម្ពោជ្ឈង្គ រមែងដល់នូវការពេញបរិបូណ៌ ដោយកិរិយាចំរើន របស់ភិក្ខុ " ។

បាលីក្នុងសម្បន្នសីលសូត្រ ចប់ ។

(៩០) បាលីក្នុងសម្បន្នសីលសូត្រ ក្នុងបឋមវគ្គ[១] ចតុក្កនិបាត ក្នុងឥតិវុត្តកៈ ថា " ម្នាលភិក្ខុទាំងឡាយ សូម្បីកិរិយាឃើញនូវភិក្ខុទាំងនោះ ។ ល ។ សូម្បីកិរិយាស្តាប់នូវភិក្ខុទាំងនោះ ។ ល ។ សូម្បីកិរិយាចូលទៅរកភិក្ខុទាំងនោះ ។ ល ។ សូម្បីកិរិយាចូលទៅអង្គុយជិតភិក្ខុទាំងនោះ ។ ល ។ សូម្បីកិរិយានឹករលឹករឿយ ៗ ដល់ភិក្ខុទាំងនោះ ។ ល ។ ម្នាលភិក្ខុទាំងឡាយ សូម្បីកិរិយាបួសតាមភិក្ខុទាំងនោះ តថាគតពោល ថា មានឧបការៈច្រើន ៗ ដំណើរនោះ ព្រោះហេតុអ្វី ? ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុសេពគប់ ចូលទៅអង្គុយជិតភិក្ខុបែបនោះហើយ, សីលក្ខន្ធ សូម្បីមិនទាន់ពេញបរិបូណ៌ រមែងដល់នូវការពេញបរិបូណ៌ ដោយភាវនាផង, សមាធិក្ខន្ធ ដែលមិនទាន់ពេញបរិបូណ៌ ... បញ្ញាខន្ធ ដែលមិនទាន់ពេញបរិបូណ៌ ... វិមុត្តិក្ខន្ធ ដែលមិនទាន់ពេញបរិបូណ៌ ... វិមុត្តិញ្ញាណទស្សនក្ខន្ធ ដែលមិនទាន់ពេញបរិបូណ៌ ... ក៏រមែងដល់នូវការពេញបរិបូណ៌ ដោយភាវនាផង " ។

---

១_ ត្រៃបិដក ភាគទី ៥៣ / ទំព័រទី ១៣៩ ។

(៩១) អដ្ឋកថាពោជ្ឈង្គសំយុត្ត ថា "សីលដែលជាលោកិយៈ និង លោកុត្តរៈ របស់ព្រះខីណាស្រព ព្រះដ៏មានព្រះភាគ ទ្រង់កំណត់យកហើយ ក្នុងបទ ថា 'សីលសម្បន្នា' នេះ ។ អធិប្បាយថា 'ដល់ព្រមដោយសីលនោះ' ។ សូម្បីក្នុងសមាធិនិងបញ្ញា ក៏មានន័យដូចគ្នានេះដែរ ។ ចំណែកវិមុត្តិ ក៏គឺផលវិមុត្តិនុ៎ះឯង ។ វិមុត្តិញ្ញាណទស្សនៈ បានដល់បច្ចវេក្ខណញ្ញាណ ។ កាលបើកំណត់យកសេចក្តី យ៉ាងដូច្នេះ, បណ្តាធម៌ទាំងនោះ ធម៌ ៣ យ៉ាង មានសីលជាដើម ព្រះដ៏មានព្រះភាគទ្រង់កំណត់យក ទាំងលោកិយៈ ទាំងលោកុត្តរៈ, វិមុត្តិ ជាលោកុត្តរៈតែម្យ៉ាង, វិមុត្តិញ្ញាណទស្សនៈ ជាលោកិយៈតែម្យ៉ាង ។ បទថា 'ទស្សនម្បហំ' កាត់បទជា **ទស្សនម្បិ អហំ** ។ ក៏កិរិយាឃើញនោះនុ៎ះ មាន ២ យ៉ាង គឺ កិរិយាឃើញដោយចក្ខុ ១ កិរិយាឃើញដោយញាណ ១ ។ បណ្តាកិរិយាឃើញទាំង ២ ប្រការនោះ កិរិយាឃើញ គឺកិរិយាសំឡឹងមើលនូវព្រះអរិយៈទាំងឡាយ ដោយចក្ខុដ៏ជ្រះថ្លា ឈ្មោះថា កិរិយាឃើញដោយចក្ខុ ។ ចំណែកកិរិយាឃើញ នូវលក្ខណៈដែលព្រះអរិយៈទាំងឡាយឃើញហើយ និងកិរិយាចាក់ធ្លុះលក្ខណៈដែលព្រះអរិយៈទាំងឡាយបានចាក់ធ្លុះហើយ ដោយឈាន ឬដោយមគ្គនិងផលទាំងឡាយ ឈ្មោះថា កិរិយាឃើញដោយញាណ" ។

(៩២) អដ្ឋកថាឥតិវុត្តកៈថា "ក៏ការសម្រេចនូវធម៌ ដែលធ្វើភាវៈជាព្រះអរិយៈ និងការសម្រេចនូវភាវៈជាព្រះអរិយៈ ដោយវិបស្សនា មគ្គ និងផល ឈ្មោះថា កិរិយាឃើញដោយញាណ" ។

អដ្ឋកថាសម្បន្នសូត្រទាំង ២ នោះថា " ក៏បណ្តាការឃើញទាំង ២ យ៉ាងនេះ ការឃើញដោយចក្ខុ ព្រះដ៏មានព្រះភាគ ទ្រង់អធិប្បាយហើយ ក្នុងសេចក្តីនេះ ។ ព្រោះថា សូម្បីកិរិយាសំឡឹងមើលនូវព្រះអរិយៈទាំងឡាយ ដោយចក្ខុដែលជ្រះថ្លា ក៏រមែងមានឧបការៈច្រើនដូចគ្នាដែរ ។ បទថា 'សវនំ' មានសេចក្តីថា កិរិយាបានស្តាប់ ដោយត្រចៀក កាលបើជនទាំងឡាយ ពោលថា 'ព្រះខីណាស្រពឈ្មោះនោះ នៅក្នុងរដ្ឋធានី ឬក្នុងជនបទ ក្នុងស្រុក ឬក្នុងនិគម ក្នុងវិហារ ឬក្នុងគុហាឈ្មោះនោះ" ដូច្នេះ, សូម្បីការបានពន្លំ៖ ក៏ឈ្មោះថា មានឧបការៈច្រើនដូចគ្នាដែរ ។ បទថា 'ឧបសង្កមនំ' បានដល់ ការចូលទៅរកនូវព្រះអរិយៈទាំងឡាយ ដោយចិត្តបែបនេះ ថា 'ខ្ញុំនឹងថ្វាយទាន, ខ្ញុំនឹងសួរនូវបញ្ហា, ខ្ញុំនឹងស្តាប់នូវធម៌, ខ្ញុំនឹងធ្វើសក្ការៈ' ។ បទថា 'បយិរុបាសនំ' បានដល់ ការចូលទៅអង្គុយជិត ដើម្បីសួរបញ្ហា ។ អធិប្បាយថា 'កិរិយាបានស្តាប់នូវគុណ របស់ព្រះអរិយៈទាំងឡាយហើយ ក៏ចូលទៅរកព្រះអរិយៈទាំងនោះ បាននិមន្តហើយ ថ្វាយទាន ទើបសួរនូវ

បញ្ហា ដោយន័យជាដើម ថា 'បពិត្រលោកម្ចាស់ដ៏ចំរើន ចុះអ្វីទៅ គឺជាកុសល ? " ដូច្នេះ ។

(៩៣) អដ្ឋកថាឥតិវុត្តកៈ ថា " កិរិយាធ្វើកិច្ចមានការជួយបម្រើជាដើម ឈ្មោះថា ការចូលទៅអង្គុយជិតដូចគ្នា ។ បទ ថា '**អនុស្សរណំ**' បានដល់ កិរិយានឹករលឹករឿយៗនូវអារម្មណ៍ គឺគុណវិសេសមានទិព្វវិហារជាដើម របស់ព្រះអរិយៈទាំងនោះ ថា 'ឥឡូវនេះ ព្រះអរិយៈទាំងឡាយ រមែងញ៉ាំងពេលវេលា ឲ្យកន្លងទៅ ដោយសេចក្ដីសុខ ដែលកើតអំពីឈាន វិបស្សនា មគ្គ និងផល ក្នុងទីទាំងឡាយ មានគុម្ពឈើ គុហា និងមណ្ឌបជាដើម' ដូច្នេះ ឬ ឱវាទណា ជាឱវាទដែលខ្លួនបានហើយ អំពីសំណាក់របស់ព្រះអរិយៈទាំងឡានោះ, កិរិយារលឹកឃើញនូវឱវាទនោះហើយ នឹករលឹករឿយៗ យ៉ាងដូច្នេះ ថា 'សីល លោកបានពោលហើយ ក្នុងទីនេះ, សមាធិ ក្នុងទីនេះ, វិបស្សនា ក្នុងទីនេះ, មគ្គក្នុងទីនេះ, ផល លោកពោលហើយ ក្នុងទីនេះ' ដូច្នេះ របស់បុគ្គលអ្នកអង្គុយក្នុងទីសម្រាកក្នុងពេលយប់និងពេលថ្ងៃ " ។

(៩៤) អដ្ឋកថាសំយុត្ត ថា " បទ ថា '**អនុស្សរណំ**' បានដល់ កិរិយានឹករលឹករឿយៗ ថា 'ឥឡូវនេះ ព្រះអរិយៈទាំងឡាយ រមែងញ៉ាំងពេលវេលា ឲ្យកន្លងទៅ ដោយសេចក្ដីសុខ ដែលកើត

អំពីឈាន វិបស្សនា មគ្គ និងផល ក្នុងទីទាំងឡាយ មានទីសម្រាក គុហានិងមណ្ឌបជាដើម' ដូច្នេះ ឬការរឭកដល់ឱវាទ ដែលខ្លួនបានហើយ អំពីសំណាក់ របស់ព្រះអរិយៈទាំងឡាយនោះ យ៉ាងនេះ ថា ' ។ល។ ផល លោកបានពោលហើយ ក្នុងទីនេះ' ដូច្នេះ របស់បុគ្គលដែលអង្គុយ ក្នុងទីសម្រាកក្នុងពេលយប់និងពេលថ្ងៃ ។ បទ ថា 'អនុប្បព្វជ្ជំ' គឺ កិរិយាធ្វើចិត្តឲ្យជ្រះថ្លា ក្នុងព្រះអរិយៈទាំងឡាយ ហើយចេញចាកផ្ទះ បួសក្នុងសំណាក់ នៃព្រះអរិយៈទាំងឡាយនោះ ។ ការបួសរបស់បុគ្គលដែលធ្វើចិត្តឲ្យជ្រះថ្លា ក្នុងព្រះអរិយៈទាំងឡាយ ហើយបួសក្នុងសំណាក់ នៃព្រះអរិយៈទាំងឡាយនោះឯង ប្រាថ្នានូវឱវាទានុសាសនី របស់ព្រះអរិយៈទាំងឡាយនោះផងដែរត្រាច់ទៅ ឈ្មោះថា ការបួសតាម ។ ការបួស សូម្បីរបស់បុគ្គលដែលប្រាថ្នា នូវឱវាទានុសាសនី ក្នុងសំណាក់ នៃភិក្ខុដទៃទៀត ត្រាច់ទៅ ក៏ឈ្មោះថា ការបួសតាម ។ បព្វជ្ជា សូម្បីរបស់បុគ្គលដែលបួសហើយ ក្នុងសំណាក់នៃពួកបព្វជិតដទៃ ដោយសេចក្ដីជ្រះថ្លា ក្នុងបព្វជិតដទៃ ហើយប្រាថ្នាឱវាទានុសាសនី របស់បព្វជិតដទៃដូចគ្នា ត្រាច់ទៅ រមែងមិនឈ្មោះថា ការបួសតាមទេ"។

អដ្ឋកថាឥតិវុត្តកៈថា "បព្វជ្ជា សូម្បីរបស់បុគ្គលដែលបួសក្នុងទីដទៃ ដោយសេចក្ដីជ្រះថ្លា ក្នុងព្រះអរិយៈទាំងឡាយហើយ

ប្រាថ្នានូវឱវាទានុសាសនី ក្នុងសំណាក់នៃព្រះអរិយៈទាំងឡាយ ត្រាច់ទៅ ក៏ឈ្មោះថា ការបួសតាម ដូចគ្នាដែរ " ។

(៩៥) អដ្ឋកថាពោជ្ឈង្គសំយុត្ត ថា " ក៏បណ្ដាកុលបុត្រទាំងឡាយ ដែលបានបួសហើយ យ៉ាងនោះ កុលបុត្រដែលបួសតាមព្រះមហាកស្សបត្ថេរ បានមានហើយចំនួន ១ សែននាក់ មុនគេបង្អស់ ។ កុលបុត្រដែលបួសតាម ព្រះចន្ទគុត្តត្ថេរ ដែលជាសទ្ធិវិហារិក របស់ព្រះថេរៈនុ៎ះឯង ក៏បានមានចំនួនប៉ុណ្ណោះដូចគ្នាដែរ ។ កុលបុត្រដែលបួសតាមព្រះសុរិយគុត្តត្ថេរ ដែលជាសទ្ធិវិហារិក របស់ព្រះចន្ទគុត្តត្ថេរនោះឯង ក៏បានមានចំនួនប៉ុណ្ណោះដូចគ្នាដែរ ។ កុលបុត្រដែលបួសតាមព្រះអស្សគុត្តត្ថេរ ដែលជាសទ្ធិវិហារិក របស់ព្រះសុរិយគុត្តត្ថេរនោះឯង ក៏មានហើយចំនួនប៉ុណ្ណោះដែរ ។ កុលបុត្រដែលបួសតាមព្រះយោនកធម្មរក្ខិតត្ថេរ ដែលជាសទ្ធិវិហារិក របស់ព្រះអស្សគុត្តត្ថេរនោះឯង ក៏បានមានហើយ ចំនួនប៉ុណ្ណោះដែរ ។ ចំណែកសទ្ធិវិហារិក របស់ព្រះយោនកធម្មរក្ខិតត្ថេរនោះ គឺជាព្រះកនិដ្ឋភាតា របស់ព្រះបាទអសោក មាននាមថា ព្រះតិស្សត្ថេរ ។ កុលបុត្រដែលបួសតាម ព្រះតិស្សត្ថេរនោះ បានមានហើយ ចំនួន ២ កោដិកន្លះ ( ២៥ លាន ) នាក់ ។ ចំណែក កុលបុត្រទាំងឡាយ ដែលបានបួសតាមព្រះមហិន្ទត្ថេរ រាប់មិនអស់ឡើយ ។

ក៏កុលបុត្រដែលបួស ដោយសេចក្ដីជ្រះថ្លា ក្នុងព្រះបរមសាស្ដា ក្នុងលង្កាទ្វីប រហូតដល់សព្វថ្ងៃនេះ គឺសុទ្ធតែឈ្មោះថា បួសតាមព្រះមហិន្ទត្ថេរនុ៎ះឯង ដោយពិត ៗ ២ បទថា 'តំ ធម្មំ' បានដល់ធម៌ គឺឱវាទានុសាសនី របស់ព្រះថេរៈទាំងនោះនោះ ៗ បទថា '**អនុស្សរតិ**' ប្រែថា រមែងរលឹក ៗ បទថា '**អនុវិតក្កេតិ**' គឺ រមែងធ្វើនូវធម៌ឲ្យជាសភាពត្រូវវិតក្កៈពាល់ត្រូវហើយ ៗ បទថា '**អារទ្ធោ**' បានដល់ រមែងជាសភាពពេញបរិបូណ៌ ៗ ពាក្យទាំងអស់មានជាអាទិ៍ថា '**បវិចិនតិ**' ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ ដោយអំណាចការឲ្យញាណប្រព្រឹត្តទៅ ក្នុងធម៌នោះ ៗ ម្យ៉ាងទៀត បទថា '**បវិចិនតិ**' បានដល់ ស្រាវជ្រាវនូវលក្ខណៈនៃធម៌ទាំងឡាយនោះ ៗ ៗ បទថា '**បវិចរតិ**' បានដល់ ញុំាងញាណឲ្យត្រាច់ទៅក្នុងធម៌នោះ ៗ បទថា '**បរិវីមំសមាបជ្ជតិ**' គឺ រមែងដល់នូវការពិចារណា គឺ ការត្រួតត្រាមើល បានដល់ការស្វែងរក " ៗ

(៩៦) ដីកាពោជ្ឈង្គសំយុត្តថា " វាចាត្រូវ ការងារត្រូវ ការចិញ្ចឹមជីវិតត្រូវ ដែលរាប់បញ្ចូលក្នុងមគ្គនិងផល និងធម៌ទាំងឡាយមានចេតនាជាដើម ដែលដទៃផ្សេង អំពីសម្មាវាចាជាដើមនោះ ដែលដល់នូវកិរិយាដុសខាត់ជម្រះកិលេស ឈ្មោះថា លោកុត្តរសីល

របស់ព្រះខីណាស្រព ។ ចំណែកលោកិយសីល រាប់បញ្ចូលក្នុងអព្យាក្រឹតផ្នែកកិរិយា ។ លោកិយសីលនោះ ឈ្មោះថា **ចារិត្តសីល** ។ ក៏ចារិត្តសីល មិនមានការកើតឡើងដោយពិត ព្រោះមិនមានការប្រព្រឹត្តិទៅ ដោយអំណាចនៃការវៀរចាក ។ អាចារ្យពួកខ្លះបានពោលថា 'សីលដែលប្រព្រឹត្តទៅ ក្នុងចំណែកខាងដើម ឈ្មោះថា **លោកិយសីល**' ។ កិរិយាឃើញនូវលក្ខណៈ ដោយខ្លួនឯង នៃសភាវធម៌ទាំងឡាយ ដែលបច្ច័យតាក់តែងហើយ ដោយបញ្ញាជាគ្រឿងកំណត់ដឹងដោយការពិចារណា និងកិរិយាឃើញនូវសាមញ្ញ-លក្ខណៈមានសេចក្ដីមិនទៀងជាដើម ដោយតីរណបរិញ្ញា ឈ្មោះថា កិរិយាឃើញនូវលក្ខណៈ ។ មែនពិត បុគ្គលសូម្បីកាលលះបង់ ឈ្មោះថា រមែងឃើញនូវសភាវធម៌ទាំងនោះ ដោយអាការៈគឺភាវៈជាធម៌ដែលបុគ្គលគប្បីលះបង់ ។ ការឃើញនូវលក្ខណៈ ដែលពិតប្រាកដ របស់ព្រះនិព្វាន ដោយមគ្គចិត្តនិងផលចិត្តក្តី ការឃើញនូវធម៌ដែលគួរវៀរចាកដោយឈាន ដោយឈានចិត្តក្តី ការឃើញនូវបឋវីកសិណជាដើម ដោយអភិញ្ញាចិត្តក្តី ក៏ឈ្មោះថា ការឃើញដោយញាណដូចគ្នាដែរ ។ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះបំណងយកការឃើញដោយចក្ខុ ព្រោះភាវៈនៃការស្ដាប់ និងកិរិយាចូលទៅអង្គុយជិត ព្រះអង្គទ្រង់កំណត់ទុកហើយ ពួដ៏ខាងមុខ ។ បទថា

'បញ្ហាបយិរុបាសនំ' បានដល់ ការចូលទៅអង្គុយជិត ដោយអំណាចការសួរបញ្ហា ព្រោះភារៈនៃការសួរបញ្ហាទាំងស្រុង ត្រូវការចូលទៅអង្គុយជិតនុ៎ះឯង គាស់គៀនហើយ ។ ដើម្បីនឹងសំដែង ថា 'ការនឹករលឹកដល់គុណមានសីលជាដើម ដែលខ្លួនបានស្តាប់រួចមកហើយ ដោយប្រការសំខាន់ ក៏គឺការមិនខុសប្លែកផ្សេង អំពីឱវាទដែលខ្លួនបានហើយ អំពីសំណាក់ព្រះអរិយៈទាំងនោះ ក្នុងទីសម្រាកក្នុងពេលយប់និងពេលថ្ងៃនោះឯង ដោយអំណាចនៃគុណ ឈ្មោះថាកិរិយានឹករលឹក ដល់ព្រះអរិយៈទាំងឡាយ' ដូច្នេះ ទើបព្រះអដ្ឋកថាចារ្យពោល ថា 'ឈានវិបស្សនា' ដូច្នេះ ជាដើម ។ ២ បទថា 'អញ្ញេសំ សន្តិកេ' បានដល់ ក្នុងសំណាក់នៃបព្វជិតទាំងឡាយ ដែលរាប់បញ្ចូលក្នុងសាសនាដទៃ ក្រៅអំពីព្រះអរិយៈទាំងឡាយនុ៎ះឯង ។ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា 'អនុប្បព្វជ្ជា នាម' ។ បទថា 'អញ្ញេសុ' បានដល់ក្នុងពួកបព្វជិតទាំងឡាយ មានតាបសនិងបរិព្វាជកជាដើម ដែលផ្សេង អំពីបព្វជិតអ្នករាប់បញ្ចូលក្នុងសាសនា ។ ព្រះអដ្ឋកថាចារ្យពោល ថា 'មិនឈ្មោះថា បួសតាមព្រះអរិយៈឡើយ' ព្រោះការបួសនោះ ជាការបួសខាងក្រៅ ។ កុលបុត្រទាំងឡាយ ដែលបួសតាមបានមានចំនួន ១ សែន ព្រោះការបួស របស់ព្រះមហាកស្សបត្ថេរ

ជាគុណជាតិនាំសេចក្ដីជ្រះថ្លាមកឲ្យទាំងស្រុង ដល់កុលបុត្រដែលត្រេកអរហើយ ។ ពាក្យថា 'លង្កាទីបេ' ជាពាក្យកំណត់យកនូវជនអ្នកនៅអាស្រ័យ ដោយសំដៅយកទីនៅអាស្រ័យ ។ ព្រោះថាការបួស មិនបានជាប់ទាក់ទង ជាមួយនឹងកោះឡើយ, ដោយពិតជាប់ទាក់ទង ជាមួយនឹងអាចារ្យដែលនៅក្នុងកោះ, កុលបុត្រទាំងឡាយ ឈ្មោះថាតែងបួសតាមព្រះមហិន្ទត្ថេរដោយពិតប្រាកដ, ព្រោះថា ការបួសរបស់ព្រះមហិន្ទត្ថេរនោះ មកហើយតាមលំដាប់ហូរហែមក ដោយប្រការដូច្នេះ ។ បទថា 'សរតិ' បានដល់ រមែងគិតគឺ រមែងធ្វើនូវធម៌ គឺឱវាទានុសាសនីនោះទុកក្នុងចិត្ត ។ ២ បទថា 'វិតក្កាហតំ ករោតិ' បានដល់ រមែងធ្វើនូវសេចក្ដីនោះ ឲ្យជាគុណជាតិ គឺសេចក្ដីត្រិះរិះ ឲ្យសម្រេចហើយ ដោយសេចក្ដីត្រិះរិះយ៉ាងហ្មត់ចត់ជារឿយ ៗ ។ បទថា 'អារទ្ធោ' គឺ ជាធម៌ដែលគិត្ត្ត ឲ្យសម្រេចហើយ ។ ក៏កិរិយាញ៉ាំងធម៌នោះ ឲ្យសម្រេចនោះក៏គឺកិរិយាធ្វើឲ្យសម្រេចនុ៎ះឯង ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យពោលថា 'បរិបុណ្ណោ ហោតិ' ។ បទថា 'តត្ថ' គឺ ក្នុងធម៌តាមដែលបានពោលហើយ ។ បទថា 'ញាណចារវសេន' គឺដោយអំណាចការប្រព្រឹត្តិទៅ នៃញាណ ។ ច្រើនបទថា 'តេសំ តេសំ ធម្មានំ' បានដល់ រូបធម៌និងអរូបធម៌ទាំងឡាយ ដែលមក

ហើយ ក្នុងធម៌ គឺ និព្វាននោះ ។ បទថា ' លក្ខណំ ' បានដល់ លក្ខណៈរបស់ខ្លួន និងលក្ខណៈ គឺជារបស់ដែលស្មើគ្នា ។ បទថា ' បរិចិនតិ ' គឺ រមែងដល់នូវការស្រាវជ្រាវ ដោយន័យជាដើមថា ' រូបនេះ ' ។ ២ បទថា ' ញាណំ ចរាបេតិ ' គឺ ឲ្យញាណប្រព្រឹត្តទៅ ដោយន័យជាដើម ថា ' មិនទៀងទាត់, មិនឋិតថេរ, បែកធ្លាយ, ពុកផុយ ' ។ ច្រើនបទ ថា ' វីមំសនំ ។ បេ។ អាបជ្ជតិ ' គឺ រមែងដល់នូវការឃើញ គឺការត្រិះរិះ នូវសភាវៈជារបស់ដែលមិនទៀងជាដើម ប្រៀបដូចជាបុគ្គលដល់នូវការឃើញច្បាស់នូវសត្វមានរូប និងសត្វគ្មានរូបដូច្នោះឯង ដោយជាក់ច្បាស់" ។

(៩៧) អដ្ឋកថាឥតិវុត្តកៈ ថា " ឥឡូវនេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នូវកិរិយាឃើញជាដើម នូវព្រះអរិយៈទាំងឡាយនោះ ថា ' មានឧបការៈច្រើន ' ដោយហេតុណា, ដើម្បីនឹងទ្រង់សំដែងនូវហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ' តថារូបេ ' ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា ' តថារូបេ ' គឺ ក្នុងព្រះអរិយៈដែលដល់ព្រមដោយសីល ប្រាកដដូច្នោះ ។ កិរិយាបានឃើញ កិរិយាបានស្ដាប់ និងកិរិយានឹករលឹករឿយៗ មានកិរិយាចូលទៅរក និងកិរិយាចូលទៅអង្គុយជិតជាអត្ថ ព្រោះហេតុណា, ព្រោះហេតុនោះ ដើម្បីនឹងទ្រង់សំដែង ចំពោះកិរិយាចូលទៅរក

និងកិរិយាចូលទៅអង្គុយជិតប៉ុណ្ណោះ មិនប៉ះពាល់ នឹងការឃើញ ការបានស្តាប់ និងការនឹករលឹករឿយ ៗ នោះទេ ទើបទ្រង់ត្រាស់ថា 'កាលបុគ្គលសេពគប់ ចូលទៅអង្គុយជិត' ដូច្នេះ ៗ ក៏កុលបុត្រទាំងឡាយ អ្នកមានសទ្ធាកើតឡើងហើយ ក្នុងព្រះអរិយៈទាំងឡាយ ព្រោះការបានឃើញ បានស្តាប់និងការនឹករលឹករឿយ ៗ ក៏ចូលទៅរក ចូលទៅអង្គុយជិត នឹងព្រះអរិយៈទាំងឡាយនោះ ទើបសួរនូវបញ្ហា បាននូវសវនានុត្តរិយៈហើយ នឹងញ៉ាំងគុណមានសីលជាដើម ដែលមិនទាន់ពេញបរិបូណ៌ ឲ្យពេញបរិបូណ៌ឡើង ដោយប្រការដូច្នេះ ៗ ពិតមែនដូច្នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា 'ជាអ្នកមានសទ្ធាកើតឡើងហើយ រមែងចូលទៅរក លុះចូលទៅរកហើយ រមែងចូលទៅអង្គុយជិត' ដូច្នេះជាដើម ៗ គប្បីជ្រាបការចំណែកនូវសេចក្តី នៃបទទាំង ៣ ថា 'បណ្តាបទទាំងនោះ បទថា 'សេវតោ' គឺ ចូលទៅរកសព្វ ៗ កាល ដោយអំណាចនៃការធ្វើវត្តនិងវត្តតប ៗ បទថា 'ភជតោ' គឺ គប់រក ដោយអំណាចនៃភត្តិភាព ដោយសេចក្តីស្រឡាញ់រាប់អានគ្នា ៗ បទថា 'បយិរុបាសតោ' គឺ ចូលទៅអង្គុយជិត ដោយការសួរនូវបញ្ហានិងដោយការធ្វើតាមឧបដិបត្តិ'ៗ ការបរិបូណ៌នៃវិមុត្តិញាណទស្សនៈ គប្បីជ្រាប ដោយការកើតឡើង នៃបច្ចវេក្ខណញ្ញាណ ទី ១៩" ៗ

(៩៨) ព្រោះហេតុនោះ បុគ្គលបានឃើញនូវភិក្ខុទាំងឡាយហើយ ដោយហោចទៅ គប្បីសំឡឹងមើលដោយចិត្តជ្រះថ្លា ។ ព្រោះហេតុនោះ ក្នុងអដ្ឋកថា ព្រះអដ្ឋកថាចារ្យពោលថា “កុលបុត្រអ្នកប្រាថ្នាប្រយោជន៍សុខ បានឃើញភិក្ខុទាំងឡាយ អ្នកមានសីល និមន្តមកដល់មាត់ទ្វារផ្ទះហើយ, បើទេយ្យធម៌មាន, គប្បីទទួលដោយទេយ្យធម៌ តាមកម្លាំង, បើទេយ្យធម៌មិនមានទេ, គប្បីធ្វើនូវការតាំងនៅចំពោះដែលប្រកបដោយអង្គ ៥ ហើយថ្វាយបង្គំ, កាលបើការធ្វើកិរិយាថ្វាយបង្គំដែលប្រកបដោយអង្គ ៥ នោះ មិនសម្រេច, គប្បីប្រណមអញ្ជលី នមស្សការ, កាលបើកិរិយាប្រណមអញ្ជលីនមស្សការនោះ មិនបានសម្រេចទេ, គប្បីសំឡឹងមើល ដោយចក្ខុដែលប្រកប ដោយសេចក្តីស្រឡាញ់ ដោយទឹកចិត្តដ៏ជ្រះថ្លា” ។

អដ្ឋកថាសូត្រ ទី ៤ នៃបញ្ចមវគ្គ ក្នុងទុតិយបណ្ណាសកៈ នៃតិកនិបាត អង្គុត្តរនិកាយថា “បណ្តាបទទាំងនោះ បទថា ‘បិយចក្ខូហិ’ គឺ ដោយចក្ខុដែលប្រកបដោយមេត្តា ដែលជ្រះថ្លាហើយ” ។

អដ្ឋកថាចូឡគោសិង្គសូត្រថា “ចក្ខុជាហេតុ ញុំាងចិត្តដែលប្រកបដោយមេត្តា ឲ្យតាំងនៅស៊ប់ហើយ សំឡឹងមើល ឈ្មោះថាចក្ខុដែលប្រកបទៅដោយសេចក្តីស្រឡាញ់” ។

ដីកាសូត្រទាំង ២ នោះថា “ចក្ខុដែលសំដែង នូវភាពជាអ្នក

ដែលជាទីស្រឡាញ់ ឈ្មោះថា ចក្ខុប្រកបដោយសេចក្ដីស្រឡាញ់”ៗ

(៩៩) លោកពោលហើយ ក្នុងអធិការនេះ ថា “ក៏ព្រោះបុណ្យ មានកិរិយាបានឃើញ យ៉ាងនេះឯង ជាមូលហេតុ រោគក្ដី ទោសក្ដី ឡើងបាយភ្នែកក្ដី រោគរលកកែវក្ដី រមែងមិនមានក្នុងភ្នែក រហូត ១ ពាន់ជាតិជាអនេក, ភ្នែកទាំងឡាយ ជាធម្មជាតិភ្លឺស្វាង មានសិរីប្រកបដោយពណ៌ ៥ យ៉ាង ប្រៀបដូចជាមេទ្វារកែវមណី ដែលនាងទេពធីតាបើកហើយ ក្នុងរតនវិមាន, បុគ្គលរមែងជាអ្នកបានសម្បត្តិគ្រប់បែបយ៉ាង ក្នុងពួកទេវតា និងមនុស្សអស់កាលប្រមាណ ១ សែនកប្បៗ បុគ្គលដែលជាមនុស្ស មានជាតិជាអ្នកមានបញ្ញា គប្បីសោយនូវសម្បត្តិដែលជាផល យ៉ាងនេះ ព្រោះបុណ្យដែលសម្រេចមក អំពីការបានឃើញសមណៈ ដែលខ្លួនបានឲ្យប្រព្រឹត្តទៅហើយ ដោយប្រពៃ (និង) ព្រះអដ្ឋកថាទាំងឡាយពណ៌នា នូវវិបាកសម្បត្តិ យ៉ាងដូច្នេះ នៃការបានឃើញនូវសមណៈដែលជាហេតុគ្រាន់តែញ៉ាំងសទ្ធា ឲ្យកើតឡើងហើយតែម្យ៉ាង សូម្បីរបស់ពួកសត្វតិរច្ឆាន ក្នុងទីណា ដោយហេតុណា, ហេតុនុ៎ះ មិនអស្ចារ្យសោះឡើយ” ដូច្នេះហើយ ទើបសំដែងគាថា ដោយប្រការផ្សេងទៀត ៗ ចំណែកក្នុងអដ្ឋកថាចូឡសីហនាទសូត្រ ក្នុងទុតិយវគ្គ នៃមូលបណ្ណាសកៈ លោកពោលហើយ ដោយពិស្ដារ ៗ

( រឿងសត្វមៀម )

(១០០) មែនពិត ក្នុងអដ្ឋកថាចូឡសីហនាទសូត្រនោះ លោកពោលហើយ ថា " បានឮមកថា ព្រះដ៏មានព្រះភាគ ទ្រង់អាស្រ័យនៅ ក្នុងគុហាឈ្មោះឥន្ទសាល លើភ្នំវេទិយកៈ ។ គ្រានោះសត្វមៀមមួយ, កាលបើព្រះដ៏មានព្រះភាគ ទ្រង់ស្ដេចយាងទៅកាន់ផ្ទះ ដើម្បីទ្រង់បិណ្ឌបាត, រមែងហើរទៅតាម រហូតដល់ពាក់កណ្ដាលផ្លូវ, កាលបើព្រះអង្គស្ដេចយាងចេញមក, តែងធ្វើនូវការក្រោកឡើងទទួល រហូតដល់ពាក់កណ្ដាលផ្លូវ ។ ក្នុងថ្ងៃមួយ សត្វមៀមនោះ បានហើរចុះអំពីភ្នំ ហើយថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែលមានភិក្ខុសង្ឃចោមរោមហើយ ទ្រង់គង់នៅ ក្នុងពេលសាយណ្ហសម័យ ហើយប្រណមស្លាបទាំងពីរ ផ្គងនូវអញ្ជលីហើយបានឱនក្បាលចុះក្រោម ឈរនមស្សការព្រះទសពលហើយ ។ ព្រះដ៏មានព្រះភាគ ទ្រង់ទតមើលសត្វមៀមនោះហើយ ទើបទ្រង់ធ្វើនូវការញញឹមញញែម ។ ព្រះអានន្ទត្ថេរ បានក្រាបទូលសួរ ថា "បពិត្រព្រះអង្គដ៏ចំរើន អ្វីទៅហ្ន៎ជាហេតុ ? អ្វីទៅហ្ន៎ជាបច្ច័យ ? នៃកិរិយាធ្វើនូវការញញឹមញញែម ឲ្យប្រាកដ ' ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា 'ម្នាលអានន្ទ អ្នកចូរមើលនូវសត្វមៀមនេះ, វាបានញ៉ាំងចិត្តឲ្យជ្រះថ្លា ក្នុងតថាគត និង ក្នុងព្រះភិក្ខុសង្ឃហើយ

នឹងត្រាច់រង្គាត់ទៅ ក្នុងទេវតានិងមនុស្ស រហូត ១ សែនកប្បហើយ នឹងបានជាព្រះបច្ចេកពុទ្ធ ប្រាកដនាមថា សោមនស្ស ’ ។

( រុក្ខទេវតា ពោលថា ) ÷

(១០១) “ ម្នាលសត្វមៀម អ្នកមានដួងភ្នែកមូលក្រឡង់ អ្នកនៅលើភ្នំវេទិយកៈមកយូរហើយ អ្នកជាអ្នកដល់ហើយនូវសេចក្ដីសុខ, ម្នាលសត្វមៀមជាម្ចាស់ អ្នកឃើញនូវព្រះពុទ្ធ ជាអ្នកប្រសើរ ព្រះអង្គទ្រង់ស្ដេចក្រោកឡើងក្នុងកាល ។

សត្វមៀមនោះ បានញុំាងចិត្តឲ្យជ្រះថ្លា ក្នុងតថាគតនិងក្នុងភិក្ខុសង្ឃ ជាអ្នកខ្ពង់ខ្ពស់ ហើយនឹងមិនទៅកាន់ទុគ្គតិភព រហូត ១ សែនកប្ប ។ សត្វមៀមនោះ ច្យុតចាកទេវលោកហើយ ត្រូវបានកុសលមូល ដាស់តឿនហើយ ក៏នឹងបានជាព្រះបច្ចេកពុទ្ធ ទ្រង់មានញាណគ្មានទីបំផុត ប្រាកដនាមថា សោមនស្ស ” ។

អដ្ឋកថា ចប់ ។

ដីកាចូឡសីហនាទសូត្រនោះ ថា “ សត្វមៀមបានឈរនែមស្មារ

ព្រោះបំពេញនូវបារមីនៃព្រះបច្ចេកពោធិ រហូត ២ អសង្ខេយ្យកប្ប ក៏ទេដែរ, ប៉ុន្តែព្រោះភាវៈនៃសត្វមៀមនោះ មានចិត្តជ្រះថ្លាហើយ ក្នុងព្រះដ៏មានព្រះភាគ ដោយសេចក្ដីស្និទ្ធស្នាល ក្នុងព្រះពុទ្ធសាសនា ។ គាថា ថា 'ឧល្លូក' ជាដើម រុក្ខទេវតា ពោលហើយ ។ បទថា '**កាលុដ្ឋិតំ**' បានដល់ ស្ដេចទ្រង់កើនឡើងអំពីទីគង់ ក្នុងពេលថ្ងៃ ក្នុងវេលាល្ងាច ។ បាទគាថា ថា '**ទុគ្គតេសោ ន គច្ឆតិ**' មានសេចក្ដីថា សត្វមៀមនុ៎ះ នឹងមិនទៅកាន់ទុគ្គតិឡើយ " ។

រឿងសត្វមៀម ចប់ ។

(១០២) ព្រោះហេតុនោះ បុគ្គលកាលឃើញ នូវសមណៈ គប្បីញ៉ាំងកុសលចិត្តប៉ុណ្ណោះ ឲ្យកើតឡើង, មិនគប្បីញ៉ាំងចិត្តគិតប្រទូសរ៉ាយ ឲ្យកើតឡើងឡើយ ។ ព្រោះ បុគ្គលអ្នកមានចិត្តគិតប្រទូសរ៉ាយ រមែងបានទុក្ខ, បុគ្គលក្រៅពីនេះ រមែងបានសុខ ។ ក្នុងដំណើរនោះ មានរឿងទាំងនេះ ( ជាឧទាហរណ៍ ) ÷

## ( រឿងនន្ទយក្ស )

បានឮថា គ្រាមួយ ព្រះអគ្គសាវកទាំង ២ អង្គ អាស្រ័យនៅក្នុងវិហារ ឈ្មោះកបោតកន្ទរៈ ។ បណ្ដាព្រះអគ្គសាវកទាំង ២ រូបនោះ ព្រះសារីបុត្រដ៏មានអាយុ មានសក់កោរហើយថ្មីៗ

ចូលសមាបត្តិ គង់នៅក្នុងទីវាល ក្នុងរាត្រីខាងខ្នើត ។ គ្រានោះ យក្សមួយ ឈ្មោះនន្ទៈ ហោះទៅតាមអាកាស ជាមួយនឹងយក្សមួយ ឃើញព្រះថេរៈ គង់ហើយ យ៉ាងនោះ ទើបញ៉ាំងចិត្តគិតប្រទូសរ៉ាយ ឲ្យកើតឡើងហើយ ។ បានឮថា យក្សនោះ បានចងអាឃាត ក្នុងព្រះថេរៈ កាលពីជាតិមុន ។ ព្រោះហេតុនោះ គ្រាន់តែបានឃើញព្រះថេរៈភ្លាម ចិត្តគិតនឹងប្រទូសរ៉ាយ ក៏កើតឡើងដល់យក្សនោះ ។ យក្សនោះ ជាអ្នកមានចិត្តគិតប្រទូសរ៉ាយហើយ ប្រាថ្នានឹងប្រហារព្រះថេរៈ ត្រង់សិរសី ទើបបានពោលសេចក្ដីនោះ ដល់យក្សក្រៅនេះ សូម្បីត្រូវយក្សនោះ ហាមប្រាមហើយ ក៏នៅតែមិនស្ដាប់ពាក្យសំដីឡើយ ញ៉ាំងសេចក្ដីឧស្សាហ៍ ឲ្យកើតឡើងហើយ ឈរនៅពួជ៍អាកាសនុ៎ះឯង បានឲ្យនូវការប្រហារត្រង់សិរសី យ៉ាងពេញទំហឹង ។ ការប្រហារ បានមានហើយ យ៉ាងខ្លាំងក្រៃលែង ។ យក្សនោះ គប្បីញ៉ាំងដំរីដែលមានទំហំ ៧ ហត្ថ ឬទំហំ ៧ ហត្ថ ១ ចំអាម ឲ្យដួលចុះបាន ឬគប្បីទំលាយនូវកំពូលភ្នំដ៏ធំបាន ដោយការប្រហារនោះ ។ តែសេចក្ដីពិការអ្វីៗ មិនបានមានហើយ ដល់សិរសីដែលកម្លាំង នៃសមាបត្តិ របស់ព្រះថេរៈឧបត្ថម្ភគាំទ្រហើយ ។ ព្រោះថា យក្សវាយប្រហារព្រះថេរៈនោះ ក្នុងវេលាដែលព្រះថេរៈ មិនទាន់បានចេញអំពីសមាបត្តិ ។ ព្រះមហាមោគ្គល្លាន បានឃើញយក្សនោះ

កំពុងតែវាយប្រហារយ៉ាងនោះ ដោយទិព្វចក្ខុហើយ ទើបចូលទៅរកព្រះថេរៈ ។ ក៏ព្រះថេរៈនោះ បានចេញហើយ អំពីសមាបត្តិ ក្នុងពេលព្រមជាមួយគ្នានឹងការចូលទៅរកនុ៎ះឯង ។ ពេលនោះ ព្រះមហាមោគ្គល្លានសួរការប្រព្រឹត្តិទៅនៃសរីរៈ នឹងព្រះសារីបុត្រនោះ ។ ព្រះថេរៈនោះ ពោល ថា "ម្នាលមោគ្គល្លាន ដ៏មានអាយុ ខ្ញុំគប្បីអត់ធន់បាន, ម្នាលមោគ្គល្លានដ៏មានអាយុ ខ្ញុំគប្បីញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន, ក៏ប៉ុន្តែថា ត្រង់សិរសី កើតទុក្ខបន្តិចបន្តួច" ។ សួរថា "ក៏ព្រោះហេតុអ្វី កាលបើសិរសី ត្រូវកម្លាំងនៃសមាបត្តិឧបត្ថម្ភហើយ, ត្រង់សិរសី របស់ព្រះថេរៈ ទើបមានទុក្ខបន្តិចបន្តួច ?" ។ ឆ្លើយថា "ព្រោះភាវៈនៃព្រះថេរៈចេញពីសមាបត្តិ មិនយូរឡើយ" ។

មែនពិត សេចក្ដីទុក្ខដែលមិនប្រាកដមាន ព្ធដ៏ខាងក្នុងនៃសមាបត្តិ ប្រាកដហើយបន្តិចបន្តួច ព្រោះភាវៈជាសភាពអាស្រ័យនូវកាយ ប្រៀបដូចជាសេចក្ដីទុក្ខដែលកើតឡើង ព្រោះមូសជាដើមមិនប្រាកដ ដល់បុគ្គលអ្នកដេកលក់ ប្រាកដដល់គេដែលក្រោកឡើងហើយ បន្តិចបន្តួច យ៉ាងដូច្នោះឯង ។ ក្នុងពេលនោះឯង យក្សកើតមានសេចក្ដីក្ដៅក្រហាយយ៉ាងខ្លាំង ក្នុងសរីរៈ ពោល ថា "ខ្ញុំក្ដៅ ! ខ្ញុំក្ដៅ!" ដូច្នេះ បានធ្លាក់អំពីអាកាសមកលើផែនដី ត្រូវផែនដីបើកប្រហោងឲ្យហើយ បានត្រូវអណ្ដាតភ្លើងក្នុងអវីចិនរក តាំង

ឡើងហើយ ទាញអូសយកទៅកាន់នរកហើយ ។ សួរថា “ ក៏យក្សនោះ ចូលទៅកាន់នរក ដោយអត្តភាពនៃយក្សនុ៎ះឯងឬ ? ” ។ ឆ្លើយថា “ ក៏បាបកម្មណា ជាទិដ្ឋធម្មវេទនីយ៍ (ឲ្យផលទាន់ភ្នែក) បានមានហើយ ក្នុងយក្សនេះ, ព្រោះកម្លាំងនៃបាបកម្មនោះ យក្សនោះ ទើបបានសោយនូវសេចក្តីទុក្ខដ៏ច្រើន ក្នុងអត្តភាពនៃយក្ស ។ ប៉ុន្តែ បាបកម្មណា ដែលជាកម្មគឺបុគ្គលគប្បីសោយ ក្នុងវេលាដែលកើតឡើង ដែលជាអនន្តរិយកម្ម, ព្រោះបាបកម្មនោះ យក្សនោះ ទើបចូលទៅកាន់នរក ក្នុងលំដាប់នៃចុតិ ” ។

រឿងនន្ទយក្ស មកក្នុងសារីបុត្តសូត្រ ក្នុងវគ្គទី ៤ នៃឧទាន ។

## ( រឿងព្រាហ្មណ៍បាដលីបុត្រ )

(១០៣) បានឮថា ព្រាហ្មណ៍ម្នាក់ អង្គុយនៅក្នុងសាលាក្បែរមាត់ទ្វារក្រុងបាដលីបុត្រ បានស្តាប់ការពណ៌នាអំពីគុណ របស់ព្រះមហានាគត្ថេរ អ្នកមានប្រក្រតីនៅ ក្នុងកាឡវល្លិមណ្ឌបវិហារ ក្នុងរោហណជនបទហើយ មានបំណងនឹងឃើញនូវព្រះថេរៈនោះ ទើបទៅកាន់មាត់ច្រាំងនៃសមុទ្រ ឡើងទូក ក៏បានទៅដល់ទីលំនៅស្ថានរបស់ព្រះថេរៈ ដោយលំដាប់ ហើយបានកំណត់យកទីសម្រាកនៅជិតៗ ក្នុងចូឡនគរគ្រាម បានចាត់ចែងចង្ហាន់ ដើម្បីព្រះថេរៈ

ហើយ បានក្រោកឡើង អំពីព្រឹកព្រលឹម ទៅកាន់ទីលំនៅស្ថាន របស់ព្រះថេរៈ ហើយបានឈរនៅក្នុងទីបំផុត ឃើញព្រះថេរៈ អំពីចម្ងាយ ហើយក៏ឈរនៅ ក្នុងទីនោះឯង ថ្វាយបង្គំម្តង ទើបបានចូលទៅជិត ចាប់ត្រង់កជើង យ៉ាងជាប់ ហើយក៏ថ្វាយបង្គំ ថ្មីម្តងទៀត ពោលថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ព្រះគុណម្ចាស់ជាអ្នកខ្ពង់ខ្ពស់"ៗ ក៏ព្រះថេរៈជាអ្នកមិនខ្ពស់ពេក មិនទាបពេក ត្រូវខ្នាតល្មមនុ៎ះឯង ៗ ព្រោះហេតុនោះ ព្រាហ្មណ៍នោះ ទើបពោលទៀតថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ព្រះគុណម្ចាស់ជាអ្នកមិនខ្ពស់ទេ, ប៉ុន្តែគុណទាំងឡាយ របស់ព្រះគុណម្ចាស់ បានល្បីល្បាញទៅដោយទីបំផុតៗ នៃសមុទ្រដែលមានពណ៌ដូចជាមេឃ ហើយគ្របដណ្តប់ពាសពេញផ្ទៃជម្ពូទ្វីបទាំងមូល ផ្សព្វផ្សាយទៅ, ខ្ញុំព្រះករុណា អង្គុយត្រង់មាត់ទ្វារនៃនគរបាដលីបុត្រ បានស្តាប់ការពណ៌នាគុណ របស់ព្រះគុណម្ចាស់ហើយ ទើបបានមកអំពីទីនោះ"ៗ ព្រាហ្មណ៍នោះ បានថ្វាយបិណ្ឌបាត ដល់ព្រះថេរៈ ចាត់ចែងបាត្រនិងចីវរ របស់ខ្លួនស្រេច ហើយបួសក្នុងសំណាក់នៃព្រះថេរៈ ស្ថិតនៅក្នុងឱវាទ ព្រះថេរៈនោះ ដោយ ២-៣ ថ្ងៃប៉ុណ្ណោះ ក៏បានសម្រេចព្រះអរហត្តៗ

រឿងព្រាហ្មណ៍បាដលីបុត្រ មកក្នុងអដ្ឋកថាឋានសូត្រ ក្នុងបញ្ចមវគ្គ បឋមបណ្ណាសកៈ ក្នុងតិកនិបាត អង្គុត្តរនិកាយ ៗ

បណ្ឌិតគប្បីសំដែងរឿងនាយព្រានសុនខ ឈ្មោះកោកៈ ក្នុងបាបវគ្គ នៃធម្មបទ ក្នុងអធិការ នៃការពណ៌នាអំពីចិត្តគិតប្រទូស ។ ក្នុងអធិការ នៃការពណ៌នាអំពីចិត្តដែលមិនគិតប្រទូសរ៉ាយ បណ្ឌិតគប្បីសំដែងរឿងទាំងនេះ គឺ រឿងមាណព ៧ នាក់ ក្នុងបញ្ចមវគ្គ នៃវិមានវត្ថុ រឿងមដ្ឋកុណ្ឌលី ក្នុងសត្តមវគ្គ នៃវិមានវត្ថុនុ៎ះឯង និងរឿងបុរសរោគស្រែង ឈ្មោះសុប្បពុទ្ធ ក្នុងបញ្ចមវគ្គ នៃឧទាន ។

ការពណ៌នាអំពីការឃើញនូវសមណៈ ចប់ ។

⁂

ប្រែចប់ ថ្ងៃពុធ ១១ រោច ខែមាឃ ឆ្នាំរកា បញ្ចស័ក ព. ស. ២៥៣៦

ថ្ងៃ ទី ១៧ ខែកុម្ភៈ ១៩៩៣

*ការចេះច្រើនភាសាជាការប្រសើរណាស់*

*តែកុំភ្លេចជាតិសាស្ត្ររបស់ខ្លួនឯង ។*

## ពណ៌នាអំពីការសន្ទនាធម៌

(១០៤) លោកពោលហើយ ក្នុងអដ្ឋកថាមង្គលសូត្រនេះថា " ឈ្មោះថាការសន្ទនាធម៌ តាមកាល ខ្ញុំនឹងពោល (ដូចតទៅ) ក្នុងវេលាព្រលប់ ឬក្នុងវេលាទៀបភ្លឺ ភិក្ខុអ្នករៀនព្រះសូត្រ ២ រូប តែងសន្ទនានូវព្រះសូត្រ ដល់គ្នានឹងគ្នា, ភិក្ខុអ្នកទ្រទ្រង់នូវព្រះវិន័យ តែងសន្ទនានូវព្រះវិន័យ, ភិក្ខុអ្នករៀនព្រះអភិធម្ម តែងសន្ទនានូវព្រះអភិធម្ម, ភិក្ខុអ្នកសំដែងនូវជាតក តែងសន្ទនានូវជាតក, ភិក្ខុអ្នករៀនអដ្ឋកថា តែងសន្ទនានូវអដ្ឋកថា ឬពួកភិក្ខុទាំងឡាយ តែងសន្ទនាគ្នា ក្នុងពេលនោះៗ ដើម្បីនឹងជម្រះនូវចិត្តដែលរួញរា រាយមាយនិងចិត្តដែលត្រូវវិចិកិច្ឆាគ្របសង្កត់ហើយ, នេះ ឈ្មោះថា **ការសន្ទនាធម៌ តាមកាល** ។ ការសន្ទនាធម៌តាមកាលនោះ លោកពោលថា ' ជាមង្គល ' ព្រោះជាហេតុនៃគុណទាំងឡាយ មានការឆ្លាតវាងវៃ ក្នុងអាគមជាដើម " ។

(១០៥) បណ្ដាបទទាំង ២ នោះ ដើម្បីនឹងសំដែងសេចក្ដីនៃបទថា ' **កាលេន** ' នេះ ទើបលោកពោលថា ' **បទោសេ វា បច្ចូសេ វា** ' ។ បណ្ដាបទទាំងនោះ បទថា ' **បទោសេ** ' មានសេចក្ដីថា ក្នុងកាលខាងដើមនៃរាត្រី គឺក្នុងកាលផ្ដើមនៃរាត្រី "ៗ

សមដូចជាពាក្យដែលលោកពោលហើយ ក្នុងដីកាសត្ថកណ្ឋថា “ កាលខាងដើម នៃពាក់កណ្ដាលអធ្រាត្រ គឺ នៃរាត្រី ឈ្មោះថា **បទោសៈ** តាមរូបស័ព្ទ ដាក់ ប ស័ព្ទ នៅខាងដើម និង **រស្សៈ** ស័ព្ទ ដែលមិនមែនជាប្រធាន ។ ម្យ៉ាងទៀត ជនទាំងឡាយ រមែងបញ្ឈប់ នូវការងារគ្រប់បែបយ៉ាង ក្នុងវេលាណា ព្រោះហេតុនោះ វេលានោះ ឈ្មោះថា វេលាជាទីបញ្ឈប់នូវការងារនៃជនទាំងឡាយ ( វេលាព្រលប់ ) ” ។

បទថា “ **បច្ចូសេ** ” គឺ ក្នុងវេលាភ្លឺហើយ ។

សមដូចជាពាក្យដែលលោកពោលហើយ ក្នុងដីកាសត្ថកណ្ឋថា “ ឱស ធាតុ ប្រព្រឹត្តទៅ ក្នុងកិរិយាកំចាត់ ។ កាលណា រមែងកំចាត់ចោល នូវសេចក្ដីងងឹត ហេតុនោះ កាលនោះ ឈ្មោះថា កំចាត់នូវសេចក្ដីងងឹត (ពេលជិតភ្លឺ) គឺ ខាងដើមនៃពេលថ្ងៃ ” ។

លោកពោលន័យ ទី ២ ដោយពាក្យជាអាទិ៍ថា “ **លីនុទ្ធត** ” ដូច្នេះ ដើម្បីនឹងសំដែងថា “ ចិត្តរមែងជាធម្មជាតិដែលរួញរា ក្នុងកាលណា, ជាធម្មជាតិដែលអណ្ដែតអណ្ដូងរាយមាយ ក្នុងកាលណា និងជាធម្មជាតិ ដែលសេចក្ដីសង្ស័យគ្របសង្កត់ គឺ ជាធម្មជាតិដែលវិចិកិច្ឆានោះ ប្រទូសរ៉ាយហើយ ក្នុងកាលណា, ការសន្ទនាធម៌ សូម្បីក្នុងកាលនោះៗ ឈ្មោះថា **ការសន្ទនាធម៌ តាមកាល** ” ។

(១០៦) ចំណែក ក្នុងអដ្ឋកថាចតុក្កនិបាត អង្គុត្តរនិកាយ លោកពោលថា "បទថា 'កាលេន' បានដល់ ក្នុងកាលដែលល្មមសមគួរ ៗ ការសន្ទនាគ្នា ដែលប្រព្រឹត្តទៅ ដោយអំណាចការសួរនូវបញ្ហា និងការឆ្លើយនូវបញ្ហា ឈ្មោះថា ការសន្ទនាធម៌" ។

(១០៧) ក៏កាលបើព្រះអង្គគប្បីនឹងត្រាស់ថា "សំកច្ឆា" តែទ្រង់ត្រាស់ថា "សាកច្ឆា" ដូច្នេះ ព្រោះធ្វើការលប់និគ្គហិតចេញ និងទីឃស្រះខាងដើម ដូចក្នុងស័ព្ទថា "សារត្តោ" ដូច្នេះជាដើម ៗ ព្រោះហេតុនោះ ក្នុងសន្និកប្បសទ្ទនីតិបករណ៍ ព្រះអគ្គវង្សមហាថេរៈ ទើបពោលសូត្រព្រមទាំងឧទាហរណ៍ ដោយពាក្យជាដើមថា "កាលបើលប់និគ្គហិតខាងចុង ត្រង់ សំ ស័ព្ទចេញហើយ, ទីឃស្រះខាងដើម" ៗ សំរត្តោ ជា សារត្តោ, សារាគោ ក៏យ៉ាងដូច្នោះដែរ" ៗ

ចំណែក ក្នុងកិព្វិធានសទ្ទនីតិបករណ៍ ព្រះអគ្គវង្សមហាថេរៈ ពោលនូវសូត្រថា "រុជាទិតោ សោ" (ខាងដើមធាតុ មាន រុជ ធាតុជាដើម ចុះ ស បច្ច័យ) ហើយសំដែងឧទាហរណ៍ថា "ការសន្ទនាគ្នា ឈ្មោះថា សាកច្ឆា" ៗ ព្រោះហេតុនោះ ការអាទេស សហ ស័ព្ទ ជា ស ដោយនិបាតនសូត្រ ក៏គួរដែរ ៗ ២ បទថា "សហាកច្ឆា សង្កច្ឆា" មានសេចក្ដី យ៉ាងដូច្នេះថា

'ការនិយាយជាមួយគ្នា នុ៎ះឯង' ។ ក៏ សំ ស័ព្ទ រមែងប្រាកដថា មាន សហ ស័ព្ទជាអត្ថ ។ ព្រោះហេតុនោះ ក្នុងដីកាសន្និពាលាវតារ ទើបលោកពោល ថា "ការប្រកបនូវព្យញ្ជនៈ ២ ឬ ៣ គូ ចូលគ្នា ជាមួយនិងស្រៈតែមួយគូ ឈ្មោះថា **សំយោគ** ។ ក៏ **សំ** ស័ព្ទ នេះ មាន **សហ** ស័ព្ទជាអត្ថ ដូចគ្នាក្នុងឧទាហរណ៍ ថា '**បុព្វេ វ សន្និវាសេន**' ដូច្នេះជាដើម " ។

(១០៨) ក៏ក្នុងបទ ថា "**អាគមព្យត្តិអាទីនំ** "នេះ និកាយ ជាទីប្រជុំនៃសូត្រ ឈ្មោះថា អាគម ។ ព្រោះហេតុនោះ ក្នុងដីកាសីលក្ខន្ធវគ្គ និង មូលបណ្ណាសកៈជាដើម លោកពោល ថា "ក៏អាគម លោកបញ្ញត្តិហើយ ព្រោះប្រកាន់យក នូវសូត្រទាំងឡាយ ។ ប្រៀបដូចជាវោហារ ថា 'ព្រះសូត្រ' ព្រោះជាទីប្រជុំ នៃអត្ថនិងព្យញ្ជនៈ យ៉ាងណាមិញ, វោហារ ថា 'អាគម' ក៏ព្រោះ ជាទីប្រជុំនៃសូត្រ ក៏យ៉ាងនោះដែរ ។ ឈ្មោះថា អាគម ព្រោះ វិគ្រោះ ថា 'ជាទីមក ឬជាហេតុមក ឬជាដែនមក នៃប្រយោជន៍ របស់ខ្លួននិង ប្រយោជន៍របស់អ្នកដទៃជាដើម " ។

ដោយអត្ថ និកាយ ៥ ឈ្មោះថា អាគម ។ ព្រោះហេតុនោះ ក្នុងអដ្ឋកថាបាបណិកសូត្រ ក្នុងតិកនិបាត អង្គុត្តរនិកាយ ទើប លោកពោល ថា "១ និកាយ ឈ្មោះថា ១ អាគម, ២ និកាយ

ឈ្មោះថា ២ អាគម ។ ល ។ ៥ និកាយ ឈ្មោះថា ៥ អាគម " ។

ការឆ្លាត គឺការឈ្លាសវៃ បានដល់ ការប៉ិនប្រសប់ ក្នុងអាគមទាំងឡាយ ឈ្មោះថាការឆ្លាតវៃក្នុងអាគម ។ ការឆ្លាតវៃក្នុងអាគមនោះ ជាដើមអាទិ៍ នៃគុណទាំងឡាយណា, គុណទាំងឡាយនោះ ឈ្មោះថា មានការឆ្លាតក្នុងអាគមជាដើម ។ នៃគុណទាំងឡាយមានការឆ្លាតក្នុងអាគមជាដើមនោះ ។ សូម្បីព្រះអរហត្ត លោកក៏បានសង្គ្រោះហើយ ដោយអាទិសព្ទ ។

ក៏ការសន្ទនាធម៌ រមែងជាហេតុបានសម្រេច នូវព្រះអរហត្តដោយពិត ។ ព្រះសូត្រ ថា "ម្នាលភិក្ខុទាំងឡាយ កាលទាំង ៤ នេះ កាលបុគ្គលចំរើនដោយប្រពៃ" ដូច្នេះជាដើម ក៏ជាហេតុឲ្យបានសម្រេច ក្នុងសេចក្ដីនេះ ។ ព្រះសូត្រនោះ ខ្ញុំបានសំដែងហើយក្នុងធម្មស្សវនកថា ពួដ៏ខាងក្រោយនុ៎ះឯង " ។

ការពណ៌នាអំពីបទ ថា 'ការសន្ទនាធម៌' ចប់ ។

សូម្បីក្នុងគាថានេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់មង្គល ៤ ប្រការ គឺ ការអត់ធន់ ១ ភាពនៃបុគ្គលជាអ្នកដែលគេប្រដៅបានដោយងាយ ១ ការបានឃើញនូវសមណៈ ១ ការសន្ទនាធម៌ ១ យ៉ាងដូច្នេះឯង ។ សូម្បីពាក្យជាគាថានេះ ក៏ជាបឋ្យាវត្តដែរ ។

ការពណ៌នាសេចក្ដីនៃគាថាទី ៨ ចប់ ។

# ពណ៌នាសេចក្ដីនៃគាថា ទី ៩

(១០៩) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ៩ ដូចតទៅនេះ÷ កិច្ចមានការសង្រួមឥន្ទ្រីយ៍ជាដើម ឈ្មោះថា តបៈ ។ កិច្ចមានការវៀរចាកមេថុនជាដើម ឈ្មោះថា ការប្រព្រឹត្តិធម៌ដ៏ប្រសើរ ។ ការឃើញនូវមគ្គ ដោយអំណាចការត្រាស់ដឹងអរិយសច្ច ទាំងឡាយ ៤ ឈ្មោះថា ការឃើញអរិយសច្ចទាំងឡាយ ។ ការសម្រេច ឬការពិចារណាឃើញនូវព្រះនិព្វាន ពោលគឺព្រះអរហត្តផល ឈ្មោះថា ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ បទថា " ឯតំ " ជាដើម មានសេចក្ដីថា ម្នាលទេវតា អ្នកចូរប្រកាន់យកថា " តបៈ ១ ការប្រព្រឹត្តិធម៌ដ៏ប្រសើរ ១ ការឃើញមគ្គដោយអំណាចនៃការត្រាស់ដឹងនូវអរិយសច្ចៈ ១ កិរិយាធ្វើនូវព្រះនិព្វានឲ្យជាក់ច្បាស់ ១, កម្មទាំង ៤ យ៉ាង មានតបៈជាដើមនេះ ជាមង្គលដ៏ប្រសើរ " ។

សេចក្ដីសង្ខេប ក្នុងគាថា ទី ៩ នេះ មានតែប៉ុណ្ណេះ ។ ចំណែកសេចក្ដីពិស្ដារ ក្នុងគាថា ទី ៩ នេះ មានដូចតទៅនេះ ÷

## ពណ៌នាអំពីតបៈ

(១១០) ធម៌ជាគ្រឿងដុតកំដៅនូវបាប ឈ្មោះថា តបៈ ។ ដោយហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោល ថា " ធម៌ដែលឈ្មោះថា តបៈ ព្រោះអត្ថ ថា 'ដុតកំដៅនូវធម៌ទាំងឡាយ ដែលអាក្រក់ " ។

បណ្ដាបទទាំងនោះ បទ ថា " តបតិ " មានសេចក្ដីថា រមែងញុំាងបាបធម៌ទាំងឡាយ ឲ្យក្ដៅរោលរាល ។ ព្រោះហេតុនោះ ទើបលោកពោល ក្នុងពួកធាតុមាន ភូ ធាតុជាដើម ថា " តប ធាតុ ចុះក្នុងអត្ថ ថា ញុំាងបាបធម៌ទាំងឡាយ ឲ្យក្ដៅរោលរាល សម្រេចរូបជា តបតិ " ។ ពួកធាតុមាន ចុរ ធាតុជាដើម ថា " តប ធាតុ ចុះក្នុងអត្ថ ថា ដុតកំទ្បោច សម្រេចរូបជា តបេតិ, ចុះក្នុងការិត សម្រេចរូបជា តាបេតិ ។ ស័ព្ទ គឺ តបៈ រមែងប្រព្រឹត្តទៅក្នុងធម៌ និងវត្ត ។ ព្រោះហេតុនោះ ក្នុងបាទានេកត្ថវគ្គ ព្រះអាចារ្យមោគ្គល្លាន ទើបពោល ថា " ស័ព្ទ គឺ តបៈ រមែងប្រព្រឹត្តទៅក្នុងធម៌និងវត្ត " ។

ដីកាបាទានេកត្ថវគ្គនោះ ថា " ស័ព្ទ គឺ តបៈ នោះ រមែងប្រព្រឹត្តទៅ ក្នុងវត្ត គឺ ទិដ្ឋិសមាចារ " ។

(១១១) គុណមានខន្តីជាដើម ឈ្មោះថា ធម៌ ៗ ពិតមែន យ៉ាងដូច្នោះ ខន្តី ឈ្មោះថា តបៈ ក្នុងបាទគាថានេះ ថា " អំណត់ គឺ សេចក្តីអត់ធន់ ជាតបៈដ៏ឧត្តម " ។

សីល ឈ្មោះថា តបៈ ក្នុងលោមសកស្សបជាតក ថា " អាត្មាអញ នឹងលះបង់នូវកាមទាំងឡាយហើយ ធ្វើនូវតបៈ " ។

ឧបោសថកម្ម ឈ្មោះថា តបៈ ក្នុងមហាហំសជាតក ថា " ទាន ១ សីល ១ ការបរិច្ចាគ ១ ភាពស្មោះត្រង់ ១ ភាពទន់ភ្លន់ ១ តបៈ ១ " ។

កិច្ចមានការរៀនព្រះពុទ្ធវចនៈជាដើម ឈ្មោះថា តបៈ ក្នុងបាទគាថានេះ ថា " សេចក្តីព្យាយាមជាគ្រឿងដុតកិលេស របស់អ្នកដែលព្រមព្រៀងគ្នាទាំងឡាយ រមែងនាំសេចក្តីសុខមកឲ្យ " ។

ដោយហេតុនោះ ក្នុងអដ្ឋកថាធម្មបទ ទើបលោកពោល ថា " ក៏ការរៀនព្រះពុទ្ធវចនៈក្តី ការរក្សានូវធុតង្គក្តី ការបំពេញនូវសមណធម៌ក្តី របស់បុគ្គលដែលព្រមព្រៀងគ្នាទាំងឡាយ គឺបុគ្គលអ្នកមានចិត្តដូចគ្នាតែមួយ រមែងនាំសេចក្តីសុខមកឲ្យ ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ត្រាស់ ថា ' សេចក្តីព្យាយាមជាគ្រឿងដុតកិលេស របស់អ្នកដែលព្រមព្រៀងគ្នាទាំងឡាយ រមែងនាំសេចក្តីសុខមកឲ្យ " ។

(១១២) ចំណែក ក្នុងដីកាទេវបុត្តសំយុត្ត លោកពោល អធិប្បាយថា " ក៏ធម៌ គឺ ធុតង្គ ឈ្មោះថា **តបៈ** ព្រោះដុតកំទេច នូវសេចក្ដីលោភដោយអំណាចនៃសេចក្ដីចំណង់ " ។

ក្នុងពួកធាតុមាន **ចុរ** ធាតុជាដើម លោកពោល ថា " សីល ឈ្មោះថា តបៈ ក្នុងបទថា '**តបោ**' នេះ ព្រោះអត្ថ ថា ញុាំង អកុសលធម៌ទាំងឡាយ ឲ្យក្ដៅរោលរាល " ។

តែក្នុងមង្គលបទ ថា " **តបោ** " នេះ កុសលចិត្តមានកិរិយា សង្រួមនូវឥន្ទ្រិយ៍ជាដើម ឈ្មោះថា **តបៈ** ។ ដោយហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោល ថា " កិរិយាសង្រួមឥន្ទ្រិយ៍ ឈ្មោះថា **តបៈ** ព្រោះដុតកំទ្បោច នូវអកុសលចេតសិកធម៌ទាំងឡាយ មាន អភិជ្ឈានិងទោមនស្សជាដើម ឬ សេចក្ដីព្យាយាម ឈ្មោះថា **តបៈ** ព្រោះដុតកំទ្បោច នូវសេចក្ដីខ្ជិលច្រអូស " ។

បណ្ដាសេចក្ដីសង្រួម និងសេចក្ដីព្យាយាម ទាំង ២ យ៉ាងនោះ ការសង្រួមដោយសតិ ឈ្មោះថា ការសង្រួមឥន្ទ្រិយ៍ ។ ក៏ដោយ សេចក្ដី ការសង្រួមដោយសតិនោះ គឺជាគួសតិ ។ ដោយហេតុនោះ ក្នុងដីកាមូលបរិយាយសូត្រ ទើបលោកពោល ថា " ភាវៈជាគ្រឿង សង្រួមនូវឥន្ទ្រិយ៍ ឈ្មោះថា សតិសំវរៈ, មួយទៀត ភាវៈជា គ្រឿងសង្រួមនូវឥន្ទ្រិយ៍នោះ ដែលប្រព្រឹត្តទៅហើយ យ៉ាងដូច្នោះឯង

ឈ្មោះថា ការសង្រួមដោយសតិ " ។

អដ្ឋកថាសព្វាសវសូត្រ ថា "ធម៌ដែលឈ្មោះថា សំវរៈ ព្រោះជាគ្រឿងការពារវាររាំង, លោកពោលអធិប្បាយ ថា 'ព្រោះបិទ គឺការពារវាររាំង' ។ ពាក្យថា 'សំវរោ' នុ៎ះ ជាឈ្មោះនៃសតិ" ។

(១១៣) មែនពិត បុគ្គលអ្នកសង្រួម ដោយការសង្រួមនូវឥន្ទ្រិយ៍ ឈ្មោះថា រមែងរក្សានូវឥន្ទ្រិយ៍ទាំងឡាយ ដើម្បីលះបង់នូវអកុសលចេតសិកធម៌ មានអភិជ្ឈាជាដើម ។ ព្រោះហេតុនោះ ក្នុងចតុត្ថវគ្គ បឋមបណ្ណាសកៈ ក្នុងចតុក្កនិបាត អង្គុត្តរនិកាយ (១) ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា " ម្នាលភិក្ខុទាំងឡាយ ក៏ភិក្ខុឈ្មោះថា ជាអ្នកមានទ្វារគ្រប់គ្រងហើយ ក្នុងឥន្ទ្រិយ៍ទាំងឡាយ តើដូចម្ដេច ? ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញនូវរូប ដោយចក្ខុហើយ ជាអ្នកមិនបានកាន់យកនូវនិមិត្ត មិនបានកាន់យកនូវអនុព្យញ្ជនៈ, អភិជ្ឈានិងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គល ដែលមិនបានសង្រួមនូវចក្ខុន្ទ្រិយ៍ នុ៎ះ ព្រោះហេតុមិនបានសង្រួមនូវចក្ខុន្ទ្រិយ៍ណា, ក៏រមែងប្រតិបត្តិ ដើម្បីសង្រួមនូវចក្ខុន្ទ្រិយ៍នោះ រមែងរក្សានូវចក្ខុន្ទ្រិយ៍ រមែងដល់នូវសេចក្ដីសង្រួម ក្នុងចក្ខុន្ទ្រិយ៍ ។ ភិក្ខុឮសំឡេង ដោយត្រចៀក ។ ល ។ ធុំក្លិនដោយច្រមុះ ។ ល ។ ជញ្ជាប់រស ដោយអណ្ដាត

១- ត្រៃបិដក ភាគទី ៤២ / ទំព័រទី ៣៨ ។

។ល។ ពាល់ត្រូវនូវផោដ្ឋព្វៈដោយកាយ ។ល។ ដឹងនូវធម្មារម្មណ៍ដោយចិត្ត ជាអ្នកមិនបានកាន់យកនូវនិមិត្ត ។ល។ រមែងដល់នូវការសង្រួមក្នុងមនិន្ទ្រីយ៍, ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះថា ជាអ្នកមានទ្វារសង្រួមហើយ ក្នុងឥន្ទ្រីយ៍ទាំងឡាយ យ៉ាងដូច្នេះឯង" ។

បាលីអបរិហានិសូត្រ ចប់ ។

(១១៤) អដ្ឋកថាតិកនិបាត អង្គុត្តរនិកាយ ថា "២ បទថា 'ឥន្ទ្រិយេសុ គុត្តទ្វារោ' មានសេចក្ដីថា ជាអ្នកមានទ្វារ ដែលខ្លួនបានបិទហើយ ក្នុងឥន្ទ្រីយ៍ទាំងឡាយ មានចិត្តជាទី ៦" ។

អដ្ឋកថាទុកនិបាត ក្នុងឥតិវុត្តកៈ ថា "បទថា 'អគុត្តទ្វារោ' គឺ ជាអ្នកមានទ្វារដែលខ្លួនមិនបានបិទហើយ ។ ដើម្បីនឹងឆ្លើយថា 'ក៏ភិក្ខុជាអ្នកមានទ្វារ ដែលមិនបានគ្រប់គ្រងហើយ ក្នុងធម៌អ្វី ?' ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា 'ក្នុងឥន្ទ្រីយ៍ទាំងឡាយ" ។

គម្ពីរវិសុទ្ធិមគ្គ ថា "ច្រើនបទថា 'ចក្ខុនា រូបំ ទិស្វា' មានសេចក្ដីថា ឃើញនូវរូប ដោយចក្ខុវិញ្ញាណ ដែលអាចឃើញក្នុងរូប ដែលបានវោហា ថា 'ចក្ខុ' ដោយអំណាចនៃហេតុ ។ បទថា 'ន និមិត្តគ្គាហី' មានសេចក្ដីថា ភិក្ខុមិនបានកាន់យកនូវនិមិត្តរបស់ស្ត្រី និងនិមិត្តរបស់បុរស ឬនូវនិមិត្តដែលជាទីតាំងនៃកិលេស មានសុភនិមិត្តជាដើម គឺ រមែងស្ថិតនៅក្នុងនិមិត្តគ្រាន់តែ

ជាហេតុបានឃើញប៉ុណ្ណោះ ៗ បទថា 'នានុព្យញ្ជនគ្គាហី' មានសេចក្ដីថា មិនបានកាន់យកនូវអាការៈផ្សេងៗ មានដៃ ជើង ការសើច ការញញឹមញញែម ការចរចា និងការក្រឡេកមើលជាដើម ដែលបានវោហាថា អនុព្យញ្ជនៈ ព្រោះប្រាកដរឿយៗ គឺព្រោះការធ្វើនូវភាវៈជារបស់ប្រាកដ នៃកិលេសទាំងឡាយ បានដល់រមែងកាន់យក នូវអវយវៈតូច-ធំ ដែលមាននៅ ក្នុងសរីរៈនោះតែម្យ៉ាង ៗ ក្នុងពាក្យថា 'យត្វាធិករណមេនំ' ជាដើម គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅ ÷ ធម៌ទាំងឡាយមានអភិជ្ឈាជាដើមនុ៎ះគប្បីគ្របសង្កត់ គឺ គប្បីតាមជាប់នូវបុគ្គលនុ៎ះ គឺជាអ្នកមិនបានសង្រួមចក្ខុន្ទ្រិយ៍ បានដល់ ជាអ្នកដែលមិនបានបិទបាំងនូវចក្ខុទ្វារ ដោយមេទ្វារ គឺសតិ ព្រោះហេតុណា គឺ ព្រោះហេតុនៃការមិនបានសង្រួមនូវចក្ខុន្ទ្រិយ៍ឯណា ៗ ច្រើនបទថា 'តស្ស សំវរាយ បតិបជ្ជតិ' មានសេចក្ដីថា រមែងប្រតិបត្តិ ដើម្បីជាប្រយោជន៍ដល់ការបិទ នូវចក្ខុន្ទ្រិយ៍នោះ ដោយមេទ្វារ គឺសតិ ៗ ក៏ភិក្ខុកាលប្រតិបត្តិ ដោយប្រការដូច្នោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅថា 'រមែងរក្សានូវចក្ខុន្ទ្រិយ៍ខ្លះ' ថា 'រមែងដល់នូវការសង្រួម ក្នុងឥន្ទ្រិយ៍ខ្លះ' ដូច្នេះ" ៗ

(១១៥) ដីកាវិសុទ្ធិមគ្គ ថា "បទថា 'ការណាវសេន'

គឺ ដោយអំណាចនៃហេតុដែលមិនទូទៅ ។ មែនពិត ព្រះដ៏មានព្រះភាគ រមែងទ្រង់សំដែងអាងនូវផល ដោយអំណាចហេតុដែលមិនទូទៅ ដូចជាឧទាហរណ៍ ថា 'ពន្លកនៃស្រូវដំណើប, សំឡេងនៃស្គរ' ដូច្នោះ ។ ន័យមួយទៀត ពាក្យថា 'ចក្ខុនា' នុ៎ះ ជាពាក្យដែលសំដែងដល់ចក្ខុ ដែលវិញ្ញាណអាស្រ័យហើយ ដោយវោហា ថា ចក្ខុជាទីអាស្រ័យ ( នៃវិញ្ញាណ ) ដូចជាឧទារហណ៍ ថា 'គ្រែទាំងឡាយ រមែងធ្វើនូវសំឡេងស្រែកហៅ' ដូច្នោះ ។ ក្នុងពាក្យថា 'ឥត្ថិបុរិសនិមិត្តំ វា' នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅ÷ សណ្ឋានទ្រង់ទ្រាយ ដែលបុគ្គលកាន់យក ដោយសំដៅដល់រូប ១ ការទុលប៉ោងឡើងនៃសាច់ដោះ ១ ភាវៈជាអ្នកមានមាត់ដែលមិនមានពុកមាត់ ១ ការចងសក់និងការប្រើប្រាស់សំពត់ ១ ឥរិយាបថផ្សេង ៗ មានការឈរនិងការដើរដែលមិនអង់អាចជាដើម ១ ទាំងអស់ អាស្រ័យនូវសន្តានរបស់ស្រ្តី ឈ្មោះថា និមិត្តរបស់ស្រ្តី ព្រោះជាហេតុនៃការដឹងច្បាស់ ថា 'ស្រ្តី' ។ និមិត្តរបស់បុរស គប្បីជ្រាប ដោយន័យដែលខុសប្លែកផ្សេង អំពីន័យដែលបានពោលមកហើយ ។ ក្នុងពាក្យថា 'សុភនិមិត្តាទិកំ វា' នេះ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅ ÷ អាការៈដែលជាទីប្រាថ្នា ដែលជាហេតុឲ្យកើតសេចក្ដីតម្រេក ឈ្មោះថា សុភនិមិត្ត ។ គប្បីជ្រាបសេចក្ដី

សង្គ្រោះនូវនិមិត្តទាំងឡាយ មានបដិឃនិមិត្តជាដើម ដោយ អាទិ
ស័ព្ទ ។ ក៏ការសង្គ្រោះនោះ គប្បីជ្រាប ថា ជាអាការៈដែលមិនជាទី
ប្រាថ្នាជាដើម ដែលជាហេតុកើតទោសៈជាដើម ។ ក្នុងបាលី ក្នុង
អបរិហានិសូត្រនេះ អភិជ្ឈានិងទោមនស្សប៉ុណ្ណោះ មកហើយ
ដោយសរុប ក៏ពិតមែនហើយ ។ ទោះជាដូច្នោះ បណ្ឌិតគប្បី
ប្រាថ្នាការសង្គ្រោះឧបេក្ខានិមិត្តផងដែរ ។ ព្រោះសូម្បីមោហៈ
ដែលកើតឡើង ដោយការសំឡឹងនូវអារម្មណ៍ដែលមិនស្មើ ជាការ
មិនសង្រួម ។ ពិតយ៉ាងនោះ ព្រះពុទ្ធឃោសាចារ្យពោល ថា
'ភាពជាអ្នកភ្លេចភ្លាំងសតិ ឬសេចក្តីមិនដឹង' ។ ក៏អារម្មណ៍
ដែលជាទីតាំងនៃការព្រងើយកន្តើយព្រោះសេចក្តីមិនដឹង ឈ្មោះថា
**ឧបេក្ខានិមិត្ត** ក្នុងពាក្យថា '**ឧបេក្ខានិមិត្តស្សាបិ**' នេះ ។
ក៏ឧបេក្ខានិមិត្តនោះ គប្បីជ្រាប ដោយអំណាចនៃការពិចារណានូវ
អារម្មណ៍នោះ ដែលមិនស្មើ ។ ហេតុនៃរាគៈ ទោសៈ និងមោហៈ
លោកពោល ថា 'សុភនិមិត្ត' ជាដើម ដោយសង្ខេប ដូចបាន
ពណ៌នាមកហើយ ។ ព្រោះហេតុនោះ ព្រះពុទ្ធឃោសាចារ្យ ទើប
ពោល ថា 'នូវនិមិត្តដែលជាទីតាំងនៃកិលេស' ។ ពាក្យថា
'**ទិដ្ឋមត្តេយេវ សណ្ឋាតិ**' មានសេចក្តីថា ឈប់នៅក្នុង
អាយតនៈគឺរូប គ្រាន់តែជាហេតុ គឺ ចក្ខុវិញ្ញាណ និងវិថីចិត្តកាន់

យកហើយប៉ុណ្ណោះ, តអំពីនោះទៅ មិនបានកំណត់នូវអាការៈថាល្អជាដើម បន្តិចបន្តួចឡើយ ៗ បទ ថា 'បាកដភាវករណតោ' បានដល់ ព្រោះធ្វើនូវភាពជារបស់ប្រាកដ គឺ ព្រោះធ្វើនូវភាពជារបស់ជាក់ច្បាស់ ៗ មែនពិត កាលបើបុគ្គលកំណត់យកនូវអវយវៈមានដៃជាដើម នៃវត្ថុដែលជាសឹកសត្រូវ ដោយអាការៈជារបស់ល្អជាដើម, កិលេសទាំងឡាយ កាលកើតឡើង ក្នុងអវយវៈ មានដៃជាដើមនោះ ជារឿយៗ រមែងជាសភាពប្រាកដជាក់ច្បាស់ ព្រោះហេតុនោះ អវយវៈទាំងឡាយមានដៃជាដើមនោះ ទើបបានឈ្មោះថាជាសភាពប្រាកដរឿយៗ នៃកិលេសទាំងឡាយនោះ ៗ ក៏កិរិយាកំណត់អវយវៈមានដៃជាដើមនោះ ដោយអាការៈថាល្អជាដើម បានដល់អាការៈគឺការប្រជុំព្រម នៃភូតរូបនិងឧបាទាយរូប ដែលតាំងនៅស៊ប់ហើយ ដោយអាការៈនោះៗ, ព្រោះ លះចោលនូវអាការៈនោះៗ ហើយ សភាពអ្វីៗ ឈ្មោះថាមានដៃជាដើម ដោយបរមត្ថរមែងមិនមានឡើយ ព្រោះហេតុណា; ព្រោះហេតុនោះ ទើបលោកពោល ថា 'ហត្ថបាទ ។ បេ ។ អាការំ ន គណ្ហាតិ'ៗ ដើម្បីនឹងឆ្លើយនូវសំនួរ ថា 'ក៏ភិក្ខុរមែងកាន់យកនូវរបស់អ្វី ?' ដូច្នេះ ទើបលោកពោល ថា 'រមែងកាន់យកនូវអវយវៈតូច-ធំដែលមាននៅ ក្នុងសរីរៈនោះនុ៎ះឯង' ៗ ភិក្ខុរមែងកាន់យក

នូវអវយវៈដែលមាននៅ ក្នុងសរីរៈនោះ មានសក់និងរោមជាដើម ឬនូវអាការៈ គ្រាន់តែជាភូតរូបនិងឧបាទាយរូបនោះ តែប៉ុណ្ណោះ តាមសេចក្តីពិត ។ លោកពោល ថា ' ព្រោះហេតុនៃការមិនបាន សង្រួមនូវចក្ខុន្ទ្រីយ៍ណា ' ដូច្នេះហើយ ពោលទៀត ថា ' ដើម្បីជា ប្រយោជន៍ដល់ការបិទនូវចក្ខុន្ទ្រីយ៍នោះ ដោយមេទ្វារ គឺសតិ ' មិនបានពោល ថា ' ដើម្បីជាប្រយោជន៍ដល់ការបិទ នូវសេចក្តីមិន សង្រួម " ដូច្នេះឡើយ ។ ពាក្យថា ដើម្បីប្រយោជន៍ដល់ការបិទ នូវចក្ខុន្ទ្រីយ៍នោះ ដោយមេទ្វារគឺសតិនេះនោះ លោកពោលហើយ ព្រោះធ្វើអធិប្បាយថា ' ការជ្រួតជ្រាបទៅនៃអភិជ្ឈាជាដើម ព្រះ ដ៏មានព្រះភាគទ្រង់សំដែង ព្រោះហេតុនៃការមិនសង្រួមនូវចក្ខុន្ទ្រីយ៍ ណា, ការជ្រួតជ្រាបទៅនៃអភិជ្ឈាជាដើម ដែលប្រព្រឹត្តទៅ ព្រោះហេតុនៃចក្ខុន្ទ្រីយ៍ ដែលភិក្ខុមិនបានសង្រួមហើយនោះ ព្រះ អង្គទ្រង់សំដែងហើយ " ។ ព្រោះថា ចក្ខុន្ទ្រីយ៍ ជាហេតុនៃ ការជ្រួតជ្រាបទៅ នៃអភិជ្ឈាជាដើម ដែលប្រព្រឹត្តទៅក្នុងចក្ខុទ្វារ ប្រៀបដូចជាចក្ខុន្ទ្រីយ៍ ដែលជាហេតុនៃវិញ្ញាណដែលអាស្រ័យនូវ ទ្វារនោះដូច្នោះ ។ កាលបើមានភាវៈ នៃចក្ខុន្ទ្រីយ៍ ដែលភិក្ខុមិន បានសង្រួមហើយ, អកុសលចេតសិកធម៌មានអភិជ្ឈាជាដើមនោះ រមែងជ្រួតជ្រាបទៅ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគ

ទ្រង់ត្រាស់ការមិនសង្រួម ដែលជាហេតុនៃចក្ខុន្ទ្រីយ៍ ដែលភិក្ខុមិនសង្រួម ដោយប្រការដូច្នោះ ។ ន័យមួយបែបទៀត បទថា 'យត្វាធិករណំ' មានសេចក្ដីថា ព្រោះហេតុនៃចក្ខុន្ទ្រីយ៍ណា ។ ក្នុងបទ ថា 'យត្វាធិករណំ' នេះ មានយោជនា ដូចតទៅនេះ ថា 'សួរថា 'ក៏ព្រោះហេតុនៃចក្ខុន្ទ្រីយ៍យ៉ាងដូចម្ដេច ?' ។ ឆ្លើយថា 'ព្រោះហេតុនៃចក្ខុន្ទ្រីយ៍ដែលភិក្ខុមិនបានសង្រួមហើយ' ។ សួរថា 'ក៏ចក្ខុន្ទ្រីយ៍យ៉ាងដូចម្ដេច ដែលភិក្ខុមិនបានសង្រួមហើយ ?' ។ ឆ្លើយថា 'អកុសលចេតសិកធម៌មានអភិជ្ឈាជាដើម រមែងជ្រួតជ្រាបទៅ ព្រោះហេតុនៃការមិនសង្រួមនូវចក្ខុន្ទ្រីយ៍ណា, ចក្ខុន្ទ្រីយ៍នោះ បណ្ឌិតកំណត់ហើយ ថា តាមជ្រួតជ្រាបទៅ, ភិក្ខុរមែងប្រតិបត្តិ ដើម្បីសង្រួមនូវចក្ខុន្ទ្រីយ៍នោះ" ។

(១១៦) អដ្ឋកថាសព្វាសវសូត្រ និងគម្ពីរឈ្មោះ វិសុទ្ធិមគ្គ ថា "ក្នុងពាក្យថា 'ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ' ជាដើមនោះ ការសង្រួម ឬការមិនសង្រួម រមែងមិនមាន ក្នុងចក្ខុន្ទ្រីយ៍ ។ ព្រោះថា ការរលឹកបានក្ដី ភាពជាអ្នកភ្លេចភ្លាំងសតិស្មារតីក្ដី រមែងមិនអាស្រ័យនូវចក្ខុប្រសាទកើតឡើងទេ ។ ក៏ប៉ុន្តែថា រូបារម្មណ៍មកកាន់គន្លងនៃចក្ខុ ក្នុងពេលណា, ក្នុងពេលនោះ កាលបើភវង្គចិត្ត កើតឡើងហើយរលត់ទៅវិញ ២ ដង, មនោធាតុផ្ទែក

ខាងកិរិយា ញ៉ាំងកិច្ចគឺការនឹក ឲ្យសម្រេចកើតឡើងហើយ រមែងរលត់ទៅវិញ, តអំពីនោះទៅ ចក្ខុវិញ្ញាណ ញ៉ាំងកិច្ចគឺការឃើញ ឲ្យសម្រេចកើតឡើងហើយ ក៏រមែងរលត់ទៅវិញ, តអំពីនោះទៅ មនោធាតុផ្នែកខាងវិបាក ញ៉ាំងកិច្ចគឺការទទួល (អារម្មណ៍) ឲ្យបានសម្រេចកើតឡើងហើយ ក៏រមែងរលត់ទៅវិញ, តអំពីនោះទៅ មនោវិញ្ញាណធាតុ ផ្នែកអហេតុកវិបាក ញ៉ាំងកិច្ច គឺការពិចារណា ឲ្យសម្រេចកើតឡើងហើយ ក៏រមែងរលត់ទៅវិញ, តអំពីនោះទៅ មនោវិញ្ញាណធាតុ ផ្នែកអហេតុកកិរិយា ញ៉ាំងកិច្ច គឺការកំណត់ (អារម្មណ៍) ឲ្យសម្រេចកើតឡើងហើយ ក៏រមែងរលត់ទៅវិញ, ក្នុងលំដាប់នោះ ជវនចិត្ត រមែងស្ទុះទៅ ៗ បណ្ដាសម័យនៃភវង្គចិត្តជាដើម សូម្បីទាំងនោះ សំវរៈ ឬអសំវរៈ រមែងមិនមាន ក្នុងសម័យនៃភវង្គចិត្តតែម្ដង (និង) រមែងមិនមាន ក្នុងសម័យនៃវិថីចិត្តមានការនឹកជាដើម យ៉ាងណាមួយ ក៏ពិតមែនហើយ ៗ ទោះជាយ៉ាងដូច្នោះ ប្រសិនបើ ទោសគ្រឿងទ្រុស្តសីលក្ដី ភាពជាអ្នកមានសតិស្មារតីភ្លេចភ្លាំងក្ដី ការមិនដឹងក្ដី សេចក្ដីមិនអត់ធន់ក្ដី ភាពខ្ជិលច្រអូសក្ដី រមែងកើតឡើង ក្នុងខណៈនៃជវនចិត្ត, ការមិនសង្រួម រមែងមាន ៗ អសំវរៈនោះ សូម្បីជាមាន យ៉ាងដូច្នោះ ក៏ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ ថា 'ការមិនសង្រួម ក្នុងចក្ខុន្ទ្រិយ៍' ៗ

សួរថា 'ព្រោះហេតុអ្វី ?' ។ ឆ្លើយថា 'ព្រោះ កាលបើសំវរៈនោះមាន, ទ្វារក្តី ភវង្គចិត្តក្តី វិថីចិត្តមានអាវជ្ជនៈជាដើមក្តី រមែងជាធម្មជាតិគឺភិក្ខុមិនបានគ្រប់គ្រង ។ សួរថា 'ប្រៀបដូចជាអ្វី ?' ។ ឆ្លើយថា 'ប្រៀបដូចជា កាលបើទ្វារទាំង ៤ ក្នុងព្រះនគរ ដែលគេមិនបានប្រយ័ត្នហើយ, ទ្វារផ្ទះខាងក្នុង ស៊ុមមាត់ទ្វារ និងបន្ទប់ជាដើម ជារបស់ដែលបុគ្គលប្រយ័ត្នល្អហើយ ក៏ពិតមែន, ទោះជាយ៉ាងដូច្នោះ របស់របរគ្រប់បែបយ៉ាង ខាងក្នុងព្រះនគរ ក៏ឈ្មោះថាជារបស់ដែលបុគ្គលមិនបានថែរក្សា មិនបានគ្រប់គ្រងតែម្តង, ព្រោះពួកចោរគប្បីចូលទៅតាមទ្វារព្រះនគរហើយ ធ្វើនូវចោរកម្ម ដែលខ្លួនប្រាថ្នាបាន យ៉ាងណាមិញ, កាលបើទោស មានទោសគ្រឿងទ្រុស្តសីលជាដើម កើតឡើងហើយ ក្នុងជវនៈ, កាលបើអសំវរៈនោះមាន, ទ្វារក្តី ភវង្គចិត្តក្តី វិថីចិត្តមានអាវជ្ជនៈជាដើមក្តី រមែងជាធម្មជាតិ គឺភិក្ខុមិនបានគ្រប់គ្រងហើយ ក៏ដូច្នោះដែរ ។ ក៏កាលបើគុណទាំងឡាយមានសីលជាដើម កើតឡើងហើយ ក្នុងជវនៈនោះ, ទ្វារក្តី ភវង្គចិត្តក្តី វិថីចិត្តមានអាវជ្ជនៈជាដើមក្តី រមែងជាធម្មជាតិ គឺភិក្ខុគ្រប់គ្រងហើយ ។ សួរថា 'ប្រៀបដូចជាអ្វី ?' ។ ឆ្លើយថា 'ប្រៀបដូចជា កាលបើទ្វារព្រះនគរទាំងឡាយ ដែលបុគ្គលបានប្រយ័ត្នហើយ, ខាងក្នុងនៃផ្ទះជាដើម ដែលបុគ្គលមិនបានប្រុង

ប្រយ័ត្នហើយ ក៏ពិតមែន, ទោះជាដូច្នោះ របស់របរទាំងអស់ ខាង ក្នុងព្រះនគរ ឈ្មោះថា ជារបស់ដែលបុគ្គលបានថែរក្សាល្អ បានគ្រប់ គ្រងល្អហើយតែម្តង, ព្រោះថា កាលបើទ្វារព្រះនគរទាំងឡាយ ដែលបុគ្គលបានបិទហើយ, ពួកចោរ ក៏ចូលទៅមិនបាន យ៉ាងណា មិញ, កាលបើគុណមានសីលជាដើម កើតឡើងហើយ ក្នុងជវនៈ, ទ្វារក្តី ភវង្គចិត្តក្តី វិថីចិត្តមានអាវជ្ជនៈជាដើមក្តី រមែងជារបស់ ដែលភិក្ខុបានគ្រប់គ្រងហើយ ក៏យ៉ាងដូច្នោះដែរ ។ ហេតុនោះ សំវរៈសូម្បីកើតឡើង ក្នុងខណៈនៃជវនៈ ព្រះដ៏មានព្រះភាគ ទ្រង់ ត្រាស់ថា 'ការសង្រួម ក្នុងចក្ខុន្ទ្រីយ៍' ដូច្នេះ" ។

(១១៧) ដីកាសព្វាសវសូត្រ ក្នុងមូលបណ្ណាសកៈថា "អកុសលធម៌ដែលជាសឹកសត្រូវដល់សតិ ឈ្មោះថា ភាពជាអ្នក មានសតិភ្លេចភ្លាំង ។ ការកំណត់ចិត្តបែបនេះថា 'ភវង្គចិត្ត រាប់ មិនអស់ រមែងកើតឡើង ក្នុងវិថីផ្សេងៗ ជាប់គ្នាមិនដាច់ ក៏ពិត មែន, ទោះជាដូច្នោះ ក្នុងចន្លោះ នៃការកើតឡើងនៃអាវជ្ជនៈ ព្រោះការមកប៉ះត្រូវប្រសាទ ភវង្គចិត្ត ២ ដួងប៉ុណ្ណោះ រមែងកើត ឡើង' ដូច្នេះ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោល ថា 'កាលបើភវង្គចិត្ត កើតឡើង ២ ដងហើយ ក៏រលត់ទៅវិញ' ។ ពាក្យជាអាទិ៍ថា 'ជវនក្ខណោ ទុស្សីល្យំ វា' អ្នកសិក្សាគប្បី

ប្រកបចូលតាមសមគួរដល់កំណើតក្នុងទ្វារទាំង ៦ ព្រោះថា ‘ពាក្យទាំងអស់ លោកពោលហើយ ក្នុងចក្ខុទ្វារនេះឯង’ ដើម្បីនឹងមិនចាំបាច់ពោលជាថ្មីម្តងទៀត ។ ព្រោះ ទោសគ្រឿងទ្រុស្តសីលពោលគឺ កាយទុច្ចរិតនិងវចីទុច្ចរិត ក្នុងទ្វារទាំង ៥ មិនមានទេ, ព្រោះហេតុនោះ អសំវរៈគឺទោសគ្រឿងទ្រុស្តសីល អ្នកសិក្សាគប្បីប្រកបដោយអំណាចនៃមនោទ្វារ, អសំវរៈក្រៅអំពីនេះ គប្បីប្រកបដោយអំណាចនៃទ្វារទាំង ៦ ។ ព្រោះ អកុសលធម៌ទាំងឡាយ មានភាពជាអ្នកមានសតិភ្លេចភ្លាំងជាដើម ដែលមានធម៌ជាសឹកសត្រូវដល់សតិជាដើមជាលក្ខណៈ គប្បីកើតឡើងបាន ក្នុងទ្វារទាំង ៥ ។ ចំណែក ទោសគ្រឿងទ្រុស្តសីល ដែលជាវីតិក្កមទោសដែលប្រព្រឹត្តទៅ ខាងផ្លូវកាយ និងវាចា មិនគប្បីកើតឡើង ក្នុងទ្វារទាំង ៥ នោះបានឡើយ ព្រោះជវនៈដែលប្រព្រឹត្តទៅ ក្នុងទ្វារទាំង ៥ នឹងញ៉ាំងវិញ្ញត្តិ ឲ្យកើតឡើងមិនបានឡើយ ។ បទថា ‘យថា កឹ’ មានសេចក្តីថា អសំវរៈដែលកើតឡើង ក្នុងជវនៈព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ‘ការមិនសង្រួម ក្នុងចក្ខុទ្វារ’ ដោយប្រការណា, ឧទាហរណ៍ជាគ្រឿងសំដែងនូវប្រការនោះ តើដូចម្តេច ?’ ។ អធិប្បាយថា ប្រៀបដូចជា កាលបើទ្វារព្រះនគរជារបស់ដែលបុគ្គលមិនបានប្រយ័ត្នហើយ, ផ្ទះជាដើមដែលជាប់

ទាក់ទងនឹងព្រះនគរនោះ ក៏ជាសភាពដែលបុគ្គលមិនបានប្រយ័ត្ន ហើយ មានឧបមាយ៉ាងណា, កាលបើមានការមិនសង្រួម ក្នុងជវនៈ, ទ្វារជាដើម ដែលជាប់ទាក់ទងនឹងជវនៈនោះ ក៏ជាសភាពដែលភិក្ខុ មិនបានសង្រួមហើយ ក៏មានឧបមេយ្យយ៉ាងនោះដែរ ព្រោះហេតុ នោះ កាលបើមានការមិនសង្រួមក្នុងវត្ថុដទៃ, ភាវៈនៃវត្ថុដទៃជា សភាពដែលបុគ្គល មិនបានប្រុងប្រយ័ត្នហើយ ក៏រមែងមានដែរ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ សំដែងនូវភាពជាអាការៈ ស្មើគ្នាតែប៉ុណ្ណោះ មិនបានសំដែងនូវភាពជាអាការៈស្មើគ្នា ក្នុង ខាងដើម និងខាងចុង ឬនូវភាពជាអាការៈស្មើគ្នាទាំងខាងក្នុង ទាំង ខាងក្រៅឡើយ ។ ក៏ការជាប់ទាក់ទងនឹងគ្នា បណ្ឌិតគប្បីឃើញ យ៉ាងដូច្នេះឯង ព្រោះភាវៈនៃទ្វារជាដើម ជារបស់ដែលរាប់ចូល ទៅក្នុងសន្តតិជាមួយគ្នា នឹងជវនៈ ។ ចិត្តមានភវង្គចិត្តជាដើម ដែលសម្រេចមកខាងដើម ដោយភាពជាបច្ច័យ ទោះបីជាមិនមាន ក្នុងកាលនៃជវនៈទេ ក៏ឈ្មោះថា មាននៅនុ៎ះឯង ព្រោះសេចក្ដី សម្រេចផល ដូចជាចក្ខុជាដើម យ៉ាងដូច្នោះ ។ ព្រោះ ភវង្គ ជាដើមដែលមាននៅនុ៎ះឯង បណ្ឌិតក៏មិនបានហៅថា 'មាននៅ' ឡើយ ។ ព្រោះហេតុនោះ កាលបើទ្វារនិងភវង្គជាដើមមាន, ជវនៈដែលកើតឡើង ជាខាងក្រោយ ព្រះអដ្ឋកថាចារ្យ ទើបពោល

ថា ស្មើគ្នានឹងទ្វារព្រះនគរ ព្រោះធ្វើឲ្យដូចជាមាននៅខាងក្រៅ ។ ចំណែក ទ្វារនិងភវង្គជាដើមក្រៅអំពីនេះ លោកពោលថា ស្មើគ្នានឹងខាងក្នុងនៃព្រះនគរ ។ មែនពិត កាលបើភាវៈនៃជវនៈមានខាងក្រៅ និងភាវៈនៃទ្វារនិងភវង្គជាដើមក្រៅអំពីនេះ ជាធម្មជាតិមានខាងក្នុង សូម្បីនឹងមិនមាន ដោយបរមត្ថ, បណ្ឌិតគប្បីជ្រាបភាពនៃជវនៈ ដែលត្រាច់មកកើតឡើង ក្នុងកាលមួយគ្រា ឈ្មោះថាជាខាងក្រៅ និងភាវៈនៃទ្វារនិងភវង្គក្រៅអំពីនេះ មានសភាពឆ្ងាយចាកអំពីជវនៈនោះ ឈ្មោះថា ជាខាងក្នុង ដោយបរិយាយ ព្រោះបាលីមានជាអាទិ៍ថា ‘ម្នាលភិក្ខុទាំងឡាយ ចិត្តនេះ ជាធម្មជាតិបភស្សរៈ ( ផូរផង់ ), ប៉ុន្តែចិត្តនោះឯង សៅហ្មងហើយ ព្រោះឧបកិលេសទាំងឡាយ ដែលសញ្ចរចូលមក’ ដូច្នេះ ។ ម្យ៉ាងទៀត កិរិយាដែលចោរ គឺទោសគ្រឿងទ្រុស្តសីលជាដើម សញ្ចរចូលទៅតាមជវនៈ ដែលដូចជាទ្វារព្រះនគរហើយ ទើបប្លន់ក្នុងទ្វារនិងភវង្គជាដើម បណ្ឌិតគប្បីឃើញថា ជាការញ៉ាំងភណ្ឌៈ គឺកុសលឲ្យសាបសូន្យទៅ ព្រោះ កាលបើអសំវរៈ កើតឡើង ក្នុងជវនៈហើយ, បន្ទាប់អំពីនោះទៅ ទ្វារនិងភវង្គជាដើម ក៏ដល់នូវភាពជាហេតុនៃអសំវរៈ ។ ព្រោះថា កាលបើអសំវរៈ កើតឡើងហើយ, ភាវៈនៃទ្វារជាដើម ជាហេតុនៃអសំវរៈនោះ រមែងប្រាកដ ។ ម្យ៉ាងទៀត

អសំវរៈនោះ គ្រាន់តែកើតឡើងប៉ុណ្ណោះ ក៏ហាមឃាត់នូវភាវៈនៃទ្វារជាដើម ជាឧបនិស្ស័យនៃសំវរៈតែម្ដង រមែងប្រព្រឹត្តទៅដូច្នេះ ។ ក៏ក្នុងសំវរៈនិងអសំវរៈទាំង ២ យ៉ាងនេះ លំដាប់នៃការប្រព្រឹត្តិទៅនៃអសំវរៈទាំងឡាយ ដូចតទៅនេះ ។ កាលបើអារម្មណ៍មានរូបារម្មណ៍ជាដើម មកដល់គន្លង ក្នុងទ្វារទាំង ៥, កាលបើអកុសលជវនៈ កើតឡើងតាមបច្ច័យ ហើយចុះទៅកាន់ភវង្គ, ជវនៈដែលប្រព្រឹត្តទៅ តាមមនោទ្វារ ធ្វើនូវរូបារម្មណ៍ជាដើមនោះឯងឲ្យជាអារម្មណ៍ហើយ ក៏ចុះទៅកាន់ភវង្គ ។ ជវនៈកំណត់អារម្មណ៍ក្នុងទ្វារនោះឯង ដោយន័យជាដើម ថា 'ស្ត្រី បុរស' ដូច្នេះហើយក៏ត្រឡប់ចុះទៅកាន់ភវង្គជាថ្មីម្ដងទៀត ។ ក្នុងវារៈតទៅ ជវនៈតែងស្ទុះទៅ ដោយអំណាចនៃហេតុមានការត្រេកត្រអាលជាដើម ។ អារម្មណ៍ប្រាកដដូច្នោះរមែងត្រឡប់មកកាន់គន្លងជាថ្មីម្ដងទៀត ។ ជវនៈប្រាកដដូច្នោះឯង ក៏កើតឡើង ក្នុងរូបារម្មណ៍ជាដើម ក្នុងបញ្ចទ្វារ ។ លោកសំដៅយកជវនៈនោះ ទើបពោលពាក្យជាដើមថា 'កាលបើទោសគ្រឿងទ្រុស្តសីលជាដើម កើតឡើងហើយ ក្នុងជវនៈ, កាលបើអសំវរៈនោះមាន, សូម្បីទ្វារក៏ជារបស់ដែលភិក្ខុមិនបានគ្រប់គ្រងហើយ ក៏យ៉ាងដូច្នោះឯង' ។ ការពណ៌នាសេចក្ដីក្នុងផ្នែកខាងអសំវរៈ ស្លេះតែត្រឹមណោះសិនចុះ ។ សូម្បីក្នុងផ្នែក

ខាងសំវរៈ អ្នកសិក្សាក៏គប្បីជ្រាបសេចក្តី ដោយន័យនេះឯង ” ។

សូម្បីដីកាវិសុទ្ធិមគ្គ ក៏គប្បីត្រួតពិនិត្យមើលដែរ ។

(១១៨) បុគ្គលអ្នកប្រកបព្រម ដោយឥន្ទ្រិយសំវរៈ ដូចបានពណ៌នាមកនេះ ឈ្មោះថារមែងរក្សានូវឥន្ទ្រីយ៍ទាំងឡាយ ដើម្បីនឹងលះបង់នូវអកុសលធម៌ទាំងឡាយមានអភិជ្ឈាជាដើម ។ ការសង្រួមនូវឥន្ទ្រីយ៍នោះ របស់បុគ្គលនោះ ឈ្មោះថា រមែងជុតកំដៅនូវអកុសលធម៌មានអភិជ្ឈាជាដើមនោះ ព្រោះហេតុណា, ព្រោះហេតុនោះ បុគ្គលគប្បីញ៉ាំងឥន្ទ្រិយសំវរៈ ឲ្យបានដល់ព្រម ដើម្បីលះបង់នូវអកុសលធម៌មានអភិជ្ឈាជាដើម ។ ក៏ឥន្ទ្រិយសំវរៈនោះ ឈ្មោះថាមានហិរិនិងឱត្តប្បៈជាឧបនិស្ស័យ ។ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ក្នុងទុតិយវគ្គ ទុតិយបណ្ណាសកៈ(១) ក្នុងសត្តកនិបាត អង្គុត្តរនិកាយ ថា “ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាដើមឈើ ដែលវិបត្តិចាកមែកនិងស្លឹកហើយ, ក្រមរនៃដើមឈើនោះ ក៏មិនសូវបរិបូណ៌, សំបកក្តី ស្រាយក្តី ខ្លឹមក្តី ក៏មិនសូវបរិបូណ៌ យ៉ាងណាមិញ, ម្នាលភិក្ខុទាំងឡាយ កាលបើហិរិនិងឱត្តប្បៈ មិនមានទេ, ឥន្ទ្រិយសំវរៈក៏មិនមាន យ៉ាងដូច្នោះដែរ, ឥន្ទ្រិយសំវរៈ របស់បុគ្គលអ្នកវិបត្តិចាកហិរិនិងឱត្តប្បៈ ឈ្មោះថារមែងមានឧបនិស្ស័យ គឺទោសកំចាត់ហើយ, កាលបើឥន្ទ្រិយសំវរៈ

១- ត្រៃបិដក ភាគទី ៤៧ / ទំព័រទី ១៨២ ។

មិនមានទេ, សីលក៏មិនមាន, សីលរបស់បុគ្គលអ្នកវិបត្តិចាកឥន្ទ្រិយសំវរៈ រមែងមានឧបនិស្ស័យ គឺទោសកំចាត់ហើយ, កាលបើសីលមិនមាន, សម្មាសមាធិ ក៏មិនមាន, សម្មាសមាធិ របស់បុគ្គលអ្នកវិបត្តិចាកសីល រមែងមានឧបនិស្ស័យ គឺទោសកំចាត់ហើយ, កាលបើសម្មាសមាធិមិនមានទេ, យថាភូតញ្ញាណទស្សនៈ ក៏មិនមាន, យថាភូតញ្ញាណទស្សនៈ របស់បុគ្គលអ្នកវិបត្តិ ចាកសម្មាសមាធិ រមែងមានឧបនិស្ស័យ គឺទោសកំចាត់ហើយ, កាលបើយថាភូតញ្ញាណទស្សនៈ មិនមានទេ, និព្វិទាវិរាគៈ ក៏មិនមាន, និព្វិទាវិរាគៈ របស់បុគ្គលអ្នកវិបត្តិ ចាកយថាភូតញ្ញាណទស្សនៈ រមែងមានឧបនិស្ស័យ គឺទោសកំចាត់ហើយ, កាលបើនិព្វិទាវិរាគៈ មិនមាន, វិមុត្តិញ្ញាណទស្សនៈ ក៏មិនមាន, វិមុត្តិញ្ញាណទស្សនៈ របស់បុគ្គលអ្នកវិបត្តិចាកនិព្វិទាវិរាគៈ រមែងមានឧបនិស្ស័យ គឺទោសកំចាត់ហើយ” ដូច្នេះ និងទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ប្រៀបឧបមាដូចជា ដើមឈើដែលបរិបូណ៌ ដោយមែកនិងស្លឹក, ក្រមររបស់ដើមឈើនោះ ក៏រមែងដល់នូវការបរិបូណ៌, សំបកក្តី ស្រាយក្តី ខ្លឹមក្តី ក៏រមែងដល់នូវការបរិបូណ៌ យ៉ាងណាមិញ; ម្នាលភិក្ខុទាំងឡាយ កាលបើហិរិនិងឱត្តប្បៈមាន, ឥន្ទ្រិយសំវរៈ ក៏មាន យ៉ាងដូច្នោះដែរ, ឥន្ទ្រិយសំវរៈ របស់បុគ្គលអ្នកបរិបូណ៌

ដោយហិរិនិងឱត្តប្បៈ ឈ្មោះថា រមែងបរិបូណ៌ដោយឧបនិស្ស័យ ។ ល ។ កាលបើនិព្វិទានិងវិរាគៈមាន, វិមុត្តិញ្ញាណទស្សនៈក៏មាន, វិមុត្តិញ្ញាណទស្សនៈ របស់បុគ្គលអ្នកបរិបូណ៌ដោយនិព្វិទានិងវិរាគៈ ឈ្មោះថា រមែងបរិបូណ៌ដោយឧបនិស្ស័យ" ។

បាលីហិរិសូត្រ ចប់ ។

(១១៩) អដ្ឋកថាហិរិសូត្រនោះ ថា "បទថា 'ហិរោត្តប្បេ' មានសេចក្តីថា កាលបើហិរិផង ឱត្តប្បៈផង ។ បណ្តាហិរិនិងឱត្តប្បៈទាំង ២ នោះ ហិរិស្ថិតនៅ ដោយអាការៈ គឺសេចក្តីខ្មាស, ឱត្តប្បៈ ស្ថិតនៅ ដោយអាការៈ គឺសេចក្តីភ័យខ្លាច ។ បទថា 'ហតុបនិសោ' មានសេចក្តីថា មានឧបនិស្ស័យ គឺទោសជីករំលើងហើយ គឺ មានបច្ច័យខាតហើយ ។ វិបស្សនាយ៉ាងទន់ឈ្មោះថា យថាភូតញ្ញាណទស្សនៈ ។ វិបស្សនាដែលមានកម្លាំងនិងមគ្គ ឈ្មោះថា និព្វិទាវិរាគៈ ។ ការរួចផុត ដោយអំណាចព្រះអរហត្ត និងបច្ចវេក្ខណញ្ញាណ ឈ្មោះថា វិមុត្តិញ្ញាណទស្សនៈ" ។

(១២០) ឥន្ទ្រិយសំវរៈ រមែងមាន ដល់បុគ្គលអ្នកបរិបូណ៌ដោយហិរិនិងឱត្តប្បៈ, រមែងមិនមាន ដល់បុគ្គលអ្នកប្រាសចាកអំពីហិរិនិងឱត្តប្បៈនោះ ដូចបានពណ៌នាមកនេះឯង ។

ក្នុងសេចក្តីនោះ មានរឿងនេះ ( ជាឧទាហរណ៍ ) ÷

## ( រឿងលោមសកស្សបតាបស )

ក្នុងអតីតកាល ព្រះពោធិសត្វ បានកើតជាតាបស ឈ្មោះថា លោមសកស្សបៈ ជាអ្នកមានតបៈ ដ៏តឹងតែង ក្នុងព្រៃហេមពាន្ត ។ ដោយតេជះនៃតបៈ របស់ព្រះពោធិសត្វនោះ ភពនៃសក្កទេវរាជ បានកំរើកហើយ ។ សក្កទេវរាជ កាលទ្រង់ពិចារណា ក៏បានទ្រង់ជ្រាបនូវហេតុការណ៍នោះ ក្នុងវេលាអធ្រាត្រ ទើបស្តេចយាងចូលទៅកាន់បន្ទប់ដ៏មានសិរី របស់ព្រះរាជាក្រុងពារាណសី ហើយទ្រង់ត្រាស់ថា "បពិត្រព្រះមហារាជ សូមព្រះអង្គទ្រង់ស្តេចតើនឡើង, ខ្ញុំជាសក្កទេវរាជ, ប្រសិនបើព្រះអង្គ ទ្រង់ប្រាថ្នានូវឯករាជ ក្នុងជម្ពូទ្វីបទាំងមូល, សូមព្រះអង្គប្រគល់នូវព្រះចន្ទវតីព្រះរាជកុមារី ដែលជាព្រះធីតា របស់ព្រះអង្គ ក្នុងដៃនៃអាមាត្យឈ្មោះសេយ្ហៈហើយទ្រង់បញ្ជូនឲ្យទៅនាំយកលោមសកស្សបតាបសមក ហើយទ្រង់ត្រាស់បញ្ជា ឲ្យបូជាយ័ញ្ញដែលត្រូវការសម្លាប់សត្វចិញ្ចឹម, ព្រះអង្គនឹងទ្រង់ជាអ្នកស្មើដោយសក្កទេវរាជ ទ្រង់មិនចាស់ជរា និងមិនទិវង្គត ទ្រង់គ្រងឯករាជ ក្នុងជម្ពូទ្វីបទាំងមូល" ដូច្នេះហើយ ទើបស្តេចគេចចេញទៅ ។

ចំណែក ព្រះរាជា ទ្រង់បានបញ្ជូនសេយ្ហអាមាត្យ ព្រមទាំងព្រះចន្ទវតីរាជធីតាទៅ ក្នុងថ្ងៃ ទី ២ ។ ឯសេយ្ហអាមាត្យ

បានទៅថ្វាយបង្គំតាបសឥសីហើយ សំដែងនូវព្រះធីតាចន្ទវតី ដែលមានព្រះរូបប្រៀបដោយនាងទេពអប្សរ ។ តាបសឥសី ទំលាយឥន្ទ្រីយ៍ហើយ លះបង់នូវហិរិនិងឱត្តប្បៈ ក្រឡេកមើលព្រះនាងចន្ទវតីនោះ ជាអ្នកមានចិត្តប្រតិព័ទ្ធហើយ វិនាសសាបសូន្យចាកឈានជាមួយគ្នានឹងការក្រឡេកមើល ។ សេយ្យអាមាត្យពោលថា បពិត្រព្រះគុណម្ចាស់ដ៏ចំរើន បានឮថា ប្រសិនបើ ព្រះគុណម្ចាស់នឹងបូជាយញ្ញ ដល់ព្រះរាជា, ព្រះរាជា នឹងទ្រង់ព្រះរាជទាននូវព្រះរាជកុមារីនេះ ដល់ព្រះគុណម្ចាស់ " ។ តាបសឥសី ទទួលថា " ប្រពៃហើយ " ដូច្នេះហើយ ទើបទៅកាន់ទីក្រុងពារាណសីព្រមទាំងជដានេះឯង ប្រារព្ធហើយ ដើម្បីនឹងបូជាយញ្ញ ។

ក្នុងគ្រានោះ មហាជនបានប្រជុំគ្នា ក្នុងសមាគមនោះ ឃើញកិរិយានៃតាបសនោះហើយ ក៏ពោលថា " ព្រះគុណម្ចាស់ បានធ្វើកម្មមិនសមគួរហើយ " ដូច្នេះហើយ ក៏ខ្សឹកខ្សួល បានពោល ២ គាថា ក្នុងលោមសកស្សបជាតក[(១)] ក្នុងនវកនិបាត ថា ៖

(១២១) " ព្រះច័ន្ទមានកម្លាំង, ព្រះអាទិត្យមានកម្លាំង, ពួកសមណព្រាហ្មណ៍មានកម្លាំង, ច្រាំងសមុទ្រមានកម្លាំង, ឯពួកស្ត្រីមានកម្លាំងលើស

១- ត្រៃបិដក ភាគទី ៥៩ / ទំព័រទី ១៤៩ ។

លុបជាងកម្លាំង (នោះទៅទៀត) ។ ដូចជាព្រះរាជធីតា ព្រះនាមចន្ទវតី បានញ៉ាំងឥសីឈ្មោះលោមសកស្សបៈ មានតបៈដ៏ខ្ពង់ខ្ពស់ ជាអ្នកស្ងប់ឲ្យបូជានូវការបូជា ឈ្មោះរាជបេយ្យៈ គឺបូជាដោយការសម្លាប់សត្វចិញ្ចឹម ដើម្បីប្រយោជន៍ដល់ព្រះរាជបិតា " ។

បណ្ដាបទទាំងនោះ បាទគាថា ថា " ពលំ ចន្ទោ ពលំ សុរិយោ " មានសេចក្ដីថា ឈ្មោះថាកម្លាំងដទៃ ក្នុងកិរិយាកំចាត់នូវសេចក្ដីងងឹតយ៉ាងធំ មិនមានឡើយ, ព្រះចន្ទ និង ព្រះអាទិត្យប៉ុណ្ណោះ មានកម្លាំង ក្នុងកិរិយាកំចាត់នូវមហន្ធការបាន ។ បទថា " សមណព្រាហ្មណា " បានដល់ សមណៈ និងព្រាហ្មណ៍ទាំងឡាយ អ្នកប្រកបដោយកម្លាំងគឺខន្តី និងកម្លាំងគឺញាណ មានបាបស្ងប់រម្ងាប់ហើយ មានបាបបណ្ដែតចោលហើយ ដោយការអត់ទ្រាំនូវកម្លាំង នៃឥដ្ឋារម្មណ៍និង អនិដ្ឋារម្មណ៍បាន ។ បាទគាថា ថា " ពលំ វេលា សមុទ្ទស្ស "មានសេចក្ដីថា ច្រាំងនៃមហាសមុទ្រឈ្មោះថាមានកម្លាំង ព្រោះភាវៈនៃច្រាំងសមុទ្រនោះ អាចដើម្បីមិនឲ្យ (ទឹក) ឡើងហៀរមក ហើយទប់ទឹកឲ្យនៅនឹងបាន ។

បាទគាថា ថា "ពលាតិពលមិត្ថិយោ" មានសេចក្ដីថា ចំណែកស្ត្រីទាំងឡាយ ឈ្មោះថា មានកម្លាំងក្រៃលែងជាង កម្លាំងទាំងឡាយទាំងពួងនុ៎ះ ព្រោះជាអ្នកអាច ដើម្បីនឹងនាំបុរសទាំងឡាយ សូម្បីអ្នកមានញាណដ៏បរិសុទ្ធវិសេស អ្នកមិនទាន់បានប្រាសចាករាគៈ ឲ្យមកកាន់អំណាច របស់ខ្លួន ហើយឲ្យវិនាសទៅបាន, អធិប្បាយថា 'កម្លាំងស្ត្រីប៉ុណ្ណោះ ធំជាងកម្លាំងគ្រប់បែបយ៉ាង' ។ បទថា "យថា" ស្មើគ្នានឹង យស្មា ។ ២ បទថា "បិតុ អត្ថាយ" បានដល់ ដើម្បីជាប្រយោជន៍នៃសេចក្ដីចំរើន ដល់ព្រះរាជបិតា ។ មានពាក្យអធិប្បាយថា 'ព្រះនាងចន្ទវតីនេះ ធ្វើសមណៈ អ្នកមានតបៈដ៏ខ្ពង់ខ្ពស់នេះ អ្នកឈ្មោះថាឥសី ព្រោះជាអ្នកស្វែងរកគុណទាំងឡាយមានសីលជាដើម ឲ្យជាអ្នកមិនមានសីល ហើយឲ្យបូជាយញ្ញឈ្មោះថាវាជបេយ្យៈ ដើម្បីប្រយោជន៍ ដល់ព្រះរាជបិតាព្រោះហេតុណា, ព្រោះហេតុនោះ អ្នកមានបញ្ញា គប្បីជ្រាបពាក្យនោះ ថា 'ស្ត្រីទាំងឡាយ មានកម្លាំងក្រៃលែងជាងកម្លាំង" ។

(១២២) ក្នុងគ្រានោះ តាបសបានលើកព្រះខ័នកែវឡើងដោយគិត ថា "អាត្មាអញនឹងប្រហារនូវដំរីមង្គលត្រង់ក" ដូច្នេះ ។ ដំរីមង្គលឃើញ នូវកិរិយានោះហើយ ត្រូវមរណភ័យបៀតបៀនក៏ស្រែកយ៉ាងខ្លាំង ។ ទាំងដំរីសេះនិងគោឧសុភៈដែលសេសសល់

បានឮសំឡេងនៃដំរីនោះហើយ ក៏បានស្រែកឡើង ។ ឯមហាជន សោត ក៏បានស្រែកដែរ ។ តាបស ស្តាប់សំឡេងនោះហើយ ដល់នូវសេចក្តីតក់ស្លុត ក្រឡេកមើលផ្នួងសក់ជាដើម របស់ខ្លួនហើយ ជាអ្នកកើតសេចក្តីក្តៅក្រហាយ បានគិត ថា "កម្មដ៏លាមក មិនសមហើយហ្ន៎ ដល់អាត្មាអញ" ដូច្នេះហើយ ទើបញ៉ាំងហិរិ និងឱត្តប្បៈឲ្យតាំងនៅចំពោះវិញ ក្នុងខណៈនោះឯង ពិចារណាកសិណហើយ បានញ៉ាំងឈាន សូម្បីវិនាសសាបសូន្យហើយ ឲ្យកើតឡើងវិញបានហើយ អង្គុយពែនភ្នែន ឰដ៏អាកាស សំដែងធម៌ ដល់ព្រះរាជា លុះថ្វាយឱវាទស្រេចហើយ ក៏បានឲ្យមនុស្សកំទេច នូវរណ្តៅនៃយញ្ញពិធី បានឲ្យព្រះរាជាទ្រង់ព្រះរាជទានអភ័យទាន ដល់មហាជនហើយក៏បានទៅកាន់ទីលំនៅស្ថាន របស់ខ្លួនតាមដើម ជាអ្នកមិនវិនាសចាកឈាន បានទៅកើតក្នុងព្រហ្មលោកហើយ ។

រឿងលោមសកស្សបៈ ចប់ ។

សេចក្តីសង្ខេប មានតែប៉ុណ្ណោះឯង ។ ចំណែកសេចក្តីពិស្តារ ខ្ញុំបានពោលហើយ ក្នុងអនាគារិយវិន័យ ឰដ៏ខាងក្រោយនុ៎ះឯង ។

ពណ៌នាអំពីឥន្ទ្រិយសំវរៈ ចប់ ។

(១២៣) ក្នុងពាក្យថា " **កោសជ្ជស្ស វា តបនតោ វិរិយំ** " នេះ មានសេចក្តីវិនិច្ឆ័យ ដូចតទៅនេះ ÷

សេចក្ដីខ្ជិលច្រអូស បណ្ឌិតគប្បីជ្រាប ដោយហេតុ ៨ ប្រការ, សេចក្ដីព្យាយាម ក៏ដូចគ្នាដែរ ។ ដោយហេតុនោះ ក្នុងតតិយវគ្គ ទុតិយបណ្ណាសកៈ ក្នុងអដ្ឋកនិបាត[១] អង្គុត្តរនិកាយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ ហេតុនៃបុគ្គលអ្នកខ្ជិលច្រអូសនេះ មាន ៨ ប្រការ ។ ៨ ប្រការ តើដូចម្ដេចខ្លះ ? ។ ម្នាលភិក្ខុទាំងឡាយ អំពើ គឺការលៃលក វាស់ កាត់ចីវរជាដើម ដែលភិក្ខុក្នុងសាសនានេះគួរធ្វើក៏មាន ។ ភិក្ខុនោះមានសេចក្ដីត្រិះរិះយ៉ាងនេះ ថា 'អំពើដែលអាត្មាអញ គួរធ្វើ គង់នឹងមាន, តែបើអាត្មាអញធ្វើនូវអំពើ (នោះ), កាយក៏នឹងលំបាក, បើដូច្នោះ អាត្មាអញដេកសិន' ដូច្នេះ ។ ភិក្ខុនោះ ក៏ដេក មិនផ្គងព្យាយាម ដើម្បីឲ្យដល់នូវគុណ គឺឈាន វិបស្សនា មគ្គ និងផល ដែលខ្លួនមិនទាន់បានដល់ ដើម្បីដឹងនូវគុណ ដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់ នូវគុណដែលខ្លួនមិនទាន់បានធ្វើឲ្យច្បាស់លាស់ទេ ។ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុ ទី ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អំពើដែលភិក្ខុធ្វើហើយក៏មាន ។ ភិក្ខុនោះមានសេចក្ដីត្រិះរិះ យ៉ាងនេះ ថា 'អាត្មាអញ បានធ្វើអំពើ (នោះ) រួចហើយ, តែកាលដែលអាត្មាអញធ្វើអំពើ (នោះ) ឯង, កាយលំបាកហើយ, បើដូច្នោះ អាត្មាអញដេកសិន' ដូច្នេះ ។ ភិក្ខុនោះក៏ដេក

១- ត្រៃបិដក ភាគទី ៤៨ / ទំព័រទី ៣៣៩ ។

មិនផ្គងព្យាយាម ។ល។ ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណ ដែលខ្លួនមិនទាន់បានធ្វើឲ្យច្បាស់លាស់ ។ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុ ទី ២ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ផ្លូវដែលភិក្ខុគួរដើរទៅក៏មាន ។ ភិក្ខុនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា 'ផ្លូវដែលអាត្មាអញ គួរដើរទៅគង់នឹងមាន, តែកាលបើអាត្មាអញដើរទៅកាន់ផ្លូវ (នោះ)ឯង, រាងកាយនឹងលំបាក, បើដូច្នោះ អាត្មាអញ ដេកសិន' ដូច្នេះ ។ ភិក្ខុនោះ ក៏ដេក មិនផ្គងព្យាយាម ។ល។ នេះជាកុសីតវត្ថុ ទី ៣ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ផ្លូវដែលភិក្ខុដើរទៅហើយក៏មាន ។ ភិក្ខុនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា 'អាត្មាអញ បានដើរទៅកាន់ផ្លូវ (នោះ) រួចហើយ, តែកាលបើអាត្មាអញដើរទៅកាន់ផ្លូវ (នោះ) ឯង, រាងកាយលំបាកហើយ, បើដូច្នោះ អាត្មាអញដេកសិន' ដូច្នេះ ។ ភិក្ខុនោះក៏ដេក មិនផ្គងព្យាយាម ។ល។ នេះជាកុសវត្ថុ ទី ៤ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏មិនបានភោជនថោកទាប ឬថ្លៃថ្លា គ្រាន់តែមួយចំអែតឡើយ ។ ភិក្ខុនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា 'កាលអាត្មាអញត្រាច់ទៅកាន់ស្រុកឬនិគម ដើម្បីបិណ្ឌបាត ក៏មិនបាននូវភោជនថោកទាប ឬថ្លៃថ្លា គ្រាន់តែមួយចំអែតសោះ, រាងកាយរបស់

អាត្មាអញនោះ លំបាកហើយ មិនគួរដល់សមណកម្ម, បើដូច្នោះ អាត្មាអញដេកសិន' ដូច្នេះ ។ ភិក្ខុនោះក៏ដេក ។ ល ។ នេះជាកុសីតវត្ថុ ទី ៥ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏បាននូវភោជនថោកទាប ឬថ្លៃថ្លា ល្មមមួយចំអែត ។ ភិក្ខុនោះ មានសេចក្ដីត្រិះរិះ យ៉ាងនេះ ថា 'កាលអាត្មាអញត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏បាននូវភោជនថោកទាប ឬថ្លៃថ្លា ល្មមតែមួយចំអែតដែរ, រាងកាយរបស់អាត្មាអញនោះធ្ងន់ ដូចជាសណ្ដែករាជមាសទទឹក មិនគួរដល់សមណកម្ម, បើដូច្នោះ អាត្មាអញដេកសិន' ដូច្នេះ ។ ភិក្ខុនោះក៏ដេក មិនផ្ដងព្យាយាម ។ ល ។ នេះជាកុសីតវត្ថុ ទី ៦ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមានអាពាធតិចតួចកើតឡើង ។ ភិក្ខុនោះ មានសេចក្ដីត្រិះរិះ យ៉ាងនេះ ថា 'អាត្មាអញមានអាពាធតិចតួចនេះ កើតឡើងហើយ គួរតែដេកសិន, បើដូច្នោះ អាត្មាអញដេកសិន' ដូច្នេះ ។ ភិក្ខុនោះក៏ដេក មិនផ្ដងព្យាយាមឡើយ ។ ល ។ នេះជាកុសីតវត្ថុ ទី ៧ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុចេញចាកជម្ងឺ ទើបតែស្បើយជម្ងឺថ្មីៗ ។ ភិក្ខុនោះ មានសេចក្ដីត្រិះរិះ យ៉ាងនេះ ថា 'អាត្មាអញជាអ្នកចេញចាកជម្ងឺ ទើបតែនឹងស្បើយជម្ងឺថ្មីៗ, រាងកាយរបស់

អាត្មាអញនោះ ថមថយកំឡាំង មិនគួរដល់សមណកម្ម, បើដូច្នោះ អាត្មាអញដេកសិន ' ដូច្នេះ ។ ភិក្ខុនោះក៏ដេក មិនផ្គងព្យាយាម ។ ល ។ ដើម្បីធ្វើឲ្យច្បាស់លាស់ នូវគុណដែលខ្លួនមិនទាន់បានធ្វើឲ្យច្បាស់លាស់ទេ ។ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុ ទី ៨ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង កុសីតវត្ថុ ៨ យ៉ាង " ។

(១២៤) ( ហើយទ្រង់ត្រាស់ ថា ) "ម្នាលភិក្ខុទាំងឡាយ ហេតុប្រារព្ធ (សេចក្តីព្យាយាម) នេះ មាន ៨ យ៉ាង ។ ៨ យ៉ាង តើដូចម្តេចខ្លះ ? ។ ម្នាលភិក្ខុទាំងឡាយ អំពើដែលភិក្ខុក្នុងសាសនានេះ គួរធ្វើក៏មាន ។ ភិក្ខុនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះ ថា ' អំពើដែលអាត្មាអញគួរធ្វើ គង់នឹងមាន, តែថា កាលអាត្មាអញធ្វើនូវអំពើ (នោះ) ឯង មិនងាយនឹងធ្វើនូវសាសនា របស់ព្រះពុទ្ធទាំងឡាយ ឲ្យតាំងនៅក្នុងចិត្តបានឡើយ, បើដូច្នោះ អាត្មាអញផ្គងព្យាយាមមុនសិន ដើម្បីឲ្យដល់នូវគុណ គឺ ឈាន វិបស្សនា មគ្គនិងផល ដែលអាត្មាអញមិនទាន់បានដល់ ដើម្បីឲ្យដឹងនូវគុណដែលអាត្មាអញ មិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណដែលអាត្មាអញ មិនទាន់បានធ្វើឲ្យច្បាស់លាស់ ។ ភិក្ខុនោះក៏ផ្គងព្យាយាម ដើម្បីឲ្យដល់នូវគុណ ដែលខ្លួនមិនទាន់បានដល់ ។ ល ។ ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណ ដែលខ្លួនមិនទាន់បានធ្វើឲ្យច្បាស់

លាស់ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុ ទី ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អំពើដែលភិក្ខុធ្វើរួចហើយ ក៏មាន ។ ភិក្ខុនោះ មានសេចក្ដីត្រិះរិះ យ៉ាងនេះ ថា ' អាត្មាអញ បានធ្វើអំពើរួចហើយ, តែថា កាលបើអាត្មាអញធ្វើអំពើ (នោះ) ឯង ក៏មិនអាចនឹងធ្វើនូវព្រះសាសនា របស់ព្រះពុទ្ធទាំងឡាយ ឲ្យតាំងនៅក្នុងចិត្តបានឡើយ, បើដូច្នោះ អាត្មាអញផ្ដងព្យាយាមមុនសិន ។ល។ នេះជាអារព្ភវត្ថុ ទី ២ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ផ្លូវដែលភិក្ខុគួរដើរទៅក៏មាន ។ ភិក្ខុនោះ មានសេចក្ដីត្រិះរិះ យ៉ាងនេះ ថា ' ផ្លូវដែលអាត្មាអញ គួរដើរទៅគង់នឹងមាន, តែថា កាលបើអាត្មាអញដើរទៅកាន់ផ្លូវ (នោះ) ឯង ក៏មិនងាយនឹងធ្វើនូវសាសនា របស់ព្រះពុទ្ធទាំងឡាយ ឲ្យតាំងនៅក្នុងចិត្តបានឡើយ, បើដូច្នោះ អាត្មាអញផ្ដងព្យាយាមមុនសិន ។ល។ នេះជាអារព្ភវត្ថុ ទី ៣ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ផ្លូវដែលភិក្ខុដើរទៅហើយក៏មាន ។ ភិក្ខុនោះ មានសេចក្ដីត្រិះរិះ យ៉ាងនេះ ថា ' អាត្មាអញ បានដើរទៅកាន់ផ្លូវ (នោះ) ឯងហើយ, តែថា កាលបើអាត្មាអញដើរទៅកាន់ផ្លូវ (នោះ) ឯង ក៏មិនអាចនឹងធ្វើនូវសាសនា របស់ព្រះពុទ្ធទាំងឡាយ ឲ្យតាំងនៅក្នុងចិត្តបានឡើយ, បើដូច្នោះ អាត្មាអញផ្ដងព្យាយាមមុនសិន ។ល។ នេះជាអារព្ភវត្ថុ ទី ៤ ។ ម្នាលភិក្ខុ

ទាំងឡាយ មួយទៀត កាលភិក្ខុត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏មិនបាននូវភោជនថោកទាប ឬថ្លៃថ្លា ល្មមមួយចំអែតទេ ។ ភិក្ខុនោះមានសេចក្ដីត្រិះរិះ យ៉ាងនេះថា ' អាត្មាអញកាលទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏មិនបាននូវភោជនថោកទាប ឬថ្លៃថ្លា ល្មមមួយចំអែតឡើយ, កាយរបស់អាត្មាអញនោះស្រាល គួរដល់សមណកម្ម, បើដូច្នោះ អាត្មាអញផ្គងព្យាយាម ។ ល ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុ ទី ៥ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុត្រាច់ទៅកាន់ស្រុក ឬនិគមដើម្បីបិណ្ឌបាត ក៏បាននូវភោជនថោកទាប ឬថ្លៃថ្លា ល្មមមួយចំអែត ។ ភិក្ខុនោះ មានសេចក្ដីត្រិះរិះ យ៉ាងនេះថា ' អាត្មាអញកាលត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏បាននូវភោជនថោកទាប ឬថ្លៃថ្លា ល្មមមួយចំអែតហើយ, កាយរបស់អាត្មាអញនោះមានកម្លាំង គួរដល់សមណកម្ម, បើដូច្នោះ អាត្មាអញផ្គងព្យាយាម ។ ល ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុ ទី ៦ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមានអាពាធតិចតួចកើតឡើង ។ ភិក្ខុនោះ មានសេចក្ដីត្រិះរិះ យ៉ាងនេះថា ' អាត្មាអញកើតអាពាធតិចតួចនេះហើយ, អាពាធគប្បីចំរើន ដល់អាត្មាអញ ដោយហេតុណា, ហេតុនុ៎ះ ជាហេតុតែងមានជាធម្មតាទេ, បើដូច្នោះ អាត្មាអញ

ផ្គងព្យាយាមឲ្យបានមុនសិន ។ ល ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុ ទី ៧ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកចេញចាកជម្ងឺ ទើបតែស្បើយអំពីជម្ងឺថ្មីៗ ។ ភិក្ខុនោះ មានសេចក្ដីត្រិះរិះ យ៉ាងនេះថា 'អាត្មាអញជាអ្នកចេញចាកជម្ងឺ ទើបតែស្បើយអំពីជម្ងឺហើយថ្មីៗ, អាពាធរបស់អាត្មាអញ គប្បីរើមកឡើងវិញដោយហេតុណា, ហេតុនុ៎ះ ជាហេតុតែងមានជាធម្មតាទេ, បើដូច្នោះ អាត្មាអញផ្គងព្យាយាម ឲ្យបានមុនសិន ដើម្បីឲ្យដល់នូវគុណគឺ ឈាន វិបស្សនា មគ្គ និងផល ដែលអាត្មាអញមិនទាន់បានដល់ ។ ល ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុ ទី ៨ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងអារព្ភវត្ថុទាំង ៨ យ៉ាង" ។

កុសីតារព្ភវត្ថុសូត្រ ចប់ ។

(១២៥) អដ្ឋកថាកុសីតារព្ភសូត្រនោះ និងអដ្ឋកថាសង្គីតិសូត្រ ថា " រឿង គឺហេតុជាទីតាំង របស់បុគ្គលអ្នកខ្ជិល គឺអ្នកខ្ជិលច្រអូស អធិប្បាយថា ហេតុនៃភាពជាអ្នកខ្ជិលច្រអូស ឈ្មោះថា កុសីតវត្ថុ ។ ច្រើនបទ ថា '**កម្មំ កត្តព្វំ ហោតិ**' មានសេចក្ដីថា អំពើមានការលៃលក,វាស់,កាត់ចីវរជាដើម ជាអំពើដែលភិក្ខុគួរធ្វើ ។ ពាក្យថា '**ន វីរិយំ អារភតិ**' គឺ មិនផ្គងនូវសេចក្ដីព្យាយាម ទាំង ២ យ៉ាង ។ បទថា '**អប្បត្តស្ស**' បានដល់

ព្យាយាម ទាំង ២ យ៉ាង ។ បទថា 'អប្បត្តស្ស' បានដល់ ដើម្បីឲ្យដល់នូវធម៌ គឺឈាន វិបស្សនា មគ្គនិងផល ដែលខ្លួនមិន ទាន់បានដល់ ។ បទ ថា 'អនធិគតស្ស' គឺ ដើម្បីប្រយោជន៍ ដល់ការដឹងនូវធម៌ គឺ ឈាន វិបស្សនា មគ្គនិងផលនោះឯង ដែល ខ្លួនមិនទាន់បានដឹង ។ បទថា 'អសច្ឆិកតស្ស' គឺ ដើម្បីធ្វើឲ្យ ច្បាស់លាស់នូវធម៌ គឺឈាន វិបស្សនា មគ្គនិងផលនោះឯង ដែល ខ្លួនមិនទាន់បានធ្វើឲ្យច្បាស់លាស់ ។ ២ បទ ថា 'ឥទំ បឋមំ' មានសេចក្តីថា នេះ គឺសេចក្តីរួញរា ព្រោះគិតយ៉ាងដូច្នេះ ថា 'បើ ដូច្នោះ អាត្មាអញដេកសិន' ដូច្នេះ ជាកុសីតវត្ថុ ទី ១ ។ ក្នុងបទ ទាំងពួង ក៏គប្បីជ្រាបសេចក្តី ដោយន័យនេះ ។ ក៏ក្នុងពាក្យថា 'មាសាចិតំ មញ្ញេ' នេះ សណ្តែករាជមាស ដែលទទឹកជោក ឈ្មោះថា មាសាចិតៈ ។ អធិប្បាយថា 'រាងកាយធ្ងន់ ដូចជា សណ្តែករាជមាសដែលទទឹក ជារបស់ដែលធ្ងន់ យ៉ាងដូច្នោះឯង' ។ ពាក្យថា 'គិលានា វុដ្ឋិតោ ហោតិ' គឺ ជាអ្នកមានជម្ងឺ ជា សះស្បើយហើយ ខាងក្រោយមក ។ ហេតុនៃសេចក្តីព្យាយាម ឈ្មោះថា អារព្ភវត្ថុ ។ សេចក្តីនៃហេតុនៃការប្រារព្ធសេចក្តី ព្យាយាមទាំងនោះ ក៏គប្បីជ្រាប ដោយន័យនេះដែរ" ។

(១២៦) ដីកានៃសូត្រទាំង ២ នោះ ថា "បុគ្គលឯណា

រមែងស្រុតចុះកាន់អាការៈ ដែលបណ្ឌិតគួរខ្ពើមរអើម ហេតុនោះ បុគ្គលនោះ ឈ្មោះថា កុសីតៈ ព្រោះផ្លាស់ ទ អក្សរ ជា ត អក្សរ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅបុគ្គលថាកុសីតៈ ដោយអំណាចនៃធម៌ណា, ធម៌នោះ គឺ ភាវៈនៃបុគ្គលជាអ្នកខ្ជិលច្រអូស ព្រះអង្គទ្រង់ត្រាស់ហើយ ដោយកុសីតស័ព្ទ ក្នុងព្រះសូត្រនេះ ។ មែនពិតអត្ថនៃភាវៈ សូម្បីវៀរចាកនូវស័ព្ទ ដែលបំភ្លឺដល់ភាវៈ ក៏បណ្ឌិតរមែងដឹងបាន ប្រៀបដូចជាឧទាហរណ៍ថា 'បដស្ស សុក្កំ' (ភាវៈនៃសំពត់ជារបស់មានពណ៌ស) ដូច្នោះ ។ ព្រោះហេតុនោះ បណ្ឌិត គប្បីជ្រាបសេចក្ដីថា 'ហេតុនៃភាវៈជាអ្នកខ្ជិលច្រអូស' ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា '**កោសជ្ជ-ការណានីតិ អត្ថោ**' ។ អំពើប្រាកដដូច្នេះ សមគួរដល់ភិក្ខុឈ្មោះថា ការងារ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា '**ចីវរវិចារណាទិ**' ។ បទថា '**វីរិយំ**' បានដល់ សេចក្ដីព្យាយាមដែលជាប្រធាន ។ ក៏សេចក្ដីព្យាយាមនោះ រមែងបាននូវភាវៈជាធម្មជាតិ ដែលបណ្ឌិតគប្បីពោល ថា 'ប្រព្រឹត្តទៅខាងផ្លូវកាយ' ដូច្នោះក៏មាន ព្រោះការធ្វើ ដោយអំណាចការចង្ក្រមន៍ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា '**ទុវិធម្បិ**' ។ បទថា 'បត្តិយា' ប្រែថា ដើម្បីឲ្យដល់ ។ សេចក្ដីរួញរា ក្នុង

ការតាមប្រកបនូវភាវនា ឈ្មោះថា ឱសីទនៈ ។ កាយណាជាធម្មជាតិធ្ងន់ ដូចទឹកដែលសណ្តែករាជមាសទាំងឡាយសន្សំគឺសន្សំឡើងហើយ ព្រោះហេតុនោះ កាយនោះ ឈ្មោះថា ដូចជាសណ្តែករាជមាសដែលទទឹក ។ សណ្តែករាជមាសទាំងឡាយ សើមហើយរមែងជារបស់ធ្ងន់ ដោយវិសេស ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា 'យថា តិន្តមាសោ' ដូច្នេះ ជាដើម ។ ២ បទថា 'វុដ្ឋិតោ ហោតិ' អធិប្បាយថា សេចក្តីមិនមានជម្ងឺ ។ បទថា 'តេសំ' គឺ ហេតុនៃការប្រារព្ធសេចក្តីព្យាយាមទាំងឡាយ ។ ២ បទថា 'ឥមិនា វា នយេន' មានសេចក្តីថា ដោយន័យនេះ គឺ តាមដែលបានពោលមកហើយក្នុងហេតុនៃបុគ្គលអ្នកខ្ជិលច្រអូសនុ៎ះឯង ។ គប្បីជ្រាបសេចក្តីដោយន័យជាដើមថា 'ភិក្ខុរមែងផ្គងព្យាយាម ទាំង ២ យ៉ាង' ដូច្នេះ និងដោយន័យជាដើមថា '២ បទថា 'ឥទំ បឋមំ' មានសេចក្តីថា ហេតុនេះ គឺ សេចក្តីព្យាយាមយ៉ាងអស្ចារ្យ ក្នុងភាវនា យ៉ាងនេះថា 'បើដូច្នោះ អាត្មាអញផ្គងនូវសេចក្តីព្យាយាម' ដូច្នេះ ជាហេតុនៃការប្រារព្ធសេចក្តីព្យាយាម ទី ១' ។ មែនពិតសេចក្តីព្យាយាម យ៉ាងអស្ចារ្យ ដែលប្រព្រឹត្តទៅហើយ ជាលើកដំបូងដោយប្រការណាមួយ រមែងជាហេតុនៃការប្រារព្ធសេចក្តីព្យាយាម

ក្នុងពេលជាបន្តៗទៅ ។ ព្រោះសេចក្ដីព្យាយាម ដ៏ក្រៃលែងទាំងឡាយ ប្រកបដោយសេចក្ដីពិចារណា តាមសមគួរ ។ សេចក្ដីពិចារណាទាំងឡាយ មានសេចក្ដីព្យាយាម ដ៏ក្រៃលែងនោះជាមូល គប្បីជ្រាប ថា ហេតុនៃការប្រារព្ធសេចក្ដីព្យាយាម ៨ យ៉ាង " ។

(១២៧) បុគ្គលដឹងនូវហេតុនៃបុគ្គលអ្នកខ្ជិលច្រអូស និងហេតុនៃការប្រារព្ធសេចក្ដីព្យាយាម ទាំង ២ ប្រការនោះ ដោយហេតុទាំងឡាយ ៨ យ៉ាង ដូចបានពណ៌នាមកហើយនេះ គប្បីលះបោលនូវភាពជាអ្នកខ្ជិលច្រអូស ហើយធ្វើសេចក្ដីព្យាយាម ។ ក៏កាលនឹងធ្វើ គប្បីធ្វើសេចក្ដីព្យាយាមនោះឲ្យប្រកបដោយអង្គ ៤ ។ ក៏សេចក្ដីព្យាយាម ដែលប្រកបដោយអង្គ ៤ នោះ មកហើយ ក្នុងបឋមវគ្គ នៃបឋមបណ្ណាសកៈ ក្នុងទុកនិបាត អង្គុត្តរនិកាយ ។ សមដូចព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ក្នុងទុកនិបាត អង្គុត្តរនិកាយ[១] នោះ ថា " ម្នាលភិក្ខុទាំងឡាយ បានឮថា តថាគត ជាអ្នកមានសេចក្ដីព្យាយាមមិនត្រឡប់ក្រោយ តាំងព្យាយាម ដោយមនសិការ ថា

' ស្បែក សរសៃ និងឆ្អឹង ចូរនៅសេសសល់ ក៏តាម
ចុះ, សាច់និងឈាម ក្នុងរាងកាយ របស់តថាគត
ទាំងអស់នោះ ចូរក្រៀមស្ងួត ហួតហែងទៅចុះ,

---

១- ត្រៃបិដក ភាគទី ៤០ / ទំព័រទី ១១០ ។

គុណវិសេសណា ដែលបុគ្គលគួរបានដល់ ដោយកំឡាំងរបស់បុរស ដោយសេចក្ដីព្យាយាមរបស់បុរស ដោយសេចក្ដីប្រឹងប្រែងរបស់បុរស (បើ) មិនទាន់បានដល់នូវគុណវិសេសនោះទេ នឹងមិនបញ្ឈប់នូវសេចក្ដីព្យាយាមទៅវិញឡើយ ’ ។ ម្នាលភិក្ខុទាំងឡាយ ពោធិញ្ញាណ គឺតថាគតនោះ បានសម្រេចហើយ ដោយសេចក្ដីមិនប្រមាទ, ធម៌ជាគ្រឿងក្សេមចាកយោគៈ ដ៏ប្រសើរ ក៏តថាគតបានសម្រេចហើយ ដោយសេចក្ដីមិនប្រមាទដែរ, ម្នាលភិក្ខុទាំងឡាយ បើសិនអ្នកទាំងឡាយ ជាអ្នកមានសេចក្ដីព្យាយាមមិនត្រឡប់ក្រោយ ផ្គងសេចក្ដីព្យាយាម ដោយធ្វើទុកក្នុងចិត្តថា ៖

‘ស្បែក សរសៃនិងឆ្អឹង សូមឲ្យសល់នៅចុះ; សាច់ និងឈាម ក្នុងសរីរៈ របស់យើង ទាំងអស់នោះ ចូរហួតហែងទៅចុះ,

គុណវិសេសណា ដែលបុគ្គលគួរបានដល់ ដោយកំឡាំងរបស់បុរស ដោយសេចក្ដីព្យាយាមរបស់បុរស ដោយសេចក្ដីប្រឹងប្រែងរបស់បុរស (បើ) មិនទាន់បានដល់នូវគុណវិសេសនោះទេ នឹងមិនបញ្ឈប់នូវសេចក្ដីព្យាយាមទៅវិញឡើយ ’ ។ ម្នាលភិក្ខុទាំងឡាយ ពួកកុលបុត្រ ចេញចាកផ្ទះ ចូលកាន់ផ្នួស ដោយប្រពៃ ដើម្បី

ប្រយោជន៍ដល់អនុត្តរធម៌ណា, សូមឲ្យអ្នកទាំងឡាយ ក៏នឹងធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយធម៌ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង សម្រេចនៅ ក្នុងបច្ចុប្បន្ននេះ ដោយកាលមិនយូរឡើយ ៗ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ គប្បីសិក្សា ក្នុងសាសនានេះ យ៉ាងនេះ ថា 'យើងទាំងឡាយ ជាអ្នកមានសេចក្ដីព្យាយាម មិនត្រឡប់ក្រោយផងសេចក្ដីព្យាយាម ដោយធ្វើទុកក្នុងចិត្ត ថា ÷

'ស្បែក សរសៃ និងឆ្អឹង សូមឲ្យសល់នៅចុះ; សាច់និងឈាម ក្នុងសរីរៈ របស់យើង ទាំងអស់នោះចូរហួតហែងទៅចុះ,

គុណវិសេសណា ដែលបុគ្គលគួរបានដល់ ដោយកំឡាំងរបស់បុរស ដោយសេចក្ដីព្យាយាមរបស់បុរស ដោយសេចក្ដីប្រឹងប្រែងរបស់បុរស (បើ) មិនទាន់បានដល់នូវគុណវិសេសនោះទេ នឹងមិនបញ្ឈប់នូវសេចក្ដីព្យាយាមទៅវិញឡើយ 'ដូច្នេះ, ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សា យ៉ាងនេះឯង " ៗ

បាលីចតុរង្គវីរិយសូត្រ ចប់ ។

(១២៨) អដ្ឋកថាចតុរង្គវីរិយសូត្រនោះ ថា "បទថា

'សុទំ' ក្នុងពាក្យថា 'អប្បដិវានី សុទាហំ ភិក្ខវេ បទហាមិ' នេះ គ្រាន់តែជានិបាត ។ ក្នុងពាក្យនោះ មានអធិប្បាយ ដូចតទៅនេះ ថា 'ម្នាលភិក្ខុទាំងឡាយ តថាគតស្ថិតនៅហើយ ក្នុងសេចក្ដីមិនរួញរា កាលប្រាថ្នានូវសព្វញ្ញុតញ្ញាណ ទើបបានធ្វើហើយនូវសេចក្ដីព្យាយាម ក្នុងកាលជាព្រះពោធិសត្វ' ។ សេចក្ដីព្យាយាមនោះ គឺ ព្រះដ៏មានព្រះភាគអង្គនេះ ទ្រង់បានធ្វើហើយ ដោយពិធីណា, កាលនឹងទ្រង់សំដែងនូវពិធីនោះ ក្នុងពេលឥឡូវនេះ ទើបទ្រង់ត្រាស់ថា 'កាមំ តចោ' ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ ដោយបទថា 'យន្តំ' នេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដែងនូវគុណជាតគ្រប់បែបយ៉ាង ដែលគប្បីសម្រេចបាន ។ ក្នុងបទថា 'បុរិសត្ថាមេន' ជាដើម ព្រះដ៏មានព្រះភាគ ទ្រង់បានសំដែងកំឡាំង គឺញាណ របស់បុរស សេចក្ដីព្យាយាម គឺញាណរបស់បុរស និងសេចក្ដីប្រឹងប្រែង គឺញាណរបស់បុរស ។ កិរិយាឈប់ គឺការបញ្ឈប់ បានដល់ ការមិនខ្វល់ខ្វាយ គឺសេចក្ដីរួញរា អធិប្បាយថា ការរម្ងាប់ចោល ឈ្មោះថា សណ្ឋានំ ។ ឈ្មោះថា កិរិយាតាំងនូវសេចក្ដីព្យាយាម ដែលប្រកបដោយអង្គ ៤ ព្រះដ៏មានព្រះភាគអង្គនេះ ត្រាស់ហើយ ដោយពាក្យមានប្រមាណប៉ុណ្ណោះ ។ ក៏ក្នុងកិរិយាផ្គងសេចក្ដីព្យាយាមនេះ គប្បីជ្រាបអង្គទាំង ៤ យ៉ាង

នេះ គឺ ពាក្យថា '**កាមំ តចោ**' ជាអង្គ ១, ពាក្យថា '**នហារូ ច**' ជាអង្គ ១, ពាក្យថា '**អដ្ឋិ ច**' ជាអង្គ ១, ពាក្យថា '**មំសលោហិតំ**' ជាអង្គ ១ ។ ពាក្យទាំងឡាយ ជាដើម ថា '**បុរិសត្ថាមេន**' ជាឈ្មោះនៃសេចក្តីព្យាយាម ដែលមានប្រមាណដ៏ក្រៃលែង ។ សេចក្តីព្យាយាម ដែលប្រកបដោយអង្គ ៤ មានក្នុងកាលមុន ព្រះដ៏មានព្រះភាគ ទ្រង់តាំងទុកហើយ យ៉ាងនេះគប្បីជ្រាប ថា 'ឈ្មោះថា ការផ្គងសេចក្តីព្យាយាម ដែលគ្រប់ដោយអង្គ ៤ យ៉ាង' ដោយប្រការដូច្នេះ ។ ព្រះដ៏មានព្រះភាគអង្គនេះទ្រង់ត្រាស់ បដិបទាដែលជាទីតាំង នៃគុណជាហេតុមកនៃផលរបស់ព្រះអង្គ លើពោធិបល្ល័ង្ក ដោយព្រះតម្រាស់ប្រមាណប៉ុណ្ណេះ ។ ឥឡូវនេះ ព្រះអង្គទ្រង់ត្រាស់ព្រះតម្រាស់ ថា '**តស្ស មយ្ហំ ភិក្ខវេ**' ដូច្នេះ ជាដើម ដើម្បីនឹងទ្រង់ត្រាស់នូវគុណ ដែលព្រះអង្គទ្រង់បានចំពោះហើយ ដោយបដិបទានោះ ។ បណ្តាបទទាំងនោះ បទថា '**អប្បមាទាធិគតា**' មានសេចក្តីថា បញ្ញាគ្រឿងត្រាស់ដឹង ដែលតថាគត បានសម្រេចហើយ ដោយសេចក្តីមិនប្រមាទ ពោលគឺកិរិយាមិននៅប្រាសចាកសតិ គឺដែលតថាគតមិនបានហើយ ដោយសេចក្តីប្រមាទដូចដេកលក់ហើយ ។ ញាណដែលប្រកបព្រមដោយមគ្គទាំង ៤ និងព្រះសព្វញ្ញុតញ្ញាណ ឈ្មោះថា **ពោធិ** ។

ពោធិញ្ញាណនុ៎ះ គឺ បុគ្គលអ្នកដែលប្រមាទ ដូចជាបុគ្គលអ្នកដេកលក់ហើយ មិនអាចសម្រេចបានឡើយ យ៉ាងនេះឯង ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ត្រាស់ថា 'អប្បមាទាធិគតា ពោធិ' ដូច្នេះ ។ ២ បទថា 'អនុត្តរោ យោគក្ខេមោ' មានសេចក្តីថា មិនមែនបញ្ញាជាគ្រឿងត្រាស់ដឹង តែម្យ៉ាងប៉ុណ្ណោះទេ, សូម្បីធម៌ជាដែនក្សេមចាកយោគៈ ដ៏ខ្ពង់ខ្ពស់ ពោលគឺព្រះអរហត្ត-ផល និងព្រះនិព្វាន ក៏តថាគត បានសម្រេចហើយ ដោយសេចក្តីមិនប្រមាទដូចគ្នាដែរ ។ ឥឡូវនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់បបួលនូវភិក្ខុសង្ឃ ក្នុងគុណដែលព្រះអង្គទ្រង់បានហើយ ទើបទ្រង់ត្រាស់ថា 'តុម្ហេ ចេបិ ភិក្ខវេ' ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា 'យស្សត្ថាយ' មានសេចក្តីថា ជាអ្នកមានគោលបំណងចូលទៅអាស្រ័យនៅ ដើម្បីប្រយោជន៍ ដល់អរិយផល ដ៏ខ្ពង់ខ្ពស់ណា ។ បទថា 'តទនុត្តរំ' កាត់បទជា តំ អនុត្តរំ (នូវអរិយផលដ៏ខ្ពង់ខ្ពស់នោះ) ។ បទថា 'ព្រហ្មចរិយបរិយោសានំ' គឺ អរិយផលដែលមាន ក្នុងទីបំផុតនៃមគ្គព្រហ្មចរិយៈ ។ ២ បទថា 'អភិញ្ញា សច្ឆិកត្វា' មានសេចក្តីថា ធ្វើឲ្យជាក់ច្បាស់ ដោយអភិញ្ញា គឺដោយបញ្ញាដ៏ខ្ពង់ខ្ពស់ ។ បទថា 'ឧបសម្បជ្ជ' មានសេចក្តីថា នឹងបានចំពោះ គឺសម្រេចនៅ ។ បទថា 'តស្មា'

គឺ ព្រោះឈ្មោះថា ការផ្គងព្យាយាម ដោយមិនរួញរានុ៎ះ ជាធម្មជាត មានឧបការៈច្រើន គឺ ញ៉ាំងប្រយោជន៍ដ៏ខ្ពង់ខ្ពស់ឲ្យសម្រេចបាន” ។

(១២៨) ដីកាចតុរង្គវីរិយសូត្រនោះ ថា “កាលបើខ្សែនៃសេចក្ដីព្យាយាម ប្រព្រឹត្តទៅ, ការថយក្រោយ គឺ ការត្រឡប់វិញបានដល់ ការរួញរា ក្នុងចន្លោះ ក៏រមែងមានដូចគ្នាដែរ ។ សេចក្ដីរួញរានោះ រមែងមាន ដល់បុគ្គលនុ៎ះ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **បដិវានី** (អ្នកមានសេចក្ដីរួញរា) ។ អ្នកមានសេចក្ដីរួញរាមិនមាន ឈ្មោះថា **អប្បដិវានី** (អ្នកមិនមានសេចក្ដីរួញរា) ។ សេចក្ដីប្រតិបត្តិ ដែលជាចំណែកខាងដើមពោលគឺសមថៈនិងវិបស្សនា ឈ្មោះថា **អាគមនីយប្បដិបទា** ។ ក៏បុព្វភាគបដិបទានោះ ឈ្មោះថា **អាគមនីយៈ** ព្រោះវិគ្រោះ ថា ជាហេតុមក គឺ សម្រេចគុណវិសេស នៃការកបុគ្គលទាំងឡាយ ឬជាគ្រឿងមក នៃកិរិយាសម្រេចនូវគុណវិសេស ។ សេចក្ដីប្រតិបត្តិនោះឯង ឈ្មោះថា **បដិបទា** ព្រោះជាធម្មជាតិ ដែលបុគ្គលគប្បីប្រតិបត្តិ ព្រោះហេតុនោះ សេចក្ដីប្រតិបត្តិនោះ ទើបឈ្មោះថា **អាគមនីយប្បដិបទា** ។ សេចក្ដីព្យាយាមដែលប្រាសចាកកិរិយារួញរា គឺ សេចក្ដីព្យាយាម ដែលបុគ្គលធ្វើមិនឲ្យរួញរាក្នុងចន្លោះ ឈ្មោះថា **អប្បដិវានប្បធានំ** ” ។

(១៣០) ព្រោះហេតុនោះ អ្នកណាមួយក៏ដោយ មិនគួរលះបង់សេចក្តីព្យាយាមចោលឡើយ ។ បើបុគ្គលអាស្រ័យបច្ច័យប្រាកដដូច្នោះ លះបង់សេចក្តីព្យាយាមចោល ក្នុងកាលមុន ក្នុងពេលក្រោយមក គប្បីលើកស្ទួយឲ្យទាល់តែបាន ដូចជាភិក្ខុអ្នកលះបង់សេចក្តីព្យាយាមចោល យ៉ាងដូច្នោះឯង ។

## ( រឿងភិក្ខុអ្នកលះសេចក្តីព្យាយាម )

បានឮថា ភិក្ខុអង្គនោះ បានរៀនកម្មដ្ឋាន ក្នុងសំណាក់ នៃព្រះសាស្តា ហើយចូលទៅព្រៃ សូម្បីខំព្យាយាម រហូត ៣ ខែ ក៏មិនអាចញ៉ាំងគុណវិសេសអ្វីមួយ ឲ្យកើតឡើងបានឡើយ ទើបគិតថា "បណ្តាបុគ្គល ៤ ពួក ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយនោះ អាត្មាអញ គប្បីជាបុគ្គលចំពួកបទបរមៈ, មគ្គនិងផល ឃើញថាដូចជា មិនមាន ដល់អាត្មាអញឡើយ ក្នុងអត្តភាពនេះ, នឹងមានប្រយោជន៍អ្វីទៅ ដោយការនៅក្នុងព្រៃ, អាត្មាអញនឹងទៅកាន់សំណាក់ នៃព្រះសាស្តាហើយ សំឡឹងមើលព្រះរូប នៃព្រះពុទ្ធ នឹងនៅស្តាប់ព្រះធម៌ដ៏ពិរោះ" ដូច្នេះ ហើយក៏បានត្រឡប់មកកាន់វត្តជេតពនវិញហើយ ។

គ្រានោះ ពួកភិក្ខុទាំងឡាយ ដឹងហេតុនោះហើយ ទើបនាំ

ភិក្ខុនោះទៅកាន់សំណាក់នៃព្រះសាស្ដា ហើយក្រាបទូល ថា “បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអង្គនេះ លះបង់សេចក្ដីព្យាយាមមកហើយ”ៗ ព្រះសាស្ដា កាលនឹងទ្រង់ឧបត្ថម្ភនូវភិក្ខុនោះ ទើបទ្រង់ត្រាស់ ថា “ម្នាលភិក្ខុ អ្នកបួសហើយ ក្នុងសាសនាដែលនាំសត្វឲ្យចេញចាកសេចក្ដីទុក្ខ យ៉ាងនេះ មិនញុំាងជនដទៃឲ្យស្គាល់ខ្លួន យ៉ាងនេះ ថា ‘ជាអ្នកប្រាថ្នាតិច... ជាអ្នកសន្ដោស ... ជាអ្នកស្ងប់ស្ងាត់... ជាអ្នកមិនច្របូកច្របល់’ ឬថា ‘ជាអ្នកប្រារព្ធសេចក្ដីព្យាយាម’ ដូច្នេះ (តែត្រឡប់ជា) ញុំាងជនដទៃ ឲ្យស្គាល់ខ្លួន ថា ‘ជាភិក្ខុអ្នកលះបង់ នូវសេចក្ដីព្យាយាម’ ដូច្នេះវិញ ព្រោះហេតុអ្វី ?, ក្នុងកាលមុន អ្នកបានជាអ្នកមានសេចក្ដីព្យាយាមហើយ មិនមែនទេឬ ?, ជនជាច្រើន អាស្រ័យនូវសេចក្ដីព្យាយាម ដែលអ្នកម្នាក់ឯងគត់ បានធ្វើហើយ ទើបបានទឹកផឹក ក្នុងផ្លូវឆ្ងាយព្រោះទន្លេខ្សាច់ បានទទួលសេចក្ដីសុខហើយ, ឥឡូវនេះ ព្រោះហេតុអ្វី ទើបអ្នកលះបង់នូវសេចក្ដីព្យាយាមចោល ?”ៗ ភិក្ខុនោះ បានជាអ្នកគឺព្រះដ៏មានព្រះភាគឧបត្ថម្ភហើយ ដោយព្រះតម្រាស់មានប្រមាណប៉ុណ្ណេះ ៗ គ្រានោះ ព្រះដ៏មានព្រះភាគ ត្រូវពួកភិក្ខុក្រាបទូលសួរហើយ ទើបទ្រង់នាំនូវអតីតនិទានមក (សំដែង ថា) ÷

(១៣១) ក្នុងអតីតកាល ក្នុងក្រុងពារាណសី ព្រះពោធិសត្វ

កើតជានាយរទេះជាចម្បង ទៅធ្វើពាណិជ្ជកម្ម ដោយរទេះ ៥០០ បានទៅដល់ទន្លេខ្សាច់ដ៏ឆ្ងាយមួយ មានចម្ងាយ ៦០ យោជន៍ ។ ក៏ក្នុងផ្លូវដ៏ឆ្ងាយនោះ ដីខ្សាច់ដ៏ល្អិតដែលបុគ្គលក្ដាប់ ដោយក្ដាប់ដៃ រមែងមិនជាប់នៅ ក្នុងដៃឡើយ, ហើយតាំងពីព្រះអាទិត្យរះឡើង មក ក៏មានកំដៅដូចជាគំនររងើករងើកភ្លើង, អ្នកណា ក៏មិនអាច ដើរជាន់បានឡើយ ។ ព្រោះហេតុនោះ ពួកឈ្មួញទាំងឡាយ កាលនឹងដើរទៅកាន់ផ្លូវឆ្ងាយនោះ ក៏ផ្ទុករបស់របរផ្សេង ៗ មាន ឧស ទឹក ប្រេង និងអង្ករជាដើម ពេញរទេះ ហើយធ្វើដំណើរទៅ ក្នុងវេលារាត្រីតែប៉ុណ្ណោះ ក្នុងវេលាព្រះអាទិត្យរះឡើង បានផ្ដុំ រទេះជារង្វង់មូល ហើយបាំងមណ្ឌបពួដ៏ខាងលើ អង្គុយសម្រាក ហើយ, កាលព្រះអាទិត្យ អស្តង្គតហើយ, ក៏នាំគ្នាទទួលទាននូវ អាហារពេលល្ងាច, កាលបើផែនដី ត្រជាក់វិញហើយ, ទើបនាំគ្នា ធ្វើដំណើរទៅ ។ ឯព្រះពោធិសត្វ ធ្វើដំណើរទៅកាន់ផ្លូវឆ្ងាយនោះ ដោយទំនងនេះដែរ ក៏បានទៅ អស់រយៈផ្លូវចម្ងាយ ៥៩ យោជន៍ ហើយគិត ថា "ឥឡូវនេះ ដោយពេលតែមួយរាត្រីទៀតប៉ុណ្ណោះ ក៏នឹងបានចេញផុត អំពីទន្លេខ្សាច់ដ៏ឆ្ងាយ" ដូច្នេះហើយ ទើប បរិភោគអាហារពេលល្ងាចស្រេច ក៏បានបញ្ជាឲ្យចាក់ទឹកទាំងអស់ ចោលរលីង ហើយក៏បររទេះទៅ ។ អ្នកនាំផ្លូវ ដែលដេកនៅ

លើររទេះខាងមុខ ក្រឡេកមើលតារា ឰដ៏អាកាស ពោលថា "ពួកអ្នកទាំងឡាយ ចូរដេញគោទៅខាងនេះ, ចូរដេញគោទៅខាងនុ៎ះ" ហត់នឿយ ព្រោះមិនបានដេក អស់កាលមកយូរហើយ ក៏បានដេកលក់ មិនបានដឹងហើយ នូវគោទាំងឡាយ ដែលវិលត្រឡប់ទៅយកផ្លូវដែលបានធ្វើដំណើរមកឡើយ ។ គោទាំងឡាយ បានទៅរហូតអស់មួយរាត្រី ។ អ្នកនាំផ្លូវបានក្រោកឡើង ក្នុងពេលព្រះអរុណរះឡើងហើយ ដឹងសេចក្ដីនោះ ទើបស្រែកថា "អ្នកទាំងឡាយចូរត្រឡប់រទេះទៅវិញ" ។ ពួកឈ្មួញទាំងអស់នោះ បានទៅដល់កន្លែងដែលខ្លួនឈប់សម្រាកហើយ ក្នុងពេលម្សិលមិញ ក៏សោកសៅ ថា "សូម្បីទឹករបស់ពួកយើងអស់ហើយ, ឥឡូវនេះ ពួកយើងជាអ្នកវិនាសហើយ" ដូច្នេះ ទើបនាំគ្នាដេកនៅក្រោមរទេះ របស់ខ្លួនៗ ។ ព្រះពោធិសត្វ កាលដើរទៅ ក្នុងវេលាដែលផែនដីត្រជាក់ នៅពេលព្រឹកនុ៎ះឯង ក៏បានឃើញគុម្ពស្មៅចិញ្ចៀនមួយគុម្ព ហើយគិតថា "ស្មៅទាំងអស់នេះ នឹងដុះលូតលាស់ឡើងបាន ព្រោះសេចក្ដីត្រជាក់នៃទឹកខាងក្រោម" ដូច្នេះហើយ ទើបបានឲ្យមនុស្សជីកនូវកន្លែងនោះ ។ កាលបើមនុស្សទាំងឡាយ ជីកគាស់អស់ទីប្រមាណ ៦០ ហត្ថ ក៏បានប៉ះលើដុំថ្ម ឰដ៏ខាងក្រោម ។ ពួកឈ្មួញទាំងអស់ បានលះបង់ចោលហើយ នូវសេចក្ដីព្យាយាម ។

ព្រះពោធិសត្វ គិត ថា “ព្ធដីខាងក្រោមដុំថ្មនេះ គង់នឹងមានទឹក” ហើយបានលោតចុះទៅ ផ្ទៀងត្រចៀកស្ដាប់ហើយ បានឮសំឡេងទឹក ទើបឡើងមកវិញ បានបញ្ជាអ្នកបម្រើ ថា “នែអ្នក បើអ្នកលះបង់សេចក្ដីព្យាយាមចោលហើយ, ពួកយើងទាំងអស់គ្នា ក៏នឹងវិនាស, ចូរអ្នកចាប់ញញួរដែកនេះ ចុះទៅវាយកំទេចដុំថ្ម” ។ អ្នកបម្រើនោះ បានធ្វើហើយ យ៉ាងដូច្នោះ ។ ដុំថ្មបានបែកជាពីរបំណែកហើយ ក៏បានទប់ខ្សែទឹកទុក ។ ខ្សែទឹកទំហំប៉ុនដើមត្នោត បានផុះឡើងហើយ ។ ឯជនទាំងអស់គ្នា បានផឹកទឹកហើយ ក៏បានធ្វើដំណើរទៅ កាន់ទីកន្លែងដែលខ្លួនប្រាថ្នាហើយ ។

ព្រះសាស្ដា លុះទ្រង់នាំអតីតនិទានមក យ៉ាងនេះហើយ កាលទ្រង់ឱវាទពួកភិក្ខុ ទើបទ្រង់ត្រាស់គាថានេះ ក្នុងវណ្ណុបថជាតក ក្នុងទុតិយវគ្គ នៃឯកនិបាត[១] ថា ÷

(១៣២) “ពួកជន អ្នកមិនខ្ជិលច្រអូស កាលជីក (ផែនដី) ត្រង់ផ្លូវខ្សាច់ ឬក្នុងទីទួល បានហើយនូវទឹក ត្រង់ផ្លូវនោះ យ៉ាងណាមិញ, អ្នកប្រាជ្ញបរិបូណ៌ ដោយព្យាយាម និងកម្លាំងកាយ មិនខ្ជិលច្រអូស បាននូវសេចក្ដីស្ងប់ នៃហឫទ័យ យ៉ាងនោះដែរ” ។

---

១- ត្រៃបិដក ភាគទី ៥៨ / ទំព័រទី ១ ។

បណ្ដាបទទាំងនោះ បទថា "អភិលាសុនោ" បានដល់ ជាអ្នកមិនខ្ជិលច្រអូស គឺ ជាអ្នកប្រារព្ធសេចក្ដីព្យាយាម ។ ខ្សាច់ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា 'វណ្ណៈ' ក្នុងបទថា 'វណ្ណុបថេ' អធិប្បាយថា ត្រង់ផ្លូវដែលប្រកបដោយខ្សាច់ ។ បទថា "ខនន្តា" គឺ ជីកនូវផែនដី ។ ស័ព្ទថា ឧទ ក្នុងបទថា "ឧទង្គណេ" នេះ ជានិបាត, អធិប្បាយថា "ក្នុងទីខ្ពស់ គឺ ក្នុងភូមិភាគ ដែលជាទីត្រាច់ចរទៅ នៃមនុស្សទាំងឡាយ" ។ បទថា "តត្ថ" គឺ ត្រង់ផ្លូវខ្សាច់នោះ ។ បទថា "បបំ" គឺ ទឹក ។ មែនពិត ទឹកព្រះដ៏មានព្រះភាគត្រាស់ហៅថា 'បបៈ' ព្រោះជារបស់សម្រាប់ផឹក ។ ម្យ៉ាងទៀត ទឹកដែលហូរទៅ អធិប្បាយថា អន្លង់ទឹក ។ បទថា "អវិន្ទុំ" គឺ បានហើយ ។ បទថា "ឯវំ" ជាបទប្រៀបធៀបដោយពាក្យឧបមា ។ បុគ្គលអ្នកបរិបូណ៌ហើយ ដោយបញ្ញាពោលគឺញាណ របស់អ្នកចេះដឹង ឈ្មោះថា មុនី ។ បទថា "វីរិយពលូបបន្នោ" គឺ អ្នកប្រកបដោយសេចក្ដីព្យាយាម និងដោយកំឡាំងកាយនិងកំឡាំងញាណ ។ បទថា "អភិលាសុ" បានដល់ អ្នកមិនខ្ជិលច្រអូស ។ មុនី ឈ្មោះថា ជាអ្នកមិនខ្ជិលច្រអូស ព្រោះជាអ្នកប្រកប ដោយសេចក្ដីព្យាយាម ដែលប្រកបដោយអង្គ ៤ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ យ៉ាងនេះ ថា ÷

"ស្បែក សរសៃនិងឆ្អឹង សូមឲ្យសល់នៅចុះ, សាច់និងឈាម ក្នុងរាងកាយ របស់យើង ទាំងអស់នោះ ចូរហួតហែងទៅចុះ " ។

ពាក្យថា "វិន្ទេ ហទយស្ស សន្តិ " មានសេចក្តីថា រមែងបាន គឺ បានចំពោះនូវអរិយធម៌ ពោលគឺឈាន វិបស្សនា អភិញ្ញា និងញាណដែលប្រកបព្រមដោយអរហត្តមគ្គ ដែលដល់ការរាប់ ថា 'សន្តិ ' ព្រោះធ្វើនូវសេចក្តីត្រជាក់ នៃចិត្តខ្លះ នៃហទយរូបខ្លះ" ។

ក៏ព្រះដ៏មានព្រះភាគ លុះទ្រង់ត្រាស់ យ៉ាងនេះឯងហើយ ទើបទ្រង់បានប្រកាសនូវសច្ចៈទាំងឡាយ ។ ក្នុងពេលជាទីបញ្ចប់នៃសច្ចៈ ភិក្ខុអង្គនោះ ត្រូវព្រះដ៏មានព្រះភាគឧបត្ថម្ភហើយ ផ្គងនូវសេចក្តីព្យាយាម ចំរើនវិបស្សនា បានសម្រេចព្រះអរហត្តហើយ ។

រឿងភិក្ខុអ្នកលះចោលព្យាយាម ចប់ ។

ភោជាជានីយជាតក និងអាជញ្ញជាតក ក្នុងតតិយវគ្គ ឯកនិបាត និងមហាសីលវជាតក ក្នុងឆដ្ឋវគ្គ ឯកនិបាតនោះឯង បណ្ឌិតគប្បី (នាំមក) ពណ៌នា ។

ពណ៌នាអំពីសេចក្តីព្យាយាម ចប់ ។

តបះ ពោលគឺសេចក្ដីព្យាយាម និងកិរិយាសង្រួមនូវឥន្ទ្រីយ៍ បណ្ឌិតគប្បីជ្រាប ថា "ជាមង្គល" ព្រោះជាហេតុលះបោលនូវអកុសលធម៌ មានអភិជ្ឈាជាដើម និងបានចំពោះនូវអរិយធម៌ មានឈានជាដើម ដោយប្រការយ៉ាងដូច្នេះឯង ។

ពណ៌នាអំពីបទ ថា 'តបះ' ចប់ ។

ប្រែចប់ ថ្ងៃសៅរ៍ ៧ កើត ខែផល្គុណ ឆ្នាំរកា បញ្ចស័ក ព.ស.២៥៣៦
ត្រូវនឹង ថ្ងៃ ទី ២៧ ខែកុម្ភៈ ១៩៩៣
វេលាល្ងាច

*បើខ្មែរមិនស្រឡាញ់ខ្មែរទេ តើជាតិសាសន៍ណា*
*គេនឹងស្រឡាញ់ខ្មែរនោះ ។*

# ពណ៌នាអំពីព្រហ្មចរិយៈ

(១៣៣) ឈ្មោះថា ព្រហ្មចរិយៈ មាន ១០ យ៉ាង ដោយអំណាចទាន, កិរិយាជួយខ្វល់ខ្វាយ, សីល ៥, អប្បមញ្ញា, កិរិយាវៀរចាកមេថុន, ការសន្តោសដោយភរិយារបស់ខ្លួន, សេចក្តីព្យាយាម, អង្គនៃឧបោសថ, អរិយមគ្គ និងសាសនា ។

( ទាន ឈ្មោះថា ព្រហ្មចរិយៈ )

ពិតមែនយ៉ាងនោះ ទាន ឈ្មោះថា ព្រហ្មចរិយៈ ក្នុងបុណ្ណកជាតក ពោលគឺ វិធុរជាតក(១) ថា ÷

(១៣៤) " ខ្ញុំនិងភរិយា ទាំងពីរនាក់ ( កាលនៅ) ក្នុងមនុស្សលោក ជាអ្នកមានសទ្ធា ជាម្ចាស់នៃទាន ក្នុងកាលនោះ ផ្ទះរបស់ខ្ញុំ ដូចជាអណ្តូង ( នៃមហាជន ) ទាំងពួកសមណៈនិងព្រាហ្មណ៍ ខ្ញុំក៏បានឲ្យឆ្អែតស្កប់ស្កល់ហើយ, ខ្ញុំ (កាលនៅ ) ក្នុងកាលចម្បានគរនោះ បានឲ្យទានដោយគោរព គឺ ឲ្យកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប គ្រឿងប្រទីប ទីដេក

---

១- ត្រៃបិដក ភាគទី ៦៣ / ទំព័រទី ៨០ ។

ទីសំណាក់អាស្រ័យ សំពត់សម្រាប់ស្លៀកដណ្តប់ កម្រាលដេក បាយ ទឹក ។ ម្យ៉ាងទៀត នោះជាវត្ត នោះជាព្រហ្មចរិយៈ របស់ខ្ញុំ, នៃអ្នកប្រាជ្ញ ឯឫទ្ធិ សេចក្តីរុងរឿង កំឡាំងកាយ សេចក្តីព្យាយាម និងការកើត (ក្នុងភពនាគ) ទាំងវិមានដ៏ធំ របស់ខ្ញុំនេះ, នេះជាផលនៃកម្មនោះ ដែលខ្ញុំបាន សន្សំទុកល្អហើយ " ។

(១៣៥) អដ្ឋកថាបុណ្ណកជាតកនោះ ថា " បណ្តាបទទាំង នោះ បទថា 'មនុស្សលោកេ' គឺ ក្នុងកាឡចម្បានគរ ក្នុង ទីក្រុងអង្គៈ ។ ស្រើនបទ ថា 'តំ មេ វតំ' មានសេចក្តីថា ទាន ដែលខ្ញុំបានឲ្យហើយ ដោយគោរពនោះនុ៎ះឯង បានជាវត្ត ដែលខ្ញុំ សមាទានហើយ និងជាព្រហ្មចរិយៈ របស់ខ្ញុំ ។ ក៏វិបាកមានឫទ្ធិ ជាដើមនេះ ជាផលនៃព្រហ្មចរិយៈនោះ ដែលខ្ញុំប្រព្រឹត្តល្អហើយ " ។

ដីកាមហាសីហនាទសូត្រ ថា " សេចក្តីប្រព្រឹត្ត ឈ្មោះថា ប្រសើរ គឺ ខ្ពង់ខ្ពស់ ព្រោះកន្លងផុតនូវបាបធម៌ មានមន្ទិល គឺការ កំណាញ់ស្វិតស្វាញជាដើម និងព្រោះចំរើនដុះដាលឡើងនូវគុណ មានមេត្តាជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា ព្រហ្មចរិយៈ

( ការប្រព្រឹត្តិប្រសើរ ) គឺ **ទាន** ។ អានុភាព ឈ្មោះថា ឫទ្ធិ ។ រស្មីនៃសរីរៈរាងកាយ ដែលលេចចេញឡើងអំពីពន្លឺនៃសំពត់និងគ្រឿងប្រដាប់ ឈ្មោះថា សេចក្ដីរុងរឿង ។ ភាវៈជាអ្នកប្រកបដោយកំឡាំងកាយ និងដោយសេចក្ដីឧស្សាហ៍ ឈ្មោះថា កិរិយាកើតឡើងនៃកំឡាំងកាយនិងសេចក្ដីព្យាយាម " ។

នាគរាជ ឈ្មោះថា វរុណ រមែងហៅ វិធូរបណ្ឌិត ថា " លោកអ្នកប្រាជ្ញ " ។

( វេយ្យាវច្ចៈ ឈ្មោះថា ព្រហ្មចរិយៈ )

(១៣៦) ការប្រព្រឹត្តិខ្វល់ខ្វាយ ឈ្មោះថា ព្រហ្មចរិយៈ ក្នុងអង្កុរបេតវត្ថុ[១] ថា ÷

" ដៃរបស់ខ្ញុំ អាចឲ្យសម្រេចសេចក្ដីប្រាថ្នា ដោយហេតុនោះ, ដៃរបស់ខ្ញុំ ទើបបញ្ចេញនូវរសផ្អែមបាន ដោយហេតុនោះ, បុណ្យក៏រមែងសម្រេច ក្នុងដៃរបស់ខ្ញុំ ដោយការប្រព្រឹត្តិដ៏ប្រសើរនោះ " ។

សេចក្ដីនៃគាថានេះ ខ្ញុំបាន (សំដែង) ឲ្យពិស្ដារហើយ ព្រមទាំងរឿង ក្នុងអនវជ្ជកម្ម ពួដ៏ខាងក្រោយ ។

---

១ - ត្រៃបិដក ភាគទី ៥៦ / ទំព័រទី ៤៨ ។

( បញ្ចសីល ឈ្មោះថា ព្រហ្មចរិយៈ )

(១៣៧) បញ្ចសីល ឈ្មោះថា **ព្រហ្មចរិយៈ** ក្នុងតិត្តិរជាតក ថា "ម្នាលភិក្ខុទាំងឡាយ បញ្ចសីលនេះឯង បានជាព្រហ្មចរិយៈ ឈ្មោះថា តិត្តិរៈ ( របស់សត្វទទា ) នោះ" ។

( អប្បមញ្ញា ឈ្មោះថា ព្រហ្មចរិយៈ )

(១៣៨) អប្បមញ្ញាទាំងឡាយ ឈ្មោះថា **ព្រហ្មចរិយៈ** ក្នុងមហាគោវិន្ទសូត្រ ក្នុងមហាវគ្គ ទីឃនិកាយ ថា "ម្នាលបញ្ចសិខៈ ក៏ព្រហ្មចរិយៈនោះឯង រមែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីនឿយណាយ ក៏មិនមែនទេ, ដើម្បីប្រាសចាកសេចក្ដីតម្រេក ក៏មិនមែនទេ, ដើម្បីសេចក្ដីរលត់ ក៏មិនមែនទេ, រមែងប្រព្រឹត្តទៅ ដើម្បីគ្រាន់តែទៅកើតក្នុងព្រហ្មលោកប៉ុណ្ណោះឯង" ។

( មេថុនវិរតិ ឈ្មោះថា ព្រហ្មចរិយៈ )

(១៣៩) មេថុនវិរតិ (ការវៀរចាកមេថុន) ឈ្មោះថា **ព្រហ្មចរិយៈ** ក្នុងឧបោសថសូត្រ ក្នុងតិកនិបាត អង្គុត្តរនិកាយ និងក្នុងព្រហ្មជាលសូត្រជាដើម ថា "លះបង់នូវការប្រព្រឹត្តិមិនប្រសើរ ហើយប្រព្រឹត្តប្រសើរជាប្រក្រតី" ។

អដ្ឋកថាឱ្យបោសថសូត្រជាដើមនោះ ថា " បណ្ដាបទទាំងនោះ បទថា 'អព្រហ្មចរិយំ' បានដល់ កិរិយាប្រព្រឹត្តិមិនប្រសើរ ។ បុគ្គលណាប្រព្រឹត្ត នូវអាចារៈ (មារយាទ) ដ៏ប្រសើរ គឺ ដ៏ខ្ពង់ខ្ពស់ ហេតុនោះ បុគ្គលនោះ ឈ្មោះថា ព្រហ្មចារី " ។

ដីកាឱ្យបោសថសូត្រជាដើមនោះ ថា "បទថា 'អសេដ្ឋចរិយំ' បានដល់ ការប្រព្រឹត្តិ របស់បុគ្គលអ្នកមិនប្រសើរ គឺ អ្នកអាក្រក់ ម្យ៉ាងទៀត បានដល់ ការប្រព្រឹត្តិមិនប្រសើរ គឺ លាមក គឺ អាក្រក់ អធិប្បាយថា មេថុន ។ ព្រះអដ្ឋកថាចារ្យ ពោលមេថុនវិរតិ ដោយពាក្យថា 'អាចារៈ ដ៏ប្រសើរ គឺ ដ៏ខ្ពង់ខ្ពស់ " ។

(១៤០) សេចក្ដីត្រេកអរ ដោយភរិយារបស់ខ្លួន ឈ្មោះថា ព្រហ្មចរិយៈ ក្នុងមហាធម្មបាលជាតក ក្នុងទសកនិបាត[(១)] ថា ÷

" យើងទាំងឡាយ មិនប្រព្រឹត្តកន្លងចិត្តភរិយាទេ,
ទាំងពួកភរិយា ក៏មិនប្រព្រឹត្តកន្លងចិត្តពួកយើងដែរ,
ពួកយើង ប្រព្រឹត្តនូវព្រហ្មចរិយធម៌ លើកលែងតែ
ភរិយាទាំងនោះចេញ, ព្រោះហេតុនោះឯង ទើប
ពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើង
មិនស្លាប់ " ។

១ – ត្រៃបិដក ភាគទី ៥៩ / ទំព័រទី ១៨៨ ។

(១៤១) អដ្ឋកថាមហាធម្មបាលជាតកនោះ ថា “បណ្ដាបទទាំងនោះ បទថា ‘នាតិក្កមាម’ មានសេចក្ដីថា យើងទាំងឡាយមិនកន្លងចិត្តកិរិយារបស់ខ្លួន ធ្វើមិច្ឆាចារ ឰដ៏ខាងក្រៅ ៗ ២ បទថា ‘អញ្ញត្រ តាហិ’ មានសេចក្ដីថា យើងទាំងឡាយ ប្រព្រឹត្តព្រហ្មចរិយៈ ក្នុងពួកស្ត្រីដែលសេសសល់ លើកលែងតែពួកភរិយារបស់ខ្លួនទាំងនោះ, ឯភរិយាទាំងឡាយ របស់ពួកយើង ក៏ប្រព្រឹត្តយ៉ាងដូច្នោះដែរ ក្នុងពួកបុរសដែលសេសសល់ ៗ ហិ អក្សរ ក្នុងពាក្យថា ‘តស្មា ហិ អម្ហំ’នេះ គ្រាន់តែជានិបាត ៗ មានសេចក្ដីថា ព្រោះហេតុនោះ យើងទាំងឡាយ ទើបមិនស្លាប់ (អំពី) ក្មេង ៗ គឺ ឈ្មោះថា សេចក្ដីស្លាប់ក្នុងកាលមិនសមគួរ រមែងមិនមានឡើយ (ដល់ពួកយើង)” ៗ

ដីកាមហាសីហនាទសូត្រ ថា “បទថា ‘នាតិក្កមាម’ មានសេចក្ដីថា យើងទាំងឡាយ មិនប្រព្រឹត្តកន្លងចិត្ត គឺ មិនកន្លងចិត្តក្នុងឋានៈដែលមិនគប្បីដល់ខ្លះ ក្នុងស្ត្រីដទៃៗខ្លះ ៗ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទើបត្រាស់ ថា ‘អញ្ញត្រ តាហិ” ដូច្នេះ ៗ

( វីរិយៈ ឈ្មោះថា ព្រហ្មចរិយៈ )

(១៤២) សេចក្ដីព្យាយាម ឈ្មោះថា ព្រហ្មចរិយៈ ក្នុង

លោមហំសសូត្រ ពោលគឺមហាសីហនាទសូត្រ ថា “ម្នាលសារីបុត្រ ក៏តថាគត ចាំបាន ថា ‘បានឮថា តថាគតប្រព្រឹត្តព្រហ្មចរិយៈដែលប្រកបដោយអង្គ ៤ ជាអ្នកមានព្យាយាមគ្រឿងដុតកំដៅបាប” ។

(១៤៣) អដ្ឋកថាលោមហំសសូត្រនោះ ថា “វីរិយៈ ព្រះដ៏មានព្រះភាគទ្រង់អធិប្បាយហើយ ថា ‘ព្រហ្មចរិយៈ’ ក្នុងពាក្យថា ‘**ព្រហ្មចរិយំ ចរិត្វា**’ នោះ ។ មែនពិត ព្រះសូត្រនេះឯងជាទីស្ថាន នៃព្រហ្មចរិយៈគឺវីរិយៈ មកហើយ ។ ព្រហ្មចរិយៈនេះនោះ ព្រះអង្គត្រាស់ ថា ‘ប្រកបដោយអង្គ ៤’ ព្រោះភាវៈនៃព្រហ្មចរិយៈ ៤ ប្រការ ដែលគេធ្វើបានដោយក្រ ព្រះអង្គទ្រង់បានធ្វើហើយ ក្នុងអត្តភាពនេះ ។ ពាក្យថា ‘**សុទំ**’ ក្នុងពាក្យថា ‘**តបស្សី សុទំ ហោមិ**’ គ្រាន់តែជានិបាត ។ អធិប្បាយថា ‘តថាគត រមែងជាអ្នកអាស្រ័យនូវតបៈ’ ដូច្នេះ” ។

ដីកាលោមហំសសូត្រនោះ ថា “អធិប្បាយថា សូត្រនេះឯងជាអាគតស្ថាន ។ មានសេចក្ដីថា ‘ក្នុងព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក សុត្តបទនេះឯង ជាទីស្ថាន នៃព្រហ្មចរិយៈ គឺវីរិយៈ មកហើយ’ ។ មែនពិត វីរិយៈ ជាគុណជាតដ៏ឧត្ដម ក្នុងអារម្មណ៍នោះ គឺ ដល់នូវកិរិយាឧក្រិដ្ឋ យ៉ាងក្រៃលែង និងជាហេតុនៃការប្រព្រឹត្តិ យ៉ាងដូច្នោះ ព្រោះហេតុនោះ វីរិយៈ ព្រះអដ្ឋកថាចារ្យ

ទើបពោលហើយ ក្នុងព្រះសូត្រនេះ ថា 'ព្រហ្មចរិយៈ' ។ បទថា 'ចតុរង្គសមន្នាគតំ' មានសេចក្ដីថា ប្រកបដោយអង្គ ៤ យ៉ាង ដោយអំណាចអាការៈនៃការប្រព្រឹត្តិទៅរបស់ខ្លួន ៤ ប្រការ ដែលញ៉ាំងកិរិយាធ្វើបានដោយលំបាក ៤ យ៉ាង ឲ្យបានសម្រេច " ។

ក៏កិរិយាធ្វើបានដោយលំបាក ៤ យ៉ាង អ្នកសិក្សាគប្បីត្រួតពិនិត្យមើល ក្នុងមហាសីហនាទសូត្រ ។

( ឧបោសថ ឈ្មោះថា ព្រហ្មចរិយៈ)

(១៨៤) ឧបោសថ ប្រកបដោយអង្គ ៨ ដែលបុគ្គលធ្វើហើយ ដោយអំណាចការទូន្មានខ្លួន ឈ្មោះថា ព្រហ្មចរិយៈ ក្នុងនិមិជាតក[១] ថា ÷

" បុគ្គលកើត ក្នុងត្រកូលក្សត្រ ដោយព្រហ្មចរិយៈ
ថ្នាក់ថោកទាប, ដល់នូវភាពជាទេវតា ដោយ
ព្រហ្មចរិយៈ ថ្នាក់កណ្ដាល, រមែងបរិសុទ្ធស្អាត
ដោយព្រហ្មចរិយៈ ថ្នាក់ខ្ពង់ខ្ពស់ " ។

(១៨៥) អដ្ឋកថានិមិជាតកនោះ ថា " បណ្ដាព្រហ្មចរិយៈ ៣ យ៉ាងនោះ សីល ត្រឹមតែមេថុនវិរតិ ក្នុងលទ្ធិ របស់តិរ្ថិយភាគច្រើន ឈ្មោះថា ព្រហ្មចរិយៈថ្នាក់ថោកទាប, បុគ្គលរមែង

---

១ _ ត្រៃបិដក ភាគទី ៦២ / ទំព័រទី ៦៩ ។

កើតក្នុងត្រកូលក្សត្រ ដោយព្រហ្មចរិយៈថោកទាបនោះ ។ សីល គ្រាន់តែឧបចារៈ នៃឈាន ឈ្មោះថា ព្រហ្មចរិយៈថ្នាក់កណ្ដាល, បុគ្គលរមែងចូលដល់ភាពជាទេវតា ដោយព្រហ្មចរិយៈថ្នាក់កណ្ដាលនោះ ។ ឯសីល ដែលញ៉ាំងសមាបត្តិ ៨ ឲ្យកើតឡើង ឈ្មោះថា ព្រហ្មចរិយៈដ៏ខ្ពង់ខ្ពស់, បុគ្គលរមែងកើត ក្នុងព្រហ្មលោក ដោយព្រហ្មចរិយៈថ្នាក់ខ្ពង់ខ្ពស់នោះ ។ បុគ្គលខាងក្រៅ (ព្រះពុទ្ធ-សាសនា) រមែងពោលនូវការកើតឡើង ក្នុងព្រហ្មលោកនោះ ថា 'ព្រះនិព្វាន' ។ ដោយហេតុនោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ត្រាស់ថា 'វិសុជ្ឈតិ' ។ ចំណែកក្នុងសាសនានេះ ព្រហ្មចរិយៈរបស់ភិក្ខុអ្នកមានសីលបរិសុទ្ធ ប្រាថ្នាទេវនិកាយណាមួយ ឈ្មោះថា ថ្នាក់ថោកទាប ព្រោះមានចេតនាថោកទាប, ភិក្ខុរមែងកើត ក្នុងទេវលោក តាមដែលខ្លួនប្រាថ្នាហើយ ដោយព្រហ្មចរិយៈថោកទាបនោះ ។ ឯការញ៉ាំងសមាបត្តិ ៨ ឲ្យកើតឡើង របស់ភិក្ខុអ្នកមានសីលបរិសុទ្ធ ឈ្មោះថា ព្រហ្មចរិយៈថ្នាក់កណ្ដាល, ភិក្ខុរមែងកើតក្នុងព្រហ្មលោក ដោយព្រហ្មចរិយៈថ្នាក់កណ្ដាលនោះ ។ កិរិយាចំរើនវិបស្សនា ហើយបានសម្រេចនូវព្រះអរហត្ត របស់ភិក្ខុអ្នកមានសីលបរិសុទ្ធ ឈ្មោះថា ព្រហ្មចរិយៈថ្នាក់ខ្ពង់ខ្ពស់, ភិក្ខុរមែងបរិសុទ្ធ ដោយព្រហ្មចរិយៈថ្នាក់ខ្ពង់ខ្ពស់នោះ" ។

ដីកាមហាសីហនាទសូត្រ ថា "បទថា 'អត្តទមនវសេន' មានសេចក្ដីថា ដោយអំណាចការទូន្មានខ្លួនដែលប្រព្រឹត្តទៅ ដោយអាការៈគឺធ្វើតាមព្រះអរហន្តទាំងឡាយ តាមការបេ្ដជ្ញា, អធិប្បាយថា 'ដោយការទូន្មាននូវឥន្រ្ទីយ៍ទាំងឡាយ មានចិត្តជាទី ៦" ។

## ( អរិយមគ្គ ឈ្មោះថា ព្រហ្មចរិយៈ )

(១៤៦) អរិយមគ្គ ឈ្មោះថា ព្រហ្មចរិយៈ ក្នុងព្រហ្មចរិយ-សូត្រ ក្នុងមហាវគ្គ សំយុត្តនិកាយ ថា "ម្នាលភិក្ខុទាំងឡាយ ក៏ព្រហ្មចរិយៈ តើដូចម្ដេច ?, មគ្គមានអង្គ ៨ ដ៏ប្រសើរនេះឯង, នេះ គឺអ្វីខ្លះ ? គឺ សម្មាទិដ្ឋិជាដើម" ។

ព្រះដីកាចារ្យពោលហើយ ក្នុងដីកាមហាសីហនាទសូត្រ ថា "អរិយមគ្គ ឈ្មោះថា ព្រហ្មចរិយៈ ព្រោះប្រព្រឹត្តប្រសើរ ដល់នូវភាវៈដែលត្រូវសិក្សា" ។

## ( សាសនា ឈ្មោះថា ព្រហ្មចរិយៈ )

(១៤៧) សាសនា ឈ្មោះថា ព្រហ្មចរិយៈ ក្នុងមហាបរិ-និព្វានសូត្រ ថា "ម្នាលមារចិត្តបាប តថាគត នឹងមិនបរិនិព្វាន ដរាបណាដែលព្រហ្មចរិយៈនេះ របស់តថាគត នៅមិនទាន់បាន

សម្រេច ទូលំទូលាយ ផ្សព្វផ្សាយទៅ ជនភាគច្រើនបានដឹង ជាបែបផែន (និង) ដរាបណាដែលទេវតានិងមនុស្សទាំងឡាយប្រកាសល្អហើយ ” ។

(១៤៨) អដ្ឋកថាមហាបរិនិព្វានសូត្រនោះ និង អដ្ឋកថាទុតិយបណ្ណាសកៈ ក្នុងអដ្ឋកនិបាត អង្គុត្តរនិកាយ ថា “ព្រហ្មចរិយៈដែលជាសាសនាទាំងមូល សង្គ្រោះដោយត្រ័យសិក្ខា ឈ្មោះថាព្រហ្មចរិយៈ ។ បទថា ‘ឥទ្ធំ’ បានដល់ សម្រេច ដោយអំណាចការពេញចិត្ត ក្នុងឈាន ។ បទថា ‘ផីតំ’ បានដល់ ដល់នូវការចំរើន ដូចជាផ្កាឈើដែលរីកចាយស្គុសស្គាយ ពាសពេញ ដោយអំណាចការដល់ព្រមនៃអភិញ្ញា ។ បទថា ‘វិត្ថារិកំ’ បានដល់ផ្សព្វផ្សាយទៅ ដោយអំណាចប្រតិស្ឋានទុក ក្នុងទិសាភាគនោះៗ ។ បទថា ‘ពហុជញ្ញំ’ មានសេចក្តីថា ដែលជនភាគច្រើនបានដឹងគឺ ចាក់ធ្លុះហើយ ដោយអំណាចការត្រាស់ដឹង នៃមហាជន ។ បទថា ‘បុថុភូតំ’ មានសេចក្តីថា ដល់នូវភាពជាបែបផែនដោយអំណាចអាការៈទាំងពួង ។ សួរថា ‘ខនោះ តើដូចម្តេច ?’ ។ ឆ្លើយថា ‘ដរាបវេលាដែលព្រហ្មចរិយៈ គឺ ទេវតានិងមនុស្សទាំងឡាយ ប្រកាសល្អហើយ’ ។ អធិប្បាយថា ‘ដែលពួកទេវតា និងមនុស្សទាំងឡាយ ជាអ្នកមានជាតិជាអ្នកចេះដឹង គ្រប់គ្នាទាំងអស់

ប្រកាសហើយ ដោយប្រពៃ" ។

(១៤៩) ដីកាមហាបរិនិព្វានសូត្រ និងទុតិយបណ្ណាសកៈ នោះថា "បទថា 'សិក្ខាត្តយសង្គហិតំ' មានសេចក្តីថា សង្គ្រោះដោយត្រ័យសិក្ខា មានអធិសីលសិក្ខាជាដើម ។ ការប្រព្រឹត្តដ៏ប្រសើរ ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា មិនសេសសល់ ឈ្មោះថា ព្រហ្មចរិយៈ ដែលជាសាសនាទាំងអស់ ។ បទថា 'សមិទ្ធំ' បានដល់ ចំរើនហើយ ដោយប្រពៃពិត ។ បទថា 'ឈានស្សាទវសេន' មានសេចក្តីថា ដោយអំណាចនៃសេចក្តីសុខក្នុងឈាន ដែលពួកភិក្ខុនោះ ៗ បានសម្រេចហើយ ។ បទថា 'វុឌ្ឍិប្បត្តំ' មានសេចក្តីថា ដែលដល់នូវការចំរើនដោយជុំវិញ ឈ្មោះថា ដោយប្រការទាំងពួង ដូចផ្កាឈើដែលរីកចាយពាសពេញ ព្រោះចូលដល់ភាវៈប្រសើរលើសលប់ និងប្រណិត ឈ្មោះថា ដោយអំណាចនៃអភិញ្ញានិងសមាបត្តិ ព្រោះសេចក្តីចំរើនរុងរឿងនៃសាសនាបានដល់ទីបំផុត ដោយការដល់ព្រមនៃអភិញ្ញា ។ បទថា 'បតិដ្ឋិតវសេន' មានសេចក្តីថា ដោយអំណាចប្រតិស្ឋាន, អធិប្បាយថា ព្រោះដល់នូវការតាំងនៅស៊ប់ ។ ឈ្មោះថា ពហុជញ្ញំ ព្រោះជាប្រយោជន៍សុខ ដល់ជនច្រើន ដោយអំណាចការចាក់ធ្លុះ ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា 'ពហូហិ . . .

... ជនាភិសមយវសេន ' ដូច្នេះ ។ ឈ្មោះថា បុថុភូតំ ព្រោះជាបែបផែន គឺ ទូលំទូលាយ មានហើយ គឺ កើតហើយ, មួយទៀតព្រោះដល់ហើយ គឺ សម្រេចហើយ នូវភាពជាបែបផែន គឺនូវភាពទូលំទូលាយ ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា 'សព្វា... ការប្បត្តិ ' ដូច្នេះ ។ បទថា 'សុដ្ឋុ បកាសិតំ' មានសេចក្តីថា ប្រកាសហើយ ដោយភាពជាធម៌ល្អ ក្នុងខាងដើមជាដើម ដោយប្រពៃពិត " ។

ព្រហ្មចរិយៈមាន ១០ យ៉ាង ដោយន័យដែលមកហើយ ក្នុងអដ្ឋកថាសាមញ្ញផលសូត្រ និងឥតិវុត្តកៈ ដោយប្រការដូច្នេះ ។

## ( ព្រហ្មចរិយៈ ១២ យ៉ាង )

(១៥០) ចំណែកក្នុងអដ្ឋកថាមហាសីហនាទសូត្រ ព្រះអដ្ឋកថាចារ្យ ពោលព្រហ្មចរិយៈ ១២ យ៉ាង ព្រោះបន្ថែមនូវធម្មទេសនា និងអធ្យាស្រ័យ ។

## ( ធម្មទេសនា ឈ្មោះថា ព្រហ្មចរិយៈ )

ក៏ធម្មទេសនា ឈ្មោះថា ព្រហ្មចរិយៈ ក្នុង ២ បទនេះថា

"ជន ១ ពាន់នាក់ លះមច្ចុបាន ព្រោះព្រហ្មចរិយៈ ជាមួយគ្នា " ។

ដីកាមហាសីហនាទសូត្រ ថា " បណ្ដាបទទាំងនោះបទ ថា ' ព្រហ្ម-
ចរិយស្មឹ ' បានដល់ ព្រោះធម្មទេសនា ។ មែនពិត ធម្មទេសនា
នោះ ហៅថា ព្រហ្មចរិយៈ ព្រោះជាចរិយា ឈ្មោះថា ប្រសើរ គឺ
ខ្ពង់ខ្ពស់ ព្រោះនាំនូវភារៈជាអ្នកប្រសើរមកឲ្យ ដល់វេនេយ្យសត្វ
ទាំងឡាយ, ម្យ៉ាងទៀត ជាចរិយាដែលប្រព្រឹត្តទៅ តាមផ្លូវវាចា
របស់ព្រហ្ម គឺ ព្រះដ៏មានព្រះភាគ ។ បាទគាថា ថា ' សហស្សំ
មច្ចុហាយិនោ ' មានសេចក្ដីថា ជនចំនួន ១ ពាន់នាក់ ឈ្មោះថា
ជាអ្នកលះមច្ចុរាជបាន ព្រោះកន្លងនូវវិស័យនៃមច្ចុ ដោយការ
បានសម្រេចព្រះអរហត្ត " ។

( អធ្យាស្រ័យ ឈ្មោះថា ព្រហ្មចរិយៈ )

(១៥១) អធ្យាស្រ័យ ឈ្មោះថា ព្រហ្មចរិយៈ ក្នុងគាថានេះ[(១)] ថា
" អើក៏ សេចក្ដីប្រាថ្នានូវផល តែងសម្រេចព្រម ដល់
ពួកជនអ្នកមិនរួសរាន់ដោយពិត, អាត្មាអញជាអ្នក
មានព្រហ្មចារ្យចាស់ក្លាហើយ, ម្នាលគាមណិ អ្នក
ចូរដឹង យ៉ាងដូច្នេះចុះ " ។

ដីកាមហាសីហនាទសូត្រ ថា " បណ្ដាបទទាំងនោះ បទថា
' អតរមានានំ ' មានសេចក្ដីថា មិនប្រញាប់ប្រញាល់ គឺ រង់ចាំ

---

១- ត្រៃបិដក ភាគទី ៥៨ / ទំព័រទី ៤ ។

មើលនូវកាលនៃព្រះធម្មទេសនា ។ បាទគាថាថា 'ផលាសា វ សមិជ្ឈតិ' មានសេចក្តីថា សេចក្តីប្រាថ្នា សូម្បីនូវផលដែលបុគ្គលបានដោយលំបាក យ៉ាងក្រៃលែង អាស្រ័យនូវសេចក្តីព្យាយាមត្រូវរមែងសម្រេចបាន ដោយពិត ។ បាទគាថាថា 'វិបក្កព្រហ្មចរិយោស្មិ' មានសេចក្តីថា ជាអ្នកមានអធ្យាស្រ័យដ៏ប្រណិតដែលសម្រេចហើយ ដោយពិសេស គឺ មានមនោរថដ៏ប្រសើរខ្ពង់ខ្ពស់ ដែលពេញបរិបូណ៌ហើយ ៗ មែនពិត អធ្យាស្រ័យនោះព្រះរាជាកម្លោះព្រះនាមគាមណិ ទ្រង់ត្រាស់ហើយ ដោយវោហារថា ព្រហ្មចរិយៈ ព្រោះជាការប្រព្រឹត្តិ ខាងផ្លូវចិត្ត ដ៏ប្រសើរ" ។

(១៥២) បណ្តាធម្មទេសនា និងអធ្យាស្រ័យទាំងនោះ ព្រះធម្មទេសនា ព្រះអដ្ឋកថាចារ្យពោល ក្នុងអដ្ឋកថាសាមញ្ញផលសូត្រជាដើមថា 'ដោយសេចក្តី ធម្មទេសនា គឺ សាសនធម៌ ដែលសង្គ្រោះដោយត្រ័យសិក្ខា នឹងមានប្រយោជន៍អ្វី ដោយកិរិយាប្រកាន់យក នូវធម្មទេសនានោះ មួយផ្នែក ៗ" ។

មួយទៀត ពាក្យណា ដែលព្រះអដ្ឋកថាចារ្យពោលហើយថា 'អធ្យាស្រ័យ ឈ្មោះថា ព្រហ្មចរិយៈ' ដូច្នេះ, ពាក្យនោះ រមែងមិនសម នឹងអដ្ឋកថាគាមណិជាតក ក្នុងបឋមវគ្គ ឯកនិបាត ។

ក៏ក្នុងអដ្ឋកថាគាថាជាតកនោះ ព្រះអដ្ឋកថាចារ្យ ពោលថា

“ពាក្យថា ‘អបិ’ គ្រាន់តែជានិបាត ។ បទថា ‘អតរមានានំ’ មានសេចក្ដីថា អ្នកតាំងនៅហើយ ក្នុងឱវាទរបស់បណ្ឌិតទាំងឡាយ មិនប្រញាប់ប្រញាល់ គឺ មិនប្រព្រឹត្តរួសរាន់បានឡើយ ហើយធ្វើការងារ ដោយឧបាយ ។ បទថា ‘ផលាសាវ’ មានសេចក្ដីថា ផលដែលប្រាថ្នា គឺ ផលតាមដែលត្រូវការ រមែងបានសម្រេចតែម្ដង ។ ក្នុងពាក្យថា ‘វិបក្កព្រហ្មចរិយោស្មិ’ នេះ សង្គហវត្ថុ ៤ ឈ្មោះថា ព្រហ្មចរិយៈ ព្រោះជាកិរិយាប្រព្រឹត្តិយ៉ាងប្រសើរ ។ ក៏ព្រហ្មចរិយៈនោះ ឈ្មោះថា សម្រេចហើយ ព្រោះការដល់ព្រមដោយយស ដែលមានក្នុងសង្គហវត្ថុនោះជាមូល គឺ ព្រហ្មចារីបុគ្គលនោះ បានហើយ ។ មួយទៀត យសណា សម្រេចហើយ, សូម្បីយសនោះ ក៏ឈ្មោះថា ព្រហ្មចរិយៈ ព្រោះអត្ថថាប្រព្រឹត្តប្រសើរ” ។

(១៥៣) ក៏ក្នុងអតីតកាល ព្រះរាជកុមារ ព្រះនាមគាមណិ ទ្រង់ជាព្រះកនិដ្ឋភាតាពៅគេបង្អស់ នៃព្រះរាជបុត្រ ១០០ ព្រះអង្គ នៃព្រះរាជាក្រុងពារាណសី ទ្រង់អាស្រ័យព្រះពោធិសត្វ ជាអាចារ្យអ្នកឲ្យសិក្សានូវសិល្បសាស្ត្រហើយ ក៏បានគ្រងរាជសម្បត្តិ ដោយកាលកន្លងទៅ នៃព្រះវរបិតា ទ្រង់មានព្រះទ័យត្រេកអរហើយ ទ្រង់បានត្រាស់នូវគាថានោះ ដោយអំណាចនៃឧទាន ។

ព្រោះហេតុនោះ ព្រះអង្គទ្រង់សំដៅយកខ្លួនព្រះអង្គ ថា "គាមណិ" ទ្រង់ត្រាស់ ថា "នែគាមណិ ដ៏ចំរើន អ្នកចូរដឹងនូវហេតុនោះ យ៉ាងដូច្នេះ ថា 'អាត្មាអញ ជាអ្នកអាស្រ័យនូវអាចារ្យហើយ ទើបបានកន្លងព្រះភាគា ១០០ ព្រះអង្គ បានដល់ហើយនូវរាជសម្បត្តិយ៉ាងធំនេះ" ដូច្នេះ ។

## ( សមណធម៌ ឈ្មោះថា ព្រហ្មចរិយៈ )

(១៥៤) ចំណែកក្នុងអដ្ឋកថានេះ ព្រះអដ្ឋកថាចារ្យ ពោលសេចក្តីថា "សមណធម៌ ឈ្មោះថា ព្រហ្មចរិយៈ ក្នុងរថវិនីតសូត្រ ថា 'ព្រះធម្មសេនាបតី សារីបុត្រសួរ ថា 'ម្នាលអ្នកដ៏មានអាយុ អ្នកនៅប្រព្រឹត្តព្រហ្មចរិយៈ ក្នុងព្រះដ៏មានព្រះភាគ នៃយើងឬ ?'។ ព្រះបុណ្ណត្ថេរ ឆ្លើយថា 'ម្នាលលោកដ៏មានអាយុ យ៉ាងនោះឯង"។

អដ្ឋកថារថវិនីតសូត្រ ថា "បណ្តាបទទាំងនោះ ត្រើនបទថា 'ភគវតិ នោ' ជាដើម មានសេចក្តីថា ម្នាលអ្នកដ៏មានអាយុ អ្នកនៅប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់ នៃព្រះដ៏មានព្រះភាគ របស់យើងទាំងឡាយឬ ?"។

អដ្ឋកថាទុកនិបាត ក្នុងឥតិវុត្តកៈ ថា "បទថា 'វុស្សតិ' ប្រែថា គឺអ្នករមែងនៅ "។

ដីកាព្រហ្មចរិយសូត្រ ក្នុងតតិយវគ្គ បឋមបណ្ណាសកៈ ក្នុងចតុក្កនិបាត អង្គុត្តរនិកាយ ថា "បទថា 'វុស្សតិ' មានសេចក្តីថា វុសិយតិ (ព្រហ្មចរិយៈ គឺ អ្នករមែងនៅ) "។

វស ធាតុ ចុះក្នុងអត្ថថានៅអាស្រ័យ ឧទាហរណ៍ថា វសតិ, ភាវៈដែល អ ជា ឧ និងភាវៈដែលជា បុព្វរូប (ស ជា ស្ស ដោយវិធីវេយ្យាករណ៍ គឺ ស + យ = ស្ស) ចុះក្នុងកម្ម ។ សម្រេចរូបអាខ្យាត ថា 'វុស្សតិ' (គឺ អ្នករមែងនៅ)" ។

បណ្តាពាក្យសួរ និងពាក្យប្តេជ្ញាទាំងនោះ ពាក្យសួរ ជាពាក្យរបស់ព្រះធម្មសេនាបតី, ពាក្យប្តេជ្ញា ថា 'ម្នាលលោកដ៏មានអាយុ យ៉ាងនោះឯង 'ដូច្នេះ ជាពាក្យ របស់ព្រះបុណ្ណត្ថេរ ។

(១៥៥) ព្រហ្មចរិយៈមាន ១១ យ៉ាង ព្រោះកំណត់យកនូវសមណធម៌នេះផង និងព្រហ្មចរិយៈ ដែលព្រះអដ្ឋកថាចារ្យពោលហើយ ក្នុងអដ្ឋកថាសាមញ្ញផលសូត្រជាដើមផង យ៉ាងនេះឯង ។

## ( សង្គ្រោះព្រហ្មចរិយៈចូលក្នុងមង្គល )

ក៏បណ្តាព្រហ្មចរិយៈទាំងនោះ ទាន មកហើយ ដោយសរុបពួដ៏ខាងក្រោយ ។ វេយ្យាវច្ចៈ និងអង្គនៃឧបោសថ ជារបស់ដែលព្រះដ៏មានព្រះភាគ ទ្រង់សង្គ្រោះហើយ ដោយអនវជ្ជកម្ម ។

បញ្ចសីល និងសទារសន្តោស ព្រះអង្គទ្រង់សង្គ្រោះហើយ ដោយបាបវិរតិ និងមជ្ជសញ្ញមៈ ។ វីរិយៈ ទ្រង់សង្គ្រោះហើយ ដោយតបៈ ។ ចំណែកក្នុងអប្បមញ្ញា មេថុនវិរតិ អរិយមគ្គ សាសនានិងសមណធម៌ អប្បមញ្ញា គួរសង្គ្រោះ ដោយខន្តី ។ ព្រោះថា អទោសៈ ឈ្មោះថា ខន្តី, មួយទៀត មេត្តា ទ្រង់កំណត់យក ដោយអទោសៈ ។ អប្បមញ្ញាទាំង ៣ យ៉ាង ក្រៅអំពីនេះ ព្រះអង្គទ្រង់កំណត់ហើយ ដោយមេត្តានោះ ដែលព្រះអង្គទ្រង់កំណត់ហើយ ។ អរិយមគ្គ រមែងមិនបាន ក្នុងមង្គលថា 'ព្រហ្មចរិយំ' នេះ ឡើយ ព្រោះទ្រង់កំណត់យក ដោយអរិយសច្ចទស្សនៈ ដែលនឹងទ្រង់ត្រាស់ខាងមុខ ។ ប្រៀបដូចជា សុរាបានៈ ព្រះអង្គមិនបានប្រកាន់យកក្នុងមង្គលថា '**អារតី វិរតី បាបា**' នេះ ព្រោះទ្រង់ប្រកាន់យកដោយមជ្ជបានៈ ខាងមុខ យ៉ាងណាមិញ, ពាក្យឧបមេយ្យនេះ ក៏គប្បីយល់ យ៉ាងដូច្នោះដែរ ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យទើបពោល ក្នុងអដ្ឋកថាថា 'ឈ្មោះថា ព្រហ្មចរិយៈ ជាឈ្មោះ នៃមេថុនវិរតិ សមណធម៌ សាសនា និងមគ្គ ។ តែព្រោះមគ្គទ្រង់កំណត់យក ខាងមុខ ដោយអរិយសច្ចទស្សនៈ ព្រហ្មចរិយៈ ដែលសេសសល់ទាំងអស់ ទើបគួរ ក្នុងមង្គលថា 'ព្រហ្មចរិយំ' នេះ' ។ បណ្តាមេថុនវិរតិជាដើមនោះ ប្រសិនបើព្រះអង្គទ្រង់ប្រកាន់យក

សាសនា ក្នុងមង្គល ថា " ព្រហ្មចរិយំ " នេះ, ក៏នឹងត្រូវទោស គឺការពោលជាន់លើគ្នាម្តងទៀត ។ ព្រោះថាសាសនា គឺព្រះបរិយត្តិ ព្រះអង្គទ្រង់កំណត់យកហើយ ដោយវាចាជាសុភាសិតនុ៎ះឯង ។ មែនពិត សូម្បីខាងដើម ព្រះអដ្ឋកថាចារ្យពោល ថា " វាចាជាគ្រឿងសំដែងធម៌ ដល់ពួកជនដ៏ទៃ បណ្ឌិតគប្បីជ្រាប ថា 'ជាវាចាសុភាសិត' ក្នុងមង្គល ថា 'សុភាសិតា ច យា វាចា ' នេះ" ។ ព្រោះហេតុនោះ និរោធសច្ចៈ ព្រះអង្គមិនទ្រង់កំណត់យក ក្នុងមង្គល ថា " និព្វានសច្ឆិកិរិយា " នេះ ពួដ៏ខាងក្រោយ ព្រោះទ្រង់កំណត់យក ក្នុងមង្គល ថា " អរិយសច្ចានទស្សនំ " នេះ យ៉ាងណាមិញ, បណ្ឌិតគប្បីជ្រាបពាក្យឧបមេយ្យនេះ ក៏យ៉ាងនោះដែរ ។

## ( ព្រហ្មចរិយៈ ជាមង្គល )

(១៥៦) ដោយបារិសេសន័យ រមែងបានព្រហ្មចរិយៈ គឺមេថុនវិរតិ និងសមណធម៌ តែប៉ុណ្ណោះ ដោយប្រការដូច្នេះឯង, ក៏ព្រហ្មចរិយៈនុ៎ះនោះ ឈ្មោះថា ជាមង្គល ព្រោះជាហេតុសម្រេចនូវគុណវិសេសមានប្រការផ្សេងៗ ខ្ពស់ៗ ឡើងទៅ ។

ក្នុងភាវៈនៃព្រហ្មចរិយៈ ជាមង្គលនោះ មានរឿងទាំងនេះ ( ជាឧទាហរណ៍ ) ÷

( រឿងជន ២ នាក់ )

បានឮថា ក្នុងក្រុងរាជគ្រឹះ បុត្ររបស់កបិលព្រាហ្មណ៍ ជាមាណព ឈ្មោះថា បិប្ផលិ អាយុ ២០ ឆ្នាំ ជាអ្នកមានបុណ្យច្រើន ។ គ្រានោះ មាតាបិតា ប្រាថ្នានឹងចងបុត្រនោះ ដោយគ្រឿងចង គឺផ្ទះ ទើបបានបញ្ជូនព្រាហ្មណ៍ ៨ នាក់ទៅ ដើម្បីនឹងឲ្យស្វែងរក នូវស្ត្រីដែលបរិបូណ៌ដោយលក្ខណៈ ។ ព្រាហ្មណ៍ទាំងនោះបានយកគ្រឿងបណ្ណាការទៅហើយ កាន់សាគលនគរ ។ ក៏ក្នុងនគរនោះ ស្ត្រីឈ្មោះនាងភទ្ទកាបិលានី ជាធីតា របស់ព្រាហ្មណ៍កោសិយគោត្រ មានអាយុ ១៦ ឆ្នាំ ទ្រង់រូបឆោមដ៏ប្រសើរ មានបុណ្យច្រើន ។ ព្រាហ្មណ៍ទាំងនោះ បានទៅក្នុងនគរនោះហើយ ប្រាប់រឿងរ៉ាវទាំងអស់ ដល់មាតាបិតា របស់នាង បានឲ្យគ្រឿងបណ្ណាការហើយ ទើបបញ្ជូនពត៌មានទៅ ដល់កបិលព្រាហ្មណ៍ ថា " ពួកយើងបាននាងទារិកាហើយ " ។ ឯមាណព បានឮដំណឹងនោះហើយ ជាអ្នកមិនត្រូវការឡើយ ទៅក្នុងទីស្ងាត់ សរសេរសំបុត្រ ថា " នាងភទ្ទាចូរបាននូវការគ្រប់គ្រងផ្ទះ ដែលសមគួរដល់ជាតិគោត្រនិងភោគៈរបស់ខ្លួនចុះ, ខ្ញុំនឹងបួស, នាងភទ្ទា កុំជាអ្នកមានសេចក្ដីក្ដៅក្រហាយស្ដាយក្រោយឡើយ " ។ ឯនាងភទ្ទា ក៏បានសរសេរសំបុត្រ ដោយន័យនោះដូចគ្នាដែរ ។ ជនទាំងឡាយ បានយក

សំបុត្រទាំង ២ ច្បាប់មកជួបគ្នា ត្រង់កណ្តាលផ្លូវ អានសំបុត្រទាំង ២ ច្បាប់ស្រេចហើយ ក៏ហែកចោល ក្នុងព្រៃនុ៎ះឯង បានសរសេរសំបុត្រប្រហែលគ្នា បានទៅហើយ ។ ការមកប្រជុំគ្នា បានមានហើយ ដល់ជនទាំង ២ នាក់នោះ ជាអ្នកមិនប្រាថ្នាឡើយ ដោយប្រការដូច្នេះ ។

ក្នុងថ្ងៃនោះឯង ឯជនទាំង ២ នាក់នោះ បរិភោគអាហារល្ងាចហើយ សូម្បីឡើងកាន់ទីដេកក៏មិនឡើង ដោយផ្លូវជាមួយគ្នាឡើយ ។ មាណព បានឡើងកាន់ទីដេក ដោយខាងស្តាំ ។ ចំណែកនាងភទ្ទា បានឡើងកាន់ទីដេក ដោយខាងឆ្វេង ។ ជនទាំង ២ នាក់នោះ បានដាក់នូវកម្រងផ្កា ២ ត្រង់កណ្តាលទីដេក ព្រោះភ័យខ្លាចនឹងប៉ះពាល់រាងកាយគ្នានឹងគ្នា មិនបានដេកលក់រហូតយាមទាំង ៣ ញាំងពេលវេលាឲ្យកន្លងផុតទៅ ។ ចំណែកពេលថ្ងៃ ក៏មិនមានត្រឹមការសើចរីករាយឡើយ ។ ជនទាំង ២ នាក់នោះ មិនបានជាប់ជំពាក់ដោយលោកាមិសឡើយ នៅគ្រប់គ្រងផ្ទះសម្បែង ដោយកាលកន្លងទៅនៃមាតាបិតា ជាអ្នកមានឆន្ទៈស្មើគ្នា ពោល ថា “ភពទាំង ៣ ប្រៀបឧបមាដូចជាខ្ទមស្លឹកដែលត្រូវភ្លើងឆេះសព្វហើយ, យើងទាំង ២ នាក់ នឹងបួស” ដូច្នេះហើយ ទើបឲ្យនាំយកសំពត់កាសាយៈទាំងឡាយ និងបាត្រដីទាំង

ឡាយ អំពីទីផ្សារមក កោរសក់ម្តងម្នាក់ហើយ ទើបបួស ដោយតាំងចិត្ត ថា "ព្រះអរហន្តទាំងឡាយណា មាននៅក្នុងលោក, បព្វជ្ជារបស់ពួកយើងទាំង ២ នាក់ ឧទ្ទិសនូវព្រះអរហន្តទាំងឡាយនោះ" ដូច្នេះហើយ ទើបប្រេកបាត្រ ក្នុងស្រោម ហើយស្ពាយលើស្មា ចុះអំពីប្រាសាទ គេចចេញទៅហើយ ។ បិប្ផលិដើរទៅខាងមុខ ឃើញផ្លូវបែកជាពីរ ហើយឈរនៅត្រង់ចុងនៃផ្លូវនោះ ពោល ថា "នែនាងភទ្ទា មហាជនអ្នកមានចិត្តគិតប្រទូស្ត ចំពោះយើងទាំង ២ នាក់ គិត ថា 'ជនទាំង ២ នាក់នេះ សូម្បីបួសហើយ ក៏មិនអាចនឹងនៅផ្សេងអំពីគ្នាបាន' ក៏គប្បីជាអ្នកញុំាងអបាយឲ្យចំរើនឡើង, បណ្តាផ្លូវទាំង ២ យ៉ាងនេះ ចូរនាងរើសយកផ្លូវមួយ, ខ្ញុំនឹងទៅ ដោយផ្លូវមួយ" ។ នាងភទ្ទា ពោល ថា "មែន លោកម្ចាស់ដ៏ចំរើន ធម្មតាមាតុគ្រាម ជាមន្ទិលរបស់បព្វជិតទាំងឡាយ, ជនទាំងឡាយនឹងឃើញទោស របស់ពួកយើងទាំង ២ នាក់ ថា 'ជនទាំង ២ នាក់នេះ សូម្បីបួសហើយ ក៏មិននៅផ្សេងពីគ្នាបាន' ដូច្នេះ, ពួកយើងនឹងនៅបែកអំពីគ្នា" ហើយធ្វើប្រទក្សិណ ៣ ជុំ ថ្វាយបង្គំ ក្នុងទីទាំង ៤ កន្លែង ដោយការតាំងចំពោះដោយអង្គ ៥ ហើយផ្គងនូវអញ្ជលី ពោល ថា "ការស្និទ្ធស្នាលដូចជាមិត្រ ដែលយើងទាំង ២ នាក់ បានធ្វើហើយ អស់រយៈពេលដ៏យូរ ប្រមាណ ១ សែនកប្ប

នឹងបែក ក្នុងថ្ងៃនេះ, លោកម្ចាស់ ឈ្មោះថា ជាអ្នកខាងស្ដាំ, ផ្លូវខាងស្ដាំសមគួរដល់លោកម្ចាស់, ពួកនាងខ្ញុំ ឈ្មោះថាជាមាតុគ្រាម ជាអ្នកខាងឆ្វេង, ផ្លូវខាងឆ្វេង រមែងសមគួរ ដល់ពួកនាងខ្ញុំ" ដូច្នេះហើយ ក៏ថ្វាយបង្គំ ចែកផ្លូវដើរទៅ ។ ក្នុងពេលដែលជនទាំង ២ នាក់នោះ បែកគ្នាជា ២ ផែនដីដ៏ធំនេះ បានកំរើកឮសូរ ញាប់ញ័រ ដូចជាពោល ថា "យើងមិនអាច ដើម្បីនឹងទ្រទ្រង់នូវគុណ របស់ពួកអ្នកទាំង ២ បានឡើយ" ។ សំឡេងដូចជាកាំរន្ទះ ស្ទុះទៅឮដ៏អាកាស ។ ភ្នំចក្រវាល ក៏បន្លឺឡើង ។

ព្រះសាស្ដាទ្រង់គង់នៅ ក្នុងព្រះគន្ធកុដិ ក្នុងវត្តវេឡុវន ទ្រង់ព្រះសណ្ដាប់ នូវសំឡេងផែនដីកំរើក កាលទ្រង់ពិចារណា ទើបទ្រង់ជ្រាបនូវហេតុនោះ តែមួយព្រះអង្គឯង ទ្រង់ចាប់បាត្រនិងចីវរហើយធ្វើការទទួល អស់រយៈផ្លូវចម្ងាយ ៣ គាវុត ទ្រង់គង់នៅក្រោមដើមពហុបុត្តកនិគ្រោធ ក្នុងចន្លោះនៃក្រុងរាជគ្រឹះ និងក្រុងនាឡន្ទាជាប់គ្នា ។ ចំណែកបិប្ផលិ ទៅតាមផ្លូវមួយ បានឃើញព្រះសាស្ដាទ្រង់គង់ ក្រោមដើមជ្រៃនោះ ថ្វាយបង្គំដោយគោរព ហើយទើបអង្គុយ ត្រូវព្រះសាស្ដាទ្រង់ប្រទានឱវាទ ដោយព្រះឱវាទ ៣ យ៉ាង ដោយន័យដែលព្រះធម្មសង្គាហកាចារ្យ ពោលហើយ ក្នុងកស្សបសំយុត្ត ក្នុងនិទានវគ្គ បានឧបសម្បទហើយ នៅជាបុថុជ្ជន

បាន ៧ ថ្ងៃ ក៏បានសម្រេចព្រះអរហត្ត ក្នុងថ្ងៃទី ៨ ។ ចំណែកនាងភទ្ទា បានទៅកាន់សំណាក់នាងភិក្ខុនី ហើយក៏បានសម្រេចនូវព្រះអរហត្ត ក្នុងកាលជាខាងក្រោយ ។

ជនទាំង ២ នាក់នេះ ប្រព្រឹត្តព្រហ្មចរិយៈ គឺមេថុនវិរតិ បានសម្រេចនូវព្រះអរហត្ត ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ មេថុនវិរតិនោះ របស់ជនទាំង ២ នាក់នោះ ទើបបានឈ្មោះថា ជាមង្គល ។ សេចក្ដីសង្ខេប ក្នុងមង្គលត្ថទីបនីនេះ តែប៉ុណ្ណោះ ។ ឯសេចក្ដីពិស្តារ គប្បីត្រួតមើល ក្នុងអដ្ឋកថាកស្សបសំយុត្ត ជាដើម ។

រឿងជន ២ នាក់ ចប់ ។

## ( រឿងភិក្ខុ ៦០ រូប )

(១៥៧) បានឮថា ភិក្ខុប្រមាណ ៦០ រូប រៀនកម្មដ្ឋានក្នុងសំណាក់នៃព្រះសាស្ដា កាលស្វែងរកទីនៅអាស្រ័យ បានចូលទៅកាន់ស្រុកឈ្មោះមាតិកៈ ដើម្បីបិណ្ឌបាត ក្បែរជើងភ្នំ ក្នុងទីក្រុងកោសល ។ ក៏អ្នកម្ចាស់ស្រុកនោះ ឈ្មោះថា មាតិកៈ ។ មាតារបស់ម្ចាស់ស្រុកនោះ ប្រាកដឈ្មោះថា មាតិកមាតា ។ មាតិកមាតានោះ ឃើញពួកភិក្ខុទាំងនោះហើយ ក៏មានចិត្តជ្រះថ្លា ថ្វាយបង្គាន់ហើយ ទើបសួរថា “ព្រះគុណម្ចាស់ទាំងឡាយ ប្រាថ្នានិមន្តទៅ

ក្នុងទីណា ? ”។ ភិក្ខុទាំងនោះ ពោល ថា “ នែឧបាសិកា អាត្មាភាពទាំងឡាយ ប្រាថ្នានឹងទៅកាន់ទីដែលសប្បាយ ”។ មាតិកមាតា នោះ ពោល ថា “ បើព្រះគុណម្ចាស់ទាំងឡាយ នឹងនៅ ក្នុងទីនេះ អស់រយៈពេល ៣ ខែ, នាងខ្ញុំនឹងទទួលនូវព្រះត្រៃសរណៈ និងសីល ៥ ហើយ ធ្វើឧបោសថកម្ម ”ដូច្នេះ, កាលបើភិក្ខុទាំងនោះ ទទួល, ទើបបានចាត់ចែងទីនៅអាស្រ័យ ថ្វាយហើយ ។ ភិក្ខុទាំងនោះ កាលនៅក្នុងទីនោះ មិនអង្គុយរួមជាមួយគ្នាទេ អង្គុយធ្វើការស្វាធ្យាយ នូវអាការៈ ៣២ ប្រការ កំណត់នូវកិរិយាអស់ទៅសូន្យទៅ ក្នុងអត្តភាព ក្នុងទីស្ថានរៀងៗខ្លួន ។

ក្រោយមកថ្ងៃមួយ នាងមាតិកមាតា បានឲ្យបុគ្គលយកនូវទឹកដោះរាវថ្លានិងទឹកអំពៅជាដើម ទៅវិហារ ក្នុងវេលាល្ងាច មិនឃើញភិក្ខុទាំងឡាយ ទើបបានសួរពួកបុរស ថា “ តើព្រះគុណម្ចាស់ទាំងឡាយ នៅក្នុងទីណាហ្ន៎ ? ”។ ពួកបុរស បានប្រាប់ ថា “ អ្នកម៉ែ ព្រះគុណម្ចាស់ទាំងឡាយ នឹងគង់នៅ ក្នុងទីកន្លែងរបស់ខ្លួនៗ ”។ នាងមាតិកមាតា សួរ ថា “ តើនាងខ្ញុំ ធ្វើដូចម្ដេចទៅហ្ន៎ នឹងអាចជួបបាន ? ”។ គ្រានោះ ពួកមនុស្សអ្នកដឹងនូវកតិកាវត្ត របស់ភិក្ខុទាំងឡាយ ទើបបានប្រាប់មាតិកមាតានោះ ថា “ នែអ្នកម៉ែ កាលបើគេវាយរគាំង, ព្រះគុណម្ចាស់ទាំងឡាយ

នឹងប្រជុំគ្នា ”។ នាងបានឲ្យគេវាយរគាំងហើយ ។ ពួកភិក្ខុបានឮសំឡេងរគាំងនោះហើយ ក៏គិត ថា “ការមិនសប្បាយ នឹងមានដល់ភិក្ខុណាមួយ ” ហើយចេញពីកន្លែងរបស់ខ្លួនៗ បានមកប្រជុំគ្នានៅកណ្តាលវិហារ ។ ជន (គឺភិក្ខុ) សូម្បី ២ រូប ឈ្មោះថាមកដោយផ្លូវជាមួយគ្នា មិនមានឡើយ ។ នាងមាតិកមាតានោះ បានឃើញភិក្ខុទាំងនោះហើយ គិត ថា “ការឈ្លោះប្រកែកគ្នានឹងគ្នា នឹងពិតជាភិក្ខុទាំងនេះ បានធ្វើហើយ ” ទើបសួរ ។ ភិក្ខុទាំងនោះពោលថា “អាត្មាភាពទាំងឡាយ មិនបានធ្វើការឈ្លោះគ្នាទេ, ប៉ុន្តែអាត្មាភាពទាំងឡាយ អង្គុយធ្វើសមណធម៌ ក្នុងកន្លែងរបស់ខ្លួនៗ”។ នាងមាតិកមាតា សួរថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ឈ្មោះថាសមណធម៌នេះ គឺជាអ្វី ?”។ ភិក្ខុទាំងនោះ ប្រាប់ ថា “គឺការស្វាធ្យាយនូវអាការៈ ៣២ ប្រការ និងកំណត់នូវការអស់ទៅសូន្យទៅ ក្នុងអត្តភាព ”។ នាងមាតិកមាតា សួរថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន សមណធម៌នេះ រមែងសមគួរដល់ព្រះគុណម្ចាស់ទាំងឡាយ តែប៉ុណ្ណោះទេឬ ? ឬក៏សមគួរ ដល់ពួកនាងខ្ញុំដែរ ? ”។ ភិក្ខុទាំងនោះប្រាប់ ថា “នែឧបាសិកា សមណធម៌នេះ ព្រះពុទ្ធ ទ្រង់មិនហាម ដល់អ្នកណាមួយឡើយ ”។ នាងមាតិកមាតា ពោល ថា “បពិត្រព្រះគុណម្ចាស់ បើដូច្នោះ សូមព្រះគុណម្ចាស់ទាំងឡាយ

ប្រាប់នូវសមណធម៌នោះ" ។ ភិក្ខុទាំងនោះ ញ៉ាំងនាងមាតិកមាតានោះឲ្យរៀនហើយ ។ នាងធ្វើសមណធម៌ តាំងពីពេលនោះមក ក៏បានសម្រេចផលទាំង ៣ ខាងក្រោម មុនពួកភិក្ខុទាំងនោះតែម្តង ។ បដិសម្ភិទា និងអភិញ្ញា ដែលជាលោកិយៈ មកហើយ ដល់នាង ដោយមគ្គតែម្តង ។ នាងបានចេញពីសេចក្តីសុខ ដែលកើតពីមគ្គនិងផល កាលពិចារណា ដោយទិព្វចក្ខុ ក៏ឃើញថាពួកភិក្ខុទាំងនោះនៅជាបុថុជ្ជន ក៏ពិចារណា ថា "អ្វីទៅ ដែលមិនជាទីសប្បាយ ដល់ភិក្ខុទាំងនោះ ?" ដូច្នេះហើយ ទើបឃើញថា មិនមានអាហារដែលជាទីសប្បាយ បានចាត់ចែងនូវអាហារជាទីសប្បាយ ប្រគេនដល់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះ កើតមានចិត្តមានអារម្មណ៍តែមួយ ព្រោះបានអាហារជាទីសប្បាយ ។ ភិក្ខុទាំងនោះមានចិត្តមានអារម្មណ៍តែមួយ ចំរើនវិបស្សនា ក៏បានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទា ។ ភិក្ខុទាំងនោះ ប្រព្រឹត្តព្រហ្មចរិយៈគឺសមណធម៌ សម្រេចមគ្គនិងផល យ៉ាងនេះឯង ។ ព្រោះហេតុនោះ សមណធម៌នោះ របស់ភិក្ខុទាំងនោះ ឈ្មោះថា ជាមង្គល ។

រឿងភិក្ខុ ៦០ រូប មកក្នុងអដ្ឋកថាគាថា ថា "ទុន្និគ្គហស្ស លហុនោ..." ដូច្នេះ ជាដើម ក្នុងចិត្តវគ្គ នៃធម្មបទ ។

ពណ៌នាអំពីព្រហ្មចរិយៈ ។

## ពណ៌នាអំពីការឃើញអរិយសច្ច

(១៥៨) ឈ្មោះថា អរិយសច្ច ខ្ញុំនឹងពណ៌នា ដូចតទៅ ៖ បទទាំង ៤ មានទុក្ខជាដើម ឈ្មោះថា សច្ចៈ ព្រោះជាធម្មជាតពិតប្រាកដ ៗ សមដូចជាព្រះដ៏មានព្រះភាគ ត្រាស់ហើយ ក្នុងទុតិយវគ្គ នៃសច្ចសំយុត្ត[១] ក្នុងមហាវគ្គ ថា " ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៤ យ៉ាងនេះ ជារបស់ពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ៗ ធម្មជាត ៤ យ៉ាងនេះ គឺអ្វីខ្លះ ? ៗ ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៤ យ៉ាងនេះ គឺ ពាក្យថា 'នេះជាទុក្ខ' នុ៎ះ ជាធម្មជាតពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ, ពាក្យថា 'នេះជាហេតុជាទីកើតឡើងនៃទុក្ខ' នុ៎ះ ជាធម្មជាតពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ, ពាក្យថា 'នេះជាសេចក្ដីរំលត់ទុក្ខ' នុ៎ះ ជាធម្មជាតពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ, ពាក្យថា 'នេះ ជាបដិបទាជាដំណើរទៅកាន់ទីរំលត់ទុក្ខ' នុ៎ះ ជាធម្មជាតពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ " ៗ

បាលីតថសូត្រ ចប់ ៗ

(១៥៩) អដ្ឋកថាតថសូត្រនោះ ថា " ទុក្ខ ឈ្មោះថា ជា

១– ត្រៃបិដក ភាគទី ៣៩ ⁄ ទំព័រទី ២៣៩ ។

ធម្មជាតពិត ព្រោះអត្ថថា មិនលះនូវសភាព ។ ព្រោះថាទុក្ខ ក៏នៅជាទុក្ខនុ៎ះឯង ។ ឈ្មោះថា ជាធម្មជាតមិនប្រែប្រួល ព្រោះភាវៈនៃសភាពដែលបានពោលហើយ ជាធម្មជាតមិនទទេ ។ ព្រោះ ទុក្ខនឹងក្លាយទៅជាធម្មជាតមិនមែនទុក្ខ មិនបានឡើយ ។ ឈ្មោះថា ជាធម្មជាតមិនក្លាយទៅជារបស់ដទៃ ព្រោះមិនចូលដល់ភាពជារបស់ដទៃ ។ មែនពិត ទុក្ខ រមែងមិនចូលដល់នូវសភាព នៃបទទាំងឡាយមានសមុទ័យជាដើម ។ សូម្បីក្នុងសច្ចៈទាំងឡាយ មានសមុទយសច្ចជាដើម ក៏ន័យនេះ ដូចគ្នាដែរ " ។

ដីកាគថសូត្រនោះ ថា " បទថា 'សភាវាវិជហនត្ថេន' មានសេចក្ដីថា ទុក្ខ ឈ្មោះថា ជាធម្មជាតពិត គឺមានភាវៈជារបស់ពិតជាសភាព ព្រោះក្នុងកាលណា ៗ ក៏មិនលះបង់នូវសភាពជាទុក្ខរបស់ខ្លួន ។ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា 'ទុក្ខញ្ហិ ទុក្ខមេវ' ។ បទថា 'វុត្តសភាវស្ស' បានដល់សភាពគឺទុក្ខភាពដែលពោលហើយ ។ បទថា 'អមោឃតាយ' គឺ ព្រោះភាវៈនៃទុក្ខនោះ ជាធម្មជាតមិនបោកបញ្ឆោត ។ បទថា 'អវិតថំ' គឺ ជាធម្មជាតពិត ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោល ថា 'ន ហិ ទុក្ខំ អទុក្ខំ នាម ហោតិ' ។ បទថា 'អញ្ញសភាវានុបគមនេន' គឺ ព្រោះមិនចូលដល់សភាព

មានសមុទ័យជាដើម ៗ បទថា ' អនញ្ញថំ ' គឺ មិនក្លាយទៅជារបស់ដទៃ ៗ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា ' ន ហោតិ ' ដូច្នេះជាដើម " ៗ

(១៦០) សច្ចៈទាំងឡាយ របស់ព្រះអរិយៈទាំងឡាយ ព្រោះហេតុនោះ ទើបឈ្មោះថា អរិយសច្ច ៗ សមដូចជាព្រះ មានព្រះភាគទ្រង់ត្រាស់ ក្នុងតតិយវគ្គ នៃសច្ចសំយុត្តនោះឯង ថា " ម្នាលភិក្ខុទាំងឡាយ អរិយសច្ចទាំង ៤ នេះឯង ជាធម្មជាតពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ, ព្រោះហេតុនោះ សច្ចៈទាំង ៤ នេះ បណ្ឌិតហៅថា " **សច្ចៈ របស់ព្រះអរិយៈទាំងឡាយ** " ៗ

បាលីកថាសូត្រ ចប់ ៗ

(១៦១) អដ្ឋកថាកថាសូត្រនោះ ថា " ច្រើនបទថា ' **តស្មា អរិយានំ សច្ចានិ** ' មានសេចក្ដីថា ព្រោះសច្ចៈទាំងឡាយជាធម្មជាតពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃ ហេតុនោះ ទើបបណ្ឌិតហៅថា ' **អរិយានំ សច្ចានិ** ' ដូច្នេះ ៗ ព្រោះថា អរិយសច្ចទាំងឡាយ រមែងចាក់ធ្លុះនូវបទទាំងឡាយ ដែលប្រែប្រួល ដោយភាវៈជាអរិយសច្ច ក៏មិនមែនទេ " ៗ

ដីកាកថាសូត្រនោះ ថា " បទថា ' **អរិយានំ** ' បានដល់ ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម ៗ ដោយហេតុនោះ ទើប

ព្រះអដ្ឋកថាចារ្យ ពោល ថា 'ន ហិ' ដូច្នេះ ជាដើម"។

(១៦២) មួយទៀត សច្ចៈទាំងឡាយ របស់ព្រះដ៏មានព្រះភាគដែលជាព្រះអរិយៈ ហេតុនោះឯង ទើបឈ្មោះថា អរិយសច្ច ។ សមដូចជាព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ ក្នុងតតិយវគ្គ នៃសច្ចសំយុត្តនោះឯង ថា "ម្នាលភិក្ខុទាំងឡាយ អរិយសច្ចទាំង ៤ យ៉ាងនេះ ។ល។ អរិយសច្ច គឺបដិបទាជាដំណើរទៅកាន់ទីរំលត់ទុក្ខ, ម្នាលភិក្ខុទាំងឡាយ តថាគត ជាព្រះអរិយៈ ក្នុងមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ។ល។ ទាំងទេវតានិងមនុស្ស, ព្រោះហេតុនោះ សច្ចៈទាំង ៤ យ៉ាង បណ្ឌិតទើបហៅថា 'អរិយសច្ច' ។

បាលីលោកសូត្រ ចប់ ។

(១៦៣) អដ្ឋកថាលោកសូត្រនោះ ថា "ពាក្យថា '**តថាគតោ អរិយោ តស្មា អរិយសច្ចានិ**' មានសេចក្តីថា សច្ចៈទាំងនោះឈ្មោះថា ជារបស់ព្រះតថាគតជាព្រះអរិយៈ ព្រោះព្រះតថាគត ជាព្រះអរិយៈ ទ្រង់ចាក់ធ្លុះហើយ និងសំដែងហើយ ព្រោះហេតុណា, ព្រោះហេតុនោះ ទើបឈ្មោះថា អរិយសច្ច ព្រោះជារបស់ពិតនៃព្រះអរិយៈ" ។

ដីកាលោកសូត្រនោះ ថា "ដោយ ២ បទថា '**បដិវិទ្ធត្តា**

ទេសិតត្តា ច ' នេះ ព្រះអដ្ឋកថាចារ្យ សំដែងនូវភាវៈនៃសច្ចៈទាំងនោះ ជារបស់នៃព្រះដ៏មានព្រះភាគ ជាព្រះអរិយៈ ថា 'ឈ្មោះថាជារបស់ នៃព្រះតថាគត ដែលជាព្រះអរិយៈ' ដូច្នេះ ព្រោះព្រះអង្គទ្រង់កំណត់ ដោយបដិវេទធញ្ញាណ និងទេសនាញាណ " ។

(១៦៤) មួយទៀត ឈ្មោះថា អរិយសច្ច ព្រោះភាវៈនៃសច្ចៈទាំងនោះ ឲ្យបានសម្រេចភាពជាព្រះអរិយៈផង ព្រោះសច្ចៈទាំងនុ៎ះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដឹងហើយ ចំពោះព្រះអង្គឯង ។

សមដូចជាព្រះដ៏មានព្រះភាគ ត្រាស់ក្នុងលោកសូត្រនោះឯងថា "ម្នាលភិក្ខុទាំងឡាយ តថាគត បណ្ឌិតហៅថា 'ជាព្រះអរហន្តសម្មាសម្ពុទ្ធ' ដូច្នេះ ព្រោះភាវៈនៃអរិយសច្ចទាំង ៤ នេះឯង ជាធម្មជាត ដែលព្រះតថាគតត្រាស់ដឹងហើយ ដោយសេចក្តីពិត " ។

ព្រះអដ្ឋកថាចារ្យ លុះពោលនូវសេចក្តីនេះហើយ ទើបពោលកែទៀត សូម្បីក្នុងអដ្ឋកថាសច្ចវិភង្គថា "មួយទៀត សច្ចៈទាំងឡាយ ជាអរិយៈ ហេតុនោះ ទើបឈ្មោះថា អរិយសច្ច" ដូច្នេះ ។ បទថា "អរិយានិ" គឺ មិនប្រែប្រួល អធិប្បាយថា មិនភ្លាំងភ្លាត់ " ។

ដីកាវិភង្គ ថា " ក្នុងពាក្យថា 'អរិយភាវសិទ្ធិតោបិ' នេះ បណ្ឌិតគប្បីយល់ការលប់បទខាងចុង ព្រោះបទខាងដើមថា

'សច្ចៈទាំងឡាយ ដែលញុំាងភាវៈជាអរិយៈឲ្យបានសម្រេច ឈ្មោះថា អរិយសច្ច'។ ក្នុងពាក្យថា 'អរិយានិ សច្ចានិ' នេះ គប្បីជ្រាបវិនិច្ឆ័យ យ៉ាងនេះថា 'សច្ចៈទាំងឡាយ ឈ្មោះថា អរិយៈ ព្រោះភាពជាធម៌ដែលបុគ្គលគប្បីដល់ គឺ ព្រោះភាពជាធម៌ ដែលបុគ្គលគប្បីសម្រេច ដោយភាវៈជាធម្មជាតដែលមិនប្រែប្រួល ។ មួយទៀត វោហារថា អរិយៈនេះ អ្នកសិក្សាគប្បីជ្រាបថា ជាវោហារដែលមិនភ្លាំងភ្លាត់ ជាវោហារដែលមានរូបមិនប្រែប្រួល "។

(១៦៥) អដ្ឋកថាកុមារប្បញ្ហា ក្នុងខុទ្ទកបាឋៈ ថា " ន័យមួយទៀត សច្ចៈទាំងឡាយ ឈ្មោះថា អរិយៈ ព្រោះជាធម្មជាតដែលសត្វលោក ព្រមទាំងទេវលោក គប្បីដល់, មានពាក្យអធិប្បាយថា គប្បីបានសម្រេច ព្រោះហេតុណា, ព្រោះហេតុនោះ សច្ចៈទាំងនោះ បណ្ឌិតទើបហៅថា 'អរិយសច្ច' ដូច្នេះ, ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវកទាំងឡាយ ដែលសន្មតថាជាព្រះអរិយៈ ព្រោះធ្វើដំណើរទៅ ក្នុងសេចក្ដីចំរើន ដែលដឹងថាជាឋានៈ ដែលសមគួរគប្បីព្យាយាម ឬ ព្រោះការមិនធ្វើដំណើរទៅ ក្នុងសេចក្ដីមិនចំរើន ឬព្រោះប្រកបត្រូវក្នុងអរិយធម៌ គឺ ពោធិបក្ខិយធម៌ទាំង ៣៧ ប្រការ រមែងចាក់ធ្លុះនូវសច្ចៈទាំងនុ៎ះ, ព្រោះហេតុនោះ សច្ចៈទាំងនោះ បណ្ឌិតទើបហៅថា 'អរិយសច្ច' ដូច្នេះ "។

អដ្ឋកថាសច្ចវិភង្គ ថា “ក៏ព្រោះព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម រមែងចាក់ធ្លុះនូវសច្ចៈទាំងឡាយនុ៎ះ ហេតុនោះសច្ចៈទាំងនុ៎ះ បណ្ឌិតទើបហៅថា ‘អរិយសច្ច’ ដូច្នេះ” ។

ដីកាសច្ចវិភង្គ ថា “ពាក្យថា ‘**ពុទ្ធាទយោ**’ ក្នុងពាក្យថា ‘**ពុទ្ធាទយោ អរិយា បដិវិជ្ឈន្តិ**’ នេះ ព្រះអដ្ឋកថាចារ្យ លើកវោហារថា ‘ពុទ្ធៈ’ ដែលប្រព្រឹត្តទៅ ក្នុងពេលដែលចាក់ធ្លុះហើយ យកមកពោល ក្នុងបុរិមកាលនុ៎ះឯង ដូចជាវោហារដែលពោលក្នុងប្រយោគជាអាទិ៍ថា ‘ព្រះពុទ្ធជាម្ចាស់ បានស្ដេចយាងទៅកាន់ទីក្រុងរាជគ្រឹះ’ យ៉ាងដូច្នោះឯង ។ មែនពិត ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើមនោះ រមែងចាក់ធ្លុះ ដោយមគ្គទាំង ៤ ដូច្នេះឯង, មួយទៀត គប្បីឃើញការលប់បទខាងចុង ព្រោះបទខាងដើម ក្នុងបទថា ‘**អរិយសច្ចានិ**’ នេះ ដោយវិគ្រោះថា ‘សច្ចៈទាំងឡាយ ដែលព្រះអរិយៈគប្បីចាក់ធ្លុះ ទើបឈ្មោះថាអរិយសច្ច” ។

(១៦៦) ចំណែកក្នុងអដ្ឋកថាកុមារបញ្ហាវិភង្គ ព្រះអដ្ឋកថាចារ្យ សំដែងបទនៃព្រះសូត្រណា ថា “ព្រះអរិយៈទាំងឡាយ រមែងចាក់ធ្លុះសច្ចៈទាំងឡាយនេះ, ព្រោះហេតុនោះ បណ្ឌិតទើបហៅសច្ចៈទាំងនោះថា ‘អរិយសច្ច’ ដូច្នេះ, បទនៃព្រះសូត្រ

នោះ ព្រះដ៏មានព្រះភាគ មិនបានសំដែងហើយ ក្នុងសច្ចសំយុត្ត ។ សេចក្ដីនៃពាក្យ នៃអរិយសច្ច ព្រះអដ្ឋកថាចារ្យ ពោលហើយ សូម្បី ក្នុងអដ្ឋកថាអដ្ឋិសញ្ញាយសូត្រ ក្នុងតតិយវគ្គ ឯកនិបាត ក្នុងឥតិវុត្តកៈ ។

អដ្ឋកថាអដ្ឋមសូត្រ ក្នុងបឋមវគ្គ នៃមគ្គសំយុត្ត ក្នុងមហាវគ្គ និងអដ្ឋកថាសច្ចវិភង្គថា "បណ្ដាសច្ចៈទាំងនោះ សច្ចៈ ២ ខាងដើម ជាវដ្ដៈ, សច្ចៈ ២ ខាងចុង ជាវិវដ្ដៈ ។ បណ្ដាវដ្ដៈនិងវិវដ្ដៈទាំងនោះ ការតាំងចិត្តស៊ប់ ក្នុងកម្មដ្ឋាននៃភិក្ខុ រមែងមាន ក្នុងសច្ចៈដែលជាវដ្ដៈ, ក្នុងសច្ចៈដែលជាវិវដ្ដៈ មិនមានការតាំងចិត្តស៊ប់ ។ ក៏ព្រះយោគាវចរ រៀនសច្ចៈ ២ យ៉ាង ខាងដើម ក្នុងសំណាក់ នៃអាចារ្យ ដោយសេចក្ដីសង្ខេប យ៉ាងនេះថា "បញ្ចក្ខន្ធ ឈ្មោះថាជាទុក្ខ, តណ្ហាជាហេតុឲ្យទុក្ខកើត" ដូច្នេះ និងដោយពិស្ដារ ដោយន័យជាដើមថា 'ខន្ធ ៥ តើដូចម្ដេច ?, បញ្ចក្ខន្ធ គឺរូបក្ខន្ធ' ដូច្នេះហើយ ក៏ទន្ទេញដោយវាចា ជាញឹកញាប់ រមែងធ្វើកម្មបាន ។ ចំណែកក្នុងសច្ចៈ ២ យ៉ាង ផ្សេងពីនេះ ព្រះយោគាវចរ រមែងធ្វើកម្មបាន ដោយការស្ដាប់ យ៉ាងនេះឯងថា 'និរោធសច្ច ជាទីប្រាថ្នា ជាទីត្រូវការ ជាទីពេញចិត្ត, មគ្គសច្ច ជាទីប្រាថ្នា ជាទីត្រូវការ ជាទីពេញចិត្ត' ដូច្នេះ ។ ព្រះយោគាវចរនោះ កាលធ្វើយ៉ាងនេះ រមែងចាក់ធ្លុះនូវសច្ចៈ ៤ ដោយបដិវេធញ្ញាណ ១ ដួង រមែង

ត្រាស់ដឹង ដោយអភិសមយញ្ញាណ ១ ដួង, គឺ រមែងចាក់ធ្លុះនូវទុក្ខ ដោយបដិវេធញ្ញាណ គ្រឿងកំណត់ដឹង, នូវសមុទ័យ ដោយបដិវេធញ្ញាណជាហេតុលះ, នូវនិរោធសច្ច ដោយបដិវេធញ្ញាណគ្រឿងធ្វើឲ្យជាក់ច្បាស់, រមែងចាក់ធ្លុះនូវមគ្គ ដោយបដិវេធញ្ញាណដែលជាហេតុធ្វើឲ្យចំរើន, រមែងត្រាស់ដឹងនូវទុក្ខ ដោយអភិសមយញ្ញាណជាគ្រឿងកំណត់ដឹង ។ល។ រមែងត្រាស់ដឹងមគ្គ ដោយអភិសមយញ្ញាណជាហេតុធ្វើឲ្យចំរើន ។ ក្នុងចំណែកខាងដើម ព្រះយោគាវចរនោះ រមែងមានបដិវេធញ្ញាណ ក្នុងសច្ចៈ ២ យ៉ាង ខាងដើម ដោយអំណាចការរៀន ការសាកសួរ ការស្តាប់ ការទ្រង់ចាំ និងការពិចារណា, មានបដិវេធញ្ញាណ ក្នុងសច្ចៈ ២ យ៉ាង ខាងចុង ដោយអំណាចការស្តាប់តែម្យ៉ាង, ក្នុងចំណែកខាងក្រោយ ព្រះយោគាវចរនោះ ទើបមានបដិវេធ ក្នុងសច្ចៈ ៣ យ៉ាង ដោយកិច្ច, មានបដិវេធញ្ញាណក្នុងនិរោធ ដោយ (កិរិយាកំណត់) ជាអារម្មណ៍ ដោយប្រការយ៉ាងដូច្នេះឯង" ។

(១៦៧) ដីកាមគ្គសំយុត្ត ថា "ការបដិបត្តិកម្មដ្ឋាន ឈ្មោះថា កម្មដ្ឋានាភិនិវេសោ ។ អ្នកសិក្សាគប្បីធ្វើការសម្ពន្ធ ថា 'រៀននូវសច្ចៈ ២ យ៉ាង ខាងដើម' ដូច្នេះចុះ ។ ដោយពាក្យថា 'ឥដ្ឋំ កន្តំ មនាបំ' នេះ ព្រះអដ្ឋកថាចារ្យ រមែងសំដែងនូវភាវៈ នៃ

ព្រះយោគាវចរបង្អោនចូលទៅ ក្នុងនិរោធនិងមគ្គ, មិនសំដែងភាវៈជាអ្នកមិនបង្អោនចូលទៅ ក្នុងនិរោធនិងមគ្គឡើយ ។ ក៏បណ្ឌិតគប្បីឃើញការធ្វើកម្ម ក្នុងនិរោធសច្ចនិងមគ្គសច្ចនោះ ថា គឺភាវៈដែលព្រះយោគាវចរ បង្អោនចូលទៅ ក្នុងនិរោធសច្ចនិងមគ្គសច្ចនោះឯង ។ ន័យមួយទៀត ភាវៈនៃព្រះយោគាវចរ ជាអ្នកបង្អោនចូលទៅក្នុងនិរោធសច្ច និងមគ្គសច្ចនោះឯង ឈ្មោះថា ការត្រាស់ដឹងដោយញាណតែមួយ ព្រោះជាគ្រឿងនិមិត្តរូប នៃការចាក់ធ្លុះសច្ចៈទាំងឡាយ ដោយញាណតែមួយប៉ុណ្ណោះឯង ព្រោះអត្ថវិគ្រោះថា 'ការប្រជុំ គឺការមកព្រមគ្នា ដោយសច្ចៈទាំងនោះ ដោយភាវៈជាធម៌មានមុខចំពោះគ្នា ។ បទថា 'អស្ស' បានដល់ ញាណ ឬព្រះយោគាវចរ ។ ក៏ក្នុងបដិវេធទាំងនេះ បដិវេធញាណគ្រប់យ៉ាងដែលប្រព្រឹត្តទៅក្នុងលោក មិនមែនជាបដិវេធដោយពិត ព្រោះមិនមានញាណជាគ្រឿងដឹង តាមសភាវៈពិត ក្នុងអារម្មណ៍, បើមានពាក្យដណ្ដឹងសួរថា 'សូម្បីការចាក់ធ្លុះ ដែលកើតអំពីកិច្ចមានការរៀនជាដើម ក៏ជាបដិវេធបានដែរ, បដិវេធនោះ មិនមែនជាលោកុត្តរៈ មិនមែនទេឬ ?" ។ ឆ្លើយថា 'រឿងនោះ មិនមែនទេ ព្រោះភាវៈនៃបដិវេធ ដែលកើតមកអំពីកិច្ចមានការរៀនជាដើម គឺបុគ្គលណាមួយ មិនគប្បីពោល ដោយបដិវេធស័ព្ទតែម្យ៉ាងបាន ។

មួ៉ាងទៀត ញាណក្នុងសច្ចៈមានទុក្ខសច្ចជាដើម ដែលប្រព្រឹត្តទៅហើយ ដោយអំណាចនៃការរៀនជាដើម លោកពោលហើយ ថា 'បដិវេធ' ក្នុងខាងដើម ព្រោះជានិមិត្តរូបនៃការចាក់ធ្លុះ, មិនមែនពោល ថា 'ជាបដិវេធ' ព្រោះភាវៈជាតួបដិវេធឡើយ, ចំណែកញាណដែលជាតួបដិវេធពិតមែន រមែងសមគួរនូវភាវៈជាញាណដែលគប្បីពោលបាន ថា 'បដិវេធ' ដោយត្រង់ ៗ បទថា '**កិច្ចតោ**' ប្រែថា ដោយកិច្ចមានការកំណត់ដឹងជាដើម ។ ព្រះអដ្ឋកថាចារ្យ ពោលបដិវេធញាណ ដោយការធ្វើឲ្យជាក់ច្បាស់ ដោយបទថា '**អារម្មណប្បដិវេធោ**' ដូច្នេះ " ។

(១៦៨) អដ្ឋកថាសច្ចវិភង្គ ថា "ញាណជាគ្រឿងចាក់ធ្លុះសូម្បីទាំងពួង ជាលោកុត្តរៈ, ញាណដែលកើតអំពីការស្តាប់ ការទ្រង់ចាំ និងការពិចារណា ជាលោកិយៈ ផ្នែកកាមាវចរ ។ ចំណែកការពិចារណា ជាញាណ នៃមគ្គសច្ច" ។

កិរិយាឃើញនូវសច្ចៈ ដោយអំណាចបដិវេធញាណ រមែងបាន សូម្បីក្នុងបទ ថា "**អរិយសច្ចានទស្សនំ**" នេះ ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលដោះស្រាយ ក្នុងអដ្ឋកថា ថា "កិរិយាឃើញមគ្គ ដោយអំណាចត្រាស់ដឹង នូវអរិយសច្ចទាំងឡាយ ៤ ឈ្មោះថា កិរិយាឃើញអរិយសច្ច, កិរិយាឃើញ

នូវអរិយសច្ចនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ ថា 'ជាមង្គល' ព្រោះជាហេតុ នៃការឆ្លងផុតអំពីសំសារទុក្ខបាន " ។

(១៦៩) ក៏ពាក្យថា "**អភិសមយវសេន**" នេះ ព្រះអដ្ឋកថាចារ្យពោល សំដៅយកការត្រាស់ដឹង ដោយញាណតែ ១ ។ ដោយហេតុនោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ត្រាស់[១] ថា "ម្នាលភិក្ខុទាំងឡាយ បុគ្គលណាឃើញទុក្ខ, បុគ្គលនោះ ឈ្មោះថាឃើញនូវទុក្ខសមុទ័យផង ឃើញទុក្ខនិរោធផង ឃើញទុក្ខនិរោធគាមិនីបដិបទាផង, បុគ្គលណាឃើញនូវទុក្ខសមុទ័យ, បុគ្គលនោះ ឈ្មោះថាឃើញទុក្ខផង ។ល។ បុគ្គលណាឃើញនូវទុក្ខនិរោធ បុគ្គលនោះ ឈ្មោះថាឃើញទុក្ខផង ។ល។ បុគ្គលណាឃើញទុក្ខនិរោធគាមិនីបដិបទា, បុគ្គលនោះ ឈ្មោះថា ឃើញទុក្ខផង ឃើញទុក្ខសមុទ័យផង ឃើញទុក្ខនិរោធផង" ។

បាលីគវម្បតិសូត្រ ក្នុងកតិយវគ្គ សច្ចសំយុត្ត ។

(១៧០) អដ្ឋកថាគវម្បតិសូត្រនោះ ថា "ពាក្យថា '**យោ ភិក្ខវេ ទុក្ខំ បស្សតិ ទុក្ខសមុទយម្បិ សោ បស្សតិ**' ជាដើម ព្រះដ៏មានព្រះភាគ ត្រាស់ហើយ ដោយអំណាចនៃការចាក់ធ្លុះ ដោយញាណតែមួយ ៗ ព្រោះថា ការចាក់ធ្លុះ ដោយញាណតែមួយ ព្រះអង្គទ្រង់ត្រាស់ហើយ ក្នុងព្រះសូត្រនេះ" ។

---

១- ត្រៃបិដក ភាគទី ៣៩ / ទំព័រទី ២៧១ ។

ដីកាគវម្បតិសូត្រនោះ ថា "ការចាក់ធ្លុះនូវសច្ចៈ ៤ ក្នុងខណៈជាមួយគ្នា ដោយញាណតែមួយគត់ ឈ្មោះថា ឯកប្បដិវេធោ"។

(១៧១) ក៏បុគ្គលណា មិនឃើញសច្ចៈ ៤, បុគ្គលនោះនឹងមិនឆ្លងនូវសេចក្ដីទុក្ខបាន ។ ព្រោះសំសារវដ្ដរបស់បុគ្គលបែបនោះ មានវែងឆ្ងាយ ។ ដោយហេតុនោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ត្រាស់ ក្នុងតតិយវគ្គ នៃសច្ចសំយុត្ត ថា "ម្នាលភិក្ខុទាំងឡាយ សំសារវដ្ដនេះ ដែលតថាគតក្ដី អ្នកទាំងឡាយក្ដី អន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលដ៏យូរអង្វែងយ៉ាងនេះ ព្រោះមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះអរិយសច្ចៈទាំងឡាយ ៤ ។ ព្រោះមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះអរិយសច្ចៈទាំងឡាយ ៤ គឺដូចម្ដេចខ្លះ ? ។ ម្នាលភិក្ខុទាំងឡាយ សំសារវដ្ដនេះ ដែលតថាគតក្ដី អ្នកទាំងឡាយក្ដី អន្ទោលទៅត្រាច់រង្គាត់ទៅ អស់កាលដ៏យូរអង្វែងយ៉ាងនេះ ព្រោះមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះទុក្ខអរិយសច្ច, ម្នាលភិក្ខុទាំងឡាយ សំសារវដ្ដនេះ ដែលតថាគតក្ដី អ្នកទាំងឡាយក្ដី បានអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលដ៏យូរអង្វែងយ៉ាងនេះ ព្រោះមិនបានត្រាស់ដឹង ព្រោះមិនបានចាក់ធ្លុះនូវទុក្ខសមុទ័យអរិយសច្ច, ម្នាលភិក្ខុទាំងឡាយ សំសារវដ្ដនេះ ដែលតថាគតក្ដី អ្នកទាំងឡាយក្ដី អន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលដ៏យូរអង្វែងយ៉ាងនេះ ព្រោះ

មិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវទុក្ខនិរោធអរិយសច្ច, ម្នាល ភិក្ខុទាំងឡាយ សំសារវដ្តនេះ ដែលតថាគតក្តី អ្នកទាំងឡាយក្តី អន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលដ៏យូរអង្វែងយ៉ាងនេះ ព្រោះ មិនបានត្រាស់ដឹង មិនបានចាក់ធ្លុះ នូវទុក្ខនិរោធគាមិនីបដិបទា-អរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ អរិយសច្ច គឺ ទុក្ខនេះនោះ តថាគតក្តី អ្នកទាំងឡាយក្តី បានត្រាស់ដឹងហើយ បានចាក់ធ្លុះហើយ, ទុក្ខសមុទយ ... ទុក្ខនិរោធ ... ទុក្ខនិរោធគាមនីបដិបទា-អរិយសច្ច តថាគតក្តី អ្នកទាំងឡាយក្តី បានត្រាស់ដឹងហើយ បាន ចាក់ធ្លុះហើយ ។ តណ្ហាក្នុងភព តថាគតក្តី អ្នកទាំងឡាយក្តី បាន កាត់ផ្តាច់អស់ហើយ, តណ្ហាដែលជាធម្មជាតិនាំសត្វឲ្យចូលទៅកាន់ ភព អស់រលីងហើយ, ភពថ្មីទៀត ក្នុងកាលឥឡូវនេះ មិនមាន សោះឡើយ" ដូច្នេះ ។ ព្រះមានព្រះភាគ បានត្រាស់ពាក្យនេះ ហើយ លុះព្រះសុគត ទ្រង់ត្រាស់ពាក្យនេះចប់ហើយ ព្រះសាស្តា ក៏បានត្រាស់គាថានេះ តទៅទៀត ថា ÷

"តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ[១]
ក្នុងជាតិទាំងឡាយនោះៗ អស់កាលដ៏យូរអង្វែង
ព្រោះមិនបានឃើញនូវអរិយសច្ចៈ ៤ តាមសេចក្តីពិត,

---

១- ត្រៃបិដក ភាគទី ៣៩ / ទំព័រទី ២៦២ ។

អរិយសច្ចទាំង ៤ នេះនុ៎ះ តថាគតនិងអ្នកទាំងឡាយ បានឃើញហើយ, តណ្ហាដែលនាំសត្វឲ្យចូលទៅកាន់ភព តថាគតនិងអ្នកទាំងឡាយ បានដកចោលហើយ, ឫសគល់នៃសេចក្ដីទុក្ខ តថាគតនិងអ្នកទាំងឡាយ បានរំលើងចោលហើយ, ភពថ្មីទៀត ក្នុងកាលឥឡូវនេះ មិនមានឡើយ " ។

បឋមគេយ្យសូត្រ ចប់ ។

(១៧២) អដ្ឋកថាបឋមគេយ្យសូត្រនោះ ថា " បទថា 'អននុពោធា' បានដល់ ព្រោះការមិនដឹងតាម ៗ បទថា 'អប្បដិវេធា' បានដល់ ព្រោះការមិនចាក់ធ្លុះ " ។

ដីកាបឋមគេយ្យសូត្រនោះ ថា " បទថា 'អននុពោធា' បានដល់ ព្រោះការមិនមាននៃញាណជាគ្រឿងត្រាស់ដឹង តាមសមគួរដល់ញាណជាគ្រឿងចាក់ធ្លុះ ៗ បទថា 'អប្បដិវេធា' បានដល់ ព្រោះការមិនមាន នៃញាណជាគ្រឿងចាក់ធ្លុះ នូវសច្ចៈទាំងឡាយ ឲ្យបានជាក់ច្បាស់ នៅចំពោះមុខ " ។

(១៧៣) អដ្ឋកថាសូត្រខាងដើម នៃសូត្រទាំងពួង ក្នុងចតុក្កនិបាត អង្គុត្តរនិកាយ ថា " បទថា 'អននុពោធា' ប្រែថា

ព្រោះមិនបានត្រាស់ដឹង គឺព្រោះមិនដឹង ។ បទថា 'អប្បដិវេធា' ប្រែថា ព្រោះមិនបានចាក់ធ្លុះ បានដល់ ព្រោះមិនបានធ្វើឲ្យជាក់ច្បាស់ ។ បទថា 'ទីឃមទ្ធានំ' គឺ អស់កាលដ៏យូរអង្វែង ។ បទថា 'សន្ធាវិតំ' បានដល់ អន្ទោលទៅ ដោយការ (ចេញ) ពីភពទៅកាន់ភព ។ បទថា 'សំសរិតំ' បានដល់ ត្រាច់រង្គាត់ទៅដោយអំណាចការទៅ និងការមក ជាញឹកញាប់ ។ ២ បទថា 'មមញ្ចេវ តុម្ហាកញ្ច' បានដល់ ដែលតថាគត និងអ្នកទាំងឡាយ ។ ន័យមួយទៀត ២ បទថា 'សន្ធាវិតំ សំសរិតំ' គឺ ការអន្ទោលទៅ ការត្រាច់រង្គាត់ទៅ បានមានហើយ ដល់តថាគត និងអ្នកទាំងឡាយ ។ សេចក្ដីប្រាថ្នា ក្នុងភពទាំងឡាយ ឈ្មោះថា **ភវតណ្ហា** ។ តណ្ហាដែលដូចជាខ្សែចងសត្វក្នុងភព ឈ្មោះថា **ភវនេត្តិ** ។ ពាក្យថា '*ភវនេត្តិ*' នោះ គឺជាឈ្មោះ នៃតណ្ហានុ៎ះឯង ។ មែនពិត សត្វទាំងឡាយ ត្រូវតណ្ហានោះ ចងហើយនាំទៅកាន់ភពនោះ ៗ ប្រៀបដូចជាសត្វគោទាំងឡាយ ដែលនាយគោបាលចង ត្រង់ក ហើយនាំយកទៅ ដូច្នោះឯង, ព្រោះហេតុនោះ តណ្ហា ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា '*ភវនេត្តិ*' ដូច្នេះ" ។

(១៧៤) ដីកាបឋមសូត្រនោះ ថា " ញាណដែលប្រព្រឹត្តទៅក្នុងចំណែកខាងដើម ឈ្មោះថា **អនុពោធោ** ។ ការត្រាស់ដឹង

ដោយមគ្គញ្ញាណ ឈ្មោះថា បដិវេធោ ។ បណ្ដាញាណទាំង ២ យ៉ាងនោះ ព្រោះការចាក់ធ្លុះ ដែលមានការដឹងតាមជាចំណែកខាងដើម វៀរចាកការត្រាស់ដឹង រមែងមិនសម្រេចបាន, សូម្បីការត្រាស់ដឹងខ្លះ ក៏ត្រូវតែទាក់ទងជាមួយនឹងបដិវេធ, មួយទៀត ការត្រាច់រង្គាត់ទៅ ក្នុងវដ្ដៈ មានការមិនមានការត្រាស់ដឹងនិងការចាក់ធ្លុះទាំង ២ យ៉ាងនោះ ជាហេតុ ហេតុនោះ ព្រះដ៏មានព្រះភាគ ទើបត្រាស់ហើយ ក្នុងបាលី ថា 'អននុពោធា ។ល។ តុម្ហាកញ្ច' ដូច្នេះ ។ ការចេញពីភព ចូលទៅកាន់ភពមួយទៀត ដោយអំណាចការចាប់បដិសន្ធិ ឈ្មោះថា ការអន្ទោលទៅ, កិរិយាត្រាច់រង្គាត់ទៅ ដោយអំណាចការច្យុតនិងការកើត ជាញឹកញាប់ ឈ្មោះថា ការត្រាច់រង្គាត់ទៅ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា 'ភវតោ' ដូច្នេះជាដើម ។ ក្នុងវិកប្បទី ១ ព្រះអដ្ឋកថាចារ្យ សំដៅយកនូវភាវៈ នៃសន្ធាវិតបទនិងសំសរិតបទ ជាកម្មសាធនៈ ទើបពោលថា 'មយា ច តុម្ហេហិ ច' ដូច្នេះ ។ ចំណែកក្នុងវិកប្បទី ២ ព្រះអដ្ឋកថាចារ្យ ធ្វើនូវភាវៈនៃស័ព្ទទាំង ២ យ៉ាងនោះ ជាភាវសាធនៈ ក្នុងហេតុវ័យ ហើយទើបពោល ដោយអំណាចនៃបទ តាមដែលព្រះដ៏មានព្រះភាគត្រាស់ហើយនុ៎ះឯង ថា 'មម ចេវ តុម្ហាកញ្ច' ។ អភិសង្ខារ រមែងនាំសន្តានសត្វ

ដែលខ្លួនចងហើយ ដោយខ្សែគឺតណ្ហា ទៅកាន់ភពផ្សេងទៀត ដោយតណ្ហានុ៎ះ ប្រៀបដូចជាបុរសដែលមានខ្សែនៅក្នុងដៃ នាំនូវសត្វដែលខ្លួនចងទុកហើយ ដោយខ្សែវែង ទៅកាន់ប្រទេសដទៃដូច្នោះ ព្រោះហេតុនោះ តណ្ហានុ៎ះ ទើបឈ្មោះថា **ភវនេត្តិ** ។ ហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា '**ភវរជ្ជុ**' ជាដើម " ។

(១៧៥) ព្រះដ៏មានព្រះភាគ កាលទ្រង់សំដែងធម៌ ដល់ភិក្ខុទាំងឡាយ ទើបទ្រង់ត្រាស់ពាក្យជាគាថានេះ ក្នុងគេយ្យសូត្រ ទី ២ ក្នុងសច្ចសំយុត្តនោះឯង(១) ថា ÷

" ពួកជនណា មិនដឹងច្បាស់នូវសេចក្ដីទុក្ខ ទាំងហេតុដែលនាំឲ្យកើតទុក្ខ, សេចក្ដីទុក្ខ រំលត់ ឥតមានសេសសល់ សព្វអន្លើ ព្រោះមគ្គឯណា, ពួកជននោះ មិនដឹងនូវមគ្គ ដែលជាដំណើរទៅកាន់សេចក្ដីរម្ងាប់ទុក្ខនោះ ជាអ្នកសាបសូន្យចាកចេតោវិមុត្តិនិងបញ្ញាវិមុត្តិ, ជនទាំងនោះ មិនគួរដើម្បីនឹងធ្វើទីបំផុត នៃសេចក្ដីទុក្ខ, ជនទាំងនោះជាអ្នកចូលទៅកាន់ជាតិនិងជរា ។ លុះតែពួកជនណា ដឹងច្បាស់នូវសេចក្ដីទុក្ខ ទាំងហេតុដែលនាំឲ្យកើតទុក្ខ, សេចក្ដីទុក្ខ រមែងរលត់ទៅ

---

១- ត្រៃបិដក ភាគទី ៥៣ / ទំព័រទី ១៣៨ ។ ភាគ ៣៩ / ទំព័រ ២៦៤ ។

ឥតមានសេសសល់ សព្វអន្លើ ព្រោះមគ្គឯណា, ពួកជននោះ ដឹងច្បាស់នូវមគ្គ ដែលជាដំណើរទៅកាន់សេចក្ដីស្ងប់រម្ងាប់សេចក្ដីទុក្ខនោះ ជាអ្នកបរិបូណ៌ដោយចេតោវិមុត្តិ និង បញ្ញាវិមុត្តិ, ពួកជននោះសមគួរដើម្បីធ្វើទីបំផុត នៃសេចក្ដីទុក្ខបាន, ពួកជននោះ ជាអ្នកមិនចូលទៅកាន់ជាតិនិងជរាឡើយ ”។

សូម្បីក្នុងទ្វយតានុបស្សនាសូត្រ ក្នុងតតិយវគ្គ នៃសុត្តនិបាត ព្រះដ៏មានព្រះភាគ ក៏ទ្រង់ត្រាស់ហើយ យ៉ាងដូច្នោះដែរ ។

(១៧៦) អដ្ឋកថាទ្វយតានុបស្សនាសូត្រ ថា “ បណ្ដាបទទាំងនោះ ដោយបទថា ‘យត្ថ ច ’ នេះ ព្រះដ៏មានព្រះភាគ ទ្រង់សំដែងនូវព្រះនិព្វាន ។ ព្រោះថា ទុក្ខ រមែងរលត់ទៅ សព្វអន្លើ គឺ រមែងរលត់ ដោយប្រការទាំងពួង គឺ រមែងរលត់ព្រមទាំងហេតុ ឈ្មោះថា រមែងរលត់ ឥតមានសេសសល់ឡើយ ក្នុងព្រះនិព្វាន ។ ២ បទថា ‘តញ្ច មគ្គំ ’ បានដល់ ទាំងមគ្គមានអង្គ ៨ នោះ ”។

អដ្ឋកថាអដ្ឋិសញ្ញាយសូត្រ ក្នុងឥតិវុត្តកៈ ថា “នូវមគ្គ ដែលជាដំណើរទៅកាន់សេចក្ដីស្ងប់រម្ងាប់សេចក្ដីទុក្ខ ព្រោះវិគ្រោះ ថា ‘ រមែងដល់ នូវសេចក្ដីស្ងប់រម្ងាប់ គឺ ការរលត់សេចក្ដីទុក្ខ” ។

(១៧៧) អដ្ឋកថាសច្ចសំយុត្ត ថា "២ បទថា 'ចេតោវិមុត្តិ បញ្ញាវិមុត្តិ' គឺ ជាឈ្មោះនៃសមាធិដែលជាគួផល និង បញ្ញាដែលជាគួផល" ។

ដីកាសច្ចសំយុត្តនោះ ថា "បទថា 'ផលសមាធិផលប្បញ្ញានំ' បានដល់ សមាធិនិងបញ្ញា ដែលជាគួផល កើតអំពីមគ្គ" ។

អដ្ឋកថាទ្វយតានុបស្សនាសូត្រ ថា "សមាធិដែលសម្បយុត្ត ដោយអរហត្តផល បណ្ឌិតគប្បីជ្រាបថា 'ចេតោវិមុត្តិ' ព្រោះសម្រកនូវសេចក្ដីតម្រេក, បញ្ញាដែលសម្បយុត្ត ដោយអរហត្តផល បណ្ឌិតគប្បីជ្រាបថា 'បញ្ញាវិមុត្តិ' ព្រោះសម្រកអវិជ្ជា ។ ន័យមួយទៀត អរហត្តផល ដែលបុគ្គលអ្នកមានតណ្ហាចរិត គ្របសង្កត់នូវកិលេសទាំងឡាយបាន ដោយកំឡាំង នៃអប្បនាឈាន ហើយក៏បានសម្រេច ឈ្មោះថា ចេតោវិមុត្តិ ព្រោះសម្រករាគៈ, អរហត្តផល ដែលបុគ្គលអ្នកមានទិដ្ឋិចរិត ញុំាំងគុណធម៌ត្រឹមតែឧបចារឈាន ឲ្យកើតឡើងហើយ ឃើញជាក់ច្បាស់ បានសម្រេចហើយ ឈ្មោះថា បញ្ញាវិមុត្តិ ព្រោះសម្រកនូវអវិជ្ជា ។

ន័យមួយទៀត អនាគាមិផល ឈ្មោះថា ចេតោវិមុត្តិ ព្រោះសម្រកនូវកាមរាគៈ, អរហត្តផល ឈ្មោះថា បញ្ញាវិមុត្តិ ព្រោះសម្រកនូវអវិជ្ជា ដោយប្រការទាំងពួង យ៉ាងដូច្នេះឯង ។

បទថា 'អន្តកិរិយាយ' បានដល់ ដើម្បីធ្វើនូវទីបំផុត នៃសេចក្ដីទុក្ខក្នុងវដ្ដៈ ។ បទថា 'ជាតិជរូបគា' បានដល់ ជាអ្នកចូលទៅដល់ជាតិនិងជរាហើយ, មួយទៀត ជាអ្នកដែលជាតិនិងជរាចូលទៅដល់ហើយ, អធិប្បាយថា ពួកជនទាំងនោះ រមែងមិនរួចផុត អំពីជាតិនិងជរាទៅបានឡើយ " ។

ក៏ពួកជនអ្នកឃើញសច្ចៈហើយ កន្លងផុតនូវសង្សារទុក្ខទៅបាន គណនាត្រារាប់មិនអស់ឡើយ ។ នឹងមានប្រយោជន៍អ្វីទៅដោយរឿង ( ដែលជាឧទាហរណ៍ ) ។

ពណ៌នាអំពីការឃើញអរិយសច្ច ចប់ ។

*សាសនាចម្រើន ព្រោះមានអ្នកសិក្សាត្រឹមត្រូវ និងប្រតិបត្តិត្រឹមត្រូវតាមការសិក្សា ។*

ប្រែចប់ ថ្ងៃពុធ ៣ រោច ខែផល្គុណ ឆ្នាំរកា បញ្ចស័ក ព.ស. ២៥៣៦
ត្រូវនឹងថ្ងៃ ទី ១០ ខែមិនា ១៩៩៣

## ពណ៌នាអំពីការធ្វើព្រះនិព្វានឱ្យជាក់ច្បាស់

(១៧៨) ឈ្មោះថា ព្រះនិព្វាន មាន ២ យ៉ាង ដោយបរិយាយ ។ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុកក្នុងសត្តមសូត្រ[១] នៃទុតិយវគ្គ ក្នុងឥតិវុត្តកៈ ថា " ម្នាលភិក្ខុទាំងឡាយ និព្វានធាតុនេះ មាន ២ យ៉ាង ។ និព្វានធាតុ ២ យ៉ាង តើដូចម្តេចខ្លះ ? ។ គឺ សឧបាទិសេសនិព្វានធាតុ ១ អនុបាទិសេសនិព្វានធាតុ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសឧបាទិ-សេសនិព្វានធាតុ តើដូចម្តេច ? ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាព្រះអរហន្តខីណាស្រព មានព្រហ្មចរិយៈ ប្រព្រឹត្តរួចហើយ មានសោឡសកិច្ច បានធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ ដោយលំដាប់ មានសំយោជនៈ ក្នុងភពអស់ហើយ ផុតស្រឡះហើយ ព្រោះដឹងប្រពៃ ។ ព្រះអរហន្ត ខីណាស្រពនោះ នៅសោយអារម្មណ៍ ដែលជាទីពេញចិត្ត និងមិនជាទីពេញចិត្ត សោយសុខនិងទុក្ខ ព្រោះឥន្ទ្រិយ៍ទាំងឡាយ ៥ ណា មិនមានការថ្នាំងថ្នាក់, ឥន្ទ្រិយ៍ទាំង ៥ នោះ របស់ព្រះអរហន្ត ខីណាស្រពនោះ តាំងនៅដដែល ។ ម្នាលភិក្ខុទាំងឡាយ ការអស់រាគៈ អស់ទោសៈ អស់មោហៈណា របស់ព្រះ

---

១ - ត្រៃបិដក ភាគទី ៥៣ / ទំព័រទី ៥០ ។

អរហន្ត ខីណាស្រពនោះ, ម្នាលភិក្ខុទាំងឡាយ នេះហៅថា សឧបាទិសេសនិព្វានធាតុ ។ ម្នាលភិក្ខុទាំងឡាយ ចុះអនុបាទិសេស-និព្វានធាតុ តើដូចម្តេច ? ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាព្រះអរហន្ត ។ ល ។ រួចផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ ការសោយនូវអារម្មណ៍ទាំងពួងរបស់ព្រះអរហន្តនោះ ដែលព្រះអរហន្តនោះ មិនត្រេកអរហើយ នឹងស្ងប់រម្ងាប់ ក្នុងអត្តភាពនេះឯង, ម្នាលភិក្ខុទាំងឡាយ នេះហៅថា អនុបាទិសេសនិព្វានធាតុ ។ ម្នាលភិក្ខុទាំងឡាយ និព្វានធាតុ មាន ២ យ៉ាងនេះឯង ។ លុះព្រះដ៏មានព្រះភាគទ្រង់ត្រាស់នូវសេចក្តីនុ៎ះហើយ ។ ព្រះអង្គទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសត្តមសូត្រនោះ ដូចតទៅនេះ ថា ÷

" និព្វានធាតុ ២ យ៉ាងនេះ គឺព្រះសម្មាសម្ពុទ្ធ ទ្រង់មានចក្ខុ ព្រះអង្គមិនអាស្រ័យ ( ដោយតណ្ហានិងទិដ្ឋិ ) មិនញាប់ញ័រ ( ដោយលោកធម៌ ) ទ្រង់ប្រកាសហើយ ។ ក៏ធាតុមួយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ននេះ ជាទីអស់ទៅនៃតណ្ហា ក្នុងភពជាសឧបាទិសេសៈ ។ ចំណែកធាតុ ដែលប្រព្រឹត្ត

ទៅក្នុងបរលោក ដែលជាទីរលត់ នៃភព គ្មានសល់ ដោយប្រការទាំងពួង ឈ្មោះថា អនុបាទិសេសៈ ។ ព្រះអរហន្តទាំងឡាយណា ជាអ្នកមានចិត្តរួចផុតស្រឡះហើយ ជាអ្នកអស់តណ្ហាដែលនាំសត្វទៅកាន់ភព ព្រោះដឹងនូវព្រះនិព្វាននេះ ដែលបច្ច័យតាក់តែងមិនបានហើយ, ព្រះអរហន្តទាំងនោះ ត្រេកអរហើយ ក្នុងព្រះនិព្វានជាទីអស់ទៅ ព្រោះបានធម៌មានខ្លឹម, ព្រះអរហន្តទាំងនោះ ជាអ្នកមិនញាប់ញ័រ បានលះភពទាំងពួងអស់ហើយ” ។

បាលី ចប់ ។

(១៧៩) អដ្ឋកថាឥតិវុត្តកៈ ថា “បទថា ‘ទ្វេមា’ កាត់បទជា ទ្វេ ឥមា (គឺ និព្វានធាតុ ២ យ៉ាងនេះ) ។ តណ្ហា ហៅថា វានៈ (គ្រឿងចាក់ដោត), ធម្មជាតណា ចេញហើយអំពីតណ្ហាឈ្មោះថា វានៈ ហេតុនោះ ធម្មជាតនោះ ឈ្មោះថា និព្វាន, មួយទៀត តណ្ហា ឈ្មោះថា វានៈ រមែងមិនមាន ក្នុងធម្មជាតនេះ ហេតុនោះ ធម្មជាតនេះ ឈ្មោះថា និព្វាន, មួយទៀត ការមិនមាននៃតណ្ហាឈ្មោះថា វានៈ ក្នុងធម្មជាតនេះ ដែលព្រះអរិយបុគ្គលបាន

សម្រេចហើយ ហេតុនោះ ធម្មជាតនោះ ឈ្មោះថា និព្វាន ។ និព្វាននោះឯង ឈ្មោះថា ធាតុ ព្រោះអត្ថថា មិនមែនជាសត្វ មិនមែនជីវៈ និងព្រោះអត្ថថា ទ្រទ្រង់ទុកនូវភាវៈរបស់ខ្លួន ហេតុនោះ ទើបឈ្មោះថា និព្វានធាតុ ។ ដោយបរមត្ថ ការប្លែកផ្សេងអំពីគ្នា នៃនិព្វានធាតុ រមែងមិនមាន, តែការប្លែកផ្សេងអំពីគ្នា រមែងប្រាកដដោយបរិយាយ ហេតុនោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់បានសំដៅយកនូវការប្លែកផ្សេងគ្នា ដោយបរិយាយនោះ ហើយទ្រង់ត្រាស់ ថា '**ទ្វេមា ភិក្ខវេ និព្វានធាតុយោ**' ដូច្នេះហើយ ទ្រង់ត្រាស់ ថា 'សឧបាទិសេសៈ' ដូច្នេះជាដើម ដើម្បីនឹងសំដែង នូវប្រភេទតាមដែលទ្រង់ព្រះបំណាងហើយ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យថា 'សឧបាទិសេសា' នោះ ដូចតទៅ សភាវៈណា ដែលកិលេសទាំងឡាយ មានតណ្ហាជាដើម រមែងចូលទៅប្រកាន់ខ្ជាប់ ដោយភាវៈជាផល ហេតុនោះ សភាវៈនោះ ឈ្មោះថា ឧបាទិ គឺ ខន្ធបញ្ចកៈ ។ ឧបាទិនុ៎ះឯង នៅសេសសល់ ទើបឈ្មោះថា ឧបាទិសេសៈ ។ និព្វានធម៌ រមែងប្រព្រឹត្តទៅ មួយអន្លើដោយឧបាទិសេសៈ ហេតុនោះ ទើបឈ្មោះថា សឧបាទិសេសៈ ។ និព្វានធម៌ ឈ្មោះថា អនុបាទិសេសៈ ព្រោះមិនមានឧបាទិនោះ " ។

(១៨០) អដ្ឋកថាមូលបរិយាយសូត្រ និងអដ្ឋកថាឥតិវុត្តកៈ ថា "បទថា 'អរហំ' មានសេចក្តីថា ជាអ្នកឆ្ងាយចាកកិលេស គឺជាអ្នកមានកិលេសក្នុងទីឆ្ងាយ អធិប្បាយថា ជាអ្នកលះកិលេសអស់ហើយ ៗ គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា 'ខីណាសវោ' ដូចតទៅ អាសវៈទាំងឡាយ ៤ របស់ភិក្ខុជាព្រះអរហន្ត អស់ហើយ គឺ ដែលភិក្ខុជាព្រះអរហន្តនោះ លះបានហើយ ដកកំរើងចោលហើយ ស្ងប់រម្ងាប់ហើយ មិនគួរកើតឡើងបាន គឺ ដែលភិក្ខុជាព្រះអរហន្តនោះ ដុតចោលហើយ ដោយភ្លើងគឺញាណ, ដោយហេតុនោះ ព្រះមានព្រះភាគទើបទ្រង់ត្រាស់ថា 'ព្រះខីណាស្រព' ៗ គប្បីជ្រាបវិគ្រោះ ក្នុងបទថា 'វុសិតវា' ដូចតទៅ ភិក្ខុណានៅហើយ គឺនៅចប់ស្រេចហើយ ទាំងក្នុងការនៅរួមគ្នាជាមួយគ្រូ ទាំងក្នុងអរិយមគ្គ ទាំងក្នុងធម៌ជាគ្រឿងនៅ របស់ព្រះអរិយៈ ១០ ប្រការ ហេតុនោះ ភិក្ខុនោះ ឈ្មោះថា វុសិតវា (នៅចប់ហើយ), ភិក្ខុណាមានព្រហ្មចរិយៈនៅចប់ហើយ គឺនៅចប់ស្រេចហើយ បានដល់ មានធម៌ជាគ្រឿងនៅប្រព្រឹត្តរួចហើយ គឺមានចរណៈប្រព្រឹត្តរួចហើយ ហេតុនោះ ភិក្ខុនោះ ទើបឈ្មោះថា វុសិតវា (ជាអ្នកមានព្រហ្មចរិយៈប្រព្រឹត្តរួចហើយ) ៗ គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា 'កតករណីយោ' ដូចតទៅ ព្រះសេក្ខបុគ្គល ៧ ពួក

វហួតដល់បុថុជ្ជនអ្នកមានធម៌ដ៏ល្អ ឈ្មោះថា រមែងធ្វើកិច្ចដែលគួរធ្វើ ដោយមគ្គទាំង ៤, កិច្ចដែលគួរធ្វើគ្រប់យ៉ាង គឺព្រះខីណាស្រព បានធ្វើហើយ គឺឲ្យចប់សព្វគ្រប់អស់ហើយ, កិច្ចដែលគួរធ្វើឲ្យខ្ពស់ៗទៅ ដើម្បីសម្រេចការអស់ទៅនៃសេចក្ដីទុក មិនមានសោះឡើយ ព្រោះហេតុនោះ ព្រះខីណាស្រពនោះ ទើបឈ្មោះថា មានកិច្ចដែលគួរធ្វើ បានធ្វើរួចស្រេចហើយ ៗ គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា ‘ឱហិតភារោ’ ដូចតទៅ ភារៈ ៣ គឺ ខន្ធភារៈ កិលេសភារៈ អភិសង្ខារភារៈ, ភារៈ ៣ នេះ គឺព្រះខីណាស្រពនោះ ដាក់ចុះហើយ គឺទំលាក់ចុះហើយ ទំលាក់ចោលហើយ បានដល់ ធ្វើឲ្យធ្លាក់ចុះហើយ ដោយហេតុនោះ ព្រះខីណាស្រពនោះ ព្រះអង្គទ្រង់ត្រាស់ថា ‘ជាអ្នកមានភារៈដាក់ចុះហើយ’ ៗ បទថា ‘អនុប្បត្តសទត្ថោ’ គឺជាអ្នកសម្រេចប្រយោជន៍របស់ខ្លួនដោយលំដាប់, មានពាក្យអធិប្បាយថា ‘នូវប្រយោជន៍របស់ខ្លួន’ ៗ ស័ព្ទថា ‘សទត្ថ’ នេះ ព្រះមានព្រះភាគ ទ្រង់ធ្វើអាទេស ក អក្សរឲ្យទៅជា ទ អក្សរ ៗ មួយទៀត ព្រះអរហត្ត បណ្ឌិតគប្បីជ្រាបថា ‘ប្រយោជន៍របស់ខ្លួន’ ៗ ព្រោះថា ព្រះអរហត្តនោះ ហៅថា ‘ប្រយោជន៍របស់ខ្លួន’ ព្រោះជាប្រយោជន៍របស់ខ្លួន ដោយអត្ថថា ជាប់ទាក់ទងក្នុងខ្លួន ដោយអត្ថថា មិនលះបង់ខ្លួន និងដោយអត្ថថា

ជាប្រយោជន៍ដ៏ក្រៃលែងរបស់ខ្លួន ៗ គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា 'បរិក្ខីណភវសំយោជនោ' ដូចតទៅ សំយោជនៈ ១០ យ៉ាង គឺ សំយោជនៈ គឺ កាមរាគៈ សំយោជនៈ គឺ បដិឃៈ មានះ ទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ភវរាគៈ ឥស្សា មច្ឆរិយៈ និងសំយោជនៈ គឺ អវិជ្ជា, ព្រោះថា សំយោជនៈទាំងនេះ រមែងប្រកប គឺ ចងពួកសត្វ ទុកក្នុងភពទាំងឡាយ, ន័យមួយទៀត រមែងប្រកបនូវភព ដោយភព, ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ត្រាស់ថា 'ភវសំយោជនៈ' ដូច្នេះ, ភវសំយោជនៈទាំងឡាយនេះ របស់ព្រះអរហន្ត អស់រលីងហើយ គឺ ព្រះអរហន្តនោះលះបានហើយ បានដល់ ដុតចោលហើយ ដោយភ្លើងគឺញាណ ដោយហេតុនោះ ភិក្ខុដែល ជាព្រះអរហន្តនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា 'ជាអ្នកមាន កិលេសគ្រឿងប្រកបទុក ក្នុងភពអស់រលីងហើយ' ។ បទថា 'សម្មទញ្ញា' បានដល់ ព្រោះដឹង ដោយប្រពៃ ។ សួរថា 'ពាក្យនេះ ព្រះអង្គទ្រង់ត្រាស់អធិប្បាយទុក យ៉ាងដូចម្តេច ?' ។ ព្រះអង្គទ្រង់ត្រាស់អធិប្បាយថា 'ព្រោះដឹង គឺ យល់ បានដល់ ព្រោះ ពិចារណា គឺ ត្រិះរិះ នូវអត្ថនៃខន្ធ ថាជាខន្ធ អត្ថនៃពួកអាយតនៈ ថាជាអាយតនៈ អត្ថនៃធាតុទាំងឡាយ ថាជាធាតុ អត្ថនៃសេចក្តីទុក្ខ ថាជាហេតុបៀតបៀន អត្ថនៃសមុទយៈ ថាជាដែនកើត (នៃទុក្ខ)

អត្ថនៃនិរោធ ថាជាធម៌ស្ងប់ អត្ថនៃមគ្គ ថាជា គ្រឿងឃើញ ឬនូវការប្លែកផ្សេងគ្នាជាដើម យ៉ាងនេះ ថា 'សង្ខារទាំងឡាយ ជារបស់មិនទៀងទាត់' ដូច្នេះ គឺ ព្រោះធ្វើឱ្យជាក់ច្បាស់ បានដល់ ព្រោះធ្វើឱ្យប្រាកដ ដោយប្រពៃ គឺ តាមសេចក្ដីពិត ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទ ថា 'វិមុត្តោ' ដូចតទៅ វិមុត្តិ មាន ២ យ៉ាង គឺ កិរិយាបង្អោនចូលទៅ នៃចិត្ត ១ និព្វាន ១ ។ មែនពិត ព្រះអរហន្តឈ្មោះថា រួចផុតហើយ សូម្បីដោយការរួចផុតនៃចិត្ត ព្រោះភាវៈជាអ្នកមានចិត្តរួចផុតហើយ ចាកកិលេសទាំងពួង, ឈ្មោះថា ជាអ្នករួចផុតស្រឡះហើយ សូម្បីក្នុងព្រះនិព្វាន ព្រោះជាអ្នកបង្អោនចូលទៅកាន់ព្រះនិព្វាន, ក៏ព្រោះហេតុនោះ ភិក្ខុជាព្រះអរហន្ត ទើបឈ្មោះថា ជាអ្នករួចស្រឡះហើយ ព្រោះដឹង ដោយប្រពៃ" ។

(១៨១) ដីកាមូលបរិយាយសូត្រ ថា "អត្ថកថានេះ ជាអត្ថកថានៃព្រះសូត្រ ក៏ពិតមែន, ក៏ប៉ុន្តែ ន័យដែលមកហើយ ក្នុងព្រះអភិធម្ម ជាន័យដោយត្រង់ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យកាលនឹងសំដែង ដោយអភិធម្មន័យនោះ ទើបពោល ថា 'ចត្តារោ អាសវា' ដូច្នេះ ។ ២ បទថា 'សមុច្ឆិន្នា បដិប្បស្សទ្ធា' មានសេចក្ដីថា អាសវៈ ៤ គឺព្រះអរហន្ត បានគាស់រំលើងហើយ ដោយផ្តាច់ជើងតែម្តង ក៏ទេដែរ, តាមពិត អាសវៈទាំងនោះ

ក៏ស្ងប់រម្ងាប់ទៅហើយផង ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបរួបរួមសម្បីនូវផលកិច្ច ចូលជាមួយនឹងមគ្គកិច្ច ។ ការធ្វើតាមនូវខប្រតិបត្តិ របស់គ្រូទាំងឡាយ ឈ្មោះថា ការនៅរួមជាមួយនឹងគ្រូ ព្រោះជាការញ៉ាំងសីលឲ្យបានបរិសុទ្ធ ។ ការសម្រេចនូវសម្បត្តិ គឺ អរិយមគ្គន៏ុះឯង ឈ្មោះថា ការនៅដោយអរិយមគ្គ ។ គុណធម៌ទាំងឡាយមានការលះអង្គ ៥ ចោល ជាដើម ឈ្មោះថា អរិយវាសៈ ១០ យ៉ាង ។ ព្រហ្មចរិយៈ គឺភិក្ខុប្រព្រឹត្តរួចស្រេច ហេតុនោះទើបឈ្មោះថា វុសិតៈ បានដល់ អរិយមគ្គ និងអរិយផល, ព្រហ្មចរិយៈ ដែលឈ្មោះថា វុសិតៈនោះ របស់ភិក្ខុន៏ុះ មាន ហេតុនោះ ភិក្ខុន៏ុះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា 'វុសិតវា' ដោយអំណាចនៃការប្រាថ្នានូវពាក្យពោល ដ៏ល្អប្រសើរ ។ ព្រះអដ្ឋកថាចារ្យពោលហើយនូវបរិញ្ញាកិច្ច បហានកិច្ច ភាវនាកិច្ច និងសច្ឆិកិរិយកិច្ច ដោយបទ ថា 'ករណីយំ' ។ ក៏ព្រោះករណីយកិច្ចនោះ បណ្ឌិតគប្បីជ្រាប ថា មាន ១៦ យ៉ាង ព្រោះភាវៈជាកិច្ចដែលភិក្ខុគប្បីធ្វើក្នុងសច្ចៈទាំងឡាយ ៤ ចំពោះមួយៗ ដោយមគ្គ ៤, ហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា 'ចតូហិ មគ្គេហិ ករណីយំ' ។ ក្នុងបទ ថា 'ភារា' ខន្ធ កិលេស និងអភិសង្ខារ ឈ្មោះថា ភារៈ ព្រោះអត្ថ ថា ញ៉ាំងសត្វឲ្យលិចលង់ ។ ដូចជាព្រះតម្រាស់ ដែលព្រះ

មានព្រះភាគត្រាស់ថា 'បញ្ចក្ខន្ធទាំងនោះ ជារបស់ធ្ងន់ពិត' ដូច្នេះ ។ ព្រះអរហត្តដែលឈ្មោះថា ជាប់ទាក់ទង ក្នុងខ្លួន ព្រោះទាក់ទង ក្នុងការធ្វើទុកក្នុងចិត្តនៃខ្លួនដោយប្រាជ្ញាញាណ ។ ដែលឈ្មោះថា ជារបស់ដែលមិនលះបង់ខ្លួន ព្រោះរាប់បញ្ចូលក្នុងសន្តានរបស់ខ្លួន ។ ព្រះអដ្ឋកថាចារ្យ កាលនឹងសំដែង ថា 'ព្រះអរហត្តនេះនោះ រមែងកើតឡើង ក្នុងធម៌ដែលមិនមានទោសទាំងពួង ក៏ពិតមែនហើយ, ទោះជាដូច្នោះ សេចក្ដីល្អដ៏ប្រសើរ ក៏រមែងមាន ក្នុងព្រះអរហត្តដែលជាធម៌ដ៏ប្រសើរ ដែលមានការមិនកម្រើកជាសភាព និងមានការមិនវិនាសសាបសូន្យជាធម្មតា នឹងមិនមានក្នុងធម៌ក្រៅអំពីនេះឡើយ' ដូច្នេះ ទើបពោល ថា 'អត្តនោ បរមត្ថត្តេន' ។ អធិប្បាយថា 'ដោយភាវៈជាប្រយោជន៍ដ៏ខ្ពង់ខ្ពស់' ។ ឈ្មោះថា ន័យដែលមកហើយ ក្នុងព្រះសូត្រ ជាន័យដែលមក ដោយបរិយាយ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ កាលនឹងសំដែង នូវសំយោជនៈទាំងឡាយ ដោយន័យដែលត្រង់ ទើបពោល ថា 'ឥស្សាមច្ឆរិយ-សំយោជនំ' ដូច្នេះ, ក៏ប៉ុន្តែនឹងមិនពោល ដោយពាក្យជាដើមថា 'រូបរាគៈ' ដូច្នេះឡើយ ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុង ២ បទថា 'ភវេសុ សំយោជេន្តិ' ដូចតទៅ សំយោជនៈទាំងនេះ ជាបច្ច័យនៃភពទាំងឡាយ ដែលជាទីតាំងនៃកិលេស កម្ម វិបាក រមែងចង

(ពួកសត្វ) ដោយអំណាចនៃការមិនព្រមឲ្យ ដើម្បីរលាស់ខ្លួនចេញ (ពីវដ្តៈ), ក៏កាលបើសូម្បីមានភាវៈ នៃធម៌ដទៃទៀតជាបច្ច័យនៃកិលេស កម្ម និងវិបាកនោះ, ភាវៈនៃធម៌ទាំងនោះ ជាបច្ច័យនៃកិលេស កម្ម និងវិបាកនោះ ដែលព្រះមានព្រះភាគ ទ្រង់សង្គ្រោះដោយឱរម្ភាគិយសំយោជនៈ វៀរលែងសំយោជនៈទាំងឡាយចេញ រមែងមានមិនបាន, ព្រោះហេតុនោះ ការកំណត់កម្ម ដែលញ៉ាំងសត្វឲ្យកើតក្នុងភពនោះ ៗ ជាការកំណត់ភពបាន, ចំណែកកម្មទាំងឡាយ ដែលព្រះអរហន្ត អ្នកគាស់រំលើងសំយោជនៈបានហើយ សូម្បីបានធ្វើហើយ ក៏មិនញ៉ាំងភពឲ្យកើតឡើង, គប្បីឃើញសេចក្តីនៃសំយោជនៈទាំងឡាយនោះឯងថា ជាគ្រឿងប្រកបសត្វទុក (ក្នុងភព) ដូចបានពណ៌នាមកនេះ ។

២ បទថា 'សម្មា អញ្ញាយ' មានសេចក្តីថា បណ្តាសច្ចធម៌មានទុក្ខសច្ចជាដើម សច្ចធម៌ណា ដែលខ្លួនគប្បីដឹងដោយប្រការណា ព្រោះដឹងសច្ចធម៌នោះ ដោយប្រការនោះ ដោយប្រពៃ គឺ តាមសេចក្តីពិត ដោយបញ្ញាដែលសម្បយុត្តដោយមគ្គដ៏ខ្ពង់ខ្ពស់ ដែលជាការដឹងទូទៅ ៗ ការលះបង់គ្រឿងសៅហ្មងនៃចិត្តគ្រប់យ៉ាង ឈ្មោះថា ចិត្តវិមុត្តិ, ការបង្អោនចូលទៅក្នុងនិព្វាន គឺភាវៈដែលចិត្តជាធម្មជាតបង្អោនទៅ បង្អោនចូលទៅ ឱនចូលទៅ ក្នុង

និព្វាននោះ ឈ្មោះថា និព្វានាធិមុត្តិ" ។

(១៨២) អដ្ឋកថាឥតិវុត្តកៈ ថា "២ បទថា 'តស្ស តិដ្ឋន្តេវ' មានសេចក្ដីថា កម្មដែលជាហេតុ ក្នុងភពមុន របស់ភិក្ខុដែលជាព្រះអរហន្តនោះ មិនទាន់អស់ទៅ ដរាបណា, ឥន្ទ្រិយ៍ ៥ មានចក្ខុន្ទ្រិយ៍ជាដើម ក៏រមែងស្ថិតនៅ ដរាបនោះដែរ ។ បទថា 'អវិឃាតត្តា' គឺ ព្រោះភាវៈនៃឥន្ទ្រិយ៍ទាំងនោះ នៅមិនទាន់រលត់ ដោយអំណាចនៃការរលត់ ដោយមិនកើតឡើងបាន ។ បទថា 'មនាបាមនាបំ' បានដល់ អារម្មណ៍មានរូបជាដើម ដែលជាទីប្រាថ្នា និងមិនជាទីប្រាថ្នា ។ បទថា 'បច្ចនុភោតិ' គឺ រមែងជួបប្រទះ បានដល់ រមែងបាន ។ ២ បទថា 'សុខទុក្ខំ បដិសំវេទេតិ' មានសេចក្ដីថា រមែងបាននូវសុខនិងទុក្ខ ដែលជាវិបាក ដោយទ្វារទាំងនោះ ។ ព្រះដ៏មានព្រះភាគ លុះទ្រង់សំដែងនូវខន្ធបញ្ចកៈ ដែលជាឧបាទិសេសៈ ដោយព្រះតម្រាស់មានប្រមាណប៉ុណ្ណេះហើយ ឥឡូវនេះ ដើម្បីទ្រង់សំដែងសឧបាទិសេសនិព្វានធាតុ ទើបត្រាស់ព្រះតម្រាស់ជាដើម ថា 'តស្ស យោ' ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងនិទ្ទេស នៃសឧបាទិសេសនិព្វានធាតុនោះ (ដូចតទៅ) បទថា 'តស្ស' បានដល់ ភិក្ខុនោះ គឺ ដែលជាព្រះអរហន្ត ជាអ្នកនៅមានខន្ធបញ្ចកៈ ដែលកិលេសមានតណ្ហា

ជាដើម ចូលទៅប្រកាន់យក សល់នៅ ។ បទថា 'រាគក្ខយោ' មានសេចក្តីថា ការអស់ទៅ គឺអាការៈដែលអស់ទៅ បានដល់ការមិនមាន គឺការមិនកើតឡើង ដោយចំណែកមួយ នៃរាគៈ ។ សូម្បីក្នុងបទដែលសេសសល់ ក៏ន័យនេះដែរ ។ ដោយព្រះតម្រាស់មានប្រមាណប៉ុណ្ណោះ មានអត្ថរូបដែលព្រះអង្គ ទ្រង់សំដែង ថា 'ការអស់ទៅនៃរាគៈជាដើម ឈ្មោះថា សឧបាទិសេសនិព្វានធាតុ' ។ បទថា 'ឥធេវ' គឺ ក្នុងអត្តភាពនេះប៉ុណ្ណោះ ។ បទថា 'សព្វ-វេទយិតានិ' បានដល់ វេទនាដែលជាអព្យាក្រឹត ទាំងអស់ មានសុខវេទនាជាដើម ។ ចំណែកវេទនា ដែលជាកុសលនិងអកុសល លោកលះចោលបានអស់ហើយ ក្នុងកាលមុននុ៎ះឯង ។ បទថា 'អនភិនន្ទិតានិ' បានដល់ មិនត្រេកអរហើយ ព្រោះកិលេសទាំងឡាយ មានតណ្ហាជាដើម ។ បទថា 'សីតិភវិស្សន្តិ' មានសេចក្តីថា នឹងជារបស់ត្រជាក់ ព្រោះការស្ងប់រម្ងាប់ នូវសេចក្តីខ្វល់ខ្វាយនៃសង្ខារ ដោយការស្ងប់រម្ងាប់ យ៉ាងដាច់ខាត, អធិប្បាយថា 'នឹងរំលត់ឥតសេសសល់ ដោយការរំលត់ដោយជាធម្មជាតមិនមានបដិសន្ធិ ។ មិនមែនតែវេទនាទាំងឡាយ តែម្យ៉ាងប៉ុណ្ណោះនឹងរលត់ទៅឡើយ, ក៏បញ្ចក្ខន្ធសូម្បីទាំងអស់ ក្នុងសន្តានរបស់ព្រះខីណាស្រព ក៏នឹងរលត់ទៅ គ្មានសល់ដែរ ។ ព្រះដ៏មានព្រះភាគ

ទ្រង់សំដែងធម៌ទេសនា ដោយទ្រង់ប្រាថ្នាយកវេទនាជាប្រធាន ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទាំងឡាយ តទៅៈ បទថា **'ចក្ខុមតា'** មានសេចក្ដីថា អ្នកមានចក្ខុ ដោយចក្ខុ ៥ គឺ 'ពុទ្ធចក្ខុ ធម្មចក្ខុ ទិព្វចក្ខុ បញ្ញាចក្ខុ សមន្តចក្ខុ' ។ បទថា **'អនិស្សិតេន'** មានសេចក្ដីថា មិនទ្រង់អាស្រ័យ នូវធម៌ណាមួយ ដោយអំណាចនៃទីអាស្រ័យ គឺ តណ្ហានិងទិដ្ឋិ, មួយទៀត ជាអ្នកគឺគ្រឿងចង មានគ្រឿងចងគឺរាគៈជាដើម ចងមិនបានហើយ ។ បទថា **'តាទិនា'** បានដល់ ជាអ្នកមិនញាប់ញ័រ ដោយលក្ខណៈនៃបុគ្គលអ្នកមិនញាប់ញ័រ ពោលគឺភាពជាអ្នកមានសភាពតែមួយ ក្នុងអារម្មណ៍ដែលជាទីប្រាថ្នាជាដើម គ្រប់យ៉ាង ដោយអំណាចឆឡង្គុបេក្ខា ។ បទថា **'ទិដ្ឋធម្មិកា'** គឺ មាន បានដល់ ប្រព្រឹត្តទៅ ក្នុងអត្តភាពនេះ ។ បទថា **'ភវនេត្តិសង្ខយា'** បានដល់ ព្រោះការអស់ទៅនៃតណ្ហាដែលនាំសត្វទៅកាន់ភព ។ បទថា **'សម្បរាយិកា'** មានសេចក្ដីថា មានក្នុងសម្បរាយភព គឺ ក្នុងកាលដែលជាចំណែកដទៃទៀតអំពីកាលទំលាយខន្ធទៅ ។ បទថា **'យម្ហិ'** គឺ ក្នុងអនុបាទិសេស-និព្វានឯណា ។ បទថា **'ភវានិ'** ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយលិង្គវិបល្លាស ។ ឱបបត្តិភពទាំងឡាយ ឥតមានសល់ រមែងរលត់ទៅ គឺ មិនប្រព្រឹត្តទៅ ដោយប្រការទាំងពួង ។

បទថា 'តេ' បានដល់ ជនទាំងនោះ មានចិត្តរួចស្រឡះហើយ យ៉ាងដូច្នេះ ។ បទថា 'ធម្មសារាធិគមា' មានសេចក្ដីថា ព្រោះសម្រេចព្រះអរហត្ត ដែលឈ្មោះថាជាសារៈ ក្នុងធម៌ទាំងឡាយ ព្រោះធម្មវិន័យនេះ មានវិមុត្តិជាសារៈ ។ បទថា 'ខយេ' មានសេចក្ដីថា ជាអ្នកត្រេកអរ គឺ ត្រេកអរក្រៃលែងហើយ ក្នុងព្រះនិព្វាន ដែលជាធម៌ជាទីអស់ទៅ នៃរាគៈជាដើម ។ម្យ៉ាងទៀត ធម្មជាតដែលឈ្មោះថា ធម្មសារៈ ព្រោះវិគ្រោះថា 'ជាសារៈ ក្នុងសភាវៈធម៌ទាំងឡាយ ព្រោះភាវៈជាធម្មជាតទៀងទាត់ និង ព្រោះភាវៈជាធម្មជាតប្រសើរ គឺ ព្រះនិព្វាន ។ សមដូចជាព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុក យ៉ាងនេះថា 'បណ្ដាធម៌ទាំងឡាយ វិរាគៈជាធម៌ប្រសើរ' ដូច្នេះ និង ថា 'វិរាគៈ បណ្ឌិតពោលថា ប្រសើរបំផុតជាងធម៌ទាំងនោះ' ដូច្នេះ ។ ឈ្មោះថា ជាអ្នកត្រេកអរហើយ ក្នុងធម៌ជាទីអស់ទៅ គឺ ក្នុងអនុបាទិសេសនិព្វាន ដែលជាទីអស់ទៅនៃសង្ខារទាំងពួង ព្រោះហេតុសម្រេចនូវធម្មសារៈនោះ ។ បទថា 'បហំសុ' ប្រែថា លះបង់ចោលហើយ ។ បទថា 'វេ' គ្រាន់តែជានិបាត " ។

(១៨៣) និព្វាននោះ មាន ២ យ៉ាង ដោយបរិយាយ ដោយប្រការដូច្នេះ ។ សូម្បីក្នុងអដ្ឋកថារថវិនីតសូត្រ ព្រះអដ្ឋកថាចារ្យ

ពោល ថា “ បរិនិព្វានដែលមិនមានបច្ច័យ ឈ្មោះថា អនុបាទាបរិ-និព្វាន ៗ ម្យ៉ាងទៀត ឧបាទាន ២ យ៉ាង គឺ ឧបាទានគឺការប្រកាន់ខ្ជាប់ ១ ឧបាទានគឺបច្ច័យ ១ ៗ ឧបាទាន ៤ យ៉ាង មានកាមុបាទានជាដើម ឈ្មោះថា ឧបាទានគឺការប្រកាន់ខ្ជាប់ ៗ បច្ច័យទាំងឡាយដែលព្រះមានព្រះភាគទ្រង់ត្រាស់ យ៉ាងនេះ ថា ‘ សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ’ ដូច្នេះជាដើម ឈ្មោះថា ឧបាទានគឺបច្ច័យ ៗ បណ្ដាឧបាទាន ២ យ៉ាងនោះ អាចារ្យទាំងឡាយអ្នកពោលឧបាទានគឺការប្រកាន់ខ្ជាប់ តែងពោលព្រះអរហត្តផលដែលមិនប្រកាន់យកធម៌ណាមួយឡើយ សូម្បីក្នុងឧបាទាន ៤ យ៉ាងដោយឧបាទានណាមួយ ប្រព្រឹត្តទៅ ថា ‘ ឧបាទាបរិនិព្វាន ’ ក្នុងពាក្យថា ‘ អនុបាទាបរិនិព្វានំ ’ ៗ មែនពិត ព្រះអរហត្តផលនោះ មិនមែនជាធម្មជាត សម្បយុត្តដោយឧបាទាន ប្រកាន់យកនូវធម៌ណាមួយឡើយ និងលោកពោល ថា ‘ បរិនិព្វាន ’ ព្រោះកើត ក្នុងទីបំផុតនៃការរលត់អស់ទៅ នៃកិលេសទាំងឡាយ ៗ ចំណែកពួកអាចារ្យអ្នកពោលឧបាទានគឺបច្ច័យ ពោលអមតធាតុ ដែលមិនកើតឡើង ដោយអំណាចបច្ច័យ ដែលបច្ច័យមិនតាក់តែងហើយនុ៎ះឯង ថា ‘ អនុបាទាបរិនិព្វាន ’ ដូច្នេះ ” ៗ

(១៨៤) ដីការថេរីគសូត្រនោះ ថា “ ព្រះអដ្ឋកថាចារ្យ

ពោលអនុបាទិសេសបរិនិព្វាន ដោយបទ ថា 'អប្បច្ចយបរិនិព្វានំ' ។ ឥឡូវនេះ ដើម្បីនឹងសំដែងអនុបាទាបរិនិព្វាន សូម្បីដោយប្រការដទៃ ព្រះអដ្ឋកថាចារ្យ ទើបពោលពាក្យជាដើម ថា 'ទ្វេ វា' ។ បណ្ដាឧបាទាន ២ យ៉ាងនោះ ឧបាទានដែលជាតួ នៃការប្រកាន់មាំ ឈ្មោះថា គហណុបាទាន ។ ដោយហេតុនោះ ទើបលោកពោលថា 'មានកាមុបាទានជាដើម' ។ លោកពោលបច្ច័យ គ្រប់យ៉ាង ដោយបទ ថា 'បច្ចយុបាទានំ' ។ ក៏បច្ច័យនោះ រមែងចូលទៅប្រកាន់យក គឺ កាន់យកនូវផលរបស់ខ្លួន ដោយអំណាចឧបាទាន ហេតុនោះ បច្ច័យនោះ ទើបលោកពោល ថា 'ឧបាទាន' ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា 'បច្ចយុបាទានំ នាម ។ បេ ។ បច្ចយា' ដូច្នេះ ។ ពួកអាចារ្យអ្នកពោលនូវឧបាទានគឺការប្រកាន់មាំ រមែងពោលអរហត្តផល ថា 'អនុបាទា-បរិនិព្វាន' ព្រោះព្រះបាលី ថា 'ចិត្តរមែងរួចផុត អំពីអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ' ដូច្នេះ ។ បទថា 'ន ច ឧបាទាន-សម្បយុត្តំ' មានសេចក្ដីថា ព្រះអរហត្តផលនោះ មិនមែនជាធម្មជាត ប្រកបដោយឧបាទានទាំងឡាយ គឺប្រព្រឹត្តទៅព្រមដោយឧបាទានទាំងឡាយ សូម្បីដោយអំណាចដែលធ្លាក់ទៅ ក្នុងឧបាទានណាមួយ ហើយប្រកាន់យកនូវធម៌ណាមួយឡើយ ។ ច្រើនបទ ថា

'កញ្ចិ ធម្មំ ឧបាទិយតិ' មានសេចក្ដីថា រមែងប្រកាន់យកដោយអំណាចការធ្វើ នូវធម៌ណាមួយឲ្យជាអារម្មណ៍ក៏ទេ ។ បទថា 'បរិនិព្វុតន្តេ' មានសេចក្ដីថា ព្រោះភាវៈជាធម្មជាតកើត ក្នុងទីបំផុតនៃការរលត់អស់នៃកិលេស ដែលមគ្គដ៏ប្រសើរគប្បីធ្វើ" ។

(១៨៥) ព្រះអរហត្តផលនុ៎ះឯង ឈ្មោះថា និព្វាន សូម្បីក្នុងមង្គលបទថា 'និព្វានសច្ឆិកិរិយា' នេះ ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យទើបពោល ក្នុងអដ្ឋកថា ថា "ព្រះអរហត្តផល ព្រះដ៏មានព្រះភាគ អធិប្បាយហើយថា 'និព្វាន' ក្នុងមង្គលខនេះ ។ មែនពិត ព្រះអរហត្តផលនោះឯង ព្រះអង្គទ្រង់ត្រាស់ថា 'និព្វាន' ព្រោះជាធម្មជាត ចេញចាកតណ្ហា ដែលដឹងបានហើយថា វានៈ ព្រោះរួបរឹតនូវគតិទាំង ៥ ទុក ។ ចំណែកការធ្វើព្រះនិព្វានក្រៅអំពីនេះ ឲ្យជាក់ច្បាស់ សម្រេចបាន ដោយការឃើញអរិយសច្ចទាំងឡាយនុ៎ះឯង, ដោយហេតុនោះ និព្វានក្រៅពីនេះនោះ ទើបព្រះអង្គមិនបានអធិប្បាយ ក្នុងមង្គលខនេះ" ។

បណ្ដាបទទាំងនោះ បទថា "បញ្ចគតិវានេន" មានសេចក្ដីថា ព្រោះចងរួបរឹតនូវគតិទាំង ៥ ទុក ។

(១៨៦) ចំណែកក្នុងដីកាអភិធម្មត្ថសង្គហៈ ព្រះដីកាចារ្យពោល ថា "ធម្មជាតណា ចេញហើយ ចាកតណ្ហា ពោលគឺវានៈ

ព្រោះចងរឹត គឺព្រោះរួបរឹតនូវភពតូចធំទុក ហេតុនោះ ធម្មជាតនោះ ឈ្មោះថា និព្វាន ដែនចេញចាកតណ្ហា, ម្យ៉ាងទៀត ភ្លើងកិលេស គឺរាគៈជាដើម រមែងរលត់ទៅ ដោយបទនុ៎ះ ហេតុនោះ បទនុ៎ះ ឈ្មោះថា និព្វាន ជាគ្រឿងរលត់ភ្លើងគឺកិលេស" ។

អនុដីកាឈ្មោះមណិសារមញ្ជុសា ថា " បទថា '**ភវាភវំ**' បានដល់ ភពតូចនិងភពធំ ដោយអំណាចនៃទុគ្គតិនិងសុគតិ និងដោយអំណាចភពថោកទាបនិងភពថ្លៃថ្លា ។ មែនពិត អ អក្សរ មានសេចក្ដីចំរើនជាអត្ថ ក៏រមែងឃើញបាន ដូចក្នុងប្រយោគ ថា '**អសេខា ធម្មា**' ជាដើម ។ ព្រោះហេតុនោះ ភពធំ លោកហៅថា '**អភវៈ**' ។ ដោយបទ ថា '**វិននតោ**' នេះ ព្រះដីកាចារ្យ រមែងសំដែងនូវសេចក្ដីថា 'ធម្មជាតណា រមែងរួបរឹតនូវភពតូចនិងភពធំទុក គឺ រមែងចងរឹត ដោយអំណាចការញ៉ាំងសត្វឲ្យប្រព្រឹត្តទៅ ក្នុងភពខាងក្រោមនិងភពខាងលើ ហេតុនោះ ធម្មជាតនោះ ឈ្មោះថា វានៈ ។ បទថា '**និក្ខន្តំ**' គឺ កន្លងទៅហើយ ដោយអំណាចការកន្លងនូវវិស័យ ។ កាលបើគប្បីនឹងពោល ថា '**វាននិ**' ដូច្នេះ, ព្រះដីកាចារ្យពោល ថា '**និព្វានំ**' ដោយអំណាច នៃការត្រឡប់អក្សរខាងដើម និងខាងចុង ដោយនិរុត្តិន័យ ដែលលោកពោលទុកហើយ ថា 'ការចុះអក្សរ ការផ្លាស់

អក្សរ ដោយបរិភាសសូត្រ ថា 'លិង្គដែលខ្ញុំបានតាំងទុកនិងចុះទុក ព្រោះមិនខុសអំពីព្រះតម្រាស់ នៃព្រះជិនស្រីនោះ' ។ បទថា 'និព្វាតិ' មានសេចក្តីថា រមែងចូលទៅស្ងប់រម្ងាប់ គឺ រលត់ ដោយការរលត់ ដោយគ្មានសេសសល់ ។ បទថា 'ឯតេន' យោគ **បទេន** ប្រែថា ដោយបទនុ៎ះ ។ ព្រះដីកាចារ្យ រមែងសង្គ្រោះនូវភ្លើងទាំងឡាយ មានភ្លើងគឺ ទោសៈ, មោហៈ, ជាតិ, ជរានិងមរណៈជាដើម ដោយ **អាទិ** ស័ព្ទ ។

ក៏ក្នុងបទថា 'និព្វានំ' នេះ គប្បីជ្រាបសេចក្តីប្លែកផ្សេងគ្នា ដូចតទៅនេះ ថា 'ក្នុងវិកប្បទី ១ **វិ** ធាតុ ចុះក្នុងអត្ថថា ចងរឹត' **វាន** ស័ព្ទ ជាកត្តុសាធនៈ, ចំណែក **និព្វាន** ស័ព្ទ ជាបញ្ចមី តប្បុរិសសមាស ។ ក្នុងវិកប្បទី ២ **វា** ធាតុ មាន និ ជាបទដើម ចុះក្នុងអត្ថថា ចូលទៅស្ងប់ ព្រោះលោកអ្នកប្រាជ្ញខាងអក្សរសាស្ត្រ សូម្បីកាលលោកពោលថា '**វា** ធាតុ ប្រព្រឹត្តទៅក្នុងការទៅ និងការចងរឹត ក៏ពោលថា 'ព្រោះថា ធាតុទាំងឡាយ មានអត្ថជាអនេក' ។ ចំណែក **និព្វាន** ស័ព្ទ ជាករណសាធនៈ" ។

(១៨៧) ក៏ពួក ៣ នៃធម៌មានធម៌ជាទីអស់ទៅ នៃរាគៈជាដើម ជាឈ្មោះ នៃព្រះអរហត្តនុ៎ះឯង ។ ក្នុងភាវៈនៃធម៌ទាំង

៣ ជាឈ្មោះ នៃអរហត្តនោះ មានព្រះបាលី ក្នុងជម្ពុខាទកសំយុត្ត ក្នុងសឡាយតនវគ្គ ដូចតទៅនេះ ថា " បរិព្វាជក ឈ្មោះជម្ពុខាទកៈ អង្គុយហើយ ក្នុងទីដ៏សមគួរ បានពោលហើយ នូវពាក្យនេះ នឹងព្រះសារីបុត្រដ៏មានអាយុ ថា 'បពិត្រព្រះសារីបុត្រដ៏មានអាយុ ព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា ' និព្វាន និព្វាន ' ដូច្នេះ, បពិត្រព្រះសារីបុត្រដ៏មានអាយុ តើព្រះនិព្វាន យ៉ាងដូចម្តេចទៅ ? " ។ ព្រះសារីបុត្រ បានពោលពាក្យនេះ នឹងបរិព្វាជកនោះ ថា "ម្នាលអ្នកដ៏មានអាយុ ការអស់ទៅនៃរាគៈ ការអស់ទៅនៃទោសៈ ការអស់ទៅនៃមោហៈ ឯណា, កិរិយាអស់ទៅ នៃរាគៈជាដើមនេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅថា ' និព្វាន ' ដូច្នេះ " ។

ព្រះបាលីក្នុងនិព្វានសូត្រ ចប់ ។

សូម្បីពាក្យ ថា " ជម្ពុខាទកសូត្រ " ក៏ជាឈ្មោះ នៃនិព្វានសូត្រនុ៎ះឯង ។

(១៨៨) បរិព្វាជកឈ្មោះជម្ពុខាទកៈ បានពោលពាក្យនេះ នឹងព្រះសារីបុត្រ ថា "បពិត្រព្រះសារីបុត្រដ៏មានអាយុ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា 'ព្រះអរហត្ត ព្រះអរហត្ត ' ដូច្នេះ, បពិត្រព្រះសារីបុត្រដ៏មានអាយុ តើព្រះអរហត្ត ដូចម្តេចទៅហ្ន៎ ? " ។

ព្រះសារីបុត្រ បានពោលពាក្យនេះ នឹងបរិព្វាជកនោះ ថា “ ម្នាលអ្នកដ៏មានអាយុ ការអស់ទៅនៃរាគៈ ការអស់ទៅនៃទោសៈ ការអស់ទៅនៃមោហៈ ឯណា, កិរិយាអស់ទៅនៃរាគៈជាដើមនេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅថា ‘ អរហត្ត ’ ដូច្នេះ ” ។

ព្រះបាលីក្នុងអរហត្តសូត្រ ចប់ ។

(១៨៩) អដ្ឋកថាជម្ពុខាទកសូត្រ ថា “ ២ បទថា ‘ **ជម្ពុខាទកោ បរិព្វាជកោ** ’ បានដល់ បរិព្វាជកអ្នកស្លៀកសំពត់ ដែលជាក្មួយរបស់ព្រះថេរៈ អ្នកមានឈ្មោះយ៉ាងដូច្នោះ ។ បទថា ‘ **រាគក្ខយោ** ’ មានសេចក្តីថា រាគៈ មកដល់ព្រះនិព្វានហើយ ក៏អស់ទៅ, ព្រោះហេតុនោះ និព្វាន ព្រះសារីបុត្រ ទើបហៅថា ‘ ធម៌ជាទីអស់ទៅនៃរាគៈ ’ ។ សូម្បីក្នុងធម៌ជាទីអស់ទៅនៃទោសៈនិងមោហៈ ក៏ន័យនេះ ដូចគ្នាដែរ ។ ចំណែកសកវាទយាចារ្យណា គប្បីពោល នូវគុណត្រឹមតែធម៌ជាទីអស់ទៅនៃកិលេស ថា ‘ និព្វាន ’ ដោយសូត្រនេះឯង, សកវាទយាចារ្យនោះ គឺបរវាទយាចារ្យ គប្បីពោល ថា ‘ កិលេស របស់បុគ្គលណាអស់ទៅ ?, របស់ខ្លួន ឬ របស់បុគ្គលដទៃ ? ” ។ សកវាទយាចារ្យនោះ នឹងពោល ថា ‘ របស់ខ្លួន ’ ដោយពិត ។ លំដាប់នោះ សកវាទយាចារ្យនោះ គប្បីត្រូវគេចោទសួរ ថា ‘ អ្វីជាអារម្មណ៍

របស់ គោត្រភូញ្ញាណ ? ’ ។ សកវាទយាចារ្យ កាលដឹង ក៏នឹងពោល ថា ‘ និព្វាន ’ ។ សកវាទយាចារ្យនោះ គប្បីត្រូវគេចោទសួរថា ‘ ក៏ក្នុងខណៈនៃគោត្រភូញ្ញាណ កិលេសទាំងឡាយ អស់ហើយ, កំពុងតែអស់, នឹងអស់ឬ ? ’ ។ សកវាទយាចារ្យនោះនឹងពោល ថា ‘ កិលេស គឺនរណា មិនគួរពោល ថា ‘ អស់ហើយ ’ ឬថា ‘ កំពុងអស់ ’ តែគួរពោល ថា ‘ នឹងអស់ ’ ។ សកវាទ-យាចារ្យគប្បីត្រូវគេចោទសួរ ថា ‘ ក៏កាលបើកិលេសទាំងនោះ មិនទាន់អស់នៅឡើយ, គោត្រភូញ្ញាណ នឹងធ្វើនូវធម៌ជាទីអស់ទៅនៃកិលេស ឲ្យជាអារម្មណ៍បាន យ៉ាងដូចម្ដេច ? ’ ។ កាលបើបរវាទយាចារ្យពោល យ៉ាងដូច្នេះ, សកវាទយាចារ្យនឹងជាអ្នកគ្មានពាក្យឆ្លើយតប ដោយពិត ។ ក៏គោត្រភូញ្ញាណនុ៎ះ គប្បីប្រកបដោយមគ្គញ្ញាណផងដែរ ។ ព្រោះថា សូម្បីក្នុងខណៈនៃមគ្គចិត្តកិលេសទាំងឡាយ នរណាក៏នឹងពោលមិនបាន ថា ‘ អស់ហើយ ’ ថា ‘ នឹងអស់ ’ ដូច្នេះ, មួយទៀត កាលបើកិលេសទាំងឡាយមិនទាន់អស់ហើយនុ៎ះឯង, ធម៌ជាទីអស់ទៅនៃកិលេស រមែងជាអារម្មណ៍មិនបានឡើយ ។ ព្រោះហេតុនោះ គួរទទួលយកពាក្យនេះ ថា ‘ រាគៈជាដើម មកដល់ធម្មជាតណាហើយ រមែងអស់ទៅ, ធម្មជាតនោះ ឈ្មោះថា និព្វាន ’ ។ ប៉ុន្តែ និព្វាននេះនោះ មិនមែន

គ្រាន់តែជាធម៌ជាទីអស់ទៅ នៃកិលេសប៉ុណ្ណោះទេ ព្រោះភាវៈជាធម្មជាតដែលព្រះមានព្រះភាគទ្រង់សង្គ្រោះ ថា 'ធម៌មិនមានរូប' ដូច្នេះ ទុកក្នុងធម៌ពួក ២ ជាអាទិ៍ ថា 'ធម៌មានរូប, ធម៌មិនមានរូប' ដូច្នេះ" ។

(១៩០) ដីកាជម្ពូខាទកសូត្រនោះ និងដីកាអាយតនវិភង្គ ថា "ក្នុងពាក្យនេះ ថា 'និព្វានំ អាគម្ម' មានវិនិច្ឆ័យដូចតទៅនេះ : បទថា 'អាគម្ម' មានសេចក្តីថា ព្រោះការធ្វើឱ្យជាក់ច្បាស់ដោយមគ្គ របស់ព្រះអរិយបុគ្គលអ្នកធុញទ្រាន់ ក្នុងសង្ខារទាំងពួងទាំងឡាយ អ្នកបង្អោនចូលទៅ ក្នុងវិសង្ខារ (និព្វាន) មានចិត្ត គឺគោត្រភូញាណឱ្យចម្រើនហើយ ។ មែនពិត មគ្គពោលគឺធម៌ជាគ្រឿងសម្រេចនិព្វាននោះ ដែលគោត្រភូញាណ ធ្វើឱ្យជាក់ច្បាស់អាស្រ័យនិព្វាន ដែលជាអារម្មណប្បច្ច័យ ស្ថិតនៅក្នុងនិព្វាននោះ ដែលជាអធិប្បតិប្បច្ច័យនុ៎ះឯង ដែលឈ្មោះថា ជាទីពឹងពំនាក់ព្រោះភាវៈជាធម៌ មានសេចក្តីស្រាលចិត្ត យ៉ាងក្រៃលែង និងព្រោះភាវៈជាគតិ របស់បុគ្គលអ្នកមានសង្ខាររួចផុតហើយ អស់ទៅ តែងញ៉ាំងកិលេស មានរាគៈជាដើម ឱ្យអស់ទៅ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា 'រាគៈមកដល់និព្វាននោះ រមែងអស់ទៅ' ព្រោះកិលេសទាំងឡាយ មានរាគៈជាដើម មិនមានការ

សម្រេចនូវកិរិយារលត់ទៅ ដោយការមិនកើតឡើង ព្រោះមិនមានការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននោះ " ។

(១៩១) អនុដីកា ថា " បទថា 'វិសង្ខារនិន្នស្ស' គឺជាអ្នកបង្អោនចូលទៅក្នុងនិព្វាន ។ បទថា 'វិនិមុត្តសង្ខារស្ស' មានសេចក្តីថា ក្នុងព្រះនិព្វានដែលជាទីពឹងពំនាក់ ដោយភាវៈជាធម៌មានសេចក្តីស្រាលចិត្ត យ៉ាងក្រៃលែង និងដោយភាវៈជាគតិនៃបុគ្គលអ្នកឈ្មោះថា មានសង្ខាររួចផុតស្រឡះហើយ ដោយល្អ ព្រោះមានមុខព្រម ដោយសមុច្ឆេទវិមុត្តិ និងបដិប្បស្សទ្ធិវិមុត្តិ និងព្រោះលះឆន្ទរាគៈ ដែលជាប់ទាក់ទងនឹងសមុច្ឆេទវិមុត្តិ និងបដិប្បស្សទ្ធិវិមុត្តិនោះ, សមដូចជាព្រះឧបាលីពោល ថា 'និព្វានជាគតិរបស់ព្រះអរហន្ត' ។ ព្រះបាលី ថា 'ឋិតិភាវេន' ដូច្នេះក៏មានផងដែរ ។ បទថា 'តំសច្ឆិករណាភាវេ' គឺ ព្រោះមិនមានការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននោះ " ។

(១៩២) ដីកាជម្ពុខាទកសូត្រ ថា " ២ បទថា 'ឥមិនា វ សុត្តេន' មានសេចក្តីថា សកវាទយាចារ្យ គប្បីពោលនូវគុណគ្រាន់តែធម៌ជាទីអស់ទៅ នៃកិលេស ថា 'និព្វាន' ព្រោះភាវៈ នៃព្រះនិព្វានមកហើយ ក្នុងព្រះសូត្រ ដោយន័យ ថា 'រាគក្ខយោ' ដូច្នេះជាដើម ដោយជម្ពុខាទកសូត្រនេះឯង ។ ព្រោះភាវៈ ដែល

លោកពោលហើយ ដោយមិនខុសប្លែកគ្នា ថា ‘គុណត្រឹមតែជាធម៌អស់ទៅនៃកិលេស ’ ដូច្នេះ ទើបព្រះអដ្ឋកថាចារ្យពោល ថា ‘របស់បុគ្គលណា ’ ដូច្នេះ ។ សកវាទយាចារ្យ នឹងពោល ថា ‘របស់ខ្លួន ’ ដោយពិត, (ព្រោះ) ការសម្រេចព្រះនិព្វាន របស់បុគ្គលដទៃ ដោយការអស់ទៅ នៃកិលេសរបស់បុគ្គលដទៃ មិនសមគួរសោះឡើយ ដូច្នេះឯង ។ ការសម្រេចកិរិយាអស់ទៅ នៃកិលេសក្នុងខណៈនៃគោត្រភូញាណ ដោយការធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ត្រឹមត្រូវពិតមែនហើយ ហេតុនោះ ព្រះអដ្ឋកថាចារ្យទើបពោលនូវពាក្យជាដើម ថា ‘កិម្បន តេសុ អក្ខីណេសុយេវ ’ ដូច្នេះ ។

បើអ្នកសួរគប្បីសួរ ថា ‘អ្នកណាមិនអាច ដើម្បីនឹងពោល ថា ‘ធម៌ជាទីអស់ទៅនៃកិលេស គឺព្រះអរិយបុគ្គលបានសម្រេចហើយ ដោយលំដាប់ ដោយហេតុត្រឹមតែ ធ្វើឲ្យជាអារម្មណ៍ ’ ដូច្នេះ មិនមែនទេឬ ?, ព្រោះថា ចិត្តរមែងគោងយក នូវអារម្មណ៍ដែលកន្លងទៅហើយ និងមិនទាន់មកដល់ជាដើមគ្រប់យ៉ាង, នឹងយឹតគោងយកនូវអារម្មណ៍ ដែលសម្រេចហើយតែប៉ុណ្ណោះក៏ពុំមែន” ។

អ្នកឆ្លើយគប្បីឆ្លើយ ថា ‘សូម្បីគោត្រភូញាណ នឹងមិនប្រារព្ធនូវភាវៈនៃកិលេសមានការមិនកើតឡើងជាធម្មតា ដែលមគ្គគប្បីធ្វើប្រព្រឹត្តទៅ ព្រោះបុគ្គលអ្នកមិនទាន់បានសម្រេចព្រះនិព្វាន មិនមាន

ញាណមានព្រះនិព្វានជាអារម្មណ៍ឡើយ ។ ព្រោះព្រះនិព្វានមិនដូចជាធម៌ដទៃទៀតទេ ។ ក៏ព្រះនិព្វាននោះ នរណាដែលមិនទាន់បានសម្រេច ក៏មិនអាចដើម្បីនឹងយឹតតោង (ឲ្យជាអារម្មណ៍) បានឡើយ ព្រោះព្រះនិព្វាននោះ ជាធម៌ជ្រាលជ្រៅក្រៃលែងណាស់ ។ ព្រោះហេតុនោះ ព្រះនិព្វាននោះ គប្បីជាភាវៈជាសភាពជ្រាលជ្រៅកន្លងផុតនូវសភាវៈ ដែលប្រព្រឹត្តទៅ ក្នុងកាលទាំង ៣ ដែលគោត្រភូញាណគប្បីសម្រេច, ម្យ៉ាងទៀត ការអស់ទៅនៃកិលេសដែលកើតឡើងមុនគេជាង គោត្រភូញាណ គប្បីមានដល់បុគ្គលអ្នកប្រាថ្នាគុណត្រឹមតែធម៌ជាទីអស់ទៅនៃកិលេស ។ ហេតុនោះព្រះអដ្ឋកថាចារ្យ ទើបពោលថា 'កាលបើកិលេសទាំងឡាយ មិនទាន់អស់នៅឡើយទេ, គោត្រភូញាណ រមែងធ្វើនូវធម៌ជាទីអស់ទៅនៃកិលេស ឲ្យជាអារម្មណ៍បាន (យ៉ាងដូចម្តេច ?) 'ដូច្នេះ ។ ក៏កាលបើកិរិយាធ្វើ នូវធម៌ជាទីអស់ទៅនៃកិលេស ដែលមិនទាន់បានសម្រេច ឲ្យជាអារម្មណ៍មាន, សូម្បីចិត្តទាំងឡាយ ក៏គប្បីយឹតតោងបានមុនគោត្រភូញាណ 'ដូច្នេះ ។ ពាក្យជាអាទិ៍ថា 'តស្មា' ជាពាក្យដែលពោលបញ្ជាក់នូវសេចក្តី ដែលលោកបានពោលហើយនុ៎ះឯង ។ ប៉ុន្តែព្រះនិព្វាននេះនោះ (មិនមែនគ្រាន់តែជាធម៌ជាទីអស់ទៅនៃកិលេសប៉ុណ្ណោះទេ ព្រោះភាវៈនៃព្រះនិព្វាននោះ គឺព្រះ

មានព្រះភាគទ្រង់សង្គ្រោះ ថា 'ជាធម៌មិនមានរូប' ដូច្នេះ ទុកក្នុងធម៌ពួក ២ ថា 'ធម៌មានរូប, ធម៌មិនមានរូប' ដូច្នេះជាដើម ) ។ គប្បីឃើញការសង្គ្រោះ នូវធម៌ទាំងឡាយមានលោកុត្តរធម៌ ដែលមិនមានអាសវៈជាដើម ដោយ **អាទិ**·សព្ទ ក្នុងពាក្យបាលី ថា **អរូបិនោ ធម្មាតិអាទីសុ**' ។ ចំណែកភាវៈ នៃព្រះនិព្វាននោះជាបរិនិប្ផន្នធម៌ ព្រះដ៏មានព្រះភាគទ្រង់សំដែង ដោយការប្រកាន់យកនូវភាវៈជាធម៌មានធម៌មិនមានរូបជាដើម ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា 'មិនមែនគ្រាន់តែជាធម៌ជាទីអស់ទៅនៃកិលេសប៉ុណ្ណោះទេ' ។ មែនពិត ភាវៈនៃព្រះនិព្វានមានគុណច្រើន ព្រោះភាវៈជាគុណជាតត្រឹមតែ ជាធម៌ជាទីអស់ទៅនៃកិលេស រមែងត្រឹមត្រូវ, កិលេសមានប្រមាណប៉ុនណា រមែងអស់ទៅ, ព្រះនិព្វាន ក៏មានប្រមាណប៉ុណ្ណោះដែរ ហេតុនោះ ភាវៈនៃព្រះនិព្វាន ជាសភាពជ្រាលជ្រៅជាដើម ព្រោះជ្រាលជ្រៅចុះទៅមិនដល់ និងភាវៈនៃព្រះនិព្វាន ជាសភាពដែលបច្ច័យតាក់តែងមិនបានជាដើម មិនគប្បីមាន ។ ក៏ភាវៈនៃព្រះនិព្វានជាសភាពជ្រាលជ្រៅជាដើមនោះ បណ្ឌិតបានពោលហើយ ។ ព្រោះហេតុនោះ គប្បីជឿភាវៈនៃព្រះនិព្វាននោះ ថា ជាទីរលត់អស់ ។ ក៏គប្បីដល់នូវការយល់ព្រម ក្នុងអធិការនេះ ថា 'ក៏ញាណមានធម៌

ជាអារម្មណ៍នៃធម៌ ពោលគឺធម្មារម្មណ៍ រមែងលះកិលេសទាំងឡាយ ដោយអំណាចការកាត់ផ្តាច់ ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះនិព្វាននោះ គឺជាទីបំផុតនៃសភាវៈ ដែលចាត់ថាជាបរិនិប្ផន្នធម៌ ដោយប្រការដូច្នេះ " ។

(១៩៣) ចំណែកការពណ៌នាអំពីព្រះនិព្វានមានច្រើន មកហើយ ដោយពិស្តារ ក្នុងអដ្ឋកថាអាយតនវិភង្គ ។

អដ្ឋកថាអរហត្តសូត្រ ថា "ព្រះអរហត្ត រមែងកើតឡើង ក្នុងទីបំផុតនៃការអស់ទៅ នៃរាគៈ ទោសៈ និងមោហៈ ទាំងឡាយ ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះសារីបុត្តត្ថេរ ទើបពោលព្រះអរហត្តថា 'ធម៌ជាទីអស់ទៅនៃរាគៈ ធម៌ជាទីអស់ទៅនៃទោសៈ ធម៌ជាទីអស់ទៅនៃមោហៈ' ដូច្នេះ " ។

អត្ថទាំង ៣ មានធម៌ជាទីអស់ទៅនៃរាគៈជាដើម រមែងជាឈ្មោះ របស់ព្រះអរហត្តពិត ដោយប្រការដូច្នេះ, ព្រោះហេតុនោះ អត្ថទាំង ៣ មានធម៌ជាទីអស់ទៅនៃរាគៈជាដើម រមែងជាឈ្មោះ របស់ព្រះអរហត្តពិត យ៉ាងណាមិញ, សូម្បីពាក្យ ថា 'និព្វាន' នេះ ក៏គប្បីជ្រាប ថា 'ជាឈ្មោះ របស់ព្រះអរហត្ត' យ៉ាងដូច្នោះដែរ ។ ការសម្រេចក្តី ការពិចារណាក្តី នូវព្រះនិព្វាននោះ ឈ្មោះថា កិរិយាធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន តាមដែលបានពោលមកហើយ ។

ការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាននោះ គប្បីជ្រាប ថា " ជាមង្គល " ព្រោះជាហេតុរស់នៅជាសុខក្នុងបច្ចុប្បន្ន ។ ក៏អត្តភាព បុគ្គល គប្បីឃើញជាក់ច្បាស់ លោកហៅថា ' ទិដ្ឋធម្ម ' ក្នុងពាក្យ ថា ' **ទិដ្ឋធម្មសុខវិហារហេតុតោ** ' នេះ, ការដល់ព្រមដោយព្រះអរហត្តផល ដែលជាធម៌ជាគ្រឿងនៅជាសុខ ក្នុងអត្តភាពនោះ ឈ្មោះថា ធម៌ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន, ការសម្រេចព្រះអរហត្ត ឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃការសម្រេចធម៌ជាគ្រឿងនៅជាសុខ ក្នុងទិដ្ឋធម្មនោះ ។

(១៩៤) ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់មង្គល ៤ ប្រការ គឺ តបៈ ព្រហ្មចរិយៈ ការឃើញអរិយសច្ច ការធ្វើព្រះនិព្វានឱ្យជាក់ច្បាស់ ដោយគាថានេះ ដោយប្រការដូច្នេះ ។

ក៏ក្នុងគាថានេះ ៣ បាទខាងដើម មាន៩អក្សរ ។ មែនពិត ព្រហ្មចរិយៈស័ព្ទ ប្រកបដោយបឋមាវិភត្តិ ឯកវចនៈ មាននិគ្គហិតជាទីបំផុតពិត រមែងប្រាកដ ក្នុងពាក្យទាំងឡាយ ថា " កិន្តេ វតំ កិម្បន ព្រហ្មចរិយំ ' ( អ្វីជាវត្តរបស់អ្នក ?, មួយទៀត អ្វីជាព្រហ្មចរិយៈ របស់អ្នក ? ), ថា ' តំ មេ វតំ តម្បន ព្រហ្មចរិយំ ' ( ទានដែលខ្ញុំបានឱ្យហើយ ដោយគោរពនោះ គឺជាវត្តរបស់ខ្ញុំ, មួយទៀត ទានដែលខ្ញុំបានឱ្យហើយដោយគោរពនោះ

ជាព្រហ្មចរិយៈ របស់ខ្ញុំ ) និងថា 'ភគវតិ នោ អាវុសោ ព្រហ្មចរិយំ វុស្សតិ ' ( ម្នាលលោកដ៏មានអាយុ លោករមែងនៅព្រហ្មចរិយៈ ក្នុងព្រះដ៏មានព្រះភាគ របស់ពួកយើងឬ ? ) ៗ ព្រោះហេតុនោះ ព្រះបាលីថា "តបោ ច ព្រហ្មចរិយញ្ច" ដូច្នេះឯង ទើបត្រឹមត្រូវ ៗ ប៉ុន្តែអាចារ្យបច្ចុប្បន្ននេះ តែងសូត្រថា "ព្រហ្មចរិយា" ៗ ពាក្យនោះមិនត្រឹមត្រូវឡើយ ៗ អាចារ្យពួកខ្លះ កាលបើខ្លួនគប្បីពោលថា "ចក្ខុ អនត្តា, រូបា អនត្តា" ដូច្នេះ តែឃើញបាលី ដែលមានអក្សរ អា បាត់ទៅថា "រូប" ពុំទាន់បានពិចារណា ដោយត្រឹមត្រូវផង ក៏បន្ថែមនិគ្គហិតចូលទៅ ដោយអំណាចការចាំរត់មាត់ថា "រូបំ អនិច្ចំ" ហើយទើបសូត្រថា "រូបំ អនត្តា" ដូច្នេះ ៗ ម្យ៉ាងទៀត អ្នកដែលសូត្រតាមអាចារ្យនោះ ក៏សូត្រយ៉ាងនោះដែរ ៗ សូម្បីពាក្យនោះ ក៏មិនត្រឹមត្រូវ ៗ សូម្បីក្នុងគាថា ទី ៩ នេះ ក៏ដូច្នោះដែរ, អាចារ្យពួកខ្លះឃើញបាលីដែលមាននិគ្គហិតបាត់ទៅថា "ព្រហ្មចរិយ" ដូច្នេះមិនបានពិចារណាផង ក៏បន្ថែម អក្សរ អា ទៅ ដោយអំណាចចាំរត់មាត់ថា "ទានញ្ច ព្រហ្មចរិយា ច" ហើយ ទើបបានសូត្រថា "ព្រហ្មចរិយា" ដូច្នេះ, ចំណែកបុគ្គលដទៃទៀត អ្នកសូត្រតាមអាចារ្យនោះ ក៏សូត្រយ៉ាងដូច្នោះដែរ, ព្រោះហេតុដូច្នោះ

ព្រះបាលី ថា " ព្រហ្មចរិយា " ទើបមិនត្រឹមត្រូវឡើយ ព្រោះខុសអំពីបាលី និងអដ្ឋកថាទាំងឡាយ ដោយប្រការដូច្នេះឯង ។

ការពណ៌នាអំពីការធ្វើព្រះនិព្វានឱ្យជាក់ច្បាស់ ចប់ ។

ពណ៌នាសេចក្ដីនៃគាថា ទី ៩ ចប់ ។

*បើខ្មែរមិនស្រឡាញ់ខ្មែរទេ តើជាតិសាសន៍ណា*
*គេនឹងស្រឡាញ់ខ្មែរនោះ ។*

ប្រែចប់ ថ្ងៃសៅរ៍ ១៣ រោច ខែផល្គុន ឆ្នាំរកា បញ្ចស័ក ព.ស. ២៥៣៦

ត្រូវនឹងថ្ងៃ ទី ២០ ខែមីនា ១៩៩៣

## ពណ៌នាអំពីសេចក្ដីនៃគាថា ទី ១០

(១៩៥) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថា ទី ១០ ដូចតទៅ : បទថា "ផុដ្ឋស្ស" បានដល់ ដែលលោកធម៌ពាល់ត្រូវ គឺ ប៉ះពាល់ ចួបប្រសព្វ គ្របសង្កត់ហើយ ។ បទថា "លោកធម្មេហិ" បានដល់ ដែលលោកធម៌ទាំង ៨ មានលាភនិងឥតលាភជាដើម ។ ស័ព្ទថា "លោកធម្មេហិ" ជាកត្តា ក្នុង ផុដ្ឋ ស័ព្ទ ។ បទថា "ន កម្បតិ" បានដល់ មិនកម្រើក គឺ មិនញាប់ញ័រ ។ បទថា "អសោកំ" គឺ មិនមានសេចក្ដីសោក បានដល់ មានកូនសរ គឺ សេចក្ដីសោកបានដកចេញហើយ ។ បទថា "វិរជំ" បានដល់ ប្រាសចាកកិលេសដូចជាធូលី គឺ មានកិលេសដូចជាធូលីដែលខ្លួន បានកំចាត់ហើយ ។ បទថា "ខេមំ" បានដល់ មិនមានភ័យ គឺ មិនមានឧបទ្រព ។

ក្នុងគាថា ទី ១០ នោះ មានវាចាប្រកប ដូចតទៅនេះ ថា "ម្នាលទេវតា អ្នកចូរប្រកាន់យក ថា 'ចិត្តរបស់បុគ្គលណា ដែលលោកធម៌ទាំងឡាយពាល់ត្រូវហើយ រមែងមិនញាប់ញ័រ, ចិត្តនុ៎ះរបស់បុគ្គលនោះ ជាមង្គលដ៏ឧត្ដម, ចិត្តរបស់បុគ្គលណា មិនមានសេចក្ដីសោក, ចិត្តរបស់បុគ្គលណា ជាចិត្តប្រាសចាកកិលេស

ដូចជាធូលី, ចិត្តរបស់បុគ្គលណា ជាចិត្តក្សេម, ចិត្តនុ៎ះ របស់បុគ្គលនោះ ជាមង្គលដ៏ឧត្តម" ។ មួយទៀត បទថា "យស្ស" សូម្បីក្នុងគាថានេះ កាត់បទថា "យំ អស្ស" ក៏ត្រឹមត្រូវ ដូចជាបទថា "យស្ស" កាត់បទថា "យេ អស្ស" ក្នុងឧទាហរណ៍នេះ ថា "ម្នាលព្រាហ្មណ៍ ជនទាំងឡាយនោះឯណា ជាមាតាក្ដី ជាបិតាក្ដី របស់បុត្រនោះ រមែងមាន ក្នុងលោកនេះ" ដូច្នេះ ជាដើមយ៉ាងដូច្នោះឯង ។

សេចក្ដីសង្ខេប ក្នុងគាថា ទី ១០ នេះ មានដូចតទៅនេះ ថា " ចិត្តណា របស់បុគ្គលនោះ ដែលលោកធម៌ពាល់ត្រូវហើយ រមែងមិនញាប់ញ័រ ១, ចិត្តណា របស់បុគ្គលនោះ មិនមានសេចក្ដីសោកសៅ ១, ចិត្តណា របស់បុគ្គលនោះ ប្រាសចាកកិលេសដូចធូលី ១, ចិត្តណា របស់បុគ្គលនោះ ជាចិត្តក្សេម ១, ចិត្តទាំង ៤ យ៉ាងនុ៎ះ ជាមង្គលដ៏ឧត្តម " ។

ចំណែកសេចក្ដីពិស្ដារ ក្នុងគាថាទី ១០ នេះ មានដូចតទៅនេះ :

⁂

## ពណ៌នាអំពីចិត្តគឺលោកធម៌ឱ្យកម្រើកញាប់ញ័រមិនបាន

(១៩៦) ធម៌ ៨ ប្រការ មានលាភនិងគ្មានលាភជាដើម ឈ្មោះថា លោកធម៌ ។ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុក ក្នុងបឋមវគ្គ នៃបឋមបណ្ណាសកៈ[១] ក្នុងអដ្ឋកនិបាត អង្គុត្តរនិកាយ ថា " ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំងឡាយ ៨ យ៉ាងនេះ រមែងជាប់តាមនូវសត្វលោក ទាំងសត្វលោក ក៏វិលទៅតាមនូវលោកធម៌ទាំង ៨ ដែរ ។ លោកធម៌ទាំង ៨ យ៉ាង តើដូចម្តេចខ្លះ ? ។ គឺ លាភ ១ អលាភ១ យស ១ អយស ១ និន្ទា ១ សរសើរ ១ សុខ ១ ទុក្ខ ១, ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំង ៨ យ៉ាងនេះឯង តែងជាប់តាមនូវសត្វលោក ទាំងសត្វលោក ក៏វិលទៅតាមនូវលោកធម៌ទាំង ៨ ប្រការដែរ " ។

បាលីក្នុងលោកធម្មសូត្រទី១ ចប់ ។

(១៩៧) អដ្ឋកថាលោកធម្មសូត្រនោះ និងអដ្ឋកថាអដ្ឋកៈក្នុងសង្គីតិសូត្រ ថា " ឈ្មោះថា លោកធម៌ ព្រោះជាធម៌សម្រាប់លោក ។ បុគ្គលអ្នកឈ្មោះថា រួចផុតអំពីលោកធម៌ទាំងនោះ តែងមិនមាន, លោកធម៌ទាំងនោះ រមែងមាន ដល់ព្រះពុទ្ធទាំងឡាយ

---

១- ត្រៃបិដក ភាគទី ៤៨ / ទំព័រទី ១៣ ។

ផងដែរ ។ ដោយហេតុនោះឯង ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា 'លោកំ អនុបរិវត្តន្តិ' ។ បទថា 'អនុវត្តន្តិ' គឺ រមែងមិនលះបង់ អធិប្បាយថា មិនត្រឡប់អំពីលោក ។ ច្រើនបទថា 'លោកោ ច អដ្ឋ លោកធម្មេ អនុបរិវត្តន្តិ' មានសេចក្តីថា ក៏លោកនេះ រមែងជាប់តាម គឺ រមែងមិនលះបង់នូវធម៌ទាំងនុ៎ះ បានដល់ រមែងមិនត្រឡប់អំពីធម៌ទាំងឡាយនោះ ។ ២ បទថា 'លាភោ អលាភោ' មានសេចក្តីថា កាលបើលាភមកដល់ហើយ, ការគ្មានលាភ បណ្ឌិតគប្បីជ្រាបថា 'ក៏មកដល់ដូចគ្នាដែរ' ។ សូម្បីក្នុងបទទាំងឡាយ មានបទថា យស ជាដើម ក៏មានន័យ យ៉ាងដូច្នេះដែរ" ។

(១៩៨) ដីកាលោកធម៌សូត្រជាដើមនោះថា "ធម៌ដែលនឹងមាន ដោយពិតប្រាកដ ដល់សត្វលោក ឈ្មោះថា ធម៌សម្រាប់លោក ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលពាក្យជាដើមថា 'បុគ្គលអ្នកឈ្មោះថា រួចផុតអំពីលោកធម៌ទាំងឡាយនុ៎ះ រមែងមិនមាន' ។ ការបាននូវវត្ថុមានគ្រឿងបរិភោគនិងគ្រឿងស្លៀកពាក់ជាដើម ឈ្មោះថា លាភ ។ម្យ៉ាងទៀត វត្ថុទាំងឡាយមានគ្រឿងបរិភោគនិងគ្រឿងស្លៀកពាក់ជាដើមនោះឯង ឈ្មោះថា លាភ ព្រោះជាវត្ថុដែលបុគ្គលគប្បីបាន ។ ការមិនមានវត្ថុមាន

គ្រឿងបរិភោគនិងគ្រឿងស្លៀកពាក់ជាដើមនោះ ឈ្មោះថា ការមិនមានលាភ ។ ក៏បណ្ដាលាភនិងអលាភទាំង ២ យ៉ាងនេះ សេចក្ដីត្រេកអរដែលមានលាភនោះជាអារម្មណ៍ លោកអាចារ្យបានប្រកាន់យកហើយ ដោយ លាភ ស័ព្ទ, សេចក្ដីមិនត្រេកអរ ដែលមានការខាតលាភនោះជាអារម្មណ៍ លោកអាចារ្យប្រកាន់យកហើយ ដោយ អលាភ ស័ព្ទ ។ ព្រោះកាលបើមានសេចក្ដីត្រេកអរ, សេចក្ដីមិនត្រេកអរ ក៏រមែងបានឱកាសដូចគ្នា ប្រៀបឧបមាដូចជាកាលបើឈាមមាន, ខ្ទុះក៏ត្រូវតែមាន ដោយអំណាចនៃការរងឈាមនោះ ដូច្នោះដែរ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា 'លាភេ អាគតេ អលាភោ អាគតោយេវ' ។ សូម្បីក្នុងលោកធម៌ មានយសជាដើម ក៏ន័យនេះដូចគ្នាដែរ " ។

ក្នុងអដ្ឋកថាមង្គលសូត្រនេះ ព្រះអដ្ឋកថាចារ្យ បានពោលទុកហើយនូវពាក្យ មានប្រមាណប៉ុណ្ណេះឯង ថា 'ធម៌ទាំងឡាយ ក្នុងលោក ឈ្មោះថា លោកធម៌ ។ មានពាក្យដែលលោកអធិប្បាយថា 'ការប្រព្រឹត្តិទៅនៃលោក រមែងមាន ដរាបណា, ធម៌ទាំងឡាយក៏មិនប្រព្រឹត្តត្រឡប់ ដរាបនោះដែរ' ដូច្នេះ " ។

(១៩៩) មនោ ឈ្មោះថា ចិត្ត ។ ដោយហេតុនោះ ក្នុងពួកធាតុមាន ចុរ ធាតុជាដើម លោកបានពោលទុកហើយ ថា ÷

“ ឈ្មោះទាំងឡាយនេះ គឺ ចិត្តៈ មនោ មានសៈ វិញ្ញាណៈ ហទយៈ មនៈ រមែងប្រព្រឹត្តទៅ ក្នុងគន្លងនៃវោហារ ដោយច្រើន ” ។

ដីកាអភិធម្មត្ថសង្គហៈ ថា “ ធម្មជាតណា តែងគិត ហេតុនោះ ធម្មជាតនោះ ឈ្មោះថា ចិត្ត, អធិប្បាយថា រមែងដឹងច្បាស់នូវអារម្មណ៍ ” ។

ដីកាមណិសារមញ្ជូសា ថា “ ចិន្ត ធាតុ ប្រព្រឹត្តទៅក្នុងអត្ថ ថា គិត ៗ ក៏ការគិតនោះ មាន ៣ យ៉ាង គឺ គិតដោយអំណាចការត្រិះរិះ គិតដោយអំណាចការដឹងជាក់ច្បាស់ គិតដោយអំណាចការយល់ច្បាស់លាស់ ៗ បណ្ដាការគិតទាំង ៣ យ៉ាងនោះ ឩហនចិន្តា បានដល់វិតក្កៈ, វិជាននចិន្តា បានដល់វិញ្ញាណ, បជាននចិន្តា បានដល់បញ្ញា ៗ តែក្នុងបទ ថា ‘ ចិន្តេតិ ’ នេះ បានចំពោះ វិជាននចិន្តា ព្រោះភាវៈនៃចិត្តជាធម្មជាតដឹងច្បាស់ ( នូវអារម្មណ៍ ) ព្រោះហេតុនោះ ព្រះដីកាចារ្យ កាលនឹងសំដែងចិត្ត ស័ព្ទនោះ ទើបពោល ថា ‘ អធិប្បាយថា រមែងដឹងច្បាស់នូវអារម្មណ៍ ’ ៗ ម្យ៉ាងទៀត ស័ព្ទថា ‘ វិជានាតិ ’ នេះ ជាស័ព្ទអធិប្បាយនូវបទ ថា ‘ ចិន្តេតិ ’ នេះ ៗ មួយទៀត កិរិយា គឺ

ការដឹងជាក់ច្បាស់ ក្នុងបទ ថា 'វិជានាតិ' នេះ ជាសេចក្តីអធិប្បាយនូវបទ ថា 'ចិន្តេតិ' នេះ" ។

(២០០) ពួកធាតុមាន ចុរ ធាតុជាដើម ថា " ចិន្ត ធាតុប្រព្រឹត្តទៅក្នុងអត្ថ ថា គិត, ធម្មជាតណា រមែងគិត អធិប្បាយថា រមែងដឹងច្បាស់នូវអារម្មណ៍ ហេតុនោះ ធម្មជាតនោះ ឈ្មោះថា ចិត្ត ។ ក៏បណ្ឌិតគប្បីឃើញបទ ថា 'ចិត្តំ' នុ៎ះ ដោយអំណាចជាបទទូទៅ ដល់ចិត្តទាំងពួង ។ ក្នុងអធិការនៃ ចិត្ត ស័ព្ទនេះ គប្បីមានពាក្យសួរ ថា 'លោកអាចារ្យសូម្បីពោល ថា 'ធម្មជាតណារមែងគិតនូវអារម្មណ៍ ហេតុនោះ ធម្មជាតនោះ ឈ្មោះថា ចិត្ត' ដូច្នេះ ហើយពោល ថា 'អធិប្បាយថា រមែងដឹងច្បាស់ (នូវអារម្មណ៍) ដូច្នេះ' ព្រោះហេតុអ្វី ?, ការគិតនិងការដឹងច្បាស់មានសភាពផ្សេងៗពីគ្នា មិនមែនទេឬ ?, ព្រោះថា បទថា 'ចិន្តេតិ' នឹងសម្រេចសេចក្តីថា 'រមែងដឹងច្បាស់' ដូច្នេះ មិនបានឡើយ, ព្រោះបុគ្គលអ្នកអាប់ប្រាជ្ញា សូម្បីជាគិត ដោយប្រការផ្សេងៗ ក៏នឹងបានសម្រេចសេចក្តីដ៏សុខុម ពុំបានឡើយ' ។ គប្បីឆ្លើយ ថា 'រឿងនោះ ពិតមែន, (តែ) បទថា 'វិជានាតិ' នេះ លោកពោលហើយ ដើម្បីសំដែងនូវការដែលចិត្តទាញយកនូវអារម្មណ៍ដ៏ពិសេស ជាកិច្ចនៃសញ្ញានិងបញ្ញា ព្រោះ ចិត្ត ស័ព្ទ

ជាសព្វទូទៅដល់ចិត្តទាំងពួង ។ មែនពិត ធម្មជាតណា លោកហៅថា ចិត្ត, ធម្មជាតនោះឯង ឈ្មោះថា វិញ្ញាណ, ព្រោះហេតុនោះ ទើបលោកពោល ថា 'វិជានាតិ' ដើម្បីនឹងទាញយកនូវសេចក្ដីថាដឹងច្បាស់ ហើយសំដែង នូវការដែលចិត្តទាញយកនូវអារម្មណ៍ដ៏ពិសេស ជាកិច្ចនៃសញ្ញានិងបញ្ញា " ។

ដីកាធម្មសង្គណី ថា "ដោយបទ ថា 'វិជានាតិ' លោកពោល នូវកិរិយាដែលចិត្តទាញយក នូវអារម្មណ៍ដ៏ពិសេស ជាកិច្ចនៃសញ្ញានិងបញ្ញា " ។

ម្យ៉ាងទៀត អនុដីកា ឈ្មោះមណិសារមញ្ជូសា ថា "ការប្រកាន់យកនូវអារម្មណ៍ មាន ៣ យ៉ាង គឺ ការដឹងព្រម ១ ការដឹងជាក់ច្បាស់ ១ ការដឹងច្បាស់លាស់ ១ ។ បណ្ដាការដឹងទាំង ៣ យ៉ាងនោះ ការដឹងជាបឋម ជាកិច្ចនៃសញ្ញា, ទី ២ ជាកិច្ចនៃវិញ្ញាណ, ទី ៣ ជាកិច្ចនៃបញ្ញា ។ តែក្នុងបទថា 'ចិន្តេតិ' នេះ រមែងបានចំពោះតែការដឹងទី ២ ព្រោះចិត្តជាធម្មជាតដឹងច្បាស់ (នូវអារម្មណ៍) ព្រោះហេតុនោះ ទើបលោកពោល ថា 'អធិប្បាយថា 'រមែងដឹងច្បាស់នូវអារម្មណ៍' ដូច្នេះ ដើម្បីនឹងសំដែង នូវកិរិយាដែលចិត្តទាញយកនូវអារម្មណ៍ ពោលគឺបាននូវអារម្មណ៍ដ៏ពិសេស ដោយកិច្ចនៃសញ្ញា និងបញ្ញាទាំងឡាយ

ពោលគឺការចាំបាន ការពិចារណា និងការចាក់ធ្លុះ " ។

(២០១) ពួកធាតុមាន ចិរ ធាតុជាដើម ថា " បណ្ដាចិត្តទាំងពួង ចិត្តណា ដែលជាកុសល អកុសល ផ្នែកលោកិយៈ និងមហាកិរិយាចិត្ត, ចិត្តនោះ ឈ្មោះថា ចិត្ត ព្រោះសន្សំនូវសន្តានរបស់ខ្លួន ដោយអំណាចជវនវិថី ។ ចំណែកវិបាកចិត្ត ឈ្មោះថា ចិត្ត ព្រោះត្រូវកម្មនិងកិលេសទាំងឡាយ សន្សំហើយ ។ នេះជាពាក្យអធិប្បាយ ដោយអំណាចនៃ ចិ ធាតុ ។ សិល្បៈដ៏វិចិត្រក្នុងលោកណានីមួយ ក៏ឈ្មោះថា ចិត្ត ព្រោះល្អត្រកាល គឺវិចិត្របានដល់ ជាគ្រឿងដែលគេធ្វើឲ្យវិចិត្រ ព្រោះធ្វើសិល្បៈទាំងពួងនោះ ដោយចិត្តនុ៎ះឯង ។ មានពាក្យដែលលោកអធិប្បាយថា 'ឈ្មោះថា ចិត្ត ព្រោះជាគ្រឿងធ្វើដោយចិត្ត' ។ នេះជាពាក្យអធិប្បាយ ដោយអំណាចនៃ ចិត្ត ធាតុ ។ ឈ្មោះថា ចិត្ត ព្រោះល្អស្អាត ។ នេះជាពាក្យអធិប្បាយ ដោយអំណាចនៃសេចក្ដីចំពោះបទ ៗ ។ ក៏ក្នុងអធិការនៃ ចិត្ត ស័ព្ទនេះ បណ្ឌិតគប្បីជ្រាបភាវៈនៃចិត្ត ឈ្មោះថា ចិត្ត ដោយអំណាចសម្បយុត្តចិត្ត ភូមិចិត្ត អារម្មណចិត្ត ហីនចិត្ត មជ្ឈិមចិត្ត បណីតចិត្ត និងអធិបតិចិត្ត ព្រោះភាវៈជាធម្មជាត ខុសប្លែកផ្សេងគ្នា ដោយប្រភេទនៃចិត្តដែលជាសរាគចិត្ត និងសទោសចិត្តជាដើម ។ ភាវៈនៃ ចិត្ត

ស័ព្ទ ៗ មួយ ជាស័ព្ទដ៏វិចិត្រ យ៉ាងដូច្នោះ តែងមិនមាន ក៏ពិតមែន, ទោះជាដូច្នោះ សូម្បីអវយវៈ ក៏លោកហៅថា ' ចិត្ត ' ដោយវោហារគឺការហៅរួម ព្រោះជាសភាពធ្លាក់ចុះទៅខាងក្នុង នៃធម៌ដ៏វិចិត្រទាំងឡាយ ប្រៀបឧបមាដូចជាបុគ្គលទាំងឡាយ, កាលបើឯកទេស នៃស្ថានទីមានភ្នំ ទន្លេ និងសមុទ្រជាដើម ដែលខ្លួនបានឃើញហើយ, រមែងហៅភ្នំជាដើមថា ' ពួកយើងបានឃើញហើយ ' ដូច្នោះឯង ៗ អ្នកសិក្សា តែងបានសេចក្តី ដោយប្រការណា ៗ ក្នុងទីណា ៗ ក៏គប្បីកាន់យកសេចក្តី ដោយប្រការនោះ ៗ ក្នុងទីនោះ ៗ ព្រោះហេតុណា, ព្រោះហេតុនោះ ធម្មជាតណា រមែងសន្សំ ដោយភាវៈជាអាសេវនប្បច្ច័យ និងធម្មជាតណា ឈ្មោះថា ចិត្ត ព្រោះជាធម្មជាត គឺកម្មតាក់តែង, ធម្មជាតនោះ លោកក៏ហៅថា ' ចិត្ត ' ដោយអាការនោះ ៗ ចំណែកធម្មជាតណា មិនប្រព្រឹត្តទៅ ដោយប្រការដូច្នោះ, ធម្មជាតនោះ គឺ កិរិយាចិត្តផ្នែកកាមាវចរៈ ទាំងគូ និងអន្តិមជវនចិត្ត បណ្ឌិតគប្បីជ្រាបថា ' ចិត្ត ' ដោយអំណាចនៃនាមធម៌ មានភាវៈនៃចិត្តជាធម្មជាតល្អ ដោយការនឹកគិត ដែលអាចារ្យកំពុងបានជាដើម ៗ តែហសិតុប្បាទចិត្ត មានជវនៈដទៃជាគតិពិត " ។

(២០២) ក្នុងអដ្ឋកថាមង្គលសូត្រនេះ ព្រះអដ្ឋកថាចារ្យ

ពោល ថា "មនោ (ចិត្ត) មានសំ (ឆន្ទៈមានក្នុងចិត្ត) ឈ្មោះថា ចិត្ត "។

អដ្ឋកថាមូលបរិយាយសូត្រ ថា "រាគៈក្តី ចិត្តក្តី អរហត្តក្តី ឈ្មោះថា មានសៈ ។ មែនពិត រាគៈ ឈ្មោះថា មានសៈ ក្នុងប្រយោគនេះ ថា 'អន្ទាក់ដែលត្រាច់ចរទៅឰដ៏អាកាស អន្ទាក់នេះនោះ រមែងត្រាច់ចរទៅ ឈ្មោះថា មានសៈ' ។ ចិត្ត ឈ្មោះថា មានសៈ ក្នុងប្រយោគនេះ ថា 'ចិត្ត ឆន្ទៈមានក្នុងចិត្ត ឈ្មោះថា ចិត្ត' ។ ព្រះអរហត្ត ឈ្មោះថា មានសៈ ក្នុងប្រយោគនេះថា 'បពិត្រព្រះអង្គអ្នកប្រាកដក្នុងពួកជន សាវ័ករបស់ព្រះអង្គ នៅជាសេក្ខៈ នៅមិនទាន់បានសម្រេចព្រះអរហត្ត គប្បីធ្វើកាលកិរិយា"។

ដីកាមូលបរិយាយសូត្រនោះថា"រាគៈ ឈ្មោះថា មានសៈ ព្រោះមានក្នុងចិត្ត ហេតុសម្បយុត្តដោយចិត្តនោះ ។ ចិត្ត ឈ្មោះថា មានសៈ ព្រោះធ្វើអធិប្បាយ ថា 'ចិត្តនុ៎ះឯង ឈ្មោះថា មានសៈ'។ មគ្គដ៏ប្រសើរ ឈ្មោះថា មានសៈ ព្រោះវិគ្រោះ ថា 'រមែងកាត់ គឺ កាត់ផ្តាច់នូវមានះ ដោយមិនមានសេសសល់'។ ក៏បណ្ឌិតគប្បីឃើញភាវៈនៃព្រះអរហត្ត ឈ្មោះថា មានសៈ ព្រោះកើតឡើងក្នុងចិត្តនោះ ។ បទថា 'ជនេសុតា' បានដល់ អ្នកប្រាកដ គឺ មានយសស័ក្តិផ្សព្វផ្សាយទៅ ក្នុងសត្វលោក "។

(២០៣) ក្នុងអដ្ឋកថាមង្គលសូត្រនេះ ព្រះអដ្ឋកថាចារ្យពោល ថា "បទថា 'យស្ស' មានសេចក្តីថា នៃភិក្ខុអ្នកបួសថ្មីក្តី ជាកណ្តាលក្តី ជាថេរៈក្តី" ។

អដ្ឋកថាបឋមបារាជិក ថា "បណ្តាភិក្ខុអ្នកដែលចំរើនដោយវ័យជាដើម ចូរជាភិក្ខុរូបណាមួយក៏ដោយ ក៏ឈ្មោះថាជាព្រះថេរៈ ព្រោះមានវស្សាគ្រប់ ១០, ឈ្មោះថា នវៈ ព្រោះមានវស្សាតិចជាង ៥, ឈ្មោះថា មជ្ឈិមៈ ព្រោះមានវស្សាលើសជាង ៥" ។

ដីកាអដ្ឋមសូត្រ ក្នុងបញ្ចមវគ្គ នៃទុតិយបណ្ណាសកៈ ក្នុងតិកនិបាត អង្គុត្តរនិកាយ ថា "ភិក្ខុសូម្បីមានអាយុ ៦០ ដោយកំណើត ឰដ៏ខាងក្រោយ អំពីកាលដែលខ្លួនមានវស្សា ៥ ដោយឧបសម្បទ ក៏នៅតែឈ្មោះថា នវៈ ដោយពិត ៗ ចាប់ដើមអំពីកាលដែលខ្លួនមានវស្សា ៥ រហូតដល់មានវស្សា ៩ ឈ្មោះថា មជ្ឈិមៈ ៗ ចាប់ដើមអំពីកាលដែលខ្លួនមានវស្សា ១០ ទៅ ឈ្មោះថា ថេរៈ" ។

អដ្ឋកថាទសមសូត្រ ក្នុងទុតិយវគ្គ នៃទេវតាសំយុត្ត ថា "ភិក្ខុអ្នកមានវស្សាមិនទាន់គ្រប់ ៥ មានឈ្មោះថា នវៈ, ចាប់ដើមអំពីមានវស្សា ៥ ឡើងទៅ ឈ្មោះថា ជាមជ្ឈិមៈ, តាំងពីមានវស្សា ១០ ឡើងទៅ ឈ្មោះថា ជាថេរៈ ៗ ន័យមួយទៀត ភិក្ខុអ្នកមានវស្សាមិនទាន់គ្រប់ ១០ ឈ្មោះថា នវៈ, តាំងពីមានវស្សា ១០

ឡើងទៅ ឈ្មោះថា មជ្ឈិមៈ, តាំងអំពីមានវស្សា ២០ ឡើងទៅ ឈ្មោះថា ព្រះថេរៈ " ។

ដីកាទសមសូត្រនោះ ថា "ព្រះអដ្ឋកថាចារ្យពោល ថា 'តាំងអំពីវស្សា ២០ ឡើងទៅ ឈ្មោះថា ព្រះថេរៈ' ដូច្នេះ សំដៅយកព្រះថេរៈ អ្នកដល់ព្រមដោយលក្ខណៈជាភិក្ខុអ្នកទូន្មាននាងភិក្ខុនី " ។

(២០៤) បណ្ដាភិក្ខុទាំងនោះ ចិត្តរបស់ភិក្ខុណា ដែលលោកធម៌ទាំងឡាយ ពាល់ត្រូវហើយ រមែងមិនកម្រើកញាប់ញ័រ, ចិត្តរបស់ភិក្ខុនោះ គឺលោកធម៌ណាមួយ គប្បីឲ្យកំរើកញាប់ញ័រមិនបាន បណ្ឌិតគប្បីជ្រាប ថា "ជាមង្គល" ព្រោះនាំមកនូវភាពជាអ្នកខ្ពង់ខ្ពស់ក្នុងលោក ។ សួរថា "ក៏ចិត្ត របស់បុគ្គលណាដែលលោកធម៌ទាំងនោះ ពាល់ត្រូវហើយ តែងមិនញាប់ញ័រ ? " ។ ឆ្លើយថា "របស់ព្រះអរហន្តខីណាស្រព, មិនមែនអ្នកណាដទៃទៀតឡើយ " ។ ពិតមែនយ៉ាងដូច្នោះ បព្វជិតទាំងឡាយមានសាមណេរជាបុថុជ្ជនជាដើម ឃើញព្រះលកុណ្ដកភទ្ទិយត្ថេរហើយ ក៏ចាប់ត្រង់សិរសា ត្រចៀក និងច្រមុះទាំងឡាយ ហើយពោល ថា "ម្នាលឪពុកតូច លោកឪ (អ្នក) មិនរសាប់រសល់ត្រេកអរ យ៉ាងក្រៃលែង ក្នុងព្រះពុទ្ធសាសនាឬ ? " ។ ព្រះថេរៈមិនក្រោធខឹង មិនប្រទូសរ៉ាយ ចំពោះសាមណេរទាំងនោះទេ ។

ពួកភិក្ខុទាំងឡាយសន្ទនាគ្នា ថា "បព្វជិតទាំងឡាយមានសាមណេរជាដើម រមែងបៀតបៀន (ព្រះថេរៈ) យ៉ាងនេះផង យ៉ាងនោះផង, ព្រះថេរៈនោះ មិនក្រោធ មិនប្រទូសរ៉ាយឡើយ" ។

ព្រះសាស្ដាទ្រង់ព្រះសណ្ដាប់ពាក្យសន្ទនានោះហើយ ទើបទ្រង់ត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ, ធម្មតាព្រះខីណាស្រពរមែងមិនក្រោធ មិនប្រទូសរ៉ាយសោះឡើយ, ព្រោះថា ព្រះខីណាស្រពទាំងនោះ ជាអ្នកដូចជាសីលាថ្មតាន់ មិនកំរើកញាប់ញ័រគឺនរណា ក៏ធ្វើឲ្យកម្រើកញាប់ញ័រពុំបានឡើយ" ដូច្នេះ ហើយទ្រង់ត្រាស់ព្រះគាថានេះ ក្នុងបណ្ឌិតវគ្គ នៃធម្មបទ ថា ៖

"ភ្នំថ្មតាន់ មិនកម្រើក ព្រោះខ្យល់ ដូចម្ដេចមិញ,
បណ្ឌិតទាំងឡាយ ក៏មិនកម្រើកញាប់ញ័រ ព្រោះ
ពាក្យតិះដៀលនិងពាក្យសរសើរ ក៏ដូច្នោះឯង" ។

អដ្ឋកថាព្រះធម្មបទនោះ ថា "បណ្ដាបទទាំងនោះ បទថា 'និន្ទាបសំសាសុ' មានវិនិច្ឆ័យ ថា ក្នុងគាថានេះ ព្រះមានព្រះភាគទ្រង់ត្រាស់លោកធម៌ ២ ប្រការ ក៏ពិតមែន, ទោះជាដូច្នោះអ្នកសិក្សាក៏គប្បីជ្រាបសេចក្ដី ដោយអំណាចនៃលោកធម៌ទាំង ៨ ប្រការដែរ ។ ប្រៀបដូចជា សីលាថ្មតាន់ គឺមិនមានប្រហោង

មិនរញ្ជួយ គឺ មិនកម្រើក បានដល់ មិនញាប់ញ័រ ព្រោះខ្យល់មានខ្យល់ដែលបក់មក អំពីទិសខាងកើតជាដើមជាប្រភេទ មានឧបមាយ៉ាងណា, បណ្ឌិតទាំងឡាយ, កាលបើលោកធម៌ទាំង ៨ ប្រការ គ្របសង្កត់, រមែងមិនរំភើប គឺមិនកម្រើក បានដល់ មិនញាប់ញ័រ ដោយអំណាចការថ្នាំងថ្នាក់ចិត្ត ឬដោយអំណាចនៃការត្រេកអរ ក៏មានឧបមេយ្យយ៉ាងនោះដែរ" ។

(២០៥) ចំណែកក្នុងអដ្ឋកថា លោកពោលពាក្យណា ថា ៖

" ភ្នំថ្មតាន់សុទ្ធ រមែងមិនកម្រើក[១] ដោយខ្យល់យ៉ាងណា, រូប សំឡេង ក្លិន រស និងសម្ផស្ស ទាំងអស់ ដែលជាទីប្រាថ្នាក្ដី ដែលមិនជាទីប្រាថ្នាក្ដី ក៏ធ្វើចិត្ត របស់អ្នកខ្ជាប់ខ្ជួន ជាចិត្តនឹងធឹង រួចស្រឡះចាកកិលេស ឲ្យញាប់ញ័រមិនបាន, ទាំងព្រះអរិយសាវ័កនោះ ក៏ពិចារណាឃើញ នូវការកើតឡើងនិងការអស់ទៅ ក៏យ៉ាងនោះដែរ" ដូច្នេះ,

ពាក្យនោះ ព្រះសោណត្ថេរដ៏មានអាយុ កាលធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តរបស់ខ្លួន ពោលហើយ ក្នុងសំណាក់នៃព្រះសាស្ដា ក្នុងបឋមវគ្គ នៃទុតិយបណ្ណាសកៈ ក្នុងឆក្កនិបាត អង្គុត្តរនិកាយ

---

១- ត្រៃបិដក ភាគទី ៤៦ / ទំព័រទី ១៩៩ ។

និងក្នុងចម្មក្ខន្ធកៈ ។

ន័យដែលមក ក្នុងអដ្ឋកថាបឋមវគ្គ និងចម្មក្ខន្ធកៈនោះ ថា "រូបារម្មណ៍ ដែលបុគ្គលគប្បីពាល់ត្រូវ ឈ្មោះថា ផស្សៈ ក្នុងគាថានោះ ។ ធម៌ដែលបុគ្គលគប្បីដឹងដោយចិត្ត ឈ្មោះថា ធម៌ ។ បទថា 'នប្បវេធេន្តិ' មានសេចក្តីថា នឹងញ៉ាំងចិត្តឲ្យកម្រើកញាប់ញ័រមិនបាន ។ បទថា 'តាទិនោ' គឺ អ្នកដល់លក្ខណៈនៃបុគ្គលអ្នកខ្ជាប់ខ្ជួន ។ បទថា 'ឋិតំ' បានដល់ តាំងនៅស្ថិតស្ថេរ គឺ ដល់នូវការមិនញាប់ញ័រ ។ បទថា 'វិប្បមុត្តំ' មានសេចក្តីថា ដែលរួចផុតហើយ ដោយអំណាចផលសមាបត្តិ ព្រោះប្រតិបត្តិខាងផ្នែកវិបស្សនា និងបង្អោនចូលទៅហើយ ក្នុងអារម្មណ៍ គឺនិព្វាន ។ បាទគាថា ថា 'វយញ្ចស្សានុបស្សតោ' មានសេចក្តីថា នៃព្រះអរិយសាវកនោះ ជាអ្នកតាមពិចារណាឃើញទាំងការកើតឡើងទាំងការអស់ទៅនៃចិត្ត បានដល់ ព្រះអរហន្ត" ។

តែក្នុងចុណ្ណិយបទ ក្នុងព្រះសូត្រនោះ មកហើយ ថា "វយញ្ចស្សានុបស្សតិ" ។

ក៏ក្នុងអដ្ឋកថាចុណ្ណិយបទនោះ លោកពោល ថា "បទថា 'វយញ្ចស្សានុបស្សតិ' មានសេចក្តីថា ទាំងព្រះអរហន្តនោះ រមែងឃើញទាំងការកើតឡើង ទាំងការអស់ទៅ នៃចិត្តនោះ" ។

អធិប្បាយ ថា ‘ភិក្ខុជាព្រះខីណាស្រពនោះ រមែងឃើញទាំងការកើតឡើងទាំងការអស់ទៅនៃចិត្តនោះ ” ។

(២០៦) ក្នុងអដ្ឋកថា លោកពោល យ៉ាងដូច្នេះថា ‘ ចិត្តរបស់ព្រះខីណាស្រពប៉ុណ្ណោះ រមែងមិនញាប់ញ័រ ” ។

ពាក្យនោះ អ្នកសិក្សាគប្បីឃើញ ថា “ លោកពោលហើយដោយអំណាចព្រះអរិយបុគ្គលថ្នាក់ដ៏ខ្ពង់ខ្ពស់ ” ។ មែនពិត អ្នកណា ក៏អាចនឹងពោលបាន ថា “ ចិត្តរបស់ព្រះអរិយសាវ័ក សូម្បីក្រៅអំពីព្រះខីណាស្រពនោះ ក៏រមែងមិនញាប់ញ័រ ” ។

ពិតមែនដូច្នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរ ព្រោះព្រះអង្គទ្រង់មានព្រះបំណងនឹងត្រាស់ យ៉ាងនេះ ថា “ ម្នាលភិក្ខុទាំងឡាយ[១] លាភក្ដី អលាភក្ដី យសក្ដី អយសក្ដី និន្ទាក្ដី សរសើរក្ដី សុខក្ដី ទុក្ខក្ដី រមែងកើតឡើង ដល់បុថុជ្ជនអ្នកមិនបានស្ដាប់សោះ ។ ម្នាលភិក្ខុទាំងឡាយ លាភក្ដី ។ល។ ទុក្ខក្ដី រមែងកើតឡើង ដល់ព្រះអរិយសាវ័ក អ្នកបានស្ដាប់ហើយដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះក្នុងលោកធម៌ទាំង ៨ នោះ មានសេចក្ដីប្លែកគ្នាដូចម្ដេច, មានអធិប្បាយដូចម្ដេច, មានហេតុផ្សេងគ្នាដូចម្ដេច របស់ព្រះអរិយសាវ័ក អ្នកបានស្ដាប់ហើយ និងបុថុជ្ជនអ្នកមិនបានស្ដាប់ហើយ ” ដូច្នេះហើយ ទើបទ្រង់ត្រាស់

១- ត្រៃបិដក ភាគទី ៤៨ / ទំព័រទី ១៥ ។

យ៉ាងនេះ ថា “ ម្នាលភិក្ខុទាំងឡាយ លាភតែងកើតឡើង ដល់បុថុជ្ជនអ្នកមិនបានស្តាប់ហើយ, បុថុជ្ជននោះ រមែងមិនពិចារណា មិនដឹងច្បាស់ តាមពិតដូច្នេះ ថា ‘លាភនេះ កើតឡើង ដល់អាត្មាអញហើយ, ក៏លាភនោះឯង មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា’ ដូច្នេះ ។ អលាភ រមែងកើតឡើង ។ល។ យស ។ល។ អយស ។ល។ និន្ទា ។ល។ សរសើរ ។ល។ សុខរមែងកើតឡើង ។ល។ ទុក្ខរមែងកើតឡើង (ដល់បុថុជ្ជនអ្នកមិនបានស្តាប់ហើយ), បុថុជ្ជននោះ រមែងមិនពិចារណា មិនដឹងច្បាស់ តាមពិតដូច្នេះ ថា ‘ទុក្ខនេះ កើតឡើងដល់អាត្មាអញហើយ, ក៏ទុក្ខនោះឯង មិនទៀង ជារបស់អត់ធន់បានដោយកម្រ មានសេចក្តីប្រែប្រួលជាធម្មតា’ ដូច្នេះ ។ លាភក្តី រមែងគ្របសង្កត់ចិត្ត របស់បុថុជ្ជននោះ ស្ថិតនៅ ។ អលាភក្តី ។ល។ ទុក្ខរមែងគ្របសង្កត់ចិត្ត របស់បុថុជ្ជននោះ ស្ថិតនៅ ។ បុថុជ្ជននោះ រមែងត្រេកអរនឹងលាភដែលកើតឡើងហើយ តែងតូចចិត្ត ព្រោះអលាភ ។ល។ រមែងត្រេកអរនឹងសុខ ដែលកើតឡើងហើយ រមែងតូចចិត្តព្រោះទុក្ខ ។ បុថុជ្ជននោះ ដល់ព្រមដោយសេចក្តីត្រេកអរ និងសេចក្តីតូចចិត្ត យ៉ាងដូច្នេះហើយ រមែងមិនរួចផុត អំពីជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខ

ទោមនស្ស ឧបាយាសៈ ។ តថាគតពោល ថា ‘បុថុជ្ជននោះ មិនរួចផុតចាកទុក្ខឡើយ’ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាសេចក្តីប្លែកគ្នា នេះជាអធិប្បាយ នេះជាហេតុផ្សេងៗគ្នា នៃអរិយសាវ័កអ្នកបានស្តាប់ហើយ និងបុថុជ្ជនអ្នកមិនបានស្តាប់ហើយ ” ។

( ព្រះមានព្រះភាគ បានត្រាស់សូត្រនេះហើយ លុះព្រះសុគតជាសាស្តា ទ្រង់ត្រាស់សូត្រនេះរួចហើយ ទើបទ្រង់ត្រាស់គាថាព័ន្ធនេះ តទៅទៀត ថា ÷ )

(២០៧) “ ធម៌ទាំងឡាយ(១) ក្នុងមនុស្សជាតទាំងឡាយ ទាំងនេះ គឺ លាភ ១ អលាភ ១ យស ១ អយស ១ និន្ទា ១ សរសើរ ១ សុខ ១ ទុក្ខ ១ ជាធម៌មិនទៀង ជាធម៌មិនឋិតថេរ មានការប្រែប្រួលជាធម្មតា, ចំណែកបុគ្គលអ្នកមានសតិស្មារតី មានប្រាជ្ញាល្អ លុះដឹងធម៌ទាំងនេះហើយ រមែងពិចារណាឃើញច្បាស់ នូវធម៌ដែលមានសេចក្តីប្រែប្រួលជាធម្មតា, ធម៌ដែលជាឥដ្ឋារម្មណ៍ទាំងឡាយ រមែងញាំញីចិត្ត របស់បុគ្គលនោះពុំបាន, បុគ្គលនោះ រមែងមិនដល់នូវការថ្នាំងថ្នាក់ចិត្ត ព្រោះធម៌

---

១- ត្រៃបិដក ភាគទី ៤៨ / ទំព័រទី ១៤ ។

ដែលជាអនិដ្ឋារម្មណ៍, សេចក្ដីត្រេកអរ ឬថាសេចក្ដីថ្នាំងថ្នាក់ចិត្ត ក៏បុគ្គលនោះបានកំចាត់បង់ហើយ ដល់នូវសេចក្ដីវិនាស មិនមានតទៅទៀតឡើយ, ម្យ៉ាងទៀត បុគ្គលអ្នកដល់ត្រើយនៃភព រមែងដឹងច្បាស់ដោយប្រពៃ ព្រោះដឹងច្បាស់នូវបទ គឺព្រះនិព្វានដែលគ្មានធូលី គឺកិលេស មិនមានសេចក្ដីសោក" ។

បាលីក្នុងលោកធម្មសូត្រទី ២ ក្នុងបឋមវគ្គ នៃបឋមបណ្ណាសកៈ ក្នុងអដ្ឋកនិបាត អង្គុត្តរនិកាយ ។

(២០៨) អដ្ឋកថាទុតិយលោកធម្មសូត្រនោះ ថា "បទថា 'កោ វិសេសោ' គឺ អ្វីជាហេតុប្លែកពីគ្នា ។ បទថា 'អធិប្បាយសោ' បានដល់ ជាការប្រកប យ៉ាងក្រៃលែង ។ បទថា 'បរិយាទាយ' គឺ ប្រកាន់យក បានដល់ គ្របសង្កត់" ។

ដីកាទុតិយលោកធម្មសូត្រនោះ ថា "ឈ្មោះថា អធិប្បាយសៈ ព្រោះជាគ្រឿងប្រកប គឺ ប្រកបទូទៅ យ៉ាងក្រៃលែង បានដល់កិរិយាដែលគប្បីធ្វើ យ៉ាងក្រៃលែង ឲ្យមានការប្លែកផ្សេងគ្នា ។

ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលហើយ ថា 'អធិកប្បយោគោ' ដូច្នេះ" ។

ដីកាមជ្ឈិមបណ្ណាសកៈ ក្នុងខន្ធកវគ្គ ថា “ឈ្មោះថា **អធិប្បាយសៈ** ព្រោះជាគ្រឿងប្រកប គឺ ប្រកបទូទៅ យ៉ាងក្រៃលែង គឺឲ្យប្លែកគ្នា បានដល់ ការប្រកបឲ្យប្លែកផ្សេងគ្នា ។

ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលហើយ ថា ‘**អធិកប្បយោគោ**’ ដូច្នេះ” ។

អដ្ឋកថាបឋមលោកធម្មសូត្រ ថា “បាទគាថាថា ‘**អវេក្ខតី វីបរិណាមធម្មេ**’ មានសេចក្ដីថា រមែងពិចារណាឃើញ យ៉ាងដូច្នេះថា ‘ធម៌ទាំងនេះ មានសេចក្ដីប្រែប្រួលជាធម្មតា’ ។ បទថា ‘**វិធូបិតា**’ បានដល់ កំចាត់ គឺ បំផ្លាញហើយ ។ ២ បទថា ‘**បទញ្ញ ញត្វា**’ បានដល់ ព្រោះដឹងបទ គឺ ព្រះនិព្វាន ។ បាទគាថា ថា ‘**សម្មប្បជានាតិ ភវស្ស បារគូ**’ មានសេចក្ដីថា ម្យ៉ាងទៀត ព្រះអរិយសាវ័កនោះ ដល់ត្រើយនៃភព គឺ ដល់នូវសេចក្ដីសម្រេច គឺ ទីបំផុត (នៃភព) រមែងដឹងដោយប្រពៃ នូវភាវៈនៃខ្លួនជាអ្នកដល់ត្រើយ នៃភពនោះ ព្រោះដឹងនូវបទ គឺ ព្រះនិព្វាននុ៎ះឯង” ។

ពណ៌នាអំពីចិត្តដែលលោកធម៌ធ្វើឱ្យកម្រើកមិនបាន ចប់ ។

⁂

## ពណ៌នាអំពីចិត្តដែលមិនសោកសៅ

(២០៩) ទោមនស្ស មានសេចក្តីវិនាសជាដើមជាហេតុ ឈ្មោះថា សោកៈ ។ សមដូចជាព្រះតម្រាស់ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកក្នុងមហាសតិបដ្ឋានសូត្រ[១] ថា " ម្នាលភិក្ខុទាំងឡាយ ក៏សេចក្តីសោក តើដូចម្តេច ?, ម្នាលភិក្ខុទាំងឡាយ សោកៈ គឺសេចក្តីស្តាយស្រណោះ សេចក្តីស្រងេះស្រងោច សេចក្តីសោកសៅ សេចក្តីរីងស្ងួតក្នុងចិត្ត សេចក្តីក្រៀមក្រំក្នុងចិត្តណា របស់សត្វ ដែលប្រកបដោយសេចក្តីវិនាសណាមួយ ( ឬ ) អ្នកដែលសេចក្តីទុក្ខធម៌ណាមួយ ពាល់ត្រូវហើយ, ម្នាលភិក្ខុទាំងឡាយ នេះ តថាគត ហៅថា សេចក្តីសោក " ។

(២១០) អដ្ឋកថាមហាសតិបដ្ឋានសូត្រនោះ ថា " បណ្តាបទទាំងនោះ បទថា ' ព្យសនេន ' មានសេចក្តីថា ដោយបណ្តាសេចក្តីវិនាសទាំងឡាយ មានសេចក្តីវិនាសចាកញាតិជាដើម ឯណានីមួយ ៗ បទថា ' ទុក្ខធម្មេន ' បានដល់ គឺហេតុនៃទុក្ខមានការសម្លាប់និងការចងជាដើម ( ពាល់ត្រូវហើយ ) ។ បទថា ' ផុដ្ឋស្ស ' បានដល់ ជិះជាន់ គឺ គ្របសង្កត់ហើយ ។ សេចក្តីសោក ដែលមានសេចក្តីសោកសៅចិត្តជាលក្ខណៈ ឯណា រមែង

១- ត្រៃបិដក ភាគទី ១៧ / ទំព័រទី ២៨៣ ។

កើតឡើង ដល់បុគ្គលអ្នក កាលបើសេចក្តីវិនាស ទាំងឡាយ មានសេចក្តីវិនាសញាតិជាដើម ឬហេតុនៃទុក្ខមានការសម្លាប់និង ការចងជាដើម ណានីមួយមាន ដែលសេចក្តីវិនាសឬហេតុនៃទុក្ខ ជាដើមនោះ គ្របសង្កត់ហើយ ឈ្មោះថា សោកៈ ។ ភាវៈនៃចិត្ត សោកសៅ ឈ្មោះថា **សោចិតត្តំ** ។ ក៏ព្រោះសេចក្តីសោកនុ៎ះ ញុំាងពួដ៏ខាងក្នុង ឲ្យរីងស្ងួត គឺ ឲ្យក្រៀមក្រំ តែងកើតឡើង, ហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា ' សេចក្តីរីងស្ងួត ក្នុងចិត្ត សេចក្តីក្រៀមក្រំក្នុងចិត្ត " ។

ដីកាមហាសតិបដ្ឋានសូត្រនោះ ថា " បទថា ' ព្យសនេន ' បានដល់ មិនមែនជាប្រយោជន៍ ។ ធម្មសព្ទ មានហេតុជា បរិយាយ ហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា ' គឺហេតុ នៃទុក្ខ ' ។ ភាវៈនៃបុគ្គល ឬនៃចិត្ត អ្នកដល់នូវសេចក្តីសោក គឺ អ្នកដែលសោកសៅ ឈ្មោះថា សេចក្តីសោកសៅចិត្តជាលក្ខណៈ ព្រោះភាវៈជាធម្មជាតដែលបុគ្គលគប្បីកំណត់ថា ' ការសោកសៅ ' ឈ្មោះថា ភាវៈនៃបុគ្គល ឬនៃចិត្ត អ្នកសោកសៅ ។ បទថា ' **អព្ភន្តរំ** ' មានសេចក្តីថា សេចក្តីសោកសៅនោះ ឈ្មោះថា ញុំាងពួដ៏ខាងក្នុង នៃអត្តភាពឲ្យរីងស្ងួត ព្រោះភាវៈនៃខ្លួនជាអ្នក សៅហ្មង, ឈ្មោះថា ញុំាងពួដ៏ខាងក្នុង នៃអត្តភាពឲ្យក្រៀមក្រំ

ដោយអំណាច នៃការសោកសៅ ដោយជុំវិញ ព្រោះដល់ភាពជារបស់មានកម្លាំង " ។

អដ្ឋកថាអដ្ឋសាលិនី ថា " ទោមនស្ស មានការសោយនូវអនិដ្ឋារម្មណ៍ជាលក្ខណៈ មានការជួបប្រសព្វនូវអាការៈ ដែលមិនជាទីប្រាថ្នាណានីមួយជាកិច្ច មានអាពាធដែលប្រព្រឹត្តទៅខាងផ្លូវចិត្តជាហេតុប្រាកដ " ។

(២១១) អដ្ឋកថាសច្ចវិភង្គ ថា " ក៏សេចក្តីសោកនេះនោះដោយសេចក្តី បានដល់ ទោមនស្សវេទនា ក៏ពិតមែន, សូម្បីកាលបើមានដូច្នោះ ក៏មានការក្រៀមខ្លោចពួដ៏ខាងក្នុងជាលក្ខណៈ មានសេចក្តីក្រៀមក្រំនៃចិត្តជាកិច្ច មានការតាមសោកសៅជាហេតុប្រាកដ " ។

ដីកាសច្ចវិភង្គនោះ ថា " ក៏ទោមនស្សវេទនា មានលក្ខណៈគឺព្រះអដ្ឋកថាចារ្យពោលហើយ ក្នុងខាងដើម ជាអាទិ៍ ឈ្មោះថាសេចក្តីសោក ហេតុនោះ មិនចាំបាច់ពោលអាការៈមានលក្ខណៈជាដើមទៀតឡើយ, ទោះបីដូច្នោះ អាការៈមានលក្ខណៈ ជាដើម ដែលមានសេចក្តីខុសប្លែកគ្នាអំពីសេចក្តីសោក ក៏គប្បីពោលព្រោះភាវៈនៃទោមនស្សមានសេចក្តីប្លែកផ្សេងគ្នា ព្រោះហេតុនោះព្រះអដ្ឋកថាចារ្យ ទើបពោលថា ' កិញ្ចាបិ ' ដូច្នេះជាដើម ។

កិរិយាគិតដែលកម្រើក ឬកិរិយាក្រៀមស្វួត ព្ធដ៏ខាងក្នុងនុ៎ះឯង ដែលប្រាសចាកភាពជាអ្នកក្លៀវក្លាអង់អាច ឈ្មោះថា ការក្រៀមក្រំក្នុងចិត្ត បានដល់ ការក្រៀមខ្លោច ការសោកសៅចិត្ត ដែលគួរដល់ការវិនាស មានការវិនាសចាកញាតិជាដើម ឈ្មោះថា សេចក្តីសោកសៅរឿយ ៗ ។ ម្យ៉ាងទៀត ការសោកសៅចិត្ត គឺការក្តៅក្រហាយ ទៅតាមគុណនិង ទោសនោះ ៗ ក៏ឈ្មោះថា សេចក្តីសោកសៅរឿយ ៗ " ។

អនុដីកា ថា "ដោយបទ ថា 'សង្កុបិតចិន្តនំ' នេះ លោកពោលកិរិយាប្រព្រឹត្តិទៅ នៃការមិនត្រេកអរយ៉ាងក្រៃលែង ក្នុងអារម្មណ៍ ព្រោះជាសឹកសត្រូវដល់បីតិនិងសោមនស្ស និងព្រោះប្រកបព្រមដោយទោមនស្ស ។ ម្យ៉ាងទៀត កិរិយាជញ្ជឹងគិត គឺការនឹកគិត ដោយអំណាច នៃការដុតកំទ្បោច នូវនិស្ស័យ របស់ខ្លួន ព្ធដ៏ខាងក្នុង ឈ្មោះថា ការក្រៀមក្រំក្នុងចិត្ត ។ បណ្ឌិតគប្បីជ្រាបសេចក្តីប្លែកផ្សេងគ្នា នៃការក្តៅក្រហាយ និងសេចក្តីសោកទាំង ២ យ៉ាងដូច្នេះថា 'កាលបើសេចក្តីសោកសៅរឿយៗ មាន, សេចក្តីក្តៅក្រហល់ក្រហាយ មានកុសលអកុសល ដែលខ្លួនបានធ្វើហើយ និងមិនបានធ្វើហើយ ជាអារម្មណ៍ ជាហេតុចាក់ដោតចិត្ត ឈ្មោះថា ការក្តៅក្រហាយ, សេចក្តីក្រៀមក្រំក្នុងចិត្ត តាមដែល

បានពោលមកហើយ ឈ្មោះថា សេចក្ដីសោកសៅ" ។

(២១២) ព្រោះហេតុនោះ បុគ្គល សូម្បីទុក្ខធមិពាល់ត្រូវហើយ ក៏មិនគួរសោកសៅ ប្រៀបដូចជាជនទាំងឡាយ មានជន ៥ នាក់ជាដើម ក្នុងអតីតកាល មិនសោកសៅដូច្នោះ ។

## ( រឿងជន ៥ នាក់ )

ក្នុងអតីតកាល ព្រះពោធិសត្វ កើតជាព្រាហ្មណ៍ ក្នុងទីក្រុងពារាណសី ចិញ្ចឹមជីវិត ដោយកសិកម្ម ។ ព្រះពោធិសត្វនោះ មានបុត្រ ២ នាក់ គឺ ប្រុស ១ ស្រី ១ ។ ព្រះពោធិសត្វនោះ នាំនាងកុមារិកា អំពីត្រកូលស្មើគ្នា ដើម្បីកូនប្រុសដែលចំរើនវ័យហើយ ។ ជនទាំង ៥ នាក់នោះ រួមបានជា ៦ នាក់ ទាំងស្ត្រីអ្នកបម្រើម្នាក់ទៀត ឈ្មោះថា នាងខុជ្ជុត្តរា ដោយប្រការដូច្នេះ ។ ព្រះពោធិសត្វ បានឲ្យឱវាទ ដល់ជនទាំងឡាយ មានភរិយាជាដើម ថា "អ្នកទាំងឡាយ ចូរចំរើនមរណស្សតិ ចូរកំណត់សេចក្ដីស្លាប់ របស់អ្នកទាំងឡាយ, ក៏សេចក្ដីស្លាប់ របស់សត្វទាំងនេះ ទៀងទាត់, ជីវិតមិនទៀងទាត់, សង្ខារទាំងឡាយទាំងពួង មិនទៀងឡើយ មានការអស់ទៅសូន្យទៅជាធម្មតា, អ្នកទាំងឡាយ ចូរជាអ្នក កុំប្រមាទ ទាំងថ្ងៃ ទាំងយប់ចុះ" ។ ជនទាំងនោះ បានឋិតនៅ ក្នុង

ឱវាទ របស់ព្រះពោធិសត្វនោះហើយ ក៏បានចំរើនមរណស្សតិ ។

ក្រោយមកថ្ងៃមួយ ព្រះពោធិសត្វទៅភ្ជួរស្រែ ជាមួយនឹងកូនប្រុស ។ កូនប្រុស បានប្រមូលនូវសម្រាមមកដុត ។ ពស់មានពិស នៅក្នុងជំបូកមួយ ក្នុងទីជិតនៃកូនប្រុសនោះ ។ ផ្សែងភ្លើងបានប៉ះត្រូវភ្នែកពស់នោះ ។ ពស់នោះខឹង បានវារចេញមកចឹកកូនប្រុសនោះ ។ កូនប្រុសនោះ ក៏ដួលស្លាប់មួយរំពេច ។ ព្រះពោធិសត្វ ដឹងថាកូនប្រុសនោះស្លាប់ហើយ ក៏លើកកូននោះឡើងដាក់ឲ្យដេក ក្រោមម្លប់ឈើមួយដើម មិនស្រែកយំឡើយ កំណត់នូវភាវៈនៃសង្ខារទាំងឡាយ ជារបស់មិនទៀងប៉ុណ្ណោះថា "ពួក ៥ នៃខន្ធ ដែលមានការបែកធ្លាយជាធម្មតា បែកធ្លាយហើយ, ដែលមានការស្លាប់ជាធម្មតា ស្លាប់ហើយ, សង្ខារទាំងឡាយទាំងពួង ជារបស់មិនទៀងទាត់ សម្រេចដោយសេចក្តីស្លាប់" ដូច្នេះហើយកំពុងតែភ្ជួរស្រែ បានឃើញបុរសអ្នកស្និទ្ធស្នាលម្នាក់ កំពុងដើរមកនៅក្បែរស្រែ ទើបសួរថា "នែអ្នក តើអ្នកទៅកាន់ផ្ទះឬ ?" ។ បុរសនោះ ប្រាប់ថា "មែនហើយ" ។ ព្រះពោធិសត្វ ប្រាប់ថា "បើដូច្នោះ អ្នកទៅផ្ទះរបស់ពួកខ្ញុំហើយ សូមជួយប្រាប់ទៅនាងព្រាហ្មណីផង ថា 'បានឮថា ថ្ងៃនេះ អ្នកមិនចាំបាច់នាំយកភត្តមកដើម្បីជន ២ នាក់ ដូចកាលមុនឡើយ គប្បីនាំមកដើម្បីជនម្នាក់

គត់ប៉ុណ្ណោះ, ក៏ក្នុងកាលមុន នាងទាសីម្នាក់ឯងនាំ (ភត្ត) មក, តែថ្ងៃនេះ ជនទាំង ៤ នាក់ត្រូវតែមក" ។ បុរសនោះ បានទៅប្រាប់ហើយ យ៉ាងដូច្នោះឯង ។ ជនទាំងអស់គ្នានោះ បានទៅក្នុងទីស្រែនោះ ឃើញកូនប្រុសនោះស្លាប់ហើយ ក៏យកគ្រឿងក្រអូបនិងផ្កាកម្រងមកបូជា ហើយបូជាសព ។ សូម្បីតែបុគ្គលម្នាក់ ក៏មិនមានការស្រែកយំ ឬការសង្រេងសង្រែឡើយ, ទឹកភ្នែកសូម្បីត្រឹមតែមួយតំណក់ ក៏មិនបានមានឡើយ ។ ព្រោះថា ជនទាំងអស់នោះ បានចំរើនមរណស្សតិប្រពៃហើយ ។ ដោយតេជះនៃគុណរបស់ជនទាំងនោះ ភពរបស់ស្តេចសក្កទេវរាជ កើតក្តៅហើយ ។

សក្កទេវរាជ ទ្រង់ពិចារណាមើល ក៏ទ្រង់ជ្រាបហេតុនោះហើយ មានព្រះទ័យត្រេកអរ ស្តេចយាងទៅក្នុងទីនោះ ហើយទ្រង់ត្រាស់សួរ នូវហេតុដែលមិនសោកសៅ នឹងជនទាំងអស់នោះ ។ ជនទាំងអស់នោះ បានក្រាបទូល ដល់ស្តេចសក្កទេវរាជនោះហើយ ។

ក៏បណ្តាជនទាំងនោះ ព្រះពោធិសត្វ ក្រាបទូលយ៉ាងនេះ ថា ÷

(២១៣) "កូនរបស់ខ្ញុំម្ចាស់,[១] កាលបើសរីរៈប្រើប្រាស់មិនបាន លះលោកនេះទៅហើយ ធ្វើកាលៈទៅហើយ, ក៏លះបង់នូវរាងកាយ របស់ខ្លួនទៅ

---

១ - ត្រៃបិដក ភាគទី ៥៩ / ទំព័រទី ៥ ។

ប្រៀបដូចជាពស់ សកសំណកចាស់ចោលហើយទៅ យ៉ាងដូច្នោះឯង, កូនរបស់ខ្ញុំម្ចាស់នោះ កាលពួកខ្ញុំម្ចាស់ប្រជុំគ្នាដុត រមែងមិនដឹងនូវការយំស្រែករបស់ពួកញាតិ ។ ព្រោះហេតុនោះ ខ្ញុំម្ចាស់ទើបមិនសោកសៅ នឹងកូននោះ, គតិណា ជាគតិរបស់គេ, គេទៅកាន់គតិ របស់គេនោះហើយ ”។

បណ្ដាបទទាំងនោះ បទថា “ ឧរគោវ ” មានសេចក្ដីថា ពស់សកសំណកចាស់ចោលហើយ ជាសត្វមិនមានអាល័យ លះបង់ចោលហើយលូនទៅ យ៉ាងណាមិញ ។ បទថា “ សន្តនុំ ” គឺ សរីរៈរបស់ខ្លួន ។ បទថា “ និព្ភោគេ ” គឺ ប្រាសចាកការប្រើប្រាស់ ព្រោះមិនមានជីវិតិន្ទ្រីយ៍ ។ បទថា “ បេតេ ” បានដល់ ត្រឡប់ទៅកាន់បរលោក ។ បទថា “ កាលកតេ ” ប្រែថា ធ្វើកាលៈទៅហើយ អធិប្បាយថា ធ្វើមរណកាលហើយ ។ បទថា “ សតិ ” មានសេចក្ដីថា កាលបើបុត្ររបស់ខ្ញុំនោះ លះលោកនេះទៅហើយ គឺ ធ្វើកាលមរណៈ ព្រាត់ប្រាសទៅហើយ, នឹងមានប្រយោជន៍អ្វី ដោយការស្រែកយំ ឬការខ្សឹកខ្សួល ។ បទថា “ ឌយ្ហមានោ ” មានសេចក្ដីថា កូនរបស់ខ្ញុំនេះ រមែងមិនដឹង

នូវការយំស្រែករបស់ពួកញាតិឡើយ ដូចជាគេត្រូវពួកយើងយកលំពែងដែករុកហើយដុត ក៏ឥតបានដឹងសុខនិងទុក្ខ ដូច្នោះឯង ។ បទថា " តស្មា " មានសេចក្ដីថា ព្រោះហេតុនោះ ខ្ញុំម្ចាស់ ទើបមិនសោកសៅដល់កូននោះ, ក៏គតិណា ជាគតិរបស់ខ្លួនគេ, គេក៏ទៅកាន់គតិ របស់ខ្លួនគេនោះហើយ ។

ចំណែកខាងនាងព្រាហ្មណី បានក្រាបទូល ថា ÷

(២១៤) " កូនរបស់នាងខ្ញុំនោះ មកហើយចាកបរលោកនោះ នាងខ្ញុំក៏មិនបានអញ្ជើញមកឡើយ, កូនរបស់នាងខ្ញុំនោះ ទៅហើយ ចាកលោកនេះ នាងខ្ញុំ ក៏មិនបានអនុញ្ញាតឲ្យទៅដែរ, គេមកហើយយ៉ាងណា, គេក៏ទៅហើយ យ៉ាងនោះ, នឹងមានការយំស្រែកអ្វី ព្រោះការទៅចាកលោកនេះ របស់គេនោះ, កូនរបស់នាងខ្ញុំនោះ ត្រូវពួកខ្ញុំប្រជុំគ្នាដុត ក៏មិនដឹង នូវការយំស្រែក របស់ពួកញាតិ, ព្រោះហេតុនោះ នាងខ្ញុំទើបមិនសោកសៅដល់គេ, គេទៅកាន់គតិ របស់គេហើយ " ។

បណ្ដាបទទាំងនោះ បទថា " អនវ្ហាតោ " មានសេចក្ដីថា

កូននេះ នាងខ្ញុំឥតបានអញ្ជើញមកទេ គឺ មិនបានសុំ អំពីបរលោក មកឡើយ ៗ បទថា “ អាគា ” មានសេចក្តីថា មកហើយកាន់ផ្ទះ របស់នាងខ្ញុំ ៗ បទថា “ ឥតោ ” មានសេចក្តីថា កូនរបស់ នាងខ្ញុំនោះ សូម្បីកាលទៅចាកមនុស្សលោក នាងខ្ញុំក៏មិនបាន អនុញ្ញាតឲ្យទៅឡើយ, គេទៅខ្លួនឯង ៗ ២ បទថា “ យថាគតោ ” មានសេចក្តីថា កូនរបស់នាងខ្ញុំនេះ សូម្បីកាលមក ក៏មក ហើយតាមសេចក្តីពេញចិត្ត របស់ខ្លួន យ៉ាងណា, កាលទៅ ក៏ទៅ ហើយតាមសេចក្តីពេញចិត្តរបស់ខ្លួន យ៉ាងដូច្នោះដែរ ៗ បទថា “ តត្ថ ” មានសេចក្តីថា នឹងមានការយំសោកអ្វី ក្នុងការទៅចាក លោកនេះ របស់គេនោះ ៗ

ឯចំណែកប្អូនស្រីវិញ បានក្រាបទូល ថា ÷

(២១៥) “ បើនាងខ្ញុំយំសោក នឹងជាស្រីស្គមស្រេក ស្រពោនស្រុតសាច់, នឹងមានផលអ្វីដល់នាងខ្ញុំដែលយំសោក នោះ, នឹងមានតែសេចក្តីថ្នាំងថ្នាក់ចិត្ត ដ៏ក្រៃលែង ដល់ញាតិមិត្រនិងសំឡាញ់ របស់យើងខ្ញុំទាំងឡាយ, បងប្រុសរបស់នាងខ្ញុំនោះ ត្រូវពួកយើងខ្ញុំប្រជុំគ្នាដុត ក៏មិនដឹងនូវការយំស្រែក របស់ពួកញាតិ, ព្រោះ

ហេតុនោះ នាងខ្ញុំទើបមិនសោកសៅ ដល់គាត់,
បងប្រុសនាងខ្ញុំ បានទៅកាន់គតិរបស់គាត់ហើយ"។

បណ្ដាបទទាំងនោះ បទថា "**រោទេ**" មានសេចក្ដីថា បើបងប្រុសស្លាប់ហើយ, នាងខ្ញុំគប្បីយំសោក ៗ ២ បទថា "**កិសា អស្សំ**" មានសេចក្ដីថា នាងខ្ញុំគប្បីមានសរីរៈស្គមស្រកស្រុតសាច់, នាងរមែងសំដែង ថា "ក៏ឈ្មោះថា សេចក្ដីចំរើន ព្រោះការយំសោកនោះជាបច្ច័យ រមែងមិនមាន ដល់បងប្រុសរបស់នាងខ្ញុំឡើយ" ។ ២ បទថា "**កឹ ផលំ**" មានសេចក្ដីថា កាលបើនាងខ្ញុំនោះ យំសោក, អានិសង្សអ្វីគប្បីកើតមាន, នាងសំដែង ថា "ក៏សេចក្ដីមិនចំរើន រមែងប្រាកដ"។ បាទគាថា ថា "ញាតិមិត្តសុហជ្ជានំ" បានដល់ ញាតិមិត្រនិងសំឡាញ់ ៗ បាលីក៏យ៉ាងដូច្នេះដែរ ៗ ២ បទថា "**ភិយ្យោ នោ**" មានសេចក្ដីថា ជនទាំងឡាយណាដែលត្រូវជាញាតិមិត្រនិងសំឡាញ់ នៃពួកនាងខ្ញុំ, សេចក្ដីថ្នាំងថ្នាក់ចិត្ត យ៉ាងក្រៃលែង ក៏គប្បីមាន ដល់ពួកជនដែលជាញាតិមិត្រនិងសំឡាញ់ទាំងនោះ ៗ

ចំណែកភរិយារបស់គេ បានក្រាបទូល ថា ÷

(២១៦) " បុគ្គលណាសោកស្ដាយ នូវជនដែល

ទៅកាន់បរលោកហើយ, បុគ្គលនោះ ក៏ដូចជាកូនក្មេងតូចដែលយំចង់បាននូវព្រះច័ន្ទ ដែលកំពុងចរ (ឰដ៏អាកាស) ដូច្នោះឯង, នេះជាពាក្យឧបមានៃការមិនសោកស្តាយ របស់នាងខ្ញុំ, ស្វាមីរបស់នាងខ្ញុំនោះ ត្រូវពួកនាងខ្ញុំប្រជុំគ្នាដុត ក៏មិនដឹងនូវការយំសោក របស់ពួកញាតិ, ព្រោះហេតុនោះទើបនាងខ្ញុំ មិនសោកសៅដល់គាត់, ស្វាមីរបស់នាងខ្ញុំនោះ បានទៅកាន់គតិរបស់គាត់ហើយ " ។

បណ្តាបទទាំងនោះ បទថា " ទារកោ " មានសេចក្តីថា ក្មេងតូចមិនដឹងនូវរបស់ដែលគួរនិងមិនគួរ របស់ដែលគួរបាននិងមិនគួរបាន អង្គុយលើភ្លៅមាតា ឃើញព្រះច័ន្ទដែលពេញវង់កំពុងចរទៅតាមផ្លូវអាកាសហើយ ក៏ស្រែកយំទាររឿយៗថា " បពិត្រអ្នកម្តាយ ចូរម៉ែឲ្យព្រះច័ន្ទដល់ខ្ញុំ, ចូរម៉ែឲ្យព្រះច័ន្ទដល់ខ្ញុំ " ។ បាទគាថាថា " ឯវំ សម្បទមេវេតំ " មានសេចក្តីថា បុគ្គលណារមែងតាមសោកសៅ ដល់បុគ្គលអ្នកលះលោកនេះទៅហើយ ធ្វើនូវកាលកិរិយាទៅហើយ, ការតាមសោកសៅនុ៎ះ របស់បុគ្គលនោះរមែងសម្រេចផល យ៉ាងដូច្នោះឯង ។ ការតាមសោកសៅនោះ

មិនមានប្រយោជន៍ ជាងការយំទារក ព្រោះចង់បានព្រះច័ន្ទ របស់កូនក្មេងតូចនោះទៅទៀត ។ ព្រោះហេតុអ្វី ? ។ ព្រោះទារកនោះ រមែងតាមសោកសៅដល់ព្រះច័ន្ទដែលមានប្រាកដ, តែស្វាមីរបស់នាងខ្ញុំស្លាប់ហើយ មិនប្រាកដមាននៅ ក្នុងពេលនេះទេ ។

ចំណែកស្រ្តីបម្រើ បានក្រាបទូល ថា ÷

(២១៧) " បពិត្រព្រះអង្គដ៏ប្រសើរ ក្អមទឹកដែលបែកហើយ មិនអាចបុគ្គលណា តភ្ជាប់ដូចដើមវិញបានឡើយ មានឧបមាយ៉ាងណា, បុគ្គលណាតែងតាមសោកស្តាយ នូវជនដែលលះលោកទៅហើយ, ការដែលបុគ្គលសោកស្តាយដល់ជននោះនេះ ក៏មានឧបមេយ្យយ៉ាងដូច្នោះដែរ, កូនរបស់ចៅហ្វាយខ្ញុំនោះ ត្រូវពួកញាតិប្រជុំគ្នាដុត ក៏ឥតបានដឹងនូវការយំសោក របស់ពួកញាតិដែរ, ព្រោះហេតុនោះទើបនាងខ្ញុំ មិនសោកសៅ ដល់ចៅហ្វាយខ្ញុំនោះ, ចៅហ្វាយខ្ញុំនោះ ទៅកាន់គតិ របស់គាត់ហើយ "។

បណ្តាបទទាំងនោះ បទថា " ឧទកុម្ភោ " មានសេចក្តីថា ក្អមទឹក ដែលបុគ្គលលើកឡើង ធ្លាក់បែក ជា ៧ ចំណែកហើយ

មិនអាចបុគ្គលណា តភ្ជាប់ដូចដើមវិញបានឡើយ យ៉ាងណាមិញ, បុគ្គលណា តាមសោកសៅ នឹងបុគ្គលអ្នកលះលោកនេះទៅហើយ, ការតាមសោកសៅនុ៎ះ សូម្បីនៃបុគ្គលនោះ រមែងសម្រេចផល យ៉ាងដូច្នោះឯង ព្រោះភារៈនៃបុគ្គលអ្នកស្លាប់ទៅហើយ នរណាក៏មិនអាចដើម្បីធ្វើឲ្យរស់ឡើងវិញបានទៀតឡើយ ។ បុគ្គលអ្នកមានឫទ្ធិប៉ុណ្ណោះ គប្បីអាចនឹងតភ្ជាប់នូវក្អមទឹក ដែលបែកហើយ ដោយអានុភាពនៃឫទ្ធិ ហើយធ្វើឲ្យពេញប្រៀប ដោយទឹកបាន, តែបុគ្គលដែលធ្វើកាលកិរិយាទៅហើយ នរណាក៏មិនអាចដើម្បីនឹងធ្វើឲ្យត្រឡប់មកជាប្រក្រតី សូម្បីដោយកំឡាំង នៃឫទ្ធិបានវិញឡើយ ។

(២១៨) ស្តេចសក្កទេវរាជ ទ្រង់ព្រះសណ្តាប់នូវធម្មកថារបស់ជនទាំងអស់ហើយ ទ្រង់ជ្រះថ្លា ទ្រង់ត្រាស់ថា “ចាប់ដើមអំពីថ្ងៃនេះទៅ ពួកអ្នក កុំធ្វើការងារ ដោយដៃរបស់ខ្លួនឡើយ, ខ្ញុំជាស្តេចសក្កទេវរាជ នឹងធ្វើនូវរតនៈ ៧ ប្រការ មិនមានប្រមាណទុកក្នុងផ្ទះ របស់អ្នកទាំងឡាយ, ពួកអ្នកចូរឲ្យទាន ចូររក្សាសីល ចូរនៅរក្សាឧបោសថសីលចុះ” ដូច្នេះហើយ ទ្រង់ធ្វើយ៉ាងដូច្នោះឯង ហើយស្តេចយាងទៅកាន់ទីស្ថាន របស់ព្រះអង្គ ដូចដើមវិញ ។

ជនទាំង ៥ នាក់នោះ ត្រឡប់បានទ្រព្យរាប់មិនអស់ ដែល

មានសេចក្តីមិនសោកសៅជាមូលហេតុ ដោយប្រការដូច្នេះឯង ។

ឯព្រះសាស្តា លុះទ្រង់នាំរឿងអតីតកាលនេះមក ដើម្បីនឹងទ្រង់នាំចេញនូវសេចក្តីសោកសៅ របស់កុដុម្ពិក៍ម្នាក់ ដែលមានកូនស្លាប់ចោលហើយ ទើបទ្រង់ប្រកាសនូវសច្ចៈទាំងឡាយ ។ ក្នុងទីបញ្ចប់នៃសច្ចៈ កុដុម្ពិក៍នោះ បន្ថយនូវសេចក្តីសោកសៅបានហើយ ក៏បានសម្រេចជាព្រះសោតាបន្ន ។

រឿងជន ៥ នាក់ មកក្នុងអដ្ឋកថាឧរគជាតក ក្នុងបឋមវគ្គ

នៃបញ្ចកនិបាត ។

## ( រឿងព្រះបាទឃតរាជ )

(២១៩) ក្នុងអតីតកាល ព្រះរាជាក្រុងសាវត្ថី ទ្រង់ព្រះនាមថាធង្កៈ ទ្រង់ដណ្តើមយករាជសម្បត្តិ ក្នុងនគរពារាណសីបានហើយ ទ្រង់ត្រាស់បញ្ជាឲ្យចងព្រះរាជាព្រះនាមឃតៈ ដោយខ្នោះឃ្នាងទាំងឡាយ ហើយត្រាស់បញ្ជាឲ្យឃុំឃាំង ក្នុងពន្ធនាគារ ។ ព្រះបាទឃតរាជ ទ្រង់មិនបានសោកសៅនឹងរាជសម្បត្តិដែលបានវិនាសបាត់ទៅហើយ ទ្រង់បានពិចារណាកសិណ ញុំាងឈានឲ្យកើតឡើងហើយ ទ្រង់គង់ចំរើនសមាធិ ពួដ៏អាកាស ។

ព្រះរាជាព្រះនាមធង្កៈ ទ្រង់កើតសេចក្តីក្តៅក្រហាយ ក្នុង

ព្រះសរីរៈ ស្តេចក្រោកឡើងហើយយាងទៅ កាន់សំណាក់ព្រះបាទយតរាជនោះ ទ្រង់ទតឃើញព្រះភក្ត្រនៃព្រះបាទយតរាជ មានរស្មីភ្លឺថ្លា ដូចជាកញ្ចក់មាស និងផ្កាបទុម ទើបទ្រង់ត្រាស់សួរហេតុដែលមិនទ្រង់សោកសៅ នឹងព្រះបាទយតរាជនោះ ។ ព្រះបាទយតរាជ កាលទ្រង់ត្រាស់ប្រាប់ដល់ព្រះបាទធង្ករាជ ទ្រង់បានត្រាស់នូវគាថាទាំងនេះ ក្នុងធង្ករាជជាតក[១] ក្នុងបញ្ចកនិបាតនោះឯង ថា ÷

> " សេចក្តីសោកនាំមកនូវសេចក្តីសុខ ដែលកន្លងទៅហើយមិនបានទេ នាំមកនូវសេចក្តីសុខ ដែលមិនទាន់មកដល់មិនបានទេ, បពិត្រស្តេចធង្កៈ ព្រោះហេតុនោះទើបខ្ញុំមិនសោកសៅ, ព្រោះថា ភាពជាសំឡាញ់ក្នុងសេចក្តីសោក មិនមានទេ, បុគ្គលកាលសោក រមែងជាអ្នកមានរោគលឿងស្គាំងស្គម, ទាំងបាយ រមែងមិនពេញចិត្ត ដល់បុគ្គលនោះ, កាលបើបុគ្គលដែលត្រូវសរគឺសេចក្តីសោកមុតហើយ ក៏ទុក្ខព្រួយ, ពួកជនជាសត្រូវ រមែងមានចិត្តត្រេកអរ " ។

បណ្តាបទទាំងនោះ បទថា " នាព្ភតីតហរោ " គឺ នាំនូវសេចក្តីសុខ ដែលកន្លងទៅហើយមកឲ្យ មិនបានទេ ។ ម្យ៉ាងទៀត

១- ត្រៃបិដក ភាគទី ៥៩ ⁄ ទំព័រទី ៧ ។

បាលីក៏យ៉ាងដូច្នេះដែរ ។ អធិប្បាយថា ធម្មតាសេចក្តីសោកសៅ រមែងនាំសេចក្តីសុខ ដែលកន្លងទៅហើយ គឺ ឆ្លងផុតហើយ រលត់ទៅហើយ សាបសូន្យទៅហើយ មកឲ្យទៀត មិនបានសោះឡើយ ។ ភាពជាសំឡាញ់ ឈ្មោះថា **ទុតិយតា** ។ អធិប្បាយថា ឈ្មោះថា សេចក្តីសោក រមែងមិនជាសំឡាញ់ ដល់អ្នកណាមួយ ដោយនាំនូវសេចក្តីសុខ ដែលកន្លងទៅហើយមកឲ្យ ឬដោយនាំសេចក្តីសុខ ដែលមិនទាន់មកដល់មកឲ្យ ។ បទថា " **តេន** " មានសេចក្តីថា ព្រោះហេតុនោះ ទើបខ្ញុំមិនសោកសៅ ។ បទថា " **សោចំ** " គឺ កាលសោកសៅ ។ បាទគាថាថា " **សល្លវិទ្ធស្ស រុប្បតោ** " មានសេចក្តីថា កាលបើបុគ្គលត្រូវកូនសរ គឺសេចក្តីសោកមុតហើយ គឺ ត្រូវកូនសរ គឺសេចក្តីសោកនោះ មកប៉ះទង្គិច, ពួកជនជាសត្រូវ រមែងមានចិត្តត្រេកអរ ថា " ពួកយើង បានឃើញខ្នងបច្ចាមិត្រហើយតើហ៎ " ដូច្នេះ, អធិប្បាយថា " ព្រោះហេតុនោះឯង ទើបខ្ញុំ មិនសោកសៅ " ។

ព្រះបាទធង្ករាជ ទ្រង់ព្រះសណ្តាប់នូវព្រះរាជឱង្ការឆ្លើយតបនោះហើយ ទ្រង់ញ៉ាំងព្រះបាទយតរាជនោះ ឲ្យទ្រង់អត់ទោសឲ្យទ្រង់បានថ្វាយរាជសម្បត្តិមកវិញ ហើយស្តេចយាងត្រឡប់ទៅកាន់ទីក្រុងសាវត្ថី ដូចដើមវិញ ។ ឯព្រះបាទយតរាជ ទ្រង់បាន

ប្រគល់រាជសម្បត្តិ ដល់ពួកអាមាត្យស្រេចហើយ ស្តេចយាងទៅកាន់ហិមវន្តប្រទេស ទ្រង់ព្រះផ្នួស មានឈានមិនវិនាសហើយ ទ្រង់ស្តេចបានទៅកើតក្នុងព្រហ្មលោកហើយ ។

ព្រះបាទយតរាជនោះ សូម្បីត្រូវទុក្ខធម៌ពាល់ត្រូវហើយ ក៏មិនទ្រង់សោកសៅ ទ្រង់បានញ៉ាំងឈានឲ្យកើតឡើងហើយ ។

រឿងព្រះបាទយតរាជ ចប់ ។

សូម្បីរឿងដែលកន្លងមកហើយ បណ្ឌិតក៏គប្បីត្រួតពិនិត្យមើល ក្នុងមតរោទនជាតក ក្នុងទុតិយវគ្គ ចតុក្កនិបាត (និង) ក្នុងអននុសោចិយជាតក ក្នុងតតិយវគ្គ នៃចតុក្កនិបាតនោះឯង ។

(២២០) ន័យមួយទៀត ធម្មតាបុថុជ្ជន រមែងមិនអាចដើម្បីនឹងជាអ្នកមិនមានសេចក្តីសោក ក្នុងកាលទាំងពួងបានឡើយ ។ ព្រោះហេតុនោះ បុគ្គលអ្នកដែលត្រូវលោកធម៌ ដែលជាហេតុនៃសេចក្តីសោកពាល់ត្រូវហើយ សូម្បីជាខាងដើម សោកសៅ (តែ) ខាងក្រោយមក គប្បីបន្ថយនូវសេចក្តីសោកនោះ ដោយកិច្ចមានការស្តាប់ធម៌ជាដើម ព្រោះថា កាលធ្វើដូច្នេះ រមែងបានសុខ ។

ក៏ក្នុងសេចក្តីនេះ មានរឿងអញ្ញត្រព្រាហ្មណ៍ជាដើម ជាឧទាហរណ៍ ។

## ( រឿងអញ្ញតរព្រាហ្មណ៍ )

បានឮថា ព្រាហ្មណ៍អ្នកនៅក្នុងទីក្រុងសាវត្ថីម្នាក់ ធ្វើស្រែនៅក្បែរមាត់ស្ទឹងអចិរវតី, កាលបើស្រូវទុំហើយ, ធ្វើសេចក្ដីតាំងចិត្តថា "ស្អែកនេះ អាត្មាអញនឹងច្រូតកាត់" ដូច្នេះហើយ ក៏ដេក ។ ក៏ក្នុងយប់នោះ ភ្លៀងធ្លាក់ព្រិល ធ្លាក់ហើយ លើស្ទឹងអចិរវតី ។ ទឹកជំនន់ដ៏ធំ បានកួចយកស្រូវទាំងអស់ ឲ្យចូលទៅកាន់សមុទ្រ មិនឲ្យនៅសល់សូម្បីត្រឹមតែមួយនាឡិឡើយ ។ កាលបើទឹកជំនន់បានស្រកចុះអស់ហើយ, ព្រាហ្មណ៍ឃើញការវិនាសខូចខាតនៃស្រូវ ត្រូវសេចក្ដីសោក ដែលមានកម្លាំងគ្របសង្កត់ហើយ យកដៃអោបដើមទ្រូង ដើរទៅផ្ទះ ហើយដេកថ្ងូររវើរវាយ ។

ព្រះសាស្ដា ទ្រង់ទតព្រះនេត្រឃើញឧបនិស្ស័យ នៃបឋមមគ្គរបស់ព្រាហ្មណ៍នោះ ទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ស្ដេចយាងទៅកាន់ផ្ទះរបស់ព្រាហ្មណ៍នោះ តែមួយព្រះអង្គឯង ទ្រង់ស្ដេចគង់លើអាសនៈ ដែលព្រាហ្មណ៍ក្រាលថ្វាយហើយ ទ្រង់ត្រាស់សំដែងនូវកាមសូត្រ ថា "**កាមំ កាមយមានស្ស**" ដូច្នេះជាដើម ដោយន័យដែលទ្រង់ត្រាស់ទុកហើយ ក្នុងចតុត្ថវគ្គ នៃសុត្តនិបាត ។ ព្រាហ្មណ៍នោះ ត្រឡប់បានសេចក្ដីសប្បាយ ព្រោះការស្ដាប់ធម៌បន្ថយនូវសេចក្ដីសោកបានហើយ ចំរើនវិបស្សនា ក៏បានជាព្រះ

សោតាបន្ន, ចំណែកនាងព្រាហ្មណី របស់ព្រាហ្មណ៍នោះ ក៏បានសម្រេចជាព្រះសោតាបន្នដែរ ក្នុងទីបញ្ចប់នៃព្រះធម៌ទេសនា ។

រឿងអញ្ញត្រព្រាហ្មណ៍ មកក្នុងអដ្ឋកថា នៃកាមសូត្រ ក្នុងសត្តនិបាត និងអដ្ឋកថាកាមជាតក ក្នុងទ្វាទសនិបាត ។

(២២១) សូម្បីកុដុម្ពីក៍អ្នកក្រុងសាវត្ថីម្នាក់ ត្រូវសេចក្តីសោកគ្របសង្កត់ហើយ ព្រោះកាលកិរិយារបស់បងប្រុស មិនងូតទឹក មិនបរិភោគ មិនលាបស្រឡាប ទៅកាន់ទីស្មសាន តាំងអំពីព្រឹកព្រលឹម ហើយស្រែកទ្រហោយំ ។

ព្រះសាស្តា ទ្រង់ទតព្រះនេត្រឃើញឧបនិស្ស័យ នៃបឋមមគ្គរបស់កុដុម្ពីក៍នោះហើយ ទ្រង់ធ្វើភត្តកិច្ចស្រេច ទ្រង់នាំភិក្ខុមួយអង្គ ជាបច្ឆាសមណៈ ហើយស្តេចយាងទៅកាន់ផ្ទះ របស់កុដុម្ពីក៍នោះ ទ្រង់គង់លើអាសនៈ ដែលកុដុម្ពីក៍នោះក្រាលថ្វាយហើយ ទ្រង់ត្រាស់ ថា " សង្ខារទាំងឡាយទាំងពួង ជារបស់មិនទៀង, ខន្ធបញ្ចកៈ គួរដល់ភាពដែលគួរបែកធ្លាយ រមែងបែកធ្លាយ, ក្នុងរឿងនោះ នរណាក៏មិនគួរគិតឡើយ" ដូច្នេះហើយ ទ្រង់ត្រាស់នូវមតរោទនជាតក ទ្រង់ប្រកាសហើយ នូវសច្ចៈទាំងឡាយ ។ ក្នុងទីបញ្ចប់នៃសច្ចៈ កុដុម្ពីក៍បានសម្រេចព្រះសោតាបន្នហើយ ។

កុដុម្ពីក៏ម្នាក់ទៀត មានភរិយាស្លាប់ហើយ ជាអ្នកគឺសេចក្ដីសោកគ្របសង្កត់ហើយ ក៏យ៉ាងដូច្នោះដែរ ។

ចំណែកព្រះសាស្ដា ក៏ស្ដេចយាងទៅកាន់ផ្ទះ របស់កុដុម្ពីក៏នោះដោយន័យមុននុ៎ះឯង ទ្រង់ត្រាស់ហើយ នូវអននុសោចិយជាតក ។ ក្នុងកាលចប់នៃសច្ចៈ កុដុម្ពីក៏នោះឯង ក៏បានជាព្រះសោតាបន្ន ។

កុដុម្ពីក៏ទាំងនេះ ជាដំបូង ជាអ្នកសោកសៅ ក្រោយមកបន្ទយនូវសេចក្ដីសោក ក៏បានទទួលសេចក្ដីសុខ យ៉ាងដូច្នេះឯង ។

ពណ៌នាអំពីចិត្តដែលមិនសោកសៅ ចប់ ។

*ការចេះច្រើនភាសាជាការប្រសើរណាស់*
*តែកុំភ្លេចជាតិសាស្ត្ររបស់ខ្លួនឯង ។*

ប្រែចប់ ថ្ងៃចន្ទ ៧ កើត ខែចេត្រ ឆ្នាំរកា បញ្ចស័ក ព.ស.២៥៣៦
ត្រូវនិងថ្ងៃទី ២៩ ខែ មិនា ១៩៩៣
វេលាព្រឹក

## ពណ៌នាអំពីចិត្តដែលប្រាសចាកកិលេសដូចជាធូលី

---

(២២២) រាគៈ ទោសៈ និងមោហៈ ឈ្មោះថា ធូលី ។ មែនពិត រាគៈ ទោសៈ និងមោហៈទាំងនោះ រមែងធ្វើនូវចិត្តនោះៗឲ្យសៅហ្មង ប្រៀបដូចជា ធូលីតាមប្រក្រតី ធ្លាក់ហើយ ក្នុងទីកន្លែងណាៗ រមែងធ្វើនូវទីកន្លែងនោះៗ ឲ្យសៅហ្មង ដូច្នោះឯង ។ ព្រោះហេតុនោះ រាគៈ ទោសៈ និងមោហៈទាំងនោះ លោកហៅថា "ធូលី" ព្រោះដូចជាធូលី ព្រោះភាពស្មើគ្នាដោយធូលី ដោយកិរិយាធ្វើឲ្យសៅហ្មង ។

ពិតមែនយ៉ាងដូច្នោះ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងផ្ទះរបស់គ្រូទេព្យជីវកន្ទុំរឯង ទ្រង់បានបញ្ចេញព្រះរស្មីទៅ ដល់ភិក្ខុឈ្មោះចូឡបន្ថក ដែលគង់នៅក្នុងវត្តវេឡុវ័ន ហើយទ្រង់ត្រាស់នូវព្រះគាថាទាំងឡាយ ៣ នេះ ថា ÷

(២២៣) "រាគៈ តថាគតហៅថា ជាធូលី ប៉ុន្តែលំអង តថាគត មិនហៅថា ជាធូលី ទេ, ព្រោះពាក្យថា រជោ នោះ ជាឈ្មោះ របស់រាគៈ, ភិក្ខុទាំងឡាយនោះ រមែងនៅ ក្នុងសាសនា របស់

លោកអ្នកប្រាសចាកធូលីហើយ ព្រោះលះចោលនូវធូលីនោះ ។ ទោសៈ តថាគត ហៅថា ធូលី ប៉ុន្តែលំអង តថាគត មិនហៅថា ជាធូលី ទេ, ព្រោះពាក្យថា រជោ នុ៎ះ ជាឈ្មោះ នៃទោសៈ, ភិក្ខុទាំងឡាយនោះ រមែងនៅ ក្នុងសាសនា របស់លោកអ្នកប្រាសចាកធូលីហើយ ព្រោះលះចោលនូវធូលីនុ៎ះ ។ មោហៈ តថាគត ហៅថា ជាធូលី ប៉ុន្តែលំអង តថាគត មិនហៅថា ជាធូលី ទេ, ព្រោះពាក្យថា រជោ នុ៎ះ ជាឈ្មោះ នៃមោហៈ, ភិក្ខុទាំងឡាយនោះ រមែងនៅក្នុងសាសនា របស់លោកអ្នកប្រាសចាកធូលីហើយ ព្រោះលះចោលនូវធូលីនុ៎ះ" ។

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថានោះ ដូចតទៅ ÷ រាគៈ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា "ជាធូលី" ក្នុងអរិយវិន័យ, ប៉ុន្តែ លំអង ព្រះអង្គ មិនត្រាស់ហៅថា "ជាធូលី" ទេ ។ ព្រោះហេតុនោះ ពាក្យថា "រជោ" នុ៎ះ ទើបជាឈ្មោះ នៃរាគៈ ព្រោះធ្វើនូវភាវៈគឺសេចក្ដីសៅហ្មង់នៃចិត្ត ។ ព្រោះលះចោលនូវធូលី ពោលគឺរាគៈនោះ ។ បទថា "វិប្បជហិត្វា" គឺ ព្រោះ

ហេតុលះ (កិលេសដូចធូលី) ដោយមគ្គដ៏ខ្ពង់ខ្ពស់ ដោយវិសេស ។ ២ បទថា "វិហរន្តិ តេ" មានសេចក្តីថា ភិក្ខុទាំងនោះ គឺជាអ្នកលះបង់ ជាបណ្ឌិត រមែងនៅ ក្នុងសាសនា របស់លោកអ្នកដែលប្រាសចាកធូលីហើយ គឺរបស់ព្រះដ៏មានព្រះភាគ ដែលជាព្រះពុទ្ធនុ៎ះឯង ព្រះអង្គទ្រង់មានធូលី គឺរាគៈជាដើម ទ្រង់លះបង់ចោលបានហើយ ដោយប្រការទាំងពួង ។

(២២៤) ក៏រាគៈ ទោសៈនិងមោហៈទាំងនោះ ឈ្មោះថាស្មើគ្នាតែមួយ ព្រោះភាវៈជាសភាពស្មើ ដោយធូលី ក៏ពិតមែន ។ ទោះជាដូច្នោះ សេចក្តីប្លែកផ្សេងគ្នា នៃរាគៈ ទោសៈ និងមោហៈទាំងនោះ រមែងមានដោយពិត ។

សមដូចជាព្រះតម្រាស់ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកក្នុងទុតិយវគ្គ នៃទុតិយបណ្ណាសកៈ ក្នុងតិកនិបាត អង្គុត្តរនិកាយ ថា "ម្នាលភិក្ខុទាំងឡាយ បើបរិព្វាជកជាអន្យតិរ្ថិយ គប្បីសួរ (នូវអ្នកទាំងឡាយ) យ៉ាងនេះថា 'ម្នាលអាវុសោទាំងឡាយ ធម៌ទាំងឡាយអម្បាលនេះ មាន ៣ យ៉ាង ។ ធម៌ទាំង ៣ យ៉ាង តើដូចម្តេចខ្លះ ? ។ ធម៌ទាំង ៣ យ៉ាង គឺ រាគៈ ១ ទោសៈ ១ មោហៈ ១ ។ ម្នាលអាវុសោទាំងឡាយ ធម៌ទាំង ៣ យ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ធម៌ទាំង ៣ យ៉ាងនេះ ប្លែកគ្នាដូចម្តេច, មានអធិប្បាយ

ដូចម្ដេច, មានសេចក្ដីផ្សេងគ្នាដូចម្ដេច" ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កាលត្រូវគេសួរ យ៉ាងនេះហើយ គប្បីដោះស្រាយ ដល់បរិព្វាជកជាអន្យតិរ្ថិយទាំងឡាយនោះ យ៉ាងនេះថា 'ម្នាលអាវុសោទាំងឡាយ រាគៈមានទោសតិច ប៉ុន្តែក្រសាបរលាប ទោសៈ មានទោសច្រើន ប៉ុន្តែ ឆាប់សាបរលាប, មោហៈមានទោសច្រើនផង ក្រសាបរលាបផង' ដូច្នេះ " ។

បាលីតិត្ថិយសូត្រ ចប់ ។

(២២៥) បណ្ដាបទទាំងនោះ បទថា "រាគោ ខោ" បានដល់ រាគៈដែលប្រព្រឹត្តទៅ ដោយអំណាច នៃសេចក្ដីត្រេកត្រអាល ។ បទថា "អប្បសាវជ្ជោ" មានសេចក្ដីថា ឈ្មោះថា មានទោសតិច គឺ មានទោសបន្តិចបន្តួច ព្រោះហេតុ ២ ប្រការ គឺ ដោយអំណាចទោសខាងផ្លូវលោកខ្លះ ដោយអំណាចទោសដែលជាវិបាកខ្លះ ។ រាគៈមានទោសតិច តើយ៉ាងដូចម្ដេច ? ។ មែនពិត មាតាបិតា និងបិយជនមានបងស្រីប្អូនស្រីជាដើម រមែងធ្វើនូវអាវាហមង្គល និងវិវាហមង្គល ដល់បុត្រនិងបងប្រុសប្អូនប្រុសក៏បាន ។ រាគៈនេះ ឈ្មោះថា មានទោសតិច ដោយអំណាចទោសខាងផ្លូវលោក យ៉ាងដូច្នេះសិន ។ តែឈ្មោះថា បដិសន្ធិក្នុងអបាយ ដែលមានសទារសន្តោសជាមូល រមែងមានមិនបាន

ព្រោះហេតុនោះ រាគៈ ទើបឈ្មោះថា មានទោសតិច ដោយអំណាចទោសដែលជាវិបាក ដោយប្រការដូច្នេះ ។ បទថា " ទន្ធវិរាគី " មានសេចក្ដីថា ក៏រាគៈនុ៎ះ កាលនឹងសាបរលាប ក៏រមែងសាបរលាបទៅ បន្តិចម្ដងៗ រមែងតាមជាប់ អស់កាលដ៏យូរ ប្រៀបដូចជាការចាប់នៃមមាញក្លើងប្រេង ដូច្នោះឯង សូម្បីទៅកាន់ភពទាំងឡាយ ២-៣ ហើយ ក៏រមែងមិនទៅប្រាសឡើយ ព្រោះហេតុនោះ ទើបឈ្មោះថា ក្រសាបរលាប ។

ក្នុងសេចក្ដីនោះ មានរឿងនេះ ( ជាឧទាហរណ៍ )

## ( រឿងស្ត្រីដែលប្រព្រឹត្តក្បត់ចិត្ត )

(២២៦) បានឮថា បុរសម្នាក់ ប្រព្រឹត្តមិច្ឆាចារ ជាមួយនឹងភរិយា របស់បងប្រុស ។ បុរសនោះឯង បានជាទីស្រឡាញ់របស់ស្រីនោះឯង ជាងស្វាមីរបស់ខ្លួនទៀត ។ ស្រីនោះ ប្រាប់បុរសនោះ ថា "កាលបើរឿងរបស់យើង របើកឡើងហើយ ព្រោះហេតុនេះ, សេចក្ដីតិះដៀលរិះគន់ដ៏ច្រើន ក៏នឹងកើតមាន, ចូរអ្នកញ៉ាំងបុគ្គលឱ្យសម្លាប់បងប្រុស របស់អ្នកចោលទៅ" ។ បុរសនោះ កាលស្រីនោះប្រាប់ដល់ទៅ ៣ ដង ក៏ទទួលពាក្យហើយទើបឱ្យបុគ្គលសម្លាប់បងប្រុសចោលទៅ ។ បុរសក្រៅនេះ មិនអាចដើម្បីនឹង

លះបង់នូវសេចក្ដីស្នេហា ក្នុងភរិយាបាន ទើបកើតជាពស់ដ៏ធំ ក្នុងផ្ទះនោះឯង ។ ពស់នោះ កាលបើភរិយានោះ ឈរក្ដី អង្គុយក្ដី ក៏វារទៅ ធ្លាក់លើសរីរៈ(នាង) ។ ក្រោយមក ស្រីនោះគិតថា "បុរសនោះឯង នឹងកើតជាពស់នេះពិត" ដូច្នេះហើយ ទើបឲ្យបុគ្គលសម្លាប់ពស់នោះចោល ។ ពស់នោះ បានកើតជាកូនសុនខក្នុងផ្ទះនោះឯងម្ដងទៀត ព្រោះសេចក្ដីស្រឡាញ់ចំពោះស្រីនោះ ។ កូនសុនខនោះ ចាប់តាំងពីដើរបានមក តែងតែដើរតាមក្រោយៗនៃស្រីនោះ, សូម្បីកាលបើស្រីនោះដើរទៅព្រៃ, ក៏ដើរទៅជាមួយគ្នាដែរ ។ មនុស្សទាំងឡាយ ឃើញហេតុនោះហើយ រមែងសើចចំអកឲ្យថា "ព្រានសុនខ ចេញហើយ នឹងទៅកាន់ទីកន្លែងណា ?" ។ ស្រីនោះ ក៏បានឲ្យបុគ្គលសម្លាប់សុនខនោះចោលម្ដងទៀត ។ ឯសុនខនោះ កើតជាកូនគោ ក្នុងផ្ទះនោះទៀត រមែងដើរទៅតាមក្រោយស្រីនោះ យ៉ាងដូច្នោះឯង ។ សូម្បីក្នុងកាលនោះ មនុស្សទាំងឡាយ ឃើញនាងនោះហើយ ក៏សើចចំអកឲ្យថា "អ្នកចិញ្ចឹមគោចេញហើយ, មេគោទាំងឡាយ នឹងត្រាច់ទៅ ក្នុងទីកន្លែងណា ?" ។ នាងឲ្យបុគ្គលសម្លាប់គោនោះចោលហើយ ក្នុងទីនោះ ។ សូម្បីក្នុងកាលនោះ គោនោះក៏មិនអាចដើម្បីនឹងកាត់ផ្ដាច់នូវសេចក្ដីស្រឡាញ់លើស្ត្រីនោះបានដែរ ក្នុងវារៈទី ៤ ក៏បាន

ទៅកើតជាអ្នករលីកជាតិបាន ក្នុងផ្ទៃពោះនៃស្រីនោះតែម្តង ៗ ក្មេងនោះ ឃើញនូវភាវៈនៃខ្លួនជាអ្នក គឺស្ត្រីនោះឲ្យគេសម្លាប់ចោល ក្នុងអត្តភាពទាំងឡាយ ៤ ដោយលំដាប់ហើយ ទើបគិតថា " អាត្មាអញជាអ្នកកើតហើយ ក្នុងផ្ទៃពោះ នៃស្រីដែលជាសឹកសត្រូវឈ្មោះនេះ " ដូច្នេះហើយ តាំងពីពេលនោះមក ក៏មិនឲ្យមាតានោះយកដៃពាល់ខ្លួនបានឡើយ ៗ បើមាតានោះ ប៉ះពាល់កូននោះ, កូននោះក៏ស្រែកយំ ៗ គ្រានោះ ជីដូនម្នាក់គត់តែងប្រតិបត្តិនូវកូនក្មេងនោះបាន ៗ ក្នុងកាលក្រោយមក ជីតាបានសួរចៅនោះដែលធំពេញវ័យហើយ ថា " នែចៅសំឡាញ់ ព្រោះហេតុអ្វីបានជាអ្នកមិនឲ្យមាតាយកដៃពាល់ខ្លួន ? " ៗ ក្មេងនោះ បានពោលថា " នាងនុ៎ះ មិនមែនជាមាតារបស់ខ្ញុំទេ, នាងនុ៎ះ គឺជាសត្រូវរបស់ខ្ញុំ " ដូច្នេះហើយ បានប្រាប់រឿងរ៉ាវទាំងអស់ (ឲ្យស្តាប់) ៗ ជីតាបានអោបចៅហើយ ក៏ស្រែកយំ បានពោលថា " នែចៅសំឡាញ់ ចូរអ្នកមកចុះ, នឹងមានប្រយោជន៍អ្វី ដល់ពួកយើង ដោយការនៅអាស្រ័យ ក្នុងទីយ៉ាងដូច្នេះ " ដូច្នេះហើយ ក៏នាំក្មេងនោះចេញទៅ បានទៅដល់វត្តមួយហើយ ៗ ជនទាំង ២ នាក់នោះបួសហើយ នៅក្នុងវត្តនោះ បានសម្រេចហើយនូវព្រះអរហត្ត ៗ

រឿងស្ត្រីអ្នកប្រព្រឹត្តក្បត់ចិត្ត ចប់ ។

(២២៧) អដ្ឋកថាតិត្ថិយសូត្រនោះ ថា "បទថា 'មហាសាវជ្ជោ' មានសេចក្ដីថា ឈ្មោះថា មានទោសច្រើន ដោយហេតុ ២ យ៉ាង ។ មានទោសច្រើនយ៉ាងដូចម្ដេច ? ។ មែនពិត បុគ្គលជាអ្នកគឺទោសៈប្រទូសរ៉ាយហើយ រមែងខុស ក្នុងមាតាខ្លះ ក្នុងបិតាខ្លះ ក្នុងបិយជនទាំងឡាយ មានបងស្រី ប្អូនស្រីជាដើមខ្លះ ក្នុងពួកបព្វជិតទាំងឡាយខ្លះ ។ បុគ្គលនោះ រមែងបាននូវការតិះដៀល ក្នុងទីកន្លែងដែលខ្លួនទៅហើយ ៗ ថា 'បុគ្គលនេះ រមែងខុស ក្នុងមាតានិងបិតាខ្លះ ក្នុងបិយជនមានបងស្រីប្អូនស្រីជាដើមខ្លះ ក្នុងពួកបព្វជិតខ្លះ' ។ ទោសៈ ឈ្មោះថា មានទោសច្រើន ដោយអំណាចទោសខាងផ្លូវលោក យ៉ាងដូច្នេះសិនចុះ ។ ម្យ៉ាងទៀត បុគ្គលនោះ រមែងឆេះ ក្នុងនរក អស់មួយកប្ប ព្រោះអនន្តរិយកម្ម ដែលខ្លួនបានធ្វើហើយ ដោយអំណាចទោសៈ ។ ទោសៈ ឈ្មោះថា មានទោសច្រើន ដោយអំណាចទោសដែលជាវិបាក ដោយប្រការដូច្នេះ។ បទថា 'ខិប្បវិរាគី' មានសេចក្ដីថា ទោសៈ ឆាប់សាបរលាប ។ មែនពិត បុគ្គលអ្នកត្រូវទោសៈប្រទូសរ៉ាយហើយ ខុសក្នុងមាតានិងបិតាខ្លះ ក្នុងចេតិយខ្លះ ក្នុងដើមពោធិខ្លះ ក្នុងបព្វជិតទាំងឡាយខ្លះ ហើយ រមែងសំដែងនូវទោសថា 'ចូរអ្នកទាំងឡាយ អត់ទោសដល់ខ្ញុំបាទ' ដូច្នេះ ។ កម្មនោះ របស់បុគ្គលនោះ រមែងត្រឡប់ទៅ

ជាកម្មតាមប្រក្រតីវិញព្រមជាមួយគ្នានឹងការឲ្យអត់ទោសតែម្តង ៗ ចំណែកមោហៈ ឈ្មោះថា មានទោសច្រើន ដោយហេតុ ២ យ៉ាង ដូចគ្នាដែរ ៗ មានទោសច្រើនដូចម្តេច ? ៗ មែនពិត បុគ្គលជាអ្នកវង្វេងហើយ ព្រោះមោហៈ ខុសក្នុងមាតានិងបិតាទាំងឡាយខ្លះ ក្នុងចេតិយខ្លះ ក្នុងដើមពោធិខ្លះ ក្នុងបព្វជិតទាំងឡាយខ្លះហើយ រមែងបាននូវការតិះដៀល ក្នុងទីកន្លែង ដែលខ្លួនទៅហើយៗ ៗ មោហៈ ឈ្មោះថា មានទោសច្រើន ដោយអំណាចទោសខាងផ្លូវលោក យ៉ាងដូច្នេះសិនចុះ ៗម្យ៉ាងទៀត បុគ្គលអ្នកវង្វេង រមែងឆេះ ក្នុងនរក រហូតមួយកប្ប ដោយអនន្តរិយកម្ម ដែលខ្លួនបានធ្វើហើយ ដោយអំណាចមោហៈ ៗ មោហៈឈ្មោះថា មានទោសច្រើន ដោយអំណាច នៃទោសដែលជាវិបាក ដោយប្រការដូច្នេះឯង ៗ

បទថា ' **ទន្ធវិរាគី** ' គឺ មោហៈសាបរលាបបន្តិចម្តងៗ ៗ មែនពិត កម្មដែលបុគ្គលអ្នកវង្វេងហើយ ព្រោះមោហៈ បានធ្វើហើយ រមែងសាបរលាប បន្តិចម្តងៗ ៗ ប្រៀបដូចជា ស្បែកខ្លាឃ្មុំ ដែលបុគ្គលលាង សូម្បី ១០០ ដង រមែងជាស្បែកមិនសយ៉ាងណាមិញ, កម្មគឺបុគ្គលអ្នកវង្វេង ព្រោះមោហៈបានធ្វើហើយក៏យ៉ាងដូច្នោះដែរ រមែងមិនសាបរលាប យ៉ាងឆាប់រហ័ស គឺសាបរលាបទៅ បន្តិចម្តងៗ ប៉ុណ្ណោះឯង " ៗ

ដីកាតិត្តិយសូត្រនោះ ថា "បណ្ឌិតគប្បីជ្រាបសេចក្ដី ក្នុងពាក្យថា 'កោ អធិប្បាយសោ' នេះ ក្នុងបាលី ថា '(បណ្ដាធម៌ទាំង ៣ ប្រការនោះ) មានអ្វី ជាគ្រឿងប្រកបឲ្យប្លែកផ្សេងពីគ្នា' ដូច្នេះ ។ បទថា 'លោកវជ្ជវសេន' មានសេចក្ដីថា ដោយអំណាចទោសដែលលោកិយមហាជន គប្បីតិះដៀល ដោយប្រក្រតី ។ បទថា 'វិបាកវជ្ជវសេន' គឺ ដោយអំណាច នៃទោសដែលជាវិបាក គឺដែលញ៉ាំងសត្វឲ្យប្រព្រឹត្តទៅព្រម ក្នុងអបាយ" ។

(២២៨) កិលេសទាំងឡាយ មានរាគៈជាដើមនុ៎ះ ជាកិលេសប្លែកផ្សេងពីគ្នា ដោយទោសមានភាវៈ ជាកិលេសដែលក្រសាបរលាបជាដើម ក៏ពិតមែន, ទោះជាយ៉ាងដូច្នោះ ក៏ឈ្មោះថាស្មើគ្នាដោយភាពតែមួយមែនពិត ព្រោះភាវៈជាកិលេសជាហេតុនៃសេចក្ដីងងឹតដ៏មានកម្លាំង ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ ដល់ភិក្ខុទាំងឡាយ ថា ÷

"លោភៈ ជាធម៌ញ៉ាំងសេចក្ដីវិនាសឲ្យកើត, លោភៈ[១] ជាធម៌ញ៉ាំងចិត្តឲ្យកម្រើក, ជនរមែងមិនដឹងនូវភ័យនោះ ដែលកើតហើយ ពួដ៏ខាងក្នុងចិត្ត, បុគ្គលអ្នកលោភ រមែងមិនស្គាល់ប្រយោជន៍, បុគ្គលអ្នក

---

១- ត្រៃបិដក ភាគទី ៥៣ / ទំព័រទី ១១២ ។

លោភ រមែងមិនឃើញធម៌, សេចក្ដីលោភ គ្របសង្កត់នរជន ក្នុងកាលណា, សេចក្ដីងងឹតដ៏មានកំឡាំង ក៏កើតឡើង ក្នុងកាលនោះ ។ ទោសៈជាធម៌ញុំាងសេចក្ដីវិនាសឲ្យកើត, ទោសៈជាធម៌ញុំាងចិត្តឲ្យកម្រើក, នរជន រមែងមិនដឹងនូវភ័យនោះ ដែលកើតហើយ ពួដ៏ខាងក្នុងចិត្ត, ជនអ្នកប្រទូស រមែងមិនស្គាល់ប្រយោជន៍, ជនអ្នកប្រទូស រមែងមិនឃើញធម៌, ទោសៈ គ្របសង្កត់នរជន ក្នុងកាលណា, សេចក្ដីងងឹតដ៏មានកំឡាំង ក៏កើតឡើង ក្នុងកាលនោះ ។ មោហៈ ជាធម៌ញុំាងសេចក្ដីវិនាសឲ្យកើត, មោហៈ ជាធម៌ញុំាងចិត្តឲ្យកម្រើក, នរជន រមែងមិនដឹងនូវភ័យនោះ ដែលកើតហើយ ពួដ៏ខាងក្នុងចិត្ត, ជនអ្នកវង្វេង រមែងមិនស្គាល់ប្រយោជន៍, ជនអ្នកវង្វេង រមែងមិនឃើញធម៌, មោហៈ គ្របសង្កត់នរជន ក្នុងកាលណា, សេចក្ដីងងឹតដ៏មានកំឡាំង ក៏កើតឡើង ក្នុងកាលនោះ ” ។

បាលីមលសូត្រ មកក្នុងចតុត្ថវគ្គ តិកនិបាត ក្នុងឥតិវុត្តកៈ ។

(២២៩) អដ្ឋកថាមលសូត្រនោះ ថា “ លោភៈ រមែងញុំាង សេចក្ដីវិនាស របស់ខ្លួន និងអ្នកដទៃ ឲ្យកើតឡើង ព្រោះហេតុ នោះ លោភៈនោះ ទើបឈ្មោះថា ញុំាងសេចក្ដីវិនាសឲ្យកើត ។ បទថា ‘ចិត្តប្បកោបនោ’ គឺ ញុំាងចិត្តឲ្យរវើរវាយ ។ មែនពិត លោភៈកាលកើតឡើង ក្នុងវត្ថុដែលជាទីតាំងនៃសេចក្ដី លោភ ញុំាងចិត្តឲ្យរវើរវាយ គឺ ឲ្យប្រែប្រួល ឲ្យដល់នូវសេចក្ដី ពិការ កើតឡើង គឺ រមែងមិនឲ្យ ដើម្បីប្រព្រឹត្តទៅបាន ដោយ អំណាចនៃអាការមានសេចក្ដីជ្រះថ្លាជាដើម ។ ២ បាទគាថា ថា ‘ភយមន្តរតោ ជាតំ តញ្ជនោ នាវពុជ្ឈតិ’ មានសេចក្ដីថា ពាលមហាជននេះ រមែងមិនដឹងនូវភ័យ គឺ ហេតុនៃភ័យនោះ គឺ ពោលគឺសេចក្ដីលោភ មានអាការញុំាងសេចក្ដីវិនាស ឲ្យកើតឡើង និងញុំាងចិត្តឲ្យកម្រើកជាដើម ដែលកើតឡើង ពួដ៏ខាងក្នុង គឺ ខាងក្នុង បានដល់ ក្នុងចិត្ត របស់ខ្លួនន៉ុះឯង ។ បាទគាថា ថា ‘លុទ្ធោ អត្ថំ ន ជានាតិ’ មានសេចក្ដីថា បុគ្គលអ្នកលោភ រមែងមិនស្គាល់នូវប្រយោជន៍ គឺ ប្រយោជន៍សុខ ផ្សេងដោយ ប្រយោជន៍មានប្រយោជន៍ របស់ខ្លួនជាដើម តាមសេចក្ដីពិត ។ ២ បទថា ‘ធម្មំ ន បស្សតិ’ មានសេចក្ដីថា បុគ្គលអ្នកលោភ គឺ បុគ្គលអ្នកដែលសេចក្ដីលោភគ្របសង្កត់ហើយ រមែងមិនឃើញ

គឺ មិនស្គាល់សូម្បីនូវធម៌គឺកុសលកម្មបថ ១០ ប្រការ ដោយច្បាស់លាស់, មិនចាំបាច់និយាយទៅដល់ឧត្តរិមនុស្សធម្មឡើយ ។ សេចក្ដីងងឹតដែលធ្វើភារៈដូចជាខ្វាក់ ឈ្មោះថា សេចក្ដីងងឹតដ៏មានកំឡាំង ។ បទថា 'យំ' គឺ យត្ថ ក្នុងកាលណា ។ បទថា 'យំ' នោះ ជាបឋមាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ អធិប្បាយថា 'សេចក្ដីលោភ រមែងគ្របសង្កត់ គឺ សង្កត់សង្កិននូវនរជន ក្នុងកាលណា, សេចក្ដីងងឹតដ៏មានកំឡាំង ក៏កើតមានក្នុងកាលនោះ' ។ ម្យ៉ាងទៀត បទថា 'យំ' ជាបទដែលបញ្ជាក់ដល់ហេតុ ។ ប្រកបសេចក្ដីថា 'ព្រោះសេចក្ដីលោភនោះ កាលកើតឡើង រមែងគ្របសង្កត់នូវនរជន, ហេតុនោះ សេចក្ដីងងឹតដ៏មានកំឡាំង ទើបមាន ក្នុងកាលនោះ' ព្រោះ យ ស័ព្ទ និង ត ស័ព្ទ ជាស័ព្ទដែលជាប់ទាក់ទងនឹងគ្នាតែមួយ ។ ម្យ៉ាងទៀត បទថា 'យំ' គឺជាកិរិយាបរាមាស ។

ក្នុងពាក្យថា 'លោភោ សហតេ' នេះ មានអធិប្បាយថា លោកពោលការគ្របសង្កត់ គឺ ការសង្កត់សង្កិននៃសេចក្ដីលោភនុ៎ះឯណា, ការគ្របសង្កត់ គឺ ការសង្កត់សង្កិន នៃសេចក្ដីលោភនោះ ក៏ជាទីទៅ គឺ ការកើតឡើង នៃសេចក្ដីងងឹត ដែលធ្វើនូវភារៈដូចជាខ្វាក់ ។ ម្យ៉ាងទៀត អធិប្បាយថា 'សេចក្ដីលោភ រមែង

គ្របសង្កត់ គឺ សង្កត់សង្កិននូវនរជនណា, សេចក្ដីងងឹតដ៏មានកំឡាំង រមែងកើតមាន ដល់នរជននោះ ក្នុងកាលនោះ ៗ ព្រោះហេតុនោះឯង បុគ្គលអ្នកលោភ រមែងមិនស្គាល់ប្រយោជន៍, បុគ្គលអ្នកលោភ រមែងមិនឃើញនូវធម៌ " ។

(២៣០) អដ្ឋកថាទុតិយបណ្ណាសកៈ ក្នុងសត្តកនិបាត អង្គុត្តរនិកាយ ថា " ២ បទថា ' **អន្តរតោ ជាតំ** ' ប្រែថា កើតឡើងហើយ ពួដ៏ខាងក្នុង ៗ ២ បទថា ' **អត្ថំ ន ជានាតិ** ' មានសេចក្ដីថា បុគ្គលអ្នកលោភ រមែងមិនស្គាល់ប្រយោជន៍ គឺសេចក្ដីចំរើន ៗ ២ បទថា ' **ធម្មំ ន បស្សតិ** ' មានសេចក្ដីថា មិនឃើញធម៌គឺសមថៈនិងវិបស្សនា ។ សេចក្ដីងងឹតដែលធ្វើនូវភាវៈដូចជាខ្វាក់ ឬសេចក្ដីងងឹតសូន្យឈឹង ឈ្មោះថា អន្ធតមៈ ៗ បទថា ' **សហតេ** ' បានដល់ រមែងសង្កត់សង្កិន " ។

ដីកាទុតិយបណ្ណាសកៈនោះ ថា " បទថា ' **អន្តរតោ** ' បានដល់ ចាកពួដ៏ខាងក្នុង ឬ ចាកចិត្ត " ។

(២៣១) អកុសលធម៌មានលោភៈជាដើមនុ៎ះ ជាកិលេសមានការប្លែកផ្សេងពីគ្នា ដោយអាការមានភាវៈជាកិលេសដែលក្រសាបរលាបជាដើម (តែ) ឈ្មោះថា ស្មើគ្នាដោយភាពតែមួយ ព្រោះភាវៈជាហេតុ នៃសេចក្ដីងងឹតដ៏មានកំឡាំង យ៉ាងនេះឯង ៗ

កិលេសមានរាគៈជាដើម បណ្ឌិតគប្បីជ្រាប ថា " ធូលី " ដោយសេចក្តីតាមដែលបានពោលមកហើយ ។ ធូលីទាំងឡាយនោះ ទៅប្រាសហើយ ចាកចិត្តនុ៎ះ ហេតុនោះ ចិត្ត (នោះ) ទើបឈ្មោះថាប្រាសចាកធូលីហើយ ។ ក៏កុលបុត្រអ្នកប្រាថ្នានឹងសម្រេចនូវវិរជចិត្តនោះ មិនគួរឲ្យអកុសលធម៌មានលោភៈជាដើម កើតឡើង ក្នុងអារម្មណ៍ទាំងឡាយ មានអារម្មណ៍ជាទីតាំងនៃលោភៈជាដើម គប្បីលះបង់ សូម្បីដោយអំណាចនៃតទង្គបហានៈ ។ ព្រោះថា បុគ្គលណា មិនលះបង់អកុសលធម៌មានលោភៈជាដើមនោះ ដោយកុសលធម៌ត្រឹមតែតទង្គបហានៈ, បុគ្គលនោះ រមែងបានជួបនូវសេចក្តីទុក្ខ ។

ក្នុងសេចក្តីនោះ មានរឿងទាំងនេះ ( ជាឧទាហរណ៍ ) ÷

## ( រឿងកូនជាងកាត់សក់ )

(២៣២) ក្នុងទីក្រុងវេសាលី មានជាងកាត់សក់ម្នាក់ ជាអ្នកមានសទ្ធាជ្រះថ្លា ដល់ត្រៃសរណៈ បានសមាទានបញ្ចសីល ជាអ្នកធ្វើកិច្ចការកោរព្រះមស្សុ (ពុកមាត់) និងកាត់តែងព្រះកេសាជាដើម របស់ឥស្សរជនទាំងឡាយ មានព្រះរាជានិងព្រះស្នំ របស់ព្រះរាជាជាដើម ។ ថ្ងៃមួយ ជាងកាត់សក់នោះ កាលនឹងទៅធ្វើការ

ក្នុងព្រះរាជវាំង បាននាំកូនប្រុសរបស់ខ្លួនទៅផង ។ ចំណែកកូនប្រុសរបស់ជាងកាត់សក់នោះ ទៅក្នុងព្រះរាជវាំងនោះហើយ ក៏បានឃើញព្រះរាជកុមារី នៃស្តេចលិច្ឆវីមួយអង្គ ទ្រង់ប្រដាប់តាក់តែងព្រះកាយ ប្រៀបដូចជានាងទេពអប្សរ ជាអ្នកមានចិត្តប្រតិព័ទ្ធ ហើយដោយអំណាចកិលេស ទៅដល់ផ្ទះហើយ រៀបចំគ្រែដេកធ្វើការអត់អាហារ ដោយគិតថា "អាត្មាអញកាលបើបានព្រះរាជកុមារីនោះ នឹងរស់នៅ, កាលបើអាត្មាអញមិនបានទេ នឹងស្លាប់នៅក្នុងទីនេះតែម្តង" ។

លំដាប់នោះ ឪពុកបានពោលប្រាប់កូនប្រុសនោះថា "នែកូនសំឡាញ់ ចូរអ្នកកុំធ្វើនូវឆន្ទរាគៈ ក្នុងរឿងដែលមិនមែនជារឿងឡើយ, អ្នកជាអ្នកមានជាតិថោកទាប ជាកូនជាងកាត់សក់, ព្រះកុមារីលិច្ឆវី ជាព្រះរាជធីតា បរិបូណ៌ដោយជាតិ, ព្រះរាជកុមារីនោះ មិនសមគួរដល់អ្នកទេ, ឪពុកនឹងនាំយកនាងកុមារិកាដទៃទៀត ដែលស្មើដោយជាតិនិងត្រកូល មកឲ្យអ្នក" ។ កូនប្រុសនោះ មិនជឿតាមនូវពាក្យរបស់ឪពុក មិនលះបង់នូវរាគៈ សូម្បីដោយធម៌ត្រឹមតែតទង្គុបហានៈ ស្គាំងស្គមហើយ ក៏បានធ្វើកាលៈក្នុងទីកន្លែងនោះឯង ។

រឿងកូនជាងកាត់សក់មកក្នុងអដ្ឋកថាសិគាលជាតក ក្នុងបឋមវគ្គ ទុកនិបាត ។

## ( រឿងទុដ្ឋរាជកុមារ )

(២៣៣) ក្នុងអតីតកាល ក្នុងក្រុងពារាណសី មានព្រះរាជា ទ្រង់ព្រះនាម ថា កិតវាសៈ ។ ព្រះរាជឱរស របស់ព្រះអង្គ ព្រះនាមថា ទុដ្ឋកុមារ ជាព្រះឧបរាជ ។ តែក្នុងពេលដែលព្រះរាជឱរសអង្គនោះ ទ្រង់ប្រសូត ពួកហោរាសាស្រ្តអ្នកទាយនូវលក្ខណៈ បានទាយ ថា "បពិត្រព្រះមហារាជ ព្រះរាជឱរសអង្គនេះ មិនបានទឹកដែលគួរសោយហើយ ក៏នឹងទិវង្គត" ។ ចំណែកព្រះរាជា ទ្រង់ត្រាស់បញ្ជាឲ្យសាងស្រះបោក្ខរណីទុក ត្រង់ទ្វារព្រះនគរទាំង ៤ និងក្នុងទីនោះៗ ពួដ៏ខាងក្នុងព្រះនគរ ព្រោះទ្រង់ភ័យខ្លាចព្រះរាជឱរសនោះ មិនបានទឹកដែលគួរសោយហើយ ទ្រង់ទិវង្គត ។ ព្រះអង្គទ្រង់ត្រាស់បញ្ជាឲ្យធ្វើមណ្ឌបទាំងឡាយ ក្នុងទីទាំងឡាយមានផ្លូវបែកជា ៤ ជាដើម ហើយទ្រង់បញ្ជាឲ្យតាំងពាងទឹកដែលគួរសោយ ។

ក្រោយមក ថ្ងៃមួយ ព្រះឧបរាជ កាលទ្រង់ស្ដេចយាងទៅកាន់ព្រះឧទ្យាន តាំងពីព្រលឹម ទ្រង់បានទតព្រះនេត្រឃើញ ព្រះបច្ចេកពុទ្ធ ក្នុងចន្លោះផ្លូវ ។ ចំណែកមហាជន ឃើញនូវព្រះបច្ចេកពុទ្ធហើយ ក៏ថ្វាយបង្គំ ពោលសរសើរនូវព្រះបច្ចេកពុទ្ធនោះមួយរំពេច និងផ្គងអញ្ជលី ចំពោះព្រះបច្ចេកពុទ្ធនោះ ។

ព្រះឧបរាជនោះទ្រង់ព្រះពិរោធហើយ ថា “ពួកជនទាំងនេះ ទៅជាមួយនឹងបុគ្គលបែបនេះ រមែងនមស្សការ ពោលសរសើរ ផ្គងនូវអញ្ជលីដល់សមណៈត្រងោលនេះ” ដូច្នេះហើយ ស្ដេចចុះអំពីដំរីទ្រង់ទទួលបាត្រ អំពីព្រះហស្តព្រះបច្ចេកពុទ្ធហើយ បោះចោលលើផែនដី ទ្រង់ជាន់ចោលព្រមជាមួយភត្តាហារ ហើយទ្រង់បានធ្វើឲ្យជាល្អិតខ្ទេចខ្ទី ដោយការជាន់កំទេចដោយព្រះបាទ ។ ព្រះបច្ចេកពុទ្ធ ក៏បានក្រឡេកមើលព្រះភក្ត្រ របស់ព្រះឧបរាជនោះដោយគិត ថា “សត្វនេះ វិនាសហើយហ្ន៎” ។

លំដាប់នោះ ព្រះឧបរាជនោះ ទ្រង់ត្រាស់ ថា “នែសមណៈខ្ញុំជាព្រះរាជឱរស នៃព្រះរាជាទ្រង់ព្រះនាមថា កិតវាសៈ ដោយមានព្រះនាមថា ទុដ្ឋកុមារ, ព្រះគុណម្ចាស់ក្រោធខឹងហើយ បើកភ្នែកមើល នឹងធ្វើនូវអ្វី ដល់ខ្ញុំបាន” ។ ព្រះបច្ចេកពុទ្ធ ជាអ្នកអត់អាហារ ហើយទៅកាន់ញកភ្នំឈ្មោះនន្ទមូលកៈ តាមវេហាស៍តែម្ដង ។ ក្នុងខណៈនោះឯង បាបកម្មប្រាកដហើយ ដល់ព្រះឧបរាជ ។ ព្រះអង្គមានសេចក្ដីក្ដៅក្រហាយ ក្នុងព្រះសរីរៈកើតឡើងហើយ ដោយទ្រង់ជ្រាប ថា “អាត្មាអញក្ដៅ” ទ្រង់ដួលហើយ ក្នុងទីនោះឯង ។ ទឹកសម្រាប់សោយ មានចំនួនប៉ុន្មាន, ទឹកទាំងអស់នោះ អស់រលីងហើយ ។ សូម្បីស្រះ ក៏រីងអស់ដែរ ។

ព្រះឧបរាជនោះ មិនបានហើយនូវទឹកដែលគួរសោយ ទិវង្គតហើយក្នុងទីនោះភ្លាម បានទៅកើតហើយ ក្នុងអវីចិនរក ។

ព្រះឧបរាជនោះ ជាមនុស្សពាល វង្វេងហើយព្រោះមោហៈ ត្រូវទោសៈប្រទូសរ៉ាយហើយ ក្រោធក្នុងបុគ្គលដែលមិនគួរក្រោធ មិនលះបង់ទោសៈ សូម្បីដោយធម៌ត្រឹមតែតទង្គុបហានៈ រមែងជួបប្រទះនូវសេចក្តីទុក្ខដ៏ច្រើន ដោយប្រការដូច្នេះ ។

រឿងព្រះទុដ្ឋកុមារ មកក្នុងអដ្ឋកថាធម្មទ្ធជជាតក ក្នុងសត្តមវគ្គ នៃទុកនិបាត ។

(២៣៤) ជនទាំងឡាយ មិនលះអកុសលធម៌មានលោភៈជាដើមនោះ សូម្បីដោយធម៌ត្រឹមតែតទង្គុបហានៈ បានជួបហើយនូវសេចក្តីទុក្ខ ដោយប្រការដូច្នេះ, ចំណែកបុគ្គលអ្នកលះបង់នូវអកុសលទាំងនោះ បានហើយនូវសេចក្តីសុខ ។

ក្នុងសេចក្តីនោះ មានរឿងនេះ ( ជាឧទាហរណ៍ ) ៖

## ( រឿងព្រះរាជាដែលធ្លាក់ក្នុងអំណាចតណ្ហា )

ក្នុងអតីតកាល ព្រះរាជាក្រុងពារាណសី ទ្រង់មានព្រះរាជឱរស ២ ព្រះអង្គ ។ បណ្តាព្រះរាជឱរសទាំង ២ ព្រះអង្គនោះ ព្រះជេដ្ឋភាតា ជាព្រះឧបរាជ, កាលព្រះបិតាទ្រង់ទិវង្គតហើយ, មិនប្រាថ្នារាជសម្បត្តិទេ ទ្រង់បានព្រះរាជទាន ដល់ព្រះកនិដ្ឋភាតា

ហើយស្តេចយាងទៅកាន់បច្ចន្តប្រទេស ទ្រង់អាស្រ័យត្រកូលសេដ្ឋីមួយ ទ្រង់ធ្វើការងារ ដោយព្រះហស្តព្រះអង្គឯង ទ្រង់បានសម្រេចហើយនូវការចិញ្ចឹមជីវិត ។

ក្នុងកាលក្រោយមក សេដ្ឋីដឹងថាព្រះអង្គជាព្រះរាជកុមារ ទើបមិនឲ្យព្រះអង្គទ្រង់ធ្វើការងារ ហើយបានទំនុកបំរុងព្រះអង្គដោយទំនងដូចជាកូនប្រុសតែម្តង ក្នុងកាលតមក ទើបបានក្រាបទូលព្រះរាជកុមារអង្គនោះ ថា "បពិត្រព្រះអង្គម្ចាស់ ទូលព្រះបង្គំទាំងឡាយ នឹងចិញ្ចឹមព្រះអង្គម្ចាស់, សូមព្រះអង្គទ្រង់បញ្ជូនព្រះរាជសាសន៍ ទៅថ្វាយដល់ព្រះកនិដ្ឋភាតាហើយ ទ្រង់ត្រាស់បញ្ជាឲ្យនាំយកពន្ធដារ មកដើម្បីទូលព្រះបង្គំទាំងឡាយ" ។ ព្រះរាជកុមារអង្គនោះ ទ្រង់បានធ្វើហើយ យ៉ាងដូច្នោះ ។ ឯព្រះរាជាទ្រង់ត្រាស់ ថា "ប្រពៃហើយ" ដូច្នេះហើយ ទ្រង់បានបង់នូវពន្ធដារ ដើម្បីជនទាំងឡាយនោះហើយ ។

គ្រានោះ ចំណែកអ្នកស្រុកទាំងអស់គ្នា ក៏បានក្រាបទូលព្រះអង្គ ថា "សូម្បីពួកទូលព្រះបង្គំ ក៏នឹងថ្វាយពន្ធដារ ដល់ព្រះអង្គវិញដូចគ្នា, សូមព្រះអង្គ ទ្រង់ត្រាស់ឲ្យបែងចែកនូវពន្ធដារ មកដល់ពួកទូលព្រះបង្គំខ្លះផង" ។ ព្រះរាជកុមារអង្គនោះ ទ្រង់បញ្ជូនព្រះរាជសាសន៍ ទៅថ្វាយព្រះកនិដ្ឋភាតា ដើម្បីប្រយោជន៍

ដល់ពួកជនទាំងនោះភ្លាម ៗ តាំងតែពីពេលនោះមក ជនទាំងឡាយនោះ បានថ្វាយរាជពលីហើយ ដល់ព្រះរាជកុមារនោះឯង ៗ ពេលនោះ លាភដ៏ច្រើន កើតឡើងហើយ ដល់ព្រះរាជកុមារនោះ ៗ ឯតណ្ហា ក៏កើតមានច្រើន ដល់ព្រះរាជកុមារនោះផងដែរ ៗ ក្នុងកាលក្រោយមក ព្រះរាជកុមារនោះ ទូលសុំនូវជនបទទាំងអស់នោះខ្លះ ទូលសុំនូវតំណែងឧបរាជខ្លះ ៗ ចំណែកព្រះកនិដ្ឋភាតាក៏បានព្រះរាជទាន ដល់ព្រះជេដ្ឋភាតានោះឯងហើយ ៗ ព្រះឧបរាជនោះ ចំរើនដោយតណ្ហា មិនទ្រង់សន្តោស សូម្បីដោយតំណែងឧបរាជ ទ្រង់ព្រះតម្រិះ ថា "អាត្មាអញនឹងដណ្តើមយកនូវរាជសម្បត្តិ" ដូច្នេះហើយ ទ្រង់ហែហមដោយអ្នកជនបទហើយ ទ្រង់គង់នៅខាងក្រៅនៃព្រះនគរ ទ្រង់បានបញ្ជូនព្រះរាជសាសន៍ទៅ ថា "ព្រះរាជា ចូរថ្វាយរាជសម្បត្តិ ដល់ទូលព្រះបង្គំ ឬក៏នឹងធ្វើចម្បាំង" ៗ ព្រះកនិដ្ឋភាតា ទ្រង់ព្រះតម្រិះ ថា "អ្នកនេះជាមនុស្សពាល កាលមុន បានហាមសូម្បីនូវរាជសម្បត្តិ មកពេលឥឡូវនេះ ប្រាថ្នានឹងដណ្តើមយករាជសម្បត្តិ ដោយការច្បាំង, ក៏ប្រសិនបើ អាត្មាអញ នឹងសម្លាប់ព្រះជេដ្ឋភាតានេះ ដោយការច្បាំង, ការតិះដៀល នឹងកើតមានដល់អាត្មាអញ, ប្រយោជន៍អ្វីដោយរាជសម្បត្តិ ដល់អាត្មាអញ" ដូច្នេះហើយ ទើបទ្រង់បាន

ព្រះរាជទាន នូវព្រះរាជសម្បត្តិ ថ្វាយដល់ព្រះជេដ្ឋភាតាអង្គនោះ ។ ព្រះជេដ្ឋភាតានោះ ទ្រង់ទទួលរាជសម្បត្តិហើយ ទ្រង់ព្រះរាជទានតំណែងឧបរាជដល់ព្រះកនិដ្ឋភាតា ជាអ្នកប្រព្រឹត្តទៅ ក្នុងអំណាចនៃតណ្ហា មិនទ្រង់ពេញព្រះទ័យ ដោយរាជសម្បត្តិប្រទេសមួយ ទ្រង់ប្រាថ្នារាជសម្បត្តិ ២-៣ ប្រទេស មិនបានឃើញទីបំផុតនៃតណ្ហាឡើយ ។

ស្តេចសក្កទេវរាជ ទ្រង់ជ្រាបហេតុនោះហើយ ទ្រង់មានព្រះបំណងចង់ឲ្យព្រះរាជាអង្គនោះសិក្សា ទើបស្តេចយាងទៅរកព្រះរាជាអង្គនោះ ដោយភេទជាមាណព ក្រាបបង្គំទូលថា “ បពិត្រព្រះមហារាជ ទូលព្រះបង្គំ ឃើញនូវព្រះនគរ ៣ យ៉ាងសម្បូររុងរឿង, ទូលព្រះបង្គំ នឹងដណ្តើមយកនូវរាជសម្បត្តិ ក្នុងនគរទាំងនោះឲ្យបាន ដោយអានុភាពនៃខ្លួនហើយ ថ្វាយដល់ព្រះអង្គ, គួរតែព្រះអង្គទ្រង់ស្តេចយាងទៅ យ៉ាងប្រញាប់ កុំបីទ្រង់យឺតយូរឡើយ” ដូច្នេះហើយ ស្តេចយាងទៅកាន់ទីស្ថានរបស់ព្រះអង្គវិញតែម្តង ។

ព្រះរាជាទ្រង់ប្រព្រឹត្តទៅក្នុងអំណាច នៃសេចក្តីលោភ ទ្រង់បានត្រាស់ថា “ ប្រពៃហើយ ” ដូច្នេះ កាលមិនអាចទ្រង់ត្រាស់សួរថា “ លោកគឺជាអ្នកណា ? ឬថាលោកមកអំពីទីណា ? ” ដូច្នេះ ដោយអានុភាពនៃសក្កទេវរាជ ទើបទ្រង់ត្រាស់បញ្ជាឲ្យហៅនូវ

ពួកអាមាត្យមកហើយ ទ្រង់ត្រាស់ប្រាប់នូវសេចក្ដីនោះ ដល់អាមាត្យទាំងឡាយនោះ ។ អាមាត្យទាំងឡាយ ត្រួតត្រាមើលសព្វទាំងនគរ ក៏មិនឃើញមាណពនោះ ។ ព្រះរាជាទ្រង់ដល់នូវទោមនស្ស ទ្រង់ព្រះចិន្តារឿយៗ ថា "រាជសម្បត្តិ ក្នុងព្រះនគរទាំង ៣ វិនាសបាត់ហើយ, អាត្មាអញជាអ្នកវិនាសហើយ ចាកយសដ៏ធំ" ។

គ្រានោះ សេចក្ដីក្ដៅក្រហាយក្នុងព្រះសរីរៈ កើតឡើងហើយដល់ព្រះរាជាអង្គនោះ ជាអ្នកឈ្លក់ក្នុងអំណាចតណ្ហា ។ បើព្រះសរីរៈត្រូវសេចក្ដីក្ដៅក្រហាយដុចរោល, អាពាធក្អួតចេញមកជាលោហិតញាំងព្រះឱទរឲ្យចុករមួលកើតឡើងហើយ ។ ភាជនៈ ១ ចូល, ភាជនៈ ១ ចេញ ។ ពួកពេទ្យមិនអាចដើម្បីនឹងរក្សាបាន ។

ក្នុងកាលនោះ ព្រះពោធិសត្វ រៀនសិល្បសាស្ត្រ អំពីនគរតក្កសីលា បានមកកាន់សំណាក់នៃមាតាបិតា ក្នុងក្រុងពារាណសី បានឮព្រះប្រវត្តិ របស់ព្រះរាជា មានបំណងនឹងថ្វាយការរក្សាព្រះរាជា ទើបចូលទៅគាល់ព្រះអង្គហើយ ក្រាបទូលសួរសមុដ្ឋាននៃរោគ ។ ព្រះរាជាទ្រង់ត្រាស់ ថា "ព្យាធិ បានកើតឡើងហើយព្រោះអាស្រ័យនូវតណ្ហា, បើអ្នកអាចដើម្បីនឹងរក្សាបាន, ក៏ចូរអ្នករក្សាចុះ" ។ ព្រះពោធិសត្វក្រាបទូលសួរ ថា "បពិត្រព្រះមហារាជ ព្រះអង្គ អាចដើម្បីនឹងបាននូវព្រះនគរទាំងនេះ ដោយ

សេចក្ដីសោកសៅបានឬ?”។ ព្រះរាជាទ្រង់ត្រាស់ថា “នែអ្នក មិនអាចបានទេ”។ ព្រះពោធិសត្វក្រាបទូល ថា “បពិត្រព្រះមហារាជ កាលបើដូច្នោះ, ព្រោះហេតុអ្វី? ទើបព្រះអង្គទ្រង់សោកសៅ, ព្រោះថា បុគ្គលនឹងត្រូវលះចោលរបស់របរទាំងពួងរហូតដល់វត្ថុដែលមានវិញ្ញាណ និងគ្មានវិញ្ញាណ របស់ខ្លួនជាដើម ហើយទៅមែនពិត, ព្រះអង្គទ្រង់គ្រប់គ្រងរាជសម្បត្តិ ក្នុងព្រះនគរទាំង ៤ ហើយ នឹងទ្រង់សោយភ័ត្តទាំង ៤ ថាស នឹងទ្រង់ព្រះបន្ទំលើទីព្រះបន្ទំទាំង ៤ នឹងទ្រង់ប្រដាប់ព្រះភូសាទាំង ៤ គូ ដោយការប្រើប្រាស់ ក្នុងពេលព្រមជាមួយគ្នានុ៎ះឯង មិនបានឡើយ, ការដែលព្រះអង្គឈ្លក់វង្វេងក្នុងអំណាចតណ្ហាមិនគួរឡើយ, ព្រោះធម្មតាតណ្ហានេះ កាលចំរើនឡើង រមែងមិនឲ្យដើម្បីនឹងរួចផុតអំពីអបាយទាំង ៤ បានទេ” ដូច្នេះហើយ ទើបថ្វាយព្រះធម្មទេសនាដល់ព្រះរាជាអង្គនោះ ដោយគាថាទាំង ៨ មានជាអាទិ៍ ថា “**កាមំ កាមយមានស្ស**” ដូច្នេះ ក្នុងកាមជាតក ។

ព្រះរាជា ទ្រង់ព្រះសណ្ដាប់ នូវព្រះធម្មទេសនានោះហើយ ទ្រង់លះតណ្ហាបាន ដោយអំណាចតទង្គបហានៈ ទ្រង់បានជាស្បើយអំពីព្រះរោគ ទ្រង់ត្រាស់ថា “អ្នកបានសំដែងគាថា ៨, (តែ)គាថាទាំងពួង ជាគាថាដែលអ្នកបានសំដែងហើយ ដល់ទៅមួយពាន់”

ដូច្នេះហើយ ទ្រង់បូជាព្រះពោធិសត្វនោះ ដោយទ្រព្យ ៨ ពាន់ ។ ព្រះពោធិសត្វ កាលថ្វាយព្រះធម្មទេសនា ដល់ព្រះរាជានុ៎ះឯង បានញុាំងឈានឱ្យទាតកសិណជាអារម្មណ៍ ឲ្យកើតឡើងហើយ ក្នុងស្វេតច្ឆត្រ របស់ព្រះរាជា បានលះរាគៈហើយ ដោយអំណាចនៃវិក្ខម្ភនបហានៈ មិនបានប្រកាន់យកអ្វីឡើយ ថ្វាយឱវាទ (ដល់ព្រះរាជា) ថា "បពិត្រព្រះមហារាជ សូមព្រះអង្គទ្រង់ស្តេចកុំបីប្រមាទ ប្រព្រឹត្តធម៌ចុះ" ដូច្នេះជាដើមហើយ ទើបទៅកាន់ព្រៃហិមវន្ត តាមអាកាស បួសហើយ មានឈានមិនវិនាស បានចូលដល់ព្រហ្មលោកហើយ ។

រឿងព្រះរាជាដែលល្ពក់វង្វេង ក្នុងតណ្ហា ចប់ ។

(២៣៥) ព្រោះហេតុនោះ កុលបុត្រគប្បីប្រតិបត្តិលះនូវកិលេសមានលោភៈជាដើមចេញ ។ ព្រោះថា បុគ្គលកាលប្រតិបត្តិបានយ៉ាងដូច្នេះ រមែងអាច ដើម្បីនឹងសម្រេច នូវចិត្តដែលប្រាសចាកធូលីបាន ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ក្នុងមលសូត្រ[(១)] ថា ÷

"ក៏បុគ្គលណា បានលះបង់សេចក្តីលោភហើយ
មិនជាប់ចិត្ត ក្នុងអារម្មណ៍ ដែលគួរជាប់ចិត្ត,

១- ត្រៃបិដក ភាគទី ៥៣ / ទំព័រទី ១១២ ។

សេចក្ដីលោភ ដែលអរិយមគ្គ កំចាត់បង់ចាកបុគ្គលនោះ ដូចជាតំណក់ទឹកដែលរមៀលចេញ អំពីស្លឹកឈូក ដូច្នោះឯង ។ ក៏បុគ្គលណា បានលះបង់នូវទោសៈហើយ ទើបមិនប្រទូសរ៉ាយ ក្នុងអារម្មណ៍ដែលគួរប្រទូសរ៉ាយ, ទោសៈដែលអរិយមគ្គកំចាត់បង់ ចាកបុគ្គលនោះ ដូចជាផ្លែត្នោតទុំដែលជ្រុះចាកទង ដូច្នោះឯង ។ ក៏បុគ្គលណា បានកំចាត់បង់មោហៈហើយ ទើបមិនវង្វេង ក្នុងអារម្មណ៍ដែលគួរវង្វេង, បុគ្គលនោះ រមែងកំចាត់បង់នូវមោហៈទាំងពួង ដូចជាព្រះអាទិត្យ កាលរះឡើងកំចាត់បង់ងងឹត ដូច្នោះឯង ” ។

(២៣៦) អដ្ឋកថាមលសូត្រនោះ ថា “បណ្ដាបទទាំងនោះ បាទគាថា ថា ‘ យោ ច លោភំ បហន្ត្វាន ’ មានសេចក្ដីថា ក៏បុគ្គលណា លះបង់នូវលោភៈ ដោយសមថៈនិងវិបស្សនា តាមសមគួរ ដោយអំណាចនៃតទង្គបហានៈនិងវិក្ខម្ភនបហានៈ ក្នុងកាលមុនបានហើយ ព្រោះហេតុដែលលះបាន យ៉ាងដូច្នោះ ទើបមិនជាប់ចិត្តក្នុងអារម្មណ៍ដែលគួរជាប់ចិត្ត គឺក្នុងអារម្មណ៍មានរូបជាដើម សូម្បី

ដូចជាទិព្វដែលប្រាកដឡើងដោយអានុភាពវិបស្សនាដ៏មានកំឡាំង ។ បាទគាថា ថា 'លោភោ បហីយតេ តម្ហា' មានសេចក្ដីថា លោភៈ រមែងសាបសូន្យចាកបុគ្គលនោះ គឺព្រះអរិយបុគ្គល គឺដែលអរិយមគ្គ កំចាត់បង់បាន យ៉ាងដាច់ខាតតែម្ដង ៗ ប្រៀបដូចជាអ្វី ? ។ ដូចជាតំណក់ទឹកដែលរមៀលចេញ អំពីស្លឹកឈូក ដូច្នោះឯង ។ អធិប្បាយថា ដូចជាតំណក់ទឹកដែលរមៀលចេញ អំពីស្លឹកបទុម ដូច្នោះឯង ។ បាទគាថា ថា 'តាលបក្កំវ ពន្ធនា' មានសេចក្ដីថា ទោសៈក្នុងចិត្តរបស់បុគ្គលនោះ រមែងសាបសូន្យទៅ គឺដែលបុគ្គល នោះ លះបង់បាន ដោយការកើតឡើងនៃមគ្គញ្ញាណទី ៣ ដូចជា ផ្លែត្នោតទុំដែលជ្រុះចាកទង ព្រោះការកើតឡើងនៃកំដៅដូច្នោះ ។ ២ បទថា 'វិហន្តិ សោ' មានសេចក្ដីថា បុគ្គលនោះ គឺព្រះ អរិយបុគ្គល រមែងកំចាត់ គឺ ទំលាយ កាត់ផ្ដាច់ នូវមោហៈទាំងពួង គឺ មិនមានសេសសល់ ដោយមគ្គទី ៤ ដូចជាព្រះអាទិត្យកាលឧទ័យ គឺ រះឡើង កំចាត់បង់នូវងងឹងបាន ដូច្នោះឯង" ។

ពណ៌នាអំពីចិត្តដែលប្រាសចាកកិលេសដូចជាធូលី ចប់ ។

⁂

ប្រែចប់ ថ្ងៃសៅរ៍ ១២ កើត ខែចេត្រ ឆ្នាំរកា បញ្ចស័ក ព.ស.២៥៣៦
ត្រូវនឹងថ្ងៃទី ៣ មេសា ១៩៩៣

## ពណ៌នាអំពីចិត្តដែលក្សេម

---

(២៣៧) ចិត្តដែលរួចផុត ចាកយោគៈ ទាំងឡាយ ៤ ឈ្មោះថា ចិត្តក្សេម ។ យោគៈមានតែ ៣ យ៉ាងប៉ុណ្ណោះ ដោយអំណាចនៃលោភៈ ទិដ្ឋិ និងមោហៈ ក៏ពិតមែន, ទោះជាដូច្នោះ យោគៈទាំងនោះ រមែងមាន ៤ យ៉ាង ដោយឈ្មោះថា កាមយោគៈជាដើម ។ ក៏បកិណ្ណកៈមានវិគ្រោះជាដើមនៃយោគៈនោះ ព្រះអដ្ឋកថាចារ្យ ពោលទុកហើយ ក្នុងអដ្ឋកថាទសមសូត្រ ក្នុងបឋមវគ្គនៃបឋមបណ្ណាសកៈ ក្នុងចតុក្កនិបាត អង្គុត្តរនិកាយ យ៉ាងដូច្នេះ ថា " កិលេសទាំងឡាយណា រមែងប្រកប (សត្វ) ទុកក្នុងវដ្តសង្សារ ព្រោះហេតុនោះ កិលេសទាំងឡាយនោះ ឈ្មោះថា យោគៈ ។ រាគៈ ដែលប្រព្រឹត្តទៅក្នុងបញ្ចកាមគុណ ឈ្មោះថា កាមយោគៈ ។ សេចក្តីត្រេកត្រអាល ដោយអំណាចសេចក្តីពេញចិត្ត ក្នុងរូបភព និងអរូបភពទាំងឡាយ ឈ្មោះថា ភវយោគៈ ។ មួយទៀត សេចក្តីជាប់ចិត្ត ក្នុងឈាន និងការត្រេកអរ ដែលដល់ព្រមដោយសស្សតទិដ្ឋិ ឈ្មោះថា ភវយោគៈ ។ ទិដ្ឋិ ៦២ យ៉ាង ឈ្មោះថា ទិដ្ឋិយោគៈ ។ កិរិយាមិនដឹង ក្នុងសច្ចៈទាំងឡាយ ៤ ឈ្មោះថា អវិជ្ជាយោគៈ ។ម្យ៉ាងទៀត កិលេសណា រមែងប្រកប (សត្វ)

ទុកក្នុងកាមទាំងឡាយ ព្រោះហេតុនោះ កិលេសនោះ ឈ្មោះថា កាមយោគៈ ។ កិលេសណា ប្រកប (សត្វ) ទុកក្នុងភពទាំងឡាយ ព្រោះហេតុនោះ កិលេសនោះ ឈ្មោះថា ភវយោគៈ ។ កិលេសណា រមែងប្រកប (សត្វ) ទុកក្នុងទិដ្ឋិទាំងឡាយ ព្រោះហេតុនោះ កិលេសនោះ ឈ្មោះថា ទិដ្ឋិយោគៈ ។ កិលេសណា រមែងប្រកប (សត្វ) ទុកក្នុងអវិជ្ជា ព្រោះហេតុនោះ កិលេសនោះ ឈ្មោះថា អវិជ្ជាយោគៈ ។ ពាក្យថា '**កាមយោគៈ**' ជាដើម ជាឈ្មោះនៃធម៌ដែលពោលហើយ ពួដ៏ខាងក្រោយ" ។

(២៣៨) ដីកាទសមសូត្រនោះ ថា " បទថា '**យោជេន្តិ**' មានសេចក្តីថា រមែងប្រកប គឺ តភ្ជាប់នូវកម្ម ជាមួយនឹងវិបាក, តភ្ជាប់នូវភពជាដើម ជាមួយនឹងភពដទៃជាដើម, រមែងចងភ្ជាប់នូវសត្វជាមួយនឹងទុក្ខ ។ យោគៈ ដោយសេចក្តីតាមដែលពោលហើយនោះផង ជាកាម ដោយសេចក្តីថាត្រេកត្រអាលផង ព្រោះហេតុនោះ ឈ្មោះថា កាមយោគៈ ។ លោកពោលពាក្យជាដើម ថា '**រូបារូបភវេសុ**' ដូច្នេះ ដើម្បីនឹងសំដែង ថា 'ការជាប់ចិត្តនៅក្នុងភព ឈ្មោះថា ភវយោគៈ' ។ បណ្តាយោគៈទាំង ៤ នោះ យោគៈទី ១ បានដល់ ការជាប់ចិត្តនៅ ក្នុងឧបបត្តិភពទាំងឡាយ, ទី ២ បានដល់ ការជាប់ចិត្តនៅ ក្នុងកម្មភពទាំងឡាយ, ទី ៣

បានដល់ ការប្រកបព្រមដោយភវទិដ្ឋិ លោកហៅថា 'យោគៈ' ដោយសេចក្ដីថា ជាគ្រឿងប្រកបទុក ដូចជាលោកហៅថា 'រាគៈ' ដោយសេចក្ដីថា ជាគ្រឿងជាប់ចិត្ត ដូច្នោះឯង ។ ពាក្យថា 'ចតូសុ សច្ចេសុ អញ្ញាណំ' នេះ លោកអាស្រ័យសុត្តន្តន័យពោលហើយ, ព្រោះថា នុ៎ះជាសុត្តន្តន័យសំវណ្ណនា ដោយប្រការដូច្នេះឯង ៗ មួយទៀត ពាក្យនេះ លោកពោលហើយ ព្រោះភាវៈនៃអវិជ្ជា ដែលជាខាងដើមនិងទីបំផុតជាដើម ជាធម៌ធ្លាក់ចុះទៅព្ធដ៏ខាងក្នុងពាក្យថា មិនដឹងក្នុងសច្ចៈទាំង ៤ នោះ " ។

(២៣៩) បណ្ដាយោគៈទាំង ៤ នោះ ពាក្យដែលគប្បីពោលក្នុងកាមយោគៈ ភវយោគៈនិងអវិជ្ជាយោគៈ គឺខ្ញុំបានពោលហើយក្នុងលោភៈនិងមោហៈនុ៎ះឯង ៗ ចំណែកពាក្យដែលគប្បីពោលក្នុងទិដ្ឋិយោគៈ ក៏ខ្ញុំបានពោលហើយ ក្នុងអាគារិយវិន័យ ព្ធដ៏ខាងក្រោយ ៗ ម្យ៉ាងទៀត បុគ្គលណា រមែងលះបង់នូវទិដ្ឋិយោគៈសូម្បីដោយអំណាចតទង្គបហានៈ, ចិត្តរបស់បុគ្គលនោះ រមែងជាចិត្តក្សេម ៗ សូម្បីចិត្តក្សេមនោះ ក៏ឈ្មោះថា ជាមង្គល ៗ ក្នុងសេចក្ដីនោះ មានរឿងនេះ ( ជាឧទាហរណ៍ ) ៖

( រឿងព្រះបាទបាយាសិ )

កាលបើព្រះមានព្រះភាគ ទ្រង់បរិនិព្វានទៅហើយ, កាលបើ

ព្រះថេរៈទាំងឡាយ គឺព្រះមហាកស្សបត្ថេរ ជ្រើសរើសយកហើយ ដើម្បីនឹងចងក្រងនូវព្រះធម្មវិន័យ និងកាលបើព្រះថេរៈទាំងឡាយ ដទៃទៀត នៅក្នុងទីកន្លែងនោះៗ ជាមួយនឹងបរិស័ទ របស់ខ្លួនៗ រហូតដល់ពេលចូលវស្សា, ព្រះកុមារកស្សបៈដ៏មានអាយុ ព្រមទាំង ភិក្ខុ ៥០០ អង្គ ទៅដល់សេតព្យនគរហើយ នៅក្នុងសីសបាវ័ន ។

គ្រានោះ ស្តេចម្ចាស់នគរ ព្រះនាមថា បាយាសិ មានពួកជន ដ៏ច្រើនហែហមហើយ ស្តេចយាងចូលទៅរកព្រះថេរៈ ទ្រង់ធ្វើនូវ បដិសណ្ឋារកិច្ច ទ្រង់ស្តេចគង់ហើយ ទ្រង់បានប្រកាសទិដ្ឋិ របស់ ព្រះអង្គ ដោយព្រះតម្រាស់ជាដើម ថា "បរលោក មិនមាន" ។

អដ្ឋកថាបាយាសិសូត្រ ថា "ព្រះរាជាដែលពុំទាន់បានអភិសេក ឈ្មោះថា ស្តេចជាម្ចាស់នគរ" ។

ដីកាបាយាសិសូត្រនោះ ថា "ព្រះរាជាដែលមានជាតិនៃក្សត្រ មិនទាន់ដល់ការអភិសេក ឈ្មោះថា ស្តេចមិនទាន់បានអភិសេក" ។

(២៤០) គ្រានោះ ព្រះថេរៈសំដែងនូវបាយាសិសូត្រ ដែល មាននៅក្នុងទីបំផុតនៃទីឃនិកាយ មហាវគ្គ រំដោះព្រះរាជាម្ចាស់ នគរនោះ ឲ្យរួចចេញអំពីការប្រកាន់ខុស បានញុំាងព្រះរាជា អង្គនោះ ឲ្យតាំងនៅចំពោះ ក្នុងទិដ្ឋិសម្បទាហើយ ។ ព្រះរាជា អង្គនោះ ទ្រង់ត្រឡប់ជាអ្នកមានទិដ្ឋិដ៏បរិសុទ្ធល្អ កាលទ្រង់ព្រះ

រាជទាននូវទាន ដល់សមណៈ ព្រាហ្មណ៍ មនុស្សកំព្រា និងមនុស្ស អ្នកដើរផ្លូវជាដើម បានទ្រង់ព្រះរាជទាន នូវវត្ថុត្រឹមតែអាហារនិង គ្រឿងស្លៀកពាក់ដែលសៅហ្មង គឺ បាយចុងអង្ករ មានទឹកជ្រក់ផ្អូម ជាគម្រប់ ២ និងសំពត់ទាំងឡាយផ្ទាំងតូចៗ ព្រោះភាវៈនៃព្រះអង្គ ជាអ្នកមានអធ្យាស្រ័យមិនទូលំទូលាយ ។ ក៏ព្រះរាជាស្ដេចម្ចាស់ នគរអង្គនោះ លុះទ្រង់ថ្វាយទាន ដោយមិនគោរព យ៉ាងនេះហើយ ទ្រង់ទិវង្គតទៅ ក៏បានទៅកើត ក្នុងវិមានប្រាក់ ឈ្មោះសេរីសកៈ សូន្យទទេ ក្នុងជាន់ចាតុម្មហារាជិកា ។ ចំណែកមាណព ឈ្មោះ ឧត្តរៈ ជាអ្នកខ្នះខ្នែង ក្នុងកិច្ចតូច-ធំ របស់ព្រះរាជាអង្គនោះ ជា អ្នកខ្វល់ខ្វាយហើយ ក្នុងទាន ។ មាណពនោះ បានថ្វាយទាន ដោយគោរពហើយ ក៏បានទៅកើត ក្នុងវិមានទំហំ ១២ យោជន៍ ក្នុងឋានតាវត្តិង្ស ។

ក៏ព្រះគវម្បតិដ៏មានអាយុ តែងនិមន្តទៅកាន់សេរីសកវិមាន ដែលស្ងាត់នោះ ជាញឹកញាប់ ដើម្បីនៅសម្រាកក្នុងវេលាថ្ងៃ ដោយ អំណាចនៃវត្តដែលធ្លាប់ប្រព្រឹត្តមក ក្នុងកាលមុន តាមប្រក្រតី ។ បានឮថា វិមាននោះជាទីសុខសប្បាយតាមវដូវ ដល់ព្រះថេរៈនោះ ។ ថ្ងៃមួយ ព្រះថេរៈនោះ និមន្តទៅក្នុងវិមាននោះ ក៏បានឃើញនូវ បាយាសិទេវបុត្រហើយ ទើបបានសួរ ថា “ម្នាលលោកដ៏មានអាយុ

តើលោកជានរណា ? ”។ បាយាសិទេវបុត្រពោល ថា “ខ្ញុំជាស្ដេចម្ចាស់នគរ ឈ្មោះបាយាសិ កើតហើយក្នុងវិមាននេះ” ។

ព្រះថេរៈ សួរថា “អ្នកជាមិច្ឆាទិដ្ឋិក៍ មានសេចក្ដីឃើញវិបរិតមិនមែនទេឬ ? អ្នកកើតក្នុងវិមាននេះបានយ៉ាងដូចម្ដេច ? ”។

ទេវបុត្រនោះពោល ថា “ខ្ញុំម្ចាស់ គឺព្រះគុណម្ចាស់ ព្រះនាមកុមារកស្សបត្ថេរ បានដកចេញហើយ ចាកការយល់ឃើញខុស, ក៏ខ្ញុំម្ចាស់ កើតហើយក្នុងវិមានទទេ ព្រោះបុញ្ញកិរិយាដែលខ្ញុំម្ចាស់ឲ្យគេធ្វើ ដោយសេចក្ដីមិនគោរព, បពិត្រព្រះគុណម្ចាស់ដ៏ចំរើនប្រពៃហើយ, ក្នុងពេលដែលព្រះគុណម្ចាស់និមន្តទៅមនុស្សលោក សូមព្រះគុណម្ចាស់ មេត្តាជួយប្រាប់ដល់បរិជន របស់ខ្ញុំម្ចាស់ផង ថា ‘ព្រះរាជាស្ដេចម្ចាស់នគរ ព្រះនាមបាយាសិ ទ្រង់បានថ្វាយទានដោយមិនគោរព បានចូលដល់សេរីសកវិមាន ដែលទទេហើយ, ចំណែកពួកអ្នកទាំងឡាយ ចូរធ្វើបុណ្យ ដោយសេចក្ដីគោរពហើយតាំងចិត្តទុក ដើម្បីទៅកើត ក្នុងវិមាននោះ” ។

ព្រះថេរៈ បានធ្វើហើយ យ៉ាងដូច្នោះ ដោយសេចក្ដីអនុគ្រោះដល់បាយាសិទេវបុត្រនោះ ។ ឯបរិជនទាំងនោះ បានស្ដាប់ពាក្យរបស់ព្រះថេរៈហើយ ក៏តាំងចិត្តទុកយ៉ាងដូច្នោះ ហើយក៏បានទៅកើត ក្នុងសេរីសកវិមានដែលទទេ ។

រឿងព្រះរាជាព្រះនាមបាយាសិ មកក្នុងអដ្ឋកថាឧត្តរវិមានវត្ថុ
សេរីសកវិមានវត្ថុ និងអដ្ឋកថាបាយាសិសូត្រ ។

(២៤១) ស្ដេចជាម្ចាស់នគរ ទ្រង់បានធ្វើចិត្តរបស់ព្រះអង្គឲ្យក្សេម ចាកទិដ្ឋិយោគៈ ដោយអំណាចតទង្គបហានៈ ស្ដេចបានទៅកើត ក្នុងឋានសួគ៌ហើយ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ សូម្បីចិត្តនោះ របស់ព្រះរាជាអង្គនោះ ក៏ឈ្មោះថា ជាមង្គល ។

ចិត្តទាំង ៣ យ៉ាង មានចិត្តដែលមិនសោកសៅជាដើម រមែងជាមង្គល ដោយន័យដែលបានពោលមកហើយ ពួដ៏ខាងក្រោយក៏ពិតមែន, ទោះជាដូច្នោះ ចិត្តរបស់បុគ្គលដទៃ ក៏មិនមែនជាចិត្តដែលមិនសោកសៅ និងប្រាសចាកធូលី ក្នុងកាលទាំងពួងឡើយ, រមែងមាន ចំពោះតែព្រះខីណាស្រព ប៉ុណ្ណោះ ។ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យទាំងឡាយ ទើបពោលហើយ ដោយអំណាចបុគ្គលថ្នាក់ខ្ពង់ខ្ពស់ យ៉ាងនេះ ថា “ ចិត្ត របស់ព្រះខីណាស្រព តែម្យ៉ាងប៉ុណ្ណោះ ឈ្មោះថា ចិត្តមិនសោកសៅ និងចិត្តប្រាសចាកធូលីចិត្តក្សេម ក៏ដូចជាចិត្តដែលមិនសោកសៅ យ៉ាងនោះឯង ” ដូច្នេះហើយ កាលនឹងសំដែងនូវភាវៈ នៃចិត្តនោះ ជាមង្គល ទើបពោលទៀត ថា “ ចិត្តទាំង ៣ យ៉ាង ដោយអំណាច នៃចិត្តដែលលោកកំណាត់យក ក្នុងខណៈដែលប្រព្រឹត្តទៅនោះ ៗ ហើយសំដែងចេញ

ដោយអាការនោះ ៗ យ៉ាងដូច្នេះ បណ្ឌិតគប្បីជ្រាប ថា 'ឈ្មោះថា ជាមង្គល' ព្រោះនាំមកនូវភាវៈជាអ្នកខ្ពង់ខ្ពស់ក្នុងលោក មានភាពជាអ្នកមានខន្ធដែលមិនប្រព្រឹត្តទៅជាដើម និងព្រោះនាំមកនូវភាវៈជាព្រះអាហុនេយ្យបុគ្គលជាដើម" ។

(២៤២) ការមិនប្រព្រឹត្តិទៅ នៃឧបាទិន្នកៈដែលប្រព្រឹត្តទៅហើយ ក្នុងភពថ្មី ឈ្មោះថា ភាពជាអ្នកមានខន្ធដែលមិនប្រព្រឹត្តទៅហើយ ក្នុងពាក្យថា "**អប្បវត្តក្ខន្ធតាទិលោកុត្តមភាវាវហនតោ**" នោះ ។ សមដូចជាពាក្យ ដែលព្រះអដ្ឋកថាចារ្យ ពោលទុកហើយក្នុងអដ្ឋកថាអដ្ឋសាលិនី ថា "បើព្រះអរហត្តមគ្គ នឹងជាធម៌ដែលព្រះអរហន្ត មិនបានចំរើនហើយ, ឧបាទិន្នកៈ ដែលប្រព្រឹត្តទៅហើយ ក្នុងរូបភពនិងអរូបភពទាំងឡាយ ក៏គប្បីប្រព្រឹត្តទៅបាន ។ ព្រោះហេតុអ្វី ? ។ ព្រោះភាវៈនៃហេតុទាំងឡាយ នៃការប្រព្រឹត្តិទៅ របស់ឧបាទិន្នកៈនោះមាន ។ ក៏មគ្គនោះ កាលកើតឡើងភ្លាមនុ៎ះឯង រមែងជីកគាស់រំលើង នូវកិលេសទាំង ៨ កងនេះ គឺ 'រូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ' ឧបាទិន្នកៈ ដែលប្រព្រឹត្តទៅហើយ ក្នុងភពថ្មី របស់ព្រះខីណាស្រព នឹងប្រព្រឹត្តទៅបាន អំពីទីណា ក្នុងពេលឥឡូវនេះ ៗ អរហត្តមគ្គ កាលធ្វើនូវឧបាទិន្នកៈ

ដែលប្រព្រឹត្តទៅហើយ មិនឲ្យប្រព្រឹត្តទៅ យ៉ាងដូច្នេះ រមែងចេញចាកឧបាទិន្នកៈ" ។

(២៤៣) ក៏ព្រះធម្មសេនាបតី ពោលភាវៈជាអ្នកមិនញាប់ញ័រ ទុកក្នុងនិទ្ទេសនៃបរមត្ថសូត្រ យ៉ាងនេះ ថា "សួរថា 'ព្រះអរហន្ត រមែងជាអ្នកមិនញាប់ញ័រ ក្នុងឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍បាន យ៉ាងដូចម្តេច? ។ ឆ្លើយថា 'ព្រះអរហន្ត រមែងជាអ្នកមិនញាប់ញ័រ សូម្បីក្នុងលាភ ជាអ្នកមិនញាប់ញ័រ សូម្បីក្នុងអលាភ សូម្បីក្នុងយស សូម្បីក្នុងអយស សូម្បីក្នុងសរសើរ សូម្បីក្នុងនិន្ទា សូម្បីក្នុងសុខ សូម្បីក្នុងទុក្ខ, ទោះជា បុគ្គលយកគ្រឿងក្រអូបមកលាបដើមដៃម្ខាង, ទោះជា បុគ្គលយកកាំបិតព្រាមកចាំងច្រាស់ដើមដៃម្ខាង, រាគៈ ក៏រមែងមិនមាន ព្រោះការលាបនុ៎ះ, បដិឃៈ ក៏រមែងមិនមាន ព្រោះការចាំងច្រាស់នុ៎ះ ។ ព្រះអរហន្តជាអ្នកលះបង់នូវសេចក្តីត្រេកអរ និងសេចក្តីអាក់អន់ចិត្តបានហើយ កន្លងផុតនូវការលើកតម្កើងនិងការជិះជាន់បានហើយ ជាអ្នកឆ្លងផុតដោយល្អនូវសេចក្តីត្រេកអរ និងសេចក្តីថ្នាំងថ្នាក់ចិត្តបានហើយ, ព្រះអរហន្តជាអ្នកមិនញាប់ញ័រ ក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ យ៉ាងនេះឯង" ។

(២៤៤) អដ្ឋកថាបរមត្ថសូត្រនោះ ថា "២ បទថា 'ឥដ្ឋានិដ្ឋេតាទិ' មានសេចក្តីថា ជាអ្នកមិនញាប់ញ័រ ក្នុងអារម្មណ៍ ២ យ៉ាង

ព្រោះជាអ្នកលះបង់ចោល នូវសេចក្ដីពេញចិត្តនិងសេចក្ដីអាក់អន់ចិត្តក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ហើយ ស្ថិតនៅ ។ ២ បទថា 'លាភេ អលាភេ' មានសេចក្ដីថា សូម្បីក្នុងការបាន សូម្បីក្នុងការមិនបាននូវបច្ច័យទាំងឡាយ ៤ ។ បទថា 'យសេបិ' បានដល់ សូម្បីក្នុងបរិវារ ។ បទថា 'អយសេបិ' បានដល់ សូម្បីក្នុងការវិបត្តិនៃបរិវារ ។ បទថា 'បសំសាយបិ' បានដល់ សូម្បីក្នុងការពោលសរសើរ ។ បទថា 'និន្ទាយបិ' បានដល់ សូម្បីក្នុងការពោលតិះដៀល ។ បទថា 'សុខេបិ' គឺ សូម្បីក្នុងសេចក្ដីសុខដែលប្រព្រឹត្តទៅក្នុងផ្លូវកាយ ។ បទថា 'ទុក្ខេបិ' គឺ សូម្បីក្នុងសេចក្ដីទុក្ខដែលប្រព្រឹត្តទៅក្នុងផ្លូវកាយ ។ ច្រើនបទថា 'ឯកញ្ចេ ពាហំ គន្ធេន លិម្បេយ្យុំ' មានសេចក្ដីថា ប្រសិនបើបុគ្គលគប្បីឲ្យនូវគ្រឿងលាបនូវដើមដៃម្ខាង ដោយគ្រឿងក្រអូបដែលកើតអំពីជាតិ ៤ យ៉ាង ព្ធដ៏ខាងលើៗឡើងទៅ ។ ២ បទថា 'វាសិយា តច្ឆេយ្យុំ' មានសេចក្ដីថា ប្រសិនបើបុគ្គលគប្បីចាំងច្រាស់នូវដើមដៃម្ខាងធ្វើឲ្យស្តើងដោយកាំបិតព្រារបស់ជាងឈើ ។ ពាក្យថា 'អមុស្មឹ នត្ថិ រាគោ' មានសេចក្ដីថា សេចក្ដីពេញចិត្តរមែងមិនមាន ព្រោះការលាបដោយគ្រឿងក្រអូបនុ៎ះ ។ ពាក្យថា 'អមុស្មឹ នត្ថិ បដិឃំ' មានសេចក្ដីថា បដិឃៈពោលគឺសេចក្ដីថ្នាំងថ្នាក់ចិត្ត បានដល់ សេចក្ដីក្រោធ រមែង

មិនមាន ព្រោះការចាំងច្រាស់ ដោយកាំបិតព្រាន់ៈ ។ បទថា '**អនុនយប្បដិឃវិប្បហីនោ**' មានសេចក្ដីថា ព្រះអរហន្តលះបង់នូវសេចក្ដីស្រឡាញ់និងសេចក្ដីក្រោធហើយ ស្ថិតនៅ ។ បទថា '**ឧគ្ឃាដិនិគ្ឃាដិវីតិវត្តោ**' មានសេចក្ដីថា លោកឆ្លងផុតហើយនូវសេចក្ដីលើកតម្កើង ដោយអំណាចនៃសេចក្ដីត្រេកអរ និងនូវការផ្ចាញ់ផ្ចាល់ ដោយអំណាចនៃបដិឃៈហើយ ស្ថិតនៅ ។ បទថា '**អនុរោធវិរោធសមតិក្កន្តោ**' មានសេចក្ដីថា លោកកន្លងផុតនូវសេចក្ដីត្រេកអរនិងសេចក្ដីថ្នាំងថ្នាក់ចិត្តបានហើយ ដោយប្រពៃ" ។

(២៤៥) អដ្ឋកថាទុតិយបណ្ណាសកៈ ក្នុងតិកនិបាត អង្គុត្តរនិកាយថា "បទថា '**អាហុនេយ្យោ**' មានសេចក្ដីថា ជាអ្នកសមគួរដើម្បីនឹងទទួលនូវបិណ្ឌបាត ពោលគឺរបស់ដែលគេនាំយកមកបូជា ។ បទថា '**បាហុនេយ្យោ**' មានសេចក្ដីថា ជាអ្នកសមគួរដល់ភត្តដើម្បីភ្ញៀវអ្នកចូលមក ។ បទថា '**ទក្ខិណេយ្យោ**' មានសេចក្ដីថា ជាអ្នកសមគួរដល់ទក្ខិណា ពោលគឺរបស់ដែលគេថ្វាយ ដោយសទ្ធាដោយអំណាច នៃការបរិច្ចាគនូវទានវត្ថុ ១០ ប្រការ ។ បទថា '**អញ្ជលិករណីយោ**' មានសេចក្ដីថា ជាអ្នកសមគួរដល់ការផ្គងនូវអញ្ជលី ។ ច្រើនបទថា '**អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស**' មានសេចក្ដីថា ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគនោះ ជាស្ថានទី

ដុះឡើងនៃបុណ្យរបស់សត្វលោកទូទៅ រកស្ថានទីដទៃស្មើគ្មាន" ។

(២៤៦) ដីកាទុតិយបណ្ណាសកៈនោះ ថា "ទានវត្ថុបានឈ្មោះថា **អាហុនៈ** ព្រោះវិគ្រោះ ថា ដែលបុគ្គលគួរនាំយកមកបូជា ។ ក៏បទថា '**អាហុតិ**' ដោយអត្ថ ជាបទតែមួយ ហេតុនោះ ទើបលោកពោល ថា '**អាហុតិសង្ខាតំ**'។ បទថា '**អាហុតិសង្ខាតំ**' នុ៎ះ ជាឈ្មោះនៃវត្ថុដែលគេនាំយកមក សូម្បីអំពីចម្ងាយ ហើយថ្វាយចំពោះលោកអ្នកមានសីលទាំងឡាយ ។ ក៏ពាក្យថា '**បិណ្ឌបាតំ**' គ្រាន់តែជាឧទាហរណ៍ ។ ក៏ពាក្យថា '**បាហុនំ**' នុ៎ះ ជាឈ្មោះនៃបច្ច័យទាំងឡាយ ៤ មានចីវរជាដើម ដែលបុគ្គលគួរនាំមកបូជា ។ ព្រះសង្ឃសាវ័ក នៃព្រះសម្មាសម្ពុទ្ធនុ៎ះ រមែងសមគួរនូវរបស់ដែលគួរបូជានោះ ហេតុនោះ ទើបលោកពោល ថា '**អាហុនេយ្យោ**' ។ បទថា '**យុត្តោ**' មានសេចក្តីថា ជាអ្នកសមគួរ ដើម្បីនឹងទទួល ព្រោះធ្វើនូវភាវៈនៃបិណ្ឌបាតនោះជារបស់មានផលច្រើន ។ បទថា '**បាហុនកភត្តស្ស**' មានសេចក្តីថា ដល់អាគន្តុកភ័ត្ត ដែលបុគ្គលតាក់តែងហើយ ក្នុងគ្រឿងសក្ការៈ ដើម្បីប្រយោជន៍ ដល់ញាតិមិត្រទាំងឡាយ ដែលជាទីស្រឡាញ់ពេញចិត្ត ដែលបានមកហើយអំពីទិសតូច-ធំ ។ មែនពិត អាគន្តុកភ័ត្តនោះ វៀរវាងនូវជនជាភ្ញៀវបែបនោះ ទាំងនោះចេញហើយ សមគួរហើយ ដើម្បីនឹងថ្វាយចំពោះ

ព្រះសង្ឃតែប៉ុណ្ណោះ ។ ព្រះសង្ឃនុ៎ះឯង សមគួរហើយ ដើម្បីនឹងទទួលនូវអាគន្តុកភត្តនោះ ។ ព្រោះថា ភ្ញៀវប្រាកដដូចជាព្រះសង្ឃមិនមាន ។ ពិតមែនយ៉ាងដូច្នោះ ព្រះសង្ឃនុ៎ះ, កាលបើចន្លោះនៃព្រះពុទ្ធមួយកន្លងទៅហើយ, ទើបប្រាកដ, ក្នុងកាលខ្លះ កាលបើអសង្ខេយ្យកប្ប កន្លងផុតទៅហើយ, ទើបប្រាកដ និងជាអ្នកប្រកបដោយធម៌ទាំងឡាយ ដែលធ្វើនូវភាពជាទីស្រឡាញ់ពេញចិត្ត មិនច្រឡូកច្រឡំ ។ វត្ថុដែលគួរទទួល សមគួរហើយ ដើម្បីនឹងប្រគេនដល់ព្រះសង្ឃនោះ និងព្រះសង្ឃនោះ ក៏ជាអ្នកសមគួរហើយ ដើម្បីនឹងទទួលនូវវត្ថុដែលគួរទទួល ព្រោះហេតុនោះ ទើបលោកពោលថា 'បាហុនេយ្យោ' ដោយប្រការដូច្នេះឯង ។ ក៏ក្នុងពាក្យ ថា 'បាហុនេយ្យោ' នេះ មានអធិប្បាយថា 'ញាតិនិងមិត្រទាំងឡាយដែលប្រាត់ប្រាសគ្នាហើយ រមែងមកជួបជុំគ្នា មិនយូរឡើយ, មួយវិញទៀត ភាពជាអ្នកដែលជាទីស្រឡាញ់ជាទីពេញចិត្ត ក្នុងញាតិនិងមិត្រទាំងឡាយនោះ មិនបានស្ថិតស្ថេរឡើយ, ចំណែកព្រះសង្ឃនេះ មិនមែនដូច្នោះសោះឡើយ, ព្រោះហេតុនោះ ព្រះសង្ឃនោះប៉ុណ្ណោះ ទើបជាអ្នកសមគួរដល់វត្ថុដែលគួរទទួល' ។ សត្វទាំងឡាយ រមែងរុងរឿង គឺចំរើន ដោយសម្បត្តិតាមដែលប៉ងប្រាថ្នាដោយទានសម្បត្តិនុ៎ះ ព្រោះហេតុនោះ ទានសម្បត្តិនុ៎ះ ទើបឈ្មោះថា

**ទក្ខិណា** បានដល់ ទានដែលបុគ្គលជឿនូវបរលោកគប្បីថ្វាយ ។ ព្រះសង្ឃ តែងសមគួរនូវទានឬទក្ខិណានោះ ឬជាអ្នកមានប្រយោជន៍ដល់ទក្ខិណា ឬរមែងញុំាងទក្ខិណានោះឲ្យបរិសុទ្ធ ព្រោះភាវៈគឺការធ្វើទក្ខិណានោះឲ្យមានផលច្រើន ព្រោះហេតុនោះ ទើបលោកពោលថា **ទក្ខិណេយ្យោ** ។ **អញ្ជលី** គឺបុគ្គលអ្នកត្រូវការបុណ្យទាំងឡាយគប្បីធ្វើ ក្នុងព្រះសង្ឃនេះ ហេតុនោះ ព្រះសង្ឃនេះ ទើបឈ្មោះថា **អញ្ជលិករណីយោ** ។ មយ៉ាងទៀត ព្រះសង្ឃរមែងសមគួរនូវអញ្ជលិកម្ម ដែលសត្វលោកទាំងពួង ផ្គងនូវដៃទាំង ២ ដាក់លើសិរសីហើយធ្វើ ព្រោះហេតុនោះ ទើបលោកពោល ថា ជាអ្នកសមគួរដល់ការផ្គងនូវអញ្ជលី ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោល ថា '**អញ្ជលិប្បគ្គហណស្ស អនុច្ឆវិកោ** ព្រះសង្ឃជាអ្នកសមគួរដល់ការផ្គងអញ្ជលី' ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា '**អនុត្តរំ**' ដូច្នេះ ក្នុងព្រះបាលី ក៏ពិតមែន, ទោះបីជាដូច្នោះ ស្រែដ៏ខ្ពង់ខ្ពស់ គឺ ដ៏ប្រសើរ ជាងស្រែគឺបុណ្យនេះ រមែងមិនមាន ហេតុនោះ ស្រែនៃបុណ្យនេះ ទើបឈ្មោះថា មិនមានស្រែដទៃក្រៃលែងជាង ។ ព្រះអដ្ឋកថាចារ្យកាលសំដែងថា 'សូម្បីស្រែដែលស្មើគ្នា ក៏មិនមាន' ទើបពោលពាក្យថា '**អសទិសំ**' ដូច្នេះជាដើម ។ ពូជដែលបុគ្គលសាចទៅ គឺ ព្រោះទៅហើយ រមែង

ការពារ គឺរក្សា ដោយកិរិយាធ្វើនូវភារៈនៃពូជដែលមានផលច្រើន, ម្យ៉ាងទៀត ជនទាំងឡាយ រមែងសាប គឺព្រោះនូវពូជ ក្នុងទីនេះ ហេតុនោះ ទីនេះ ទើបឈ្មោះថា ស្រែ, បានដល់ ទីដែលមានស្រែ ជាដើម ។ ព្រះសង្ឃប្រៀបដូចជាស្រែ ដែលឈ្មោះថា ខេត្តំ ។ ស្រែនៃបុណ្យទាំងឡាយ ឈ្មោះថា បុញ្ញក្ខេត្តំ ។ ប្រៀបដូចជាទីដែលជាទីដុះឡើង នៃស្រូវសាលី ឬស្រូវដំណើបទាំងឡាយ របស់ព្រះរាជាក្តី របស់អាមាត្យក្តី ពួកជនតែងហៅថា ‘ស្រែស្រូវសាលី ស្រែស្រូវដំណើប របស់ព្រះរាជា’ យ៉ាងណាមិញ, ព្រះសង្ឃ រមែងជាទីដុះដាលឡើង នៃបុណ្យទាំងឡាយ របស់សត្វលោកទាំងពួង ក៏យ៉ាងដូច្នោះដែរ ។ ព្រោះថា បុណ្យទាំងឡាយ ដែលប្រព្រឹត្តទៅព្រម ដើម្បីជាប្រយោជន៍ និងសេចក្តីសុខមានប្រការផ្សេងៗ រមែងដុះដាលឡើង ដល់សត្វលោក ព្រោះអាស្រ័យនូវព្រះសង្ឃ, ព្រោះហេតុនោះ ព្រះសង្ឃ ទើបជាទីដុះឡើងនៃពូជ គឺបុណ្យ របស់សត្វលោក រកស្រែបុណ្យដទៃក្រៃលែងជាងគ្មាន ” ។

(២៤៧) ចិត្ត ៣ យ៉ាង មានចិត្តដែលមិនសោកសៅជាដើមនុ៎ះ ឈ្មោះថា ជាមង្គល ព្រោះនាំមកនូវភាពជាអ្នកមានខន្ធដែលមិនប្រព្រឹត្តទៅជាដើម ដោយប្រការដូច្នេះ ។ វិថីចិត្តទាំងឡាយ ៤៤ ដួង ដោយអំណាចនៃវិបាកចិត្ត ផ្នែកកាមាវចរ ២៣ ដួង

កិរិយាចិត្ត ២០ ដួង និងអរហត្តផលចិត្ត ១ ដួងដ៏សេស វៀរលែងចិត្ត ៤៥ ដួងចេញ ដោយអំណាចនៃកុសលចិត្តនិងអកុសលចិត្ត ៣៣ ដួង នៃពួក ៣ នៃផលចិត្តថ្នាក់ទាប និងនៃមហគ្គតវិបាកចិត្ត ៩ ដួង ដែលផុតស្រឡះ អំពីវិថីចិត្តចេញហើយ រមែងមានព្រម ដល់ព្រះខីណាស្រព ព្រោះព្រះបាលី ថា "អសេក្ខានំ ចតុច្ចត្តាឡីសំ" ដូច្នេះ ក៏ពិតមែន ៗ ទោះបីជាដូច្នោះ សូម្បីទេវតាទាំងឡាយ តែងមិនអាច ដើម្បីនឹងឃើញនូវចិត្ត របស់ព្រះខីណាស្រពនោះ ជាអ្នកប្រកបព្រមហើយដោយអរហត្តផលចិត្តណា, អរហត្តផលចិត្តនោះឯង ដែលបណ្ឌិតតែងបាន ក្នុងគាថាទី ១០ នេះ ព្រោះព្រះបាលី ថា "ន កម្បតិ អសោកំ វិរជំ ខេមំ" ដូច្នេះៗ សមដូចជាក្នុងភទ្ទិយសូត្រ ក្នុងទុតិយវគ្គ នៃឧទាន ព្រះមានព្រះភាគ ទ្រង់បានត្រាស់ទុក ថា "ទេវតាទាំងឡាយ រមែងមិនអាចដើម្បីនឹងឃើញនូវព្រះខីណាស្រពនោះ ជាអ្នកមានភ័យទៅប្រាសហើយ ជាអ្នកមានសេចក្តីសុខ មិនមានសេចក្តីសោកសៅ" ៗ

(២៤៨) អដ្ឋកថាភទ្ទិយសូត្រនោះ ថា "បណ្តាបទទាំងនោះ ២ បទថា 'តំ វិគតភយំ' មានសេចក្តីថា នូវព្រះខីណាស្រពនោះឈ្មោះថា ជាអ្នកមានភ័យទៅប្រាសហើយ ព្រោះប្រាសចាកហេតុនៃភ័យ ឈ្មោះថា ជាអ្នកមានសេចក្តីសុខ ព្រោះសេចក្តីសុខដែល

កើតអំពីសេចក្តីស្ងាត់ និងដោយសេចក្តីសុខដែលសម្បយុត្តដោយផល ដ៏ប្រសើរ ឈ្មោះថា ជាអ្នកមិនសោកសៅ ព្រោះជាអ្នកមានភ័យទៅប្រាសហើយនុ៎ះឯង ។ ពាក្យថា 'ទេវា នានុភវន្តិ ទស្សនាយ' មានសេចក្តីថា ឧបបត្តិទេវតាសូម្បីទាំងពួង លើកលែងតែលោកអ្នកដែលមានមគ្គបានចំរើនហើយ សូម្បីកាលព្យាយាម ក៏រមែងមិនមានសមត្ថភាព គឺមិនអាច ដើម្បីនឹងឃើញ ដោយអំណាចនៃការឃើញវារៈនៃចិត្តបាន, មិនចាំបាច់ទៅនិយាយដល់មនុស្សឡើយ ។ ព្រោះសូម្បីព្រះសេក្ខបុគ្គល ក៏មិនដឹងនូវសេចក្តីប្រព្រឹត្តិទៅនៃចិត្ត របស់ព្រះអរហន្ត ដូចជាបុថុជ្ជន យ៉ាងនោះឯង " ។

(២៤៩) អដ្ឋកថាសម្បសាទនីយសូត្រ ក្នុងបាដិកវគ្គ និងអដ្ឋកថាសង្គារសូត្រ ក្នុងបឋមវគ្គ នៃទុតិយបណ្ណាសកៈ ក្នុងតិកនិបាតអង្គុត្តរនិកាយ ថា " បណ្តាជនទាំងនោះ បុថុជ្ជនអ្នកដែលបាននូវចេតោបរិយញ្ញាណ រមែងដឹងនូវចិត្ត របស់បុថុជ្ជនតែប៉ុណ្ណោះ មិនដឹងចិត្តរបស់ព្រះអរិយបុគ្គលទាំងឡាយឡើយ ។ សូម្បីបណ្តាព្រះអរិយបុគ្គលទាំងឡាយ ព្រះអរិយបុគ្គលដែលស្ថិតនៅ ក្នុងមគ្គថ្នាក់ក្រោម ក៏មិនដឹងនូវចិត្ត របស់ព្រះអរិយបុគ្គល ដែលស្ថិតនៅក្នុងមគ្គថ្នាក់ខ្ពង់ខ្ពស់បានឡើយ, ចំណែកព្រះអរិយបុគ្គល ដែលស្ថិតនៅក្នុងមគ្គថ្នាក់ខ្ពង់ខ្ពស់ រមែងដឹងនូវចិត្ត របស់ព្រះអរិយបុគ្គលដែលស្ថិត

នៅក្នុងមគ្គថ្នាក់ក្រោមបាន"។

(២៥០) ដីកាសម្បសាទនីយសូត្រ ថា "ព្រះអដ្ឋកថាចារ្យ កាលនឹងសំដែង ថា 'នោ' ដើម្បីនឹងឆ្លើយនូវពាក្យចោទសួរ ថា 'ក៏ចេតោបរិយញ្ញាណនេះ កំណត់ដឹងចិត្តរបស់បុគ្គលដទៃបាន ព្រោះភាវៈជាចិត្តដែលសម្រេចដោយឫទ្ធិ នឹងដឹងនូវចិត្ត សូម្បីរបស់ជនទាំងឡាយទាំងពួង ដោយមិនប្លែកគ្នា បានដែរឬទេ?' ដូច្នេះ ទើបពោលពាក្យ ថា 'តត្ថ' ដូច្នេះជាដើម ។ បទថា 'ន អរិយានំ' មានសេចក្តីថា បុគ្គលទាំងឡាយនោះ ឈ្មោះថា ជាព្រះអរិយៈ ដោយចិត្តឯណា, បុថុជ្ជនរមែងមិនដឹងនូវចិត្តនោះ គឺ នូវលោកុត្តរចិត្ត, ព្រះអរិយបុគ្គល អ្នកតាំងនៅក្នុងមគ្គថ្នាក់ក្រោម រមែងមិនដឹងនូវចិត្ត របស់ព្រះអរិយបុគ្គលអ្នកតាំងនៅក្នុងមគ្គថ្នាក់ខ្ពស់បាន ព្រោះភាវៈនៃចិត្តនោះ ជាធម្មជាតដែលខ្លួនមិនទាន់បានចាក់ធ្លុះហើយ ។ អធិប្បាយថា 'ប្រៀបដូចជា បុថុជ្ជន រមែងមិនដឹងនូវលោកុត្តរចិត្តនៃព្រះអរិយបុគ្គលទាំងឡាយទាំងពួងបានដែរ ព្រោះភាវៈនៃលោកុត្តរៈចិត្តគឺខ្លួននៅមិនទាន់បានចាក់ធ្លុះហើយ យ៉ាងណាមិញ, សូម្បីព្រះអរិយបុគ្គល ក៏យ៉ាងដូច្នោះដែរ, ប៉ុន្តែព្រះអរិយបុគ្គលដែលស្ថិតនៅក្នុងផលថ្នាក់ខ្ពស់ រមែងដឹងនូវចិត្តនៃព្រះអរិយបុគ្គលថ្នាក់ទាបបាន ព្រោះភាវៈនៃចិត្តនោះ គឺលោកបានចាក់ធ្លុះហើយ"។

(២៥១) ដីកាតិកនិបាតអង្គុត្តរនិកាយ ថា " បទថា 'អរិយានំ' មានសេចក្ដីថា បុថុជ្ជន រមែងមិនដឹងនូវមគ្គចិត្តនិងផលចិត្ត របស់ព្រះអរិយៈទាំងឡាយ ។ មែនពិត បុថុជ្ជន មិនអាចដើម្បីនឹងដឹងនូវមគ្គចិត្តនិងផលចិត្តនោះ សូម្បីដោយចេតោបរិយញ្ញាណ ព្រោះភាវៈនៃចេតោបរិយញ្ញាណ គឺបុថុជ្ជនមិនអាចសម្រេចបាន ដោយមគ្គចិត្តនិងផលចិត្តនោះ ។ ប៉ុន្តែបុថុជ្ជន ក៏រមែងដឹងនូវចិត្តដទៃបានដូចគ្នាដែរ ។ ក៏ពាក្យទាំងឡាយជាអាទិ៍ ថា 'ព្រះអរិយបុគ្គល អ្នកតាំងនៅក្នុងមគ្គថ្នាក់ទាប រមែងមិនដឹងនូវចិត្តរបស់ព្រះអរិយបុគ្គលថ្នាក់ខ្ពស់បាន' ដូច្នេះ បណ្ឌិតគប្បីជ្រាប ថា 'លោកពោលហើយ សំដៅយកមគ្គចិត្តផលចិត្តប៉ុណ្ណោះឯង' ។ ក៏សូម្បីព្រះអរិយបុគ្គលទាំងឡាយ មានព្រះសោតាបន្នជាដើម រមែងអាចដើម្បីនឹងដឹងនូវផលដែលខ្លួនបានសម្រេចប៉ុណ្ណោះ ដែលព្រះអរិយៈទាំងឡាយដទៃ ឲ្យកើតឡើងហើយដោយចេតោបរិយញ្ញាណ, មិនអាចដើម្បីនឹងដឹងនូវផលដែលខ្លួនមិនទាន់បានសម្រេចឡើយ " ។

បណ្ឌិតគប្បីត្រួតពិនិត្យមើលសេចក្ដីនេះ សូម្បីក្នុងអដ្ឋកថាបរិត្តារម្មណត្តិកៈ ក្នុងអដ្ឋកថាក័ណ្ឌ ។

ពណ៌នាអំពីចិត្តដែលក្សេម ចប់ ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយនូវពួក ៤ នៃមង្គល គឺ ចិត្តដែលមិនកម្រើកញាប់ញ័រ ចិត្តដែលមិនសោកសៅ ចិត្តដែលប្រាសចាកកិលេសដូចជាធូលី ចិត្តដែលក្សេម ដោយព្រះគាថានេះដោយប្រការដូច្នេះឯង ។

ពាក្យជាគាថានេះ ជាបឋ្យាវត្ត ដោយប្រការដូច្នេះឯង ។

ពណ៌នាអំពីសេចក្តីនៃគាថាទី ១០ ចប់ ។

*ការធ្វើកិច្ចការគ្រប់យ៉ាង គឺពិតជាមានការពិបាកជាងការនិយាយ ។*

ប្រែចប់ ថ្ងៃសុក្រ ៣ រោច ខែចេត្រ ឆ្នាំរកា បញ្ចស័ក ព.ស. ២៥៣៦
ត្រូវនឹងថ្ងៃទី ៩ ខែមេសា ១៩៩៣
( វេលាយប់ )

(២៥២) ព្រះមានព្រះភាគ ត្រូវទេវតាក្រាបទូលសួរហើយ យ៉ាងដូច្នេះ ទើបទ្រង់ត្រាស់នូវមង្គល ៣៨ ប្រការ ដោយគាថាទាំងឡាយ ១០ គឺ ក្នុងគាថា ទី ១-២-៦ គាថាមួយ ៗ មានមង្គល ៣ ៗ, ក្នុងគាថាទី ៣-៤-៥-៨-៩-១០ គាថាមួយៗ មានមង្គល ៤ ៗ, និងក្នុងគាថា ទី ៧ មាន ៥ មង្គល ហើយ កាលទ្រង់ត្រាស់សរសើរ នូវគាថាទាំងឡាយនេះ ក្នុងកាលឥឡូវនេះ ទើបត្រាស់នូវគាថាទី ១១ ថា "ឯតាទិសានិ កត្វាន" ដូច្នេះជាដើម ៗ

## ( អធិប្បាយបទឯតាទិសានិ )

គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ១១ នោះ ដូចតទៅនេះ ÷

មង្គលទាំងនោះ រមែងប្រាកដដូចមង្គលទាំងនេះ ព្រោះហេតុនោះ មង្គលទាំងនោះ ឈ្មោះថា ឯតាទិសានិ (ប្រាកដដូចមង្គលទាំងនេះ) ៗ ធាតុ គឺ ទិស ធាតុ មាន ឥម ស័ព្ទជាបទប្រៀបធៀប ប្រព្រឹត្តទៅក្នុងការពិចារណា ៗ ចុះ ក្វិ បច្ច័យ ៗ កាលបើការលប់ទីបំផុតនៃធាតុ ដោយសូត្រថា "លប់ទីបំផុតនៃធាតុ ព្រោះ ក្វិ បច្ច័យ ខាងចុង" ដល់ព្រមហើយ, ការផ្លាស់ ស អក្សរ និង

ការលប់ ក្វិ បច្ច័យ រមែងមាន ដោយសូត្រ ថា "ស្រៈទីបំផុតនៃ សព្វនាម គឺ ត-យ-ត-ម-កិ-ឯ-ស រមែងដល់នូវភាពជា ទីឃៈ (ដូចជា ត ជា តា) ឌ ទុស ធាតុ រមែងដល់នូវកិរិយា គុណក្នុងពេលខ្លះ (គឺយក ឌ ត្រង់ ទុស ធាតុ ជា ត) ទ រមែង ដល់នូវភាពជា រ (ដូចជា តារិស) និងយក ស (ត្រង់ ទុស ធាតុ ជា ស (ដូចជា តាទិស) ជា ក្ខ (ដូចជា តាទិក្ខ) និង ជា តា (ដូចជា តាទី)" ។

មតិក្នុងន្យាសបករណ៍ ថា "ទីឃៈ ត អក្សរ នៃ តម ស័ព្ទ ព្រោះធ្វើនូវការគុណ ពោលគឺភាវៈដែល ឌ អក្សរ ជា ត អក្សរ ដោយសូត្រ ថា 'ត-យ-ត ជាដើមនុ៎ះឯង និងលប់ ម អក្សរ" ។

ចំណែកក្នុងរូបសិទ្ធិបករណ៍ លោកពោល ថា "កាលបើលោក ធ្វើ ត អក្សរ នៃ តម ស័ព្ទ ដោយចុះសូត្រ ថា 'ត' ជាដើម និង ទីឃៈ ត អក្សរនោះ ដោយសូត្រនេះ, ការកើតឡើងនៃ សិ វិភត្តិជាដើម ក៏រមែងមាន" ។

(២៥៣) មង្គលទាំងឡាយនោះ ប្រាកដដូចមង្គលទាំងឡាយ នេះ ឈ្មោះថា **ឯតាទិសានិ** (មង្គលទាំងនោះ ប្រាកដដូចមង្គលទាំង ឡាយនេះ) ។ កាលបើលប់ស័ព្ទខាងក្រោយ ក៏ត្រូវទីឃៈស័ព្ទ ខាងមុខ ។ ដោយហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោល ថា

" បទថា 'ឯតាទិសានិ' បានដល់ មង្គលទាំងនោះ ដែលប្រាកដដូចមង្គលទាំងនេះ' ដូច្នេះហើយ ដើម្បីនឹងសំដែងនូវសេចក្តីនោះនិងវិស័យ ទើបពោលទៀតថា 'មង្គលទាំងឡាយ មានការមិនសេពគប់នូវបុគ្គលពាលជាដើម មានប្រការដូចខ្ញុំបានពោលមកហើយ" ។

មែនពិត ព្រះអដ្ឋកថាចារ្យពោលសេចក្តីនៃ ឦទិស ស័ព្ទ ដោយពាក្យនេះ ថា "**វុត្តប្បការានិ**" ។ លោកពោលវិស័យ នៃ **ឯត** ស័ព្ទ ដោយពាក្យនេះ ថា "**អសេវនាទីនិ**" ។ ក្នុងពាក្យថា "**អសេវនាទីនិ**" នោះ មានសេចក្តីថា ទាំងនេះ ។ មែនពិត ស័ព្ទថា **ឯត** និង **ឥម** មានសេចក្តីស្មើគ្នា ។ ដោយហេតុនោះ សូម្បីក្នុងអដ្ឋកថាឧបោសថក្ខន្ធកៈ ក៏លោកពោល ថា "២ បទថា '**ឯតានិ បុព្វករណំ**' បានដល់ កិច្ចទាំង ៤ យ៉ាងនេះ ឈ្មោះថាបុព្វករណ៍" ។

សូម្បីក្នុងអដ្ឋកថាសច្ចវិភង្គ លោកពោលថា "បទថា '**ឥទម្បិ**' បានដល់ **ឯតម្បិ** ។ សូម្បីក្នុងសទ្ទនីតិបករណ៍ ក៏លោកពោល ថា " **ត** ស័ព្ទ ពោលក្នុងទីកំបាំងមុខ, **ឯត** ស័ព្ទ ពោលក្នុងទីជិត, **ឥទ** ស័ព្ទ ពោលក្នុងទីជិតបង្អើយ" ។ ចំណែកពួកអាចារ្យក្នុងកាលឥឡូវនេះ ពោលនូវភាវៈនៃ ឯត ស័ព្ទថា មានសេចក្តីស្មើគ្នានឹង ត ស័ព្ទ ។ ពាក្យនោះ មិនត្រឹមត្រូវ ព្រោះខុសអំពីពាក្យតាមដែលបានពោលមកហើយ ។ ម្យ៉ាងទៀត ក្នុងបទនេះសោត សូម្បី

សេចក្តីថា “ មង្គលទាំងនោះប្រាកដដូចមង្គលទាំងនេះ បានដល់ តាមដែលបានពោលមកហើយ ក្នុងពេលនេះ ” ក៏ត្រឹមត្រូវដូចគ្នា ព្រោះលោកពោលហើយ ក្នុងអដ្ឋកថាបឋមបិដ្ឋវិមានវត្ថុ ថា “ ក្នុងបាទគាថាថា ‘ **កេន តេ តាទិសោ វណ្ណោ** ’ នេះ បទថា ‘ **តេ** ’ ប្រែថា របស់អ្នក, បទថា ‘ **ឯតាទិសោ** ’ ប្រែថា ដូច្នេះ, អធិប្បាយថា ‘ តាមដែលមានប្រាកដ ក្នុងកាលឥឡូវនេះ ” ។

( កែបទ កត្វាន )

(២៥៤) បទថា “ **កត្វាន** ” ប្រែថា ធ្វើហើយ ។ គប្បីបន្ថែមពាក្យដែលសេសសល់ ថា “ **ហោន្តិ** ” ប្រែថា រមែងមាន ។ ហេតុនោះ ក្នុងអដ្ឋកថា លោកពោល ថា “ម្នាលទេវតា ចូរអ្នកកំណត់យកយ៉ាងនេះ ថា ‘បុគ្គលទាំងឡាយណា តែងធ្វើនូវមង្គលទាំងឡាយដូច្នេះនុ៎ះ, បុគ្គលទាំងឡាយនោះ រមែងដល់នូវសេចក្តីសួស្តី ក្នុងកាលទាំងពួង ព្រោះហេតុណា, ព្រោះហេតុនោះ ទើបលោកពោលថា កម្មសូម្បីទាំង ៣៨ ប្រការ មានការមិនសេពគប់នូវបុគ្គលពាលជាដើមនោះ ជាមង្គលដ៏ឧត្តម ដ៏ខ្ពង់ខ្ពស់ គឺដ៏ប្រសើរបំផុត របស់បុគ្គលទាំងឡាយនោះ ជាអ្នកធ្វើមង្គលដូច្នេះនុ៎ះ ” ។

( កែបទ សព្វត្ថ ខាងដើម )

(២៥៥) បទថា “ **សព្វត្ថ** ” មានសេចក្តីថា ក្នុងបច្ចាមិត្រ

ទាំងឡាយ ៤ ផ្សេងដោយខន្ធមារ កិលេសមារ អភិសង្ខារមារ និងទេវបុត្តមារ ។ មែនពិត ក្នុងគម្ពីរខន្ធកវគ្គ ព្រះធម្មសង្គាហកាចារ្យពោលទុក ថា “ព្រះរាធៈដ៏មានអាយុ បានក្រាបទូលនូវពាក្យនេះ នឹងព្រះដ៏មានព្រះភាគ ថា ‘បពិត្រព្រះអង្គដ៏ចំរើន គេហៅថា ‘មារ មារ’ ដូច្នេះ, បពិត្រព្រះអង្គដ៏ចំរើន តើមារដូចម្ដេចទៅហ្ន៎ ?” ។ ព្រះមានព្រះភាគទ្រង់ត្រាស់ ថា “ម្នាលរាធៈ មារគឺរូប មារគឺវេទនា មារគឺសញ្ញា មារគឺសង្ខារ មារគឺវិញ្ញាណ” ។

អដ្ឋកថាខន្ធកវគ្គនោះ ថា “មរណៈ លោកហៅថា ‘មារ’ ក្នុងគាថានោះ, ក៏ឈ្មោះថា មរណៈ ដែលរួចផុតអំពីរូបជាដើម មិនមាន ព្រោះហេតុណា, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ ដល់ព្រះរាធៈដ៏មានអាយុនោះ ថា ‘ម្នាលរាធៈ មារគឺរូបនុ៎ះឯង’ ដូច្នេះជាដើម” ។

(២៥៦) ដីកាខន្ធកវគ្គនោះ ថា “ក៏ឈ្មោះថា មរណៈ ដែលរួចផុតអំពីរូបជាដើម រមែងមិនមាន, ព្រោះការបែកធ្លាយនៃរូបជាដើមនុ៎ះឯង ទើបមានឈ្មោះថា មរណៈ” ។

អដ្ឋកថាមារសំយុត្ត ថា “សភាវៈណា ញុំាំងសត្វទាំងឡាយដែលប្រតិបត្តិ ដើម្បីកន្លង នូវវិស័យរបស់ខ្លួន ឲ្យស្លាប់ ហេតុនោះសភាវៈនោះ ទើបឈ្មោះថា មារ” ។

ដីកាមារសំយុត្តនោះ ថា "បទថា 'មារេតិ' បានដល់ រមែង បៀតបៀន ៗ មែនពិត សេចក្តីប្រកបដោយវិបត្តិជាដើម នៃសាធុជនទាំងឡាយ ឈ្មោះថា មរណៈ ដោយបរមត្ថ" ៗ

អដ្ឋកថាអដ្ឋកនិបាត អង្គុត្តរនិកាយ ថា "សភាវៈណា កាលប្រកបសត្វទាំងឡាយ ក្នុងសេចក្តីវិនាស ធ្វើឲ្យស្លាប់ រហេតុនោះ សភាវៈនោះ ទើបឈ្មោះថា មារ" ៗ

ដីកាអដ្ឋកនិបាត អង្គុត្តរនិកាយនោះ ថា "សភាវៈណា កាលប្រកបសត្វទាំងឡាយទុក ក្នុងសេចក្តីវិនាស ឈ្មោះថា ធ្វើឲ្យស្លាប់ ព្រោះធ្វើឲ្យវិនាសចាកគុណ, ម្យ៉ាងទៀត រមែងដូចជាធ្វើសត្វដែលកើតហើយ ក្នុងភពនោះៗឲ្យស្លាប់ ព្រោះមានជាតិជានិមិត្ត ដោយកាត់បំផ្លាញនូវវិរាគធម៌ចោល ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យទើបពោល ថា '**មារេតីតិ មារោ**' ដូច្នេះ" ៗ

(២៥៧) ម អក្សរ ក្នុងពាក្យ ថា "**មបរាជិតា**" គ្រាន់តែជាការធ្វើបទសន្ធិ ៗ មានសេចក្តីថា "ទៅ គឺ ដល់នូវការមិនចាលចាញ់ គឺ មិនបរាជ័យ ៗ អធិប្បាយថា "រមែងមិនដល់នូវការបរាជ័យ" ៗ មិនដល់នូវការបរាជ័យ ក្នុងហេតុអ្វី ? ៗ ក្នុងបច្ចាមិត្រទាំងពួង ៗ មែនពិត បទថា "**សព្វត្ថ**" នេះ ជាពាក្យប្រាប់ដល់អាធារៈ ៗ ក៏អាចារ្យទាំងឡាយណា ពោល ថា " បទថា

'សព្វត្ថ' នេះ ជានិទ្ធារណៈ" ដូច្នេះ ព្រោះលោកពោលហើយថា "ជាអ្នកគឺសូម្បីបណ្តាសឹកសត្រូវទាំង ៤ ណាមួយ ឲ្យបរាជ័យមិនបានហើយ, មានពាក្យដែលលោកអធិប្បាយថា 'ខ្លួនឯងប៉ុណ្ណោះធ្វើមារទាំងឡាយ ៤ នោះ ឲ្យបរាជ័យហើយ" ដូច្នេះ, អាចារ្យទាំងឡាយនោះ គប្បីត្រូវគេពោលតវ៉ា យ៉ាងដូច្នេះ ។ សូម្បីពាក្យនេះថា "ជាអ្នកធ្វើនូវមង្គលទាំងឡាយដូច្នេះនោះហើយ ជាអ្នកគឺមារទាំង ៤ ឲ្យបរាជ័យមិនបានហើយ" ដូច្នេះ លោកពោលហើយ ក្នុងអដ្ឋកថា ។ តាមមតិរបស់លោកទាំងឡាយ ដោយអំណាចនៃបទថា "សព្វត្ថ" នោះ បណ្ឌិតគប្បីកំណត់យកសេចក្តីថា "បទថា 'សព្វត្ថ' ស្មើនឹង សព្វេហិ ប្រែថា ដែលសឹកសត្រូវទាំងពួង" ដូច្នេះហើយ គប្បីពោលថា "ជាកត្តា ឬ ជាប្រធាន" ។ តែពាក្យនេះ បណ្ឌិតមិនគួរឃើញ យ៉ាងដូច្នេះ ។ មែនពិត បទថា "សព្វត្ថ" នេះគ្រប់ៗបទ លោកពោលហើយ ដោយអំណាចនៃសេចក្តីដែលអធិប្បាយ ។ ព្រោះហេតុនោះ គប្បីដល់ការយល់ព្រម ក្នុងបទថា សព្វត្ថ នេះ ថា "បទថា 'សព្វត្ថ' ជាអាធារៈតែម្យ៉ាង" ។

( កែបទ អបរាជិត )

ក្នុងអដ្ឋកថា ឈ្មោះកង្ខាវិតរណី លោកពោល ថា "២ បទថា

'បារាជិកោ ហោតិ' មានសេចក្ដីថា រមែងជាអ្នកចាលចាញ់ហើយមែនពិត គឺ ដល់ហើយនូវការបរាជ័យ" ។

ដីកាកង្ខាវិតរណីនោះ ថា " បរាជិត សត្រូ លោកបានសំដែងថា " បារាជិកោ ហោតិ " ដូច្នេះ ព្រោះធ្វើការផ្លាស់ឧបសគ្គ និងព្រោះធ្វើ ត អក្សរ ឲ្យទៅជា ក អក្សរ " ។

ព្រោះហេតុនោះ ក្នុងបទ ថា " អបរាជិតា " នេះឯង សេចក្ដីដែលលោកពោលហើយ ថា " បទថា 'អបរាជិតា' ប្រែថា ដល់ហើយនូវការមិនបរាជ័យ " ដូច្នេះ ក៏ត្រឹមត្រូវដូចគ្នា ។

## ( កែបទ សព្វត្ថ ខាងចុង )

(២៥៨) បទថា " សព្វត្ថ " គឺក្នុងលោកនេះ និងលោកខាងមុខ និងក្នុងទីឈរ និងទីចង្ក្រមន៍ជាដើម ។

## ( កែបទ សោត្ថឹ )

បទថា " សោត្ថឹ " ប្រែថា សេចក្ដីសួស្ដី ។ ចុះនិគ្គហិតអាគម ។ ដោយហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោល ថា " ក៏និគ្គហិត ក្នុងបទថា 'សោត្ថឹ' នេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ ដើម្បីនឹងងាយស្រួលក្នុងការនិពន្ធគាថា " ។

(២៥៩) ក៏ក្នុងបទ ថា " សោត្ថឹ " នេះ ពាក្យណាដែល

លោកអាចារ្យបានពោលទុកហើយ ថា "ដើម្បីទ្រង់រក្សានូវឆ័ន្ទ" ថា "ដើម្បីទ្រង់រក្សានូវព្រឹទ្ធ" និង ថា "ដើម្បីនឹងសូត្រស្រួល" ដូច្នេះ, ពាក្យនោះ គប្បីឃើញ ថា "លោកពោលហើយ ដោយអំណាចនៃអាការត្រឹមតែកិរិយាប្រព្រឹត្តដ៏ថោកទាប" ។ ក៏ព្រះដ៏មានព្រះភាគទ្រង់រក្សានូវឆ័ន្ទនិងព្រឹទ្ធក៏ទេ និងទ្រង់ធ្វើសន្និកិរិយោបករណ៍មានការលប់អក្សរជាដើម ដើម្បីសូត្រស្រួលក៏ទេដែរ ។ ក៏បុគ្គលណាមានមន្ទិលសង្ស័យ មានសេចក្តីភ័យខ្លាច, បុគ្គលនោះតែងរក្សានូវឆ័ន្ទនិងព្រឹទ្ធ និងធ្វើនូវសន្និកិរិយោបករណ៍មានការលប់អក្សរជាដើម ដើម្បីនឹងសូត្រស្រួល ព្រោះភ័យខ្លាចអំពីការនិន្ទា ដែលកើតឡើងអំពីសំណាក់នៃពួកអ្នកប្រាជ្ញដទៃទៀត ។ ចំណែកព្រះមានព្រះភាគទ្រង់មិនមានសេចក្តីសង្ស័យ ទ្រង់មិនមានសេចក្តីភ័យខ្លាច, ព្រោះថាសេចក្តីភ្លាំងភ្លាត់ ក្នុងព្រះតម្រាស់ របស់ព្រះមានព្រះភាគ តែងមិនមាន, ព្រះអង្គទ្រង់អាស្រ័យនូវពាក្យរិះគន់ របស់ជនដទៃហើយនឹងទ្រង់រក្សានូវឆ័ន្ទនិងព្រឹទ្ធ និងទ្រង់ធ្វើនូវសន្និកិរិយោបករណ៍មានការលប់អក្សរជាដើម ដើម្បីនឹងសូត្រស្រួល យ៉ាងដូចម្តេចទៅ ។ សមដូចជាពាក្យដែលលោកពោលហើយ ក្នុងដីកាអភិធម្ម ថា "ក៏ព្រះដ៏មានព្រះភាគ មិនទ្រង់កំណត់យកនូវភារៈ នៃព្រះតម្រាស់ដែលជាគរុនិងលហុទេ តែមិនទ្រង់ប្រឆាំងបំពាន នឹងសភាវធម៌ឡើយ

ទ្រង់ពិចារណាព្រះធម៌ទេសនា ដោយប្រការនោះៗ ដោយអនុលោមទៅតាមអធ្យាស្រ័យ របស់ពួកសត្វអ្នកដែលគួរត្រាស់ដឹង ”ៗ

ក្នុងសទ្ទនីតិត្រង់សន្ធិកប្ប លោកពោលទុក ថា “នរណាក៏មិនគួរជំទាស់ សេចក្តីនៃអក្សរទាំងឡាយ ច្រើនឬតិច ក្នុងកាលណាៗ”ៗ

ព្រោះហេតុនោះ សូម្បីពាក្យនេះ ថា “ដើម្បីងាយស្រួល ក្នុងការនិពន្ធគាថា” បណ្ឌិតគប្បីជ្រាប ដោយន័យនោះដូចគ្នាដែរ ៗ

(២៦០) ក៏ដោយពាក្យ ថា “អនុនាសិកោ” នេះ សូម្បីវាទៈ ថា “អក្សរទី ៥ ជាលហុ ក្នុងទីទាំងពួង” ជាវាទៈដែលព្រះអដ្ឋកថាចារ្យ ពោលបដិសេធហើយ ៗ

មែនពិត ក្នុងនេរុត្តិកបទវិភត្តិបករណ៍ លោកពោលសេចក្តីនេះ ថា “សោត្ថិ ស័ព្ទ ជាស័ព្ទមានវិភត្តិ ដែលមិនទាន់បានលប់ លោកសំដែងហើយ ២ ប្រការ ដោយអំណាច នៃទុតិយាវិភត្តិនិងតតិយាវិភត្តិ យ៉ាងដូច្នេះ ថា “សោត្ថឹ បស្សាមិ បាណិនំ (និង) សោត្ថិនាម្ហិ សមុដ្ឋិតោ” រមែងខុសចាកបាលី ថា ÷

‘ បទនិបាតណា រមែងដូចគ្នា ក្នុងលិង្គទាំង ៣ ក្នុង
វិភត្តិទាំងពួង និងក្នុងវចនៈទាំងពួង មិនប្រែប្រួល,
បទនិបាតនោះ ជាអព្យយស័ព្ទ ’

ដូច្នេះ ក៏ពិតមែន, ទោះបីជាយ៉ាងដូច្នោះ ព្រោះអាស្រ័យនូវវិភត្តិ

ដែលសេសសល់ សេចក្ដីប្រែប្រួលទៅនៃ សោត្ថិ សព្ទនោះ ក៏រមែងមិនមាន ព្រោះហេតុនោះ គប្បីធ្វើសេចក្ដីសង្គ្រោះនុ៎ះឯង ក្នុងបទនិបាតទាំងឡាយ ព្រោះជាអព្យយសព្ទ"។ ព្រោះហេតុនោះ គប្បីឃើញថា 'សោត្ថិ សព្ទ ជានិបាត'។ ក៏ក្នុងបទថា 'សោត្ថី' នោះ បឋមាវិភត្តិ ពហុវចនៈនុ៎ះឯង ព្រះដ៏មានព្រះភាគទ្រង់លប់ហើយ ។ ដោយហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោល ថា "អាសវៈទាំងឡាយ (និង) សេចក្ដីក្ដៅក្រហល់ក្រហាយ ដែលធ្វើសេចក្ដីចង្អៀតចង្អល់ឯណា គប្បីកើតឡើង ព្រោះការសេពគប់បុគ្គលពាលជាដើម, ព្រោះការមិនមានអាសវៈ និងសេចក្ដីក្ដៅក្រហល់ក្រហាយ ដែលធ្វើសេចក្ដីចង្អៀតចង្អល់ទាំងឡាយនោះ ទេវតានិងមនុស្សទាំងឡាយជាអ្នកមានសេចក្ដីសួស្ដី មិនមានឧបទ្រព មិនមានឧបសគ្គ ជាអ្នកក្សេមក្សាន្ត មិនមានភ័យចំពោះមុខ"។

(២៦១) អដ្ឋកថាសព្វាសវសូត្រ និងអដ្ឋកថាអាហុនេយ្យសូត្រ ក្នុងឆក្កនិបាត អង្គុត្តរនិកាយ ថា "អាសវៈទាំងឡាយ ៤ និងសេចក្ដីក្ដៅក្រហល់ក្រហាយព្រោះកិលេស ឬសេចក្ដីក្ដៅក្រហល់ក្រហាយព្រោះវិបាក ដែលធ្វើសេចក្ដីចង្អៀតចង្អល់ដទៃទៀត ឈ្មោះថាអាសវៈ (និង) សេចក្ដីក្ដៅក្រហាយ ដែលធ្វើសេចក្ដីចង្អៀតចង្អល់ ក្នុងព្រះសូត្រនោះ ។ មែនពិត កាមាសវៈ រមែងកើតឡើង ដល់បុគ្គល

អ្នកចូលចិត្ត ត្រេកអរដីក្រៃលែងនូវឥដ្ឋារម្មណ៍ ដែលមកកាន់គន្លង ក្នុងចក្ខុទ្វារ ដោយអំណាចសេចក្តីត្រេកអរក្នុងកាម ។ ភវាសវៈ រមែងកើតឡើង ដល់បុគ្គលអ្នកត្រេកអរ ដោយសេចក្តីប្រាថ្នាភព ថា 'អាត្មាអញនឹងបាននូវអារម្មណ៍ដូច្នេះ ក្នុងសុគតិភពដទៃទៀតពិត' ។ ទិដ្ឋាសវៈ រមែងកើតឡើង ដល់បុគ្គលអ្នកប្រកាន់មាំថា 'ជាសត្វ ឬ ថា របស់សត្វ' ។ ការមិនដឹងដែលកើតព្រមគ្នានឹងអាសវៈទាំងឡាយ ទាំងពួងនុ៎ះឯង ឈ្មោះថា អវិជ្ជាសវៈ ។ កិលេសទាំងឡាយដទៃ ទៀតនុ៎ះឯង ដែលសម្បយុត្តដោយអាសវៈទាំងនោះ ឈ្មោះថា សេចក្តី ក្តៅក្រហាយដែលធ្វើសេចក្តីចង្អៀតចង្អល់, ម្យ៉ាងទៀត វិបាកនៃ អាសវៈទាំងនោះ ក្នុងកាលតទៅ ឈ្មោះថា សេចក្តីក្តៅក្រហាយដែល ធ្វើសេចក្តីចង្អៀតចង្អល់ "។

(២៦២) ដីកាសព្វាសវសូត្រជាដើមនោះ ថា " បទថា 'វិឃាតករា' បានដល់ ដែលធ្វើសេចក្តីចង្អៀតចង្អល់ចិត្ត ឬធ្វើ សេចក្តីទុក្ខខាងផ្លូវកាយ និងផ្លូវចិត្ត ឲ្យកើតឡើង ។ វិបាកដែល ជិតតាមជាប់ទៅ ដុតកំទេច ដែលមានកិលេស ដូចបានពោលមក ហើយជាហេតុនុ៎ះឯង ឈ្មោះថា សេចក្តីក្តៅក្រហាយព្រោះវិបាក ។ អាសវៈទាំងឡាយ និងកិលេសជាគ្រឿងធ្វើសេចក្តីចង្អៀតចង្អល់ចិត្ត គឺសេចក្តីក្តៅក្រហាយព្រោះវិបាកដទៃទៀត រមែងកើតមាន ព្រោះ

ការសេពគប់នូវបុគ្គលពាលជាដើមនេះ ដោយប្រការណា, ដើម្បីនឹងសំដែងនូវប្រការនោះ ព្រះអដ្ឋកថាចារ្យពោលពាក្យ ថា 'ចក្ខុទ្វារេហិ' ដូច្នេះជាដើម " ។

ចំណែកការសរុបនៃអាសវៈ បណ្ឌិតគប្បីត្រួតពិនិត្យមើល ក្នុងអដ្ឋកថានៃនិក្ខេបកណ្ឌសង្គីតិសូត្រនិងសព្វាសវសូត្រព្រមទាំងដីកា ។ ប៉ុន្តែដោយសង្ខេប គប្បីឃើញ ថា " លោភៈ មានធម៌ជាកាមាវចរទាំងពួងជាអារម្មណ៍ ប្រកបដោយទិដ្ឋិ ឈ្មោះថា កាមាសវៈ, លោភៈមានកម្មភពនិងឧបបត្តិភព ដែលជារូបាវចរជាអារម្មណ៍ប្រាសចាកទិដ្ឋិ ឈ្មោះថា ភវាសវៈ, ទិដ្ឋិ ៦២ ឈ្មោះថា ទិដ្ឋាសវៈ, មោហៈឈ្មោះថា អវិជ្ជាសវៈ " ។

( កែបទ តន្តេសំ )

(២៦៣) បទថា " តន្តេសំ " ជាដើម មានសេចក្តីថា ជនទាំងឡាយណា ជាអ្នកធ្វើនូវមង្គលទាំងឡាយដូច្នេះនោះ, ជនទាំងឡាយនោះ ជាអ្នកមិនបរាជ័យ ក្នុងសឹកសត្រូវទាំងពួង ជាអ្នកមានសួស្តី គឺជាអ្នកមានសុវត្ថិភាព ទៅក្នុងទីទាំងពួង ព្រោះហេតុណា, ព្រោះហេតុនោះ ម្នាលទេវតា ចូរអ្នកប្រកាន់យក ថា " កម្ម ៣៨ ប្រការ មានការមិនសេពគប់នូវបុគ្គលពាលជាដើមនោះ របស់បុគ្គលទាំងឡាយនោះ គឺអ្នកធ្វើនូវមង្គលដូច្នេះនោះ ជាមង្គលដ៏ឧត្តម គឺ

ដ៏ប្រសើរ ខ្ពង់ខ្ពស់បំផុត "ដូច្នេះ ។ ក៏ក្នុងគាថាទី ១១ នេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់បទ ថា "**ឯតាទិសានិ**" ដោយអំណាចនៃការសំឡឹងរំពៃនូវប្រភេទ, ត្រាស់បទ ថា "**តំ**" ដោយអំណាចនៃការសំឡឹងរំពៃនូវជាតិ ប្រៀបដូចជាពាក្យដែលទេវតាក្រាបទូល ថា "**មង្គលានិ អាចិន្តយុំ**" និង ថា "**ព្រូហិ មង្គលំ**" ដូច្នោះឯង ។ ពាក្យថា "**សព្វត្ថ សោត**" ជា រ គណៈ, ពាក្យថា "**ថី គច្ឆន្តិ**" ជា ម គណៈ, សូម្បីគាថានេះ ក៏ឈ្មោះថា បថ្យាវត្ត ។

( និគមវចនៈ )

(២៦៤) ព្រះដ៏មានព្រះភាគ ទ្រង់ញ៉ាំងព្រះធម៌ទេសនា ឲ្យចប់ហើយ ដោយគាថានេះ ដោយប្រការដូច្នេះ ។ ក្នុងទីបញ្ចប់ព្រះធម៌ទេសនា ទេវតា ១ សែនកោដិ បានសម្រេចនូវព្រះអរហត្ត ។ ទេវតាដែលបានសម្រេចផលថ្នាក់ទាប ហួសគណនា ។ សូម្បីទេវតាទាំងអស់នោះ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ក៏អន្តរធានបាត់ទៅ ក្នុងទីនោះឯង ។

ចំណែកព្រះអានន្ទត្ថេរ សំដៅយកទេវតាអ្នកក្រាបទូលសួរនូវបញ្ហាតែមួយអង្គគត់ ទើបពោល ថា "ព្រះមានព្រះភាគ ទ្រង់បានត្រាស់មង្គលសូត្រនេះហើយ, ទេវតានោះ មានចិត្តត្រេកអរ ពោល

សរសើរភាសិតនៃព្រះមានព្រះភាគហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ អន្តរធានហើយ ក្នុងទីនោះឯង "។ ភារៈនៃមង្គលសូត្រល្អក្នុងទីបំផុត គឺព្រះថេរៈបានសំដែងហើយ ដោយបាទនេះ ។

( កែនិគមវចនៈ )

បណ្តាបទទាំងនោះ ដោយបទថា "ឥទំ" នេះ ព្រះថេរៈតែងរួបរួមសូម្បីនូវពាក្យទាំងពួង ថា "ពហូ ទេវា មនុស្សា ច" ដូច្នេះជាដើម ។ គាថាទីមួយ គឺទេវតាពោល ក៏ពិតមែន, ទោះបីជាដូច្នោះ ព្រះថេរៈសំដៅយកគាថានោះ ដែលព្រះមានព្រះភាគទ្រង់បានត្រាស់សំដែងហើយ ដល់ខ្លួន ទើបពោល យ៉ាងដូច្នេះ ។

បានឮថា ព្រះសាស្តាទ្រង់ត្រាស់មង្គលសូត្រទាំងពួង ដល់ព្រះថេរៈនោះ ក្នុងថ្ងៃទី ២ ។ ដោយហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោល ថា "គ្រានោះ ក្នុងថ្ងៃទី ២ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទមកហើយ ទ្រង់ត្រាស់ ថា 'ម្នាលអានន្ទ ក្នុងរាត្រីយប់នេះ ទេវតាមួយអង្គ បានចូលមករកតថាគត ហើយបានក្រាបទូលសួរនូវបញ្ហារឿងមង្គល, គ្រានោះ តថាគតក៏បានសំដែងមង្គល ៣៨ ប្រការ ដល់ទេវតាអង្គនោះ, ម្នាលអានន្ទ ចូរអ្នករៀនមង្គលបរិយាយនេះ លុះរៀនហើយ ចូរប្រាប់ភិក្ខុទាំងឡាយផង "។

ព្រះថេរៈ បានរៀនហើយ ប្រាប់នូវភិក្ខុទាំងឡាយហើយ" ដូច្នេះ ។

## ( សរុបសេចក្ដីនៃមង្គលសូត្រ )

(២៦៥) ឥឡូវនេះ ដើម្បីប្រាកដជាក់ច្បាស់ នៃការអប់រំបន្ទំញាណ ក្នុងមង្គលទាំងពួង ទើបព្រះអដ្ឋកថាចារ្យទាំងឡាយធ្វើការប្រមែប្រមូលសេចក្ដី តាំងអំពីដើមមក ដូចមានតទៅនេះ ÷ សត្វទាំងឡាយនេះ ជាអ្នកប្រាថ្នានូវសេចក្ដីសុខ ក្នុងលោកនេះសេចក្ដីសុខក្នុងលោកខាងមុខ និងសេចក្ដីសុខដែលជាលោកុត្តរៈ លះបង់នូវការសេពគប់នូវជនពាលចោល អាស្រ័យនូវបណ្ឌិតហើយ បូជានូវលោកអ្នកដែលគួរបូជាទាំងឡាយ យ៉ាងដូច្នេះ ជាអ្នកគឺការរស់នៅក្នុងប្រទេសដ៏សមគួរ និងភាវៈជាអ្នកមានបុណ្យដែលបានធ្វើទុកមកហើយក្នុងកាលមុន ដាស់តឿនក្រើនរំលឹក ក្នុងកិរិយាញ៉ាំងកុសលឲ្យកើតឡើង តាំងខ្លួនទុកហើយដោយប្រពៃ ជាអ្នកមានអត្តភាពគឺពាហុសច្ចៈ សិប្បៈ និងវិន័យ ប្រដាប់តាក់តែងហើយ ពោលនូវវាចាជាសុភាសិត ដែលសមគួរដល់វិន័យ ដរាបវេលាដែលមិនទាន់លះបង់នូវភាពជាគ្រហស្ថចេញ ក៏ដោះជម្រះ នូវថ្លៃបំណុលចាស់ដោយកិរិយាទំនុកបំរុងមាតាបិតា ប្រគបថ្លៃបំណុលថ្មី ដោយការសង្គ្រោះ នូវបុត្រនិងភរិយា ដល់នូវការសម្រេច ដោយទ្រព្យ និង

ធញ្ញាហារជាដើម ព្រោះភាវៈជាអ្នកមានការងារ ដែលមិនច្របូកច្របល់ ប្រកាន់យកនូវខ្លឹមសារនៃភោគៈ ដោយការឲ្យទាន និងប្រកាន់យកនូវខ្លឹមសារនៃជីវិត ដោយកិរិយាប្រព្រឹត្តិធម៌ ធ្វើនូវប្រយោជន៍សុខដល់ជនរបស់ខ្លួន ដោយការសង្គ្រោះញាតិ និងធ្វើនូវប្រយោជន៍សុខដល់ជនដទៃទៀត ដោយភាពជាអ្នកមានការងារ ដែលមិនមានទោស វៀរចាកនូវការបៀតបៀនអ្នកដទៃ ដោយការវៀរចាកបាប និង វៀរចាកនូវការបៀតបៀនខ្លួនឯង ដោយការសង្រួមចាកការផឹកនូវគ្រឿងស្រវឹង ញុំាងធម៌ផ្នែកកុសលឲ្យចំរើនឡើង ដោយការមិនប្រមាទ ក្នុងធម៌ទាំងឡាយ លះបង់ភេទជាគ្រហស្ថចោលចេញ ព្រោះភាពជាអ្នកមានកុសលបានចំរើនហើយ សូម្បីតាំងនៅស៊ប់ហើយ ក្នុងភាពជាបព្វជិត ក៏ញុំាងវត្តសម្ប័ទឲ្យបរិបូណ៌សព្វគ្រប់ដោយការគោរព ក្នុងលោកអ្នកដែលគួរគោរពទាំងឡាយ មានព្រះពុទ្ធ ព្រះសាវ័ករបស់ព្រះពុទ្ធ ព្រះឧបជ្ឈាយ៍ និងអាចារ្យជាដើម និងដោយកិរិយាប្រព្រឹត្តិបន្ទាបខ្លួនហើយ លះបង់នូវការជាប់ជំពាក់ក្នុងបច្ច័យ ដោយការសន្ដោស ស្ថិតនៅក្នុងភូមិនៃសប្បុរស ព្រោះភាពជាអ្នកដឹងនូវឧបការគុណ ដែលលោកបានធ្វើហើយ លះបង់នូវភាពជាអ្នកមានចិត្តរួញរា ដោយកិរិយាស្ដាប់ព្រះធម៌ គ្របសង្កត់នូវសេចក្ដីអន្តរាយទាំងពួងចេញ ដោយសេចក្ដីអត់ធន់ ធ្វើខ្លួនឲ្យមាន

ទីពឹង ដោយភាពជាអ្នកដែលគេប្រដៅងាយ ពិចារណាឃើញនូវការប្រកបនូវសេចក្ដីប្រតិបត្តិ ដោយកិរិយាឃើញនូវសមណៈ បន្ទោបង់នូវសេចក្ដីសង្ស័យ ក្នុងធម៌ដែលជាទីតាំង នៃសេចក្ដីសង្ស័យ ដោយការសន្ទនាធម៌ ញុំាងសីលវិសុទ្ធិ ឲ្យដល់ព្រម ដោយតបៈ គឺការសង្រួមឥន្ទ្រីយ៍ ញុំាងចិត្តវិសុទ្ធិ និងវិសុទ្ធិទាំងឡាយ ៤ ក្រៅអំពីនោះ ឲ្យដល់ព្រម ដោយការប្រព្រឹត្តិដ៏ប្រសើរ គឺសមណធម៌ សម្រេចហើយនូវញាណទស្សនវិសុទ្ធិ ដែលជាបរិយាយនៃការឃើញនូវសច្ចៈ ដោយបដិបទានេះ ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលរាប់ថាជាព្រះអរហត្តផល ដែលព្រះអរិយបុគ្គលទាំងឡាយធ្វើឲ្យជាក់ហើយ ជាអ្នកមានចិត្តមិនញាប់ញ័រ ដោយលោកធម៌ទាំង ៨ ប្រការ ដូចភ្នំព្រះសុមេរុ មិនកម្រើកញាប់ញ័រ ដោយខ្យល់និងភ្លៀង យ៉ាងដូច្នោះឯង ជាអ្នកមិនសោកសៅ មិនមានកិលេសដូចធូលី ជាអ្នកមានសេចក្ដីក្សេមក្សាន្ត, ក៏បុគ្គលទាំងឡាយណា ជាអ្នកមានសេចក្ដីក្សេមក្សាន្ត, បុគ្គលទាំងឡាយនោះ រមែងជាអ្នកមិនបរាជ័យ ក្នុងទីស្ថានទាំងពួង និងរមែងដល់នូវសេចក្ដីសួស្ដី ក្នុងទីទាំងពួង ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា " ឯតាទិសានិ កត្វា ។ បេ ។ តន្តេសំ មង្គលមុត្តមំ " ដូច្នេះ ។

ព្រះសូត្រនេះ លោកបានចងក្រងរួបរួមទុកហើយ ក្នុងស្ថានទី

ទាំងឡាយ ២ គឺ ក្នុងទុតិយវគ្គ នៃសុត្តនិបាត ១ ក្នុងខុទ្ទកបាឋៈ ១ ដែលរាប់ចូលក្នុងខុទ្ទកនិកាយ ដូច្នេះឯង ។

( ការតែងមង្គលត្ថទីបនី )

(២៦៦) ក៏មង្គលត្ថទីបនីនេះឯណា ដែលខ្ញុំបានប្តេជ្ញាហើយ ដោយពាក្យពេចន៍ មានប្រមាណប៉ុណ្ណោះ បាននាំយកសេចក្តីដែលមានខ្លឹមសារ ជាអនេក អំពីព្រះត្រៃបិដកមកតែងទុកហើយ, មង្គលត្ថទីបនីនោះ ក៏បានសម្រេចហើយ ដែលវិញ្ញូជន គប្បីអានមើលដោយប្រពៃ, កាលនឹងមើល នូវមង្គលត្ថទីបនីនេះ ក៏បានភាពជាអ្នកឈ្លៀវឆ្លាត ក្នុងមង្គលទាំងពួង ។

ព្រះថេរៈ ជាអ្នកប្រសើរ ប្រកបដោយនាម ថា មង្គល មាន សិរិ ស័ព្ទ ជាបទខាងដើម (សិរិមង្គល) ជាសិស្សរបស់ព្រះពុទ្ធវីរៈ ជាអ្នកមានវិចារណញ្ញាណ ក្នុងព្រះសូត្រ ព្រះអភិធម្ម និងព្រះវិន័យ មានសេចក្តីឧស្សាហ៍ បានរចនា (តែង) នូវមង្គលត្ថទីបនីនេះ ដែលមានអត្ថរសគួរជាទីចាប់ចិត្ត យ៉ាងក្រៃលែង ។

(២៦៧) ព្រះមហាថេរ ជាអ្នកមាននាម ដែលគ្រូទាំងឡាយ

បានតាំងនាម ថា "សិរិមង្គល" អ្នកនៅក្នុងសុញ្ញាគារ ដែលជាទីកើត នៃសេចក្ដីជ្រះថ្លា របស់ជនទាំងឡាយអ្នកដែលមកដល់ហើយ ដែលជាទីស្ងប់ស្ងាត់ ក្នុងស្ថានទី ១ គាវុត ពួដ៏ទិសទក្សិណ នៃនវបុរៈ ជាអ្នកត្រេកអរក្នុងសេចក្ដីស្ងាត់ មានសេចក្ដីឧស្សាហ៍ច្រើន ចេះចាំនូវព្រះត្រៃបិដក ប្រដាប់ដោយសេចក្ដីជ្រះថ្លា ការចេះដឹង និងសេចក្ដីព្យាយាម ប្រាថ្នាសេចក្ដីឆ្លាតវាងវៃ ដើម្បីខ្លួន និងបុគ្គលដទៃទៀត បានតែងមង្គលត្ថទីបនីនេះទុក នៅក្នុងឆ្នាំវក ក្នុងស័ករាជ ៨៨៦ ក្នុងរជ្ជកាល នៃព្រះរាជាធិរាជ ជាស្ដេចនៃមនុស្ស ជាអ្នកកំពូលជាងព្រះរាជាទាំងពួង ជាព្រះរាជនត្តា នៃព្រះរាជាទ្រង់ព្រះនាមថា លកៈ ទ្រង់ជាឥស្សរៈ ក្នុងនវបុរៈរាជធានី ទ្រង់មានព្រះសទ្ធាជ្រះថ្លាយ៉ាងក្រៃលែង ទ្រង់ប្រាថ្នាព្រះសព្វញ្ញុតញ្ញាណ ទ្រង់ជ្រះថ្លាហើយក្នុងព្រះពុទ្ធសាសនា ដោយប្រការដូច្នេះ ។

## ( សេចក្ដីប្រាថ្នារបស់អ្នកតែង )

មង្គលត្ថទីបនីនោះ សម្រេចហើយ ប្រាសចាកអន្តរាយ យ៉ាងណាមិញ, សូមសេចក្ដីប្រាថ្នាដ៏ល្អប្រសើរ របស់ពួកសត្វទាំងអស់នោះឯង ចូរសម្រេច ក៏យ៉ាងដូច្នោះដែរ ។

" បុណ្យណា ឲ្យសេចក្ដីសុខ ដែលខ្ញុំអ្នកតែងនូវ

មង្គលត្ថទីបនីនេះ បានសម្រេចហើយ, ដោយបុណ្យរបស់ខ្ញុំនោះ សូមឲ្យសេចក្ដីប្រាថ្នាដ៏ល្អសោភា របស់ប្រជាជន ចូរបានសម្រេច ។ សូមឲ្យសត្វទាំងឡាយអ្នកមានកាយជាអនន្ត ដោយជុំវិញ ក្នុងអនន្តចក្កវាឡ ចូរមានសេចក្ដីសុខ មានអាយុយឺនយូរ ឃើញតែកម្មដែលចំរើន សព្វៗកាល ។

ម្យ៉ាងទៀត សត្វទាំងឡាយ អ្នកប្រាថ្នាបុណ្យជ្រះថ្លាហើយ ក្នុងព្រះពុទ្ធ មានព្រះធម៌ដែលជាទីជ្រះថ្លាហើយ និងជ្រះថ្លាហើយ ក្នុងព្រះសង្ឃ, សូមឲ្យសត្វទាំងឡាយនោះ ដែលមានប្រការ យ៉ាងដូច្នោះ ចូរបាននូវសេចក្ដីសម្រេច នៃសេចក្ដីប្រាថ្នា និងការរួចផុតចាកសេចក្ដីទុក្ខ ។

ចំណែកខ្លួនខ្ញុំ គប្បីបាននូវផល ដ៏ខ្ពង់ខ្ពស់ដែលស្គាល់ហើយ ថា 'ព្រះអរហត្ត' ដែលប្រដាប់ហើយ ដោយគុណទាំងពួង ក្នុងភពជាទីបំផុត ។

ព្រះពុទ្ធជាអ្នកដឹកនាំលោក ទ្រង់មានព្រះនាមថា ព្រះអរិយមេត្តេយ្យ ទ្រង់ស្ដេចឧបត្តិឡើងហើយក្នុងកាលណា, ក្នុងកាលនោះ ខ្ញុំម្ចាស់ គប្បីនៅ

ចំពោះព្រះភក្ត្រ គប្បីស្តាប់នូវធម៌នោះ របស់ព្រះអង្គ លុះខ្ញុំម្ចាស់បានស្តាប់ព្រះធម៌ របស់ព្រះអង្គហើយ គប្បីបានដល់នូវផលដ៏ប្រសើរ, គ្រានោះ ខ្ញុំម្ចាស់ គប្បីជាអ្នកប្រកបហើយ ដោយគុណទាំងឡាយគ្រប់យ៉ាង ។

ប្រសិនបើខ្ញុំម្ចាស់ មិនគប្បីសម្រេចនូវផល ក្នុងសំណាក់របស់ព្រះអរិយមេត្តេយ្យអង្គនោះទេ, ខ្ញុំម្ចាស់កាលអន្ទោលទៅ ក្នុងភពតូចនិងភពធំ មិនគប្បីសេពគប់នូវបាបមិត្រ គប្បីសេពគប់នូវបុរស ដ៏ខ្ពង់ខ្ពស់ទាំងឡាយ ខ្ញុំម្ចាស់មិនគប្បីប្រកបដោយទិដ្ឋិអាក្រក់ គប្បីប្រកបដោយទិដ្ឋិដ៏ល្អប្រសើរ ។

ខ្ញុំម្ចាស់ចូរជាអ្នកប្រកបព្រម ដោយគុណធម៌មានទានជាដើម ជាអ្នកជ្រះថ្លាហើយ ដែលសត្វលោកបានដឹងឮប្រពៃហើយ ខ្ញុំម្ចាស់គប្បីជាអ្នករលឹកជាតិបាន ជាអ្នកមានបញ្ញាច្រើន ជាអ្នកដែលអ្វីៗ ឲ្យកម្រើកញាប់ញ័រមិនបាន ប្រៀបដូចជាសាគរ ជាអ្នកឆ្លាតវាងវៃ ក្នុងធម៌ទាំងឡាយទាំងពួង គ្រប់ៗជាតិ ។

សូមព្រះសទ្ធម្ម គឺពាក្យប្រៀនប្រដៅ របស់ព្រះលោកនាថ ចូរចំរើនរុងរឿង, សូមឲ្យសត្វទាំងឡាយ

ទាំងពួង ចូរជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ។

សូមភ្លៀងបង្អុរចុះមក ក្នុងកាលដ៏គួរ ចូរនាំមកនូវផែនដីទៅកាន់សេចក្ដីសិរីវុឌ្ឍិ ចូរបង្ហូរនូវទឹកដោយប្រពៃ ចូររក្សានូវសត្វមានជីវិត និងតិណ្ណជាតិ ដែលកើតមកអំពីភូមិភាគ ក្នុងកាលទាំងពួង ។

មាតាក្ដី បិតាក្ដី បីបាច់រក្សានូវកូនតូច ជាកូនដែលកើតអំពីខ្លួន ជានិច្ច យ៉ាងណាមិញ, សូមព្រះរាជាទាំងឡាយ រក្សានូវប្រជាជន ដោយធម៌ ឲ្យបានសព្វៗកាល ក៏យ៉ាងដូច្នោះឯង ។

មង្គលត្ថទីបនី ចប់បរិបូណ៌ ។

សូម្បីព្រះនាម ថា 'ពុទ្ធោ' របស់ព្រះដ៏មានព្រះភាគ ព្រះអង្គមិនញាប់ញ័រ រមែងប្រព្រឹត្តទៅ ក្នុងលោក ដរាបណា, មង្គលត្ថទីបនីនោះ កាលសំដែងនូវន័យ ដល់ជនទាំងឡាយ ដែលប្រាថ្នាដើម្បីនឹងសិក្សា ចូរតាំងនៅ ដរាបនោះចុះ ដូច្នេះឯង " ។

---

ប្រែចប់ ថ្ងៃពុធ ៨ រោច ខែចេត្រ ឆ្នាំរកា បញ្ចស័ក ព.ស. ២៥៣៦
ត្រូវនឹងថ្ងៃទី ១៤ មេសា ១៩៩៣

សៀវភៅ "មង្គលត្ថទីបនីប្រែ" ទាំង ៤ ភាគ នេះ ខ្ញុំបានបកប្រែចេញពីភាសាបាលី មកជាខេមរភាសា នៅថ្ងៃសៅរ៍ ២ កើត ខែកត្តិក ឆ្នាំវក ចត្វាស័ក ព.ស. ២៥៣៥ ត្រូវនឹងថ្ងៃទី ២៩ ខែសីហា ឆ្នាំ ១៩៩២ ហើយបានប្រែចប់សព្វគ្រប់ នៅថ្ងៃសុក្រ ១៥ កើត ខែមាឃ ឆ្នាំច ឆស័ក ព.ស. ២៥៣៧ ត្រូវនឹងថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ១៩៩៤ អស់រយៈពេល ១ ឆ្នាំ ៥ ខែ ២៨ ថ្ងៃ ។

---

ដោយអំណាចផលានិសង្ស នៃធម្មទាន ដែលកើតឡើងពីការព្យាយាមប្រឹងប្រែង ប្រែអត្ថមង្គលត្ថទីបនីនេះ ខ្ញុំសូមប្រាថ្នាឱ្យបាន អស់ទៅនូវអាសវក្កិលេស ក្នុងអនាគតជាតិ កុំបីខានឡើយ ។

---

សូមខេមរជនគ្រប់ៗរូប ជួយនាំគ្នាស្តារនិងលើកស្ទួយនូវសាមគ្គីធម៌, ព្រហ្មវិហារធម៌, សង្គហធម៌ ដែលយើងធ្លាប់មានមកពីកាលមុន ជាយូរអង្វែងហើយ ឱ្យស្ថិតនៅជាប់ក្នុងដួងចិត្តយើងគ្រប់ៗគ្នាឡើងវិញ ហើយនាំគ្នាកំចាត់ចោលនូវការចងក្រោធទុក, ការចងកម្មចងពៀរវេរានឹងគ្នា, ការចងគំនុំគុំគួនគ្នា និងការព្យាបាទបៀតបៀនដល់គ្នានឹងគ្នា មិនចេះឈប់ឈរ ឱ្យប្រាសចាកពីខន្ធសន្តានរបស់យើង ដើម្បីទទួលយកនូវសេចក្តីសុខសន្តិភាពទាំងផ្លូវកាយ-ផ្លូវចិត្ត ដ៏ពិតប្រាកដតាមមាគ៌ានៃព្រះពុទ្ធសាសនា ។ មែនពិតអំពើអាក្រក់ទាំងប៉ុន្មានខាងលើនេះ ពុំដែលធ្វើឱ្យមនុស្សចម្រើនឡើយ មានតែធ្វើឱ្យមនុស្សយើងវិនាសតែម្យ៉ាងប៉ុណ្ណោះ ។

**វត្តខេមរពុទ្ធិការាម សហរដ្ឋអាមេរិក**

១៥កើត ខែវិសាខ ឆ្នាំមមែត្រីស័ក ព.ស.២៥៣៤

**ភិក្ខុវិនយធរោ មហាយិន-ធឿន**

**វត្តនានានៃពុទ្ធិកសមាគមន៍ព្រះសង្ឃខ្មែរដែលបាន**
**ជួយឧបត្ថម្ភក្នុងការបោះពុម្ពសៀវភៅ**
**មង្គលត្ថទីបនីប្រែ ទាំង៤ ភាគ ដើម្បីចែកផ្សាយ**
**ជាធម្មទាននេះ មានដូចតទៅ**

-------------

១- វត្តខេមរពុទ្ធិការាម ទីក្រុងឡុងប៊ិច
២- វត្តវិបស្សនារាម ទីក្រុងឡុងប៊ិច
៣- វត្តពុទ្ធវង្សី ទីក្រុងហ្យូស្តុន តិចសាស់
៤- វត្តជេតពន ទីក្រុងដាល់ឡាស់ តិចសាស់
៥- វត្តខេមររតនារាម ទីក្រុងសាន់ឌីកូ
៦- វត្តសុវណ្ណគិរី ទីក្រុងសាន់ឌីកូ
៧- វត្តសាន់តាអាណា ទីក្រុងសាន់តាអាណា
៨- វត្តពុទ្ធសាសនវង្សី ទីក្រុងប្រេះស្ទូ
៩- វត្តសាន់ហូសេ ទីក្រុងសាន់ហូសេ
១០- វត្តប៉ូម៉ូណារាម ទីក្រុងប៉ូម៉ូណា
១១- វត្តត្រៃកូដ ទីក្រុងអិលអេ
១២- វត្តធម្មិការាម ទីក្រុងប្រូវីដង់
១៣- វត្តធម្មចក្ការាម ទីក្រុងស៊ីអាថុល
១៤- វត្តសាមគ្គីរតនារាម ទីក្រុងតាក់កូមា

*ព្រមទាំងពុទ្ធបរិស័ទទូទាំងសហរដ្ឋអាមេរិកដែលមាន*
*រាយនាម ក្នុងភាគទី១-២ នោះផង ។*

កិច្ចការទាំងឡាយទាំងពួង គឺពិតជាមានការភ្លេចភ្លាំងជាធម្មតា ហេតុនេះ បើមានការធ្លាក់ឬបាត់ឈ្មោះអស់លោក ញាតិញោម ពុទ្ធបរិស័ទដែលបានជួយឧបត្ថម្ភ ក្នុងការបោះពុម្ពសៀវភៅនេះ សូមមេត្តាខន្តីអភ័យទោសដល់ខ្ញុំផងចុះ ។

ម្យ៉ាងទៀត ខ្ញុំសូមទទួលការរិះគន់ គ្រប់ពីមជ្ឈដ្ឋានទាំងអស់ ដែលបានឃើញនូវកំហុស ឬការភ្លាំងភ្លាត់ត្រង់កន្លែងណាទីមួយនោះ ហើយសូមផ្តល់ជាយោបល់ទៅខ្ញុំអ្នកធ្វើកុំបីខាន ។

សូមអរគុណ

------------

| | | |
|---|---|---|
| អក្សរ | : | សិល្បៈប្រពៃណី |
| រលុប | : | ខ្មែរខ្ចីគ្មានសល់សោះ |
| ជាតិ | : | ក៏រលំខ្មែរខ្លាំអស់ |
| រលាយ | : | បាត់ឈ្មោះពីផែនលោក ។ |
| ខ្មែរ | : | យើងប្រុសស្រីខំខ្មីឃ្មាត |
| ត្រូវ | : | ប្រឹងប្រែងឆ្លៀតខំរៀនយក |
| វេចស្លាយ | : | អក្សរបន្តរក |
| គ្រប់វិជ្ជា | : | មកទើបជាតិគង់ ។ |

**គទីនិពន្ធ ហៀង~គៀន**

# ធម្មទានឈ្នះអស់ទានទាំងពួង

~~~

*បើអស់លោក ញាតិញោម ជាពុទ្ធបរិស័ទមាន បំណងចង់យកសៀវភៅនេះ ទៅបោះពុម្ពចែកផ្សាយ ជាធម្មទានសូមអញ្ជើញទាក់ទងនឹងខ្ញុំ* **ភិក្ខុវិនយធរោ មហាយិន-នៀន** *ឬ* **នឹងសហគមន៍ព្រះសង្ឃខ្មែរ** *ហើយបញ្ជាក់អំពីគោលបំណង ឱ្យបានច្បាស់លាស់ តាមអាស័យដ្ឋាននៅក្នុងសៀវភៅនេះស្រាប់ ។*

~~~~~

**វត្តខេមរពុទ្ធិការាម**

***2100 W. Willow St.***
***Long Beach, CA 90810***
***U. S. A.***

ឬ

**មជ្ឈមណ្ឌលសហគមន៍ព្រះសង្ឃខ្មែរ**

**វត្តត្រៃរតនារាម**

***21 Quigley Ave.***
***N. Chelmsford, MA 01863***
***U. S. A.***

**សៀវភៅដែលខ្ញុំបានចម្លងប្រែរៀបរៀងហើយ**
**បានបោះពុម្ពផ្សាយជាធម្មទានចែកជូនតទៅនេះគឺៈ**

០០

១- គាថាធម្មបទប្រែ ព.ស.២៥២៩
២- អនុពុទ្ធប្បវត្តិ ព.ស.២៥២៩
៣- ពង្សាវតារខ្មែរ ព.ស.២៥២៩
៤- បុណ្យភ្ជុំបិណ្ឌ ព.ស.២៥២៩
៥- មង្គលជីវិត ព.ស.២៥៣០
៦- កម្មកថា ព.ស.២៥៣០
៧- សីមាវិនិច្ឆ័យ ព.ស.២៥៣២
៨- គិហិសង្ខេប ព.ស.២៥៣២,២៥៣៦
៩- គិហិពិស្តារ ព.ស.២៥៣៣,២៥៣៦
១០- មហាវេស្សន្តរជាតកពិស្តារ ព.ស.២៥៣៤
១១- មហាវេស្សន្តរជាតកសង្ខេប ព.ស.២៥៣៥
១២- សាមណេរវិន័យ ព.ស.២៥៣៥
១៣- វេយ្យាករណ៍បាលី ព.ស.២៥៣៥
១៤- ពិធីប្រែបាលី ព.ស.២៥៣៥
១៥- សម្ពន្ធមាលា ព.ស.២៥៣៥
១៦- ចតុបារិសុទ្ធិសីល ព.ស.១៥៣៥
១៧- មង្គលត្ថទីបនីប្រែភាគ១-៤ ព.ស.២៥៣៨
និងសៀវភៅផ្សេងៗទៀត ។

××××××